

# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្តីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
# មជ្ឈិមនិកាយ ឧបរិបណ្ណាសក
# នវមភាគ
# ២៨



ផ្សព្វផ្សាយដោយសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា
ព. ស. ២៥៥៣

# SUTTANTAPIṬAKA

## MAJJHIMANIKĀYA

## UPARIPAṆṆĀSAKA

## NAVAMABHĀGA

## 28

សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

# និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ៥០០ឆ្នាំថ្វាយ ក្រោយអំពីការរំលត់ព្រះខន្ធចូលកាន់ព្រះបរមនិព្វានរបស់សម្តេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេសអ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំ ៗ តែងតែបានទទួលយកមកតម្កល់ទុកធ្វើជាគ្រឹះ ដើម្បីធ្វើការស្រាវជ្រាវសិក្សាស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើមឡើយគេនាំគ្នាកត់ត្រាលើស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈក៏មាន លុះចំណេរតមកក៏បាននាំគ្នាបោះពុម្ពលើក្រដាសចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ននេះ បច្ចេកវិជ្ជាកាន់តែចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេសម៉ាស៊ីនចម្រើនឡើងយ៉ាងណាក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើបយើងខ្ញុំបានខិតខំធ្វើឲ្យកើតមានឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុបមិនអាចអានច្បាស់បាន ឲ្យមានការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្តេចព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួលពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឃបូជា ។

សូមសេចក្តីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្តីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាកិយ្យោភាពតរៀងទៅ ។

វត្តបទុមជ. ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩

បួរ-គ្រី

VATT Botum Dhammavutt Sangkat Chatumuk Khan Daun Penh P.Penh

# សេចក្តីណែនាំក្នុងការអាន

១ ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះ គឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។

ឧទាហរណ៍

-ពាក្យខ្មែរៈ **សម̟ល** ក្នុងពាក្យនេះ ព្យញ្ជនៈ **ល** គឺជាជើងរបស់ព្យញ្ជនៈ **ម** ដូច្នេះពាក្យនេះគឺ **សម្ល** ។

-ពាក្យបាលីៈ **តស̟ស** គឺ **តស្ស** ។

២ ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជជោតញ្ញាណោ (**ជួន-ណាត**) ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។

៣ ចំពោះ **សន្ទឹកក្រាប់ពាក្យខុស-ត្រូវ** ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។

# សុត្តន្តបិដក

## មជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ

## នវមភាគ

## ២៨

ព. ស. ២៥៥៣

គ. ស. ២០០៩

# សុត្តន្តបិដកេ មជ្ឈិមនិកាយស្ស

# ឧបរិបណ្ណាសកំ

# នវមោ ភាគោ

## វិភង្គវគ្គោ

### បឋមំ ភទ្ទេករត្តសុត្តំ

[១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច ភទ្ទេករត្តស្ស វោ ភិក្ខវេ ឧទ្ទេសញ្ច វិភង្គញ្ច ទេសិស្សាមិ តំ សុណាថ សាធុកំ[១] មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

---

១ ឱ. សាធុកន្តិ ន ទិស្សតិ ។

# សុត្តន្តបិដក មជ្ឈិមនិកាយ

# ឧបរិបណ្ណាសកៈ

## នវមភាគ

## វិភង្គវគ្គ

## ភទ្ទេករត្តសូត្រទី ១

[១] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅពួកភិក្ខុក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវឧទ្ទេស គឺមាតិកាជាគ្រឿងសំដែងឡើង និងវិភង្គគឺបទជាគ្រឿងចែកដោយពិស្តារ របស់បុគ្គលអ្នកមានរាត្រីមួយដ៏ចម្រើន ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់នូវសូត្រនោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែងប្រាប់ ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

២



[២] ភគវា ឯតទវោច

អតីតំ នាន្វាគមេយ្យ
នប្បដិកង្ខេ អនាគតំ
យទតីតម្បហីនន្តំ
អប្បត្តញ្ច អនាគតំ
បច្ចុប្បន្នញ្ច យោ ធម្មំ
តត្ថ តត្ថ វិបស្សតិ
អសំហិរំ អសង្កុប្បំ
តំ វិទ្វា មនុព្រូហយេ
អជ្ជេវ កិច្ចមាតប្បំ
កោ ជញ្ញា មរណំ សុវេ
ន ហិ នោ សង្គរន្តេន
មហាសេនេន មច្ចុនា
ឯវំវិហារិមាតាបឹ
អហោរត្តមតន្ទិតំ
តំ វេ ភទ្ទេករត្តោតិ
សន្តោ អាចិក្ខតេ មុនីតិ[១] ។

---
១ ម. ឥតិសទ្ទោ នត្ថិ ។

[២] ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា បុគ្គលមិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធ ដែលកន្លងទៅហើយ មិនគប្បីប្រាថ្នាបញ្ចក្ខន្ធ ដែលមិនទាន់មកដល់ទេ ព្រោះបញ្ចក្ខន្ធណា ជាអតីត បញ្ចក្ខន្ធនោះ កន្លងហួសទៅហើយ បញ្ចក្ខន្ធណា ជាអនាគត បញ្ចក្ខន្ធនោះ ក៏មិនទាន់មកដល់មួយទៀត បុគ្គលណា ឃើញច្បាស់ នូវធម៌ជាបច្ចុប្បន្នក្នុងទីនោះ ៗ បុគ្គលនោះ លុះដឹងច្បាស់ នូវព្រះនិព្វានដែលមិនរសេមរសាម(១) និងមិនបានកម្រើក (ដោយពួកកិលេស) គប្បីចម្រើនឲ្យរឿយ ៗ នូវផលសមាបត្តិ ដែលជាអារម្មណ៍របស់ព្រះនិព្វាននោះ ឯការព្យាយាមជាគ្រឿងដុតកិលេស បុគ្គលគួរតែធ្វើក្នុងថ្ងៃនេះឯង អ្នកណានឹងដឹងថា សេចក្តីស្លាប់ នឹងមានក្នុងថ្ងៃស្អែកបាន ព្រោះថាការតទល់របស់យើងចំពោះមច្ចុ ដែលមានសេនាដ៏ច្រើននោះ មិនមានសោះឡើយ អ្នកប្រាជ្ញដែលស្ងប់ទុក្ខហើយ តែងហៅបុគ្គលដែលមានវិហារធម៌យ៉ាងនេះ ជាអ្នកមានព្យាយាមដុតកិលេស ជាអ្នកមិនខ្ជិលច្រអូស អស់យប់និងថ្ងៃនោះឯង ថាជាអ្នកមានរាត្រីមួយដ៏ចម្រើន ។

---

១ ប្រែថា មិនងើកងាកក៏បាន ។

៣

វិភង្គវគ្គស្ស ភទ្ទេកវគ្គសុត្តេ អនាគតប្បដិកង្ខតា

[៣] កាថញ្ច ភិក្ខវេ អតីតំ អន្វាគមេតិ ។ ឯវំរូបោ អហោសឹ អតីតមទ្ធានន្តិ តត្ថ នន្ទឹ សមន្វានេតិ ឯវំវេទនោ អហោសឹ អតីតមទ្ធានន្តិ តត្ថ នន្ទឹ សមន្វានេតិ ឯវំសញ្ញោ អហោសឹ អតីតមទ្ធានន្តិ តត្ថ នន្ទឹ សមន្វានេតិ ឯវំសង្ខារោ អហោសឹ អតីតមទ្ធានន្តិ តត្ថ នន្ទឹ សមន្វានេតិ ឯវំវិញ្ញាណោ អហោសឹ អតីតមទ្ធានន្តិ តត្ថ នន្ទឹ សមន្វានេតិ ។ ឯវំ ខោ ភិក្ខវេ អតីតំ អន្វាគមេតិ ។

[៤] កាថញ្ច ភិក្ខវេ អតីតំ នាន្វាគមេតិ ។ ឯវំរូបោ អហោសឹ អតីតមទ្ធានន្តិ តត្ថ នន្ទឹ ន សមន្វានេតិ

វិភង្គវគ្គ ភទ្ទេករត្តសូត្រ សេចក្តីសង្ស័យក្នុងខន្ធជាអនាគត

[៣] ម្នាលភិក្ខុទាំងឡាយ បុគ្គលអាឡោះអាល័យបញ្ចក្ខន្ធ ដែលកន្លងទៅហើយ តើដូចម្តេច ។ បុគ្គលរមែងប្រព្រឹត្តទៅតាមសេចក្តីត្រេកអរក្នុងរូបនោះថា អាត្មាអញមានរូបយ៉ាងនេះ ក្នុងកាលដែលកន្លងទៅហើយ ប្រព្រឹត្តទៅតាមតណ្ហាក្នុងវេទនានោះថា អាត្មាអញមានវេទនាយ៉ាងនេះ ក្នុងកាលជាអតីត ប្រព្រឹត្តទៅតាមសេចក្តីត្រេកអរក្នុងសញ្ញានោះថា អាត្មាអញមានសញ្ញាយ៉ាងនេះ ក្នុងកាលជាអតីត ប្រព្រឹត្តទៅតាមសេចក្តីត្រេកអរ ក្នុងសង្ខារទាំងឡាយនោះថា អាត្មាអញមានសង្ខារយ៉ាងនេះ ក្នុងកាលជាអតីត ប្រព្រឹត្តទៅតាមសេចក្តីត្រេកអរក្នុងវិញ្ញាណនោះថា អាត្មាអញមានវិញ្ញាណយ៉ាងនេះ ក្នុងកាលជាអតីត ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអាឡោះអាល័យបញ្ចក្ខន្ធ ដែលកន្លងទៅហើយ យ៉ាងនេះឯង ។

[៤] ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនអាឡោះអាល័យបញ្ចក្ខន្ធជាអតីត តើដូចម្តេច ។ បុគ្គល មិនប្រព្រឹត្តទៅតាមសេចក្តីត្រេក-អរ ក្នុងរូបនោះថា អាត្មាអញ មានរូបយ៉ាងនេះ ក្នុងកាលជាអតីត

ឯវំវេទនោ អហោសឹ អតីតមទ្ធានន្តិ តត្ថ នន្ទឹ ន សមន្វានេតិ ឯវំសញ្ញោ អហោសឹ អតីតមទ្ធានន្តិ តត្ថ នន្ទឹ ន សមន្វានេតិ ឯវំសង្ខារោ អហោសឹ អតីតមទ្ធានន្តិ តត្ថ នន្ទឹ ន សមន្វានេតិ ឯវំ-វិញ្ញាណោ អហោសឹ អតីតមទ្ធានន្តិ តត្ថ នន្ទឹ ន សមន្វានេតិ ។ ឯវំ ខោ ភិក្ខវេ អតីតំ នាន្វាគមេ-តិ ។

[៤] កថញ្ច ភិក្ខវេ អនាគតំ បដិកង្ខតិ ។ ឯវំរូបោ សិយំ អនាគតមទ្ធានន្តិ តត្ថ នន្ទឹ ស-មន្វានេតិ ឯវំវេទនោ សិយំ ។ បេ ។ ឯវំសញ្ញោ សិ-យំ ។ បេ ។ ឯវំសង្ខារោ សិយំ ។ បេ ។ ឯវំវិញ្ញាណោ សិយំ អនាគតមទ្ធានន្តិ តត្ថ នន្ទឹ សមន្វានេតិ ។ ឯវំ ខោ ភិក្ខវេ អនាគតំ បដិកង្ខតិ ។

មិនប្រព្រឹត្តទៅតាមសេចក្តីត្រេកអរ ក្នុងវេទនានោះថា អាត្មាអញមានវេទនាយ៉ាងនេះ ក្នុងកាលជាអតីត មិនប្រព្រឹត្តទៅតាមសេចក្តីត្រេកអរ ក្នុងសញ្ញានោះថា អាត្មាអញមានសញ្ញាយ៉ាងនេះ ក្នុងកាលជាអតីត មិនប្រព្រឹត្តទៅតាមសេចក្តីត្រេកអរ ក្នុងសង្ខារទាំងឡាយនោះថា អាត្មាអញមានសង្ខារយ៉ាងនេះ ក្នុងកាលជាអតីត មិនប្រព្រឹត្តទៅតាមសេចក្តីត្រេក-អរ ក្នុងវិញ្ញាណនោះថា អាត្មាអញមានវិញ្ញាណយ៉ាងនេះ ក្នុងកាលជាអតីត ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនអាឡោះអាល័យបញ្ចក្ខន្ធ ដែលកន្លងទៅហើយ យ៉ាងនេះឯង ។

[៥] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រាថ្នានូវបញ្ចក្ខន្ធ ក្នុងកាលជាអនាគត តើដូចម្តេច ។ បុគ្គលប្រព្រឹត្តទៅតាមសេចក្តីត្រេកអរ ក្នុងរូបនោះថា សូមឲ្យអាត្មាអញមានរូបយ៉ាងនេះ ក្នុងកាលជាអនាគត មានវេទនាយ៉ាងនេះ ។ បេ ។ មានសញ្ញាយ៉ាងនេះ ។ បេ ។ មានសង្ខារយ៉ាងនេះ ។ បេ ។ រមែងប្រព្រឹត្តទៅតាមសេចក្តីត្រេកអរ ក្នុងវិញ្ញាណនោះថា សូមឲ្យអាត្មាអញមានវិញ្ញាណយ៉ាងនេះ ក្នុងកាលជាអនាគត ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រាថ្នានូវបញ្ចក្ខន្ធក្នុងកាលជាអនាគត យ៉ាងនេះឯង ។

[៦] កថញ្ច ភិក្ខវេ អនាគតំ នប្បដិកង្ខតិ ។ ឯវំរូបោ សិយំ អនាគតមទ្ធានន្តិ តត្ថ នន្ទឹ ន សមន្វានេតិ ឯវំវេទនោ សិយំ ។ បេ ។ ឯវំសញ្ញោ សិយំ ។ បេ ។ ឯវំសង្ខារោ សិយំ ។ បេ ។ ឯវំវិញ្ញាណោ សិយំ អនាគតមទ្ធានន្តិ តត្ថ នន្ទឹ ន សមន្វានេតិ ។ ឯវំ ខោ ភិក្ខវេ អនាគតំ នប្បដិកង្ខតិ ។

[៧] កថញ្ច ភិក្ខវេ បច្ចុប្បន្នេសុ ធម្មេសុ សំហិរតិ ។ ឥធ ភិក្ខវេ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្មស្ស អកោវិទោ អរិយធម្មេ អវិនីតោ សប្បុរិសានំ អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិសធម្មេ អវិនីតោ រូបំ អត្តតោ សមនុបស្សតិ រូបវន្តំ វា អត្តានំ អត្តនិ វា រូបំ រូបស្មឹ វា អត្តានំ

វិភង្គវគ្គ ភទ្ទេករត្តសូត្រ សេចក្តីមិនសង្ស័យក្នុងខន្ធជាអនាគត

[៦] ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនប្រាថ្នានូវបញ្ចក្ខន្ធ ក្នុងកាលជាអនាគតនោះ តើដូចម្តេច ។ បុគ្គលមិនប្រព្រឹត្តទៅតាមសេចក្តីត្រេកអរ ក្នុងរូបនោះថា សូមឲ្យអាត្មាអញមានរូបយ៉ាងនេះ ក្នុងកាលជាអនាគត មានវេទនាយ៉ាងនេះ ។ បេ ។ មានសញ្ញាយ៉ាងនេះ ។ បេ ។ មានសង្ខារយ៉ាងនេះ ។ បេ ។ មិនប្រព្រឹត្តទៅតាមសេចក្តីត្រេកអរ ក្នុងវិញ្ញាណនោះថា សូមឲ្យអាត្មាអញមានវិញ្ញាណយ៉ាងនេះ ក្នុងកាលជាអនាគត ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនប្រាថ្នានូវបញ្ចក្ខន្ធ ក្នុងកាលជាអនាគត យ៉ាងនេះឯង ។

[៧] ម្នាលភិក្ខុទាំងឡាយ បុគ្គលរសេមរសាម (ដោយតណ្ហានិងទិដ្ឋិ) ក្នុងពួកធម៌ជាបច្ចុប្បន្ន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនបានស្តាប់ មិនបានជួបប្រទះនឹងពួកព្រះអរិយៈ ជាអ្នកមិនឈ្លាស ក្នុងធម៌របស់ព្រះអរិយៈ មិនបានហាត់ក្នុងធម៌របស់ព្រះអរិយៈ មិនបានជួបប្រទះ នូវសប្បុរសទាំងឡាយ មិនឈ្លាសក្នុងធម៌របស់សប្បុរស មិនបានហាត់ក្នុងធម៌របស់សប្បុរស រមែងពិចារណាឃើញនូវរូបថាជាខ្លួន ពិចារណាឃើញនូវខ្លួនថាមានរូប នូវរូបថាមានក្នុងខ្លួន ឬនូវខ្លួនថាមាន

វេទនំ ។ បេ ។ សញ្ញំ ។ បេ ។ សង្ខារេ ។ បេ ។ វិញ្ញាណំ អត្តតោ សមនុបស្សតិ វិញ្ញាណវន្តំ វា អត្តានំ អត្តនិ វា វិញ្ញាណំ វិញ្ញាណស្មឹ វា អត្តានំ ។ ឯវំ ខោ ភិក្ខវេ បច្ចុប្បន្នេសុ ធម្មេសុ សំហីរតិ ។

[៨] កថញ្ច ភិក្ខវេ បច្ចុប្បន្នេសុ ធម្មេសុ ន សំហីរតិ ។ ឥធ ភិក្ខវេ សុតវា អរិយសាវកោ អរិយានំ ទស្សាវី អរិយធម្មស្ស កោវិទោ អរិយធម្មេ សុវិនីតោ[១] សប្បុរិសានំ ទស្សាវី សប្បុរិសធម្មស្ស កោវិទោ សប្បុរិសធម្មេ សុវិនីតោ ន រូបំ អត្តតោ សមនុបស្សតិ ន រូបវន្តំ វា អត្តានំ ន អត្តនិ វា រូបំ ន រូបស្មឹ វា អត្តានំ ន វេទនំ ។ បេ ។ ន សញ្ញំ ។ បេ ។ ន សង្ខារេ ។ បេ ។ ន វិញ្ញាណំ អត្តតោ សមនុបស្សតិ ន វិញ្ញាណវន្តំ វា អត្តានំ ន អត្តនិ វា វិញ្ញាណំ ន វិញ្ញាណស្មឹ វា អត្តានំ ។ ឯវំ ខោ ភិក្ខវេ បច្ចុប្បន្នេសុ ធម្មេសុ ន សំហីរតិ ។

---

១ ឱ. វិនីតោ សុសទ្ទោ នត្ថិ ។

ក្នុងរូប ពិចារណាឃើញ នូវវេទនា ។ បេ ។ នូវសញ្ញា ។ បេ ។ នូវសង្ខារទាំងឡាយ ។ បេ ។ នូវវិញ្ញាណថាជាខ្លួន នូវខ្លួនថាមានវិញ្ញាណ នូវវិញ្ញាណថាមានក្នុងខ្លួន ឬនូវខ្លួនថាមានក្នុងវិញ្ញាណ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលរសេមរសាមក្នុងពួកធម៌ជាបច្ចុប្បន្ន យ៉ាងនេះឯង ។

[៨] ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនរសេមរសាម ក្នុងធម៌ជាបច្ចុប្បន្ន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កក្នុងសាសនានេះ ជាអ្នកបានស្តាប់ ជាអ្នកបានចួបប្រទះនឹងពួកព្រះអរិយៈ ជាអ្នកឈ្លាសវៃក្នុងធម៌របស់ព្រះអរិយៈ បានហាត់ល្អ ក្នុងធម៌របស់ព្រះអរិយៈ បានចួបប្រទះនឹងពួកសប្បុរស ឈ្លាសវៃក្នុងធម៌របស់សប្បុរស បានហាត់ក្នុងធម៌របស់សប្បុរស មិនពិចារណាឃើញរូបថាជាខ្លួន មិនពិចារណាឃើញខ្លួនថាមានរូប មិនពិចារណាឃើញរូបថាមានក្នុងខ្លួន មិនពិចារ-ណាឃើញខ្លួនថាមានក្នុងរូប មិនពិចារណាឃើញវេទនា ។ បេ ។ មិនពិចារណាឃើញសញ្ញា ។ បេ ។ មិនពិចារណាឃើញសង្ខារទាំងឡាយ ។ បេ ។ មិនពិចារណាឃើញវិញ្ញាណ ថាជាខ្លួន មិនពិចារណាឃើញខ្លួនថាមានវិញ្ញាណ មិនពិចារណាឃើញវិញ្ញាណថាមានក្នុងខ្លួន មិនពិចារ-ណាឃើញខ្លួនថាមានក្នុងវិញ្ញាណឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនរសេមរសាម ក្នុងពួកធម៌ជាបច្ចុប្បន្ន យ៉ាងនេះឯង ។

៧

វិភង្គវគ្គស្ស ភទ្ទេករត្តសុត្តេ ភទ្ទេករត្តភាវោ

[៩] អតីតំ នាន្វាគមេយ្យ
នប្បដិកង្ខេ អនាគតំ
យទតីតម្បហីនន្តំ
អប្បត្តញ្ច អនាគតំ
បច្ចុប្បន្នញ្ច យោ ធម្មំ
តត្ថ តត្ថ វិបស្សតិ
អសំហិរំ អសង្កុប្បំ
តំ វិទ្វា មនុព្រូហយេ
អជ្ជេវ កិច្ចមាតប្បំ
កោ ជញ្ញា មរណំ សុវេ
ន ហិ នោ សង្គរន្តេន
មហាសេនេន មច្ចុនា
ឯវំវិហារិមាតាបឹ
អហោរត្តមតន្ទិតំ
តំ វេ ភទ្ទេករត្តោតិ
សន្តោ អាចិក្ខតេ មុនីតិ ។

វិភង្គវគ្គ ភទ្ទេករត្តសូត្រ ភាពនៃបុគ្គលអ្នកមានរាត្រីមួយចម្រើន

[៩] បុគ្គលមិនគប្បីអាឡោះអាល័យនូវបញ្ចក្ខន្ធជាអតីត មិនគប្បីប្រាថ្នា នូវបញ្ចក្ខន្ធជាអនាគតឡើយ ព្រោះបញ្ចក្ខន្ធណាជាអតីត បញ្ចក្ខន្ធនោះ កន្លងហួសទៅហើយ បញ្ចក្ខន្ធណាជាអនាគត បញ្ចក្ខន្ធនោះ ក៏មិនទាន់មកដល់ មួយទៀត បុគ្គលណា ពិចារណាឃើញច្បាស់នូវធម៌ជាបច្ចុប្បន្ន ក្នុងទីនោះ ៗ បុគ្គលនោះ លុះដឹងច្បាស់នូវព្រះនិព្វាន ដែលមិនរសេមរសាមនិងមិនកម្រើកហើយ គប្បីចម្រើនផលសមាបត្តិ ដែលជាអារម្មណ៍របស់ព្រះនិព្វាននោះឲ្យរឿយ ៗ ឯការព្យាយាមជាគ្រឿងដុតកិលេស បុគ្គលគួរតែធ្វើក្នុងថ្ងៃនេះឯង អ្នកណាអាចដឹង ថាសេចក្ដីស្លាប់នឹងមានក្នុងថ្ងៃស្អែកបាន ព្រោះថាការតទល់របស់យើងចំពោះមច្ចុ ដែលមានសេនាដ៏ច្រើននោះ មិនមានសោះឡើយ អ្នកប្រាជ្ញដែលស្ងប់ទុក្ខហើយ តែងហៅបុគ្គលដែលមានវិហារធម៌យ៉ាងនេះ មានព្យាយាមដុតកម្ដៅកិលេស ជាអ្នកមិនខ្ជិលច្រអូស អស់ថ្ងៃនិងយប់នោះឯង ថាជាអ្នកមានរាត្រីមួយដ៏ចម្រើន ។

ភទ្ទេការត្តស្ស វោ ភិក្ខវេ ឧទ្ទេសញ្ច វិភង្គញ្ច ទេសិស្សាមីតិ ។ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តន្តិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

ភទ្ទេករត្តសុត្តំ បឋមំ និដ្ឋិតំ ។

ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវឧទ្ទេសគឺមាតិកានិងវិភង្គ គឺភាជនីយ របស់បុគ្គលអ្នកមានរាត្រីមួយដ៏ចម្រើន ដល់អ្នកទាំងឡាយ ។ ពាក្យណា ដែលតថាគតពោលហើយ ដោយប្រការដូច្នេះ ពាក្យនោះ តថាគតពោលសំដៅហេតុនេះឯង ។ លុះព្រះមានព្រះភាគទ្រង់ត្រាស់ ភាសិតនេះចប់ហើយ ពួកភិក្ខុទាំងនោះក៏មានចិត្តត្រេកអរ រីករាយនឹង ភាសិត របស់ព្រះមានព្រះភាគ ។

ចប់ ភទ្ទេករត្តសូត្រទី ១ ។

# ទុតិយំ អានន្ទភទ្ទេករត្តសុត្តំ

[១០] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា
សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អា-
រាមេ ។ តេន ខោ បន សមយេន អាយស្មា អា-
នន្ទោ ឧបដ្ឋានសាលាយំ ភិក្ខូ ធម្មិយា កថាយ
សន្ទស្សេតិ សមាទបេតិ សមុត្តេជេតិ សម្បហំសេតិ
ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ច ភាសតិ ។

[១១] អថខោ ភគវា សាយណ្ហសមយំ បដិ-
សល្លានា វុដ្ឋិតោ យេនុបដ្ឋានសាលា តេនុបសង្កមិ
ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ
ខោ ភគវា ភិក្ខូ អាមន្តេសិ កោ នុ ខោ
ភិក្ខវេ ឧបដ្ឋានសាលាយំ ភិក្ខូ ធម្មិយា កថាយ
សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្ប-
ហំសេសិ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ច
អភាសីតិ ។ អាយស្មា ភន្តេ អានន្ទោ

# អានន្ទភទ្ទេករត្តសូត្រ ទី ២

[១០] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក៏សម័យនោះឯង ព្រះអានន្ទមានអាយុ បានពន្យល់ ណែនាំពួកភិក្ខុ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ក្នុងឧបដ្ឋានសាលា ហើយសំដែងនូវឧទ្ទេស គឺមាតិកា និងវិភង្គ គឺភាជនីយ របស់បុគ្គលដែលមានរាត្រីមួយដ៏ចម្រើន ។

[១១] គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ចេញចាកផលសមាបត្តិក្នុងសាយណ្ហសម័យ ចូលទៅឯឧបដ្ឋានសាលា លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគ គង់ស្រេចហើយ ទើបត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកណាហ្ន៎ ពន្យល់ ណែនាំពួកភិក្ខុ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាក្នុងឧបដ្ឋានសាលា ហើយសំដែងនូវឧទ្ទេសនិងវិភង្គ របស់បុគ្គលដែលមានរាត្រីមួយដ៏ចម្រើន ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអានន្ទមានអាយុ

ឧបដ្ឋានសាលាយំ ភិក្ខូ[១] កថាយំ សន្ទ-ស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ច អភាសីតិ ។ អថខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ យថាកថំ បន ត្វំ អានន្ទ ភិក្ខូ ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំ-សេសិ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ច អភាសីតិ ។

[១២] ឯវំ ខោ អហំ ភន្តេ ភិក្ខូ ធម្មិយា ក-ថាយ សន្ទស្សេមិ[២] សមាទបេមិ សមុត្តេជេមិ សម្ប-ហំសេមិ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ច អភាសឹ

អតីតំ នាន្វាគមេយ្យ
នប្បដិកង្ខេ អនាគតំ
យទតីតម្បហីនន្តំ
អប្បត្តញ្ច អនាគតំ

---

១ ម. ភិក្ខូនំ ។ ២ ម. សន្ទស្សេសិ ។

លោកពន្យល់ ណែនាំពួកភិក្ខុ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ក្នុងឧបដ្ឋានសាលា ហើយសំដែងនូវឧទ្ទេសនិងវិភង្គ របស់បុគ្គលអ្នកមានរាត្រីមួយដ៏ចម្រើន ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ ចុះអ្នកពន្យល់ ណែនាំពួកភិក្ខុ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ហើយសំដែងនូវឧទ្ទេសនិងវិភង្គ របស់បុគ្គល អ្នកមានរាត្រីមួយដ៏ចម្រើន ដូចម្តេចខ្លះ ។

[១២] ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពន្យល់ ណែនាំពួកភិក្ខុ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ហើយសំដែងនូវឧទ្ទេសនិងវិភង្គ របស់បុគ្គលអ្នកមានរាត្រីមួយដ៏ចម្រើន យ៉ាងនេះថា

បុគ្គលមិនត្រូវអាឡោះអាល័យនូវបញ្ចក្ខន្ធ ដែលកន្លងទៅហើយ
ទេ មិនគប្បីប្រាថ្នានូវបញ្ចក្ខន្ធដែលជាអនាគតឡើយ ព្រោះ
បញ្ចក្ខន្ធណាជាអតីត បញ្ចក្ខន្ធនោះ កន្លងហួសទៅហើយ
បញ្ចក្ខន្ធណាជាអនាគត បញ្ចក្ខន្ធនោះ ក៏មិនទាន់មកដល់

បច្ចុប្បន្នញ្ច យោ ធម្មំ
តត្ថ តត្ថ វិបស្សតិ
អសំហិរំ អសង្កុប្បំ
តំ វិទ្វា មនុព្រូហយេ
អជ្ជេវ កិច្ចមាតប្បំ
កោ ជញ្ញា មរណំ សុវេ
ន ហិ នោ សង្គរន្តេន
មហាសេនេន មច្ចុនា
ឯវំវិហារឹ អាតាបឹ
អហោរត្តមតន្ទិតំ
តំ វេ ភទ្ទេករត្តោតិ
សន្តោ អាចិក្ខតេ មុនីតិ[១] ។

[១៣] កថញ្ចាវុសោ អតីតំ អន្វាគមេតិ ។ ឯវំរូបោ អហោសឹ អតីតមទ្ធានន្តិ តត្ថ នន្ទឹ សមន្វានេតិ ឯវំវេទនោ អហោសឹ អតីតមទ្ធានន្តិ តត្ថ នន្ទឹ សមន្វានេតិ ឯវំសញ្ញោ អហោសឹ

១ ម. ឥតិសទ្ទោ នត្ថិ ។

បុគ្គលណា ពិចារណាឃើញច្បាស់នូវធម៌ជាបច្ចុប្បន្នក្នុងទីនោះ ៗ បុគ្គលនោះ លុះដឹងច្បាស់នូវព្រះនិព្វាន ដែលមិនរសេមរសាម មិនបានកម្រើកនោះហើយ គប្បីចម្រើននូវផលសមាបត្តិ ដែលជាអារម្មណ៍របស់ព្រះនិព្វាននោះឲ្យរឿយ ៗ ឯការព្យាយាមជាគ្រឿងដុតកិលេស បុគ្គលគួរតែធ្វើក្នុងថ្ងៃនេះឯង អ្នកណាអាចដឹងថា សេចក្ដីស្លាប់នឹងមានក្នុងថ្ងៃស្អែកបាន ព្រោះថា ការតទល់របស់យើងចំពោះមច្ចុ ដែលមានសេនាដ៏ច្រើននោះ មិនមានសោះឡើយ អ្នកប្រាជ្ញស្ងប់ទុក្ខតែងហៅបុគ្គលដែលមានវិហារធម៌យ៉ាងនេះ មានព្យាយាមដុតកម្ដៅកិលេស មិនខ្ជិលច្រអូស អស់ថ្ងៃនិងយប់នោះឯង ថាជាអ្នកមានរាត្រីមួយដ៏ចម្រើន ។

[១៣] ម្នាលអាវុសោ បុគ្គលអាឡោះអាល័យបញ្ចក្ខន្ធជាអតីតតើដូចម្ដេច ។ បុគ្គលប្រព្រឹត្តទៅតាមនូវតណ្ហា ក្នុងរូបនោះថា អាត្មាអញមានរូបយ៉ាងនេះ ក្នុងកាលជាអតីត ប្រព្រឹត្តទៅតាមនូវតណ្ហា ក្នុងវេទនានោះថា អាត្មាអញមានវេទនាយ៉ាងនេះ ក្នុងកាលជាអតីត ប្រព្រឹត្តទៅតាមនូវតណ្ហា ក្នុងសញ្ញានោះថា អាត្មាអញមានសញ្ញាយ៉ាងនេះ

អតីតមទ្ធានន្តិ តត្ថ នន្ទឹ សមន្វានេតិ ឯវំសង្ខារោ អហោសឹ អតីតមទ្ធានន្តិ តត្ថ នន្ទឹ សមន្វានេតិ ឯវំវិញ្ញាណោ អហោសឹ អតីតមទ្ធានន្តិ តត្ថ នន្ទឹ សមន្វានេតិ ។ ឯវំ ខោ អាវុសោ អន្វាគមេតិ ។

[១៤] កថញ្ចាវុសោ អតីតំ នាន្វាគមេតិ ។ ឯវំរូបោ អហោសឹ អតីតមទ្ធានន្តិ តត្ថ នន្ទឹ ន សមន្វានេតិ ឯវំវេទនោ អហោសឹ អតីតមទ្ធានន្តិ តត្ថ នន្ទឹ ន សមន្វានេតិ ឯវំសញ្ញោ អហោសឹ អតីតមទ្ធានន្តិ តត្ថ នន្ទឹ ន សមន្វានេតិ ឯវំសង្ខារោ អហោសឹ អតីតមទ្ធានន្តិ តត្ថ នន្ទឹ ន សមន្វានេតិ ឯវំវិញ្ញាណោ អហោសឹ អតីតមទ្ធានន្តិ តត្ថ នន្ទឹ ន សមន្វានេតិ ។ ឯវំ ខោ អាវុសោ អតីតំ នាន្វាគមេតិ ។

ក្នុងកាលជាអតីត ប្រព្រឹត្តទៅតាមនូវតណ្ហាក្នុងសង្ខារទាំងឡាយនោះថា អាត្មាអញមានសង្ខារយ៉ាងនេះ ក្នុងកាលជាអតីត ប្រព្រឹត្តទៅតាមនូវតណ្ហាក្នុងវិញ្ញាណនោះថា អាត្មាអញមានវិញ្ញាណយ៉ាងនេះ ក្នុងកាលជាអតីត ។ ម្នាលអាវុសោ បុគ្គលអាឡោះអាល័យបញ្ចក្ខន្ធជាអតីត យ៉ាងនេះឯង ។

[១៤] ម្នាលអាវុសោ បុគ្គលមិនអាឡោះអាល័យបញ្ចក្ខន្ធ ដែលជាអតីត តើដូចម្តេច ។ បុគ្គលមិនប្រព្រឹត្តទៅតាមនូវតណ្ហាក្នុងរូបនោះថា អាត្មាអញមានរូបយ៉ាងនេះ ក្នុងកាលជាអតីត មិនប្រព្រឹត្តទៅតាមនូវតណ្ហាក្នុងវេទនានោះថា អាត្មាអញមានវេទនាយ៉ាងនេះ ក្នុងកាលជាអតីត មិនប្រព្រឹត្តទៅតាម នូវតណ្ហាក្នុងសញ្ញានោះថា អាត្មាអញមានសញ្ញាយ៉ាងនេះ ក្នុងកាលជាអតីត មិនប្រព្រឹត្តទៅតាមនូវតណ្ហាក្នុងសង្ខារទាំងឡាយនោះថា អាត្មាអញមានសង្ខារយ៉ាងនេះ ក្នុងកាលជាអតីត មិនប្រព្រឹត្តទៅតាមនូវតណ្ហា ក្នុងវិញ្ញាណនោះថា អាត្មាអញមានវិញ្ញាណយ៉ាងនេះ ក្នុងកាលជាអតីត ។ ម្នាលអាវុសោ បុគ្គលមិនអាឡោះអាល័យបញ្ចក្ខន្ធជាអតីត យ៉ាងនេះឯង ។

វិភង្គវគ្គស្ស អានន្ទភទ្ទេករត្តសុត្តេ អនាគតំ នប្បដិកង្ខតា

[១៨] កាថញ្ចាវុសោ អជាគតំ បដិកង្ខតិ ។ ឯវំរូបោ សិយំ អជាគតមទ្ធានន្តិ តត្ថ នន្ទឹ សមន្វា-នេតិ ឯវំវេទនោ សិយំ ។ បេ ។ ឯវំសញ្ញោ សិយំ ។ បេ ។ ឯវំសង្ខារោ សិយំ ។ បេ ។ ឯវំវិញ្ញាណោ សិយំ អជាគតមទ្ធានន្តិ តត្ថ នន្ទឹ សមន្វានេតិ ។ ឯវំ ខោ អាវុសោ អជាគតំ បដិកង្ខតិ ។

[១៦] កាថញ្ចាវុសោ អជាគតំ នប្បដិកង្ខតិ ។ ឯវំរូបោ សិយំ អជាគតមទ្ធានន្តិ តត្ថ នន្ទឹ ន ស-មន្វានេតិ ឯវំវេទនោ សិយំ ។ បេ ។ ឯវំសញ្ញោ សិយំ ។ បេ ។ ឯវំសង្ខារោ សិយំ ។ បេ ។ ឯវំវិញ្ញាណោ សិយំ អជាគតមទ្ធានន្តិ តត្ថ នន្ទឹ ន សមន្វា-នេតិ ។ ឯវំ ខោ អាវុសោ អជាគតំ នប្បដិកង្ខតិ ។

វិភង្គវគ្គ អានន្ទភទ្ទេករត្តសូត្រ សេចក្តីមិនប្រាថ្នានូវបញ្ចក្ខន្ធជាអនាគត

[១៥] ម្នាលអាវុសោ បុគ្គលប្រាថ្នានូវបញ្ចក្ខន្ធជាអនាគត តើដូចម្តេច ។ បុគ្គលប្រព្រឹត្តទៅតាមនូវតណ្ហា ក្នុងរូបនោះថា សូមឲ្យអាត្មាអញមានរូបយ៉ាងនេះ ក្នុងកាលជាអនាគត មានវេទនាយ៉ាងនេះ ។ បេ ។ មានសញ្ញាយ៉ាងនេះ ។ បេ ។ មានសង្ខារយ៉ាងនេះ ។ បេ ។ ប្រព្រឹត្តទៅតាមនូវតណ្ហាក្នុងវិញ្ញាណនោះថា សូមឲ្យអាត្មាអញ មានវិញ្ញាណយ៉ាងនេះ ក្នុងកាលជាអនាគត ។ ម្នាលអាវុសោ បុគ្គលប្រាថ្នានូវបញ្ចក្ខន្ធដែលជាអនាគត យ៉ាងនេះឯង ។

[១៦] ម្នាលអាវុសោ បុគ្គលមិនប្រាថ្នានូវបញ្ចក្ខន្ធ ជាអនាគតតើដូចម្តេច ។ បុគ្គលមិនប្រព្រឹត្តទៅតាមនូវតណ្ហា ក្នុងរូបនោះថា សូមឲ្យអាត្មាអញមានរូបយ៉ាងនេះ ក្នុងកាលជាអនាគត មានវេទនាយ៉ាងនេះ ។ បេ ។ មានសញ្ញាយ៉ាងនេះ ។ បេ ។ មានសង្ខារយ៉ាងនេះ ។ បេ ។ មិនប្រព្រឹត្តទៅតាមនូវតណ្ហា ក្នុងវិញ្ញាណនោះថា សូមឲ្យអាត្មាអញមានវិញ្ញាណយ៉ាងនេះ ក្នុងកាលជាអនាគត ។ ម្នាលអាវុសោ បុគ្គលមិនប្រាថ្នានូវបញ្ចក្ខន្ធជាអនាគត យ៉ាងនេះឯង ។

[១៧] កាចញ្ចាវុសោ បច្ចុប្បន្នេសុ ធម្មេសុ សំហិរតិ ។ ឥធាវុសោ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្មស្ស អកោវិទោ អរិយធម្មេ អវិនីតោ សប្បុរិសានំ អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិសធម្មេ អវិនីតោ រូបំ អត្តតោ សមនុបស្សតិ រូបវន្តំ វា អត្តានំ អត្តនិ វា រូបំ រូបស្មឹ វា អត្តានំ វេទនំ ។ បេ ។ សញ្ញំ ។ បេ ។ សង្ខារេ ។ បេ ។ វិញ្ញាណំ អត្តតោ សមនុបស្សតិ វិញ្ញាណវន្តំ វា អត្តានំ អត្តនិ វា វិញ្ញាណំ វិញ្ញាណស្មឹ វា អត្តានំ ។ ឯវំ ខោ អាវុសោ បច្ចុប្បន្នេសុ ធម្មេសុ សំហិរតិ ។

[១៨] កាចញ្ចាវុសោ បច្ចុប្បន្នេសុ ធម្មេសុ ន សំហិរតិ ។ ឥធាវុសោ សុតវា អរិយសាវកោ អរិយានំ ទស្សាវី អរិយធម្មស្ស កោវិទោ អរិយធម្មេ សុវិនីតោ សប្បុរិសានំ ទស្សាវី សប្បុរិសធម្មស្ស កោវិទោ សប្បុរិសធម្មេ សុវិនីតោ ន រូបំ អត្តតោ សមនុបស្សតិ ន រូបវន្តំ វា អត្តានំ

[១៧] ម្នាលអាវុសោ បុគ្គលរសេមរសាម ក្នុងពួកធម៌ជាបច្ចុប្បន្ន តើដូចម្តេច ។ ម្នាលអាវុសោ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនបានស្តាប់ មិនបានជួបប្រទះនឹងពួកព្រះអរិយៈ ជាអ្នកមិនយល់ធម៌ របស់ព្រះអរិយៈ មិនបានហាត់ក្នុងធម៌របស់ព្រះអរិយៈ មិនបានជួបប្រទះ នឹងពួកសប្បុរស មិនយល់ធម៌របស់សប្បុរស មិនបានហាត់ក្នុងធម៌របស់សប្បុរស រមែងពិចារណាឃើញនូវរូបថាជាខ្លួន នូវខ្លួនថាមានរូប នូវរូបថាមានក្នុងខ្លួន នូវខ្លួនថាមានក្នុងរូប នូវវេទនា ។ បេ ។ នូវសញ្ញា ។ បេ ។ នូវសង្ខារទាំងឡាយ ។ បេ ។ រមែងពិចារណាឃើញនូវវិញ្ញាណថាជាខ្លួន នូវខ្លួនថាមានវិញ្ញាណ នូវវិញ្ញាណថាមានក្នុងខ្លួន នូវខ្លួនថាមានក្នុងវិញ្ញាណ ។ ម្នាលអាវុសោ បុគ្គលរសេមរសាម ក្នុងពួកធម៌ជាបច្ចុប្បន្ន យ៉ាងនេះឯង ។

[១៨] ម្នាលអាវុសោ បុគ្គលមិនរសេមរសាម ក្នុងពួកធម៌ជាបច្ចុប្បន្ន តើដូចម្តេច ។ ម្នាលអាវុសោ អរិយសាវ័កក្នុងលោកនេះ ជាអ្នកបានស្តាប់ បានជួបប្រទះនឹងពួកព្រះអរិយៈ យល់ធម៌របស់ព្រះអរិយៈ បានហាត់ល្អក្នុងធម៌របស់ព្រះអរិយៈ ជាអ្នកបានឃើញពួកសប្បុរស យល់ធម៌របស់សប្បុរស បានហាត់ល្អក្នុងធម៌របស់សប្បុរស មិនពិចារណាឃើញនូវរូបថាខ្លួន មិនពិចារណាឃើញនូវខ្លួនថាមានរូប

ន អត្តនិ វា រូបំ ន រូបស្មឹ វា អត្តានំ ន វេទនំ ។ បេ ។ ន សញ្ញំ ។ បេ ។ ន សង្ខារេ ។ បេ ។ ន វិញ្ញាណំ អត្តតោ សមនុបស្សតិ ន វិញ្ញាណវន្តំ វា អត្តានំ ន អត្តនិ វា វិញ្ញាណំ ន វិញ្ញាណស្មឹ វា អត្តានំ ។ ឯវំ ខោ អាវុសោ បច្ចុប្បន្នេសុ ធម្មេសុ ន សំហិរតិ ។

[១៩] អតីតំ នាន្វាគមេយ្យ
នប្បដិកង្ខេ អនាគតំ
យទតីតម្បហីនន្តំ
អប្បត្តញ្ច អនាគតំ
បច្ចុប្បន្នញ្ច យោ ធម្មំ
តត្ថ តត្ថ វិបស្សតិ
អសំហិរំ អសង្កុប្បំ
តំ វិទ្វា មនុព្រូហយេ
អជ្ជេវ កិច្ចមាតប្បំ

មិនពិចារណាឃើញនូវរូបថាមានក្នុងខ្លួន មិនពិចារណាឃើញនូវខ្លួនថាមានក្នុងរូប មិនពិចារណាឃើញនូវវេទនា ។ បេ ។ មិនពិចារណាឃើញនូវសញ្ញា ។ បេ ។ មិនពិចារណាឃើញនូវសង្ខារទាំងឡាយ ។ បេ ។ មិនពិចារណាឃើញនូវវិញ្ញាណថាជាខ្លួន មិនពិចារណាឃើញនូវខ្លួនថាមានវិញ្ញាណ មិនពិចារណាឃើញនូវវិញ្ញាណថាមានក្នុងខ្លួន មិនពិចារណាឃើញនូវខ្លួនថាមានក្នុងវិញ្ញាណឡើយ ។ ម្នាលអាវុសោ បុគ្គលមិនរសេមរសាមក្នុងពួកធម៌ជាបច្ចុប្បន្ន យ៉ាងនេះឯង ។

[១៩] បុគ្គល មិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធជាអតីត មិនគប្បីប្រាថ្នានូវបញ្ចក្ខន្ធជាអនាគតទេ ព្រោះថាបញ្ចក្ខន្ធណាជាអតីត បញ្ចក្ខន្ធនោះ កន្លងហួសទៅហើយ បញ្ចក្ខន្ធណាជាអនាគត បញ្ចក្ខន្ធនោះ ក៏មិនទាន់មកដល់ មួយទៀត បុគ្គលណា ឃើញច្បាស់នូវធម៌ជាបច្ចុប្បន្ន ក្នុងទីនោះ ៗ បុគ្គលនោះ លុះដឹងច្បាស់នូវព្រះនិព្វានដែលមិនរសេមរសាម មិនកម្រើកហើយ គប្បីចម្រើនឲ្យរឿយ ៗ នូវផលសមាបត្តិ ដែលជាអារម្មណ៍នៃព្រះនិព្វាននោះ ឯការព្យាយាមជាគ្រឿងដុតកិលេស បុគ្គលគួរតែធ្វើក្នុងថ្ងៃនេះឯង

កោ ជញ្ញា មរណំ សុវេ
ន ហិ នោ សង្គរន្តេន
មហាសេនេន មច្ចុនា
ឯវំវិហារិមាតាបឹ
អហោរត្តមតន្ទិតំ
តំ វេ ភទ្ទេករត្តោតិ
សន្តោ អាចិក្ខតេ មុនីតិ ។

ឯវំ ខោ អហំ ភន្តេ ភិក្ខូ ជម្ពិយា កាថាយ សន្ទស្សេសឹ សមាទបេសឹ សមុត្តេជេសឹ សម្បហំសេសឹ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ច អភាសិន្តិ ។

[២០] សាធុ សាធុ អានន្ទ សាធុ ខោ ត្វំ អានន្ទ ភិក្ខូ ជម្ពិយា កាថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ច អភាសិ

អតីតំ នាន្វាគមេយ្យ ។ បេ ។
តំ វេ ភទ្ទេករត្តោតិ
សន្តោ អាចិក្ខតេ មុនីតិ ។

*អ្នកណានឹងដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែកបាន ព្រោះថា ការតទល់របស់យើង ចំពោះមច្ចុដែលមានសេនាច្រើននោះ មិនមានសោះឡើយ មុនីជាអ្នកស្ងប់ទុក្ខ តែងហៅបុគ្គល ដែលមានវិហារធម៌យ៉ាងនេះ មានព្យាយាមដុតកម្តៅកិលេស ជាអ្នកមិនខ្ជិលច្រអូស អស់ថ្ងៃនិងយប់នោះឯង ថាជាអ្នកមានរាត្រីមួយដ៏ចម្រើន ។*

*បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានពន្យល់ពួកភិក្ខុឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ហើយសំដែងនូវឧទ្ទេសនិងវិភង្គ របស់បុគ្គលដែលមានរាត្រីមួយដ៏ចម្រើន យ៉ាងនេះឯង ។*

*[២០] ម្នាលអានន្ទ ប្រពៃហើយ ប្រពៃហើយ ម្នាលអានន្ទ អ្នកបានពន្យល់ ណែនាំពួកភិក្ខុ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ហើយសំដែងនូវឧទ្ទេសនិងវិភង្គ របស់បុគ្គលដែលមានរាត្រីមួយដ៏ចម្រើនថា*

*បុគ្គល មិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធ ដែលជាអតីត ។ បេ ។ មុនីជាអ្នកស្ងប់ទុក្ខ រមែងហៅបុគ្គលនោះឯង ថាជាអ្នកមានរាត្រីមួយដ៏ចម្រើន ដូច្នេះនោះត្រឹមត្រូវហើយ ។*

វិភង្គវគ្គស្ស  អានន្ទភទ្ទេករត្តសុត្តេ  អតីតានាគមនំ

[២១] កថញ្ចានន្ទ អតីតំ អន្វាគមេតិ ។ បេ ។ ឯវំ ខោ អានន្ទ អតីតំ អន្វាគមេតិ ។ កថញ្ចានន្ទ អតីតំ នាន្វាគមេតិ ។ បេ ។ ឯវំ ខោ អានន្ទ អតីតំ នាន្វាគមេតិ ។ កថញ្ចានន្ទ អនាគតំ បដិកង្ខតិ ។ បេ ។ ឯវំ ខោ អានន្ទ អនាគតំ បដិកង្ខតិ ។ កថញ្ចានន្ទ អនាគតំ នប្បដិកង្ខតិ ។ បេ ។ ឯវំ ខោ អានន្ទ អនាគតំ នប្បដិកង្ខតិ ។ កថញ្ចានន្ទ បច្ចុប្បន្នេសុ ធម្មេសុ សំហិរតិ ។ បេ ។ ឯវំ ខោ អានន្ទ បច្ចុប្បន្នេសុ ធម្មេសុ សំហិរតិ ។ កថញ្ចានន្ទ បច្ចុប្បន្នេសុ ធម្មេសុ ន សំហិរតិ ។ បេ ។ ឯវំ ខោ អានន្ទ បច្ចុប្បន្នេសុ ធម្មេសុ ន សំហិរតិ ។

វិភង្គវគ្គ អានន្ទភទ្ទេករត្តសូត្រ សេចក្ដីអាឡោះអាល័យបញ្ចក្ខន្ធជាអតីត

[២១] ម្នាលអានន្ទ បុគ្គល អាឡោះអាល័យបញ្ចក្ខន្ធជាអតីត តើដូចម្ដេច ។ បេ ។ ម្នាលអានន្ទ បុគ្គលអាឡោះអាល័យបញ្ចក្ខន្ធជាអតីតយ៉ាងនេះឯង ។ ម្នាលអានន្ទ បុគ្គលមិនអាឡោះអាល័យបញ្ចក្ខន្ធជាអតីត តើដូចម្ដេច ។ បេ ។ ម្នាលអានន្ទ បុគ្គលមិនអាឡោះអា-ល័យបញ្ចក្ខន្ធជាអតីតយ៉ាងនេះឯង ។ ម្នាលអានន្ទ បុគ្គលប្រាថ្នានូវបញ្ចក្ខន្ធជាអនាគត តើដូចម្ដេច ។ បេ ។ ម្នាលអានន្ទ បុគ្គលប្រាថ្នានូវបញ្ចក្ខន្ធជាអនាគតយ៉ាងនេះឯង ។ ម្នាលអានន្ទ បុគ្គលមិនប្រាថ្នានូវបញ្ចក្ខន្ធជាអនាគត តើដូចម្ដេច ។ បេ ។ ម្នាលអានន្ទ បុគ្គលមិនប្រាថ្នានូវបញ្ចក្ខន្ធជាអនាគតយ៉ាងនេះឯង ។ ម្នាលអានន្ទ បុគ្គលរសេមរសាម ក្នុងពួកធម៌ជាបច្ចុប្បន្ន តើដូចម្ដេច ។ បេ ។ ម្នាលអានន្ទ បុគ្គលរសេមរសាម ក្នុងពួកធម៌ជាបច្ចុប្បន្នយ៉ាងនេះឯង ។ ម្នាលអានន្ទ បុគ្គលមិនរសេមរសាម ក្នុងពួកធម៌ជាបច្ចុប្បន្ន តើដូចម្ដេច ។ បេ ។ ម្នាលអានន្ទ បុគ្គលមិនរសេមរសាម ក្នុងពួកធម៌ជាបច្ចុប្បន្នយ៉ាងនេះឯង ។

១៨



[២២] អតីតំ នាន្វាគមេយ្យ ។ បេ ។

តំ វេ ភទ្ទេករត្តោតិ

សន្តោ អាចិក្ខតេ មុនីតិ ។

ឥទមវោច ភគវា អត្តមនោ អាយស្មា អានន្ទោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

អានន្ទភទ្ទេករត្តសុត្តំ ទុតិយំ និដ្ឋិតំ ។

[២២] បុគ្គល មិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធ ជាអតីត ។ បេ ។ មុនីជាអ្នកស្ងប់ទុក្ខ តែងហៅបុគ្គលនោះឯង ថា ជាអ្នកមានរាត្រីមួយដ៏ចម្រើន ។

លុះព្រះមានព្រះភាគ ត្រាស់ភាសិតនេះចប់ហើយ ព្រះអានន្ទមានអាយុ ក៏មានចិត្តត្រេកអរ រីករាយ នឹងភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ អានន្ទភទ្ទេករត្តសូត្រ ទី ២ ។

# តតិយំ មហាកច្ចានភទ្ទេករត្តសុត្តំ

[២៣] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ តបោទារាមេ ។ អថខោ អាយស្មា សមិទ្ធិ រត្តិយា បច្ចូសសមយំ បច្ចុដ្ឋាយ យេន តបោទោ តេនុបសង្កមិ គត្តានិ បរិសិញ្ចិតុំ ។ តបោទេ គត្តានិ បរិសិញ្ចិត្វា បច្ចុត្តរិត្វា ឯកចីវរោ អដ្ឋាសិ គត្តានិ បុព្វាបយមានោ[១] ។ អថខោ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ តបោទំ ឱភាសេត្វា យេនាយស្មា សមិទ្ធិ តេនុបសង្កមិ ឧបសង្កមិត្វា ឯកមន្តំ អដ្ឋាសិ ។

[២៤] ឯកមន្តំ ឋិតា ខោ សា ទេវតា អាយស្មន្តំ សមិទ្ធឹ ឯតទវោច ធារេសិ ត្វំ ភិក្ខុ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ចាតិ ។ ន ខោ អហំ អាវុសោ ធារេមិ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ច

---

១ ម. សុក្ខាបយមានោ ។

# មហាកច្ចានភទ្ទេករត្តសូត្រ ទី ៣

[២៣] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់សម្រេចព្រះឥរិយាបថ ក្នុងតបោទារាម ជិតក្រុងរាជគ្រឹះ ។ គ្រានោះឯង ព្រះសមិទ្ធិមានអាយុ ក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រី ហើយចូលទៅរកស្ទឹងឈ្មោះតបោទា ដើម្បីនឹងស្រលាបខ្លួន ។ លុះចុះទៅស្រលាបខ្លួនក្នុងស្ទឹងឈ្មោះតបោទាស្រេចហើយ លោកក៏ឡើងមកវិញ មានតែចីវរមួយ ឈរហាលខ្លួនឲ្យស្ងួត ។ គ្រានោះឯង កាលរាត្រីបឋមយាមកន្លងទៅហើយ មានទេវតាមួយអង្គមានរស្មីដ៏រុងរឿង ញុំាងស្ទឹងឈ្មោះតបោទាទាំងមូលឲ្យភ្លឺស្វាង ហើយចូលទៅរកព្រះសមិទ្ធិមានអាយុ លុះចូលទៅដល់ហើយ ទើបឈរក្នុងទីសមគួរ ។

[២៤] លុះទេវតានោះ ឈរក្នុងទីសមគួរហើយ បាននិយាយនឹងព្រះសមិទ្ធិមានអាយុយ៉ាងនេះថា បពិត្រភិក្ខុ លោកចាំនូវឧទ្ទេសនិងវិភង្គ របស់បុគ្គលដែលមានរាត្រីមួយដ៏ចម្រើនឬទេ ។ ម្នាលអាវុសោអាត្មាមិនចាំនូវឧទ្ទេសនិងវិភង្គ របស់បុគ្គលដែលមានរាត្រីមួយដ៏ចម្រើនទេ

ត្វំ បនាវុសោ ជានាសិ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ចាតិ ។ អហម្បិ ខោ ភិក្ខុ ន ជានាមិ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ច ជានាសិ បន ត្វំ ភិក្ខុ ភទ្ទេករត្តិយោ គាថាតិ ។ ន ខោ អហំ អាវុសោ ជានាមិ ភទ្ទេករត្តិយោ គាថា ត្វំ បនាវុសោ ជានាសិ ភទ្ទេករត្តិយោ គាថាតិ ។ អហម្បិ ខោ ភិក្ខុ ន ជានាមិ ភទ្ទេករត្តិយោ គាថា ឧគ្គណ្ហាហិ ត្វំ ភិក្ខុ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ច បរិយាបុណាហិ ត្វំ ភិក្ខុ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ច ធារេហិ ត្វំ ភិក្ខុ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ច អត្ថសញ្ហិតោ ភិក្ខុ ភទ្ទេករត្តស្ស ឧទ្ទេសោ ច វិភង្គោ ច អាទិព្រហ្មចរិយកោតិ ។ ឥទមវោច សា ទេវតា ឥទំ វត្វា តត្ថេវន្តរធាយិ ។

[២៥] អថខោ អាយស្មា សមិទ្ធិ តស្សា រត្តិយា អច្ចយេន យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។

ម្នាលអាវុសោ ចុះអ្នកចាំនូវឧទ្ទេសនិងវិភង្គ របស់បុគ្គលដែលមានរាត្រីមួយដ៏ចម្រើនឬទេ ។ បពិត្រភិក្ខុ ខ្ញុំព្រះករុណាក៏មិនចាំនូវឧទ្ទេសនិងវិភង្គ របស់បុគ្គលដែលមានរាត្រីមួយដ៏ចម្រើនដែរ បពិត្រភិក្ខុ ចុះលោកចាំគាថាមានរាត្រីមួយដ៏ចម្រើនឬទេ ។ ម្នាលអាវុសោ អាត្មាមិនចាំគាថាមានរាត្រីមួយដ៏ចម្រើនទេ ម្នាលអាវុសោ ចុះអ្នកចាំគាថាមានរាត្រីមួយដ៏ចម្រើនឬទេ ។ បពិត្រភិក្ខុ ខ្ញុំព្រះករុណាក៏មិនចាំគាថាមានរាត្រីមួយដ៏ចម្រើនដែរ បពិត្រភិក្ខុ ចូរលោករៀន នូវឧទ្ទេសនិងវិភង្គ របស់បុគ្គលមានរាត្រីមួយដ៏ចម្រើន បពិត្រភិក្ខុ ចូរលោកទន្ទេញ នូវឧទ្ទេសនិងវិភង្គរបស់បុគ្គលមានរាត្រីមួយដ៏ចម្រើន បពិត្រភិក្ខុ ចូរលោកចាំទុក នូវឧទ្ទេសនិងវិភង្គរបស់បុគ្គលមានរាត្រីមួយដ៏ចម្រើន បពិត្រភិក្ខុ ព្រោះឧទ្ទេសនិងវិភង្គរបស់បុគ្គលមានរាត្រីមួយដ៏ចម្រើន ជាធម៌ប្រកបដោយប្រយោជន៍ ហើយជាខាងដើមនៃមគ្គព្រហ្មចារ្យ ។ ទេវតានោះ បានពោលពាក្យនេះ លុះពោលពាក្យនេះចប់ហើយ ក៏បាត់ក្នុងទីនោះទៅ ។

[២៥] គ្រានោះឯង ព្រះសមិទ្ធិមានអាយុ លុះកន្លងរាត្រីនោះហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំចំពោះព្រះមានព្រះភាគ រួចអង្គុយ ក្នុងទីសមគួរ ។

## ២១

### វិភង្គវគ្គស្ស  កច្ចានភទ្ទេករត្តសុត្តេ  ភគវន្តូបសង្កមនំ

ឯកមន្តំ និសិន្នោ ខោ អាយស្មា សមិទ្ធិ ភគវន្តំ ឯតទវោច ឥធាហំ ភន្តេ រត្តិយា បច្ចូសសមយំ បច្ចុដ្ឋាយ យេន តបោទោ តេនុបសង្កមឹ គត្តានិ បរិសិញ្ចិតុំ ។ តបោទេ គត្តានិ បរិសិញ្ចិត្វា បច្ចុត្តរិត្វា ឯកចីវរោ អដ្ឋាសឹ គត្តានិ បុព្វាបយមានោ ។ អថខោ ភន្តេ អញ្ញតរា ទេវតា អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណា កេវលកប្បំ តបោទំ ឱភាសេត្វា យេនាហំ តេនុបសង្កមិ ឧបសង្កមិត្វា ឯកមន្តំ អដ្ឋាសិ ឯកមន្តំ ឋិតា ខោ សា ទេវតា មំ ឯតទវោច ធារេសិ ត្វំ ភិក្ខុ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ចាតិ ។ ឯវំ វុត្តេ អហំ ភន្តេ តំ ទេវតំ ឯតទវោចំ ន ខោ អហំ អាវុសោ ធារេមិ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ច ត្វំ បនាវុសោ ធារេសិ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ចាតិ ។ អហម្បិ ខោ ភិក្ខុ ន ធារេមិ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ច

*លុះព្រះសមិទ្ធិមានអាយុ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រីក្នុងទីនេះ បានចូលទៅឯស្ទឹងតបោទា ដើម្បីនឹងស្រោចស្រពខ្លួន ។ លុះបានស្រោចស្រពខ្លួនក្នុងស្ទឹងតបោទាស្រេចហើយ ខ្ញុំព្រះអង្គក៏ឡើងមកវិញ មានតែចីវរមួយ ឈរហាលខ្លួនឲ្យស្ងួត ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងគ្រារាត្រីបឋមយាមកន្លងហើយ មានទេវតាមួយអង្គ មានរស្មីដ៏រុងរឿង ញ៉ាំងស្ទឹងតបោទាឲ្យភ្លឺស្វាង ហើយចូលទៅរកខ្ញុំព្រះអង្គ លុះចូលទៅដល់ហើយ ក៏ឈរក្នុងទីសមគួរ លុះទេវតានោះ ឈរក្នុងទីសមគួរហើយ បាននិយាយនឹងខ្ញុំព្រះអង្គដូច្នេះថា បពិត្រភិក្ខុ លោកចាំនូវឧទ្ទេសនិងវិភង្គ របស់បុគ្គលមានរាត្រីមួយដ៏ចម្រើនឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលទេវតាពោលយ៉ាងនេះហើយ ខ្ញុំព្រះអង្គបានពោលនឹងទេវតានោះដូច្នេះថា ម្នាលអាវុសោ អាត្មាមិនចាំនូវឧទ្ទេសនិងវិភង្គ របស់បុគ្គលមានរាត្រីមួយដ៏ចម្រើនទេ ម្នាលអាវុសោ ចុះអ្នកចាំនូវឧទ្ទេសនិងវិភង្គ របស់បុគ្គលមានរាត្រីមួយដ៏ចម្រើនឬទេ ។ ទេវតានោះតបថា បពិត្រភិក្ខុ ខ្ញុំករុណាក៏មិនចាំនូវឧទ្ទេសនិងវិភង្គ របស់បុគ្គលមានរាត្រីមួយដ៏ចម្រើនដែរ*

ជានាសិ បន ត្វំ ភិក្ខុ ភទ្ទេករត្តិយោ គាថាតិ ។ ន ខោ អហំ អាវុសោ ជានាមិ ភទ្ទេករត្តិយោ គាថា ត្វំ បនាវុសោ ជានាសិ ភទ្ទេករត្តិយោ គាថាតិ ។ អហម្បិ ខោ ភិក្ខុ ន ជានាមិ ភទ្ទេករត្តិយោ គាថា ឧគ្គណ្ហាហិ ត្វំ ភិក្ខុ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ច បរិយាបុណាហិ ត្វំ ភិក្ខុ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ច ធារេហិ ត្វំ ភិក្ខុ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ច អត្ថសញ្ហិតោ ភិក្ខុ ភទ្ទេករត្តស្ស ឧទ្ទេសោ ច វិភង្គោ ច អាទិព្រហ្មចរិយកោតិ ។ ឥទម-វោច ភន្តេ សា ទេវតា ឥទំ វត្វា តត្ថេវន្តរធាយិ ។ សាធុ មេ ភន្តេ ភគវា ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ច ទេសេតូតិ ។ តេនហិ ភិក្ខុ សុណាហិ សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវម្ភន្តេតិ ខោ អាយស្មា សមិទ្ធិ ភគវតោ បច្ចស្សោសិ ។

បពិត្រភិក្ខុ ចុះលោកចាំនូវគាថាមានរាត្រីមួយដ៏ចម្រើនឬទេ ។ ខ្ញុំព្រះអង្គតបថា ម្នាលអាវុសោ អាត្មាមិនចាំនូវគាថាមានរាត្រីមួយដ៏ចម្រើនទេ ម្នាលអាវុសោ ចុះអ្នកចាំនូវគាថាមានរាត្រីមួយដ៏ចម្រើនឬទេ ។ ទេវតាតបថា បពិត្រភិក្ខុ ខ្ញុំករុណាក៏មិនចាំ នូវគាថាមានរាត្រីមួយដ៏ចម្រើនដែរ បពិត្រភិក្ខុ ចូរលោករៀនយក នូវឧទ្ទេសនិងវិភង្គរបស់បុគ្គលមានរាត្រីមួយដ៏ចម្រើន បពិត្រភិក្ខុ ចូរលោកទន្ទេញនូវឧទ្ទេសនិងវិភង្គរបស់បុគ្គលមានរាត្រីមួយដ៏ចម្រើន បពិត្រភិក្ខុ ចូរលោកចាំទុក នូវឧទ្ទេសនិងវិភង្គរបស់បុគ្គលមានរាត្រីមួយដ៏ចម្រើន បពិត្រភិក្ខុ ព្រោះថាឧទ្ទេសនិងវិភង្គរបស់បុគ្គលមានរាត្រីមួយដ៏ចម្រើន ជាធម៌ប្រកបដោយប្រយោជន៍ ជាខាងដើមនៃព្រហ្មចារ្យ ។ បពិត្រព្រះអង្គដ៏ចម្រើន ទេវតានោះ បានពោលពាក្យនេះ លុះពោលពាក្យនេះចប់ហើយ ក៏បាត់ក្នុងទីនោះទៅ ។ បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះអង្គទ្រង់សំដែងនូវឧទ្ទេសនិងវិភង្គរបស់បុគ្គលមានរាត្រីមួយដ៏ចម្រើន ដល់ខ្ញុំព្រះអង្គ ។ ព្រះអង្គក៏ទ្រង់ត្រាស់ថា ម្នាលភិក្ខុ បើដូច្នោះ អ្នកចូរស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែងប្រាប់ ។ ព្រះសមិទ្ធិមានអាយុបានទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

២៣

វិភង្គវគ្គស្ស កច្ចានភទ្ទេករត្តសុត្តេ ភទ្ទេករត្តភាវោ

[២៦] ភគវា ឯតទវោច

អតីតំ នាន្វាគមេយ្យ
នប្បដិកង្ខេ អនាគតំ
យទតីតម្បហីនន្តំ
អប្បត្តញ្ច អនាគតំ
បច្ចុប្បន្នញ្ច យោ ធម្មំ
តត្ថ តត្ថ វិបស្សតិ
អសំហិរំ អសង្កុប្បំ
តំ វិទ្វា មនុព្រូហយេ
អជ្ជេវ កិច្ចមាតប្បំ
កោ ជញ្ញា មរណំ សុវេ
ន ហិ នោ សង្គរន្តេន
មហាសេនេន មច្ចុនា
ឯវំវិហារិមាតាបឹ
អហោរត្តមតន្ទិតំ
តំ វេ ភទ្ទេករត្តោតិ
សន្តោ អាចិក្ខតេ មុនីតិ ។

[២៦] ព្រះមានព្រះភាគ ទ្រង់បានត្រាស់គាថានេះថា បុគ្គលមិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធ ជាអតីត មិនគប្បីប្រាថ្នាបញ្ចក្ខន្ធជាអនាគត ព្រោះបញ្ចក្ខន្ធណា ជាអតីត បញ្ចក្ខន្ធនោះកន្លងហួសទៅហើយ បញ្ចក្ខន្ធណាជាអនាគត បញ្ចក្ខន្ធនោះក៏មិនទាន់មកដល់ មួយទៀត បុគ្គលណា ឃើញច្បាស់នូវធម៌ជាបច្ចុប្បន្នក្នុងទីនោះ ៗ បុគ្គលនោះ លុះដឹងច្បាស់នូវព្រះនិព្វាន ដែលមិនរសេមរសាម មិនកម្រើកហើយ គប្បីចម្រើនឲ្យរឿយ ៗ នូវផលសមាបត្តិ ដែលជាអារម្មណ៍របស់ព្រះនិព្វាននោះ ឯការព្យាយាមជាគ្រឿងដុតនូវកិលេសបុគ្គលគួរតែធ្វើក្នុងថ្ងៃនេះឯង អ្នកណានឹងដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែកបាន ព្រោះថា ការតទល់របស់យើងចំពោះមច្ចុ ដែលមានសេនាច្រើននោះ មិនមានសោះឡើយ មុនីជាអ្នកស្ងប់ទុក្ខ តែងហៅបុគ្គល ដែលមានវិហារធម៌យ៉ាងនេះ មានព្យាយាមដុតកម្តៅកិលេស មិនខ្ជិលច្រអូសអស់ថ្ងៃនិងយប់នោះឯង ថាជាអ្នកមានរាត្រីមួយដ៏ចម្រើន ។

ឥទមវោច ភគវា ឥទំ វត្វាន សុគតោ ឧដ្ឋាយា-សនា វិហារំ បាវិសិ ។

[២៧] អថខោ តេសំ ភិក្ខូនំ អចិរបក្កន្តស្ស ភគវតោ ឯតទហោសិ ឥទំ ខោ នោ អាវុសោ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ

អតីតំ នាន្វាគមេយ្យ
នប្បដិកង្ខេ អនាគតំ
យទតីតម្បហីនន្តំ
អប្បត្តញ្ច អនាគតំ
បច្ចុប្បន្នញ្ច យោ ធម្មំ
តត្ថ តត្ថ វិបស្សតិ
អសំហិរំ អសង្កុប្បំ
តំ វិទ្វា មនុព្រូហយេ
អជ្ជេវ កិច្ចមាតប្បំ

ព្រះមានព្រះភាគ បានត្រាស់ភាសិតនេះ លុះព្រះសុគតត្រាស់ភាសិតនេះចប់ហើយ ទ្រង់ក្រោកអំពីអាសនៈ ហើយចូលទៅកាន់វិហារ ។

[២៧] គ្រានោះឯង កាលព្រះមានព្រះភាគ ចៀសចេញទៅមិនយូរប៉ុន្មាន ពួកភិក្ខុទាំងនោះ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគ បានសំដែងឧទ្ទេសនេះឯង ដោយសេចក្តីបំប្រួញ មិនទាន់ចែកសេចក្តីដោយពិស្តារ ដល់យើងទាំងឡាយនៅឡើយ ទ្រង់ក្រោកអំពីអាសនៈ ចូលទៅកាន់វិហារ (ឧទ្ទេសនោះគឺ)

បុគ្គល មិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធជាអតីត មិនគប្បីប្រាថ្នាបញ្ចក្ខន្ធជាអនាគត ព្រោះថា បញ្ចក្ខន្ធណា ជាអតីត បញ្ចក្ខន្ធនោះ កន្លងហួសទៅហើយ បញ្ចក្ខន្ធណា ជាអនាគត បញ្ចក្ខន្ធនោះ ក៏មិនទាន់មកដល់ មួយទៀត បុគ្គលណា ពិចារណាឃើញច្បាស់ នូវធម៌ជាបច្ចុប្បន្ន ក្នុងទីនោះ ៗ បុគ្គលនោះ លុះដឹងច្បាស់នូវព្រះនិព្វាន ដែលមិនរសេមរសាម មិនកម្រើកហើយ ត្រូវចម្រើនឲ្យរឿយ ៗ នូវផលសមាបត្តិ ដែលជាអារម្មណ៍របស់ព្រះនិព្វាននោះ ឯការព្យាយាមជាគ្រឿងដុតនូវកិលេស បុគ្គលគួរធ្វើក្នុងថ្ងៃនេះឯង

២៤

វិភង្គវគ្គស្ស កច្ចានភទ្ទេករត្តសុត្តេ ភិក្ខូនំ បរិវិតក្កនំ

កោ ជញ្ញា មរណំ សុវេ
ន ហិ នោ សង្គរន្តេន
មហាសេនេន មច្ចុនា
ឯវំវិហារិមាតាបឹ
អហោរត្តមតន្ទិតំ
តំ វេ ភទ្ទេករត្តោតិ
សន្តោ អាចិក្ខតេ មុនីតិ

កោ នុ ខោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជេយ្យាតិ ។ អថខោ តេសំ ភិក្ខូនំ ឯតទហោសិ អយំ ខោ អាយស្មា មហាកច្ចានោ សត្ថុ ចេវ សំវណ្ណិតោ សម្ភាវិតោ ច វិញ្ញូនំ សព្រហ្មចារីនំ បហោតិ ចាយស្មា មហាកច្ចានោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជិតុំ យន្នូន មយំ យេនាយស្មា មហាកច្ចានោ តេនុបសង្កមេយ្យាម ឧបសង្កមិត្វា អាយស្មន្តំ មហាកច្ចានំ ឯតមត្ថំ បដិបុច្ឆេយ្យាមាតិ ។

អ្នកណានឹងដឹងថា សេចក្តីស្លាប់ នឹងមានក្នុងថ្ងៃស្អែក បាន ព្រោះថា ការតទល់របស់យើងចំពោះមច្ចុ ដែលមានសេនាច្រើននោះ មិនមានសោះឡើយ មុនីជាអ្នកស្ងប់ទុក្ខ តែងហៅបុគ្គល ដែលមានវិហារធម៌យ៉ាងនេះ មានព្យាយាមដុតកម្តៅកិលេស ជាអ្នកមិនខ្ជិលច្រអូស អស់ថ្ងៃនិងយប់នោះឯង ថាជាអ្នកមានរាត្រីមួយចម្រើន

កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងនូវឧទ្ទេសនេះដោយសេចក្តីបំប្រួញ មិនចែកសេចក្តីដោយពិស្តារហើយ អ្នកណាគប្បីចែកសេចក្តីដោយពិស្តារបាន ។ គ្រានោះឯង ភិក្ខុទាំងនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះមហាកច្ចានៈមានអាយុនេះ ព្រះសាស្តាទ្រង់សរសើរផង ពួកសព្រហ្មចារីជាអ្នកចេះដឹងបានលើកតម្កើងផង ព្រះមហាកច្ចានៈមានអាយុ អាចចែករំលែក នូវសេចក្តីនៃឧទ្ទេស ដែលព្រះមានព្រះភាគ ទ្រង់សំដែងដោយសង្ខេប មិនបានចែករំលែកសេចក្តីដោយពិស្តារនេះឲ្យពិស្តារបានផង បើដូច្នោះ គួរពួកយើងនាំគ្នាចូលទៅរកព្រះមហាកច្ចានៈមានអាយុ លុះចូលទៅដល់ហើយ យើងត្រូវសួរសេចក្តីនុ៎ះនឹងព្រះកច្ចានៈមានអាយុ ។

[២៨] អថខោ តេ ភិក្ខូ យេនាយស្មា មហាកច្ចានោ តេនុបសង្កមឹសុ ឧបសង្កមិត្វា អាយស្មតា មហាកច្ចានេន សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ អាយស្មន្តំ មហាកច្ចានំ ឯតទវោចុំ ឥទំ ខោ នោ អាវុសោ កច្ចាន ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ

អតីតំ នាន្វាគមេយ្យ ។ បេ ។

តំ វេ ភទ្ទេករត្តោតិ

សន្តោ អាចិក្ខតេ មុនីតិ

តេសន្នោ អាវុសោ កច្ចាន អម្ហាកំ អចិរប្បក្កន្តស្ស ភគវតោ ឯតទហោសិ ឥទំ ខោ នោ អាវុសោ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ

[២៨] គ្រានោះឯង ភិក្ខុទាំងនោះ ក៏នាំគ្នាចូលទៅរកព្រះមហាកច្ចានៈមានអាយុ លុះចូលទៅដល់ហើយ ក៏រាក់ទាក់សំណេះសំណាលជាមួយនឹងព្រះមហាកច្ចានៈមានអាយុ លុះបញ្ចប់ពាក្យរាក់ទាក់សំណេះសំណាល និងពាក្យគួរឲ្យរលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ ក៏បាននិយាយនឹងព្រះមហាកច្ចានៈមានអាយុ យ៉ាងនេះថា ម្នាលអាវុសោកច្ចានៈ ព្រះមានព្រះភាគ ទ្រង់សំដែងនូវឧទ្ទេសនេះឯង ដោយសេចក្តីសង្ខេប មិនចែករំលែកសេចក្តីដោយពិស្តារ ដល់យើងទាំងឡាយនៅឡើយ ហើយទ្រង់ក្រោកអំពីអាសនៈ ចូលទៅកាន់វិហារទៅ (ឧទ្ទេសនោះគឺ)

បុគ្គល មិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធជាអតីត ។ បេ ។
មុនីជាអ្នកស្ងប់ទុក្ខ តែងហៅបុគ្គលនោះឯង ថាជាអ្នកមាន
រាត្រីមួយដ៏ចម្រើន

ម្នាលអាវុសោកច្ចានៈ កាលព្រះមានបុណ្យ ស្តេចចេញទៅមិនយូរប៉ុន្មាន ពួកយើងខ្ញុំទាំងនោះ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា ម្នាលអាវុសោ ព្រះមានព្រះភាគទ្រង់សំដែងនូវឧទ្ទេសនេះឯង ដោយសេចក្តីសង្ខេប មិនបានចែកសេចក្តីដោយពិស្តារ ដល់យើងទាំងឡាយនៅឡើយ ហើយទ្រង់ក្រោកអំពីអាសនៈ ចូលទៅកាន់វិហារទៅ (ឧទ្ទេសនោះគឺ)

២៧



អតីតំ នាន្វាគមេយ្យ ។ បេ ។

តំ វេ ភទ្ទេករត្តោតិ

សន្តោ អាចិក្ខតេ មុនីតិ

កោ នុ ខោ ឥមស្ស ភគវតោ សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ អវិភជេយ្យាតិ តេសន្នោ អាវុសោ កច្ចាន អម្ហាកំ ឯតទហោសិ អយំ ខោ អាយស្មា មហាកច្ចានោ សត្ថុ ចេវ សំវណ្ណិតោ សម្ភាវិតោ ច វិញ្ញូនំ សព្រហ្មចារីនំ បហោតិ ចាយស្មា មហាកច្ចានោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ វិភជិតុំ យន្នូន មយំ យេនាយស្មា មហាកច្ចានោ តេនុបសង្កមេយ្យាម ឧបសង្កមិត្វា អាយស្មន្តំ មហាកច្ចានំ ឯតមត្ថំ បដិបុច្ឆេយ្យាមាតិ វិភជតាយស្មា មហាកច្ចានោតិ ។

បុគ្គល  មិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធជាអតីត ។ បេ ។
មុនីជាអ្នកស្ងប់ទុក្ខ  តែងហៅបុគ្គលនោះឯង  ថាជាអ្នកមាន
រាត្រីមួយដ៏ចម្រើន ។

ឧទ្ទេសនេះ  បើព្រះមានបុណ្យ  ទ្រង់សំដែងដោយសេចក្តីសង្ខេប មិនបានចែកសេចក្តីដោយពិស្តារ  អ្នកណាហ្ន៎  គប្បីចែកសេចក្តីដោយពិស្តារបាន  ម្នាលអាវុសោកច្ចានៈ  ពួកយើងខ្ញុំទាំងនោះ  មានសេចក្តីត្រិះរិះយ៉ាងនេះថា  ព្រះមហាកច្ចានៈមានអាយុនេះឯង  ព្រះសាស្តាតែងសរសើរផង  ពួកសព្រហ្មចារីជាអ្នកចេះដឹងបានលើកតម្កើងផង  ព្រះមហាកច្ចានៈមានអាយុ  អាចចែករំលែកសេចក្តីនៃឧទ្ទេស  ដែលព្រះមានព្រះភាគទ្រង់សំដែងដោយសង្ខេបនេះ  ឲ្យពិស្តារបានផង  បើដូច្នោះ គួរតែយើងនាំគ្នាចូលទៅរកព្រះមហាកច្ចានៈមានអាយុ  លុះចូលទៅដល់ហើយ  ត្រូវសួរសេចក្តីនេះ  នឹងព្រះមហាកច្ចានៈមានអាយុ  សូមឲ្យព្រះមហាកច្ចានៈមានអាយុ  ចែកសេចក្តីឲ្យទាន ។

[២៩] សេយ្យថាបិ អាវុសោ បុរិសោ សារត្ថិកោ សារគវេសី សារបរិយេសនញ្ចរមានោ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ អតិក្កម្មេវ មូលំ អតិក្កម្ម ខន្ធំ សាខាបលាសេ សារំ បរិយេសិតព្វំ មញ្ញេយ្យ ឯវំ សម្បទមិទំ អាយស្មន្តានំ សត្ថរិ សម្មុខីភូតេ តំ ភគវន្តំ អតិសិត្វា(១) អម្ហេ ឯតមត្ថំ បដិបុច្ឆិតព្វំ មញ្ញថ(២) សោ ហាវុសោ ភគវា ជានំ ជានាតិ បស្សំ បស្សតិ ចក្ខុភូតោ ញាណភូតោ ធម្មភូតោ ព្រហ្មភូតោ វត្តា បវត្តា អត្ថស្ស និន្នេតា អមតស្ស ទាតា ធម្មស្សាមី តថាគតោ សោ ចេវ បនេតស្ស កាលោ អហោសិ(៣) យំ ភគវន្តំយេវ ឯតមត្ថំ បដិបុច្ឆេយ្យាថ យថា វោ ភគវា ព្យាករេយ្យ តថា នំ ធារេយ្យាថាតិ ។ អទ្ធាវុសោ កច្ចាន ភគវា ជានំ ជានាតិ បស្សំ បស្សតិ ចក្ខុភូតោ ញាណភូតោ ធម្មភូតោ ព្រហ្មភូតោ វត្តា បវត្តា

---

១ ម. អតិក្កមិត្វា ។ ២ ឱ. មញ្ញេថ ។ ៣ ឱ. ហោសិ ។

[២៩] ព្រះមហាកច្ចានៈពោលថា ម្នាលអាវុសោ បុរសអ្នកត្រូវការដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ស្វែងរកខ្លឹមឈើ កាលឈើមានខ្លឹមដុះ (នៅមុខ) ក៏រំលងគល់ រំលងដើម ហើយសំគាល់រកខ្លឹមឯមែកនិងសន្ទឹកវិញ មានឧបមាយ៉ាងណាមិញ សេចក្តីនេះ ក៏មានឧបមេយ្យយ៉ាងនោះដែរ ព្រះសាស្តានៅក្នុងទីចំពោះមុខ របស់លោកមានអាយុទាំងឡាយ ពួកលោករំលងព្រះមានព្រះភាគនោះហើយសំគាល់សេចក្តីដែលត្រូវសួរនោះចំពោះខ្ញុំវិញ ម្នាលអាវុសោ ព្រោះថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ជ្រាបនូវធម៌ ដែលគួរជ្រាបបាន ឃើញនូវធម៌ ដែលគួរឃើញបាន ទ្រង់មានបញ្ញាចក្ខុ មានញាណ ទ្រង់មានធម៌ មានគុណដ៏ប្រសើរ ទ្រង់កាន់ធម៌ ប្រព្រឹត្តធម៌ ពន្យល់សេចក្តី ទ្រង់ប្រទាននូវអមតៈ (និព្វាន) ជាម្ចាស់ធម៌ ជាព្រះតថាគត ឯកាលដ៏សមគួរដល់ប្រស្នានុ៎ះ គឺកាលវេលាដែលអ្នកទាំងឡាយ គួរតែសួរសេចក្តីនុ៎ះ នឹងព្រះមានព្រះភាគ បើព្រះមានព្រះភាគទ្រង់ដោះស្រាយដល់អ្នកទាំងឡាយ យ៉ាងណា ចូរអ្នកទាំងឡាយ ចាំទុកសេចក្តីនោះយ៉ាងនោះចុះ ។ ម្នាលអាវុសោកច្ចានៈ ព្រះមានព្រះភាគ ព្រះអង្គជ្រាបនូវធម៌ ដែលគួរជ្រាប ឃើញនូវធម៌ ដែលគួរឃើញ មានបញ្ញាចក្ខុ មានញាណ មានធម៌ មានគុណដ៏ប្រសើរ ទ្រង់កាន់ធម៌ ប្រព្រឹត្តធម៌

២៩

វិភង្គវគ្គស្ស  កច្ចានភទ្ទេករត្តសុត្តេ  មហាកច្ចានបសំសនំ

អត្ថស្ស និន្នេតា អមតស្ស ទាតា ធម្មស្សាមី តថាគតោ សោ ចេវ បនេតស្ស កាលោ អ-ហោសិ យំ ភគវន្តំយេវ ឯតមត្ថំ បដិបុច្ឆេយ្យាម យថា នោ ភគវា ព្យាករេយ្យ តថា នំ ធា-រេយ្យាម អបិចាយស្មា មហាកច្ចានោ សត្ថុ ចេវ សំវណ្ណិតោ សម្ភាវិតោ ច វិញ្ញូនំ សព្រហ្មចារីនំ ប-ហោតិ ចាយស្មា មហាកច្ចានោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិ-ភត្តស្ស វិត្ថារេន អត្ថំ វិភជិតុំ វិភជតាយស្មា មហា-កច្ចានោ អគរុករិត្វាតិ ។ តេនហាវុសោ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវមាវុសោ-តិ ខោ តេ ភិក្ខូ អាយស្មតោ មហាកច្ចានស្ស បច្ចស្សោសុំ ។

ពន្យល់សេចក្តី ប្រទានអមតៈ (និព្វាន) ជាម្ចាស់ធម៌ ជាព្រះតថាគត ឯកាលដ៏សមគួរដល់ប្រស្នានុ៎ះ គឺកាលវេលាដែលយើងទាំងឡាយគួរតែសួរសេចក្តីនុ៎ះ នឹងព្រះមានព្រះភាគ បើព្រះមានព្រះភាគ ទ្រង់ដោះស្រាយដល់យើងទាំងឡាយ យ៉ាងណា យើងទាំងឡាយ គប្បីចាំទុកសេចក្តីនោះយ៉ាងនោះ ក៏ពិតមែនហើយ តែថា ព្រះមហាកច្ចានៈមានអាយុ ព្រះសាស្តាតែងសរសើរផង ពួកសព្រហ្មចារីបុគ្គលជាអ្នកចេះដឹងតែងលើកតម្កើងផងមួយទៀត ព្រះមហាកច្ចានៈមានអាយុ លោកអាចចែកសេចក្តីនៃឧទ្ទេសដែលព្រះមានព្រះភាគ សំដែងហើយដោយសេចក្តីសង្ខេប មិនទាន់ចែករំលែកសេចក្តីដោយពិស្តារនេះ ឲ្យពិស្តារបានផង សូមព្រះមហា-កច្ចានៈមានអាយុ កុំធ្វើឲ្យយឺតយូរឡើយ សូមចែកឲ្យទាន ។ ព្រះមហា-កច្ចានៈតបថា ម្នាលអាវុសោ បើដូច្នោះ លោកទាំងឡាយចូរស្តាប់ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ ខ្ញុំនឹងសំដែងប្រាប់ ។ ពួកភិក្ខុទាំងនោះក៏ទទួលពាក្យរបស់ព្រះមហាកច្ចានៈមានអាយុថា ករុណា អាវុសោ ។

[៣០] អាយស្មា មហាកច្ចានោ ឯតទវោច យំ ខោ នោ អាវុសោ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ

អតីតំ នាន្វាគមេយ្យ ។ បេ ។
តំ វេ ភទ្ទេករត្តោតិ
សន្តោ អាចិក្ខតេ មុនីតិ

ឥមស្ស ខោ អហំ អាវុសោ ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស ឯវំ វិត្ថារេន អត្ថំ អាជានាមិ ។

[៣១] កថញ្ចាវុសោ អតីតំ អន្វាគមេតិ ។ ឥតិ មេ ចក្ខុ អហោសិ អតីតមទ្ធានំ ឥតិ រូបាតិ តត្ថ ឆន្ទរាគប្បដិពទ្ធំ ហោតិ វិញ្ញាណំ ឆន្ទរាគប្បដិពទ្ធត្តា វិញ្ញាណស្ស តទភិនន្ទតិ តទភិនន្ទន្តោ អតីតំ អន្វាគមេតិ ។ ឥតិ មេ សោតំ អហោសិ អតីតមទ្ធានំ

[៣០] ព្រះមហាកច្ចានៈមានអាយុ បានពោលពាក្យនេះថា ម្នាលអាវុសោ ព្រះមានព្រះភាគទ្រង់សំដែងនូវឧទ្ទេសណា ដល់អ្នកទាំង-ឡាយ ដោយសេចក្តីសង្ខេប មិនទាន់ចែកសេចក្តីដោយពិស្តារនៅឡើយ ស្រាប់តែទ្រង់ក្រោកអំពីអាសនៈ ចូលទៅកាន់វិហារ (ឧទ្ទេសនោះគឺ)

បុគ្គល មិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធជាអតីត ។ បេ ។
មុនីជាអ្នកស្ងប់ទុក្ខ តែងហៅបុគ្គលនោះឯង ថាជាអ្នកមាន
រាត្រីមួយដ៏ចម្រើន ។

ម្នាលអាវុសោ កាលព្រះមានព្រះភាគ ទ្រង់សំដែងនូវឧទ្ទេសនេះ ដោយសង្ខេប មិនបានចែកសេចក្តីឲ្យពិស្តារ ខ្ញុំយល់សេចក្តីពិស្តារ ដូចតទៅនេះ ។

[៣១] ម្នាលអាវុសោ បុគ្គលអាឡោះអាល័យបញ្ចក្ខន្ធជាអតីត តើដូចម្តេច ។ វិញ្ញាណ រមែងជាប់ចំពាក់នឹងឆន្ទរាគក្នុងចក្ខុនិងរូបនោះ ថា អាត្មាអញ មានចក្ខុ ក្នុងកាលជាអតីតដូច្នេះ មានរូបដូច្នេះ បុគ្គលតែងត្រេកអរចំពោះចក្ខុនិងរូបនោះ ព្រោះវិញ្ញាណជាប់ចំពាក់ដោយឆន្ទរាគ កាលបុគ្គលត្រេកអរចំពោះចក្ខុនិងរូបនោះ ឈ្មោះថា អាឡោះអាល័យចក្ខុនិងរូបជាអតីត ។ អាត្មាអញ មានសោតៈ ក្នុងកាលជាអតីតដូច្នេះ

ឥតិ សទ្ទាតិ... ឥតិ មេ ឃានំ អហោសិ អតីត-មទ្ធានំ ឥតិ គន្ធាតិ... ឥតិ មេ ជិវ្ហា អហោសិ អតីតមទ្ធានំ ឥតិ រសោតិ... ឥតិ មេ កាយោ អហោ-សិ អតីតមទ្ធានំ ឥតិ ផោដ្ឋព្វាតិ... ឥតិ មេ មនោ អហោសិ អតីតមទ្ធានំ ឥតិ ធម្មាតិ តត្ថ ឆន្ទរា-គប្បដិពទ្ធំ ហោតិ វិញ្ញាណំ ឆន្ទរាគប្បដិពទ្ធត្តា វិញ្ញាណស្ស តទភិនន្ទតិ តទភិនន្ទន្តោ អតីតំ អន្វា-គមេតិ ។ ឯវំ ខោ អាវុសោ អតីតំ អន្វាគមេតិ ។

[៣២] កាថញ្ចាវុសោ អតីតំ នាន្វាគមេតិ ។ ឥតិ មេ ចក្ខុ អហោសិ អតីតមទ្ធានំ ឥតិ រូបាតិ តត្ថ ន ឆន្ទរាគប្បដិពទ្ធំ ហោតិ វិញ្ញាណំ ន ឆន្ទរាគប្បដិ-ពទ្ធត្តា វិញ្ញាណស្ស ន តទភិនន្ទតិ ន តទភិនន្ទន្តោ អតីតំ នាន្វាគមេតិ ។ ឥតិ មេ សោតំ អហោសិ

មានសំឡេងដូច្នេះ... អាត្មាអញ មានឃានៈ ក្នុងកាលជាអតីតដូច្នេះ មានក្លិនដូច្នេះ... អាត្មាអញ មានជិវ្ហា ក្នុងកាលជាអតីតដូច្នេះ មានរស ដូច្នេះ... អាត្មាអញ មានកាយ ក្នុងកាលជាអតីតដូច្នេះ មានផោដ្ឋព្វៈ ដូច្នេះ... អាត្មាអញ មានចិត្ត ក្នុងកាលជាអតីតដូច្នេះ មានធម្មារម្មណ៍ ដូច្នេះ វិញ្ញាណ រមែងជាប់ចំពាក់នឹងឆន្ទរាគ ក្នុងចិត្តនិងអារម្មណ៍នោះ ដូច្នេះ បុគ្គលរមែងត្រេកអរចំពោះចិត្តនិងអារម្មណ៍នោះ ព្រោះវិញ្ញាណ ជាប់ចំពាក់នឹងឆន្ទរាគ កាលបុគ្គលត្រេកអរចំពោះចិត្តនិងអារម្មណ៍នោះ ឈ្មោះថានៅអាឡោះអាល័យចិត្ត និងធម្មារម្មណ៍ជាអតីត ។ ម្នាល អាវុសោ បុគ្គលនៅអាឡោះអាល័យបញ្ចក្ខន្ធជាអតីត យ៉ាងនេះឯង ។

[៣២] ម្នាលអាវុសោ បុគ្គល មិនអាឡោះអាល័យបញ្ចក្ខន្ធជា អតីត តើដូចម្តេច ។ វិញ្ញាណរមែងមិនជាប់ចំពាក់នឹងឆន្ទរាគក្នុងចក្ខុនិងរូប នោះថា អាត្មាអញ មានចក្ខុ ក្នុងកាលជាអតីតដូច្នេះ មានរូបដូច្នេះ បុគ្គល រមែងមិនត្រេកអរចំពោះចក្ខុនិងរូបនោះ ព្រោះវិញ្ញាណមិនបានជាប់ចំពាក់ នឹងឆន្ទរាគ កាលបុគ្គលមិនត្រេកអរចំពោះចក្ខុនិងរូបនោះ ឈ្មោះថាមិន បានអាឡោះអាល័យចក្ខុនិងរូបជាអតីត ។ អាត្មាអញ មានសោតៈ ក្នុង

អតីតមទ្ធានំ ឥតិ សទ្ទាតិ... ឥតិ មេ ឃានំ អហោសិ អតីតមទ្ធានំ ឥតិ គន្ធាតិ... ឥតិ មេ ជិវ្ហា អហោសិ អតីតមទ្ធានំ ឥតិ រសាតិ... ឥតិ មេ កាយោ អហោសិ អតីតមទ្ធានំ ឥតិ ផោដ្ឋព្វាតិ... ឥតិ មេ មនោ អហោសិ អតីតមទ្ធានំ ឥតិ ធម្មាតិ តត្ថ ឆន្ទរាគប្បដិពទ្ធំ ហោតិ វិញ្ញាណំ ឆន្ទរាគប្បដិពទ្ធត្តា វិញ្ញាណស្ស តទភិនន្ទតិ តទភិនន្ទន្តោ អតីតំ ជាន្វាគមេតិ ។ ឯវំ ខោ អាវុសោ អតីតំ ជាន្វាគមេតិ ។

[៣៣] កាថញ្ចាវុសោ អនាគតំ បដិកង្ខតិ ។ ឥតិ មេ ចក្ខុ សិយា អនាគតមទ្ធានំ ឥតិ រូបាតិ អប្បដិលទ្ធស្ស បដិលាភាយ ចិត្តំ បណិទហតិ ចេតសោ បណិធានប្បច្ចយា តទភិនន្ទតិ

កាលជាអតីតដូច្នេះ មានសំឡេងដូច្នេះ... អាត្មាអញ មានឃានៈក្នុងកាលជាអតីតដូច្នេះ មានក្លិនដូច្នេះ... អាត្មាអញ មានជិវ្ហា ក្នុងកាលជាអតីតដូច្នេះ មានរសដូច្នេះ... អាត្មាអញ មានកាយ ក្នុងកាលជាអតីតដូច្នេះ មានផោដ្ឋព្វៈដូច្នេះ... វិញ្ញាណ រមែងមិនជាប់ចំពាក់ដោយឆន្ទៈរាគ ក្នុងចិត្តនិងអារម្មណ៍នោះថា អាត្មាអញ មានចិត្ត ក្នុងកាលជាអតីតដូច្នេះ មានធម្មារម្មណ៍ដូច្នេះ បុគ្គលមិនត្រេកអរចំពោះចិត្តនិងធម្មារម្មណ៍នោះ ព្រោះវិញ្ញាណមិនជាប់ចំពាក់ដោយឆន្ទរាគ កាលបុគ្គលមិនត្រេកអរចំពោះចិត្ត និងធម្មារម្មណ៍នោះ ឈ្មោះថាមិនអាឡោះអាល័យចិត្តនិងធម្មារម្មណ៍ជាអតីត ។ ម្នាលអាវុសោ បុគ្គល មិនអាឡោះអាល័យបញ្ចក្ខន្ធជាអតីត យ៉ាងនេះឯង ។

[៣៣] ម្នាលអាវុសោ បុគ្គលប្រាថ្នានូវបញ្ចក្ខន្ធជាអនាគត តើដូចម្តេច ។ បុគ្គល តម្កល់ចិត្តដើម្បីការបាននូវរបស់ដែលមិនទាន់បានថា ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញ មានចក្ខុដូច្នេះ មានរូបដូច្នេះ ព្រោះការតម្កល់ចិត្តជាបច្ច័យ នាំឲ្យបុគ្គលត្រេកអរចំពោះចក្ខុនិងរូបនោះ

៣៣

វិភង្គវគ្គស្ស  កច្ចានភទ្ទេករត្តសុត្តេ  អនាគតប្បដិកង្ខតា

តទភិនន្ទន្តោ អនាគតំ បដិកង្ខតិ ។ ឥតិ មេ សោតំ សិយា អនាគតមទ្ធានំ ឥតិ សទ្ទាតិ... ឥតិ មេ ឃានំ សិយា អនាគតមទ្ធានំ ឥតិ គន្ធាតិ... ឥតិ មេ ជិវ្ហា សិយា អនាគតមទ្ធានំ ឥតិ រសាតិ... ឥតិ មេ កាយោ សិយា អនាគតមទ្ធានំ ឥតិ ផោដ្ឋព្វា-តិ... ឥតិ មេ មនោ សិយា អនាគតមទ្ធានំ ឥតិ ធម្មាតិ អប្បដិលទ្ធស្ស បដិលាភាយ ចិត្តំ បណិទ-ហតិ ចេតសោ បណិធានប្បច្ចយា តទភិនន្ទតិ តទ-ភិនន្ទន្តោ អនាគតំ បដិកង្ខតិ ។ ឯវំ ខោ អាវុសោ អនាគតំ បដិកង្ខតិ ។

កាលបុគ្គលត្រេកអរចំពោះចក្ខុនិងរូបនោះ ឈ្មោះថាប្រាថ្នានូវចក្ខុនិងរូបជាអនាគត ។ ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញ មានសោតៈ ដូច្នេះ មានសំឡេងដូច្នេះ... ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញ មានឃានៈ ដូច្នេះ មានក្លិនដូច្នេះ... ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញ មានជិវ្ហាដូច្នេះ មានរសដូច្នេះ... ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញ មានកាយដូច្នេះ មានផោដ្ឋព្វៈដូច្នេះ... បុគ្គលតម្កល់ចិត្ត ដើម្បីការបាននូវចិត្តនិងធម្មារម្មណ៍ ដែលមិនទាន់បានថា ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញ មានចិត្តដូច្នេះ មានធម្មារម្មណ៍ដូច្នេះ ព្រោះការតម្កល់ចិត្តជាបច្ច័យ នាំឲ្យបុគ្គលនោះត្រេកអរចំពោះចិត្តនិងធម្មារម្មណ៍នោះ កាលបុគ្គលត្រេកអរចំពោះចិត្តនិងធម្មារម្មណ៍នោះ ឈ្មោះថាប្រាថ្នានូវចិត្តនិងធម្មារម្មណ៍ជាអនាគត ។ ម្នាលអាវុសោ បុគ្គលប្រាថ្នានូវបញ្ចក្ខន្ធជាអនាគត យ៉ាងនេះឯង ។

[៣៤] កថញ្ចាវុសោ អនាគតំ នប្បដិកង្ខតិ ។ ឥតិ មេ ចក្ខុ សិយា អនាគតមទ្ធានំ ឥតិ រូបាតិ អប្បដិលទ្ធស្ស បដិលាភាយ ចិត្តំ ន បណិទហតិ ចេតសោ អបណិធានប្បច្ចយា ន តទភិនន្ទតិ ន តទភិនន្ទន្តោ អនាគតំ នប្បដិកង្ខតិ ។ ឥតិ មេ សោតំ សិយា អនាគតមទ្ធានំ ឥតិ សទ្ទា- តិ... ឥតិ មេ ឃានំ សិយា អនាគតមទ្ធានំ ឥតិ គន្ធាតិ... ឥតិ មេ ជិវ្ហា សិយា អនាគតមទ្ធានំ ឥតិ រសាតិ... ឥតិ មេ កាយោ សិយា អនាគត- មទ្ធានំ ឥតិ ផោដ្ឋព្វាតិ... ឥតិ មេ មនោ សិយា អនាគតមទ្ធានំ ឥតិ ធម្មាតិ អប្បដិលទ្ធស្ស បដិ- លាភាយ ចិត្តំ ន បណិទហតិ ចេតសោ អប- ណិធានប្បច្ចយា ន តទភិនន្ទតិ ន តទភិនន្ទន្តោ អនាគតំ នប្បដិកង្ខតិ ។ ឯវំ ខោ អាវុសោ អនាគតំ នប្បដិកង្ខតិ ។

[៣៤] ម្នាលអាវុសោ បុគ្គលមិនប្រាថ្នានូវបញ្ចក្ខន្ធជាអនាគត តើដូចម្តេច ។ បុគ្គល មិនបានតម្កល់ចិត្ត ដើម្បីការបាននូវរបស់ដែលខ្លួនមិនទាន់បានថា ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញ មានចក្ខុដូច្នេះ មានរូបដូច្នេះ ព្រោះការមិនបានតម្កល់ចិត្តជាបច្ច័យ នាំឲ្យបុគ្គលលែងត្រេកអរចំពោះចក្ខុនិងរូបនោះ កាលបុគ្គលលែងត្រេកអរចំពោះចក្ខុនិងរូបនោះ ឈ្មោះថាមិនប្រាថ្នានូវចក្ខុនិងរូបជាអនាគត ។ ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញ មានសោតៈដូច្នេះ មានសំឡេងដូច្នេះ... ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញ មានឃានៈដូច្នេះ មានក្លិនដូច្នេះ... ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញ មានជិវ្ហាដូច្នេះ មានរសដូច្នេះ... ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញ មានកាយដូច្នេះ មានផោដ្ឋព្វៈដូច្នេះ... បុគ្គលមិនបានតម្កល់ចិត្តទុក ដើម្បីការបាននូវចិត្តនិងធម្មារម្មណ៍ដែលមិនទាន់បានថា ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញ មានចិត្តដូច្នេះ មានធម្មារម្មណ៍ដូច្នេះ ព្រោះការមិនបានតម្កល់ចិត្តទុកជាបច្ច័យ នាំឲ្យបុគ្គលលែងត្រេកអរចំពោះចិត្តនិងធម្មារម្មណ៍នោះ កាលបុគ្គលលែងត្រេកអរចំពោះចិត្តនិងធម្មារម្មណ៍នោះ ឈ្មោះថាមិនប្រាថ្នានូវចិត្តនិងធម្មា-រម្មណ៍ជាអនាគត ។ ម្នាលអាវុសោ បុគ្គល មិនប្រាថ្នានូវបញ្ចក្ខន្ធជាអនាគត យ៉ាងនេះឯង ។

[៣៤] កាថញ្ចាវុសោ បច្ចុប្បន្នេសុ ធម្មេសុ សំហិរតិ ។ យញ្ចាវុសោ ចក្ខុ យេ ច រូបា ឧភយមេតំ បច្ចុប្បន្នំ តស្មឹយេវ បច្ចុប្បន្នេ ឆន្ទរាគប្បដិពទ្ធំ ហោតិ វិញ្ញាណំ ឆន្ទរាគប្បដិពទ្ធត្តា វិញ្ញាណស្ស តទភិនន្ទតិ តទភិនន្ទន្តោ បច្ចុប្បន្នេសុ ធម្មេសុ សំហិរតិ ។ យញ្ចាវុសោ សោតំ យេ ច សទ្ទា... យញ្ចាវុសោ ឃានំ យេ ច គន្ធា... យា ចាវុសោ ជិវ្ហា យេ ច រសា... យោ ចាវុសោ កាយោ យេ ច ផោដ្ឋព្វា... យោ ចាវុសោ មនោ យេ ច ធម្មា ឧភយមេតំ បច្ចុប្បន្នំ តស្មឹយេវ បច្ចុប្បន្នេ ឆន្ទរាគប្បដិពទ្ធំ ហោតិ វិញ្ញាណំ ឆន្ទរាគប្បដិពទ្ធត្តា វិញ្ញាណស្ស តទភិនន្ទតិ តទភិនន្ទន្តោ បច្ចុប្បន្នេសុ ធម្មេសុ សំហិរតិ ។ ឯវំ ខោ អាវុសោ បច្ចុប្បន្នេសុ ធម្មេសុ សំហិរតិ ។

វិភង្គវគ្គ កច្ចានភទ្ទេករត្តសូត្រ សេចក្តីរសេមរសាមក្នុងពួកធមិជាបច្ចុប្បន្ន

[៣៥] ម្នាលអាវុសោ បុគ្គលរសេមរសាម ក្នុងពួកធម៌ជាបច្ចុប្បន្ន តើដូចម្តេច ។ ម្នាលអាវុសោ ចក្ខុនិងរូបទាំង ២ នេះ ជាបច្ចុប្បន្ន វិញ្ញាណរមែងជាប់ចំពាក់នឹងឆន្ទរាគ ក្នុងចក្ខុនិងរូបជាបច្ចុប្បន្ននោះឯង បុគ្គលត្រេកអរចំពោះចក្ខុនិងរូបនោះ ព្រោះវិញ្ញាណជាប់ចំពាក់នឹងឆន្ទរាគ កាលបុគ្គលត្រេកអរចំពោះចក្ខុនិងរូបនោះ ឈ្មោះថារសេម-រសាម ក្នុងពួកធម៌ជាបច្ចុប្បន្ន ។ ម្នាលអាវុសោ ត្រចៀកនិងសំឡេង... ម្នាលអាវុសោ ច្រមុះនិងក្លិន... ម្នាលអាវុសោ អណ្តាតនិងរស... ម្នាលអាវុសោ កាយនិងផោដ្ឋព្វៈ... ម្នាលអាវុសោ ចិត្តនិងធម្មារម្មណ៍ទាំង ២ នេះ ជាបច្ចុប្បន្ន វិញ្ញាណរមែងជាប់ចំពាក់នឹងឆន្ទរាគក្នុងចិត្តនិងធម្មារម្មណ៍ជាបច្ចុប្បន្ននោះឯង បុគ្គលរមែងត្រេកអរចំពោះចិត្តនិងធម្មា-រម្មណ៍នោះ ព្រោះវិញ្ញាណជាប់ចំពាក់នឹងឆន្ទរាគ កាលបុគ្គលត្រេកអរចំពោះចិត្តនិងធម្មារម្មណ៍ជាបច្ចុប្បន្ននោះ ឈ្មោះថារសេមរសាមក្នុងពួកធម៌ជាបច្ចុប្បន្ន ។ ម្នាលអាវុសោ បុគ្គលរសេមរសាមក្នុងពួកធម៌ជាបច្ចុប្បន្ន យ៉ាងនេះឯង ។

[៣៦] កាជញ្ហាវុសោ បច្ចុប្បន្នេសុ ធម្មេសុ ន សំហិរតិ ។ យញ្ហាវុសោ ចក្ខុ យេ ច រូបា ឧភ-យមេតំ បច្ចុប្បន្នំ តស្មឹយេវ បច្ចុប្បន្នេ ន ឆន្ទរា-គប្បដិពទ្ធំ ហោតិ វិញ្ញាណំ ន ឆន្ទរាគប្បដិពទ្ធត្តា វិញ្ញាណស្ស ន តទភិនន្ទតិ ន តទភិនន្ទន្តោ បច្ចុប្បន្នេ-សុ ធម្មេសុ ន សំហិរតិ ។ យញ្ហាវុសោ សោតំ យេ ច សទ្ទា... យញ្ហាវុសោ ឃានំ យេ ច គន្ធា... យា ចាវុសោ ជិវ្ហា យេ ច រសា... យោ ចាវុសោ កាយោ យេ ច ផោដ្ឋព្វា... យោ ចាវុសោ មនោ យេ ច ធម្មា ឧភយមេតំ បច្ចុប្បន្នំ តស្មឹយេវ បច្ចុប្បន្នេ ន ឆន្ទរាគប្បដិពទ្ធំ ហោតិ វិញ្ញាណំ ន ឆន្ទរា-គប្បដិពទ្ធត្តា វិញ្ញាណស្ស ន តទភិនន្ទតិ ន តទភិ-នន្ទន្តោ បច្ចុប្បន្នេសុ ធម្មេសុ ន សំហិរតិ ។ ឯវំ ខោ អាវុសោ បច្ចុប្បន្នេសុ ធម្មេសុ ន សំហិរតិ ។

[៣៦] ម្នាលអាវុសោ បុគ្គលមិនរសេមរសាម ក្នុងពួកធម៌ជាបច្ចុប្បន្ន តើដូចម្តេច ។ ម្នាលអាវុសោ ចក្ខុនិងរូបទាំង ២ នេះ ជាបច្ចុប្បន្ន វិញ្ញាណមិនជាប់ចំពាក់នឹងឆន្ទរាគ ក្នុងចក្ខុនិងរូបជាបច្ចុប្បន្ននោះឯង បុគ្គលមិនត្រេកអរចំពោះចក្ខុនិងរូបនោះ ព្រោះវិញ្ញាណមិនជាប់ចំពាក់នឹងឆន្ទរាគ កាលបុគ្គលមិនត្រេកអរចំពោះចក្ខុនិងរូបនោះ ឈ្មោះថាមិនរសេមរសាម ក្នុងពួកធម៌ជាបច្ចុប្បន្ន ។ ម្នាលអាវុសោ ត្រចៀកនិងសំឡេង... ម្នាលអាវុសោ ច្រមុះនិងក្លិន... ម្នាលអាវុសោ អណ្តាតនិងរស... ម្នាលអាវុសោ កាយនិងផោដ្ឋព្វៈ... ម្នាលអាវុសោ ចិត្តនិងធម្មារម្មណ៍ទាំង ២ នេះ ជាបច្ចុប្បន្ន វិញ្ញាណរមែងមិនជាប់ចំពាក់នឹងឆន្ទរាគ ក្នុងចិត្តនិងធម្មារម្មណ៍ជាបច្ចុប្បន្ននោះឯង បុគ្គលមិនត្រេកអរចំពោះចិត្តនិងធម្មារម្មណ៍ជាបច្ចុប្បន្ននោះ ព្រោះវិញ្ញាណមិនជាប់ចំពាក់នឹងឆន្ទរាគ កាលបុគ្គលមិនត្រេកអរ ចំពោះចិត្តនិងធម្មារម្មណ៍នោះ ឈ្មោះថាមិនរសេមរសាម ក្នុងពួកធម៌ជាបច្ចុប្បន្ន ។ ម្នាលអាវុសោ បុគ្គលមិនរសេមរសាម ក្នុងពួកធម៌ជាបច្ចុប្បន្ន យ៉ាងនេះឯង ។

## ៣៧

### វិភង្គវគ្គស្ស កច្ចានភទ្ទេករត្តសុត្តេ ភាសិតាភិនន្ទនំ

[៣៧] យំ ខោ វោ អាវុសោ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ

អតីតំ នាន្វាគមេយ្យ ។ បេ ។
តំ វេ ភទ្ទេករត្តោតិ
សន្តោ អាចិក្ខតេ មុនីតិ

ឥមស្ស ខោ អហំ អាវុសោ ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស ឯវំ វិត្ថារេន អត្ថំ អាជានាមិ អាកង្ខមានា ច បន តុម្ហេ អាយស្មន្តោ ភគវន្តំយេវ ឧបសង្កមិត្វា ឯតមត្ថំ បដិបុច្ឆេយ្យាថ យថា វោ ភគវា ព្យាករោតិ តថា នំ ធារេយ្យាថាតិ ។

[៣៨] អថខោ តេ ភិក្ខូ អាយស្មតោ មហាកច្ចានស្ស ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។

[៣៧] ម្នាលអាវុសោ ត្រង់ដែលព្រះមានព្រះភាគ ត្រាស់សំដែងនូវឧទ្ទេសដោយសេចក្តីសង្ខេប មិនបានចែករំលែកសេចក្តីដោយពិស្តារ ដល់អ្នកទាំងឡាយ ហើយទ្រង់ក្រោកអំពីអាសនៈ ចូលទៅកាន់វិហារ (ឧទ្ទេសនោះគឺ)

បុគ្គល មិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធជាអតីត ។ បេ ។
មុនីជាអ្នកស្ងប់ទុក្ខ តែងហៅបុគ្គលនោះឯង ថាជាអ្នក
មានរាត្រីមួយដ៏ចម្រើន

ម្នាលអាវុសោ ឧទ្ទេសដែលព្រះមានព្រះភាគ ទ្រង់សំដែងដោយសង្ខេប មិនបានចែកសេចក្តីដោយពិស្តារនេះឯង ខ្ញុំយល់សេចក្តីដោយពិស្តារយ៉ាងនេះ តែប្រសិនបើលោកមានអាយុប្រាថ្នា ត្រូវចូលទៅគាល់ព្រះមានព្រះភាគ ហើយសួរបញ្ជាក់សេចក្តីនុ៎ះ ហើយត្រូវចាំទុកសេចក្តីនោះ តាមទំនងដែលព្រះមានព្រះភាគទ្រង់ដោះស្រាយ យ៉ាងនោះចុះ ។

[៣៨] គ្រានោះឯង ពួកភិក្ខុទាំងនោះ ក៏ត្រេកអរអនុមោទនានឹងភាសិតរបស់ព្រះមហាកច្ចានៈមានអាយុ ហើយក្រោកអំពីអាសនៈចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។

ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោ-ចុំ យំ ខោ នោ ភន្តេ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ

អតីតំ នាន្វាគមេយ្យ ។ បេ ។

តំ វេ ភទ្ទេករត្តោតិ

សន្តោ អាចិក្ខតេ មុនីតិ

តេសន្នោ ភន្តេ អម្ហាកំ អចិរប្បក្កន្តស្ស ភគវ-តោ ឯតទហោសិ ឥទំ ខោ នោ អាវុសោ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិ-ភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ

លុះពួកភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ បានក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងនូវឧទ្ទេសណា ដោយសេចក្តីសង្ខេប មិនទាន់បានចែករំលែកសេចក្តីដោយពិស្តារនៅឡើយ ហើយទ្រង់ក្រោកអំពីអាសនៈចូលទៅកាន់វិហារទៅ (ឧទ្ទេសនោះគឺ)

បុគ្គល មិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធជាអតីត ។ បេ ។
មុនីជាអ្នកស្ងប់ទុក្ខ តែងហៅបុគ្គលនោះឯង ថាជាអ្នកមាន
រាត្រីមួយដ៏ចម្រើន

បពិត្រព្រះអង្គដ៏ចម្រើន កាលព្រះមានព្រះភាគ ស្តេចចេញទៅមិនយូរប៉ុន្មាន យើងខ្ញុំទាំងនោះ ក៏មានសេចក្តីត្រិះរិះដូច្នេះថា ម្នាលអាវុសោ ព្រះមានព្រះភាគទ្រង់ត្រាស់សំដែងនូវឧទ្ទេសនេះឯង ដោយសេចក្តីសង្ខេប មិនទាន់ចែកសេចក្តីដោយពិស្តារនៅឡើយ ហើយទ្រង់ក្រោកអំពីអាសនៈ ចូលទៅកាន់វិហារ (ឧទ្ទេសនោះគឺ)

៣៩

វិភង្គវគ្គស្ស កច្ចានភទ្ទេករត្តសុត្តេ ភទ្ទេករត្តគាថា

អតីតំ នាន្វាគមេយ្យ

នប្បដិកង្ខេ អនាគតំ

យទតីតម្បហីនន្តំ

អប្បត្តញ្ច អនាគតំ

បច្ចុប្បន្នញ្ច យោ ធម្មំ

តត្ថ តត្ថ វិបស្សតិ

អសំហិរំ អសង្កុប្បំ

តំ វិទ្វា មនុព្រូហយេ

អជ្ជេវ កិច្ចមាតប្បំ

កោ ជញ្ញា មរណំ សុវេ

ន ហិ នោ សង្គរន្តេន

មហាសេនេន មច្ចុនា

ឯវំវិហារិមាតាបឹ

អហោរត្តមតន្ទិតំ

តំ វេ ភទ្ទេករត្តោតិ

សន្តោ អាចិក្ខតេ មុនីតិ

បុគ្គលមិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធជាអតីតទេ មិនគប្បីប្រាថ្នាបញ្ចក្ខន្ធជាអនាគតទេ ព្រោះថា បញ្ចក្ខន្ធណា ជាអតីត បញ្ចក្ខន្ធនោះ កន្លងហួសទៅហើយ បញ្ចក្ខន្ធណាជាអនាគត បញ្ចក្ខន្ធនោះ មិនទាន់មកដល់ មួយទៀតបុគ្គលណា ឃើញច្បាស់នូវធម៌ជាបច្ចុប្បន្នក្នុងទីនោះ ៗ បុគ្គលនោះ លុះដឹងច្បាស់នូវព្រះនិព្វាន ដែលមិនរសេមរសាមមិនកម្រើកហើយ ត្រូវចម្រើនឲ្យរឿយ ៗ នូវផលសមាបត្តិដែលជាអារម្មណ៍របស់ព្រះនិព្វាននោះ ឯការព្យាយាមដុតកម្ដៅកិលេស បុគ្គលគួរតែធ្វើក្នុងថ្ងៃនេះឯង នរណានឹងដឹងថា សេចក្ដីស្លាប់នឹងមានក្នុងថ្ងៃស្អែកបាន ព្រោះថាការតទល់របស់យើងចំពោះមច្ចុ ដែលមានសេនាច្រើននោះ មិនមានឡើយ មុនីជាអ្នកស្ងប់ទុក្ខ តែងហៅបុគ្គលដែលមានវិហារធម៌យ៉ាងនេះ មានព្យាយាមដុតកម្ដៅកិលេស ជាអ្នកមិនខ្ជិលច្រអូសអស់ថ្ងៃនិងយប់នោះឯង ថាជាអ្នកមានរាត្រីមួយដ៏ចម្រើន ។

កោ នុ ខោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជេយ្យាតិ តេសន្នោ ភន្តេ អម្ហាកំ ឯតទហោសិ អយំ ខោ អាយស្មា មហាកច្ចានោ សត្ថុ ចេវ សំវណ្ណិតោ សម្ភាវិតោ ច វិញ្ញូនំ សព្រហ្មចារីនំ បហោតិ ចាយស្មា មហាកច្ចានោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជិតុំ យន្នូន មយំ យេនាយស្មា មហាកច្ចានោ តេនុបសង្កមេយ្យាម ឧបសង្កមិត្វា អាយស្មន្តំ មហាកច្ចានំ ឯតមត្ថំ បដិបុច្ឆេយ្យាមាតិ អថខោ មយំ ភន្តេ យេនាយស្មា មហាកច្ចានោ តេនុបសង្កមិម្ហា ឧបសង្កមិត្វា អាយស្មន្តំ មហាកច្ចានំ ឯតមត្ថំ បដិបុច្ឆិម្ហា តេសន្នោ ភន្តេ អាយស្មតា មហាកច្ចានេន ឥមេហិ អាការេហិ ឥមេហិ បទេហិ ឥមេហិ ព្យញ្ជនេហិ អត្ថោ វិភត្តោតិ ។

នរណាហ្ន៎ គប្បីចែករំលែកសេចក្តីនៃឧទ្ទេស ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងដោយសង្ខេប ទ្រង់មិនទាន់ចែកសេចក្តីដោយពិស្តារនេះ ឲ្យពិស្តារបាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយនោះ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះមហាកច្ចានៈមានអាយុនេះឯង ព្រះសាស្តាតែងសរសើរផង ពួកសព្រហ្មចារីបុគ្គលជាអ្នកចេះដឹងតែងលើកតម្កើងផង ព្រះមហាកច្ចានៈមានអាយុ អាចចែកសេចក្តីនៃឧទ្ទេស ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែង ដោយសង្ខេប មិនទាន់ចែកសេចក្តីដោយពិស្តារនេះ ឲ្យពិស្តារបានផង បើដូច្នោះ គួរពួកយើងចូលទៅរកព្រះមហាកច្ចានៈមានអាយុ លុះចូលទៅដល់ហើយ ពួកយើងគប្បីសួរបញ្ហាក់សេចក្តីនុ៎ះ នឹងព្រះមហាកច្ចានៈមានអាយុចុះ បពិត្រព្រះអង្គដ៏ចម្រើន កាលបើហេតុយ៉ាងនេះ ពួកខ្ញុំព្រះអង្គ ក៏នាំគ្នាចូលទៅរកព្រះមហាកច្ចានៈមានអាយុ លុះចូលទៅដល់ហើយ បានសួរបញ្ជាក់សេចក្តីនុ៎ះនឹងព្រះមហាកច្ចានៈមានអាយុ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមហាកច្ចានៈមានអាយុ ក៏បានចែកសេចក្តី ដោយអាការៈទាំងឡាយនេះ ដោយបទទាំងឡាយនេះ ដោយព្យញ្ជនៈទាំងឡាយនេះ ដល់ពួកខ្ញុំព្រះអង្គទាំងនោះ ។

៤១

វិភង្គវគ្គស្ស កច្ចានភទ្ទេករត្តសុត្តេ ភាសិតាភិនន្ទនំ

[៣៩] បណ្ឌិតោ ភិក្ខវេ មហាកច្ចានោ មហាបញ្ញោ ភិក្ខវេ មហាកច្ចានោ មញ្ចេបិ ភិក្ខវេ ឯតមត្ថំ បដិបុច្ឆេយ្យាថ អហម្បិ តំ ឯវមេវំ ព្យាករេយ្យំ យថាតំ មហាកច្ចានេន ព្យាកតំ ឯសោ ចេវ តស្ស អត្ថោ ឯវញ្ច នំ ធារេថាតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

កច្ចានភទ្ទេករត្តសុត្តំ តតិយំ និដ្ឋិតំ ។

[៣៩] ម្នាលភិក្ខុទាំងឡាយ មហាកច្ចានៈ ជាបណ្ឌិត ម្នាលភិក្ខុទាំងឡាយ មហាកច្ចានៈ មានប្រាជ្ញាច្រើន ម្នាលភិក្ខុទាំងឡាយ ប្រសិនបើអ្នកទាំងឡាយ សួរបញ្ហាក់សេចក្ដីនុ៎ះនឹងតថាគត តថាគតក៏នឹងដោះស្រាយសេចក្ដីនោះ តាមទំនង ដែលមហាកច្ចានៈដោះស្រាយយ៉ាងនោះដែរ សេចក្ដីនៃភាសិតនោះ ដូច្នោះមែនហើយ ចូរអ្នកទាំង-ឡាយ ចាំទុកយ៉ាងនេះចុះ ។ លុះព្រះមានព្រះភាគ ត្រាស់ភាសិតនេះចប់ហើយ ពួកភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអរ រីករាយ នឹងភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ កច្ចានភទ្ទេករត្តសូត្រ ទី ៣ ។

# ចតុត្ថំ លោមសកង្គិយសុត្តំ[១]

[៤០] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា លោមសកង្គិយោ សក្កេសុ វិហរតិ កបិលវត្ថុស្មឹ និគ្រោធារាមេ ។ អថខោ ចន្ទនោ ទេវបុត្តោ អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណោ កេវលកប្បំ និគ្រោធារាមំ ឱភាសេត្វា យេនាយស្មា លោមសកង្គិយោ តេនុបសង្កមិ ឧបសង្កមិត្វា ឯកមន្តំ អដ្ឋាសិ ។

[៤១] ឯកមន្តំ ឋិតោ ខោ ចន្ទនោ ទេវបុត្តោ អាយស្មន្តំ លោមសកង្គិយំ ឯតទវោច ធារេសិ ត្វំ ភិក្ខុ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ចាតិ ។ ន ខោ អហំ អាវុសោ ធារេមិ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ច ត្វំ បនាវុសោ ធារេសិ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ចាតិ ។ អហម្បិ ខោ ភិក្ខុ ន ធារេមិ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ច ធារេសិ ត្វំ[៣] ភិក្ខុ

១ ឱ. លោមសកង្គិយភទ្ទេករត្តសុត្តំ ។ ម. លោមសកង្គិយត្ថេរស្ស ភទ្ទេករត្តសុត្តំ ។
២ ឱ. បន ត្វំ ។

# លោមសកង្គិយសូត្រ ទី ៩

[៤០] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ស្តេចគង់នៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះលោមសកង្គិយៈមានអាយុ នៅក្នុងនិគ្រោធារាម ទៀបក្រុងកបិលព័ស្តុ ក្នុងដែនសក្កៈ ។

គ្រានោះឯង ទេវបុត្តឈ្មោះចន្ទនៈ នាកាលរាត្រីបឋមយាមកន្លងហើយ មានរស្មីដ៏រុងរឿង ញ៉ាំងនិគ្រោធារាមទាំងមូលឲ្យរុងរឿង បានចូលទៅរកព្រះលោមសកង្គិយៈមានអាយុ លុះចូលទៅដល់ហើយ បានឋិតនៅក្នុងទីសមគួរ ។

[៤១] លុះចន្ទនទេវបុត្ត ឋិតនៅក្នុងទីសមគួរហើយ បានពោលពាក្យនេះ នឹងព្រះលោមសកង្គិយៈមានអាយុថា បពិត្រភិក្ខុ លោកចាំនូវឧទ្ទេសនិងវិភង្គនៃភទ្ទេករត្តៈដែរឬទេ ។ ព្រះលោមសកង្គិយៈតបថា ម្នាលអាវុសោ យើងមិនបានចាំនូវឧទ្ទេសនិងវិភង្គនៃភទ្ទេករត្តៈទេ ម្នាលអាវុសោ ចុះអ្នកចាំនូវឧទ្ទេសនិងវិភង្គនៃភទ្ទេករត្តៈឬ ។ បពិត្រភិក្ខុ ខ្ញុំក៏មិនចាំនូវឧទ្ទេសនិងវិភង្គនៃភទ្ទេករត្តៈដែរ បពិត្រភិក្ខុ ចុះលោកចាំ

ភទ្ទេករត្តិយោ គាថាតិ ។ ន ខោ អហំ អាវុសោ ជានាមិ ភទ្ទេករត្តិយោ គាថា ត្វំ បនាវុសោ ជា-នាសិ ភទ្ទេករត្តិយោ គាថាតិ ។ ជានាមិ ខោ អហំ ភិក្ខុ ភទ្ទេករត្តិយោ គាថាតិ ។ យថាកថំ បន ត្វំ អាវុសោ ជានាសិ ភទ្ទេករត្តិយោ គាថាតិ ។

[៤២] ឯកមិទំ ភិក្ខុ សមយំ ភគវា ទេវេសុ តាវត្តឹសេសុ វិហរតិ ចារិច្ឆត្តកមូលេ បណ្ឌុកម្ពល-សិលាយំ ។ តត្រ ខោ ភគវា ទេវានំ តាវត្តឹសានំ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ច អភាសិ

អតីតំ នាន្វាគមេយ្យ
នប្បដិកង្ខេ អនាគតំ
យទតីតម្បហីនន្តំ
អប្បត្តញ្ច អនាគតំ
បច្ចុប្បន្នញ្ច យោ ធម្មំ
តត្ថ តត្ថ វិបស្សតិ

នូវភទ្ទេករត្តិគាថាទាំងឡាយឬ ។ ម្នាលអាវុសោ យើងមិនចាំ នូវភទ្ទេករត្តិគាថាទាំងឡាយទេ ម្នាលអាវុសោ ចុះអ្នកចាំនូវភទ្ទេករត្តិគាថាទាំងឡាយឬ ។ បពិត្រភិក្ខុ ខ្ញុំចាំភទ្ទេករត្តិគាថាទាំងឡាយ ។ ម្នាលអាវុសោ ចុះអ្នកចាំភទ្ទេករត្តិគាថាទាំងឡាយ ដោយប្រការដូចម្តេច ។

[៤២] បពិត្រភិក្ខុ សម័យមួយ ព្រះមានព្រះភាគ ស្តេចគង់នៅលើបណ្ឌុកម្ពលសិលា ទៀបដើមបារិច្ឆត្តកព្រឹក្ស ក្នុងឋានតាវត្តិង្ស ទេវលោក ។ គ្រានោះ ព្រះមានព្រះភាគ បានទ្រង់ភាសិតនូវឧទ្ទេស និងវិភង្គនៃភទ្ទេករត្តៈ ដល់ពួកទេវតាឋានតាវត្តិង្សថា

បុគ្គល មិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធជាអតីត មិនគប្បីប្រាថ្នាបញ្ចក្ខន្ធជាអនាគត ព្រោះថា បញ្ចក្ខន្ធណាជាអតីត បញ្ចក្ខន្ធនោះ កន្លងហួសទៅហើយ បញ្ចក្ខន្ធណាជាអនាគត បញ្ចក្ខន្ធនោះ ក៏មិនទាន់មកដល់ មួយទៀត បុគ្គលណា ឃើញច្បាស់នូវធម៌កើតឡើងចំពោះមុខក្នុងទីនោះ ។

អសំហិរំ អសង្កុប្បំ
តំ វិទ្វា មនុព្រូហយេ
អជ្ជេវ កិច្ចមាតប្បំ
កោ ជញ្ញា មរណំ សុវេ
ន ហិ នោ សង្គរន្តេន
មហាសេនេន មច្ចុនា
ឯវំវិហារិមាតាបឹ
អហោរត្តមតន្ទិតំ
តំ វេ ភទ្ទេករត្តោតិ
សន្តោ អាចិក្ខតេ មុនីតិ ។

[៤៣] ឯវំ ខោ អហំ ភិក្ខុ ជានាមិ ភទ្ទេករត្តិ-យោ គាថា ឧគ្គណ្ហាហិ ត្វំ ភិក្ខុ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ច បរិយាបុណាហិ ត្វំ ភិក្ខុ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ច ធារេហិ

បុគ្គលនោះ លុះដឹងច្បាស់នូវព្រះនិព្វាន ដែលមិនរសេមរសាម មិនកម្រើកហើយ ត្រូវចម្រើនឲ្យរឿយ ៗ នូវផលសមាបត្តិ ដែលជាអារម្មណ៍របស់ព្រះនិព្វាននោះ ឯសេចក្តីព្យាយាម បុគ្គលគួរធ្វើក្នុងថ្ងៃនេះ នរណានឹងដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែកបាន ព្រោះថា ការតទល់របស់យើងចំពោះមច្ចុដែលមានសេនាច្រើន មិនមានឡើយ មុនីជាអ្នកស្ងប់ទុក្ខ តែងហៅបុគ្គល អ្នកមានព្យាយាម មិនខ្ជិលច្រអូសទាំងថ្ងៃទាំងយប់ នៅដោយសេចក្តីមិនប្រមាទយ៉ាងនេះ ថាជាអ្នកមានរាត្រីមួយដ៏ចម្រើន ។

[៤៣] បពិត្រភិក្ខុ ខ្ញុំចាំនូវភទ្ទេករត្តិគាថាទាំងឡាយ ដោយប្រការយ៉ាងនេះឯង បពិត្រភិក្ខុ ចូរលោករៀននូវឧទ្ទេសនិងវិភង្គនៃភទ្ទេករត្តិគាថាចុះ បពិត្រភិក្ខុ ចូរលោកទន្ទេញនូវឧទ្ទេសនិងវិភង្គនៃភទ្ទេករត្តិគាថាចុះ បពិត្រភិក្ខុ ចូរលោកចាំទុកនូវឧទ្ទេសនិងវិភង្គនៃភទ្ទេ-

ត្វំ ភិក្ខុ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ច អត្ថសញ្ហិតោ ភិក្ខុ ភទ្ទេករត្តស្ស ឧទ្ទេសោ ច វិភង្គោ ច អាទិព្រហ្មចរិយកោតិ ។ ឥទមវោច ចន្ទនោ ទេវបុត្តោ ឥទំ វត្វា តត្ថេវន្តរធាយិ ។

[៤៤] អថខោ អាយស្មា លោមសកង្គិយោ តស្សា រត្តិយា អច្ចយេន សេនាសនំ សំសាមេត្វា បត្តចីវរំ អាទាយ យេន សាវត្ថី តេន ចារិកំ បក្កាមិ ។ អនុបុព្វេន ចារិកញ្ចរមានោ យេន សាវត្ថី ជេតវនំ អនាថបិណ្ឌិកស្សារាមោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា លោមសកង្គិយោ ភគវន្តំ ឯតទវោច ឯកមិទាហំ ភន្តេ សមយំ សក្កេសុ វិហរាមិ កបិលវត្ថុស្មឹ និគ្រោធារាមេ អថខោ ភន្តេ អញ្ញតរោ ទេវបុត្តោ អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណោ កេវលកប្បំ និគ្រោធារាមំ ឱភាសេត្វា យេនាហំ តេនុបសង្កមិ ឧបសង្កមិត្វា

ករត្តិគាថាចុះ បពិត្រភិក្ខុ ព្រោះថា ឧទ្ទេសនិងវិភង្គនៃភទ្ទេករត្តិគាថា ដែលប្រកបដោយប្រយោជន៍ ចាត់ទុកថា ជាអាទិព្រហ្មចរិយៈ (ព្រហ្មចរិយៈខាងដើម) ។ ចន្ទនទេវបុត្របានពោលពាក្យនេះ លុះពោលពាក្យនេះចប់ហើយ ក៏បាត់ក្នុងទីនោះទៅ ។

[៤៤] គ្រានោះឯង ព្រះលោមសកង្គិយៈមានអាយុ កាលកន្លងរាត្រីនោះហើយ រៀបចំសេនាសនៈ កាន់បាត្រនិងចីវរ ហើយចៀសទៅកាន់ចារិក ក្នុងក្រុងសាវត្ថី ។ កាលលោកត្រាច់ទៅកាន់ចារិកដោយលំដាប់ ក៏ចូលទៅគាល់ព្រះមានព្រះភាគ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិក ទៀបក្រុងសាវត្ថី លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះព្រះលោមសកង្គិយៈមានអាយុ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សម័យមួយខ្ញុំព្រះអង្គនៅក្នុងនិគ្រោធារាម ទៀបក្រុងកបិលព័ស្តុ ក្នុងដែនសក្កៈ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះឯង នាកាលរាត្រីបឋមយាមកន្លងហើយ មានទេវបុត្រមួយអង្គ មានរស្មីដ៏រុងរឿង ញុំាំងនិគ្រោធារាមទាំងមូលឲ្យភ្លឺច្បាស់ ហើយចូលទៅរកខ្ញុំព្រះអង្គ លុះចូលទៅដល់ហើយ

ឯកមន្តំ អដ្ឋាសិ ឯកមន្តំ ឋិតោ ខោ ភន្តេ សោ ទេវបុត្តោ មំ ឯតទវោច ជានាសិ ត្វំ ភិក្ខុ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ចាតិ ឯវំ វុត្តេ អហំ ភន្តេ តំ ទេវបុត្តំ ឯតទវោចំ ន ខោ អហំ អាវុសោ ជានាមិ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ច ត្វំ បនាវុសោ ជានាសិ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ចាតិ អហម្បិ ខោ ភិក្ខុ ន ជានាមិ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ច ជានាសិ បន ត្វំ ភិក្ខុ ភទ្ទេករត្តិយោ គាថាតិ ន ខោ អហំ អាវុសោ ជានាមិ ភទ្ទេករត្តិយោ គាថា ត្វំ បនាវុសោ ជានាសិ ភទ្ទេករត្តិយោ គាថាតិ ជានាមិ ខោ អហំ ភិក្ខុ ភទ្ទេករត្តិយោ គាថាតិ យថាកថំ បន ត្វំ អាវុសោ ជានាសិ ភទ្ទេករត្តិយោ គាថាតិ ឯកមិទំ ភិក្ខុ សមយំ ភគវា ទេវេសុ តាវតឹសេសុ វិហរតិ បារិច្ឆត្តកមូលេ បណ្ឌុកម្ពលសិលាយំ តត្រ ខោ ភគវា ទេវានំ តាវតឹសានំ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ច អភាសិ

ទើបឋិតនៅក្នុងទីសមគួរ បពិត្រព្រះអង្គ លុះទេវបុត្រនោះ ឋិតនៅក្នុងទីសមគួរហើយ ទើបបានពោលពាក្យនេះនឹងខ្ញុំព្រះអង្គ យ៉ាងនេះថា បពិត្រភិក្ខុ លោកចាំនូវឧទ្ទេសនិងវិភង្គនៃភទ្ទេករត្តៈឬទេ កាលទេវបុត្រនោះ សួរយ៉ាងនេះហើយ បពិត្រព្រះអង្គ ខ្ញុំព្រះអង្គបានពោលនឹងទេវបុត្រនោះយ៉ាងនេះថា ម្នាលអាវុសោ យើងមិនចាំនូវឧទ្ទេសនិងវិភង្គនៃភទ្ទេករត្តៈទេ ម្នាលអាវុសោ ចុះអ្នកចាំនូវឧទ្ទេសនិងវិភង្គនៃភទ្ទេករត្តៈឬ បពិត្រភិក្ខុ ខ្ញុំមិនចាំនូវឧទ្ទេសនិងវិភង្គនៃភទ្ទេករត្តៈទេ បពិត្រភិក្ខុ ចុះលោកចាំ នូវភទ្ទេករត្តិគាថាទាំងឡាយឬ ម្នាលអាវុសោ យើងមិនចាំនូវភទ្ទេករត្តិគាថាទាំងឡាយទេ ម្នាលអាវុសោ ចុះអ្នកចាំនូវភទ្ទេករត្តិ-គាថាទាំងឡាយឬ បពិត្រភិក្ខុ ខ្ញុំចាំនូវភទ្ទេករត្តិគាថាទាំងឡាយ ម្នាលអាវុសោ ចុះអ្នកចាំនូវភទ្ទេករត្តិគាថាទាំងឡាយ ដោយប្រការដូចម្តេច បពិត្រភិក្ខុ សម័យមួយ ព្រះមានព្រះភាគ ស្តេចគង់នៅលើបណ្ឌុ-កម្ពលសិលា ទៀបដើមបារិច្ឆត្តកព្រឹក្ស ក្នុងឋានតាវត្តិង្សទេវលោក គ្រានោះ ព្រះមានព្រះភាគ បានភាសិតនូវឧទ្ទេសនិងវិភង្គនៃភទ្ទេករត្តៈដល់ពួកទេវតាឋានតាវត្តិង្សថា

វិភង្គវគ្គស្ស លោមសកង្គិយភទ្ទេករត្តសុត្តេ ភគវតោ បដិបុច្ឆនំ

អតីតំ នានុាគមេយ្យ ។ បេ ។
តំ វេ ភទ្ទេករត្តោតិ
សន្តោ អាចិក្ខតេ មុនីតិ

ឯវំ ខោ អហំ ភិក្ខុ ជានាមិ ភទ្ទេករត្តិយោ គាថា ឧគ្គណ្ហាហិ ត្វំ ភិក្ខុ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ច បរិយាបុណាហិ ត្វំ ភិក្ខុ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ច ធារេហិ ត្វំ ភិក្ខុ ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ច អត្ថសញ្ហិតោ ភិក្ខុ ភទ្ទេករត្តស្ស ឧទ្ទេសោ ច វិភង្គោ ច អាទិព្រហ្មចរិយកោតិ ។ ឥទមវោច ភន្តេ សោ ទេវបុត្តោ ឥទំ វត្វា តត្ថេ-វន្តរធាយិ សាធុ មេ ភន្តេ ភគវា ភទ្ទេករត្តស្ស ឧទ្ទេសញ្ច វិភង្គញ្ច ទេសេតូតិ ។

[៤៨] ជានាសិ បន ត្វំ ភិក្ខុ តំ ទេវបុត្តន្តិ ។ ន ខោ អហំ ភន្តេ ជានាមិ តំ ទេវបុត្តន្តិ ។ ចន្ទនោ នាមេសោ ភិក្ខុ ទេវបុត្តោ ចន្ទនោ ភិក្ខុ ទេវបុត្តោ អដ្ឋិកត្វា មនសិកត្វា សព្វំ ចេតសោ សមន្នាហរិត្វា ឱហិតសោតោ ធម្មំ សុណាតិ តេនហិ ភិក្ខុ

បុគ្គល មិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធ ជាអតីត ។ បេ ។ មុនីដែលជាអ្នកស្ងប់រម្ងាប់ តែងហៅបុគ្គលនោះឯង ថាជាអ្នកមានរាត្រីមួយដ៏ចម្រើន ។

បពិត្រភិក្ខុ ខ្ញុំចាំនូវភទ្ទេករត្តិគាថាទាំងឡាយ ដោយប្រការយ៉ាងនេះ បពិត្រភិក្ខុ ចូរលោករៀន នូវឧទ្ទេសនិងវិភង្គ នៃភទ្ទេករត្តិគាថា បពិត្រភិក្ខុ ចូរលោកទន្ទេញនូវឧទ្ទេសនិងវិភង្គនៃភទ្ទេករត្តិគាថា បពិត្រភិក្ខុ ចូរលោកចាំទុកនូវឧទ្ទេសនិងវិភង្គ នៃភទ្ទេករត្តិគាថា បពិត្រភិក្ខុ ព្រោះថា ឧទ្ទេសនិងវិភង្គ នៃភទ្ទេករត្តិគាថា ប្រកបដោយប្រយោជន៍ ចាត់ថាជាអាទិព្រហ្មចរិយៈ ។ បពិត្រព្រះអង្គដ៏ចម្រើន ទេវបុត្រនោះ បានពោលពាក្យនេះ លុះពោលពាក្យនេះចប់ហើយ ក៏បាត់ក្នុងទីនោះទៅ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទ្រង់សំដែងនូវឧទ្ទេសនិងវិភង្គ នៃភទ្ទេករត្តិគាថា ដល់ខ្ញុំព្រះអង្គឲ្យទាន ។

[៤៥] ព្រះអង្គទ្រង់សួរថា ម្នាលភិក្ខុ ចុះលោកស្គាល់ទេវបុត្រនោះឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនបានស្គាល់ទេវបុត្រនោះទេ ។ ម្នាលភិក្ខុ ទេវបុត្រនោះឈ្មោះចន្ទនៈ ម្នាលភិក្ខុ ចន្ទនទេវ-បុត្រ បានធ្វើឲ្យជាក់ច្បាស់ យកចិត្តទុកដាក់ ប្រមូលមកនូវធម៌ទាំងអស់ដោយចិត្ត ហើយផ្ទៀងសោតប្រសាទប្រុងស្តាប់ធម៌ ម្នាលភិក្ខុ បើដូច្នោះ

សុណាហិ សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។

ឯវម្ភន្តេតិ ខោ សោ ភិក្ខុ[១] ភគវតោ បច្ចស្សោសិ ។

[៤៦] ភគវា ឯតទវោច

អតីតំ នាន្វាគមេយ្យ

នប្បដិកង្ខេ អនាគតំ

យទតីតម្បហីនន្តំ

អប្បត្តញ្ច អនាគតំ

បច្ចុប្បន្នញ្ច យោ ធម្មំ

តត្ថ តត្ថ វិបស្សតិ

អសំហិរំ អសង្កុប្បំ

១ ឱ. ម. ខោ អាយស្មា លោមសកង្គិយោតិ ទិស្សតិ ។

ចូរអ្នកយកចិត្តទុកដាក់ស្តាប់ចុះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ភិក្ខុនោះ ទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[៤៦] ព្រះមានព្រះភាគ ទ្រង់ត្រាស់ យ៉ាងនេះថា បុគ្គល មិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធជាអតីត មិនគប្បីប្រាថ្នាបញ្ចក្ខន្ធជាអនាគត ព្រោះថា បញ្ចក្ខន្ធណា ដែលជាអតីត បញ្ចក្ខន្ធនោះ កន្លងហួសទៅហើយ បញ្ចក្ខន្ធណា ដែលជាអនាគត បញ្ចក្ខន្ធនោះ ក៏នៅមិនទាន់មកដល់ មួយទៀត បុគ្គលណា ឃើញច្បាស់នូវធម៌កើតឡើងចំពោះមុខ ក្នុងទីនោះ ៗ បុគ្គលនោះ លុះដឹងច្បាស់នូវព្រះនិព្វាន ដែលមិនរសេមរសាម មិនកម្រើកហើយ

តំ វិទ្វា មនុព្រូហយេ
អជ្ជេវ កិច្ចមាតប្បំ
កោ ជញ្ញា មរណំ សុវេ
ន ហិ នោ សង្គរន្តេន
មហាសេនេន មច្ចុនា
ឯវំវិហារិមាតាបឹ
អហោរត្តមតន្ទិតំ
តំ វេ ភទ្ទេករត្តោតិ
សន្តោ អាចិក្ខតេ មុនីតិ ។

[៤៧] កថញ្ច ភិក្ខុ អតីតំ អន្វាគមេតិ ។ ឯវំរូបោ អហោសឹ អតីតមទ្ធានន្តិ តត្ថ នន្ទឹ ស-មន្វានេតិ ឯវំវេទនោ អហោសឹ ។ បេ ។ ឯវំសញ្ញោ អហោសឹ ។ បេ ។ ឯវំសង្ខារោ អហោសឹ ។ បេ ។ ឯវំវិញ្ញាណោ អហោសឹ អតីតមទ្ធានន្តិ តត្ថ នន្ទឹ សមន្វានេតិ ។ ឯវំ ខោ ភិក្ខុ អតីតំ អន្វាគមេតិ ។

ចម្រើនឲ្យរឿយ ៗ នូវផលសមាបត្តិ ដែលជាអារម្មណ៍ របស់ព្រះនិព្វាននោះ ឯសេចក្តីព្យាយាមគួរធ្វើក្នុងថ្ងៃនេះ នរណានឹងដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែកបាន ព្រោះថាការតទល់របស់យើង ចំពោះមច្ចុ ដែលមានសេនាច្រើន មិនមានឡើយ មុនីដែលជាអ្នកស្ងប់រម្ងាប់ តែងហៅបុគ្គលអ្នកមានព្យាយាម មិនខ្ជិលច្រអូសទាំងថ្ងៃទាំងយប់ នៅដោយសេចក្តីមិនប្រមាទយ៉ាងនេះ ថាជាអ្នកមានរាត្រីដ៏ចម្រើន ។

[៤៧] ម្នាលភិក្ខុ ចុះបុគ្គល អាឡោះអាល័យបញ្ចក្ខន្ធជាអតីតតើដូចម្តេច ។ បុគ្គលអាឡោះអាល័យនូវតម្រេកក្នុងទីនោះ ៗ ថា អាត្មាអញមានរូបយ៉ាងនេះ ក្នុងកាលជាអតីត អាត្មាអញមានវេទនាយ៉ាងនេះ ។ បេ ។ អាត្មាអញមានសញ្ញាយ៉ាងនេះ ។ បេ ។ អាត្មាអញមានសង្ខារយ៉ាងនេះ ។ បេ ។ បុគ្គលអាឡោះអាល័យនូវតម្រេកក្នុងទីនោះ ៗ ថា អាត្មាអញមានវិញ្ញាណយ៉ាងនេះ ក្នុងកាលជាអតីត ។ ម្នាលភិក្ខុ បុគ្គលអាឡោះអាល័យបញ្ចក្ខន្ធជាអតីត យ៉ាងនេះឯង ។

[៤៨] កាថញ្ច ភិក្ខុ អតីតំ ជាន្វាគមេតិ ។ ឯវំ-រូបោ អហោសឹ អតីតមទ្ធានន្តិ តត្ថ នន្ទឹ ន ស-មន្វានេតិ ឯវំវេទនោ អហោសឹ ។ បេ ។ ឯវំសញ្ញោ អហោសឹ ។ បេ ។ ឯវំសង្ខារោ អហោសឹ ។ បេ ។ ឯវំវិញ្ញាណោ អហោសឹ អតីតមទ្ធានន្តិ តត្ថ នន្ទឹ ន សមន្វានេតិ ។ ឯវំ ខោ ភិក្ខុ អតីតំ ជាន្វាគមេតិ ។

[៤៩] កាថញ្ច ភិក្ខុ អនាគតំ បដិកង្ខតិ ។ ឯវំរូបោ សិយំ អនាគតមទ្ធានន្តិ តត្ថ នន្ទឹ សមន្វា-នេតិ ឯវំវេទនោ សិយំ ។ បេ ។ ឯវំសញ្ញោ សិយំ ។ បេ ។ ឯវំសង្ខារោ សិយំ ។ បេ ។ ឯវំវិញ្ញាណោ សិយំ អនាគតមទ្ធានន្តិ តត្ថ នន្ទឹ សមន្វានេតិ ។ ឯវំ ខោ ភិក្ខុ អនាគតំ បដិកង្ខតិ ។

[៤៨] ម្នាលភិក្ខុ ចុះបុគ្គលមិនអាឡោះអាល័យបញ្ចក្ខន្ធជាអតីត តើដូចម្តេច ។ បុគ្គលមិនអាឡោះអាល័យនូវតម្រេកក្នុងទីនោះ ៗ ថា អាត្មាអញមានរូបយ៉ាងនេះ ក្នុងកាលជាអតីត អាត្មាអញមានវេទនាយ៉ាងនេះ ។ បេ ។ អាត្មាអញមានសញ្ញាយ៉ាងនេះ ។ បេ ។ អាត្មាអញមានសង្ខារយ៉ាងនេះ ។ បេ ។ បុគ្គល មិនអាឡោះអាល័យ នូវតម្រេកក្នុងទីនោះ ៗ ថា អាត្មាអញមានវិញ្ញាណយ៉ាងនេះ ក្នុងកាលជាអតីត ។ ម្នាលភិក្ខុ បុគ្គលអាឡោះអាល័យបញ្ចក្ខន្ធជាអតីត យ៉ាងនេះឯង ។

[៤៩] ម្នាលភិក្ខុ ចុះបុគ្គលប្រាថ្នាបញ្ចក្ខន្ធជាអនាគត តើដូចម្តេច ។ បុគ្គលអាឡោះអាល័យនូវតម្រេកក្នុងទីនោះ ៗ ថា សូមឲ្យអាត្មាអញមានរូបយ៉ាងនេះ ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញមានវេទនាយ៉ាងនេះ ។ បេ ។ សូមឲ្យអាត្មាអញមានសញ្ញាយ៉ាងនេះ ។ បេ ។ សូមឲ្យអាត្មាអញមានសង្ខារយ៉ាងនេះ ។ បេ ។ បុគ្គលអាឡោះអាល័យនូវតម្រេកក្នុងទីនោះ ៗ ថា សូមឲ្យអាត្មាអញមានវិញ្ញាណយ៉ាងនេះ ក្នុងកាលជាអនាគត ។ ម្នាលភិក្ខុ បុគ្គលប្រាថ្នាបញ្ចក្ខន្ធជាអនាគត យ៉ាងនេះឯង ។

[៤០] កថញ្ច ភិក្ខុ អនាគតំ នប្បដិកង្ខតិ ។ ឯវំរូបោ សិយំ អនាគតមទ្ធានន្តិ តត្ថ នន្ទឹ ន សមន្វានេតិ ឯវំវេទនោ សិយំ ។ បេ ។ ឯវំសញ្ញោ សិយំ ។ បេ ។ ឯវំសង្ខារោ សិយំ ។ បេ ។ ឯវំវិញ្ញាណោ សិយំ អនាគតមទ្ធានន្តិ តត្ថ នន្ទឹ ន សមន្វានេតិ ។ ឯវំ ខោ ភិក្ខុ អនាគតំ នប្បដិកង្ខតិ ។

[៤១] កថញ្ច ភិក្ខុ បច្ចុប្បន្នេសុ ធម្មេសុ សំហិរតិ ។ ឥធ ភិក្ខុ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្មស្ស អកោវិទោ អរិយធម្មេ អវិនីតោ សប្បុរិសានំ អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិសធម្មេ អវិនីតោ រូបំ អត្តតោ សមនុបស្សតិ រូបវន្តំ វា អត្តានំ អត្តនិ វា រូបំ រូបស្មឹ វា អត្តានំ វេទនំ ។ បេ ។ សញ្ញំ ។ បេ ។

[៥០] ម្នាលភិក្ខុ ចុះបុគ្គលមិនប្រាថ្នាបញ្ចក្ខន្ធជាអនាគត តើដូចម្តេច ។ បុគ្គលមិនអាឡោះអាល័យនូវតម្រេកក្នុងទីនោះ ៗ ថា ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញមានរូបយ៉ាងនេះ សូមឲ្យអាត្មាអញមានវេទនាយ៉ាងនេះ ។ បេ ។ សូមឲ្យអាត្មាអញមានសញ្ញាយ៉ាងនេះ ។ បេ ។ សូមឲ្យអាត្មាអញមានសង្ខារយ៉ាងនេះ ។ បេ ។ បុគ្គលមិនអាឡោះអាល័យនូវតម្រេកក្នុងទីនោះ ៗ ថា ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញមានវិញ្ញាណយ៉ាងនេះ ។ ម្នាលភិក្ខុ បុគ្គលមិនប្រាថ្នាបញ្ចក្ខន្ធជាអនាគតយ៉ាងនេះឯង ។

[៥១] ម្នាលភិក្ខុ ចុះបុគ្គលរសេមរសាម ក្នុងពួកធម៌ជាបច្ចុប្បន្ន តើដូចម្តេច ។ ម្នាលភិក្ខុ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនបានស្តាប់ មិនបានឃើញពួកព្រះអរិយៈ មិនឈ្លាសក្នុងធម៌របស់ព្រះអរិយៈ មិនបានទទួលណែនាំក្នុងធម៌របស់ព្រះអរិយៈ មិនបានឃើញពួកសប្បុរស មិនឈ្លាសក្នុងធម៌របស់សប្បុរស មិនបានទទួលណែនាំក្នុងធម៌របស់សប្បុរស រមែងពិចារណាឃើញរូបថាជាខ្លួន ឃើញខ្លួនថាមានរូប ឃើញរូបថាមានក្នុងខ្លួន ឬ ឃើញខ្លួនថាមានក្នុងរូប នូវវេទនា ។ បេ ។ នូវសញ្ញា ។ បេ ។

សង្ខារេ ។ បេ ។ វិញ្ញាណំ អត្តតោ សមនុបស្សតិ វិញ្ញាណវន្តំ វា អត្តានំ អត្តនិ វា វិញ្ញាណំ វិញ្ញាណស្មឹ វា អត្តានំ ។ ឯវំ ខោ ភិក្ខុ បច្ចុប្បន្នេសុ ធម្មេសុ សំហិរតិ ។

[៤២] កថញ្ច ភិក្ខុ បច្ចុប្បន្នេសុ ធម្មេសុ ន សំហិរតិ ។ ឥធ ភិក្ខុ សុតវា អរិយសាវកោ អរិយានំ ទស្សាវី អរិយធម្មស្ស កោវិទោ អរិយធម្មេ សុវិនីតោ សប្បុរិសានំ ទស្សាវី សប្បុរិសធម្មស្ស កោវិទោ សប្បុរិសធម្មេ សុវិនីតោ ន រូបំ អត្តតោ សមនុបស្សតិ ន រូបវន្តំ វា អត្តានំ ន អត្តនិ វា រូបំ ន រូបស្មឹ វា អត្តានំ ន វេទនំ ។ បេ ។ ន សញ្ញំ ។ បេ ។ ន សង្ខារេ ។ បេ ។ ន វិញ្ញាណំ អត្តតោ សមនុបស្សតិ ន វិញ្ញាណវន្តំ វា អត្តានំ ន អត្តនិ វា វិញ្ញាណំ ន វិញ្ញាណស្មឹ វា អត្តានំ ។ ឯវំ ខោ ភិក្ខុ បច្ចុប្បន្នេសុ ធម្មេសុ ន សំហិរតិ ។

នូវសង្ខារទាំងឡាយ ។ បេ ។ ពិចារណាឃើញនូវវិញ្ញាណថាជាខ្លួន ឃើញខ្លួនថាមានវិញ្ញាណ ឃើញវិញ្ញាណថាមានក្នុងខ្លួន ឬឃើញខ្លួនថាមានក្នុងវិញ្ញាណ ។ ម្នាលភិក្ខុ បុគ្គល រសេមរសាមក្នុងពួកធម៌ជាបច្ចុប្បន្ន យ៉ាងនេះឯង ។

[៥២] ម្នាលភិក្ខុ ចុះបុគ្គលមិនរសេមរសាម ក្នុងពួកធម៌ជាបច្ចុប្បន្ន តើដូចម្តេច ។ ម្នាលភិក្ខុ អរិយសាវ័កក្នុងសាសនានេះ ជាអ្នកបានស្តាប់ បានឃើញពួកព្រះអរិយៈ ជាអ្នកឈ្លាសក្នុងធម៌របស់ព្រះអរិយៈ ជាអ្នកទទួលណែនាំដោយប្រពៃក្នុងធម៌របស់ព្រះអរិយៈ ជាអ្នកឃើញពួកសប្បុរស ជាអ្នកឈ្លាសក្នុងធម៌របស់សប្បុរស ជាអ្នកទទួលណែនាំដោយប្រពៃក្នុងធម៌របស់សប្បុរស មិនពិចារណាឃើញនូវរូបថាជាខ្លួន មិនឃើញខ្លួនថាមានរូប មិនឃើញរូបថាមានក្នុងខ្លួន ឬមិនឃើញខ្លួនថាមានក្នុងរូប មិនឃើញវេទនា ។ បេ ។ មិនឃើញសញ្ញា ។ បេ ។ មិនឃើញសង្ខារទាំងឡាយ ។ បេ ។ មិនពិចារណាឃើញវិញ្ញាណថាជាខ្លួន មិនឃើញខ្លួនថាមានវិញ្ញាណ មិនឃើញវិញ្ញាណថាមានក្នុងខ្លួន ឬមិនឃើញខ្លួនថាមានក្នុងវិញ្ញាណ ។ ម្នាលភិក្ខុ បុគ្គលមិនរសេមរសាមក្នុងពួកធម៌ជាបច្ចុប្បន្ន យ៉ាងនេះឯង ។

៤៣

វិភង្គវគ្គស្ស លោមសកង្គិយភទ្ទេករត្តសុត្តេ ភាសិតាភិនន្ទនំ

[៤៣] អតីតំ នានុគមេយ្យ ។ បេ ។

តំ វេ ភទ្ទេករត្តោតិ

សន្តោ អាចិក្ខតេ មុនីតិ ។

ឥទមវោច ភគវា អត្តមនោ អាយស្មា លោម-សកង្គិយោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

លោមសកង្គិយភទ្ទេករត្តសុត្តំ ចតុត្ថំ និដ្ឋិតំ ។

វិភង្គវគ្គ លោមសកង្គិយភទ្ទេករត្តសូត្រ សេចក្តីត្រេកអរចំពោះភាសិត

[៥៣] បុគ្គល មិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធជាអតីត ។ បេ ។ មុនីជាអ្នកស្ងប់រម្ងាប់ តែងហៅបុគ្គលនោះឯង ថាជាអ្នកមានរាត្រីមួយដ៏ចម្រើន ។

លុះព្រះមានព្រះភាគ បានត្រាស់ព្រះសូត្រនេះចប់ហើយ ព្រះលោមសកង្គិយៈមានអាយុ ក៏មានចិត្តត្រេកអរ រីករាយ នឹងភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ លោមសកង្គិយភទ្ទេករត្តសូត្រ ទី ៤ ។

# បញ្ចមំ ចូឡកម្មវិភង្គសុត្តំ

[៥៤] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ សុភោ មាណវោ តោទេយ្យបុត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។

[៥៥] ឯកមន្តំ និសិន្នោ ខោ សុភោ មាណវោ តោទេយ្យបុត្តោ ភគវន្តំ ឯតទវោច កោ នុ ខោ ភោ គោតម ហេតុ កោ បច្ចយោ យេន មនុស្សានំយេវ សតំ មនុស្សភូតានំ ទិស្សតិ ហីនប្បណីតតា ទិស្សន្តិ ភោ[១] គោតម មនុស្សា អប្បាយុកា ទិស្សន្តិ ទីឃាយុកា ទិស្សន្តិ ពហ្វាពាធា ទិស្សន្តិ អប្បាពាធា ទិស្សន្តិ ទុព្វណ្ណា ទិស្សន្តិ វណ្ណវន្តោ ទិស្សន្តិ អប្បេសក្ខា ទិស្សន្តិ មហេសក្ខា ទិស្សន្តិ អប្បភោគា ទិស្សន្តិ

---

១ ឱ. ម. ហិ ភោ ។

# ចូឡកម្មវិភង្គសូត្រ ទី ៥

[៩៤] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង សុភមាណព ជាបុត្ររបស់តោទេយ្យព្រាហ្មណ៍ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យសំណេះសំណាល នឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យសំណេះសំណាលនិងពាក្យគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។

[៩៥] លុះសុភមាណព តោទេយ្យបុត្រ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន អ្វីហ្ន៎ជាហេតុ អ្វីហ្ន៎ជាបច្ច័យ ដែលនាំឲ្យពួកមនុស្សកាលកើតមកជាមនុស្ស មានសេចក្តីថោកទាបនិងខ្ពង់ខ្ពស់ ប្រាកដឡើង បពិត្រព្រះគោតមដ៏ចម្រើន ព្រោះថា មនុស្សទាំងឡាយ មានអាយុខ្លី មានអាយុវែង មានអាពាធច្រើន មានអាពាធតិច មានសម្បុរអាក្រក់ មានសម្បុរល្អ មានសក្តិតូច មានសក្តិធំ មានភោគសម្បត្តិតិច

មហាភោគា ទិស្សន្តិ នីចាកុលីនា[១] ទិស្សន្តិ ឧច្ចា-
កុលីនា[២] ទិស្សន្តិ អប្បបញ្ញា[៣] ទិស្សន្តិ បញ្ញវន្តោ
កោ នុ ខោ ភោ គោតម ហេតុ កោ បច្ចយោ
យេន មនុស្សានំយេវ សតំ មនុស្សភូតានំ ទិស្ស-
តិ ហីនប្បណីតតាតិ ។

[៥៦] កម្មស្សកា មាណវ សត្តា កម្មទាយា-
ទា កម្មយោនី កម្មពន្ធូ កម្មប្បដិសរណា កម្មំ
សត្តេ វិភជតិ យទិទំ ហីនប្បណីតតាយាតិ ។ ន
ខោ អហំ ឥមស្ស ភោតោ គោតមស្ស សង្ខិត្តេន
ភាសិតស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន
អត្ថំ អាជានាមិ សាធុ មេ ភវំ គោតមោ តថា ធម្មំ
ទេសេតុ យថាហំ ឥមស្ស ភោតោ គោតមស្ស
សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អវិភត្តស្ស
វិត្ថារេន អត្ថំ អាជានេយ្យន្តិ ។ តេនហិ មាណវ

---

១ ម. នីចកុលិនោ ។ ២ ម. ឧច្ចាកុលិនោ ។ ៣ ឱ. ម. ទុប្បញ្ញា ។

មានភោគសម្បត្តិច្រើន មានត្រកូលទាប មានត្រកូលខ្ពស់ មានប្រាជ្ញាតិច មានប្រាជ្ញាច្រើន បពិត្រព្រះគោតមដ៏ចម្រើន អ្វីហ្ន៎ជាហេតុ អ្វីហ្ន៎ជាបច្ច័យ ដែលនាំឲ្យពួកមនុស្ស កាលកើតមកជាមនុស្ស មានសេចក្ដីថោកទាបនិងខ្ពង់ខ្ពស់ ប្រាកដឡើង ។

[៥៦] ម្នាលមាណព សត្វទាំងឡាយ មានកម្មជារបស់ខ្លួន មានកម្មជាទាយាទ មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាគ្រឿងរលឹក កម្មតែងចែកសត្វទាំងឡាយ ដើម្បីឲ្យថោកទាបនិងខ្ពង់ខ្ពស់ ។ ខ្ញុំព្រះអង្គមិនយល់សេចក្ដីពិស្ដារ របស់ភាសិតសង្ខេបនេះ ដែលព្រះគោតមដ៏ចម្រើន មិនទាន់ចែកសេចក្ដីដោយពិស្ដារបានឡើយ សូមព្រះគោតមជាម្ចាស់ទ្រង់សំដែងធម៌ តាមទំនងដែលខ្ញុំព្រះអង្គ នឹងយល់សេចក្ដីពិស្ដាររបស់ភាសិតសង្ខេបនេះ ដែលព្រះគោតមដ៏ចម្រើន មិនទាន់ចែកសេចក្ដីដោយពិស្ដារឲ្យទាន ។ ម្នាលមាណព បើដូច្នោះ

សុណាហិ សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវំ ភោតិ ខោ សុភោ មាណវោ តោទេយ្យបុត្តោ ភគវតោ បច្ចស្សោសិ ។

[៩៧] ភគវា ឯតទវោច ឥធ មាណវ ឯកច្ចោ ឥត្ថី វា បុរិសោ វា បាណាតិបាតី ហោតិ លុទ្ទោ លោហិតបាណី ហតប្បហតេ និវិដ្ឋោ អទយាបន្នោ បាណភូតេសុ ។ សោ តេន កម្មេន ឯវំ ស-មត្តេន ឯវំ សមាទិន្នេន កាយស្ស ភេទា បរម្មរ-ណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ នោ ចេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ សចេ មនុស្សត្តំ អាគច្ឆតិ យត្ថ យត្ថ បច្ចា ជាយតិ អប្បាយុកោ ហោតិ ។ អប្បាយុកសំវត្តនិកា ឯសា មាណវ បដិបទា យទិទំ បាណាតិបាតី ហោតិ លុទ្ទោ លោហិតបាណី ហតប្បហតេ និវិដ្ឋោ អទយាបន្នោ បាណភូតេសុ ។

ចូរអ្នកយកចិត្តទុកដាក់ស្តាប់ឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ សុភមាណព តោទេយ្យបុត្រ ទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[៥៧] ព្រះមានព្រះភាគ បានត្រាស់យ៉ាងនេះថា ម្នាលមាណព ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ប្រព្រឹត្តអាក្រក់ មានដៃប្រឡាក់ឈាម តាំងនៅក្នុងការបៀតបៀន និងការសម្លាប់ មិនដល់នូវសេចក្តីអាណិតក្នុងពួកសត្វ ។ ព្រោះអំពើនោះដែលខ្លួនបានបំពេញយ៉ាងនេះ បានសមាទានយ៉ាងនេះ បុគ្គលនោះលុះរំលាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ប្រសិនបើរំលាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ មិនទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរកទេ បើបានត្រឡប់មកកាន់ភាពជាមនុស្ស ក្នុងទីណា ៗ រមែងជាអ្នកមានអាយុខ្លី ។ ម្នាលមាណព បុគ្គលសម្លាប់សត្វ ជាអ្នកប្រព្រឹត្តអាក្រក់ មានដៃប្រឡាក់ឈាម តាំងនៅក្នុងការបៀតបៀន និងការសម្លាប់ មិនដល់នូវសេចក្តីអាណិតក្នុងពួកសត្វ នេះឈ្មោះថាបដិបទាប្រព្រឹត្តទៅដើម្បីឲ្យមានអាយុខ្លី ។

[៤៨] ឥធ បន មាណវ ឯកច្ចោ ឥត្ថី វា បុរិសោ វា បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតោ ហោតិ និហិតទណ្ឌោ និហិតសត្ថោ លជ្ជី ទយាបន្នោ សព្វបាណភូតហិតានុកម្បី វិហរតិ ។ សោ តេន កម្មេន ឯវំ សមត្តេន ឯវំ សមាទិន្នេន កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ នោ ចេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ សចេ មនុស្សត្តំ អាគច្ឆតិ យត្ថ យត្ថ បច្ចាជាយតិ ទីឃាយុកោ ហោតិ ។ ទីឃាយុកសំវត្តនិកា ឯសា មាណវ បដិ-បទា យទិទំ បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតោ ហោតិ និហិតទណ្ឌោ និហិតសត្ថោ លជ្ជី ទយាបន្នោ សព្វបាណភូតហិតានុកម្បី វិហរតិ ។

វិភង្គវគ្គ ចូឡកម្មវិភង្គសូត្រ ការវៀរចាកបាណាតិបាត

[៥៨] ម្នាលមាណព មួយទៀត ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ លះបង់បាណាតិបាត វៀរស្រឡះចាកបាណាតិបាត មានដំបងដាក់ចុះហើយ មានសស្ត្រាដាក់ចុះហើយ ជាអ្នកមានសេចក្តីអៀនខ្មាស មានសេចក្តីអាណិតអាសូរ អនុគ្រោះដោយប្រយោជន៍ ក្នុងពួកសត្វទាំងអស់ ។ ព្រោះអំពើនោះដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះ លុះរំលាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ប្រសិនបើបុគ្គលនោះរំលាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ មិនទៅកើតក្នុងសុគតិសួគ៌ទេវលោកទេ បើបានត្រឡប់មកកាន់ភាពជាមនុស្ស កើតក្នុងទីណា ៗ រមែងមានអាយុវែង ។ ម្នាលមាណព បុគ្គលដែលលះបង់បាណាតិបាត វៀរចាកបាណាតិបាត មានដំបងដាក់ចុះហើយ មានសស្ត្រាដាក់ចុះហើយ មានសេចក្តីអៀនខ្មាស មានសេចក្តីអាណិតអាសូរ ជាអ្នកមានសេចក្តីអនុគ្រោះដោយប្រយោជន៍ក្នុងពួកសត្វទាំងអស់ នេះ ឈ្មោះថាបដិបទាប្រព្រឹត្តទៅដើម្បីឲ្យមានអាយុវែង ។

[៥៩] ឥធ មាណវ ឯកច្ចោ ឥត្ថី វា បុរិសោ វា សត្តានំ វិហេឋកជាតិកោ ហោតិ បាណិនា វា លេឌ្ឌុនា វា ទណ្ឌេន វា សត្ថេន វា ។ សោ តេន កម្មេន ឯវំ សមត្តេន ឯវំ សមាទិន្នេន កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧ-បបជ្ជតិ នោ ចេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ សចេ មនុស្សត្តំ អាគច្ឆតិ យត្ថ យត្ថ បច្ចា ជាយតិ ពហ្វាពាធោ ហោតិ ។ ពហ្វាពាធសំវត្តនិកា ឯសា មាណវ ប-ដិបទា យទិទំ សត្តានំ វិហេឋកជាតិកោ ហោតិ បាណិនា វា លេឌ្ឌុនា វា ទណ្ឌេន វា សត្ថេន វា ។

[៦០] ឥធ បន មាណវ ឯកច្ចោ ឥត្ថី វា បុរិសោ វា សត្តានំ អវិហេឋកជាតិកោ ហោតិ បាណិនា វា លេឌ្ឌុនា វា ទណ្ឌេន វា សត្ថេន វា ។ សោ តេន កម្មេន ឯវំ សមត្តេន ឯវំ សមាទិន្នេន

[៥៩] ម្នាលមាណព ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកបៀតបៀនសត្វទាំងឡាយ ដោយបាតដៃខ្លះ ដោយដុំដីខ្លះ ដោយដំបងខ្លះ ដោយសស្ត្រាខ្លះ ។ ព្រោះអំពើនោះដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត-វិស័យ អសុរកាយ នរក ប្រសិនបើបុគ្គលនោះ ទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ មិនទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរកទេ បើបានត្រឡប់មកកាន់ភាពជាមនុស្ស កើតក្នុងទីណា ៗ រមែងជាអ្នកមានអាពាធច្រើន ។ ម្នាលមាណព បុគ្គលដែលជាអ្នកបៀតបៀនសត្វទាំងឡាយ ដោយបាតដៃខ្លះ ដោយដុំដីខ្លះ ដោយដំបងខ្លះ ដោយសស្ត្រាខ្លះ នេះ ឈ្មោះថាបដិបទាប្រព្រឹត្តទៅដើម្បីមានអាពាធច្រើន ។

[៦០] ម្នាលមាណព មួយទៀត ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនបៀតបៀនសត្វទាំងឡាយ ដោយបាតដៃខ្លះ ដោយដុំដីខ្លះ ដោយដំបងខ្លះ ដោយសស្ត្រាខ្លះ ។ ព្រោះអំពើនោះដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះ

[៥៩] ម្នាលមាណព ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកបៀតបៀនសត្វទាំងឡាយ ដោយបាតដៃខ្លះ ដោយដុំដីខ្លះ ដោយដំបងខ្លះ ដោយសស្ត្រាខ្លះ ។ ព្រោះអំពើនោះដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត-វិស័យ អសុរកាយ នរក ប្រសិនបើបុគ្គលនោះ ទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ មិនទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរកទេ បើបានត្រឡប់មកកាន់ភាពជាមនុស្ស កើតក្នុងទីណា ៗ រមែងជាអ្នកមានអាពាធច្រើន ។ ម្នាលមាណព បុគ្គលដែលជាអ្នកបៀតបៀនសត្វទាំងឡាយ ដោយបាតដៃខ្លះ ដោយដុំដីខ្លះ ដោយដំបងខ្លះ ដោយសស្ត្រាខ្លះ នេះ ឈ្មោះថាបដិបទាប្រព្រឹត្តទៅដើម្បីមានអាពាធច្រើន ។

[៦០] ម្នាលមាណព មួយទៀត ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនបៀតបៀនសត្វទាំងឡាយ ដោយបាតដៃខ្លះ ដោយដុំដីខ្លះ ដោយដំបងខ្លះ ដោយសស្ត្រាខ្លះ ។ ព្រោះអំពើនោះដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះ

លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ប្រសិនបើបុគ្គលនោះ ទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ មិនបានទៅកើតក្នុងសុគតិសួគ៌ទេវលោកទេ បើបានត្រឡប់មកកាន់ភាពជាមនុស្ស កើតក្នុងទីណា ៗ រមែងជាអ្នកមានអាពាធតិច ។ ម្នាលមាណព បុគ្គលដែលជាអ្នកមិនបៀតបៀនសត្វទាំងឡាយដោយបាតដៃខ្លះ ដោយដុំដីខ្លះ ដោយដំបងខ្លះ ដោយសស្ត្រាខ្លះ នេះឈ្មោះថាបដិបទាប្រព្រឹត្តទៅដើម្បីមានអាពាធតិច ។

[៦១] ម្នាលមាណព ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកមានសេចក្តីក្រោធ ច្រើនដោយសេចក្តីចង្អៀតចង្អល់ចិត្ត គ្រាន់តែគេស្តីថាបន្តិចបន្តួច ក៏ថ្នាំងថ្នាក់ ខឹង ព្យាបាទ តបត សំដែងសេចក្តីក្រោធ សេចក្តីប្រទូស្តនិងសេចក្តីមិនត្រេកអរឲ្យប្រាកដឡើង ។ ព្រោះអំពើនោះដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះ លុះទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក បើបុគ្គលនោះ ទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ មិនទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរកទេ បើបានត្រឡប់មកកាន់ភាពជាមនុស្ស កើតក្នុងទី

ទុព្វណ្ណោ ហោតិ ។ ទុព្វណ្ណសំវត្តនិកា ឯសា មាណវ បដិបទា យទិទំ កោធនោ ហោតិ ឧបា-យាសពហុលោ អប្បម្បិ វុត្តោ សមានោ អភិសជ្ជតិ កុប្បតិ ព្យាបជ្ជតិ បតិត្ថីយតិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ ។

[៦២] ឥធ បន មាណវ ឯកច្ចោ ឥត្ថី វា បុរិសោ វា អកោធនោ ហោតិ អនុបាយាសពហុ-លោ ពហុម្បិ វុត្តោ សមានោ នាភិសជ្ជតិ ន កុប្បតិ ន ព្យាបជ្ជតិ ន បតិត្ថីយតិ ន កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ ។ សោ តេន កម្មេន ឯវំ សមត្តេន ឯវំ សមាទិន្នេន កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ នោ ចេ កាយស្ស ភេទា បរម្ម-រណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ សចេ មនុស្សត្តំ អាគច្ឆតិ យត្ថ យត្ថ បច្ចា ជាយតិ

ណា ៗ រមែងជាអ្នកមានសម្បុរអាក្រក់ ។ ម្នាលមាណព បុគ្គលដែលមានសេចក្តីក្រោធ ច្រើនដោយសេចក្តីចង្អៀតចង្អល់ចិត្ត គ្រាន់តែគេស្តីថាបន្តិចបន្តួច ក៏ថ្នាំងថ្នាក់ ក្រោធ ព្យាបាទ តបត សំដែងសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីមិនត្រេកអរឲ្យប្រាកដឡើង នេះឈ្មោះថាបដិបទាប្រព្រឹត្តទៅដើម្បីមានសម្បុរអាក្រក់ ។

[៦២] ម្នាលមាណព មួយទៀត ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនក្រោធ មិនច្រើនដោយសេចក្តីចង្អៀតចង្អល់ចិត្ត ទុកជាគេស្តីថាច្រើន ក៏មិនថ្នាំងថ្នាក់ មិនក្រោធ មិនព្យាបាទ មិនតបត មិនសំដែងសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីមិនត្រេកអរឲ្យប្រាកដឡើង ។ ព្រោះអំពើនោះដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ប្រសិនបើបុគ្គលនោះ ទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ មិនបានទៅកើតក្នុងសុគតិសួគ៌ទេវលោកទេ បើបានត្រឡប់មកកាន់ភាពជាមនុស្ស កើតក្នុងទីណា ៗ

បាសាទិកោ ហោតិ ។ បាសាទិកសំវត្តនិកា ឯសា មាណវ បដិបទា យទិទំ អកោធនោ ហោតិ អនុបាយាសពហុលោ ពហុម្បិ វុត្តោ សមានោ នាភិសជ្ជតិ ន កុប្បតិ ន ព្យាបជ្ជតិ ន បតិត្ថីយតិ ន កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ ។

[៦៣] ឥធ មាណវ ឯកច្ចោ ឥត្ថី វា បុរិសោ វា ឥស្សាមនកោ ហោតិ បរលាភសក្ការគរុការមាននវន្ទនបូជនាសុ ឥស្សតិ ឧបទុស្សតិ ឥស្សំ ពន្ធតិ ។ សោ តេន កម្មេន ឯវំ សមត្តេន ឯវំ សមាទិន្នេន កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ នោ ចេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ សចេ មនុស្សត្តំ អាគច្ឆតិ យត្ថ យត្ថ បច្ចា ជាយតិ

រមែងជាអ្នកប្រកបដោយសម្បុរជ្រះថ្លា ។ ម្នាលមាណព បុគ្គលដែលមិនមានសេចក្ដីក្រោធ មិនច្រើនដោយសេចក្ដីចង្អៀតចង្អល់ចិត្ត ទុកជាគេស្ដីថាច្រើន ក៏មិនថ្នាំងថ្នាក់ មិនក្រោធ មិនព្យាបាទ មិនតបត មិនសំដែងសេចក្ដីក្រោធ សេចក្ដីប្រទូស្ដ និងសេចក្ដីមិនត្រេកអរឲ្យប្រាកដឡើង នេះ ឈ្មោះថាបដិបទាប្រព្រឹត្តទៅដើម្បីជាអ្នកមានសម្បុរជ្រះថ្លា ។

[៦៣] ម្នាលមាណព ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកប្រណែន តែងប្រណែន ប្រទូស្ដ ចងទុកនូវសេចក្ដីប្រណែនក្នុងលាភៈ សក្ការៈ សេចក្ដីគោរព ការរាប់អាន ការថ្វាយបង្គំ និងការបូជា របស់បុគ្គលដទៃ ។ ព្រោះអំពើនោះដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្ដីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត-វិស័យ អសុរកាយ នរក បើបុគ្គលនោះ ទម្លាយរាងកាយបន្ទាប់អំពីសេចក្ដីស្លាប់ទៅ មិនទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរ-កាយ នរកទេ បើបានត្រឡប់មកកាន់ភាពជាមនុស្ស កើតក្នុងទីណា ៗ

អប្បេសក្ខោ ហោតិ ។ អប្បេសក្ខសំវត្តនិកា ឯសា មាណវ បដិបទា យទិទំ ឥស្សាមនកោ ហោតិ បរលាភសក្ការគរុការមាននវន្ទនបូជនាសុ ឥស្សតិ ឧបទុស្សតិ ឥស្សំ ពន្ធតិ ។

[៦៤] ឥធ បន មាណវ ឯកច្ចោ ឥត្ថី វា បុរិសោ វា អនិស្សាមនកោ ហោតិ បរលាភសក្ការគរុការមាននវន្ទនបូជនាសុ ន ឥស្សតិ ន ឧបទុស្សតិ ន ឥស្សំ ពន្ធតិ ។ សោ តេន កម្មេន ឯវំ សមត្តេន ឯវំ សមាទិន្នេន កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ នោ ចេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ សចេ មនុស្សត្តំ អាគច្ឆតិ យត្ថ យត្ថ បច្ចាជាយតិ មហេសក្ខោ ហោតិ ។ មហេសក្ខសំវត្តនិកា ឯសា មាណវ បដិបទា យទិទំ អនិស្សាមនកោ ហោតិ បរលាភសក្ការគរុការមាននវន្ទនបូជនាសុ ន ឥស្សតិ ន ឧបទុស្សតិ ន ឥស្សំ ពន្ធតិ ។

រមែងជាអ្នកមានស័ក្តិតូច ។ ម្នាលមាណព បុគ្គលជាអ្នកច្រណែន តែងច្រណែន ប្រទូស្ត ចងទុកនូវសេចក្តីច្រណែន ក្នុងលាភៈ សក្ការៈ សេចក្តីគោរព ការរាប់អាន ការថ្វាយបង្គំ និងការបូជា របស់បុគ្គលដទៃ នេះ ឈ្មោះថាបដិបទាប្រព្រឹត្តទៅដើម្បីមានស័ក្តិតូច ។

[៦៤] ម្នាលមាណព មួយទៀត ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនច្រណែន រមែងមិនច្រណែន មិនប្រទូស្ត មិនចងទុកនូវសេចក្តីច្រណែន ក្នុងលាភៈ សក្ការៈ សេចក្តីគោរព ការរាប់អាន ការថ្វាយបង្គំ និងការបូជា របស់បុគ្គលដទៃ ។ ព្រោះអំពើនោះ ដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក បើបុគ្គលនោះ ទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ មិនបានទៅកើតក្នុងសុគតិសួគ៌ទេវលោកទេ បើបានត្រឡប់មកកាន់ភាពជាមនុស្ស កើតក្នុងទីណា ៗ រមែងជាអ្នកមានស័ក្តិធំ ។ ម្នាលមាណព បុគ្គលដែលមិនច្រណែន តែងមិនច្រណែន មិនប្រទូស្ត មិនចងទុកនូវសេចក្តីច្រណែន ក្នុងលាភៈ សក្ការៈ សេចក្តីគោរព ការរាប់អាន ការថ្វាយបង្គំ និងការបូជា របស់បុគ្គលដទៃ នេះ ឈ្មោះថាបដិបទា ប្រព្រឹត្តទៅដើម្បីមានស័ក្តិធំ ។

វិភង្គវគ្គស្ស ចូឡកម្មវិភង្គសុត្តេ អន្នាទិអទានំ

[៦៤] ឥធ មាណវ ឯកច្ចោ ឥត្ថី វា បុរិសោ វា ន ទាតា ហោតិ សមណស្ស វា ព្រាហ្មណស្ស វា អន្នំ បានំ វត្ថំ យានំ មាលាគន្ធវិលេបនំ សេយ្យាវសថំ បទីបេយ្យំ ។ សោ តេន កម្មេន ឯវំ សមត្តេន ឯវំ សមាទិន្នេន កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ នោ ចេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ សចេ មនុស្សត្តំ អាគច្ឆតិ យត្ថ យត្ថ បច្ចាជាយតិ អប្បភោគោ ហោតិ ។ អប្បភោគសំវត្តនិកា ឯសា មាណវ បដិបទា យទិទំ ន ទាតា ហោតិ សមណស្ស វា ព្រាហ្មណស្ស វា អន្នំ បានំ វត្ថំ យានំ មាលាគន្ធវិលេបនំ សេយ្យាវសថំ បទីបេយ្យំ ។

វិភង្គវគ្គ ចូឡកម្មវិភង្គសូត្រ ការមិនឲ្យវត្ថុមានបាយជាដើម

[៦៥] ម្នាលមាណព ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនបានឲ្យបាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សេង ៗ ទីដេក ទីអាស្រ័យ ប្រទីប ដល់សមណៈឬព្រាហ្មណ៍ ។ ព្រោះអំពើនោះ ដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ប្រសិនបើបុគ្គលនោះ ទម្លាយរាងកាយស្លាប់ទៅ មិនទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរកទេ បើបានត្រឡប់មកកាន់ភាពជាមនុស្ស កើតក្នុងទីណា ៗ រមែងជាអ្នកមានភោគសម្បត្តិតិច ។ ម្នាលមាណព បុគ្គលដែលមិនបានឲ្យបាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សេង ៗ ទីដេក ទីអាស្រ័យ ប្រទីប ដល់សមណៈឬព្រាហ្មណ៍ នេះឯង ឈ្មោះថាបដិបទា ប្រព្រឹត្តទៅដើម្បីមានភោគ-សម្បត្តិតិច ។

[៦៦] ឥធ បន មាណវ ឯកច្ចោ ឥត្ថី វា បុរិសោ វា ទាតា ហោតិ សមណស្ស វា ព្រាហ្មណស្ស វា អន្នំ បានំ វត្ថំ យានំ មាលាគន្ធវិលេបនំ សេយ្យាវសថំ បទីបេយ្យំ ។ សោ តេន កម្មេន ឯវំ សមត្តេន ឯវំ សមាទិន្នេន កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ នោ ចេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ សចេ មនុស្សត្តំ អាគច្ឆតិ យត្ថ យត្ថ បច្ចា ជាយតិ មហាភោគោ ហោតិ ។ មហាភោគសំវត្តនិកា ឯសា មាណវ បដិបទា យទិទំ ទាតា ហោតិ សមណស្ស វា ព្រាហ្មណស្ស វា អន្នំ បានំ វត្ថំ យានំ មាលាគន្ធវិលេបនំ សេយ្យាវសថំ បទីបេយ្យំ ។

[៦៧] ឥធ មាណវ ឯកច្ចោ ឥត្ថី វា បុរិសោ វា ថទ្ធោ ហោតិ អតិមានី អភិវាទេតព្វំ ន អភិវាទេតិ បច្ចុដ្ឋាតព្វំ ន បច្ចុដ្ឋេតិ អាសនារហស្ស អាសនំ ន ទេតិ

[៦៦] ម្នាលមាណព មួយទៀត ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកឲ្យបាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សេង ៗ ទីដេក ទីអាស្រ័យ ប្រទីប ដល់សមណៈឬព្រាហ្មណ៍ ។ ព្រោះអំពើនោះដែលខ្លួនបានបំពេញយ៉ាងនេះ បានសមាទានយ៉ាងនេះ បុគ្គលនោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក បើបុគ្គលនោះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ មិនទៅកើតក្នុងសុគតិសួគ៌ទេវលោកទេ បើបានត្រឡប់មកកាន់ភាពជាមនុស្ស កើតក្នុងទីណា ៗ រមែងជាអ្នកមានភោគសម្បត្តិច្រើន ។ ម្នាលមាណព បុគ្គលដែលឲ្យបាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សេង ៗ ទីដេក ទីអាស្រ័យ ប្រទីប ដល់សមណៈឬព្រាហ្មណ៍ នេះ ឈ្មោះថាបដិបទា ប្រព្រឹត្តទៅដើម្បីមានភោគសម្បត្តិច្រើន ។

[៦៧] ម្នាលមាណព ស្ត្រីឬបុរសពួកខ្លះក្នុងលោកនេះ ជាអ្នករឹងត្អឹង មើលងាយ មិនសំពះបុគ្គលដែលគួរសំពះ មិនក្រោកទទួលបុគ្គលដែលគួរក្រោកទទួល មិនឲ្យអាសនៈដល់បុគ្គលដែលគួរដល់អាសនៈ

៦៤



មគ្គារហស្ស មគ្គំ ន ទេតិ សក្កាតព្វំ ន សក្កា-រោតិ គរុកាតព្វំ ន គរុការោតិ មានេតព្វំ ន មានេតិ បូជេតព្វំ ន បូជេតិ ។ សោ តេន កម្មេន ឯវំ សមត្តេន ឯវំ សមាទិន្នេន កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ នោ ចេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ សចេ មនុស្សត្តំ អាគច្ឆតិ យត្ថ យត្ថ បច្ចាជាយតិ នីចាកុលីនោ ហោតិ ។ នីចាកុលីនសំវត្តនិកា ឯសា មាណវ បដិបទា យទិ-ទំ ថទ្ធោ ហោតិ អតិមានី អភិវាទេតព្វំ ន អភិវាទេតិ បច្ចុដ្ឋាតព្វំ ន បច្ចុដ្ឋេតិ អាសនារហស្ស អាសនំ ន ទេតិ មគ្គារហស្ស មគ្គំ ន ទេតិ សក្កាតព្វំ ន សក្ការោតិ គរុកាតព្វំ ន គរុការោតិ មានេតព្វំ ន មានេតិ បូជេតព្វំ ន បូជេតិ ។

មិនឲ្យផ្លូវដល់បុគ្គលដែលគួរដល់ផ្លូវ មិនធ្វើសក្ការៈដល់បុគ្គលដែលគួរដល់សក្ការៈ មិនធ្វើសេចក្តីគោរពដល់បុគ្គលដែលគួរធ្វើសេចក្តីគោរព មិនរាប់អានដល់បុគ្គលដែលគួររាប់អាន មិនបូជាដល់បុគ្គលដែលគួរបូជា ។ ព្រោះអំពើនោះ ដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក បើបុគ្គលនោះទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ មិនទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរកទេ បើបានត្រឡប់មកកាន់ភាពជាមនុស្ស កើតក្នុងទីណា ៗ រមែងជាអ្នកមានត្រកូលថោកទាប ។ ម្នាលមាណព បុគ្គលដែលរឹងត្អឹង មើលងាយ មិនសំពះបុគ្គលដែលគួរសំពះ មិនក្រោកទទួលបុគ្គលដែលគួរក្រោកទទួល មិនឲ្យអាសនៈ ដល់បុគ្គលដែលគួរដល់អាសនៈ មិនឲ្យផ្លូវដល់បុគ្គលដែលគួរដល់ផ្លូវ មិនធ្វើសក្ការៈដល់បុគ្គលដែលគួរធ្វើសក្ការៈ មិនធ្វើសេចក្តីគោរពដល់បុគ្គលដែលគួរធ្វើសេចក្តីគោរព មិនរាប់អានបុគ្គលដែលគួររាប់អាន មិនបូជាបុគ្គលដែលគួរបូជា នេះ ឈ្មោះថាបដិបទាប្រព្រឹត្តទៅដើម្បីមានត្រកូលថោកទាប ។

[៦៨] ឥធ បន មាណវ ឯកច្ចោ ឥត្ថី វា បុរិសោ វា អត្ថទ្ធោ ហោតិ អនតិមានី អភិវាទេតព្ពំ អភិវា-ទេតិ បច្ចុដ្ឋាតព្ពំ បច្ចុដ្ឋេតិ អាសនារហស្ស អាសនំ ទេតិ មគ្គារហស្ស មគ្គំ ទេតិ សក្កាតព្ពំ សក្ករោតិ គរុកាតព្ពំ គរុករោតិ មានេតព្ពំ មានេតិ បូជេតព្ពំ បូជេតិ ។ សោ តេន កម្មេន ឯវំ សមត្តេន ឯវំ សមាទិន្នេន កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ នោ ចេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ សចេ មនុស្សត្តំ អាគច្ឆតិ យត្ថ យត្ថ បច្ចាជាយតិ ឧច្ចាកុលីនោ ហោតិ ។ ឧច្ចាកុលីនសំវត្តនិកា ឯសា មាណវ បដិបទា យទិទំ អត្ថទ្ធោ ហោតិ អនតិមានី អភិវាទេតព្ពំ អភិវាទេតិ បច្ចុដ្ឋាតព្ពំ បច្ចុដ្ឋេតិ អាស-នារហស្ស អាសនំ ទេតិ មគ្គារហស្ស មគ្គំ ទេតិ សក្កាតព្ពំ សក្ករោតិ គរុកាតព្ពំ គរុករោតិ មា-នេតព្ពំ មានេតិ បូជេតព្ពំ បូជេតិ ។

[៦៨] ម្នាលមាណព មួយទៀត ស្ត្រីឬបុរស ពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនរឹងត្អឹង មិនមើលងាយ សំពះបុគ្គលដែលគួរសំពះ ក្រោកទទួលបុគ្គលដែលគួរក្រោកទទួល ឲ្យអាសនៈដល់បុគ្គលដែលគួរដល់អាសនៈ ឲ្យផ្លូវដល់បុគ្គលដែលគួរដល់ផ្លូវ ធ្វើសក្ការៈដល់បុគ្គលដែលគួរធ្វើសក្ការៈ ធ្វើសេចក្តីគោរពដល់បុគ្គលដែលគួរគោរព រាប់អានបុគ្គលដែលគួររាប់អាន បូជាដល់បុគ្គលដែលគួរបូជា ។ ព្រោះអំពើនោះ ដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក បើបុគ្គលនោះ ទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ មិនទៅកើតក្នុងសុគតិសួគ៌ទេវលោកទេ បើបានត្រឡប់មកកាន់ភាពជាមនុស្ស កើតក្នុងទីណា ៗ រមែងជាអ្នកមានត្រកូលខ្ពង់ខ្ពស់ ។ ម្នាលមាណព បុគ្គលដែលមិនរឹងត្អឹង មិនមើលងាយគេ សំពះបុគ្គលដែលគួរសំពះ ក្រោកទទួលបុគ្គលដែលគួរក្រោកទទួល ឲ្យអាសនៈដល់បុគ្គលដែលគួរដល់អាសនៈ ឲ្យផ្លូវដល់បុគ្គលដែលគួរដល់ផ្លូវ ធ្វើសក្ការៈដល់បុគ្គលដែលគួរធ្វើសក្ការៈ ធ្វើសេចក្តីគោរពដល់បុគ្គល ដែលគួរធ្វើសេចក្តីគោរព រាប់អានបុគ្គលដែលគួររាប់អាន បូជាបុគ្គលដែលគួរបូជា នេះ ឈ្មោះថាបដិបទាប្រព្រឹត្តទៅដើម្បីមានត្រកូលខ្ពង់ខ្ពស់ ។

វិភង្គវគ្គស្ស ចូឡកម្មវិភង្គសុត្តេ អបរិបុច្ឆិតភាវោ

[៦៩] ឥធ មាណវ ឯកច្ចោ ឥត្ថី វា បុរិសោ វា សមណំ វា ព្រាហ្មណំ វា ឧបសង្កមិត្វា ន បរិបុច្ឆិតា ហោតិ កឹ ភន្តេ កុសលំ កឹ អកុស-លំ កឹ សាវជ្ជំ កឹ អនវជ្ជំ កឹ សេវិតព្វំ កឹ ន សេវិតព្វំ កឹ មេ ករិយមានំ[(១)] ទីឃរត្តំ អហិតាយ ទុក្ខាយ ហោតិ កឹ វា បន មេ ករិយមានំ ទីឃរត្តំ ហិតាយ សុខាយ ហោតីតិ ។ សោ តេន កម្មេន ឯវំ សមត្តេន ឯវំ សមាទិន្នេន កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ នោ ចេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ សចេ មនុស្សត្តំ អាគច្ឆតិ យត្ថ យត្ថ បច្ចា ជាយតិ ទុប្បញ្ញោ ហោតិ ។

---

១ ឱ. កយិរមានំ ។

វិភង្គវគ្គ ចូឡកម្មវិភង្គសូត្រ ភាពនៃបុគ្គលជាអ្នកមិនសាកសួរ

[៦៩] ម្នាលមាណព ស្រ្តីឬបុរសពួកខ្លះ ក្នុងលោកនេះ ចូលទៅរកសមណៈឬព្រាហ្មណ៍ ហើយមិនបានសួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន អ្វីជាកុសល អ្វីជាអកុសល អ្វីមានទោស អ្វីឥតទោស អ្វីគួរសេព អ្វីមិនគួរសេព អ្វីកាលបើខ្ញុំធ្វើ ប្រព្រឹត្តទៅដើម្បីទោសដើម្បីទុក្ខ អស់កាលដ៏យូរ មួយទៀត អ្វីកាលបើខ្ញុំធ្វើ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ អស់កាលដ៏យូរ ។ ព្រោះអំពើនោះ ដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក បើបុគ្គលនោះ ទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ មិនទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរកទេ បើបានត្រឡប់មកកាន់ភាពជាមនុស្ស កើតក្នុងទីណា ៗ រមែងជាអ្នកគ្មានប្រាជ្ញា ។

ទុប្បញ្ញសំវត្តនិកា ឯសា មាណវ បដិបទា យទិទំ សមណំ វា ព្រាហ្មណំ វា ឧបសង្កមិត្វា ន បរិបុច្ឆិតា ហោតិ កឹ ភន្តេ កុសលំ កឹ អកុសលំ កឹ សាវជ្ជំ កឹ អនវជ្ជំ កឹ សេវិតព្វំ កឹ ន សេវិតព្វំ កឹ មេ ករិយមានំ ទីឃរត្តំ អហិតាយ ទុក្ខាយ ហោតិ កឹ វា បន មេ ករិយមានំ ទីឃរត្តំ ហិតាយ សុខាយ ហោតីតិ ។

[៧០] ឥធ បន មាណវ ឯកច្ចោ ឥត្ថី វា បុរិសោ វា សមណំ វា ព្រាហ្មណំ វា ឧបសង្កមិត្វា បរិបុច្ឆិតា ហោតិ កឹ ភន្តេ កុសលំ កឹ អកុសលំ កឹ សាវជ្ជំ កឹ អនវជ្ជំ កឹ សេវិតព្វំ កឹ ន សេវិតព្វំ កឹ មេ ករិយមានំ ទីឃរត្តំ អហិតាយ ទុក្ខាយ ហោតិ កឹ វា បន មេ ករិយមានំ ទីឃរត្តំ ហិតាយ សុខាយ ហោតីតិ ។ សោ តេន កម្មេន ឯវំ សមត្តេន ឯវំ សមាទិន្នេន កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ នោ ចេ កាយស្ស ភេទា

ម្នាលមាណព បុគ្គលដែលចូលទៅរកសមណៈឬព្រាហ្មណ៍ ហើយមិនបានសួរថា បពិត្រលោកដ៏ចម្រើន អ្វីជាកុសល អ្វីជាអកុសល អ្វីមានទោស អ្វីឥតទោស អ្វីគួរសេព អ្វីមិនគួរសេព អ្វីកាលបើខ្ញុំធ្វើ ប្រព្រឹត្តទៅ ដើម្បីទោស ដើម្បីទុក្ខ អស់កាលដ៏យូរ មួយទៀត អ្វីកាលបើខ្ញុំធ្វើ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ អស់កាលដ៏យូរ នេះ ឈ្មោះថាបដិបទាប្រព្រឹត្តទៅដើម្បីមិនមានប្រាជ្ញា ។

[៧០] ម្នាលមាណព មួយទៀត ស្ត្រីឬបុរស ពួកខ្លះ ក្នុងលោកនេះ ចូលទៅជិតសមណៈឬព្រាហ្មណ៍ ហើយសួរថា បពិត្រលោកដ៏ចម្រើន អ្វីជាកុសល អ្វីជាអកុសល អ្វីមានទោស អ្វីឥតទោស អ្វីគួរសេព អ្វីមិនគួរសេព អ្វីកាលបើខ្ញុំធ្វើ ប្រព្រឹត្តទៅដើម្បីទោស ដើម្បីទុក្ខ អស់កាលដ៏យូរ មួយទៀត អ្វីកាលបើខ្ញុំធ្វើ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ អស់កាលដ៏យូរ ។ ព្រោះអំពើនោះ ដែលខ្លួនបានបំពេញយ៉ាងនេះ បានសមាទានយ៉ាងនេះ បុគ្គលនោះ លុះទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក បើបុគ្គលនោះ ទម្លាយរាងកាយ

បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ សចេ មនុស្សត្តំ អាគច្ឆតិ យត្ថ យត្ថ បច្ឆា ជាយតិ មហាបញ្ញោ ហោតិ ។ មហាបញ្ញសំវត្តនិកា ឯសា មាណវ បដិបទា យទិទំ សមណំ វា ព្រាហ្មណំ វា ឧបសង្កមិត្វា បរិបុច្ឆិតា ហោតិ កឹ ភន្តេ កុសលំ កឹ អកុសលំ កឹ សាវជ្ជំ កឹ អនវជ្ជំ កឹ សេវិ-តព្វំ កឹ ន សេវិតព្វំ កឹ មេ ករិយមានំ ទីឃរត្តំ អហិតាយ ទុក្ខាយ ហោតិ កឹ វា បន មេ ករិយមានំ ទីឃរត្តំ ហិតាយ សុខាយ ហោតីតិ ។

[៧១] ឥតិ ខោ មាណវ អប្បាយុកសំវត្តនិកា បដិបទា អប្បាយុកត្តំ ឧបនេតិ ទីឃាយុកសំវត្តនិកា បដិបទា ទីឃាយុកត្តំ ឧបនេតិ ពហ្វាពាធសំវត្តនិ-កា បដិបទា ពហ្វាពាធត្តំ ឧបនេតិ អប្បាពាធសំ-វត្តនិកា បដិបទា អប្បាពាធត្តំ ឧបនេតិ ទុព្វណ្ណ-សំវត្តនិកា បដិបទា ទុព្វណ្ណត្តំ ឧបនេតិ ចាសា-ទិកសំវត្តនិកា បដិបទា ចាសាទិកត្តំ ឧបនេតិ

បន្ទាប់អំពីសេចក្ដីស្លាប់ទៅ មិនទៅកើតក្នុងសុគតិសួគ៌ទេវលោកទេ បើត្រឡប់មកកាន់ភាពជាមនុស្ស កើតក្នុងទីណា ៗ រមែងជាអ្នកមានប្រាជ្ញាច្រើន ។ ម្នាលមាណព បុគ្គលដែលចូលទៅរកសមណៈឬព្រាហ្មណ៍ ហើយបានសួរថា បពិត្រលោកដ៏ចម្រើន អ្វីជាកុសល អ្វីជាអកុសល អ្វីមានទោស អ្វីឥតទោស អ្វីគួរសេព អ្វីមិនគួរសេព អ្វីកាលបើខ្ញុំធ្វើប្រព្រឹត្តទៅ ដើម្បីទោស ដើម្បីសេចក្ដីទុក្ខ អស់កាលដ៏យូរ មួយទៀត អ្វីកាលបើខ្ញុំធ្វើ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ អស់កាលដ៏យូរ នេះ ឈ្មោះថាបដិបទាប្រព្រឹត្តទៅដើម្បីមានប្រាជ្ញាច្រើន ។

[៧១] ម្នាលមាណព ព្រោះហេតុថា សេចក្ដីប្រតិបត្តិដែលប្រព្រឹត្តទៅឲ្យមានអាយុខ្លី រមែងនាំឲ្យមានអាយុខ្លី សេចក្ដីប្រតិបត្តិដែលប្រព្រឹត្តទៅ ដើម្បីឲ្យមានអាយុវែង រមែងនាំឲ្យមានអាយុវែង សេចក្ដីប្រតិបត្តិប្រព្រឹត្តទៅ ដើម្បីឲ្យមានអាពាធច្រើន រមែងនាំឲ្យមានអាពាធច្រើន សេចក្ដីប្រតិបត្តិដែលប្រព្រឹត្តទៅ ដើម្បីអាពាធតិច រមែងនាំឲ្យមានអាពាធតិច សេចក្ដីប្រតិបត្តិដែលប្រព្រឹត្តទៅ ដើម្បីឲ្យមានសម្បុរអាក្រក់ រមែងនាំឲ្យមានសម្បុរអាក្រក់ សេចក្ដីប្រតិបត្តិដែលប្រព្រឹត្តទៅ ដើម្បីជាអ្នកមានសម្បុរជ្រះថ្លា រមែងនាំឲ្យជាអ្នកមានសម្បុរជ្រះថ្លា

អប្បេសក្ខសំវត្តនិកា បដិបទា អប្បេសក្ខត្តំ ឧប-នេតិ មហេសក្ខសំវត្តនិកា បដិបទា មហេសក្ខត្តំ ឧបនេតិ អប្បភោគសំវត្តនិកា បដិបទា អប្បភោគត្តំ ឧបនេតិ មហាភោគសំវត្តនិកា បដិបទា មហាភោគត្តំ ឧបនេតិ នីចាកុលីនសំវត្តនិកា បដិបទា នីចាកុ-លីនត្តំ ឧបនេតិ ឧច្ចាកុលីនសំវត្តនិកា បដិបទា ឧច្ចាកុលីនត្តំ ឧបនេតិ ទុប្បញ្ញសំវត្តនិកា បដិបទា ទុប្បញ្ញត្តំ ឧបនេតិ មហាបញ្ញសំវត្តនិកា បដិបទា មហាបញ្ញត្តំ ឧបនេតិ ។ កម្មស្សកា មាណវ សត្តា កម្មទាយាទា កម្មយោនី កម្មពន្ធូ កម្មប្បដិសរណា កម្មំ សត្តេ វិភជតិ យទិទំ ហីនប្បណីតតាយាតិ ។

សេចក្តីប្រតិបត្តិដែលប្រព្រឹត្តទៅ ដើម្បីឲ្យមានស័ក្តិតូច រមែងនាំឲ្យមានស័ក្តិតូច សេចក្តីប្រតិបត្តិដែលប្រព្រឹត្តទៅ ដើម្បីឲ្យមានស័ក្តិធំ រមែងនាំឲ្យមានស័ក្តិធំ សេចក្តីប្រតិបត្តិដែលប្រព្រឹត្តទៅ ដើម្បីឲ្យមានភោគសម្បត្តិតិច រមែងនាំឲ្យមានភោគសម្បត្តិតិច សេចក្តីប្រតិបត្តិដែលប្រព្រឹត្តទៅ ដើម្បីឲ្យមានភោគសម្បត្តិច្រើន រមែងនាំឲ្យមានភោគសម្បត្តិច្រើន សេចក្តីប្រតិបត្តិដែលប្រព្រឹត្តទៅ ដើម្បីឲ្យមានត្រកូលថោកទាប រមែងនាំឲ្យមានត្រកូលថោកទាប សេចក្តីប្រតិបត្តិដែលប្រព្រឹត្តទៅ ដើម្បីឲ្យមានត្រកូលខ្ពង់ខ្ពស់ រមែងនាំឲ្យមានត្រកូលខ្ពង់ខ្ពស់ សេចក្តីប្រតិបត្តិដែលប្រព្រឹត្តទៅ ដើម្បីមិនមានប្រាជ្ញា រមែងនាំឲ្យមិនមានប្រាជ្ញា សេចក្តីប្រតិបត្តិដែលប្រព្រឹត្តទៅ ដើម្បីឲ្យមានប្រាជ្ញាច្រើន រមែងនាំឲ្យមានប្រាជ្ញាច្រើន ។ ម្នាលមាណព សត្វទាំងឡាយមានកម្មជារបស់ខ្លួន មានកម្មជាទាយាទ មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាគ្រឿងរលឹក កម្មតែងចែកពួកសត្វដើម្បីឲ្យថោកទាប និងខ្ពង់ខ្ពស់

[៧២] ឯវំ វុត្តេ សុភោ មាណវោ តោទេយ្យ-បុត្តោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម សេយ្យថាបិ ភោ គោតម និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេ-លបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ ភោតា គោតមេន អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។

ចូឡកម្មវិភង្គសុត្តំ បញ្ចមំ និដ្ឋិតំ ។

វិភង្គវគ្គ ចូឡកម្មវិភង្គសូត្រ ការដល់ត្រៃសរណៈ

[៧២] កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ សុភមាណព តោទេយ្យបុត្រ បានក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះអង្គសំដែងហើយ ដោយអនេកបរិយាយយ៉ាងនេះ (ភ្លឺច្បាស់ណាស់) ដូចជាគេផ្ងាររបស់ដែលផ្កាប់ ឬបើកបង្ហាញរបស់ដែលកំបាំង ឬក៏ប្រាប់ផ្លូវដល់មនុស្សវង្វេង ពុំនោះសោត ដូចជាគេទ្រោលប្រទីបបំភ្លឺក្នុងទីងងឹត ដោយគិតថា ឲ្យពួកមនុស្សដែលមានភ្នែកភ្លឺ មើលឃើញរូបទាំងឡាយបាន ខ្ញុំព្រះអង្គសូមដល់នូវព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹង ទីរលឹក សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសក អ្នកដល់នូវសរណៈ ស្មើដោយជីវិត ចាប់ដើមតាំងពីថ្ងៃនេះតរៀងទៅ ។

ចប់ ចូឡកម្មវិភង្គសូត្រ ទី ៥ ។

# ឆដ្ឋំ មហាកម្មវិភង្គសុត្តំ

[៧៣] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន អាយស្មា សមិទ្ធិ អរញ្ញកុដិកាយំ វិហរតិ ។ អថខោ បោតលិបុត្តោ បរិព្វាជកោ ជង្ឃាវិហារំ អនុចង្កមមានោ អនុវិចរមានោ យេនាយស្មា សមិទ្ធិ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា សមិទ្ធិនា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។

[៧៤] ឯកមន្តំ និសិន្នោ ខោ បោតលិបុត្តោ បរិព្វាជកោ អាយស្មន្តំ សមិទ្ធឹ ឯតទវោច សម្មុខា មេតំ អាវុសោ សមិទ្ធិ សមណស្ស គោតមស្ស សុតំ សម្មុខា បដិគ្គហិតំ មោឃំ កាយកម្មំ មោឃំ វចីកម្មំ មនោកម្មមេវ សច្ចន្តិ អត្ថិ ច សា សមាបត្តិ យំ សមាបត្តឹ សមាបន្នោ ន កិញ្ចិ វេទិយតីតិ ។

# មហាកម្មវិភង្គសូត្រ ទី ៦

[៧៣] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះសមិទ្ធិមានអាយុ គង់នៅក្នុងកុដិដែលតាំងនៅក្នុងព្រៃ ។ គ្រានោះឯង បរិព្វាជក ឈ្មោះបោតលិបុត្រដើរចង្ក្រមត្រាច់ទៅមកដើម្បីសម្រួលស្មង ហើយចូលទៅរកព្រះសមិទ្ធិមានអាយុ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់នឹងព្រះសមិទ្ធិមានអាយុ លុះបញ្ចប់ពាក្យរាក់ទាក់និងពាក្យគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។

[៧៤] លុះបោតលិបុត្តបរិព្វាជក អង្គុយក្នុងទីសមគួរហើយ ទើបពោលពាក្យនេះនឹងព្រះសមិទ្ធិមានអាយុថា ម្នាលអាវុសោសមិទ្ធិ ពាក្យនេះខ្ញុំបានស្តាប់មកក្នុងទីចំពោះព្រះភក្ត្រ បានទទួលមកក្នុងទីចំពោះព្រះភក្ត្រ នៃព្រះសមណគោតមថា កាយកម្មជាកម្មឥតអំពើ វចីកម្មជាកម្មឥតអំពើ មនោកម្មទើបជាកម្មពិត មួយទៀត បុគ្គលចូលកាន់សមា-បត្តិណា ហើយមិនទទួលអារម្មណ៍អ្វីមួយ សមាបត្តិនោះក៏មានដែរ ។

មា ឯវំ អាវុសោ បោតលិបុត្ត អវច[១] មា ភគវន្តំ អព្ភាចិក្ខ[២] ន ហិ សាធុ ភគវតោ អព្ភក្ខានំ ន ហិ ភគវា ឯវំ វទេយ្យ មោឃំ កាយកម្មំ មោឃំ វចីកម្មំ មនោកម្មមេវ សច្ចន្តិ អត្ថិ ច ខោ សា អាវុសោ សមាបត្តិ យំ សមាបត្តឹ សមាបន្នោ ន កិញ្ចិ វេទិយតីតិ ។ កីវចិរំ បព្វជិតោសិ អាវុសោ សមិទ្ធីតិ ។ ន ចិរំ អាវុសោ តីណិ វស្សានីតិ ។ ឯត្ថទានិ មយំ ថេរេ ភិក្ខូ កឹ វក្ខាម យត្រ ហិ នាម ឯវំ នវោ ភិក្ខុ សត្ថារំ បរិរក្ខិតព្វំ មញ្ញិស្សតិ សញ្ចេតនិកំ អាវុសោ សមិទ្ធិ កម្មំ កត្វា កាយេន វាចាយ មនសា កឹ សោ វេទិយតីតិ ។ សញ្ចេតនិកំ អាវុសោ បោតលិបុត្ត កម្មំ កត្វា កាយេន វាចាយ មនសា ទុក្ខំ សោ វេទិយតីតិ ។ អថខោ បោតលិបុត្តោ បរិព្វាជកោ

១ កត្ថចិ អម្ហាកំ បោត្ថកេ មា ឯវំ អាវុសោ បោតលិបុត្ត អវច មា ឯវំ អាវុសោ បោតលិបុត្ត អវចាតិបិ មា ហេវំ អាវុសោ...អវច មា ហេវំ អាវុសោ...អវចាតិបិ ទិស្សន្តិ ។ ២ ឱ. ម. អព្ភាចិក្ខិ ។

ព្រះសមិទ្ធិពោលតបថា ម្នាលអាវុសោបោតលិបុត្ត អ្នកកុំពោលយ៉ាងនេះឡើយ អ្នកកុំពោលបង្កាច់ព្រះមានព្រះភាគ ព្រោះថា ការពោលបង្កាច់ព្រះមានព្រះភាគ មិនល្អទេ ដ្បិតថា ព្រះមានព្រះភាគ មិនបានត្រាស់ថា កាយកម្មជាកម្មឥតអំពើ វចីកម្មជាកម្មឥតអំពើ មនោកម្មទើបជាកម្មពិត យ៉ាងនេះទេ ម្នាលអាវុសោ តែចំណែកខាង បុគ្គលចូលកាន់សមាបត្តិណា មិនទទួលអារម្មណ៍អ្វីមួយ សមាបត្តិនោះ ក៏មានមែន ។ ម្នាលអាវុសោ សមិទ្ធិ លោកបួសបានយូរប៉ុន្មានវស្សាហើយ ។ ម្នាលអាវុសោ មិនយូរប៉ុន្មានទេ ទើបតែនឹងបាន ៣ វស្សា ។ ឥឡូវនេះ យើងទាំងឡាយ ចាំនិយាយថ្វីចំពោះពួកភិក្ខុជាថេរៈក្នុងរឿងនេះ ព្រោះសូម្បីភិក្ខុថ្មី ក៏គង់សំគាល់នូវសាស្តាដែលខ្លួនគួរការពារយ៉ាងនេះបានដែរ ម្នាលអាវុសោសមិទ្ធិ បុគ្គលធ្វើកម្មប្រកបដោយចេតនា ដោយកាយវាចាចិត្តហើយ តើរងវេទនាដូចម្តេច ។ ម្នាលអាវុសោបោតលិបុត្ត បុគ្គលធ្វើកម្មប្រកបដោយចេតនា ដោយកាយវាចាចិត្តហើយ រមែងរងទុក្ខវេទនា ។ គ្រានោះ បោតលិបុត្តបរិព្វាជក

អាយស្មតោ សមិទ្ធិស្ស ភាសិតំ នេវ អភិនន្ទិ នប្បដិក្កោសិ អនភិនន្ទិត្វា អប្បដិក្កោសិត្វា ឧដ្ឋាយាសនា បក្កាមិ ។

[៧៥] អថខោ អាយស្មា សមិទ្ធិ អចិរបក្កន្តេ ចោតលិបុត្តេ បរិព្វាជកេ យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា អានន្ទេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សមិទ្ធិ យាវតកោ អហោសិ ចោតលិបុត្តេន បរិព្វាជកេន សទ្ធឹ កថាសល្លាបោ តំ សព្វំ អាយស្មតោ អានន្ទត្ថេរស្ស[១] អារោចេសិ ។ ឯវំ វុត្តេ អាយស្មា អានន្ទោ អាយស្មន្តំ សមិទ្ធឹ ឯតទវោច អត្ថិ ខោ ឥទំ អាវុសោ សមិទ្ធិ កថាបាភតំ ភគវន្តំ ទស្សនាយ អាយាមាវុសោ សមិទ្ធិ យេន ភគវា តេនុបសង្កមេយ្យាម ឧបសង្កមិត្វា ឯតមត្ថំ ភគវតោ អារោចេយ្យាម យថា នោ ភគវា ព្យាករិស្សតិ

១ ឱ. ម. អានន្ទស្ស ។

មិនត្រេកអរ មិនខាំងឃាត់ភាសិតរបស់ព្រះសមិទ្ធិមានអាយុ លុះមិនត្រេកអរ មិនខាំងឃាត់ហើយ ក៏ក្រោកអំពីអាសនៈចៀសចេញទៅ ។

[៧៥] គ្រានោះឯង ព្រះសមិទ្ធិមានអាយុ កាលបោតលិបុត្តបរិព្វាជកចៀសចេញទៅ មិនយូរប៉ុន្មាន ក៏ចូលទៅរកព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់នឹងព្រះអានន្ទមានអាយុ លុះបញ្ចប់ពាក្យដែលគួររាក់ទាក់ និងពាក្យគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះសមិទ្ធិមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ទើបផ្តៀងពាក្យចរចាទាំងអស់ ដែលខ្លួននិយាយនឹងបោតលិបុត្តបរិព្វាជកទាំងប៉ុន្មាន ដល់ព្រះអានន្ទមានអាយុ ។ កាលព្រះសមិទ្ធិមានអាយុ ពោលយ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏ពោលនឹងព្រះសមិទ្ធិមានអាយុ យ៉ាងនេះថា ម្នាលអាវុសោសមិទ្ធិ ពាក្យនេះ ជាពាក្យមានមូលហេតុហើយ ម្នាលអាវុសោសមិទ្ធិ គួរយើងនាំគ្នាមក ដើម្បីគាល់ព្រះមានព្រះភាគ គួរនាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ គួរក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ព្រះមានព្រះភាគ នឹងព្យាករ ដល់យើងយ៉ាងណា

តថា នំ ធារេយ្យាមាតិ ។ ឯវមាវុសោតិ ខោ អាយស្មា សមិទ្ធិ អាយស្មតោ អានន្ទស្ស បច្ចស្សោសិ ។ អថខោ អាយស្មា ច សមិទ្ធិ អាយស្មា ច អានន្ទោ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ យាវតកោ អហោសិ អាយស្មតោ សមិទ្ធិស្ស បោតលិបុត្តេន បរិព្វាជកេន សទ្ធឹ កថាសល្លាបោ តំ សព្វំ ភគវតោ អារោចេសិ ។

[៧៦] ឯវំ វុត្តេ ភគវា អាយស្មន្តំ អានន្ទំ ឯតទវោច ទស្សនម្បិ ខោ អហំ អានន្ទ បោតលិបុត្តស្ស បរិព្វាជកស្ស នាភិជានាមិ កុតោ បនេវរូបំ កថាសល្លាបំ ឥមិនា អានន្ទ សមិទ្ធិនា មោឃបុរិសេន បោតលិបុត្តស្ស បរិព្វាជកស្ស វិភជព្យាករណីយោ បញ្ហោ ឯកំសេន ព្យាកតោតិ ។

យើងគប្បីចងចាំសេចក្តីនោះ យ៉ាងនោះ ។ ព្រះសមិទ្ធិមានអាយុ ទទួលពាក្យព្រះអានន្ទមានអាយុថា ករុណា អាវុសោ ។ គ្រានោះ ព្រះសមិទ្ធិមានអាយុ និងព្រះអានន្ទមានអាយុ ក៏នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលពាក្យចរចាទាំងប៉ុន្មាន របស់ព្រះសមិទ្ធិមានអាយុ ជាមួយនឹងបោតលិបុត្តបរិព្វាជកទាំងអស់ ចំពោះព្រះមានព្រះភាគ ។

[៧៦] លុះព្រះអានន្ទក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុ យ៉ាងនេះថា ម្នាលអានន្ទ តថាគតមិនទាំងធ្លាប់ឃើញ នូវបោតលិបុត្តបរិព្វាជកសោះ តើនឹងមានការចរចាជាមួយបែបនេះ មកពីណា ម្នាលអានន្ទ ប្រស្នាដែលគួរចែក គួរដោះស្រាយ ដល់បោតលិបុត្តបរិព្វាជក លោកសមិទ្ធិ ជាមោឃបុរសនេះឯង ដោះស្រាយហើយតែមួយចំណែក ។

ឯវំ វុត្តេ អាយស្មា ឧទាយិ ភគវន្តំ ឯតទវោច សចេ បន[១] ភន្តេ អាយស្មតា សមិទ្ធិនា ឥទំ សន្ធាយ ភាសិតំ យំ កិញ្ចិ វេទយិតំ តំ ទុក្ខស្មិន្តិ ។

[៧៧] ឯវំ វុត្តេ[២] ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ បស្ស ខោ ត្វំ អានន្ទ ឥមស្ស ឧទា-យិស្ស មោឃបុរិសស្ស ឧម្មង្គំ អញ្ញាសឹ ខោ អហំ អានន្ទ ឥទានេវាយំ ឧទាយិ មោឃបុរិសោ ឧម្មុជ្ជ-មានោ អយោនិសោ ឧម្មុជ្ជិស្សតិ អាទឹយេវ[៣] អា-នន្ទ ចោតលិបុត្តេន បរិព្វាជកេន តិស្សោ វេទនា បុច្ឆិតា សចាយំ អានន្ទ សមិទ្ធិ មោឃបុរិសោ ចោ-តលិបុត្តស្ស បរិព្វាជកស្ស ឯវំ បុដ្ឋោ ឯវំ ព្យា-ករេយ្យ សញ្ចេតនិកំ អាវុសោ ចោតលិបុត្ត កម្មំ កត្វា កាយេន វាចាយ មនសា សុខវេទនីយំ សុខំ សោ វេទិយតិ សញ្ចេតនិកំ អាវុសោ ចោតលិបុត្ត កម្មំ កត្វា កាយេន វាចាយ មនសា ទុក្ខវេទនីយំ ទុក្ខំ សោ វេទិយតិ សញ្ចេតនិកំ អាវុសោ ចោតលិបុត្ត

១ កឹ បនាតិបិ ទិស្សតិ ។ ២ អថខោតិបិ ។ ៣ ឱ. អាទិសោ វ ។

កាលព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះឧទាយិមានអាយុ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្រែងសមិទ្ធិមានអាយុ ពោលដូច្នោះ ព្រោះអាងហេតុនេះថា វេទនាណានីមួយ វេទនានោះ សុទ្ធតែជាទុក្ខដូច្នេះទេដឹង ។

[៧៧] កាលព្រះឧទាយិ ក្រាបទូលយ៉ាងនេះហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅព្រះអានន្ទមានអាយុថា ម្នាលអានន្ទ ចូរអ្នកមើល នូវសេចក្តីល្ងង់របស់ឧទាយិ ជាមោឃបុរសនេះ ម្នាលអានន្ទ តថាគតបានដឹងច្បាស់ហើយថា ឥឡូវនេះ ឧទាយិនេះជាមោឃបុរស កាលងើបឡើង តែងងើបឡើងដោយឧបាយមិនមែនជាប្រាជ្ញា ម្នាលអានន្ទ បោតលិបុត្តបរិព្វាជកបានសួរវេទនា ៣ ខាងដើម ម្នាលអានន្ទ ប្រសិនបើសមិទ្ធិជាមោឃបុរសនេះ ត្រូវបោតលិបុត្តបរិព្វាជកសួរយ៉ាងនេះ គប្បីដោះស្រាយយ៉ាងនេះថា ម្នាលអាវុសោបោតលិបុត្តបុគ្គល ធ្វើអំពើប្រកបដោយចេតនា ដោយកាយវាចាចិត្ត ជាហេតុនៃសុខវេទនា បុគ្គលនោះក៏រងសុខវេទនា ម្នាលអាវុសោបោតលិបុត្តបុគ្គល ធ្វើកម្មប្រកបដោយចេតនា ដោយកាយវាចាចិត្ត ជាហេតុនៃទុក្ខវេទនា បុគ្គលនោះ តែងរងទុក្ខវេទនា ម្នាលអាវុសោបោតលិបុត្ត

កម្មំ កត្វា កាយេន វាចាយ មនសា អ-
ទុក្ខមសុខវេទនីយំ អទុក្ខមសុខំ សោ វេទិយតីតិ
ឯវំ ព្យាករមានោ ខោ អានន្ទ សមិទ្ធិ មោឃបុរិសោ
ចោតលិបុត្តស្ស បរិព្វាជកស្ស សម្មា[១] ព្យាករេយ្យ
អបិចានន្ទ តេ[២] អញ្ញតិត្ថិយបរិព្វាជកា ពាលា អព្យត្តា
កេ ច តថាគតស្ស មហាកម្មវិភង្គំ ជានិស្សន្តិ
សចេ តុម្ហេ អានន្ទ សុណេយ្យាថ តថាគតស្ស
មហាកម្មវិភង្គំ វិភជន្តស្សាតិ ។ ឯតស្ស ភគវា
កាលោ ឯតស្ស សុគត កាលោ យំ ភគវា
មហាកម្មវិភង្គំ វិភជេយ្យ ភគវតោ សុត្វា ភិក្ខូ
ធារេស្សន្តីតិ ។ តេនហានន្ទ សុណាហិ សាធុកំ
មនសិករោហិ ភាសិស្សាមីតិ ។ ឯវម្ភន្តេតិ ខោ
អាយស្មា អានន្ទោ ភគវតោ បច្ចស្សោសិ ។

[៧៨] ភគវា ឯតទវោច ចត្តារោមេ អានន្ទ
បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ
ចត្តារោ ។ ឥធានន្ទ ឯកច្ចោ បុគ្គលោ ឥធ

---
១ ម. សម្មា ព្យាករមានោ ។ ២ ឱ. កេ ច ។ ម. កេចិ ។

បុគ្គល ធ្វើអំពើប្រកបដោយចេតនា ដោយកាយវាចាចិត្ត ជាហេតុនៃអទុក្ខមសុខវេទនា បុគ្គលនោះ តែងវេងអទុក្ខមសុខវេទនា ម្នាលអានន្ទ សមិទ្ធិជាមោឃបុរស កាលព្យាករយ៉ាងនេះ ឈ្មោះថា គួរព្យាករដោយប្រពៃ ដល់បោតលិបុត្តបរិព្វាជក ម្នាលអានន្ទ មួយទៀត ពួកតិរ្ថិយបរិព្វាជកដទៃទាំងនោះ ជាមនុស្សល្ងង់ មិនឈ្លាសប្រតិពល ម្តេចឡើយនឹងដឹងមហាកម្មវិភង្គ របស់តថាគតបាន ម្នាលអានន្ទ បើដូច្នោះ កាលបើតថាគត ចែកមហាកម្មវិភង្គ អ្នកទាំងឡាយគប្បីស្តាប់ចុះ ។ បពិត្រព្រះមានព្រះភាគ កាលនេះជាកាលគួរ ព្រះមានព្រះភាគគួរចែកនូវមហាកម្មវិភង្គ បពិត្រព្រះសុគត កាលនេះជាកាលគួរ ព្រះមានព្រះភាគគួរចែកមហាកម្មវិភង្គ ពួកភិក្ខុបានស្តាប់ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគ នឹងបានចងចាំទុក ។ ម្នាលអានន្ទ បើដូច្នោះ ចូរអ្នកយកចិត្តទុកដាក់ ស្តាប់ដោយប្រពៃចុះ តថាគតនឹងសំដែង ។ ព្រះអានន្ទមានអាយុ ក៏ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[៧៨] ព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះថា ម្នាលអានន្ទ បុគ្គលក្នុងលោកនេះ មាន ៤ ពួក ។ បុគ្គល ៤ ពួក តើដូចម្តេចខ្លះ ។ ម្នាលអានន្ទ បុគ្គលពួកមួយ ក្នុងលោកនេះ

បាណាតិបាតី ហោតិ អទិន្នាទាយី ហោតិ កាមេសុ មិច្ឆាចារី ហោតិ មុសាវាទី ហោតិ បិសុណាវាចោ ហោតិ ផរុសវាចោ ហោតិ សម្ផប្បលាបី ហោតិ អភិជ្ឈាលុ ហោតិ ព្យាបន្នចិត្តោ ហោតិ មិច្ឆាទិដ្ឋី ហោតិ សោ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ ឥធ បនានន្ទ ឯកច្ចោ បុគ្គលោ ឥធ បាណាតិបាតី ហោតិ អទិន្នាទាយី ហោតិ កាមេសុ មិច្ឆាចារី ហោតិ មុសាវាទី ហោតិ បិសុណាវាចោ ហោតិ ផរុសវាចោ ហោតិ សម្ផប្បលាបី ហោតិ អភិជ្ឈាលុ ហោតិ ព្យាបន្នចិត្តោ ហោតិ មិច្ឆាទិដ្ឋី ហោតិ សោ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ ឥធានន្ទ ឯកច្ចោ បុគ្គលោ ឥធ បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ បិសុណាយ វាចាយ បដិវិរតោ ហោតិ

ជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ពោលពាក្យកុហក ពោលពាក្យញុះញង់ ពោលពាក្យអាក្រក់ ពោលពាក្យឥតប្រយោជន៍ សំឡឹងរំពៃចំពោះទ្រព្យរបស់គេ មានចិត្តព្យាបាទ មានគំនិតយល់ខុស ក្នុងលោកនេះ បុគ្គលនោះ លុះទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ។ ម្នាលអានន្ទ មួយទៀត បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ ពោលពាក្យកុហក ពោលពាក្យញុះញង់ ពោលពាក្យអាក្រក់ ពោលពាក្យឥតប្រយោជន៍ ជាអ្នកសំឡឹងរំពៃចំពោះទ្រព្យរបស់គេ មានចិត្តព្យាបាទ មានគំនិតយល់ខុស ក្នុងលោកនេះ បុគ្គលនោះ លុះទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក[១] ។ ម្នាលអានន្ទ បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកវៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន វៀរស្រឡះចាកកាមេសុមិច្ឆាចារ វៀរស្រឡះចាកមុសាវាទ វៀរស្រឡះចាកបិសុណាវាចា

១ ព្រោះកុសលជ្រែកអកុសល ក្នុងវេលាជិតស្លាប់ ។

ផរុសាយ វាចាយ បដិវិរតោ ហោតិ សម្ផប្បលាបា បដិវិរតោ ហោតិ អនភិជ្ឈាលុ ហោតិ អព្យាបន្នចិត្តោ ហោតិ សម្មាទិដ្ឋី ហោតិ សោ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ ឥធ បនានន្ទ ឯកច្ចោ បុគ្គលោ ឥធ បាណា-តិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិ-រតោ ហោតិ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ បិសុណាយ វាចាយ បដិវិរតោ ហោតិ ផរុសាយ វាចាយ បដិវិរតោ ហោតិ សម្ផប្បលាបា បដិវិរតោ ហោតិ អនភិជ្ឈាលុ ហោតិ អព្យាបន្នចិត្តោ ហោតិ សម្មាទិដ្ឋី ហោតិ សោ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។

[៧៩] ឥធានន្ទ ឯកច្ចោ សមណោ វា ព្រាហ្ម-ណោ វា អាតប្បមន្វាយ បធានមន្វាយ អនុយោ-គមន្វាយ អប្បមាទមន្វាយ សម្មាមនសិការមន្វាយ

វៀរស្រឡះចាកផរុសវាចា វៀរស្រឡះចាកសម្ផប្បលាបៈ ជាអ្នកមានចិត្តមិនបានសំឡឹងរំពៃ ចំពោះទ្រព្យរបស់គេ មានចិត្តមិនបានព្យាបាទ ជាអ្នកមានគំនិតយល់ត្រូវ ក្នុងលោកនេះ បុគ្គលនោះ លុះទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើត ក្នុងសុគតិសួគ៌ទេវលោក ។ ម្នាលអានន្ទ មួយទៀត បុគ្គលពួកមួយ ក្នុងលោកនេះ វៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន វៀរស្រឡះចាកកាមេសុមិច្ឆាចារ វៀរស្រឡះ ចាកមុសាវាទ វៀរស្រឡះចាកបិសុណាវាចា វៀរស្រឡះចាកផរុសវាចា វៀរស្រឡះចាកសម្ផប្បលាបៈ ជាអ្នកមានចិត្តមិនបានរំពៃ ចំពោះទ្រព្យរបស់គេ មានចិត្តមិនព្យាបាទ ជាអ្នកមានគំនិតយល់ត្រូវ ក្នុងលោកនេះ បុគ្គលនោះ លុះទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើត ក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក[១] ។

[៧៩] ម្នាលអានន្ទ សមណៈឬព្រាហ្មណ៍ពួកមួយ ក្នុងលោកនេះ អាស្រ័យសេចក្តីព្យាយាមជាគ្រឿងដុតកម្តៅកិលេស អាស្រ័យសេចក្តីព្យាយាមជាគ្រឿងតម្កល់ចិត្តទុក អាស្រ័យសេចក្តីប្រឹងប្រែង អាស្រ័យសេចក្តីមិនប្រមាទ អាស្រ័យសេចក្តីយកចិត្តទុកដាក់ដោយប្រពៃ

១ ព្រោះអកុសលជ្រែកកុសល ក្នុងវេលាជិតស្លាប់ ។

តថារូបំ ចេតោសមាធឹ ផុសតិ ។ យថាសមាហិតេ ចិត្តេ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន អមុំ បុគ្គលំ បស្សតិ ឥធ បាណាតិបាតឹ អទិន្នាទាយឹ កាមេសុមិច្ឆាចារឹ មុសាវាទឹ បិសុណាវាចឹ ផរុសវាចឹ សម្ផប្បលាបឹ អភិជ្ឈាលុំ ព្យាបន្នចិត្តំ មិច្ឆាទិដ្ឋឹ កាយស្ស ភេទា បរម្មរណា បស្សតិ អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នំ ។ សោ ឯវមាហ អត្ថិ កិរ ភោ បាបកានិ កម្មានិ អត្ថិ ទុច្ចរិតស្ស វិបាកោ អមាហំ[១] បុគ្គលំ អទ្ទសំ ឥធ បាណាតិបាតឹ អទិន្នាទាយឹ កាមេសុមិច្ឆាចារឹ ។ បេ ។ មិច្ឆាទិដ្ឋឹ កាយស្ស ភេទា បរម្មរណា បស្សាមិ អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នន្តិ

១ ឱ. ម. អបាហំ ។

រមែងបាននូវចេតោសមាធិ មានសភាពដូច្នោះ ។ កាលបើតម្កល់ចិត្តនឹងហើយ សមណៈឬព្រាហ្មណ៍នោះ រមែងឃើញ ដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្លងបង់ចក្ខុរបស់មនុស្សធម្មតា នូវបុគ្គលឯណោះដែលសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ពោលពាក្យកុហក ពោលពាក្យញុះញង់ ពោលពាក្យអាក្រក់ ពោលពាក្យឥតប្រយោជន៍ មានចិត្តសំឡឹងរំពៃចំពោះទ្រព្យរបស់គេ មានចិត្តព្យាបាទ មានគំនិតយល់ខុស ក្នុងលោកនេះ រមែងឃើញបុគ្គលនោះដែលទម្លាយរាងកាយ បន្ទាប់អំពីសេចក្ដីស្លាប់ទៅ ទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ។ សមណៈឬព្រាហ្មណ៍នោះពោលយ៉ាងនេះថា អើហ្ន៎ អំពើអាក្រក់ក៏មាន ផលរបស់ទុច្ចរិតក៏មាន អាត្មាអញបានឃើញបុគ្គលឯណោះ ដែលសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។ បេ ។ មានគំនិតយល់ខុស ក្នុងលោកនេះ បានឃើញបុគ្គលនោះ ដែលទម្លាយរាងកាយបន្ទាប់អំពីសេចក្ដីស្លាប់ទៅ ទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ។

៨១

### វិភង្គវគ្គស្ស មហាកម្មវិភង្គសុត្តេ អភិនិវិស្សវោហារោ

សោ ឯវមាហ យោ កិរ ចាណាតិចាតី អទិន្នាទាយី ។ បេ ។ មិច្ឆាទិដ្ឋី សព្វោ សោ កាយស្ស ភេទា បរម្មរណា អចាយំ ទុក្កតឹ វិនិចាតំ និរយំ ឧបបជ្ជតិ ។ យេ ឯវំ ជានន្តិ តេ សម្មា ជានន្តិ យេ អញ្ញថា ជានន្តិ មិច្ឆា តេសំ ញាណន្តិ ។ ឥតិ សោ យទេវ តស្ស សាមំ ញាតំ សាមំ ទិដ្ឋំ សាមំ វិទិតំ តទេវ តត្ថ ថាមសា បរាមាសា អភិនិវិស្ស វោហរតិ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។

សមណៈឬព្រាហ្មណ៍នោះ ពោលពាក្យយ៉ាងនេះថា អើហ្ន៎ បានឮថា បុគ្គលណា ជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនឲ្យ ។ បេ ។ មានគំនិតយល់ខុស បុគ្គលទាំងអស់នោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ។ បុគ្គលណាដឹងយ៉ាងនេះ បុគ្គលនោះ ឈ្មោះថាដឹងត្រូវ បុគ្គលណា ដឹងផ្សេង (អំពីនេះ) ការដឹងរបស់បុគ្គលនោះ ឈ្មោះថាដឹងខុស ។ សមណព្រាហ្មណ៍នោះ រមែងក្ខចកាន់ ព្រោះស្ទាបអង្អែលនូវហេតុដែលយល់ខ្លួនឯង ឃើញខ្លួនឯង ដឹងច្បាស់ខ្លួនឯងនោះ ដោយកម្លាំងទិដ្ឋិ ហើយពោលថា សេចក្តីយល់នេះឯង ជារបស់ពិត សេចក្តីយល់ដទៃ ជាមោឃៈ ។

[៨០] ឥធ បនានន្ទ ឯកច្ចោ សមណោ វា ព្រាហ្មណោ វា អាតប្បមន្វាយ បធានមន្វាយ អនុយោគមន្វាយ អប្បមាទមន្វាយ សម្មាមនសិការមន្វាយ តថារូបំ ចេតោសមាធឹ ផុសតិ ។ យថាសមាហិតេ ចិត្តេ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន អមុំ បុគ្គលំ បស្សតិ ឥធ បាណាតិបាតឹ អទិន្នាទាយឹ ។ បេ ។ មិច្ឆាទិដ្ឋឹ កាយស្ស ភេទា បរម្មរណា បស្សតិ សុគតឹ សគ្គំ លោកំ ឧបបន្នំ ។ សោ ឯវមាហ នត្ថិ កិរ ភោ បាបកានិ កម្មានិ នត្ថិ ទុច្ចរិតស្ស វិបាកោ អមាហំ បុគ្គលំ អទ្ទសំ ឥធ បាណាតិបាតឹ អទិន្នាទាយឹ ។ បេ ។ មិច្ឆាទិដ្ឋឹ កាយស្ស ភេទា បរម្មរណា បស្សាមិ សុគតឹ សគ្គំ លោកំ ឧបបន្នន្តិ ។ សោ ឯវមាហ យោ កិរ ភោ បាណាតិបាតី អទិន្នាទាយី ។ បេ ។ មិច្ឆាទិដ្ឋី សព្វោ សោ កាយស្ស ភេទា

[៨០] ម្នាលអានន្ទ មួយទៀត សមណៈឬព្រាហ្មណ៍ ពួកមួយ ក្នុងលោកនេះ អាស្រ័យនូវសេចក្តីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស អាស្រ័យនូវសេចក្តីព្យាយាមតម្កល់ចិត្តទុក អាស្រ័យនូវសេចក្តីប្រឹងប្រែង អាស្រ័យនូវសេចក្តីមិនប្រមាទ អាស្រ័យនូវការយកចិត្តទុកដាក់ដោយប្រពៃ រមែងបាននូវចេតោសមាធិ មានសភាពដូច្នោះ ។ កាលបើបានតម្កល់ចិត្តនឹងហើយ សមណៈឬព្រាហ្មណ៍នោះ រមែងឃើញដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុរបស់មនុស្សធម្មតា នូវបុគ្គលឯណោះ ដែលសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ។ បេ ។ មានគំនិតយល់ខុស ក្នុងលោកនេះ រមែងឃើញបុគ្គលនោះ ដែលទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ ទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ សមណៈឬព្រាហ្មណ៍នោះ ពោលយ៉ាងនេះថា អើហ្ន៎ កម្មដ៏លាមកមិនមាន ផលរបស់ទុច្ចរិតក៏មិនមាន ខ្ញុំបានឃើញបុគ្គលឯណោះ ជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ។ បេ ។ មានគំនិតយល់ខុស ក្នុងលោកនេះ បានឃើញបុគ្គលនោះ ដែលទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ ទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ សមណៈឬព្រាហ្មណ៍នោះ ពោលយ៉ាងនេះទៀតថា អើហ្ន៎ បុគ្គលណា ជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យ ដែលគេមិនបានឲ្យ ។ បេ ។ មានគំនិតយល់ខុស បុគ្គលទាំងអស់នោះ លុះទម្លាយរាងកាយ

បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ យេ ឯវំ ជានន្តិ តេ សម្មា ជានន្តិ យេ អញ្ញថា ជានន្តិ មិច្ឆា តេសំ ញាណន្តិ ។ ឥតិ សោ យទេវ តស្ស សាមំ ញាតំ សាមំ ទិដ្ឋំ សាមំ វិទិតំ តទេវ តត្ថ ថាមសា បរាមាសា អភិនិវិស្ស វោហរតិ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។

[៨១] ឥធានន្ទ ឯកច្ចោ សមណោ វា ព្រាហ្ម-ណោ វា អាតប្បមន្វាយ បធានមន្វាយ អនុយោគ-មន្វាយ អប្បមាទមន្វាយ សម្មាមនសិការមន្វាយ តថារូបំ ចេតោសមាធឹ ផុសតិ ។ យថាសមាហិតេ ចិត្តេ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន អមុំ បុគ្គលំ បស្សតិ ឥធ បាណាតិបាតា បដិវិរតំ អ-ទិន្នាទានា បដិវិរតំ កាមេសុមិច្ឆាចារា បដិវិរតំ មុសា-វាទា បដិវិរតំ បិសុណាយ វាចាយ បដិវិរតំ ផរុសាយ វាចាយ បដិវិរតំ សម្ផប្បលាបា បដិវិរតំ អនភិជ្ឈាលុំ

បន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើត ក្នុងសុគតិសួគ៌ទេវលោក ។ បុគ្គលណា ដឹងយ៉ាងនេះ បុគ្គលនោះ ឈ្មោះថាដឹងត្រូវ បុគ្គលណាដឹងផ្សេង (អំពីនេះ) ការដឹងរបស់បុគ្គលនោះ ឈ្មោះថាដឹងខុស ។ សមណព្រាហ្មណ៍នោះ ក្លួចកាន់ ព្រោះស្ទាបអង្អែលនូវហេតុ ដែលយល់ខ្លួនឯង ឃើញខ្លួនឯង ដឹងច្បាស់ខ្លួនឯងនោះ ដោយកម្លាំងទិដ្ឋិ ហើយពោលថា សេចក្តីយល់នេះឯង ជារបស់ពិត សេចក្តីយល់ដទៃជាមោឃៈ ។

[៨១] ម្នាលអានន្ទ សមណៈឬព្រាហ្មណ៍ពួកមួយ ក្នុងលោកនេះ អាស្រ័យនូវសេចក្តីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស អាស្រ័យនូវសេចក្តីព្យាយាមតម្កល់ចិត្តទុក អាស្រ័យនូវសេចក្តីប្រឹងប្រែង អាស្រ័យនូវសេចក្តីមិនប្រមាទ អាស្រ័យនូវការយកចិត្តទុកដាក់ដោយប្រពៃ រមែងបាននូវចេតោសមាធិ មានសភាពដូច្នោះ ។ កាលបើតម្កល់ចិត្តមាំហើយ សមណៈឬព្រាហ្មណ៍នោះ រមែងឃើញ ដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុជារបស់មនុស្សធម្មតា នូវបុគ្គលឯណោះដែលវៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន វៀរស្រឡះចាកកាមេសុមិច្ឆាចារ វៀរស្រឡះចាកមុសាវាទ វៀរស្រឡះចាកបិសុណវាចា វៀរស្រឡះចាកផរុសវាចា វៀរស្រឡះចាកសម្ផប្បលាបៈ ជាអ្នកមានចិត្តមិនបានសំឡឹងរំពៃ ចំពោះទ្រព្យរបស់គេ មានចិត្តមិនព្យាបាទ

អព្យាបន្នចិត្តំ សម្មាទិដ្ឋឹ កាយស្ស ភេទា បរម្មរណា បស្សតិ សុគតឹ សគ្គំ លោកំ ឧបបន្នំ ។ សោ ឯវមាហ អត្ថិ កិរ ភោ កល្យាណានិ កម្មានិ អត្ថិ សុចរិតស្ស វិបាកោ អមាហំ បុគ្គលំ អទ្ទសំ ឥធ ចាណាតិចាតា បដិវិរតំ អទិន្នាទានា បដិវិរតំ ។ បេ ។ សម្មាទិដ្ឋឹ កាយស្ស ភេទា បរម្មរណា បស្សាមិ សុគតឹ សគ្គំ លោកំ ឧបបន្នន្តិ ។ សោ ឯវមាហ យោ កិរ ភោ ចាណាតិចាតា ប-ដិវិរតោ អទិន្នាទានា បដិវិរតោ ។ បេ ។ សម្មាទិដ្ឋី សព្វោ សោ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ យេ ឯវំ ជានន្តិ តេ សម្មា ជានន្តិ យេ អញ្ញថា ជានន្តិ មិច្ឆា តេសំ ញាណន្តិ ។ ឥតិ សោ យទេវ តស្ស សាមំ ញាតំ សាមំ ទិដ្ឋំ សាមំ វិទិតំ តទេវ តត្ថ ថាមសា បរាមា-សា អភិនិវិស្ស វោហរតិ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។

មានគំនិតយល់ត្រូវ ក្នុងលោកនេះ រមែងឃើញបុគ្គលនោះ ដែលទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ ទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ សមណៈឬព្រាហ្មណ៍នោះ ពោលយ៉ាងនេះថា អើហ្ន៎ អំពើជាកុសលក៏មាន ផលរបស់សុចរិតក៏មាន ខ្ញុំបានឃើញបុគ្គលឯណោះ ដែលជាអ្នកវៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន ។ បេ ។ មានគំនិតយល់ត្រូវ ក្នុងលោកនេះ បានឃើញបុគ្គលនោះ ដែលទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ ទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ សមណៈឬព្រាហ្មណ៍នោះ ក៏ពោលយ៉ាងនេះថា អើហ្ន៎ បុគ្គលណា វៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន ។ បេ ។ មានគំនិតយល់ត្រូវ បុគ្គលទាំងអស់នោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ ទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ បុគ្គលណាដឹងយ៉ាងនេះ បុគ្គលនោះឈ្មោះថាដឹងត្រូវ បុគ្គលណាដឹងផ្សេង (អំពីនេះ) ការដឹងរបស់បុគ្គលនោះ ឈ្មោះថាដឹងខុស ។ សមណព្រាហ្មណ៍នោះ រមែងក្ដួចកាន់ ព្រោះស្ទាបអង្អែល នូវហេតុដែលយល់ខ្លួនឯង ឃើញខ្លួនឯង ដឹងច្បាស់ខ្លួនឯងនោះ ដោយកម្លាំងទិដ្ឋិ ហើយពោលថា សេចក្តីយល់នេះឯង ជារបស់ពិត សេចក្តីយល់ដទៃ ជាមោឃៈ ។

[៨២] ឥធ បនានន្ទ ឯកច្ចោ សមណោ វា ព្រាហ្មណោ វា អាតប្បមន្វាយ បធានមន្វាយ អនុយោគមន្វាយ អប្បមាទមន្វាយ សម្មាមនសិការមន្វាយ តថារូបំ ចេតោសមាធឹ ផុសតិ ។ យថាសមាហិតេ ចិត្តេ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន អមុំ បុគ្គលំ បស្សតិ បាណាតិបាតា បដិវិរតំ អទិន្នាទានា បដិវិរតំ ។ បេ ។ សម្មាទិដ្ឋឹ កាយស្ស ភេទា បរម្មរណា បស្សតិ អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នំ ។ សោ ឯវមាហ នត្ថិ កិរ ភោ កល្យាណានិ កម្មានិ នត្ថិ សុចរិតស្ស វិបាកោ អមាហំ បុគ្គលំ អទ្ទសំ ឥធ បាណាតិបាតា បដិវិរតំ អទិន្នាទានា បដិវិរតំ ។ បេ ។ សម្មាទិដ្ឋឹ កាយស្ស ភេទា បរម្មរណា បស្សាមិ អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នន្តិ ។ សោ ឯវមាហ យោ កិរ ភោ បាណាតិបាតា បដិវិរតោ

[៨២] ម្នាលអានន្ទ មួយទៀត សមណៈឬព្រាហ្មណ៍ពួកមួយ ក្នុងលោកនេះ អាស្រ័យនូវសេចក្តីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស អាស្រ័យនូវសេចក្តីព្យាយាមតម្កល់ចិត្តទុក អាស្រ័យនូវសេចក្តីប្រឹងប្រែង អាស្រ័យនូវសេចក្តីមិនប្រមាទ អាស្រ័យនូវការយកចិត្តទុកដាក់ដោយប្រពៃ រមែងបាននូវចេតោសមាធិ មានសភាពដូច្នោះ ។ កាលបើបានតម្កល់ចិត្តនឹងហើយ សមណៈឬព្រាហ្មណ៍នោះ រមែងឃើញដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្លងបង់ចក្ខុរបស់មនុស្សធម្មតា នូវបុគ្គលឯណោះ ដែលវៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន ។ បេ ។ មានគំនិតយល់ត្រូវ រមែងឃើញបុគ្គលនោះ ដែលទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ ទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ។ សមណៈឬព្រាហ្មណ៍នោះ ពោលយ៉ាងនេះថា អើហ្ន៎ អំពើជាកុសលក៏មិនមាន ផលរបស់សុចរិត ក៏មិនមាន ខ្ញុំបានឃើញបុគ្គលឯណោះ ដែលវៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន ។ បេ ។ មានគំនិតយល់ត្រូវ ក្នុងលោកនេះ បានឃើញបុគ្គលនោះ ដែលទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ ទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ។ សមណៈឬព្រាហ្មណ៍នោះពោលយ៉ាងនេះថា អើហ្ន៎ បុគ្គលណា វៀរស្រឡះចាកបាណាតិបាត

អភិជ្ឈាលុ ហោតិ ព្យាបន្នចិត្តោ ។ បេ ។ មិច្ឆាទិដ្ឋិ ហោតិ វិបរីតទស្សនោ ។ សោ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ យេ ឯវំ ជានន្តិ តេ សម្មា ជានន្តិ យេ អញ្ញថា ជានន្តិ មិច្ឆា តេសំ ញាណន្តិ ។ ឥតិ សោ យទេវ តស្ស សាមំ ញាតំ សាមំ ទិដ្ឋំ សាមំ វិទិតំ តទេវ តត្ថ ថាមសា បរាមាសា អភិនិវិស្ស វោហរតិ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។

[៨៣] តត្រានន្ទ យ្វាយំ សមណោ វា ព្រាហ្ម-ណោ វា ឯវមាហ អត្ថិ កិរ ភោ បាបកានិ កម្មានិ អត្ថិ ទុច្ចរិតស្ស វិបាកោតិ ឥទមស្ស អនុជានាមិ ។ យម្បិ សោ ឯវមាហ អហាហំ បុគ្គលំ អទ្ទសំ ឥធ បាណាតិបាតឹ អទិន្នាទាយឹ ។ បេ ។ មិច្ឆាទិដ្ឋឹ

វៀរស្រឡះចាកអទិន្នាទាន ។ បេ ។ មានគំនិតយល់ត្រូវ បុគ្គលទាំងអស់នោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ។ បុគ្គលណា ដឹងយ៉ាងនេះ បុគ្គលនោះ ឈ្មោះថាដឹងត្រូវ បុគ្គលណាដឹងផ្សេង (អំពីនេះ) ការដឹងរបស់បុគ្គលនោះ ឈ្មោះថាដឹងខុស ។ សមណ-ព្រាហ្មណ៍នោះ រមែងស្ទាបអង្អែល ប្រកាន់នូវហេតុដែលយល់ខ្លួនឯង ឃើញខ្លួនឯង ដឹងច្បាស់ខ្លួនឯងនោះ ដោយកម្លាំងទិដ្ឋិ ហើយពោលថា សេចក្តីយល់នេះឯង ជារបស់ពិត សេចក្តីយល់ដទៃ ជាមោឃៈ ។

[៨៣] ម្នាលអានន្ទ បណ្តាសមណព្រាហ្មណ៍ទាំងនោះ សមណៈឬព្រាហ្មណ៍ណា ពោលយ៉ាងនេះថា អើហ្ន៎ អំពើដ៏លាមកក៏មាន ផលរបស់ទុច្ចរិតក៏មាន ដូច្នេះ តថាគតយល់ស្រប តាមពាក្យរបស់ពួកសមណព្រាហ្មណ៍នោះដែរ ។ ទាំងត្រង់សមណព្រាហ្មណ៍នោះពោលពាក្យយ៉ាងនេះថា ខ្ញុំបានឃើញបុគ្គលឯណោះ ដែលជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ។ បេ ។ មានគំនិតយល់ខុស ក្នុងលោកនេះ

កាយស្ស ភេទា បរម្មរណា បស្សាមិ អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នន្តិ ឥទម្បិស្ស អនុជានាមិ ។ យញ្ច ខោ សោ ឯវមាហ យោ កិរ ភោ បាណាតិបាតី អទិន្នាទាយី ។ បេ ។ មិច្ឆា-ទិដ្ឋី សព្វោ សោ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតីតិ ឥទមស្ស នានុជានាមិ ។ យម្បិ សោ ឯវមាហ យេ ឯវំ ជានន្តិ តេ សម្មា ជានន្តិ យេ អញ្ញថា ជានន្តិ មិច្ឆា តេសំ ញាណន្តិ ឥទម្បិស្ស នានុជានាមិ ។ យម្បិ សោ យទេវ តស្ស សាមំ ញាតំ សាមំ ទិដ្ឋំ សាមំ វិទិតំ តទេវ តត្ថ ថាមសា បរាមាសា អភិនិវិស្ស វោហរតិ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឥទម្បិស្ស នានុជានាមិ តំ កិស្ស ហេតុ អញ្ញថា ហិ អានន្ទ តថាគតស្ស មហាកម្មវិភង្គេ ញាណំ ហោតិ ។

បានឃើញបុគ្គលនោះ ដែលទម្លាយរាងកាយបន្ទាប់អំពីសេចក្ដីស្លាប់ទៅ ទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក តថាគត ក៏យល់ស្របតាមពាក្យ របស់សមណព្រាហ្មណ៍នោះដែរ ។ តែត្រង់សមណព្រាហ្មណ៍នោះ ពោលពាក្យយ៉ាងនេះថា អើហ្ន៎ បុគ្គលណាជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ។ បេ ។ មានគំនិតយល់ខុស បុគ្គលទាំងអស់នោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្ដីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរ-កាយ នរក តថាគតមិនយល់ស្របតាមពាក្យរបស់សមណព្រាហ្មណ៍នោះទេ ។ ទាំងត្រង់សមណព្រាហ្មណ៍នោះ ពោលពាក្យយ៉ាងនេះថា បុគ្គលណាដឹងយ៉ាងនេះ បុគ្គលនោះឈ្មោះថាដឹងត្រូវ បុគ្គលណាដឹងផ្សេង (អំពីនេះ) ការដឹងរបស់បុគ្គលនោះ ឈ្មោះថាដឹងខុស តថាគតក៏មិនយល់ស្របតាមពាក្យ របស់សមណព្រាហ្មណ៍នោះដែរ ។ ទាំងត្រង់សមណព្រាហ្មណ៍នោះ ស្ទាបអង្អែលប្រកាន់ នូវហេតុដែលយល់ខ្លួនឯង ឃើញខ្លួនឯង ដឹងច្បាស់ខ្លួនឯងនោះ ដោយកម្លាំងទិដ្ឋិ ហើយពោលថា សេចក្ដីយល់នេះឯង ជារបស់ពិត សេចក្ដីយល់ដទៃជាមោឃៈ តថាគតក៏មិនយល់ស្របតាមពាក្យ របស់សមណព្រាហ្មណ៍នោះទេ ដំណើរនោះ ព្រោះហេតុអ្វី ម្នាលអានន្ទ ព្រោះសត្វតែងមានសេចក្ដីយល់ ក្នុងមហាកម្មវិភង្គ ផ្សេងគ្នា ។

[៨៤] តត្រានន្ទ យ្វាយំ សមណោ វា ព្រាហ្មណោ វា ឯវមាហ នត្ថិ កិរ ភោ បាបកានិ កម្មានិ នត្ថិ ទុច្ចរិតស្ស វិបាកោតិ ឥទមស្ស នានុជានាមិ ។ យញ្ច ខោ សោ ឯវមាហ អមាហំ បុគ្គលំ អទ្ទសំ ឥធ បាណាតិបាតឹ អទិន្នាទាយឹ ។ បេ ។ មិច្ឆាទិដ្ឋឹ កាយស្ស ភេទា បរម្មរណា បស្សាមិ សុគតឹ សគ្គំ លោកំ ឧបបន្នន្តិ ឥទមស្ស អនុជានាមិ ។ យញ្ច ខោ សោ ឯវមាហ យោ កិរ ភោ បាណាតិបាតី អទិន្នាទាយី ។ បេ ។ មិច្ឆាទិដ្ឋី សព្វោ សោ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតីតិ ឥទមស្ស នានុជានាមិ ។ យម្បិ សោ ឯវមាហ យេ ឯវំ ជានន្តិ

[៨៤] ម្នាលអានន្ទ បណ្តាសមណព្រាហ្មណ៍ទាំងនោះ សមណៈឬព្រាហ្មណ៍ណា ពោលយ៉ាងនេះថា អើហ្ន៎ កម្មដ៏លាមកមិនមានទេ ទាំងផលរបស់ទុច្ចរិតក៏មិនមានដែរ តថាគតមិនយល់ស្របតាមពាក្យ របស់សមណព្រាហ្មណ៍នោះទេ ។ តែត្រង់សមណព្រាហ្មណ៍នោះ ពោលយ៉ាងនេះថា យើងបានឃើញបុគ្គលឯណោះ ដែលជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ។ បេ ។ មានគំនិតយល់ខុសក្នុងលោកនេះ បានឃើញបុគ្គលនោះ ដែលទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ ទៅកើតក្នុងសុគតិសួគ៌ទេវលោក តថាគតយល់ស្របតាមពាក្យរបស់សមណ-ព្រាហ្មណ៍នោះ[១] ។ ឯត្រង់សមណព្រាហ្មណ៍នោះ ពោលពាក្យយ៉ាងនេះថា អើហ្ន៎ បុគ្គលណាជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ។ បេ ។ មានគំនិតយល់ខុស បុគ្គលទាំងអស់នោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក តថាគតមិនយល់ស្របតាមពាក្យ របស់សមណព្រាហ្មណ៍នោះទេ ។ ទាំងត្រង់សមណព្រាហ្មណ៍នោះពោលពាក្យយ៉ាងនេះថា បុគ្គលណាដឹងយ៉ាង

---

១ បានជាទ្រង់យល់ស្រប ព្រោះទ្រង់ជ្រាបច្បាស់ថា ទោះបីធ្វើអកុសលមកពីដើមក៏ពិត តែដល់វេលាជិតស្លាប់ ជួនមានកុសលណាមួយមកឲ្យផល កុសលនោះក៏អាចជ្រែកអកុសលបាន ទើបទៅកើតក្នុងសុគតិភព ។

តេ សម្មា ជានន្តិ យេ អញ្ញថា ជានន្តិ មិច្ឆា តេសំ ញាណន្តិ ឥទម្បិស្ស ជានុជានាមិ ។ យម្បិ សោ យទេវ តស្ស សាមំ ញាតំ សាមំ ទិដ្ឋំ សាមំ វិទិតំ តទេវ តត្ថ ថាមសា បរាមាសា អភិនិវិស្ស វោហរតិ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឥទម្បិស្ស ជានុជានាមិ តំ កិស្ស ហេតុ អញ្ញថា ហិ អានន្ទ តថាគតស្ស មហាកម្មវិភង្គេ ញាណំ ហោតិ ។

[៨៥] តត្រានន្ទ យ្វាយំ សមណោ វា ព្រាហ្មណោ វា ឯវមាហ អត្ថិ កិរ ភោ កល្យាណានិ កម្មានិ អត្ថិ សុចរិតស្ស វិបាកោតិ ឥទមស្ស អនុជានាមិ ។ យម្បិ(១) សោ ឯវមាហ អមាហំ បុគ្គលំ ឥធ បាណាតិបាតា បដិវិរតំ អទិន្នាទានា បដិវិរតំ ។ បេ ។ សម្មាទិដ្ឋឹ

---

១ ឱ. យញ្ច ខោ ។

នេះ បុគ្គលនោះឈ្មោះថាដឹងត្រូវ បុគ្គលណាដឹងផ្សេង (អំពីនេះ) ការដឹងរបស់បុគ្គលនោះ ឈ្មោះថាដឹងខុស តថាគតក៏មិនយល់ស្របតាមពាក្យរបស់សមណព្រាហ្មណ៍នោះទេ ។ តែត្រង់សមណព្រាហ្មណ៍នោះ ស្ទាបអង្អែល ប្រកាន់នូវហេតុដែលយល់ខ្លួនឯង ឃើញខ្លួនឯង ដឹងច្បាស់ខ្លួនឯងនោះ ដោយកម្លាំងទិដ្ឋិ ហើយពោលថា សេចក្តីយល់នេះឯងជារបស់ពិត សេចក្តីយល់ដទៃ ជាមោឃៈ តថាគតមិនយល់ស្របតាមពាក្យរបស់សមណព្រាហ្មណ៍នោះទេ ដំណើរនោះ ព្រោះហេតុអ្វី ម្នាលអានន្ទ ព្រោះសត្វ តែងមានសេចក្តីយល់ក្នុងមហាកម្មវិភង្គ ផ្សេងគ្នា ។

[៨៥] ម្នាលអានន្ទ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ សមណៈឬព្រាហ្មណ៍ណា ពោលយ៉ាងនេះថា អើហ្ន៎ អំពើជាកុសលក៏មានផលរបស់សុចរិតក៏មាន តថាគតយល់ស្របតាមពាក្យរបស់សមណ-ព្រាហ្មណ៍នោះ ។ ទាំងត្រង់សមណព្រាហ្មណ៍នោះ ពោលពាក្យយ៉ាងនេះថា ខ្ញុំឃើញបុគ្គលឯណោះ ជាអ្នកវៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន ។ បេ ។ មានគំនិតយល់ត្រូវ ក្នុងលោកនេះ

៩០

កាយស្ស ភេទា បរម្មរណា បស្សាមិ សុគតឹ សគ្គំ លោកំ ឧបបន្នន្តិ ឥទម្បិស្ស អនុជានាមិ ។ យញ្ច ខោ សោ ឯវមាហ យោ កិរ ភោ បាណាតិបាតា បដិវិរតោ អទិន្នាទានា បដិវិរតោ ។ បេ ។ សម្មាទិដ្ឋី សព្វោ សោ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតីតិ ឥទមស្ស អនុជានាមិ ។ យម្បិ សោ ឯវមាហ យេ ឯវំ ជានន្តិ តេ សម្មា ជានន្តិ យេ អញ្ញថា ជានន្តិ មិច្ឆា តេសំ ញាណន្តិ ឥទម្បិស្ស នានុជានាមិ ។ យម្បិ សោ យទេវ តស្ស សាមំ ញាតំ សាមំ ទិដ្ឋំ សាមំ វិទិតំ តទេវ តត្ថ ថាមសា បរាមាសា អភិនិវិស្ស វោហរតិ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឥទម្បិស្ស នានុជានាមិ តំ កិស្ស ហេតុ អញ្ញថា ហិ អានន្ទ តថាគតស្ស មហាកម្មវិភង្គេ ញាណំ ហោតិ ។

បានឃើញបុគ្គលនោះ ដែលទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ ទៅកើតក្នុងសុគតិសួគ៌ទេវលោក តថាគតក៏យល់ស្របតាមពាក្យ របស់សមណព្រាហ្មណ៍នោះ ។ ទាំងត្រង់សមណព្រាហ្មណ៍នោះ ពោលពាក្យយ៉ាងនេះថា អើហ្ន៎ បុគ្គលណា វៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន ។ បេ ។ មានគំនិតយល់ត្រូវ បុគ្គលទាំងអស់នោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក តថាគតក៏យល់ស្របតាមពាក្យ របស់សមណព្រាហ្មណ៍នោះដែរ ។ ឯត្រង់សមណព្រាហ្មណ៍នោះ ពោលពាក្យយ៉ាងនេះថា បុគ្គលណាដឹងយ៉ាងនេះ បុគ្គលនោះឈ្មោះថាដឹងត្រូវ បុគ្គលណាដឹងផ្សេង (អំពីនេះ) ការដឹងរបស់បុគ្គលនោះ ឈ្មោះថាដឹងខុស តថាគតមិនយល់ស្របតាមពាក្យ របស់សមណព្រាហ្មណ៍នោះទេ ។ ទាំងត្រង់បុគ្គលនោះ ស្ទាបអង្អែលប្រកាន់ នូវហេតុដែលយល់ខ្លួនឯង ឃើញខ្លួនឯង ដឹងច្បាស់ខ្លួនឯងនោះ ដោយកម្លាំងទិដ្ឋិ ហើយពោលថា សេចក្តីយល់នេះឯង ជារបស់ពិត សេចក្តីយល់ដទៃ ជាមោឃៈ តថាគតមិនយល់ស្របតាមពាក្យ របស់សមណព្រាហ្មណ៍នោះទេ ដំណើរនោះព្រោះហេតុអ្វី ម្នាលអានន្ទ ព្រោះសត្វតែងមានសេចក្តីយល់ ក្នុងមហាកម្មវិភង្គ ផ្សេងគ្នា ។

[៨៦] តត្រានន្ទ យ្វាយំ សមណោ វា ព្រាហ្មណោ វា ឯវមាហ នត្ថិ កិរ ភោ កល្យាណានិ កម្មានិ នត្ថិ សុចរិតស្ស វិបាកោតិ ឥទមស្ស នានុជានាមិ ។ យញ្ច ខោ សោ ឯវមាហ អមាហំ បុគ្គលំ អទ្ទសំ ឥធ បាណាតិបាតា បដិវិរតំ អទិន្នាទានា បដិវិរតំ ។ បេ ។ សម្មាទិដ្ឋឹ កាយស្ស ភេទា បរម្មរណា បស្សាមិ អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នន្តិ ឥទមស្ស អនុជានាមិ ។ យញ្ច ខោ សោ ឯវមាហ យោ កិរ ភោ បាណាតិបាតា បដិវិរតោ អទិន្នាទានា បដិវិរតោ ។ បេ ។ សម្មាទិដ្ឋី សព្វោ សោ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧប-បជ្ជតីតិ ឥទមស្ស នានុជានាមិ ។ យម្បិ សោ ឯ-វមាហ យេ ឯវំ ជានន្តិ តេ សម្មា ជានន្តិ យេ

[៨៦] ម្នាលអានន្ទ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ សមណៈឬព្រាហ្មណ៍ណា ពោលពាក្យយ៉ាងនេះថា អើហ្ន៎ អំពើជាកុសលមិនមាន ផលរបស់សុចរិតក៏មិនមាន តថាគតមិនយល់ស្របតាមពាក្យរបស់សមណព្រាហ្មណ៍នោះទេ ។ តែត្រង់សមណព្រាហ្មណ៍នោះពោលពាក្យយ៉ាងនេះថា ខ្ញុំឃើញបុគ្គលឯណោះ ក្នុងលោកនេះ ជាអ្នកវៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន ។ បេ ។ មានគំនិតយល់ត្រូវ រមែងឃើញបុគ្គលនោះ ដែលទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ ទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយនរក តថាគតយល់ស្របតាមពាក្យរបស់សមណព្រាហ្មណ៍នោះ[១] ។ ឯត្រង់សមណព្រាហ្មណ៍នោះពោលពាក្យយ៉ាងនេះថា អើហ្ន៎ បុគ្គលណាជាអ្នកវៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន ។ បេ ។ មានគំនិតយល់ត្រូវ បុគ្គលទាំងអស់នោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយនរក តថាគតមិនយល់ស្របតាមពាក្យរបស់សមណព្រាហ្មណ៍នោះទេ ។ ទាំងត្រង់សមណព្រាហ្មណ៍នោះ ពោលពាក្យយ៉ាងនេះថា បុគ្គលណាដឹង

---

១ បានជាទ្រង់យល់តាម ព្រោះទ្រង់ជ្រាបច្បាស់ថា ទោះបីធ្វើកុសលមកពីដើមក៏ពិត តែដល់វេលាជិតស្លាប់ ចួនមានអកុសលណាមួយមកឲ្យផល អកុសលនោះអាចជ្រែកកុសលបាន ទើបបានទៅកើតក្នុងទុគ្គតិភព ។

អញ្ញថា ជានន្តិ មិច្ឆា តេសំ ញាណន្តិ ឥទម្បិស្ស ជានុជានាមិ ។ យម្បិ សោ យទេវ តស្ស សាមំ ញាតំ សាមំ ទិដ្ឋំ សាមំ វិទិតំ តទេវ តត្ថ ថាមសា បរាមាសា អភិនិវិស្ស វោហរតិ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឥទម្បិស្ស ជានុជានាមិ តំ កិស្ស ហេតុ អញ្ញថា ហិ អានន្ទ តថាគតស្ស មហា-កម្មវិភង្គេ ញាណំ ហោតិ ។

[៨៧] តត្រានន្ទ យ្វាយំ បុគ្គលោ ឥធ បាណាតិ-បាតី អទិន្នាទាយី ។ បេ ។ មិច្ឆាទិដ្ឋី កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ បុព្វេ វាស្ស តំ កតំ ហោតិ បាបកម្មំ ទុក្ខវេទនីយំ

យ៉ាងនេះ បុគ្គលនោះឈ្មោះថាដឹងត្រូវ បុគ្គលណាដឹងផ្សេង (អំពីនេះ) ការដឹងរបស់បុគ្គលនោះ ឈ្មោះថាដឹងខុស តថាគតក៏មិនយល់ស្របតាមពាក្យរបស់សមណព្រាហ្មណ៍នោះទេ ។ ទាំងត្រង់សមណព្រាហ្មណ៍នោះស្ទាបអង្អែល ប្រកាន់នូវហេតុដែលយល់ខ្លួនឯង ឃើញខ្លួនឯង ដឹងច្បាស់ខ្លួនឯងនោះ តាមកម្លាំងទិដ្ឋិ ហើយពោលថា សេចក្តីយល់នេះឯង ជារបស់ពិត សេចក្តីយល់ដទៃ ជាមោឃៈ តថាគតមិនយល់ស្របតាមពាក្យរបស់បុគ្គលនោះទេ ដំណើរនោះ ព្រោះហេតុអ្វី ម្នាលអានន្ទ ព្រោះសត្វតែងមានសេចក្តីយល់ ក្នុងមហាកម្មវិភង្គ ផ្សេងគ្នា ។

[៨៧] ម្នាលអានន្ទ បណ្តាពួកបុគ្គលទាំងនោះ បុគ្គលណាក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ។ បេ ។ មានគំនិតយល់ខុស លុះទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក បាបកម្មនោះ ដែលបុគ្គលនោះបានធ្វើក្នុងកាលមុន ក៏ជាហេតុនៃទុក្ខវេទនា

បច្ឆា វាស្ស តំ កតំ ហោតិ បាបកម្មំ ទុក្ខវេទនីយំ មរណកាលេ វាស្ស ហោតិ មិច្ឆាទិដ្ឋិ សមត្តា សមាទិន្នា តេន សោ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ យញ្ច ខោ សោ ឥធ បាណាតិបាតី ហោតិ អទិន្នាទាយី ហោតិ ។ បេ ។ មិច្ឆាទិដ្ឋី ហោតិ ។ តស្ស ទិដ្ឋេវ ធម្មេ វិបាកំ បដិសំវេទេតិ ឧបបជ្ជេ[១] វា អបរេ វា បរិយាយេ ។

[៨៨] តត្រានន្ទ យ្វាយំ បុគ្គលោ ឥធ បាណាតិបាតី អទិន្នាទាយី ។ បេ ។ មិច្ឆាទិដ្ឋី កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ បុព្វេ វាស្ស តំ កតំ ហោតិ កល្យាណកម្មំ សុខវេទនីយំ បច្ឆា វាស្ស តំ កតំ ហោតិ កល្យាណកម្មំ សុខវេទនីយំ

១ ឱ. ឧប្បជ្ជំ ។

បាបកម្មនោះ ដែលបុគ្គលនោះបានធ្វើក្នុងខាងក្រោយ ក៏ជាហេតុនៃទុក្ខ-វេទនាដែរ មិច្ឆាទិដ្ឋិដែលបុគ្គលនោះបានធ្វើឲ្យបរិបូណ៌ បានសមាទាន ហើយក្នុងពេលជិតស្លាប់ ដោយអំពើនោះ បុគ្គលនោះ លុះទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ។ បុគ្គលនោះ សម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ។ បេ ។ មានគំនិតយល់ខុស ក្នុងលោកនេះ ដោយហេតុណា ។ បុគ្គលនោះ រមែងទទួលវិបាករបស់ហេតុនោះ ក្នុងបច្ចុប្បន្ននេះ ឬក្នុងជាតិជាលំដាប់ ឬក្នុងអត្តភាពជាខាងក្រោយ ៗ មក ។

[៨៨] ម្នាលអានន្ទ បណ្តាបុគ្គលទាំងនោះ បុគ្គលណា ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ។ បេ ។ មានគំនិតយល់ខុស លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក អំពើជាកុសលនោះ ដែលបុគ្គលនោះធ្វើក្នុងកាលមុន ក៏ជាហេតុនៃសុខវេទនា អំពើជាកុសលនោះ ដែលបុគ្គលនោះធ្វើខាងក្រោយ ក៏ជាហេតុនៃសុខវេទនាដែរ

មរណកាលេ វាស្ស ហោតិ សម្មាទិដ្ឋិ សមត្តា សមាទិន្នា តេន សោ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ យញ្ច[១] ខោ សោ ឥធ បាណាតិបាតី ហោតិ អទិន្នាទាយី ហោតិ ។ បេ ។ មិច្ឆាទិដ្ឋី ហោតិ ។ តស្ស ទិដ្ឋេវ ធម្មេ វិបាកំ បដិសំវេទេតិ ឧបបជ្ជេ វា អបរេ វា បរិយាយេ ។

[៨៩] តត្រានន្ទ យ្វាយំ បុគ្គលោ ឥធ បាណាតិបាតា បដិវិរតោ អទិន្នាទានា បដិវិរតោ ។ បេ ។ សម្មាទិដ្ឋី កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ បុព្វេ វាស្ស តំ កតំ ហោតិ កល្យាណកម្មំ សុខវេទនីយំ បច្ឆា វាស្ស តំ កតំ ហោតិ កល្យាណកម្មំ សុខវេទនីយំ មរណកាលេ វាស្ស ហោតិ សម្មាទិដ្ឋិ សមត្តា សមាទិន្នា តេន សោ

---

១ ឱ. សចេ ។

សម្មាទិដ្ឋិដែលបុគ្គលធ្វើឲ្យបរិបូណ៌ហើយ បានសមាទានហើយក្នុងកាលជិតស្លាប់ ព្រោះអំពើនោះ បុគ្គលនោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ ព្រោះហេតុតែ បុគ្គលនោះ ជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ។ បេ ។ មានគំនិតយល់ខុស ក្នុងលោកនេះ ។ បានជាបុគ្គលនោះ ទទួលវិបាករបស់កម្មនោះ ក្នុងបច្ចុប្បន្ន ឬក្នុងជាតិជាលំដាប់ ឬក៏ក្នុងអត្តភាពជាខាងក្រោយ ៗ មក ។

[៨៩] ម្នាលអានន្ទ បណ្តាបុគ្គលទាំងនោះ បុគ្គលណាក្នុងលោកនេះ ជាអ្នកវៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន ។ បេ ។ មានគំនិតយល់ត្រូវ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក អំពើជាកុសលនោះ ដែលបុគ្គលនោះធ្វើក្នុងកាលមុន ក៏ជាហេតុនៃសុខវេទនា អំពើជាកុសលនោះ ដែលបុគ្គលនោះធ្វើក្នុងខាងក្រោយ ក៏ជាហេតុនៃសុខវេទនាដែរ សម្មាទិដ្ឋិ ដែលបុគ្គលនោះបានធ្វើឲ្យបរិបូណ៌ហើយ បានសមាទានហើយ ក្នុងកាលជិតស្លាប់ ព្រោះអំពើនោះ បុគ្គលនោះ

កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ ។ យញ្ច ខោ សោ ឥធ ចាណាតិចាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ ។ បេ ។ សម្មាទិដ្ឋី ហោតិ ។ តស្ស ទិដ្ឋេវ ធម្មេ វិចាកំ បដិសំវេទេតិ ឧបបជ្ជេ វា អបរេ វា បរិយាយេ ។

[៩០] តត្រានន្ទ យ្វាយំ បុគ្គលោ ឥធ ចាណាតិចាតា បដិវិរតោ អទិន្នាទានា បដិវិរតោ ។ បេ ។ សម្មាទិដ្ឋី កាយស្ស ភេទា បរម្មរណា អចាយំ ទុគ្គតឹ វិនិចាតំ និរយំ ឧបបជ្ជតិ បុព្វេ វាស្ស តំ កតំ ហោតិ ចាបកម្មំ ទុក្ខវេទនីយំ បច្ឆា វាស្ស តំ កតំ ហោតិ ចាបកម្មំ ទុក្ខវេទនីយំ មរណកាលេ វាស្ស ហោតិ មិច្ឆាទិដ្ឋិ សមត្តា សមាទិន្នា តេន សោ កាយស្ស ភេទា បរម្មរណា អចាយំ ទុគ្គតឹ វិនិចាតំ និរយំ ឧបបជ្ជតិ ។ យញ្ច ខោ សោ ឥធ ចាណាតិចាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ ។ បេ ។

លុះទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ ព្រោះហេតុតែបុគ្គលនោះ វៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន ។ បេ ។ មានគំនិតយល់ត្រូវ ក្នុងលោកនេះ ។ បានជាបុគ្គលនោះ ទទួលនូវវិបាករបស់កម្មនោះ ក្នុងបច្ចុប្បន្ន ឬក្នុងជាតិជាលំដាប់ ឬក៏ក្នុងអត្តភាពខាងក្រោយ ៗ មក ។

[៩០] ម្នាលអានន្ទ បណ្តាបុគ្គលទាំងនោះ បុគ្គលណា ក្នុងលោកនេះ ជាអ្នកវៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន ។ បេ ។ មានគំនិតយល់ត្រូវ លុះទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក បាបកម្មនោះ ដែលបុគ្គលនោះបានធ្វើក្នុងកាលមុន ក៏ជាហេតុនៃទុក្ខវេទនា បាបកម្មនោះ ដែលបុគ្គលនោះធ្វើខាងក្រោយ ក៏ជាហេតុនៃទុក្ខវេទនាដែរ មិច្ឆាទិដ្ឋិដែលបុគ្គលនោះបានធ្វើឲ្យបរិបូណ៌ហើយ បានសមាទានហើយ ក្នុងកាលជិតស្លាប់ ព្រោះអំពើនោះ បុគ្គលនោះ លុះទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ។ ព្រោះហេតុតែបុគ្គលនោះ វៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន ។ បេ ។

សម្មាទិដ្ឋី ហោតិ ។ តស្ស ទិដ្ឋេវ ធម្មេ វិបាកំ បដិសំវេទេតិ ឧបបជ្ជេ វា អបរេ វា បរិយាយេ ។

[៩១] ឥតិ ខោ អានន្ទ អត្ថិ កម្មំ អភព្វំ អភព្វាភាសំ អត្ថិ កម្មំ អភព្វំ ភព្វាភាសំ អត្ថិ កម្មំ ភព្វញ្ចេវ ភព្វាភាសញ្ច អត្ថិ កម្មំ ភព្វំ អភព្វាភាសន្តិ ។ ឥទមវោច ភគវា អត្តមនោ អាយស្មា អានន្ទោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

មហាកម្មវិភង្គសុត្តំ ឆដ្ឋំ និដ្ឋិតំ ។

មានគំនិតយល់ត្រូវ ក្នុងលោកនេះ ។ បានជាបុគ្គលនោះ ទទួលនូវវិបាករបស់កម្មនោះ ក្នុងបច្ចុប្បន្ន ឬក្នុងជាតិជាលំដាប់ ឬក៏ក្នុងអត្តភាពជាខាងក្រោយ ៗ មក ។

[៩១] ម្នាលអានន្ទ ព្រោះហេតុនេះ កម្មមិនគួរ ឃាត់កម្មមិនគួរក៏មាន កម្មមិនគួរ ឃាត់កម្មគួរក៏មាន កម្មគួរ ឃាត់កម្មគួរក៏មាន កម្មគួរ ឃាត់កម្មមិនគួរក៏មាន ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ ព្រះអានន្ទមានអាយុ ក៏មានចិត្តត្រេកអររីករាយ នឹងភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ មហាកម្មវិភង្គសូត្រ ទី ៦ ។

# សត្តមំ សឡាយតនវិភង្គសុត្តំ

[៩២] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អា-
រាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខ-
វោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោ-
សុំ ។ ភគវា ឯតទវោច សឡាយតនវិភង្គំ វោ ភិក្ខវេ ទេសិស្សាមិ តំ សុណាថ សាធុកំ មនសិ-
ករោថ ភាសិស្សាមីតិ ។ ឯវម្ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

[៩៣] ភគវា ឯតទវោច ឆ អជ្ឈត្តិកានិ អាយតនានិ វេទិតព្វានិ ឆ ពាហិរានិ អាយត-
នានិ វេទិតព្វានិ ឆ វិញ្ញាណកាយា វេទិតព្វា ឆ ផស្សកាយា វេទិតព្វា អដ្ឋារស មនោបវិចារា វេទិ-
តព្វា ឆត្តឹស សត្តបទា វេទិតព្វា តត្រិទំ និស្សា-
យ ឥទំ បជហថ តយោ សតិប្បដ្ឋានា យ-
ទរិយោ សេវតិ យទរិយោ សេវមានោ សត្ថា

# សឡាយតនវិភង្គសូត្រ ទី ៧

[៩២] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយ ក្នុងទីនោះឯងថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងសឡាយ-តនវិភង្គ (ចំណែកអាយតនៈទាំង ៦) ដល់អ្នកទាំងឡាយ ចូរអ្នកទាំង-ឡាយប្រុងស្តាប់ នូវសឡាយតនវិភង្គនោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ភិក្ខុទាំងនោះ ក៏ទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[៩៣] ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា បុគ្គលគប្បីដឹងអាយតនៈខាងក្នុង ៦ គប្បីដឹងអាយតនៈខាងក្រៅ ៦ គប្បីដឹងកងនៃវិញ្ញាណ ៦ គប្បីដឹងកងនៃផស្សៈ ៦ គប្បីដឹងមនោបវិចារៈ (សេចក្តីពិចារណានៃចិត្ត) ១៨ គប្បីដឹងសត្តបទ (ចំណែកនៃសត្វដែលអាស្រ័យនូវវដ្តៈនិងវិវដ្តៈ) ៣៦ បណ្តាធម៌ទាំងនោះ អ្នកទាំងឡាយចូរអាស្រ័យនូវធម៌នេះ ហើយលះបង់ធម៌នេះចេញ ឯសតិប្បដ្ឋានមាន ៣ ប្រការ ជាធម៌ដែលសាស្តាដ៏ប្រសើរតែងសេព កាលសាស្តាដ៏ប្រសើរសេពហើយ

គណាមនុសាសិតុមរហតិ សោ វុច្ចតិ យោគ្គាចរិយានំ អនុត្តរោ បុរិសទម្មសារថីតិ អយមុទ្ទេសោ សឡាយតនវិភង្គស្ស ។

[៩៦] ឆ អជ្ឈត្តិកានិ អាយតនានិ វេទិតព្វានីតិ ឥតិ ខោ បនេតំ វុត្តំ ។ កិញ្ចេតំ បដិច្ច វុត្តំ ។ ចក្ខាយតនំ[១] សោតាយតនំ ឃានាយតនំ ជិវ្ហាយតនំ កាយាយតនំ មនាយតនំ ។ ឆ អជ្ឈត្តិកានិ អាយតនានិ វេទិតព្វានីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

[៩៤] ឆ ពាហិរានិ អាយតនានិ វេទិតព្វានីតិ ឥតិ ខោ បនេតំ វុត្តំ ។ កិញ្ចេតំ បដិច្ច វុត្តំ ។ រូបាយតនំ សទ្ទាយតនំ គន្ធាយតនំ រសាយតនំ ផោដ្ឋព្វាយតនំ ធម្មាយតនំ ។

---

១ ឱ. ចក្ខាយតនំ ។

ទើបគួរប្រៀនប្រដៅនូវគណៈបាន សាស្តានោះ តថាគតពោលថា ជាសារថីអ្នកទូន្មាននូវបុរស ជាអាចារ្យដ៏ប្រសើរ ជាង៏អាចារ្យអ្នកបង្ហាត់នូវវាហនៈមានដំរីជាដើម នេះជាឧទ្ទេស របស់សឡាយតនវិភង្គ ។

[៩៤] ពាក្យថា បុគ្គលគប្បីដឹងអាយតនៈខាងក្នុង ៦ ដូច្នេះនេះ តថាគតបានពោលហើយ ។ ចុះពាក្យនុ៎ះ តថាគតពោលព្រោះអាស្រ័យអ្វី ។ អាយតនៈ (អណ្តូងជាទីកើតនៃអារម្មណ៍) គឺភ្នែក ១ អាយតនៈគឺត្រចៀក ១ អាយតនៈគឺច្រមុះ ១ អាយតនៈគឺអណ្តាត ១ អាយតនៈគឺកាយ ១ អាយតនៈគឺចិត្ត ១ ។ ពាក្យណា ដែលតថាគតពោលហើយថា បុគ្គលគប្បីដឹងអាយតនៈខាងក្នុង ៦ ដូច្នេះ ពាក្យនុ៎ះ តថាគតពោលព្រោះអាស្រ័យ នូវហេតុនេះឯង ។

[៩៥] ពាក្យថា បុគ្គលគប្បីដឹងអាយតនៈខាងក្រៅ ៦ ដូច្នេះនេះ តថាគតបានពោលហើយ ។ ចុះពាក្យនុ៎ះ តថាគតពោលព្រោះអាស្រ័យអ្វី ។ អាយតនៈ គឺរូប ១ អាយតនៈ គឺសំឡេង ១ អាយតនៈ គឺក្លិន ១ អាយតនៈ គឺរស ១ អាយតនៈ គឺផោដ្ឋព្វៈ ១ អាយតនៈ គឺធម៌ ១ ។

ធ ពាហិរានិ អាយតនានិ វេទិតព្វានីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

[៩៦] ឆ វិញ្ញាណកាយា វេទិតព្វាតិ ឥតិ ខោ បនេតំ វុត្តំ ។ កិញ្ចេតំ បដិច្ច វុត្តំ ។ ចក្ខុវិញ្ញាណំ សោតវិញ្ញាណំ ឃានវិញ្ញាណំ ជិវ្ហាវិញ្ញាណំ កាយ-វិញ្ញាណំ មនោវិញ្ញាណំ ។ ឆ វិញ្ញាណកាយា វេទិ-តព្វាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

[៩៧] ឆ ផស្សកាយា វេទិតព្វាតិ ឥតិ ខោ បនេតំ វុត្តំ ។ កិញ្ចេតំ បដិច្ច វុត្តំ ។ ចក្ខុសម្ផស្សោ សោតសម្ផស្សោ ឃានសម្ផស្សោ ជិវ្ហាសម្ផស្សោ កា-យសម្ផស្សោ មនោសម្ផស្សោ ។ ឆ ផស្សកាយា វេទិតព្វាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

ពាក្យណា ដែលតថាគតពោលហើយថា បុគ្គលគប្បីដឹងអាយតនៈខាងក្រៅ ៦ ដូច្នេះ ពាក្យនុ៎ះ តថាគតពោលព្រោះអាស្រ័យ នូវហេតុនេះឯង ។

[៩៦] ពាក្យថា បុគ្គលគប្បីដឹងកងនៃវិញ្ញាណ ៦ ដូច្នេះនេះ តថាគតបានពោលហើយ ។ ចុះពាក្យនុ៎ះ តថាគតពោល ព្រោះអាស្រ័យអ្វី ។ ចក្ខុវិញ្ញាណ (សេចក្តីដឹងតាមទ្វារភ្នែក) ១ សោត-វិញ្ញាណ ១ ឃានវិញ្ញាណ ១ ជិវ្ហាវិញ្ញាណ ១ កាយវិញ្ញាណ ១ មនោវិញ្ញាណ ១ ។ ពាក្យណា ដែលតថាគតពោលហើយថា បុគ្គលគប្បីដឹងកងនៃវិញ្ញាណ ៦ ដូច្នេះ ពាក្យនុ៎ះ តថាគតពោល ព្រោះអាស្រ័យនូវហេតុនេះឯង ។

[៩៧] ពាក្យថា បុគ្គលគប្បីដឹងកងនៃផស្សៈ ៦ ដូច្នេះនេះ តថាគតបានពោលហើយ ។ ចុះពាក្យនុ៎ះ តថាគតពោលព្រោះអាស្រ័យអ្វី ។ ចក្ខុសម្ផស្ស (អារម្មណ៍ដែលប៉ះពាល់ដោយភ្នែក) ១ សោតសម្ផស្ស ១ ឃានសម្ផស្ស ១ ជិវ្ហាសម្ផស្ស ១ កាយសម្ផស្ស ១ មនោសម្ផស្ស ១ ពាក្យណា ដែលតថាគតពោលហើយថា បុគ្គលគប្បីដឹងកងនៃផស្សៈ ៦ ដូច្នេះ ពាក្យនុ៎ះ តថាគតពោលព្រោះអាស្រ័យ នូវហេតុនេះឯង ។

[៩៨] អដ្ឋារស មនោបវិចារា វេទិតព្វាតិ ឥតិ ខោ បនេតំ វុត្តំ ។ កិញ្ចេតំ បដិច្ច វុត្តំ ។ ចក្ខុនា រូបំ ទិស្វា សោមនស្សដ្ឋានីយំ រូបំ ឧបវិចរតិ ទោមនស្សដ្ឋានីយំ រូបំ ឧបវិចរតិ ឧបេក្ខដ្ឋានីយំ រូបំ ឧបវិចរតិ ។ សោតេន សទ្ទំ សុត្វា... ឃានេន គន្ធំ ឃាយិត្វា... ជិវ្ហាយ រសំ សាយិត្វា... កាយេន ផោដ្ឋព្វំ ផុសិត្វា... មនសា ធម្មំ វិញ្ញាយ សោមនស្សដ្ឋានីយំ ធម្មំ ឧបវិចរតិ ទោមនស្សដ្ឋានីយំ ធម្មំ ឧបវិចរតិ ឧបេក្ខដ្ឋានីយំ ធម្មំ ឧបវិចរតិ ។ ឥតិ ឆ សោមនស្សុបវិចារា ឆ ទោមនស្សុបវិចារា ឆ ឧបេក្ខុបវិចារា ។ អដ្ឋារស មនោបវិចារា វេទិតព្វាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

[៩៨] ពាក្យថា បុគ្គល គប្បីដឹងមនោបវិចារៈទាំង ១៨ ដូច្នេះ នេះ តថាគតបានពោលហើយ ។ ចុះពាក្យនុ៎ះ តថាគតពោលព្រោះអាស្រ័យអ្វី ។ បុគ្គលឃើញរូបដោយភ្នែកហើយ ក៏ពិចារណានូវរូបជាទីតាំងនៃសោមនស្ស ពិចារណានូវរូបជាទីតាំងនៃទោមនស្ស ពិចារណានូវរូបជាទីតាំងនៃឧបេក្ខា ។ ឮសំឡេងដោយត្រចៀក... ធុំក្លិនដោយច្រមុះ... ទទួលរសដោយអណ្តាត... ប៉ះពាល់ផោដ្ឋព្វៈដោយកាយ... ដឹងនូវធម៌ដោយចិត្តហើយ ក៏ពិចារណានូវធម៌ជាទីតាំងនៃសោមនស្ស ពិចារណានូវធម៌ជាទីតាំងនៃទោមនស្ស ពិចារណានូវធម៌ជាទីតាំងនៃឧបេក្ខា ។ សោមនស្សូបវិចារៈ (សេចក្តីពិចារណាដោយសោមនស្ស) មាន ៦ ទោមនស្សូបវិចារៈ មាន ៦ ឧបេក្ខូបវិចារៈ មាន ៦ (រួមគ្នាត្រូវជា ១៨) ដោយប្រការដូច្នេះ ។ ពាក្យណា ដែលតថាគតបានពោលហើយថា បុគ្គលគប្បីដឹងមនោបវិចារៈ ទាំង ១៨ ដូច្នេះ ពាក្យនុ៎ះ តថាគតពោលព្រោះអាស្រ័យ នូវហេតុនេះឯង ។

[៩៩] ឆត្តឹស សត្តបទា វេទិតព្វាតិ ឥតិ ខោ បនេតំ វុត្តំ ។ កិញ្ចេតំ បដិច្ច វុត្តំ ។ ឆ គេហសិតានិ សោមនស្សានិ ឆ នេក្ខម្មសិតានិ សោមនស្សានិ ឆ គេហសិតានិ ទោមនស្សានិ ឆ នេក្ខម្មសិតានិ ទោមនស្សានិ ឆ គេហសិតា ឧបេក្ខា ឆ នេក្ខម្មសិតា ឧបេក្ខា ។

[១០០] តត្ថ កតមានិ ឆ គេហសិតានិ សោមនស្សានិ ។ ចក្ខុវិញ្ញេយ្យានំ រូបានំ ឥដ្ឋានំ កន្តានំ មនាបានំ មនោរមានំ លោកាមិសប្បដិសំយុត្តានំ បដិលាភំ វា បដិលាភតោ សមនុបស្សតោ បុព្វេ វា បដិលទ្ធបុព្វំ អតីតំ និរុទ្ធំ វិបរិណតំ សមនុស្សរតោ ឧប្បជ្ជតិ សោមនស្សំ យំ ឯវរូបំ សោមនស្សំ ឥទំ

[៩៩] ពាក្យថា បណ្ឌិតគប្បីដឹងសត្តបទ (ចំណែកនៃសត្វ) ៣៦ ដូច្នេះនេះ តថាគតបានពោលហើយ ។ ចុះពាក្យនុ៎ះ តថាគតពោលព្រោះអាស្រ័យអ្វី ។ គេហសិតសោមនស្ស (សោមនស្សអាស្រ័យកាមគុណ) មាន ៦ នេក្ខម្មសិតសោមនស្ស (សោមនស្សអាស្រ័យនេក្ខម្មៈ គឺវិបស្សនា) មាន ៦ គេហសិតទោមនស្ស មាន ៦ នេក្ខម្មសិតទោមនស្ស មាន ៦ គេហសិតឧបេក្ខា មាន ៦ នេក្ខម្មសិតឧបេក្ខា មាន ៦ (ត្រូវជា ៣៦) ។

[១០០] បណ្ដាធម៌ទាំងនោះ គេហសិតទោមនស្ស មាន ៦ យ៉ាង តើដូចម្ដេច ។ បុគ្គល កាលឃើញច្បាស់ នូវការបានរូបដែលគប្បីដឹងដោយភ្នែក ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ជាតម្រេកនៃចិត្ត ប្រកបដោយលោកាមិសៈ គឺតណ្ហា ថាជាការបានក្ដី កាលរលឹកឃើញ (នូវរូប) ដែលខ្លួនធ្លាប់បានហើយក្នុងកាលមុន ដែលកន្លងហើយ ដែលរលត់ហើយ ដែលប្រែប្រួលហើយក្ដី ហើយក៏កើតសេចក្ដីសោមនស្សឡើង សោមនស្សណា មានសភាពដូច្នេះ សោមនស្សនេះ

វុច្ចតិ គេហសិតំ សោមនស្សំ ។ សោតវិញ្ញេយ្យានំ សទ្ទានំ... ឃានវិញ្ញេយ្យានំ គន្ធានំ... ជិវ្ហាវិញ្ញេយ្យានំ រសានំ... កាយវិញ្ញេយ្យានំ ផោដ្ឋព្វានំ... មនោវិញ្ញេយ្យានំ ធម្មានំ ឥដ្ឋានំ កន្តានំ មនាបានំ មនោរមានំ លោកាមិសប្បដិសំយុត្តានំ បដិលាភំ វា បដិលាភតោ សមនុបស្សតោ បុព្វេ វា បដិលទ្ធបុព្វំ អតីតំ និរុទ្ធំ វិបរិណតំ សមនុស្សរតោ ឧប្បជ្ជតិ សោមនស្សំ យំ ឯវរូបំ សោមនស្សំ ឥទំ វុច្ចតិ គេហសិតំ សោមនស្សំ ។ ឥមានិ ឆ គេហសិតានិ សោមនស្សានិ ។

[១០១] តត្ថ កតមានិ ឆ នេក្ខម្មសិតានិ សោមនស្សានិ ។ រូបានំ ត្វេវ អនិច្ចតំ វិទិត្វា វិបរិណាមវិរាគនិរោធំ បុព្វេ ចេវ រូបា ឯតរហិ ច សព្វេ តេ រូបា អនិច្ចា ទុក្ខា វិបរិណាមធម្មាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតោ ឧប្បជ្ជតិ សោមនស្សំ យំ ឯវរូបំ សោមនស្សំ ឥទំ វុច្ចតិ

តថាគតហៅថា គេហសិតសោមនស្ស ។ បុគ្គល កាល ឃើញច្បាស់ នូវការបានសំឡេង ដែលគប្បីដឹងដោយត្រចៀក... ក្លិនដែលគប្បីដឹងដោយច្រមុះ... រសដែលគប្បីដឹងដោយអណ្តាត... ផោដ្ឋព្វៈដែលគប្បីដឹងដោយកាយ... ធម៌ដែលគប្បីដឹងដោយចិត្ត ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ជាតម្រេកនៃចិត្ត ប្រកបដោយលោកាមិសៈ ថាជាការបានក្តី កាលរលឹកឃើញនូវធម៌ដែលខ្លួនធ្លាប់បានហើយក្នុងកាលមុន ដែលកន្លងហើយ ដែលរលត់ហើយ ដែលប្រែប្រួលហើយក្តី ហើយក៏កើតសេចក្តីសោមនស្សឡើង សោមនស្សណា មានសភាពដូច្នេះ សោមនស្សនេះ តថាគតហៅថា គេហសិតសោមនស្ស ។ នេះគេហសិតសោមនស្ស ៦ យ៉ាង ។

[១០១] បណ្តាធម៌ទាំងនោះ នេក្ខម្មសិតសោមនស្ស មាន ៦ យ៉ាង តើដូចម្តេច ។ បុគ្គលកាលដឹងច្បាស់ថា រូបមានការមិនទៀង មានការប្រែប្រួល មានការវិនាស មានការរលត់ ហើយឃើញច្បាស់តាមពិតដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនេះថា រូបក្នុងកាលមុនក្តី ក្នុងកាលឥឡូវនេះក្តី រូបទាំងអស់នោះ សុទ្ធតែមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា ហើយក៏កើតសោមនស្សឡើង សោមនស្សណា មានសភាពដូច្នេះ សោមនស្សនេះ តថាគតហៅថា

នេក្ខម្មសិតំ សោមនស្សំ ។ សទ្ទានំ ត្វេវ... គន្ធានំ ត្វេវ... រសានំ ត្វេវ... ផោដ្ឋព្វានំ ត្វេវ... ធម្មានំ ត្វេវ អនិច្ចតំ វិទិត្វា វិបរិណាមវិរាគនិរោធំ បុព្វេ ចេវ ធម្មា ឯតរហិ ច សព្វេ តេ ធម្មា អនិច្ចា ទុក្ខា វិបរិណាមធម្មាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតោ ឧប្បជ្ជតិ សោមនស្សំ យំ ឯវរូបំ សោមនស្សំ ឥទំ វុច្ចតិ នេក្ខម្មសិតំ សោមនស្សំ ។ ឥមានិ ឆ នេក្ខម្មសិតានិ សោមនស្សានិ ។

[១០២] តត្ថ កតមានិ ឆ គេហសិតានិ ទោមនស្សានិ ។ ចក្ខុវិញ្ញេយ្យានំ រូបានំ ឥដ្ឋានំ កន្តានំ មនាបានំ មនោរមានំ លោកាមិសប្បដិសំយុត្តានំ អប្បដិលាភំ វា អប្បដិលាភតោ សមនុបស្សតោ បុព្វេ វា អប្បដិលទ្ធបុព្វំ អតីតំ និរុទ្ធំ

នេក្ខម្មសិតសោមនស្ស ។ បុគ្គលកាលដឹងច្បាស់ថា សំឡេង... ដឹងច្បាស់ថា ក្លិន... ដឹងច្បាស់ថា រស... ដឹងច្បាស់ថា ផោដ្ឋព្វៈ... ដឹងច្បាស់ថា ធម៌ មានការមិនទៀង មានការប្រែប្រួល មានការវិនាស មានការរលត់ ហើយឃើញច្បាស់តាមពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាង នេះដូច្នេះថា ធម៌ទាំងឡាយក្នុងកាលមុនក្តី ក្នុងកាលឥឡូវនេះក្តី ធម៌ទាំងអស់នោះ សុទ្ធតែមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា ហើយក៏កើតសោមនស្សឡើង សោមនស្សណា មានសភាពដូច្នេះ សោមនស្សនេះ តថាគតហៅថា នេក្ខម្មសិតសោមនស្ស ។ នេះ នេក្ខម្មសិតសោមនស្ស ៦ យ៉ាង ។

[១០២] បណ្តាធម៌ទាំងនោះ គេហសិតទោមនស្ស មាន ៦ យ៉ាង តើដូចម្តេច ។ បុគ្គល កាលឃើញច្បាស់ នូវការមិនបាន រូបដែលគប្បីដឹងដោយភ្នែក ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ជាតម្រេកនៃចិត្តប្រកបដោយលោកាមិសៈ ថាជាការមិនបានក្តី កាលរលឹកឃើញ នូវរូបដែលខ្លួនមិនធ្លាប់បានក្នុងកាលមុនក្តី ដែលកន្លងហើយ ដែលរលត់ហើយ

វិបរិណតំ សមនុបស្សតោ ឧប្បជ្ជតិ ទោមនស្សំ យំ ឯវរូបំ ទោមនស្សំ ឥទំ វុច្ចតិ គេហសិតំ ទោមនស្សំ ។ សោតវិញ្ញេយ្យានំ សទ្ទានំ... ឃានវិញ្ញេយ្យានំ គន្ធានំ... ជិវ្ហាវិញ្ញេយ្យានំ រសានំ... កាយវិញ្ញេយ្យានំ ផោដ្ឋព្វានំ... មនោវិញ្ញេយ្យានំ ធម្មានំ ឥដ្ឋានំ កន្តានំ មនាបានំ មនោរមានំ លោកាមិសប្បដិសំយុត្តានំ អប្បដិលាភំ វា អប្បដិលាភតោ សមនុបស្សតោ បុព្វេ វា អប្បដិលទ្ធបុព្វំ អតីតំ និរុទ្ធំ វិបរិណតំ សមនុបស្សតោ ឧប្បជ្ជតិ ទោមនស្សំ យំ ឯវរូបំ ទោមនស្សំ ឥទំ វុច្ចតិ គេហសិតំ ទោមនស្សំ ។ ឥមានិ ឆ គេហសិតានិ ទោមនស្សានិ ។

[១០៣] តត្ថ កតមានិ ឆ នេក្ខម្មសិតានិ ទោមនស្សានិ ។ រូបានំ ត្វេវ អនិច្ចតំ វិទិត្វា

ដែលប្រែប្រួលហើយក្តី ហើយក៏កើតទោមនស្សឡើង ទោមនស្ស ណា មានសភាពដូច្នេះ ទោមនស្សនេះ តថាគតហៅថា គេហសិត-ទោមនស្ស ។ បុគ្គល កាលឃើញច្បាស់ នូវការមិនបាន សំឡេង ដែលគប្បីដឹងដោយត្រចៀក... ក្លិន ដែលគប្បីដឹងដោយ ច្រមុះ... រស ដែលគប្បីដឹងដោយអណ្តាត... ផោដ្ឋព្វៈ ដែលគប្បី ដឹងដោយកាយ... ធម៌ ដែលគប្បីដឹងដោយចិត្ត ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ជាតម្រេកនៃចិត្ត ប្រកបដោយលោកាមិសៈ ថាជាការមិនបានក្តី កាលរលឹកឃើញនូវធម៌ ដែលខ្លួនមិនធ្លាប់បានក្នុងកាលមុន ដែលកន្លង ហើយ ដែលរលត់ហើយ ដែលប្រែប្រួលហើយក្តី ហើយក៏កើតទោម-នស្សឡើង ទោមនស្សណាមានសភាពដូច្នេះ ទោមនស្សនេះ តថាគត ហៅថា គេហសិតទោមនស្ស ។ នេះ គេហសិតទោមនស្ស ៦ យ៉ាង ។

[១០៣] បណ្តាធម៌ទាំងនោះ នេក្ខម្មសិតទោមនស្ស មាន ៦ យ៉ាង តើដូចម្តេច ។ បុគ្គលដឹងច្បាស់ថា រូបមានការមិនទៀង

វិបរិណាមវិរាគនិរោធំ បុព្វេ ចេវ រូបា ឯតរហិ ច សព្វេ តេ រូបា អនិច្ចា ទុក្ខា វិបរិណាមធម្មាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា អនុត្តរេសុ វិមោក្ខេសុ បិហំ ឧបដ្ឋាបេតិ កទាស្សុ[១] នាមហំ តទាយតនំ ឧបសម្បជ្ជ វិហរិស្សាមិ យទរិយា ឯតរហិ អាយតនំ ឧបសម្បជ្ជ វិហរន្តីតិ ឥតិ អនុត្តរេសុ វិមោក្ខេសុ បិហំ ឧបដ្ឋាបយតោ ឧប្បជ្ជតិ បិហប្បច្ចយា ទោមនស្សំ យំ ឯវរូបំ ទោមនស្សំ ឥទំ វុច្ចតិ នេក្ខម្មសិតំ ទោមនស្សំ ។ សទ្ទានំ ត្វេវ... គន្ធានំ ត្វេវ... រសានំ ត្វេវ... ផោដ្ឋព្វានំ ត្វេវ... ធម្មានំ ត្វេវ អនិច្ចតំ វិទិត្វា វិបរិណាមវិរាគនិរោធំ បុព្វេ ចេវ ធម្មា ឯតរហិ ច សព្វេ តេ ធម្មា អនិច្ចា

១ ម. កុទាស្សុ ។

មានការប្រែប្រួល មានការវិនាស មានការរលត់ ឃើញច្បាស់តាមពិតដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនេះដូច្នេះថា រូបក្នុងកាលមុនក្តី ក្នុងកាលឥឡូវនេះក្តី រូបទាំងអស់នោះ សុទ្ធតែមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា ហើយក៏ញុំាងសេចក្តីស្រឡាញ់ឲ្យតាំងឡើងក្នុងអនុត្តរវិមោក្ខ គឺព្រះអរហត្តថា កាលណាហ្ន៎ អាត្មាអញនឹងបានដល់នូវអាយតនៈគឺព្រះអរហត្ត ជាអាយតនៈដែលព្រះអរិយៈទាំងឡាយតែងបានដល់ក្នុងកាលឥឡូវនេះ កាលញុំាងសេចក្តីស្រឡាញ់ឲ្យតាំងឡើងក្នុងអនុត្តរវិមោក្ខដូច្នេះ ហើយក៏កើតទោមនស្សឡើង ព្រោះតែសេចក្តីស្រឡាញ់ជាបច្ច័យ ទោមនស្សណា មានសភាពដូច្នេះ ទោម-នស្សនេះ តថាគតហៅថា នេក្ខម្មសិតទោមនស្ស ។ បុគ្គលកាលដឹងច្បាស់ថា សំឡេង... ដឹងច្បាស់ថា ក្លិន... ដឹងច្បាស់ថា រស... ដឹងច្បាស់ថា ផោដ្ឋព្វៈ... ដឹងច្បាស់ថា ធម៌ មានការមិនទៀង មានការប្រែប្រួល មានការវិនាស មានការរលត់ ឃើញច្បាស់តាមពិត ដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនេះដូច្នេះថា ធម៌ ក្នុងកាលមុនក្តី ក្នុងកាលឥឡូវនេះក្តី ធម៌ទាំងអស់នោះ សុទ្ធតែមិនទៀង

ទុក្ខា វិបរិណាមធម្មាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា អនុត្តរេសុ វិមោក្ខេសុ បិហំ ឧបដ្ឋាបេតិ កទាស្សុ នាមហំ តទាយតនំ ឧបសម្បជ្ជ វិហរិស្សាមិ យទរិយា ឯតរហិ អាយតនំ ឧបសម្បជ្ជ វិហរន្តីតិ ឥតិ អនុត្តរេសុ វិមោក្ខេសុ បិហំ ឧបដ្ឋាបយតោ ឧប្បជ្ជតិ បិហាប្បច្ចយា ទោមនស្សំ យំ ឯវរូបំ ទោមនស្សំ ឥទំ វុច្ចតិ នេក្ខម្មសិតំ ទោមនស្សំ ។ ឥមានិ ឆ នេក្ខម្មសិតានិ ទោមនស្សានិ ។

[១០៤] តត្ថ កតមា ឆ គេហសិតា ឧបេក្ខា ។ ចក្ខុនា រូបំ ទិស្វា ឧប្បជ្ជតិ[១] ឧបេក្ខា ពាលស្ស មូឡ្ហស្ស[២] បុថុជ្ជនស្ស អនោធិជិនស្ស អវិបាកជិនស្ស អនាទីនវទស្សាវិនោ អស្សុតវតោ បុថុជ្ជនស្ស យា ឯវរូបា ឧបេក្ខា រូបំ សា នាតិវត្តតិ តស្មា សា ឧបេក្ខា គេហសិតាតិ វុច្ចតិ ។ សោតេន សទ្ទំ សុត្វា... ឃានេន គន្ធំ ឃាយិត្វា... ជិវ្ហាយ រសំ សាយិត្វា... កាយេន ផោដ្ឋព្វំ ផុសិត្វា...

១ ឱ. ឧប្បជ្ជតីតិ ន ទិស្សតិ ។ ២ ម. ឯត្ថន្តរេ មន្ទស្សាតិ ទិស្សតិ ។

ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា ហើយក៏ញ៉ាំងសេចក្តីស្រឡាញ់ឲ្យតាំងឡើងក្នុងអនុត្តរវិមោក្ខថា កាលណាហ្ន៎ អាត្មាអញនឹងបានដល់នូវអាយតនៈ ជាអាយតនៈដែលព្រះអរិយៈទាំងឡាយ តែងបានដល់ក្នុងកាលឥឡូវនេះ កាលញ៉ាំងសេចក្តីស្រឡាញ់ឲ្យតាំងឡើង ក្នុងអនុត្តរ-វិមោក្ខដូច្នេះហើយ ក៏កើតទោមនស្សឡើង ព្រោះតែសេចក្តីស្រឡាញ់ជាបច្ច័យ ទោមនស្សណា មានសភាពដូច្នេះ ទោមនស្សនេះ តថា-គតហៅថា នេក្ខម្មសិតទោមនស្ស ។ នេះ នេក្ខម្មសិតទោមនស្ស ៦ យ៉ាង ។

[១០៤] បណ្តាធម៌ទាំងនោះ គេហសិតឧបេក្ខា ៦ យ៉ាង តើដូចម្តេច ។ បុថុជ្ជន ជាបុគ្គលល្ងង់ វង្វេង ឬបុថុជ្ជន ដែលមិនទាន់ផ្ចាញ់កិលេសបាន មិនទាន់ផ្ចាញ់វិបាកបាន ជាអ្នកឃើញថាមិនមានទោស ជាអ្នកមិនចេះដឹងពុទ្ធវចនៈ ឃើញរូបដោយភ្នែក ហើយក៏កើតឧបេក្ខាឡើង ឧបេក្ខា[១] ណា មានសភាពដូច្នេះ ឧបេក្ខានោះ មិនប្រព្រឹត្តកន្លងនូវរូបឡើយ ព្រោះហេតុនោះ ឧបេក្ខានោះ តថាគតហៅថា គេហសិតឧបេក្ខា ។ ឮសំឡេងដោយត្រចៀក... ធុំក្លិនដោយច្រមុះ... ទទួលរសដោយអណ្តាត... ពាល់ត្រូវផោដ្ឋព្វៈដោយកាយ...

១ សំដៅយកអញ្ញាណុបេក្ខា ការព្រងើយកន្តើយ ប្រាសចាកសេចក្តីដឹងពិត ។ អដ្ឋកថា ។

មនសា ធម្មំ វិញ្ញាយ ឧប្បជ្ជតិ ឧបេក្ខា ពាលស្ស មូឡ្ហស្ស បុថុជ្ជនស្ស អនោធិជិនស្ស អវិចាកជិនស្ស អនាទីនវទស្សាវិនោ អស្សុតវតោ បុថុជ្ជនស្ស យា ឯវរូបា ឧបេក្ខា ធម្មំ សា ណាតិវត្តតិ តស្មា សា ឧបេក្ខា គេហសិតាតិ វុច្ចតិ ។ ឥមា ឆ គេហសិតា ឧបេក្ខា ។

[១០៨] តត្ថ កតមា ឆ នេក្ខម្មសិតា ឧបេក្ខា ។ រូបានំ ត្វេវ អនិច្ចតំ វិទិត្វា វិបរិណាមវិរាគនិរោធំ បុព្វេ ចេវ រូបា ឯតរហិ ច សព្វេ តេ រូបា អនិច្ចា ទុក្ខា វិបរិណាមធម្មាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតោ ឧប្បជ្ជតិ ឧបេក្ខា យា ឯវរូបា ឧបេក្ខា រូបំ សា ណាតិវត្តតិ[១] តស្មា

១ ឱ. អតិវត្តតិ ។

បុថុជ្ជន ល្វង់ វង្វេង បុថុជ្ជន ដែលមិនទាន់ផ្ចាញ់កិលេសបាន មិនទាន់ផ្ចាញ់វិបាកបាន ជាអ្នកឃើញថាមិនមានទោស ជាអ្នកមិនចេះដឹងពុទ្ធវចនៈ ដឹងនូវធម៌ដោយចិត្ត ហើយក៏កើតឧបេក្ខាឡើង ឧបេក្ខាណា មានសភាពដូច្នេះ ឧបេក្ខានោះ មិនប្រព្រឹត្តកន្លងនូវធម៌ឡើយ ព្រោះហេតុនោះ ឧបេក្ខានោះ តថាគតហៅថា គេហសិតឧបេក្ខា ។ នេះគេហសិតឧបេក្ខា ៦ យ៉ាង ។

[១០៥] បណ្ដាធម៌ទាំងនោះ នេក្ខម្មសិតឧបេក្ខា ៦ យ៉ាង តើដូចម្ដេច ។ បុគ្គលកាលដឹងច្បាស់ថា រូប មានការមិនទៀង មានការប្រែប្រួល មានការវិនាស មានការរលត់ ឃើញច្បាស់តាមពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះដូច្នេះថា រូប ក្នុងកាលមុនក្តី ក្នុងកាលឥឡូវនេះក្តី រូបទាំងអស់នោះ សុទ្ធតែមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា ហើយក៏កើតឧបេក្ខាឡើង ឧបេក្ខាណា មានសភាពដូច្នេះ ឧបេក្ខានោះ មិនប្រព្រឹត្តកន្លងនូវរូបឡើយ ព្រោះហេតុនោះ

សា ឧបេក្ខា នេក្ខម្មសិតាតិ វុច្ចតិ ។ សទ្ទានំ ត្វេវ... គន្ធានំ ត្វេវ... រសានំ ត្វេវ... ផោដ្ឋព្វានំ ត្វេវ... ធម្មានំ ត្វេវ អនិច្ចតំ វិទិត្វា វិបរិណាមវិរាគនិរោធំ បុព្វេ ចេវ ធម្មា ឯតរហិ ច សព្វេ តេ ធម្មា អនិច្ចា ទុក្ខា វិបរិណាមធម្មាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតោ ឧប្បជ្ជតិ ឧបេក្ខា យា ឯវរូបា ឧបេក្ខា ធម្មំ សា នាតិវត្តតិ តស្មា សា ឧបេក្ខា នេក្ខម្មសិតាតិ វុច្ចតិ ។ ឥមា ឆ នេក្ខម្មសិតា ឧបេក្ខា ។ ឆត្តឹស សត្តបទា វេទិតព្វាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

[១០៦] តត្រិទំ និស្សាយ ឥទំ បជហថាតិ ឥតិ ខោ បនេតំ វុត្តំ ។ កិញ្ចេតំ បដិច្ច វុត្តំ ។

ឧបេក្ខានោះ តថាគតហៅថា នេក្ខម្មសិតឧបេក្ខា ។ បុគ្គលកាលដឹង ច្បាស់ថា សំឡេង... ថាក្លិន... ថារស... ថាផោដ្ឋព្វ... ដឹងច្បាស់ ថាធម៌ មានការមិនទៀង មានការប្រែប្រួល មានការវិនាស មានការ រលត់ ឃើញច្បាស់តាមពិត ដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនេះដូច្នេះថា ធម៌ក្នុងកាលមុនក្តី ក្នុងកាលឥឡូវនេះក្តី ធម៌ទាំងអស់នោះ សុទ្ធតែមិន ទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា ហើយក៏កើតឧបេក្ខាឡើង ឧបេក្ខាណាមានសភាពដូច្នេះ ឧបេក្ខានោះ មិនប្រព្រឹត្តកន្លងនូវធម៌ឡើយ ព្រោះហេតុនោះ ឧបេក្ខានោះ តថាគតហៅថា នេក្ខម្មសិតឧបេក្ខា ។ នេះ នេក្ខម្មសិតឧបេក្ខាមាន ៦ យ៉ាង ។ ពាក្យណា ដែលតថាគត ពោលហើយថា បណ្ឌិតគប្បីដឹងសត្តបទ ៣៦ ដូច្នេះ ពាក្យនុ៎ះ តថាគត ពោល ព្រោះអាស្រ័យនូវហេតុនេះឯង ។

[១០៦] ពាក្យថា បណ្តាធម៌ទាំងនោះ អ្នកទាំងឡាយ ចូរអា-ស្រ័យនឹងធម៌នេះ ហើយលះបង់នូវធម៌នេះចេញ[១] ដូច្នេះនេះ តថាគត បានពោលហើយ ។ ចុះពាក្យនុ៎ះ តថាគតពោលព្រោះអាស្រ័យអ្វី ។

---

១ សេចក្តីថា សត្តបទទាំង ៣៦ ត្រូវអាស្រ័យនូវបទទាំង ១៨ ហើយ លះបង់នូវបទទាំង ១៨ ចោលចេញ ។ អដ្ឋកថា ។

១០៩



តត្រ ភិក្ខវេ យានិ ឆ នេក្ខម្មសិតានិ សោមនស្សានិ តានិ និស្សាយ តានិ អាគម្ម យានិ ឆ គេហសិតានិ សោមនស្សានិ តានិ បជហថ តានិ សមតិក្កមថ ឯវមេតេសំ បហានំ ហោតិ ឯវមេតេសំ សមតិក្កមោ ហោតិ ។ តត្រ ភិក្ខវេ យានិ ឆ នេក្ខម្មសិតានិ ទោមនស្សានិ តានិ និស្សាយ តានិ អាគម្ម យានិ ឆ គេហសិតានិ ទោមនស្សានិ តានិ បជហថ តានិ សមតិក្កមថ ឯវមេតេសំ បហានំ ហោតិ ឯវមេតេសំ សមតិក្កមោ ហោតិ ។ តត្រ ភិក្ខវេ យា ឆ នេក្ខម្ម-សិតា ឧបេក្ខា តា និស្សាយ តា អាគម្ម យា ឆ គេហសិតា ឧបេក្ខា តា បជហថ តា សមតិក្កមថ ឯវមេតាសំ បហានំ ហោតិ ឯវមេតាសំ សមតិក្កមោ ហោតិ ។ តត្រ ភិក្ខវេ យានិ ឆ នេក្ខម្មសិតានិ សោមនស្សានិ តានិ និស្សាយ តានិ អាគម្ម យានិ ឆ នេក្ខម្មសិតានិ ទោមនស្សានិ តានិ បជហថ តានិ សមតិក្កមថ ឯវមេតេសំ បហានំ ហោតិ

ម្នាលភិក្ខុទាំងឡាយ បណ្ដាធម៌ទាំងនោះ អ្នកទាំងឡាយ ចូរអាស្រ័យពឹងផ្អែកនូវនេក្ខម្មសិតសោមនស្សទាំង ៦ ហើយលះបង់ កន្លងឲ្យផុតនូវគេហសិតសោមនស្សទាំង ៦ ចេញ ការលះបង់នូវសោមនស្សទាំងនោះយ៉ាងនេះឯង ការកន្លងឲ្យផុតនូវសោមនស្សទាំងនោះ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាធម៌ទាំងនោះ អ្នកទាំងឡាយ ចូរអាស្រ័យពឹងផ្អែកនូវនេក្ខម្មសិតទោមនស្សទាំង ៦ ហើយលះបង់ កន្លងឲ្យផុតនូវគេហសិតទោមនស្សទាំង ៦ ចេញ ការលះបង់នូវទោមនស្សទាំងនោះយ៉ាងនេះឯង ការកន្លងឲ្យផុតនូវទោមនស្សទាំងនោះ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាធម៌ទាំងនោះ អ្នកទាំងឡាយ ចូរអាស្រ័យពឹងផ្អែកនឹងនេក្ខម្មសិតឧបេក្ខាទាំង ៦ ហើយលះបង់ កន្លងឲ្យផុតនូវគេហសិតឧបេក្ខាទាំង ៦ ចេញ ការលះបង់ឧបេក្ខាទាំងនោះ យ៉ាងនេះឯង ការកន្លងឲ្យផុតនូវឧបេក្ខាទាំងនោះ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាធម៌ទាំងនោះ អ្នកទាំងឡាយ ចូរអាស្រ័យពឹងផ្អែកនឹងនេក្ខម្មសិតសោមនស្សទាំង ៦ ហើយលះបង់ កន្លងឲ្យផុតនូវនេក្ខម្មសិតទោមនស្សទាំង ៦ ចេញ ការលះបង់នូវទោមនស្សទាំងនោះ យ៉ាងនេះឯង

ឯវមេតេសំ សមតិក្កមោ ហោតិ ។ តត្រ ភិក្ខវេ យា ច នេក្ខម្មសិតា ឧបេក្ខា តា និស្សាយ តា អាគម្ម យានិ ច នេក្ខម្មសិតានិ សោមនស្សានិ តានិ បជហថ តានិ សមតិក្កមថ ឯវមេតេសំ បហានំ ហោតិ ឯវមេតេសំ សមតិក្កមោ ហោតិ ។

[១០៧] អត្ថិ ភិក្ខវេ ឧបេក្ខា នានត្តា នានត្តសិតា អត្ថិ ឧបេក្ខា ឯកត្តា ឯកត្តសិតា ។ កតមា ច ភិក្ខវេ ឧបេក្ខា នានត្តា នានត្តសិតា ។ អត្ថិ ភិក្ខវេ ឧបេក្ខា រូបេសុ អត្ថិ សទ្ទេសុ អត្ថិ គន្ធេសុ អត្ថិ រសេសុ អត្ថិ ផោដ្ឋព្វេសុ ។ អយំ ភិក្ខវេ ឧបេក្ខា នានត្តា នានត្តសិតា ។ កតមា ច ភិក្ខវេ ឧបេក្ខា ឯកត្តា ឯកត្តសិតា ។ អត្ថិ ភិក្ខវេ ឧបេក្ខា អាកាសានញ្ចាយតននិស្សិតា អត្ថិ វិញ្ញាណញ្ចាយតននិស្សិតា អត្ថិ អាកិញ្ចញ្ញាយតននិស្សិតា អត្ថិ នេវសញ្ញានាសញ្ញាយតននិស្សិតា ។

ការកន្ធ្វង់ឲ្យផុតនូវទោមនស្សទាំងនោះ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំង-ឡាយ បណ្តាធម៌ទាំងនោះ អ្នកទាំងឡាយ ចូរអាស្រ័យពឹងផ្អែកនឹងនេក្ខម្មសិតឧបេក្ខាទាំង ៦ ហើយលះបង់ កន្ធ្វង់ឲ្យផុត នូវនេក្ខម្មសិត-សោមនស្សទាំង ៦ ចេញ ការលះបង់នូវសោមនស្សទាំងនោះ យ៉ាងនេះឯង ការកន្ធ្វង់ឲ្យផុតនូវសោមនស្សទាំងនោះ យ៉ាងនេះឯង ។

[១០៧] ម្នាលភិក្ខុទាំងឡាយ ឧបេក្ខាផ្សេងគ្នា អាស្រ័យនូវអារម្មណ៍ផ្សេងគ្នា ក៏មាន ឧបេក្ខាជាមួយគ្នា អាស្រ័យនូវអារម្មណ៍ជាមួយគ្នា ក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ឧបេក្ខាផ្សេងគ្នា អាស្រ័យនូវអារម្មណ៍ផ្សេងគ្នា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ឧបេក្ខាក្នុងរូបក៏មាន ក្នុងសំឡេងក៏មាន ក្នុងក្លិនក៏មាន ក្នុងរសក៏មាន ក្នុងផោដ្ឋព្វៈក៏មាន ។ ម្នាលភិក្ខុទាំងឡាយ នេះ ឧបេក្ខាផ្សេងគ្នា អាស្រ័យ នូវអារម្មណ៍ផ្សេងគ្នា ។ ម្នាលភិក្ខុទាំងឡាយ ឧបេក្ខាជាមួយគ្នា អាស្រ័យ នូវអារម្មណ៍ជាមួយគ្នា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ឧបេក្ខា អាស្រ័យនូវអាកាសានញ្ចាយតនជ្ឈាន ក៏មាន អាស្រ័យនូវវិញ្ញាណញ្ចាយតនជ្ឈាន ក៏មាន អាស្រ័យនូវអាកិញ្ចញ្ញាយ-តនជ្ឈានក៏មាន អាស្រ័យនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ក៏មាន ។

ឧបេក្ខា ឯកត្តា ឯកត្តសិតា ។ តត្រ ភិក្ខវេ យាយំ ឧបេក្ខា ឯកត្តា ឯកត្តសិតា តំ និស្សាយ តំ អាគម្ម យាយំ ឧបេក្ខា នានត្តា នានត្តសិតា តំ បជហថ តំ សមតិក្កមថ ឯវមេតិស្សា បហានំ ហោតិ ឯវមេតិស្សា សមតិក្កមោ ហោតិ ។ អតម្ម-យតំ[១] ភិក្ខវេ និស្សាយ អតម្មយតំ អាគម្ម យាយំ ឧបេក្ខា ឯកត្តា ឯកត្តសិតា តំ បជហថ តំ ស-មតិក្កមថ ឯវមេតិស្សា បហានំ ហោតិ ឯវមេតិស្សា សមតិក្កមោ ហោតិ ។ តត្រិទំ និស្សាយ ឥទំ បជ-ហថាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

[១០៨] តយោ សតិប្បដ្ឋានា យទរិយោ សេវតិ យទរិយោ សេវមានោ សត្ថា គណមនុសាសិតុមរហ-តីតិ ឥតិ ខោ បនេតំ វុត្តំ ។ កិញ្ចេតំ បដិច្ច វុត្តំ ។

១ អនុបទវគ្គស្ស សប្បុរិសសុត្តេ បន អតម្មយតាតិ ទិស្សតិ ។

ម្នាលភិក្ខុទាំងឡាយ នេះជាឧបេក្ខាជាមួយគ្នា អាស្រ័យនូវអារម្មណ៍ជា-មួយគ្នា ។ ម្នាលភិក្ខុទាំងឡាយ បណ្តាឧបេក្ខាទាំងពីរនោះ អ្នកទាំង-ឡាយ ចូរអាស្រ័យ ពឹងផ្អែកនឹងឧបេក្ខាជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ហើយលះបង់ កន្ទង់ឲ្យផុតនូវឧបេក្ខាផ្សេងគ្នា មានអារម្មណ៍ផ្សេងគ្នាចេញ ការលះបង់នូវឧបេក្ខានុ៎ះ យ៉ាងនេះឯង ការកន្ទង់ឲ្យផុតនូវឧបេក្ខានុ៎ះ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរអាស្រ័យនឹងតណ្ហា ពឹងផ្អែកនឹងតណ្ហា ហើយលះបង់ កន្ទង់ឲ្យផុតនូវឧបេក្ខាជាមួយគ្នា មានអារម្មណ៍ជាមួយគ្នាចេញ ការលះបង់ឧបេក្ខានុ៎ះ យ៉ាងនេះឯង ការកន្ទង់ឲ្យផុតនូវឧបេក្ខានុ៎ះ យ៉ាងនេះឯង ។ ពាក្យណាដែលតថាគតពោលហើយថា បណ្តាធម៌ទាំងនោះ អ្នកទាំងឡាយចូរអាស្រ័យនឹងធម៌នេះ ហើយលះបង់នូវធម៌នេះចេញ ដូច្នេះនេះ ពាក្យនុ៎ះ តថាគតពោល ព្រោះអាស្រ័យហេតុនេះឯង ។

[១០៨] ពាក្យថា សតិប្បដ្ឋាន មាន ៣ ប្រការ ដែលសាស្តាដ៏ប្រសើរតែងសេព កាលសាស្តាដ៏ប្រសើរសេពហើយ ទើបគួរនឹងប្រៀនប្រដៅគណៈបាន ដូច្នេះនេះ តថាគតបានពោលហើយ ។ ចុះពាក្យនុ៎ះ តថាគតពោលព្រោះអាស្រ័យអ្វី ។

[១០៩] ឥតិ[១] ភិក្ខវេ សត្ថា សាវកានំ ធម្មំ ទេសេតិ អនុកម្បកោ ហិតេសី អនុកម្បំ ឧបាទាយ ឥទំ វោ ហិតាយ ឥទំ វោ សុខាយាតិ ។ តស្ស សាវកា ន សុស្សុយន្តិ[២] ន សោតំ ឱទហន្តិ ន អញ្ញាចិត្តំ ឧបដ្ឋបេន្តិ វោក្កម្ម ច សត្ថុ សាសនា វត្តន្តិ ។ តត្រ ភិក្ខវេ តថាគតោ ន ចេវ អត្តមនោ ហោតិ ន ច អត្តមនតំ បដិសំវេទេតិ អនវស្សុតោ ច វិហរតិ សតោ សម្បជានោ ឥទំ វុច្ចតិ ភិក្ខវេ បឋមំ សតិប្បដ្ឋានំ យទរិយោ សេវតិ យទរិយោ សេវមានោ សត្ថា គណមនុសាសិតុមរហតិ ។

[១១០] បុន ចបរំ ភិក្ខវេ សត្ថា សាវកានំ ធម្មំ ទេសេតិ អនុកម្បកោ ហិតេសី អនុកម្បំ ឧបាទាយ ឥទំ វោ ហិតាយ ឥទំ វោ សុខាយាតិ ។ តស្ស ឯកច្ចេ សាវកា ន សុស្សុយន្តិ

១ ឱ. ម. ឥធ ។ ២ ឱ. សុស្សូយន្តិ ។ ម. សុស្សុសន្តិ ។

[១០៩] ម្នាលភិក្ខុទាំងឡាយ សាស្តាជាអ្នកអនុគ្រោះ ជាអ្នកស្វែងរកប្រយោជន៍ តែងសំដែងធម៌ដល់ពួកសាវ័ក ព្រោះអាស្រ័យនូវសេចក្តីអនុគ្រោះដូច្នេះថា ធម្មជាតនេះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់អ្នកទាំងឡាយ ធម្មជាតនេះ ប្រព្រឹត្តទៅដើម្បីសេចក្តីសុខ ដល់អ្នកទាំងឡាយ ។ តែពួកសាវ័ក របស់សាស្តានោះ មិនចង់ស្តាប់ មិនផ្ចង់ត្រចៀក មិនតាំងចិត្តដើម្បីដឹងសេចក្តី ក៏ប្រព្រឹត្តកន្លងពាក្យប្រៀនប្រដៅ របស់សាស្តាទៅវិញ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងដំណើរនោះ ព្រះតថាគត មិនមានចិត្តរីករាយ មិនទទួលនូវសេចក្តីរីករាយ មានចិត្តមិនប្រឡាក់ដោយរាគៈ មានតែសតិសម្បជញ្ញៈ ប្រព្រឹត្តទៅគ្រប់ឥរិយាបថ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សតិប្បដ្ឋាន ទី ១ ដែលសាស្តាដ៏ប្រសើរតែងសេព កាលសាស្តាដ៏ប្រសើរសេពហើយ ទើបគួរនឹងប្រៀនប្រដៅគណៈបាន ។

[១១០] ម្នាលភិក្ខុទាំងឡាយ មួយទៀត សាស្តាជាអ្នកអនុគ្រោះស្វែងរកប្រយោជន៍ តែងសំដែងធម៌ដល់ពួកសាវ័ក ព្រោះអាស្រ័យនូវសេចក្តីអនុគ្រោះថា ធម្មជាតនេះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់អ្នកទាំងឡាយ ធម្មជាតនេះ ប្រព្រឹត្តទៅដើម្បីសេចក្តីសុខ ដល់អ្នកទាំងឡាយ ។ សាវ័កពួកខ្លះ របស់សាស្តានោះ មិនចង់ស្តាប់

ន សោតំ ឱទហន្តិ ន អញ្ញាចិត្តំ ឧបដ្ឋបេន្តិ វោក្កម្ម ច សត្ថុ សាសនា វត្តន្តិ ។ ឯកាច្ចេ សាវកា សុស្សូយន្តិ សោតំ ឱទហន្តិ អញ្ញាចិត្តំ ឧបដ្ឋបេន្តិ ន ច វោក្កម្ម សត្ថុ សាសនា វត្តន្តិ ។ តត្រ ភិក្ខវេ តថាគតោ ន ចេវ អត្តមនោ ហោតិ ន ច អត្តមនតំ បដិសំវេទេតិ ន ច អនត្តមនោ ហោតិ ន ច អនត្តមនតំ បដិសំវេទេតិ អត្តមនតញ្ច អនត្តមនតញ្ច តទុភយំ អភិនិវជ្ជេត្វា[១] ឧបេក្ខកោ វិហរតិ សតោ សម្បជានោ ឥទំ វុច្ចតិ[២] ភិក្ខវេ ទុតិយំ សតិប្បដ្ឋានំ យទរិយោ សេវតិ យទរិយោ សេវមានោ សត្ថា គណមនុសាសិតុមរហតិ ។

[១១១] បុន ចបរំ ភិក្ខវេ សត្ថា សាវកានំ ធម្មំ ទេសេតិ អនុកម្បកោ ហិតេសី អនុកម្បំ ឧបាទាយ ឥទំ វោ ហិតាយ ឥទំ វោ សុខាយាតិ ។ តស្ស សាវកា សុស្សូយន្តិ សោតំ ឱទហន្តិ អញ្ញាចិត្តំ ឧបដ្ឋបេន្តិ ន ច វោក្កម្ម សត្ថុ សាសនា វត្តន្តិ ។ តត្រ ភិក្ខវេ

---

១ ឱ. ឯត្ថន្តរេ សោតិ អត្ថិ ។ ២ ឱ. វុច្ចតីតិ ន ទិស្សតិ ។

មិនផ្ទង់ត្រចៀក មិនតាំងចិត្តដើម្បីឲ្យដឹងសេចក្តី ក៏ប្រព្រឹត្តកន្លងពាក្យប្រៀនប្រដៅរបស់សាស្តា ។ សាវ័កពួកខ្លះ ចង់ស្តាប់ ផ្ទង់ត្រចៀក តាំងចិត្តដើម្បីឲ្យដឹងសេចក្តី មិនហ៊ានប្រព្រឹត្តកន្លង នូវពាក្យប្រៀនប្រដៅរបស់សាស្តាឡើយ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងដំណើរនោះ ព្រះតថាគត ក៏មិនមានចិត្តរីករាយ មិនទទួលនូវសេចក្តីរីករាយ មិនមានតូចចិត្ត មិនទទួលនូវសេចក្តីតូចចិត្ត វៀរបង់នូវសេចក្តីរីករាយនិងសេចក្តីតូចចិត្តទាំងពីរនោះ ជាអ្នកព្រងើយ ប្រកបដោយសតិសម្បជញ្ញៈប្រព្រឹត្តទៅគ្រប់ឥរិយាបថ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សតិប្បដ្ឋានទី ២ ដែលសាស្តាដ៏ប្រសើរតែងសេព កាលសាស្តាដ៏ប្រសើរសេពហើយ ទើបគួរនឹងប្រៀនប្រដៅនូវគណៈបាន ។

[១១១] ម្នាលភិក្ខុទាំងឡាយ មួយទៀត សាស្តាជាអ្នកអនុគ្រោះ ស្វែងរកប្រយោជន៍ រមែងសំដែងធម៌ដល់ពួកសាវ័ក ព្រោះអាស្រ័យ នូវសេចក្តីអនុគ្រោះថា ធម្មជាតនេះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់អ្នកទាំងឡាយ ធម្មជាតនេះ ប្រព្រឹត្តទៅដើម្បីសេចក្តីសុខដល់អ្នកទាំងឡាយ ។ តែពួកសាវ័ក របស់សាស្តានោះ ចង់ស្តាប់ ផ្ទង់ត្រចៀក តាំងចិត្តដើម្បីឲ្យដឹងសេចក្តី ទាំងមិនបានប្រព្រឹត្តកន្លងពាក្យប្រៀនប្រដៅរបស់សាស្តា ។ ម្នាលភិក្ខុទាំងឡាយ ក្នុងដំណើរនោះ

តថាគតោ អត្តមនោ ចេវ ហោតិ អត្តមនតញ្ច បដិសំវេទេតិ អនវស្សុតោ ច វិហរតិ សតោ សម្បជានោ ឥទំ វុច្ចតិ ភិក្ខវេ តតិយំ សតិប្បដ្ឋានំ យទរិយោ សេវតិ យទរិយោ សេវមានោ សត្ថា គណមនុសាសិតុមរហតិ ។ តយោ សតិប្បដ្ឋានា យទរិយោ សេវតិ យទរិយោ សេវមានោ សត្ថា គណមនុសាសិតុមរហតីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

[១១២] សោ វុច្ចតិ យោគាចរិយានំ អនុត្តរោ បុរិសទម្មសារថីតិ ឥតិ ខោ បនេតំ វុត្តំ ។ កិញ្ចេតំ បដិច្ច វុត្តំ ។ ហត្ថិទមកេន ភិក្ខវេ ហត្ថិទម្មោ សារិតោ ឯកំយេវ ទិសំ ធាវ-តិ បុរត្ថិមំ វា បច្ឆិមំ វា ឧត្តរំ វា ទក្ខិណំ វា ។ អស្សទមកេន ភិក្ខវេ អស្សទម្មោ សារិតោ

ព្រះតថាគតរមែងមានចិត្តរីករាយ ទទួលនូវសេចក្តីរីករាយ តែថាមានចិត្តមិនប្រឡាក់ដោយរាគៈ ជាអ្នកមានសតិសម្បជញ្ញៈ ប្រព្រឹត្តទៅគ្រប់ឥរិយាបថ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សតិប្បដ្ឋាន ទី ៣ ដែលសាស្តាដ៏ប្រសើរតែងសេព កាលសាស្តាដ៏ប្រសើរសេពហើយ ទើបគួរនឹងប្រៀនប្រដៅនូវគណៈបាន ។ ពាក្យថា សតិប្បដ្ឋានមាន ៣ ប្រការ ដែលសាស្តាដ៏ប្រសើរតែងសេព កាលសាស្តាដ៏ប្រសើរសេពហើយ ទើបគួរប្រៀនប្រដៅនូវគណៈបាន ដូច្នេះ តថាគតពោលហើយ ពាក្យនេះ ដែលតថាគតពោល ព្រោះអាស្រ័យនូវហេតុនេះឯង ។

[១១២] ពាក្យថា បុគ្គលនោះ តថាគតហៅថា ជាសារថីទូន្មាននូវបុរស ជាអាចារ្យប្រសើរ ជាងអាចារ្យអ្នកទូន្មាននូវវាហនៈមានដំរីជាដើមដូច្នេះនេះ តថាគតបានពោលហើយ ។ ចុះពាក្យនុ៎ះ តថាគតពោល ព្រោះអាស្រ័យអ្វី ។ ម្នាលភិក្ខុទាំងឡាយ ដំរីគួរទូន្មាន ដែលទម័កដំរី បានទូន្មានហើយ រមែងស្ទុះទៅកាន់ទិសតែមួយៗ គឺទិសខាងកើតក្តី ខាងលិចក្តី ខាងជើងក្តី ខាងត្បូងក្តី ។ ម្នាលភិក្ខុទាំងឡាយ សេះគួរទូន្មាន ដែលទម័កសេះ បានទូន្មានហើយ

ឯកំយេវ ទិសំ ធាវតិ បុរត្ថិមំ វា បច្ឆិមំ វា ឧត្តរំ វា ទក្ខិណំ វា ។ គោទមកេន ភិក្ខវេ គោទម្មោ សារិតោ ឯកំយេវ ទិសំ ធាវតិ បុរត្ថិមំ វា បច្ឆិមំ វា ឧត្តរំ វា ទក្ខិណំ វា ។ តថាគតេន ភិក្ខវេ អរហតា សម្មាសម្ពុទ្ធេន បុរិសទម្មោ សារិតោ អដ្ឋ ទិសា វិធាវតិ រូបី រូបានិ បស្សតិ អយំ បឋមា ទិសា ។ អជ្ឈត្តំ អរូបសញ្ញី ពហិទ្ធា រូបានិ បស្សតិ អយំ ទុតិយា ទិសា ។ សុភន្តេវ អធិមុត្តោ ហោតិ អយំ តតិយា ទិសា ។ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ អយំ ចតុត្ថា ទិសា ។

រមែងស្ទុះទៅកាន់ទិសតែមួយៗ គឺទិសខាងកើតក្តី ខាងលិចក្តី ខាងជើងក្តី ខាងត្បូងក្តី ។ ម្នាលភិក្ខុទាំងឡាយ គោគួរទូន្មាន ដែលទម័កគោបានទូន្មានហើយ រមែងស្ទុះទៅកាន់ទិសតែមួយៗ គឺទិស ខាងកើតក្តី ខាងលិចក្តី ខាងជើងក្តី ខាងត្បូងក្តី ។ ម្នាលភិក្ខុទាំងឡាយ ឯបុរសគួរទូន្មាន ដែលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ បានទូន្មានហើយ រមែងស្ទុះទៅកាន់ទិសទាំង ៨ បាន គឺបុគ្គលបាននូវរូបជ្ឈាន តែងមើលឃើញនូវរូបទាំងឡាយ នេះជាទិស ទី ១ ។ បុគ្គលមិនបានសំគាល់នូវរូបខាងក្នុង តែងឃើញនូវរូបខាងក្រៅទាំងឡាយ នេះជាទិស ទី ២ ។ បុគ្គល បង្អោនចិត្តទៅកាន់អារម្មណ៍ថា (នេះ) ល្អដូច្នេះ នេះជាទិស ទី ៣ ។ បុគ្គល ព្រោះកន្លងនូវសញ្ញាដោយប្រការទាំងពួង ព្រោះអស់បដិឃសញ្ញា ព្រោះលែងធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ក៏បានដល់នូវអាកាសានញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុតដូច្នេះ ប្រព្រឹត្តនៅគ្រប់ឥរិយាបថទាំង ៤ នេះជាទិស ទី ៤ ។

សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ អយំ បញ្ចមី ទិសា ។ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ អយំ ឆដ្ឋា ទិសា ។ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ អយំ សត្តមី ទិសា ។ សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ អយំ អដ្ឋមី ទិសា ។ តថាគតេន ភិក្ខវេ អរហតា សម្មាសម្ពុទ្ធេន ឫរិសទម្មា សារិតោ

បុគ្គល ព្រោះកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុតដូច្នេះ ប្រព្រឹត្តនៅគ្រប់ឥរិយាបថទាំង ៤ នេះជាទិស ទី ៥ ។ បុគ្គល ព្រោះកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា អ្វីតិចតួចមិនមាន ដូច្នេះ ប្រព្រឹត្តនៅគ្រប់ឥរិយាបថទាំង ៤ នេះជាទិស ទី ៦ ។ បុគ្គល ព្រោះកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ប្រព្រឹត្តនៅគ្រប់ឥរិយាបថទាំង ៤ នេះជាទិស ទី ៧ ។ បុគ្គល ព្រោះកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់នូវសញ្ញាវេទយិតនិរោធ ប្រព្រឹត្តនៅគ្រប់ឥរិយាបថទាំង ៤ នេះជាទិស ទី ៨ ។ ម្នាលភិក្ខុទាំងឡាយ បុរសគួរទូន្មាន ដែលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ទូន្មានហើយ

ឥមា អដ្ឋ ឧិសា វិជាវតិ ។ សោ វុច្ចតិ យោគា-
ចរិយានំ អនុត្តរោ បុរិសឧម្មសារថីតិ ឥតិ យន្តំ
វុត្តំ ឥឧមេតំ បដិច្ច វុត្តន្តិ ។ ឥឧមវោច ភគវា
អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

សឡាយតនវិភង្គសុត្តំ សត្តមំ និដ្ឋិតំ ។

*រមែងស្ទុះទៅកាន់ទិសទាំង ៨ នេះឯង ។ ពាក្យណា ថា បុគ្គលនោះ តថាគតហៅថា ជាសារថីអ្នកទូន្មាននូវបុរស ជាអាចារ្យប្រសើរ ជាង អាចារ្យអ្នកទូន្មាននូវវាហនៈមានដំរីជាដើម ដូច្នេះ តថាគតបានពោល ហើយ ពាក្យនុ៎ះ តថាគតពោល ព្រោះអាស្រ័យនូវហេតុនេះឯង ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអរ រីករាយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។*

ចប់ សឡាយតនវិភង្គសូត្រ ទី ៧ ។

# អដ្ឋមំ ឧទ្ទេសវិភង្គសុត្តំ

[១១៣] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច ឧទ្ទេសវិភង្គំ វោ ភិក្ខវេ ទេសិស្សាមិ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវម្ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

# ឧទ្ទេសវិភង្គសូត្រ ទី ៨

[១១៣] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយ មកក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវឧទ្ទេស-វិភង្គ (ចំណែកឧទ្ទេសគឺមាតិកា) ប្រាប់អ្នកទាំងឡាយ អ្នកទាំងឡាយចូរប្រុងស្តាប់នូវឧទ្ទេសនិងវិភង្គនោះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសំដែង ។ ភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

វិភង្គវគ្គស្ស ឧទ្ទេសវិភង្គសុត្តេ ភិក្ខូនំ បរិវិតក្កនំ

[១១៤] ភគវា ឯតទវោច តថា តថា ភិក្ខវេ ភិក្ខុ ឧបបរិក្ខេយ្យ យថា យថាស្ស ឧបបរិក្ខតោ ពហិទ្ធា ចស្ស វិញ្ញាណំ អវិក្ខិត្តំ អវិសដំ អជ្ឈត្តំ អសណ្ឋិតំ អនុបាទាយ ន បរិតស្សេយ្យ ពហិទ្ធា ភិក្ខវេ វិញ្ញាណេ អវិក្ខិត្តេ អវិសដេ សតិ អជ្ឈត្តំ អសណ្ឋិតេ អនុបាទាយ អបរិតស្សតោ អាយតឹ ជាតិជរាមរណទុក្ខសមុទយសម្ភវោ ន ហោតីតិ ។ ឥទមវោច ភគវា ឥទំ វត្វាន សុគតោ ឧដ្ឋាយា-សនា វិហារំ ចាវិសិ ។

វិភង្គវគ្គ ឧទ្ទេសវិភង្គសូត្រ សេចក្តីត្រិះរិះរបស់ភិក្ខុទាំងឡាយ

[១១៨] ព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាដូច្នេះថា កាលបើភិក្ខុនោះ ពិចារណាហើយ វិញ្ញាណរបស់ភិក្ខុនោះ មិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ មិនឋិតនៅខាងក្នុង មិនតក់ស្លុត ព្រោះមិនប្រកាន់មាំ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះ មានវិញ្ញាណមិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ មិនឋិតនៅខាងក្នុង មិនតក់ស្លុត ព្រោះមិនប្រកាន់មាំហើយ សេចក្តីកើតឡើងព្រម មានព្រមនៃជាតិ ជរា មរណៈ ដ៏សេសសល់ រមែងមិនមានតទៅទៀត ដោយប្រការយ៉ាងណា ៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីពិចារណាដោយប្រការយ៉ាងនោះ ៗ ចុះ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះ លុះព្រះសុគតទ្រង់មានព្រះពុទ្ធដីកាដូច្នេះហើយ ក៏ទ្រង់ក្រោកអំពីអាសនៈចូលទៅកាន់វិហារ ។

[១១៤] អថខោ តេសំ ភិក្ខូនំ អចិរប្បក្កន្តស្ស ភគវតោ ឯតទហោសិ ឥទំ ខោ នោ អាវុសោ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ តថា តថា ភិក្ខវេ ភិក្ខុ ឧបបរិក្ខេយ្យ យថា យថាស្ស ឧបបរិក្ខតោ ពហិទ្ធា ចស្ស វិញ្ញាណំ អវិក្ខិត្តំ អវិសដំ អជ្ឈត្តំ អសណ្ឋិតំ អនុបាទាយ ន បរិតស្សេយ្យ ពហិទ្ធា ភិក្ខវេ វិញ្ញាណេ អវិក្ខិត្តេ អវិសដេ សតិ អជ្ឈត្តំ អសណ្ឋិតេ អនុបាទាយ អបរិតស្សតោ អាយតឹ ជាតិជរាមរណទុក្ខសមុទយសម្ភវោ ន ហោតីតិ កោ នុ ខោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជេយ្យាតិ ។ អថខោ តេសំ ភិក្ខូនំ ឯតទហោសិ

[១១៥] គ្រាកាលដែលព្រះមានព្រះភាគ ទ្រង់ស្តេចចេញទៅមិនយូរប៉ុន្មាន ភិក្ខុទាំងនោះ ក៏មានសេចក្តីត្រិះរិះដូច្នេះថា ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគទ្រង់សំដែង នូវឧទ្ទេសនេះ ដល់យើងទាំងឡាយ ដោយសង្ខេប មិនបានចែកអត្ថ ដោយពិស្តារ ស្រាប់តែទ្រង់ក្រោកអំពីអាសនៈ ចូលទៅកាន់វិហារ គឺទ្រង់ត្រាស់ថា កាលបើភិក្ខុនោះពិចារណាហើយ វិញ្ញាណរបស់ភិក្ខុនោះ មិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ មិនបិតនៅខាងក្នុង មិនតក់ស្លុត ព្រោះមិនប្រកាន់មាំ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះ មានវិញ្ញាណមិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ មិនបិតនៅខាងក្នុង មិនតក់ស្លុត ព្រោះមិនប្រកាន់មាំហើយ សេចក្តីកើតឡើងព្រម មានព្រមនៃជាតិ ជរា មរណៈ និងទុក្ខ រមែងមិនមានតទៅទៀត ដោយប្រការយ៉ាងណា ៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីពិចារណាដោយប្រការយ៉ាងនោះ ៗ ចុះ តើឧទ្ទេសដែលព្រះមានព្រះភាគ ទ្រង់សំដែងដោយសង្ខេប មិនបានចែកអត្ថដោយពិស្តារនេះ នរណាហ្ន៎ នឹងអាចចែកអត្ថដោយពិស្តារបាន ។ គ្រានោះ ភិក្ខុទាំងនោះ មានសេចក្តីត្រិះរិះដូច្នេះថា

អយំ ខោ អាយស្មា មហាកច្ចានោ សត្ថុ ចេវ សំវណ្ណិតោ សម្ភាវិតោ ច វិញ្ញូនំ សព្រហ្មចារីនំ បហោតិ ចាយស្មា មហាកច្ចានោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជិតុំ យន្នូន មយំ យេនាយស្មា មហាកច្ចានោ តេនុបសង្កមេយ្យាម ឧបសង្កមិត្វា អាយស្មន្តំ មហាកច្ចានំ ឯតមត្ថំ បដិបុច្ឆេយ្យាមាតិ ។

[១១៦] អថខោ តេ ភិក្ខូ យេនាយស្មា មហាកច្ចានោ តេនុបសង្កមឹសុ ឧបសង្កមិត្វា អាយស្មតា មហាកច្ចានេន សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នោ ខោ តេ ភិក្ខូ អាយស្មន្តំ មហាកច្ចានំ ឯតទវោចុំ ឥទំ ខោ នោ អាវុសោ កច្ចាន ភគវា សង្ខិត្តេន ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា

ព្រះមហាកច្ចានៈមានអាយុនេះ ព្រះសាស្តាទ្រង់សរសើរផង សព្រហ្ម-ចារីទាំងឡាយជាអ្នកប្រាជ្ញ លើកតម្កើងផង ឧទ្ទេសដែលព្រះមានព្រះភាគទ្រង់សំដែង ដោយសង្ខេប មិនបានចែកអត្ថ ដោយពិស្តារនេះ មានតែព្រះមហាកច្ចានៈមានអាយុ ទើបអាចចែកអត្ថដោយពិស្តារបាន បើដូច្នោះ គួរតែយើងទាំងឡាយ នាំគ្នាចូលទៅរកព្រះមហាកច្ចានៈមានអាយុ លុះចូលទៅដល់ហើយ យើងទាំងឡាយគប្បីសួរនូវសេចក្តីនេះនឹងព្រះមហាកច្ចានៈមានអាយុ ។

[១១៦] លំដាប់នោះ ភិក្ខុទាំងនោះ ក៏នាំគ្នាចូលទៅរកព្រះមហាកច្ចានៈមានអាយុ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់-ទាក់សំណេះសំណាល នឹងព្រះមហាកច្ចានៈមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ ក៏ពោលនឹងព្រះមហាកច្ចានៈមានអាយុ ដូច្នេះថា បពិត្រព្រះកច្ចានៈមានអាយុ ព្រះមានព្រះភាគទ្រង់សំដែងឧទ្ទេសនេះ ដល់យើងទាំងឡាយដោយសង្ខេប មិនបានចែកអត្ថដោយពិស្តារ ស្រាប់តែទ្រង់ក្រោកអំពីអាសនៈ

វិហារំ បវិដ្ឋោ តថា តថា ភិក្ខវេ ភិក្ខុ ឧបបរិក្ខេយ្យ យថា យថាស្ស ឧបបរិក្ខតោ ពហិទ្ធា ចស្ស វិញ្ញាណំ អវិក្ខិត្តំ អវិសដំ អជ្ឈត្តំ អសណ្ឋិតំ អនុបាទាយ ន បរិតស្សេយ្យ ពហិទ្ធា ភិក្ខវេ វិញ្ញាណេ អវិក្ខិត្តេ អវិសដេ សតិ អជ្ឈត្តំ អសណ្ឋិតេ អនុបាទាយ អបរិតស្សតោ អាយតឹ ជាតិជរាមរណទុក្ខសមុទយសម្ភវោ ន ហោតីតិ តេសន្នោ អាវុសោ អម្ហាកំ អចិរបក្កន្តស្ស ភគវតោ ឯតទហោសិ ឥទំ ខោ នោ អាវុសោ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា

ចូលទៅកាន់វិហារ គឺទ្រង់ត្រាស់ថា កាលបើភិក្ខុនោះ ពិចារណាហើយ វិញ្ញាណរបស់ភិក្ខុនោះ មិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ ទាំងមិនឋិតនៅខាងក្នុង ហើយមិនបានតក់ស្លុត ព្រោះមិនប្រកាន់មាំ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះ មានវិញ្ញាណមិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ ទាំងមិនឋិតនៅខាងក្នុង មិនតក់ស្លុត ព្រោះមិនបានប្រកាន់មាំហើយ សេចក្តីកើតឡើងព្រម មានព្រមនៃជាតិ ជរា មរណៈ និងទុក្ខ រមែងមិនមានតទៅទៀត ដោយប្រការយ៉ាងណា ៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីពិចារណាដោយប្រការយ៉ាងនោះ ៗ ចុះបពិត្រព្រះកច្ចានៈមានអាយុ កាលដែលព្រះមានព្រះភាគ ទ្រង់ស្តេចចេញទៅ មិនយូរប៉ុន្មាន យើងទាំងឡាយនោះ ក៏មានសេចក្តីត្រិះរិះដូច្នេះថា ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគទ្រង់សំដែងឧទ្ទេសនេះដល់យើងទាំងឡាយ ដោយសង្ខេប មិនបានចែកអត្ថដោយពិស្តារ

ឧដ្ឋាយាសនា វិហារំ បាវិដ្ឋោ តថា តថា ភិក្ខវេ ភិក្ខុ ឧបបរិក្ខេយ្យ យថា យថាស្ស ឧបបរិក្ខតោ ពហិទ្ធា ចស្ស វិញ្ញាណំ អវិក្ខិត្តំ អវិសដំ អជ្ឈត្តំ អសណ្ឋិតំ អនុបាទាយ ន បរិតស្សេយ្យ ពហិទ្ធា ភិក្ខវេ វិញ្ញា-ណេ អវិក្ខិត្តេ អវិសដេ សតិ អជ្ឈត្តំ អសណ្ឋិតេ អនុបាទាយ អបរិតស្សតោ អាយតឹ ជាតិជរាមរណ-ទុក្ខសមុទយសម្ភវោ ន ហោតីតិ កោ នុ ខោ ឥ-មស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថា-រេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជេយ្យាតិ តេ-សន្នោ អាវុសោ កច្ចាន អម្ហាកំ ឯតទហោសិ អយំ ខោ អាយស្មា មហាកច្ចានោ សត្ថុ ចេវ សំវណ្ណិ-តោ សម្ភាវិតោ ច វិញ្ញូនំ សព្រហ្មចារីនំ បហោតិ

ឡើយ ក៏ស្រាប់តែទ្រង់ក្រោកអំពីអាសនៈ ចូលទៅកាន់វិហារ គឺទ្រង់ត្រាស់ថា កាលបើភិក្ខុនោះពិចារណាហើយ វិញ្ញាណរបស់ភិក្ខុនោះមិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ ទាំងមិនឋិតនៅខាងក្នុង ហើយមិនតក់ស្លុត ព្រោះមិនប្រកាន់មាំ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះ មានវិញ្ញាណមិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ ទាំងមិនឋិតនៅខាងក្នុង មិនតក់ស្លុត ព្រោះមិនប្រកាន់មាំហើយ សេចក្តីកើតឡើងព្រម មានព្រមនៃជាតិ ជរា មរណៈ និងទុក្ខ រមែងមិនមានតទៅទៀត ដោយប្រការយ៉ាងណា ៗ ម្នាលភិក្ខុទាំងឡាយភិក្ខុគប្បីពិចារណា ដោយប្រការ យ៉ាងនោះ ៗ ចុះ តើឧទ្ទេសដែលព្រះមានព្រះភាគទ្រង់សំដែង ដោយសង្ខេប មិនបានចែកអត្ថដោយពិស្តារនេះ នរណាហ្ន៎ នឹងអាចចែកអត្ថដោយពិស្តារបាន បពិត្រព្រះកច្ចានៈមានអាយុ យើងទាំងឡាយនោះ ក៏មានសេចក្តីត្រិះរិះដូច្នេះថា ព្រះមហាកច្ចានៈមានអាយុនេះឯង ព្រះសាស្តាទ្រង់សរសើរផង សព្រហ្មចារីទាំងឡាយជាអ្នកប្រាជ្ញ លើកតម្កើងផង

ចាយស្មា មហាកច្ចានោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជិតុំ យន្នូន មយំ យេនាយស្មា មហាកច្ចានោ តេនុបសង្កមេយ្យាម ឧបសង្កមិត្វា អាយស្មន្តំ មហាកច្ចានំ ឯតមត្ថំ បដិបុច្ឆេយ្យាមាតិ វិភជតាយស្មា មហាកច្ចានោតិ ។

[១១៧] សេយ្យថាបិ អាវុសោ បុរិសោ សារត្ថិកោ សារគវេសី សារបរិយេសនចារិកំ ចរមានោ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ អតិក្កម្មេវ មូលំ អតិក្កម្ម ខន្ធំ សាខាបលាសេ សារំ បរិយេសិតព្វំ មញ្ញេយ្យ ឯវំ សម្បទមិទំ អាយស្មន្តានំ សត្ថរិ សម្មុខីភូតេ តំ ភគវន្តំ អតិសិត្វា អម្ហេ ឯតមត្ថំ បដិបុច្ឆិតព្វំ មញ្ញថ

ឧទ្ទេសដែលព្រះមានព្រះភាគទ្រង់សំដែង ដោយសង្ខេប មិនបានចែកអត្ថដោយពិស្តារនេះ មានតែព្រះមហាកច្ចានៈមានអាយុ ទើបអាចចែកអត្ថដោយពិស្តារបាន បើដូច្នោះ គួរតែយើងទាំងឡាយនាំគ្នាចូលទៅរកព្រះមហាកច្ចានៈមានអាយុ លុះចូលទៅដល់ហើយ យើងទាំងឡាយគប្បីសួរនូវសេចក្តីនេះ នឹងព្រះមហាកច្ចានៈមានអាយុ ដូច្នេះ សូមព្រះមហាកច្ចានៈមានអាយុ ចែក (អត្ថនោះដោយពិស្តារឲ្យទាន) ។

[១១៧] ព្រះមហាកច្ចានៈ មានអាយុ ពោលថា ម្នាលអាវុសោទាំងឡាយ បុរសអ្នកត្រូវការដោយឈើខ្លឹម ជាអ្នកស្វែងរកឈើខ្លឹម បានដើរទៅស្វែងរកឈើខ្លឹម កាលបើដើមឈើធំដុះនៅ (ចំពោះមុខ) ក៏ដើររំលងឫស រំលងដើម សំគាល់នូវមែកនិងសន្ទឹកថាជាខ្លឹមដែលខ្លួនត្រូវស្វែងរកវិញ មានឧបមាដូចម្តេចមិញ សេចក្តីនេះក៏មានឧបមេយ្យដូច កាលដែលព្រះសាស្តា ឋិតនៅចំពោះមុខ នៃលោកមានអាយុទាំងឡាយ លោកទាំងឡាយ ក៏រំលងព្រះមានព្រះភាគនោះ ហើយសំគាល់នូវយើងថាជាបុគ្គលគួរសួរនូវសេចក្តីនេះវិញ

សោ ហាវុសោ[១] ភគវា ជានំ ជានាតិ បស្សំ បស្សតិ ចក្ខុភូតោ ញាណភូតោ ធម្មភូតោ ព្រហ្មភូតោ វត្តា បវត្តា អត្ថស្ស និន្នេតា អមតស្ស ទាតា ធម្មស្សាមី តថាគតោ សោ ចេវ បនេតស្ស កាលោ អហោសិ យំ ភគវន្តំយេវ ឯតមត្ថំ បដិបុច្ឆេយ្យាថ យថា នោ[២] ភគវា ព្យាករេយ្យ តថា នំ ធារេយ្យាថាតិ ។ អទ្ធាវុសោ កច្ចាន ភគវា ជានំ ជានាតិ បស្សំ បស្សតិ ចក្ខុភូតោ ញាណភូតោ ធម្មភូតោ ព្រហ្មភូតោ វត្តា បវត្តា អត្ថស្ស និន្នេតា អមតស្ស ទាតា

១ ម. អាវុសោ ។ ២ ឱ. ម. វោ ។

ម្នាលអាវុសោទាំងឡាយ ព្រោះថា ព្រះមានព្រះភាគនោះ ព្រះអង្គជ្រាបនូវហេតុដែលគួរជ្រាប ឃើញនូវហេតុដែលគួរឃើញបាន ជាអ្នកមានបញ្ញាចក្ខុកើតហើយ មានញាណកើតហើយ មានធម៌កើតហើយ មានសេចក្តីប្រសើរកើតហើយ ជាអ្នកពោលធម៌ ជាអ្នកញ៉ាំងធម៌ឲ្យប្រព្រឹត្តទៅ ជាអ្នកពន្យល់សេចក្តី ជាអ្នកឲ្យនូវអមតៈ (និព្វាន) ព្រះតថាគតជាម្ចាស់នៃធម៌ កាលនោះជាកាលគួរ អ្នកទាំងឡាយសួរសេចក្តីនេះ នឹងព្រះមានព្រះភាគបាន ព្រះមានព្រះភាគព្យាករដល់អ្នកទាំងឡាយ យ៉ាងណា អ្នកទាំងឡាយ គប្បីចាំទុកនូវសេចក្តីនោះយ៉ាងនោះ ។ ភិក្ខុទាំងឡាយពោលថា ម្នាលព្រះកច្ចានៈមានអាយុ ព្រះមានព្រះភាគ ព្រះអង្គជ្រាបនូវហេតុដែលគួរជ្រាប ឃើញនូវហេតុដែលគួរឃើញ ព្រះអង្គមានចក្ខុកើតហើយ មានញាណកើតហើយ មានធម៌កើតហើយ មានសេចក្តីប្រសើរកើតហើយ ជាអ្នកពោលធម៌ ជាអ្នកញ៉ាំងធម៌ឲ្យប្រព្រឹត្តទៅ ជាអ្នកពន្យល់សេចក្តី ជាអ្នកឲ្យនូវអមតៈ (និព្វាន)

ធម្មស្សាមី តថាគតោ សោ ចេវ បនេតស្ស កាលោ អហោសិ យំ ភគវន្តំយេវ ឯតមត្ថំ បដិបុច្ឆេយ្យាម យថា នោ ភគវា ព្យាករេយ្យ តថា នំ ធារេយ្យាម អបិចាយស្មា មហាកច្ចានោ សត្ថុ ចេវ សំវណ្ណិតោ សម្ភាវិតោ ច វិញ្ញូនំ សព្រហ្មចារីនំ បហោតិ ចា-យស្មា មហាកច្ចានោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជិតុំ វិភជតាយស្មា មហាកច្ចានោ អគរុករិត្វាតិ ។ តេនហាវុសោ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវមាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ មហាកច្ចានស្ស បច្ចស្សោ-សុំ ។

ព្រះតថាគតជាម្ចាស់នៃធម៌ កាលនោះជាកាលគួរយើងទាំងឡាយ សួរសេចក្តីនេះ នឹងព្រះមានព្រះភាគហើយ បើព្រះមានព្រះភាគព្យាករ ដល់យើងទាំងឡាយ យ៉ាងណា យើងទាំងឡាយ គប្បីចាំទុកនូវសេចក្តីនោះ យ៉ាងនោះ ដោយពិតមែនហើយ តែថាព្រះមហាកច្ចានៈ មានអាយុ ព្រះសាស្តាសរសើរផង សព្រហ្មចារីទាំងឡាយជាអ្នកប្រាជ្ញលើកតម្កើងផង ឧទ្ទេសដែលព្រះមានព្រះភាគទ្រង់សំដែងដោយសង្ខេប មិនបានចែកអត្ថដោយពិស្តារនេះ មានតែព្រះមហាកច្ចានៈ ទើបអាចចែកនូវអត្ថដោយពិស្តារបាន សូមព្រះមហាកច្ចានៈមានអាយុ កុំធ្វើនូវសេចក្តីចង្អៀតចង្អល់ឡើយ សូមចែក (អត្ថនេះដោយពិស្តារ) ។ ព្រះមហាកច្ចានៈពោលថា ម្នាលអាវុសោទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយ ចូរស្តាប់ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ ខ្ញុំនឹងសំដែងឲ្យស្តាប់ ។ ភិក្ខុទាំងនោះ ទទួលស្តាប់ពាក្យព្រះមហាកច្ចានៈមានអាយុថា ករុណា អាវុសោ ។

១២៧

វិភង្គវគ្គស្ស ឧទ្ទេសវិភង្គសុត្តេ វិត្ថារុទ្ទេសត្ថវិភជនំ

[១១៨] អាយស្មា មហាកច្ចានោ ឯតទវោច យំ ខោ នោ អាវុសោ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ តថា តថា ភិក្ខវេ ភិក្ខុ ឧបបរិក្ខេយ្យ យថា យថាស្ស ឧបបរិក្ខតោ ពហិទ្ធា ចស្ស វិញ្ញាណំ អវិក្ខិត្តំ អវិសដំ អជ្ឈត្តំ អសណ្ឋិតំ អនុបាទាយ ន បរិតស្សេយ្យ ពហិទ្ធា ភិក្ខវេ វិញ្ញាណេ អវិក្ខិត្តេ អវិសដេ សតិ អជ្ឈត្តំ អសណ្ឋិតេ អនុបាទាយ អបរិតស្សតោ អាយតឹ ជាតិជរាមរណទុក្ខសមុទយសម្ភវោ ន ហោតីតិ ឥមស្ស ខោ អហំ អាវុសោ ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស ឯវំ វិត្ថារេន អត្ថំ អាជានាមិ ។

[១១៨] ព្រះមហាកច្ចាន:មានអាយុ ពោលដូច្នេះថា ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគទ្រង់សំដែងឧទ្ទេសណា ដល់យើងទាំងឡាយដោយសង្ខេប មិនបានចែកអត្ថដោយពិស្តារ ស្រាប់តែទ្រង់ក្រោកអំពីអាសន: ចូលទៅកាន់វិហារ គឺទ្រង់ត្រាស់ថា កាលបើភិក្ខុនោះ ពិចារណាហើយ វិញ្ញាណរបស់ភិក្ខុនោះ មិនរាត់រាយមិនខ្ចាត់ខ្ចាយទៅខាងក្រៅ ទាំងមិនឋិតនៅខាងក្នុង ហើយមិនតក់ស្លុតព្រោះមិនប្រកាន់មាំ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះ មានវិញ្ញាណមិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ ទាំងមិនឋិតនៅខាងក្នុង មិនតក់ស្លុត ព្រោះមិនប្រកាន់មាំហើយ ការកើតឡើងព្រម មានព្រមនៃជាតិ ជរា មរណ: និងទុក្ខ រមែងមិនមានតទៅទៀត ដោយប្រការយ៉ាងណា ៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីពិចារណា ដោយប្រការយ៉ាងនោះ ៗ ចុះ ម្នាលអាវុសោទាំងឡាយ ឧទ្ទេសនេះឯង ដែលព្រះមានព្រះភាគទ្រង់សំដែង ដោយសង្ខេប មិនបានចែកអត្ថដោយពិស្តារ ខ្ញុំក៏ដឹងច្បាស់នូវអត្ថ ដោយពិស្តារ ដូចនឹងពោលតទៅនេះឯង ។

[១១៩] កថញ្ចាវុសោ ពហិទ្ធា វិញ្ញាណំ វិក្ខិត្តំ វិសដន្តិ វុច្ចន្តិ ។ ឥធាវុសោ ភិក្ខុនោ ចក្ខុនា រូបំ ទិស្វា រូបនិមិត្តានុសារិ វិញ្ញាណំ ហោតិ រូបនិមិត្តស្សាទគធិតំ រូបនិមិត្តស្សាទវិនិពន្ធំ រូបនិមិត្តស្សាទសញ្ញោជនសំយុត្តំ ពហិទ្ធា វិញ្ញាណំ វិក្ខិត្តំ វិសដន្តិ វុច្ចតិ ។ សោតេន សទ្ទំ សុត្វា... ឃានេន គន្ធំ ឃាយិត្វា... ជិវ្ហាយ រសំ សាយិត្វា... កាយេន ផោដ្ឋព្វំ ផុសិត្វា... មនសា ធម្មំ វិញ្ញាយ ធម្មនិមិត្តានុសារិ វិញ្ញាណំ ហោតិ ធម្មនិមិត្តស្សាទគធិតំ ធម្មនិមិត្តស្សាទវិនិពន្ធំ ធម្មនិមិត្តស្សាទសញ្ញោជនសំយុត្តំ ពហិទ្ធា វិញ្ញាណំ វិក្ខិត្តំ វិសដន្តិ វុច្ចតិ ។ ឯវំ ខោ អាវុសោ ពហិទ្ធា វិញ្ញាណំ វិក្ខិត្តំ វិសដន្តិ វុច្ចតិ ។

[១១៩] ម្នាលអាវុសោទាំងឡាយ ដូចម្តេចហៅថាវិញ្ញាណរាត់-រាយ ខ្ចាត់ខ្ចាយទៅខាងក្រៅ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយចក្ខុហើយ ក៏មានវិញ្ញាណរលឹកទៅតាមរូបនិមិត្ត ប្រាថ្នាដោយសេចក្តីត្រេកអរក្នុងរូបនិមិត្ត ជាប់ចំពាក់ដោយសេចក្តីត្រេកអរក្នុងរូបនិមិត្ត ប្រកបដោយសេចក្តីត្រេកអរក្នុងរូបនិមិត្ត (នេះ) ហៅថាវិញ្ញាណរាត់រាយ ខ្ចាត់ខ្ចាយទៅខាងក្រៅ ។ ភិក្ខុឮសំឡេងដោយត្រចៀក... ធុំក្លិនដោយច្រមុះ... ទទួលរសដោយអណ្តាត... ប៉ះពាល់ផោដ្ឋព្វៈដោយកាយ... ដឹងនូវធម៌ដោយចិត្តហើយ ក៏មានវិញ្ញាណរលឹកទៅតាមធម្មនិមិត្ត ប្រាថ្នាដោយសេចក្តីត្រេកអរក្នុងធម្មនិមិត្ត ជាប់ចំពាក់ដោយសេចក្តីត្រេកអរក្នុងធម្មនិមិត្ត ប្រកបព្រមដោយសេចក្តីត្រេកអរក្នុងធម្មនិមិត្ត (នេះ) ហៅថាវិញ្ញាណរាត់រាយ ខ្ចាត់ខ្ចាយទៅខាងក្រៅ ។ ម្នាលអាវុសោទាំងឡាយ ដែលហៅថា វិញ្ញាណរាត់រាយ ខ្ចាត់ខ្ចាយទៅខាងក្រៅ យ៉ាងនេះឯង ។

[១២០] កាចញារុសោ ពហិទ្ធា វិញ្ញាណំ អវិក្ខិត្តំ អវិសដន្តិ វុច្ចតិ ។ ឥជារុសោ ភិក្ខុនោ ចក្ខុនា រូបំ ទិស្វា ន រូបនិមិត្តានុសារិ វិញ្ញាណំ ហោតិ ន រូបនិមិត្តស្សាទគធិតំ ន រូបនិមិត្តស្សាទវិនិពន្ធំ ន រូបនិមិត្តស្សាទសញ្ញោជនសំយុត្តំ ពហិទ្ធា វិញ្ញាណំ អវិក្ខិត្តំ អវិសដន្តិ វុច្ចតិ ។ សោតេន សទ្ទំ សុត្វា... ឃានេន គន្ធំ ឃាយិត្វា... ជិវ្ហាយ រសំ សាយិត្វា... កាយេន ផោដ្ឋព្វំ ផុសិត្វា... មនសា ជម្មំ វិញ្ញាយ ន ជម្មនិមិត្តានុសារិ វិញ្ញាណំ ហោតិ ន ជម្មនិមិត្តស្សាទគធិតំ ន ជម្មនិមិត្តស្សាទវិនិពន្ធំ ន ជម្មនិមិត្តស្សាទសញ្ញោជនសំយុត្តំ ពហិទ្ធា វិញ្ញាណំ អវិក្ខិត្តំ អវិសដន្តិ វុច្ចតិ ។ ឯវំ ខោ អាវុសោ ពហិទ្ធា វិញ្ញាណំ អវិក្ខិត្តំ អវិសដន្តិ វុច្ចតិ ។

វិភង្គវគ្គ ឧទ្ទេសវិភង្គសូត្រ វិញ្ញាណមិនរាត់រាយ

[១២០] ម្នាលអាវុសោទាំងឡាយ ដូចម្តេចហៅថាវិញ្ញាណមិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយចក្ខុហើយ តែវិញ្ញាណមិនបានរលឹកទៅតាមរូបនិមិត្ត មិនបានប្រាថ្នាដោយសេចក្តីត្រេកអរក្នុងរូបនិមិត្ត មិនជាប់ចំពាក់ដោយសេចក្តីត្រេកអរក្នុងរូបនិមិត្ត មិនប្រកបព្រមដោយសេចក្តីត្រេកអរក្នុងរូបនិមិត្ត (នេះ) ហៅថាវិញ្ញាណមិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ ។ ភិក្ខុឮសំឡេងដោយត្រចៀក... ធុំក្លិនដោយច្រមុះ... ទទួលរសដោយអណ្តាត... ប៉ះពាល់នូវផោដ្ឋព្វៈដោយកាយ... ដឹងនូវធម៌ដោយចិត្តហើយ វិញ្ញាណក៏មិនបានរលឹកទៅតាមធម្មនិមិត្ត មិនប្រាថ្នាដោយសេចក្តីត្រេកអរ ក្នុងធម្មនិមិត្ត មិនជាប់ចំពាក់ដោយសេចក្តីត្រេកអរក្នុងធម្មនិមិត្ត មិនប្រកបព្រមដោយសេចក្តីត្រេកអរក្នុងធម្មនិមិត្ត (នេះ) ហៅថាវិញ្ញាណមិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ ។ ម្នាលអាវុសោទាំងឡាយ ដែលហៅថាវិញ្ញាណមិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ យ៉ាងនេះឯង ។

[១២១] កាចញ្ចាវុសោ អជ្ឈត្តំ ចិត្តំ សណ្ឋិតន្តិ វុច្ចតិ ។ ឥធាវុសោ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ តស្ស វិវេកជប្បីតិសុខានុសារិ វិញ្ញាណំ ហោតិ វិវេកជប្បីតិសុខស្សាទគធិតំ វិវេកជប្បីតិសុខស្សាទវិនិពទ្ធំ វិវេកជប្បីតិសុខស្សាទសញ្ញោជនសំយុត្តំ អជ្ឈត្តំ ចិត្តំ សណ្ឋិតន្តិ វុច្ចតិ ។ បុន ចបរំ អាវុសោ ភិក្ខុ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។

[១២១] ម្នាលអាវុសោទាំងឡាយ ដូចម្តេចហៅថា ចិត្តឋិតនៅខាងក្នុង ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ បានដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្កៈ វិចារៈ មានតែបីតិនិងសុខដែលកើតអំពីវិវេក ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ភិក្ខុនោះ រមែងមានវិញ្ញាណ រលឹកទៅតាមបីតិនិងសុខដែលកើតអំពីវិវេក ប្រាថ្នាដោយសេចក្តីត្រេកអរ ក្នុងបីតិនិងសុខដែលកើតអំពីវិវេក ជាប់ចំពាក់ដោយសេចក្តីត្រេកអរ ក្នុងបីតិនិងសុខដែលកើតអំពីវិវេក ប្រកបព្រមដោយសេចក្តីត្រេកអរក្នុងបីតិនិងសុខដែលកើតអំពីវិវេក (នេះ) ហៅថា ចិត្តឋិតនៅខាងក្នុង ។ ម្នាលអាវុសោទាំងឡាយ មួយវិញទៀត ភិក្ខុព្រោះរម្ងាប់នូវវិតក្កៈនិងវិចារៈ រួចហើយបានដល់នូវទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្តានចិត្ត ប្រកបដោយសេចក្តីជ្រះថ្លាគឺសទ្ធា មានភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខកើតអំពីសមាធិគឺបឋមជ្ឈាន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។

តស្ស សមាធិជប្បីតិសុខានុសារិ វិញ្ញាណំ ហោតិ សមាធិជប្បីតិសុខស្សាទគធិតំ សមាធិជប្បីតិសុខស្សាទ-វិនិពន្ធំ សមាធិជប្បីតិសុខស្សាទសញ្ញោជនសំយុត្តំ អជ្ឈត្តំ ចិត្តំ សណ្ឋិតន្តិ វុច្ចតិ ។ បុន ចបរំ អាវុសោ ភិក្ខុ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិ-ហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ តស្ស ឧបេក្ខាសុខានុសារិ វិញ្ញាណំ ហោតិ ឧបេក្ខាសុខស្សា-ទគធិតំ ឧបេក្ខាសុខស្សាទវិនិពន្ធំ ឧបេក្ខាសុខស្សា-ទសញ្ញោជនសំយុត្តំ អជ្ឈត្តំ ចិត្តំ សណ្ឋិតន្តិ វុច្ចតិ ។ បុន ចបរំ អាវុសោ ភិក្ខុ សុខស្ស ច បហានា

ភិក្ខុនោះ រមែងមានវិញ្ញាណរលឹកទៅតាមនូវបីតិនិងសុខ ដែលកើតអំពីសមាធិ ប្រាថ្នាដោយសេចក្តីត្រេកអរ ក្នុងបីតិនិងសុខ ដែលកើតអំពីសមាធិ ជាប់ចំពាក់ដោយសេចក្តីត្រេកអរក្នុងបីតិនិងសុខ ដែលកើតអំពីសមាធិ ប្រកបព្រមដោយសេចក្តីត្រេកអរក្នុងបីតិនិងសុខ ដែលកើតអំពីសមាធិ (នេះ) ហៅថា ចិត្តឋិតនៅខាងក្នុង ។ ម្នាលអាវុសោទាំង-ឡាយ មួយទៀត ភិក្ខុ ព្រោះនឿយណាយចាកបីតិហើយ ប្រកបដោយឧបេក្ខា មានស្មារតី និងមានសេចក្តីដឹងខ្លួន ទទួលសេចក្តីសុខដោយនាមកាយ ព្រះអរិយៈទាំងឡាយ តែងសរសើរបុគ្គលដែលបានតតិយជ្ឈាន ទោះបីបុគ្គលដែលបានតតិយជ្ឈាន តែងមានចិត្តប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ព្រោះតតិយជ្ឈានណា ក៏បានដល់នូវតតិយជ្ឈាននោះ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ភិក្ខុនោះ រមែងមានវិញ្ញាណរលឹកទៅតាមនូវឧបេក្ខា ប្រាថ្នាដោយសេចក្តីត្រេកអរ ក្នុងសុខប្រកបដោយឧបេក្ខា ជាប់ចំពាក់ដោយសេចក្តីត្រេកអរ ក្នុងសុខប្រកបដោយឧបេក្ខា ប្រកបព្រមដោយសេចក្តីត្រេកអរ ក្នុងឧបេក្ខានិងសុខ (នេះ) ហៅថាចិត្តឋិតនៅខាងក្នុង ។ ម្នាលអាវុសោទាំងឡាយ មួយវិញទៀត ភិក្ខុព្រោះលះបង់នូវសុខផង

ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ តស្ស អទុក្ខមសុខានុសារិ វិញ្ញាណំ ហោតិ អទុក្ខមសុខស្សាទគធិតំ អទុក្ខមសុខស្សាទវិនិពន្ធំ អទុក្ខមសុខស្សាទសញ្ញោជនសំយុត្តំ អជ្ឈត្តំ ចិត្តំ សណ្ឋិតន្តិ វុច្ចតិ ។ ឯវំ ខោ អាវុសោ អជ្ឈត្តំ ចិត្តំ សណ្ឋិតន្តិ វុច្ចតិ ។

[១២២] កថញ្ចាវុសោ អជ្ឈត្តំ ចិត្តំ អសណ្ឋិតន្តិ វុច្ចតិ ។ ឥធាវុសោ ភិក្ខុ វិវិច្ចេវ កាមេហិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ តស្ស ន វិវេកជបីតិសុខានុសារិ វិញ្ញាណំ ហោតិ ន វិវេកជបីតិសុខស្សាទគធិតំ ន វិវេកជបីតិសុខស្សាទវិនិពន្ធំ ន វិវេកជបីតិសុខស្សាទសញ្ញោជនសំយុត្តំ អជ្ឈត្តំ ចិត្តំ អសណ្ឋិតន្តិ វុច្ចតិ ។ បុន ចបរំ អាវុសោ

លះបង់នូវទុក្ខផង មានសោមនស្សនិងទោមនស្សអស់ហើយក្នុងកាលមុនផង ក៏បានដល់នូវចតុត្ថជ្ឈាន ដែលមិនមានទុក្ខ មិនមានសុខ មានតែសតិដ៏បរិសុទ្ធដោយឧបេក្ខា ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ភិក្ខុនោះ រមែងមានវិញ្ញាណរលឹកទៅតាមអទុក្ខមសុខគឺឧបេក្ខា ប្រាថ្នាដោយសេចក្តីត្រេកអរក្នុងអទុក្ខមសុខ ជាប់ចំពាក់ដោយសេចក្តីត្រេកអរក្នុងអទុក្ខមសុខ ប្រកបព្រមដោយសេចក្តីត្រេកអរ ក្នុងអទុក្ខមសុខ (នេះ) ហៅថា ចិត្តឋិតនៅខាងក្នុង ។ ម្នាលអាវុសោទាំងឡាយ យ៉ាងនេះឯង ដែលហៅថា ចិត្តឋិតនៅខាងក្នុង ។

[១២២] ម្នាលអាវុសោទាំងឡាយ ចុះដូចម្តេចហៅថាចិត្តមិនឋិតនៅខាងក្នុង ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ បានដល់នូវបឋមជ្ឈាន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ភិក្ខុនោះ រមែងមានវិញ្ញាណមិនបានរលឹកទៅតាមបីតិនិងសុខដែលកើតអំពីវិវេក មិនបានប្រាថ្នាដោយសេចក្តីត្រេកអរ ក្នុងបីតិនិងសុខដែលកើតអំពីវិវេក មិនបានជាប់ចំពាក់ដោយសេចក្តីត្រេកអរក្នុងបីតិនិងសុខដែលកើតអំពីវិវេក មិនប្រកបព្រមដោយសេចក្តីត្រេកអរក្នុងបីតិនិងសុខដែលកើតអំពីវិវេក (នេះ) ហៅថា ចិត្តមិនឋិតនៅខាងក្នុង ។ ម្នាលអាវុសោទាំងឡាយ មួយវិញទៀត

ភិក្ខុ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ តស្ស ន សមាធិជប្បីតិសុខានុសារិ វិញ្ញាណំ ហោតិ ន សមាធិជប្បីតិសុខស្សាទគធិតំ ន សមាធិជប្បីតិសុខស្សាទវិនិពន្ធំ ន សមាធិជប្បីតិសុខស្សាទសញ្ញោជនសំយុត្តំ អជ្ឈត្តំ ចិត្តំ អសណ្ឋិតន្តិ វុច្ចតិ ។ បុន ចបរំ អាវុសោ ភិក្ខុ បីតិយា ច វិរាគា ។ បេ ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ តស្ស ន ឧបេក្ខាសុខានុសារិ វិញ្ញាណំ ហោតិ ន ឧបេក្ខាសុខស្សាទគធិតំ ន ឧបេក្ខាសុខស្សាទវិនិពន្ធំ ន ឧបេក្ខាសុខស្សាទសញ្ញោជនសំយុត្តំ អជ្ឈត្តំ ចិត្តំ អសណ្ឋិតន្តិ វុច្ចតិ ។ បុន ចបរំ អាវុសោ ភិក្ខុ សុខស្ស ច បហានា ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ តស្ស ន អទុក្ខមសុខានុសារិ វិញ្ញាណំ ហោតិ

ភិក្ខុ ព្រោះរម្ងាប់នូវវិតក្កៈនិងវិចារៈ ។ បេ ។ បានដល់នូវទុតិយជ្ឈាន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ភិក្ខុនោះរមែងមានវិញ្ញាណមិនបានរលឹកទៅតាមបីតិនិងសុខដែលកើតអំពីសមាធិ មិនបានប្រាថ្នាដោយសេចក្តីត្រេកអរ ក្នុងបីតិនិងសុខដែលកើតអំពីសមាធិ មិនជាប់ចំពាក់ដោយសេចក្តីត្រេកអរក្នុងបីតិនិងសុខដែលកើតអំពីសមាធិ មិនប្រកបព្រមដោយសេចក្តីត្រេកអរ ក្នុងបីតិនិងសុខ ដែលកើតអំពីសមាធិ (នេះ) ហៅថាចិត្តមិនឋិតនៅខាងក្នុង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុ ព្រោះនឿយណាយចាកបីតិ ។ បេ ។ បានដល់នូវតតិយជ្ឈាន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ភិក្ខុនោះរមែងមានវិញ្ញាណមិនបានរលឹកទៅតាមឧបេក្ខា មិនបានប្រាថ្នាដោយសេចក្តីត្រេកអរក្នុងសុខប្រកបដោយឧបេក្ខា មិនជាប់ចំពាក់ដោយសេចក្តីត្រេកអរ ក្នុងឧបេក្ខានិងសុខ មិនប្រកបព្រមដោយសេចក្តីត្រេកអរ ក្នុងសុខប្រកបដោយឧបេក្ខា (នេះ) ហៅថា ចិត្តមិនឋិតនៅខាងក្នុង ។ ម្នាលអាវុសោទាំងឡាយ មួយវិញទៀត ភិក្ខុ ព្រោះលះបង់នូវសុខផង ។ បេ ។ បានដល់នូវចតុត្ថជ្ឈាន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ភិក្ខុនោះ រមែងមានវិញ្ញាណមិនបានរលឹកទៅតាមអទុក្ខមសុខ

ន អទុក្ខមសុខស្សាទគធិតំ ន អទុក្ខមសុខស្សាទវិនិពន្ធំ ន អទុក្ខមសុខស្សាទសញ្ញោជនសំយុត្តំ អជ្ឈត្តំ ចិត្តំ អសណ្ឋិតន្តិ វុច្ចតិ ។ ឯវំ ខោ អាវុសោ អជ្ឈត្តំ ចិត្តំ អសណ្ឋិតន្តិ វុច្ចតិ ។

[១២៣] កថញ្ចាវុសោ អនុបាទា បរិតស្សនា ហោតិ ។ ឥធាវុសោ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្មស្ស អកោវិទោ អរិយធម្មេ អវិនីតោ សប្បុរិសានំ អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិសធម្មេ អវិនីតោ រូបំ អត្តតោ សមនុបស្សតិ រូបវន្តំ វា អត្តានំ អត្តនិ វា រូបំ រូបស្មឹ វា អត្តានំ ។ តស្ស តំ រូបំ វិបរិណាមតិ អញ្ញថា ហោតិ ។ តស្ស រូបវិបរិណាមញ្ញថាភាវា រូបវិបរិណាមានុបរិវត្តិ វិញ្ញាណំ ហោតិ ។ តស្ស រូបវិបរិណាមានុបរិវត្តជា បរិតស្សនា ធម្មសមុប្បាទា ចិត្តំ បរិយាទាយ តិដ្ឋន្តិ ។

មិនប្រាថ្នាដោយសេចក្តីត្រេកអរ ក្នុងអទុក្ខមសុខ មិនជាប់ចំពាក់ដោយសេចក្តីត្រេកអរ ក្នុងអទុក្ខមសុខ មិនប្រកបព្រមដោយសេចក្តីត្រេកអរក្នុងអទុក្ខមសុខ (នេះ) ហៅថា ចិត្តមិនឋិតនៅខាងក្នុង ។ ម្នាលអាវុសោទាំងឡាយ យ៉ាងនេះឯង ហៅថា ចិត្តមិនឋិតនៅខាងក្នុង ។

[១២៣] ម្នាលអាវុសោទាំងឡាយ ចុះសេចក្តីតក់ស្លុតព្រោះមិនប្រកាន់មាំនោះ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ បុថុជ្ជនក្នុងលោកនេះ មិនចេះដឹងពុទ្ធវចនៈ មិនបានឃើញព្រះអរិយៈ មិនឈ្លាសវៃក្នុងអរិយធម៌ មិនបានទូន្មានខ្លួនក្នុងអរិយធម៌ មិនឃើញសប្បុរស មិនឈ្លាសវៃក្នុងសប្បុរិសធម៌ មិនទូន្មានខ្លួនក្នុងសប្បុរិសធម៌ រមែងពិចារណាឃើញនូវរូបថាជាខ្លួន ឬឃើញនូវខ្លួនថាមានរូប ឃើញនូវរូបថាមានក្នុងខ្លួន ឃើញនូវខ្លួនថាមានក្នុងរូប ។ រូបនោះ របស់បុគ្គលនោះ រមែងប្រែប្រួលទៅជាដទៃ ។ បុគ្គលនោះ រមែងមានវិញ្ញាណត្រឡប់ទៅតាមសេចក្តីប្រែប្រួលនៃរូប ព្រោះភាវៈនៃរូបប្រែប្រួលទៅជាដទៃ ។ ឯសេចក្តីតក់ស្លុត និងហេតុជាទីកើតឡើងនៃអកុសលធម៌ ដែលកើតអំពីការត្រឡប់ទៅតាមសេចក្តីប្រែប្រួលនៃរូប រមែងគ្របសង្កត់ចិត្តរបស់បុគ្គលនោះ ។

ចេតសោ បរិយាទាយ ឧត្តាសវា ច ហោតិ វិឃាតវា ច អបេក្ខវា[១] ច អនុបាទាយ ច បរិតស្សតិ ។ វេទនំ... សញ្ញំ... សង្ខារេ... វិញ្ញាណំ អត្តតោ សមនុបស្សតិ វិញ្ញាណវន្តំ វា អត្តានំ អត្តនិ វា វិញ្ញាណំ វិញ្ញាណស្មឹ វា អត្តានំ ។ តស្ស តំ វិញ្ញាណំ វិបរិណាមតិ អញ្ញថា ហោតិ ។ តស្ស វិញ្ញាណវិបរិណាមញ្ញថាភាវា វិញ្ញាណវិបរិណាមានុប-រិវត្តិ វិញ្ញាណំ ហោតិ ។ តស្ស វិញ្ញាណវិបរិណា-មានុបរិវត្តជា បរិតស្សនា ធម្មសមុប្បាទា ចិត្តំ បរិ-យាទាយ តិដ្ឋន្តិ ។ ចេតសោ បរិយាទាយ ឧត្តាសវា ច ហោតិ វិឃាតវា ច អបេក្ខវា[២] ច អនុបាទាយ ច បរិតស្សតិ ។ ឯវំ ខោ អាវុសោ អនុបាទា បរិ-តស្សនា ហោតិ ។

---

១-២ ឱ. ឧបេក្ខវា ។

បុគ្គលនោះ ព្រោះតែសេចក្ដីគ្របសង្កត់ចិត្ត ក៏ប្រកបដោយសេចក្ដីខ្លាចផង ប្រកបដោយសេចក្ដីចង្អៀតចង្អល់ផង ប្រកបដោយសេចក្ដីអាឡោះអាល័យផង រមែងតក់ស្លុត ព្រោះមិនប្រកាន់មាំ ។ បុគ្គលពិចារណាឃើញនូវវេទនា... សញ្ញា... សង្ខារ... បុគ្គលពិចារណាឃើញនូវវិញ្ញាណថាជាខ្លួន ឬឃើញនូវខ្លួនថាមានវិញ្ញាណ ឃើញវិញ្ញាណថាមានក្នុងខ្លួន ឬឃើញខ្លួនថាមានក្នុងវិញ្ញាណ ។ វិញ្ញាណនោះ របស់បុគ្គលនោះ ក៏ប្រែប្រួលទៅជាដទៃ ។ បុគ្គលនោះ រមែងមានវិញ្ញាណត្រឡប់ទៅតាមសេចក្ដីប្រែប្រួលនៃវិញ្ញាណ ព្រោះភាវៈនៃវិញ្ញាណប្រែប្រួលទៅជាដទៃ ។ ឯសេចក្ដីតក់ស្លុតនិងហេតុជាទីកើតឡើងនៃអកុសលធម៌ ដែលកើតអំពីការត្រឡប់ទៅតាម នូវសេចក្ដីប្រែប្រួលនៃវិញ្ញាណ រមែងគ្របសង្កត់ចិត្តរបស់បុគ្គលនោះ ។ បុគ្គលនោះ ព្រោះតែសេចក្ដីគ្របសង្កត់ចិត្ត ក៏ប្រកបដោយសេចក្ដីខ្លាចផង ប្រកបដោយសេចក្ដីចង្អៀតចង្អល់ផង ប្រកបដោយសេចក្ដីអាឡោះអាល័យផង រមែងតក់ស្លុតព្រោះមិនប្រកាន់មាំ ។ ម្នាលអាវុសោទាំងឡាយ សេចក្ដីតក់ស្លុតព្រោះមិនប្រកាន់មាំ យ៉ាងនេះឯង ។

[១៦៤] កថញ្ចាវុសោ អនុបាទា អបរិតស្សនា ហោតិ ។ ឥធាវុសោ សុតវា អរិយសាវកោ អរិយានំ ទស្សាវី អរិយធម្មស្ស កោវិទោ អរិយធម្មេ សុវិនីតោ សប្បុរិសានំ ទស្សាវី សប្បុរិសធម្មស្ស កោវិទោ សប្បុរិសធម្មេ សុវិនីតោ ន រូបំ អត្តតោ សមនុបស្សតិ ន រូបវន្តំ វា អត្តានំ ន អត្តនិ វា រូបំ ន រូបស្មឹ វា អត្តានំ ។ តស្ស តំ រូបំ វិបរិណាមតិ អញ្ញថា ហោតិ ។ តស្ស រូបវិបរិណាមញ្ញថាភាវា ន រូបវិបរិណាមានុបរិវត្តិ វិញ្ញាណំ ហោតិ ។ តស្ស ន រូបវិបរិណាមានុបរិវត្តជា បរិតស្សនា ធម្មសមុប្បាទា ចិត្តំ បរិយាទាយ តិដ្ឋន្តិ ។ ចេតសោ អបរិយាទានា ន ចេវ ឧត្តាសវា ហោតិ ន ច វិឃាតវា ន ច អបេក្ខវា អនុបាទាយ ច ន បរិតស្សតិ ។

[១២៤] ម្នាលអាវុសោទាំងឡាយ ចុះសេចក្តីមិនតក់ស្លុតព្រោះមិនប្រកាន់មាំ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ អរិយសាវ័កក្នុងសាសនានេះ ជាអ្នកចេះដឹងពុទ្ធវចនៈ បានឃើញព្រះអរិយៈ ឈ្លាសវៃក្នុងអរិយធម៌ ទូន្មានខ្លួនក្នុងអរិយធម៌ បានឃើញសប្បុរស ឈ្លាសវៃក្នុងសប្បុរិសធម៌ បានទូន្មានខ្លួនក្នុងសប្បុរិសធម៌ រមែងមិនពិចារណាឃើញនូវរូបថាជាខ្លួន មិនឃើញនូវខ្លួនថាមានរូប មិនឃើញរូបថាមានក្នុងខ្លួន មិនឃើញខ្លួនថាមានក្នុងរូប ។ រូបនោះ របស់បុគ្គលនោះ ក៏ប្រែប្រួលទៅជាដទៃ ។ បុគ្គលនោះ ក៏រមែងមានវិញ្ញាណមិនបានត្រឡប់ទៅតាម នូវសេចក្តីប្រែប្រួលនៃរូប ព្រោះតែភាវៈនៃរូបប្រែប្រួលទៅជាដទៃឡើយ ។ ឯសេចក្តីតក់ស្លុត និងហេតុជាទីកើតឡើងនៃអកុសលធម៌ ដែលកើតអំពីការត្រឡប់ទៅតាម នូវសេចក្តីប្រែប្រួលនៃរូប រមែងមិនគ្របសង្កត់ចិត្តរបស់បុគ្គលនោះទេ ។ បុគ្គលនោះ ព្រោះតែសេចក្តីមិនគ្របសង្កត់ចិត្ត ក៏មិនបានប្រកបដោយសេចក្តីខ្វាចផង មិនប្រកបដោយសេចក្តីចង្អៀតចង្អល់ផង មិនប្រកបដោយសេចក្តីអាឡោះអាល័យផង រមែងមិនតក់ស្លុត ព្រោះមិនប្រកាន់មាំ ។

ន វេទនំ... ន សញ្ញំ... ន សង្ខារេ... ន វិញ្ញាណំ អត្តតោ សមនុបស្សតិ ន វិញ្ញាណវន្តំ វា អត្តានំ ន អត្តនិ វា វិញ្ញាណំ ន វិញ្ញាណស្មឹ វា អត្តានំ ។ តស្ស តំ វិញ្ញាណំ វិបរិណាមតិ អញ្ញថា ហោតិ ។ តស្ស វិញ្ញាណវិបរិណាមញ្ញថាភាវា ន វិញ្ញាណវិបរិណាមានុបរិវត្តិ វិញ្ញាណំ ហោតិ ។ តស្ស ន វិញ្ញាណវិបរិណាមានុបរិវត្តជា បរិតស្សនា ធម្មសមុប្បាទា ចិត្តំ បរិយាទាយ តិដ្ឋន្តិ ។ ចេតសោ អបរិយាទានា ន ចេវ ឧត្តាសវា ហោតិ ន ច វិឃាតវា ន ច អបេក្ខវា អនុបាទាយ ច ន បរិតស្សតិ ។ ឯវំ ខោ អាវុសោ អនុបាទា អបរិតស្សនា ហោតិ ។

បុគ្គលមិនបានពិចារណាឃើញនូវវេទនា... សញ្ញា... សង្ខារ... បុគ្គលមិនបានពិចារណាឃើញនូវវិញ្ញាណថាជាខ្លួន មិនឃើញខ្លួនថាមានវិញ្ញាណ មិនឃើញវិញ្ញាណថាមានក្នុងខ្លួន មិនឃើញខ្លួនថាមានក្នុងវិញ្ញាណ ។ វិញ្ញាណនោះ របស់បុគ្គលនោះ ប្រែប្រួលទៅជាដទៃ ។ បុគ្គលនោះ រមែងមានវិញ្ញាណ មិនបានត្រឡប់ទៅតាមសេចក្ដីប្រែប្រួលនៃវិញ្ញាណ ព្រោះភាវៈនៃវិញ្ញាណប្រែប្រួលទៅជាដទៃទេ ។ ឯសេចក្ដីតក់ស្លុតនិងហេតុជាទីកើតឡើងនៃអកុសលធម៌ ដែលកើតឡើងអំពីការត្រឡប់ទៅតាមនូវសេចក្ដីប្រែប្រួលនៃវិញ្ញាណ រមែងមិនគ្របសង្កត់ចិត្តរបស់បុគ្គលនោះឡើយ ។ បុគ្គលនោះ ព្រោះតែសេចក្ដីមិនគ្របសង្កត់ចិត្ត ក៏មិនបានប្រកបដោយសេចក្ដីខ្វាចផង មិនប្រកបដោយសេចក្ដីចង្អៀតចង្អល់ផង មិនប្រកបដោយសេចក្ដីអាឡោះអាល័យផង រមែងមិនតក់ស្លុត ព្រោះមិនប្រកាន់មាំ ។ ម្នាលអាវុសោទាំងឡាយ សេចក្ដីមិនតក់ស្លុត ព្រោះមិនប្រកាន់មាំ យ៉ាងនេះឯង ។

[១៦៥] យំ ខោ នោ អាវុសោ ភគវា សង្ខិ-ត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ តថា តថា ភិក្ខវេ ភិក្ខុ ឧបបរិក្ខេយ្យ យថា យថាស្ស ឧបបរិក្ខតោ ពហិទ្ធា ចស្ស វិញ្ញាណំ អវិក្ខិត្តំ អវិសដំ អជ្ឈត្តំ អសណ្ឋិ-តំ អនុបាទាយ ន បរិតស្សេយ្យ ពហិទ្ធា ភិក្ខវេ វិញ្ញាណេ អវិក្ខិត្តេ អវិសដេ សតិ អជ្ឈត្តំ អសណ្ឋិ-តេ អនុបាទាយ អបរិតស្សតោ អាយតឹ ជាតិជ-រាមរណទុក្ខសមុទយសម្ភវោ ន ហោតីតិ ឥមស្ស ខោ អហំ អាវុសោ ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស ឯវំ វិត្ថារេន អត្ថំ អាជានាមិ អាកង្ខមានា ច បន តុម្ហេ អា-យស្មន្តោ ភគវន្តំយេវ ឧបសង្កមិត្វា ឯតមត្ថំ បដិ-បុច្ឆេយ្យាថ យថា នោ ភគវា ព្យាករោតិ តថា នំ ធារេយ្យាថាតិ ។

[១២៥] ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគ ទ្រង់សំដែងនូវឧទ្ទេសណា ដល់យើងទាំងឡាយ ដោយសង្ខេប មិនបានចែកអត្ថដោយពិស្តារ ស្រាប់តែទ្រង់ក្រោកអំពីអាសនៈ ស្តេចចូលទៅកាន់វិហារ គឺទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះពិចារណាហើយ វិញ្ញាណរបស់ភិក្ខុនោះ មិនរាត់រាយមិនខ្ចាត់ខ្ចាយទៅខាងក្រៅ មិនឋិតនៅខាងក្នុង មិនតក់ស្លុត ព្រោះមិនប្រកាន់មាំ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះ មានវិញ្ញាណមិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ មិនឋិតនៅខាងក្នុង មិនតក់ស្លុត ព្រោះមិនប្រកាន់មាំហើយ ឯការកើតឡើងព្រម មានព្រម នៃជាតិ ជរា មរណៈ និងទុក្ខ រមែងមិនមានតទៅទៀត ដោយប្រការយ៉ាងណា ៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីពិចារណាដោយប្រការយ៉ាងនោះ ៗ ចុះ ម្នាលអាវុសោទាំងឡាយ នេះឯងឧទ្ទេស ដែលព្រះមានព្រះភាគទ្រង់សំដែងដោយសង្ខេប មិនបានចែកអត្ថដោយពិស្តារ ខ្ញុំយល់ច្បាស់នូវអត្ថដោយពិស្តារយ៉ាងនេះឯង បើលោកមានអាយុទាំងឡាយ ប្រាថ្នា (ចង់ដឹង) គប្បីចូលទៅគាល់ព្រះមានព្រះភាគ ហើយសួរសេចក្តីនេះថែមទៀតចុះ បើព្រះមានព្រះភាគទ្រង់ព្យាករ ដល់យើងទាំងឡាយ យ៉ាងណា អ្នកទាំងឡាយ គប្បីចាំទុកនូវសេចក្តីនោះ យ៉ាងនោះចុះ ៗ

១៣៩

វិភង្គវគ្គស្ស ឧទ្ទេសវិភង្គសុត្តេ ភគវន្តាពោចនំ

[១៦៦] អថខោ តេ ភិក្ខូ អាយស្មតោ មហាកច្ចានស្ស ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ យំ ខោ នោ ភន្តេ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ តថា តថា ភិក្ខវេ ភិក្ខុ ឧបបរិក្ខេយ្យ យថា យថាស្ស ឧបបរិក្ខតោ ពហិទ្ធា ចស្ស វិញ្ញាណំ អវិក្ខិត្តំ អវិសដំ អជ្ឈត្តំ អសណ្ឋិតំ អនុបាទាយ ន បរិតស្សេយ្យ ពហិទ្ធា ភិក្ខវេ វិញ្ញាណេ អវិក្ខិត្តេ អវិសដេ សតិ អជ្ឈត្តំ អសណ្ឋិតេ អនុបាទាយ អបរិតស្សតោ អាយតឹ ជាតិជរាមរណទុក្ខសមុទយសម្ភវោ ន ហោតីតិ តេសន្នោ ភន្តេ អម្ហាកំ អចិរបក្កន្តស្ស ភគវតោ

[១២៦] លំដាប់នោះ ភិក្ខុទាំងនោះ ត្រេកអរ អនុមោទនានឹងភាសិតរបស់ព្រះមហាកច្ចានៈមានអាយុ ហើយក៏ក្រោកអំពីអាសនៈ នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីសមគួររួចហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់សំដែងឧទ្ទេសណាដល់យើងខ្ញុំព្រះអង្គទាំងឡាយ ដោយសង្ខេប មិនបានចែកអត្ថដោយពិស្តារ ស្រាប់តែទ្រង់ក្រោកអំពីអាសនៈ ស្តេចចូលទៅកាន់វិហារ គឺទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះពិចារណាហើយ វិញ្ញាណរបស់ភិក្ខុនោះ មិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ មិនឋិតនៅខាងក្នុង ហើយមិនតក់ស្លុត ព្រោះមិនប្រកាន់មាំ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះ មានវិញ្ញាណមិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ មិនឋិតនៅខាងក្នុង មិនតក់ស្លុត ព្រោះមិនប្រកាន់មាំហើយ ឯការកើតឡើងព្រម មានព្រម នៃជាតិ ជរា មរណៈនិងទុក្ខ រមែងមិនមានតទៅទៀត ដោយប្រការយ៉ាងណា ៗ ភិក្ខុគប្បីពិចារណា ដោយប្រការយ៉ាងនោះ ៗ ចុះ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលព្រះមានព្រះភាគ ស្តេចចេញទៅមិនយូរប៉ុន្មាន ខ្ញុំព្រះអង្គទាំងនោះ

ឯតទហោសិ ឥទំ ខោ នោ អាវុសោ ភគវា សង្ខិត្តេន ឧទ្ទេសំ ឧទ្ទិសិត្វា វិត្ថារេន អត្ថំ អវិភជិត្វា ឧដ្ឋាយាសនា វិហារំ បវិដ្ឋោ តថា តថា ភិក្ខវេ ភិក្ខុ ឧបបរិក្ខេយ្យ យថា យថាស្ស ឧបបរិក្ខតោ ពហិទ្ធា ចស្ស វិញ្ញាណំ អវិក្ខិត្តំ អវិសដំ អជ្ឈត្តំ អសណ្ឋិតំ អនុបាទាយ ន បរិតស្សេយ្យ ពហិទ្ធា ភិក្ខវេ វិញ្ញាណេ អវិក្ខិត្តេ អវិសដេ សតិ អជ្ឈត្តំ អសណ្ឋិតេ អនុបាទាយ អបរិតស្សតោ អាយតឹ ជាតិជរាមរណទុក្ខសមុទយសម្ភវោ ន ហោតីតិ កោ នុ ខោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជេយ្យាតិ តេសន្នោ ភន្តេ អម្ហាកំ ឯតទហោសិ អយំ ខោ អាយស្មា មហាកច្ចានោ

ក៏មានសេចក្តីត្រិះរិះដូច្នេះថា ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគ ទ្រង់សំដែងឧទ្ទេសនេះ ដល់យើងទាំងឡាយ ដោយសង្ខេប មិនបាន ចែកអត្ថ ដោយពិស្តារ ស្រាប់តែទ្រង់ក្រោកអំពីអាសនៈ ស្តេចចូល ទៅកាន់វិហារ គឺទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុ នោះពិចារណាហើយ វិញ្ញាណរបស់ភិក្ខុនោះ មិនរាត់រាយ មិនខ្ចាត់ ខ្ចាយទៅខាងក្រៅ មិនបិតនៅខាងក្នុង មិនតក់ស្លុត ព្រោះមិនប្រកាន់ មាំ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះ មានវិញ្ញាណមិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ មិនបិតនៅខាងក្នុង មិនតក់ស្លុត ព្រោះមិន ប្រកាន់មាំហើយ ឯការកើតព្រម មានព្រម នៃជាតិ ជរា មរណៈ និងទុក្ខ រមែងមិនមានតទៅទៀត ដោយប្រការយ៉ាងណា ៗ ភិក្ខុគប្បី ពិចារណា ដោយប្រការយ៉ាងនោះ ៗ ចុះ ឧទ្ទេសដែលព្រះមានព្រះភាគ ទ្រង់សំដែងដោយសង្ខេប មិនចែកអត្ថដោយពិស្តារនេះ តើនរណាហ្ន៎ នឹងចែកអត្ថដោយពិស្តារបាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំង នោះ ក៏មានសេចក្តីត្រិះរិះដូច្នេះថា ព្រះមហាកច្ចានៈមានអាយុនេះឯង

១៤១

## វិភង្គវគ្គស្ស ឧទ្ទេសវិភង្គសុត្តេ ភគវន្តារោចនំ

សត្ថុ ចេវ សំវណ្ណិតោ សម្ភាវិតោ ច វិញ្ញូនំ សព្រហ្មចារីនំ បហោតិ ចាយស្មា មហាកច្ចានោ ឥមស្ស ភគវតា សង្ខិត្តេន ឧទ្ទេសស្ស ឧទ្ទិដ្ឋស្ស វិត្ថារេន អត្ថំ អវិភត្តស្ស វិត្ថារេន អត្ថំ វិភជិតុំ យន្នូន មយំ យេនាយស្មា មហាកច្ចានោ តេនុបសង្កមេយ្យាម ឧបសង្កមិត្វា អាយស្មន្តំ មហាកច្ចានំ ឯតមត្ថំ បដិបុច្ឆេយ្យាមាតិ អថខោ មយំ ភន្តេ យេនាយស្មា មហាកច្ចានោ តេនុបសង្កមិម្ហ ឧបសង្កមិត្វា អាយស្មន្តំ មហាកច្ចានំ ឯតមត្ថំ បដិបុច្ឆិម្ហ តេសន្នោ ភន្តេ អាយស្មតា មហាកច្ចានេន ឥមេហិ អាការេហិ ឥមេហិ បទេហិ ឥមេហិ ព្យញ្ជនេហិ អត្ថោ វិភត្តោតិ ។

ព្រះសាស្តាសរសើរផង សព្រហ្មចារីទាំងឡាយជាអ្នកប្រាជ្ញ លើកតម្កើងផង ឯឧទ្ទេសដែលព្រះមានព្រះភាគ ទ្រង់សំដែងដោយសង្ខេប មិនចែកអត្ថដោយពិស្តារនេះ មានតែព្រះមហាកច្ចានៈមានអាយុ ទើបអាចចែកអត្ថដោយពិស្តារបាន បើដូច្នោះ គួរតែយើងទាំងឡាយ នាំគ្នាចូលទៅរកព្រះមហាកច្ចានៈមានអាយុ លុះចូលទៅដល់ហើយ គប្បីសួរសេចក្តីនេះនឹងព្រះមហាកច្ចានៈមានអាយុ បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះ ខ្ញុំព្រះអង្គទាំងឡាយ ក៏នាំគ្នាចូលទៅរកព្រះមហាកច្ចានៈមានអាយុ លុះចូលទៅដល់ហើយ ក៏បានសួរសេចក្តីនេះ នឹងព្រះមហាកច្ចានៈមានអាយុ បពិត្រព្រះអង្គដ៏ចម្រើន ឯព្រះមហាកច្ចានៈមានអាយុ ក៏បានចែកអត្ថដោយអាការទាំងនេះ ដោយបទទាំងនេះ ដោយព្យញ្ជនៈទាំងនេះ ដល់ខ្ញុំព្រះអង្គទាំងឡាយ ។

[១២៧] បណ្ឌិតោ ភិក្ខវេ មហាកច្ចានោ មហាបញ្ញោ ភិក្ខវេ មហាកច្ចានោ មំ ចេបិ តុម្ហេ ភិក្ខវេ ឯតមត្ថំ បដិបុច្ឆេយ្យាថ អហម្បិ[១] ឯវមេវំ ព្យាករេយ្យំ យថាតំ មហាកច្ចានេន ព្យាកតំ ឯសោ ចេវ តស្ស អត្ថោ ឯវញ្ច នំ ធារេយ្យាថាតិ[២] ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

ឧទ្ទេសវិភង្គសុត្តំ អដ្ឋមំ និដ្ឋិតំ ។

---

១ ឱ. ឯត្តន្តរេ តន្តិ ទិស្សតិ ។ ២ ឱ. ធារេថាតិ ។

[១២៧] ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មហាកច្ចានៈជាបណ្ឌិត ម្នាលភិក្ខុទាំងឡាយ មហាកច្ចានៈមានបញ្ញាច្រើន ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយសួរសេចក្តីនេះ នឹងតថាគតទៀត តថាគតក៏គប្បីព្យាករ ដូចជាសេចក្តីដែលមហាកច្ចានៈបានព្យាកររួចហើយ យ៉ាងនុ៎ះដែរ នេះហើយជាសេចក្តីរបស់ឧទ្ទេសនោះ អ្នកទាំងឡាយ គប្បីចាំទុកនូវសេចក្តីនោះ យ៉ាងនេះចុះ ។ លុះព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាដូច្នេះចប់ហើយ ភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអរ រីករាយ នឹងភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ ឧទ្ទេសវិភង្គសូត្រ ទី ៨ ។

# នវមំ អរណវិភង្គសុត្តំ

[១២៨] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច អរណវិភង្គំ វោ ភិក្ខវេ ទេសិស្សាមិ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវម្ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

[១២៩] ភគវា ឯតទវោច ន កាមសុខមនុយុញ្ជេយ្យ ហីនំ គម្មំ បោថុជ្ជនិកំ អនរិយំ អនត្ថសញ្ហិតំ ន ច អត្តកិលមថានុយោគមនុយុញ្ជេយ្យ ទុក្ខំ

# អរណវិភង្គសូត្រ ទី ៩

[១២៨] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្នុងសាវត្ថី ។ ព្រះមានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយ ក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ។ ព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវអរណវិភង្គ[១] ចំពោះអ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់នូវអរណវិភង្គនោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[១២៩] ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា បុគ្គលមិនគប្បីប្រកបរឿយ ៗ នូវសេចក្តីសុខក្នុងកាម ដែលជាធម៌ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ឡើយ មួយទៀត មិនគប្បីប្រកបរឿយ ៗ នូវសេចក្តីព្យាយាមធ្វើខ្លួនឯងឲ្យលំបាក ជារបស់នាំមក នូវសេចក្តីទុក្ខ

១ ការចែកនូវធម៌ដែលមិនមានសឹកសត្រូវ គឺសេចក្តីសៅហ្មង ។

អនរិយំ អនត្ថសញ្ហិតំ ឯតេតេ(១) ឧភោ អន្តេ អនុបគម្ម មជ្ឈិមា បដិបទា តថាគតេន អភិសម្ពុទ្ធា ចក្ខុករណី ញាណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ ។ ឧស្សាទនញ្ច ជញ្ញា អបសាទនញ្ច ជញ្ញា ឧស្សាទនញ្ច ញត្វា អបសាទនញ្ច ញត្វា នេវុស្សាទេយ្យ ន អបសាទេយ្យ ធម្មមេវ ទេសេយ្យ សុខវិនិច្ឆយំ ជញ្ញា សុខវិនិច្ឆយំ ញត្វា អជ្ឈត្តំ សុខមនុយុញ្ជេយ្យ រហោវាទំ ន ភាសេយ្យ សម្មុខា នាតិខីណំ(២) ភណេ អតរមានោ វ ភាសេយ្យ នោ តរមានោ ជនបទនិរុត្តឹ នាភិនិវេសេយ្យ សមញ្ញំ នាតិធាវេយ្យាតិ អយមុទ្ទេសោ អរណវិភង្គស្ស ។

១ ឯតេ តេ ភិក្ខវេតិបិ ទិស្សតិ ។ ២ ឱ. ន ខណំ ។

មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ឡើយ ឯមជ្ឈិមប្បដិបទា គឺសេចក្តីប្រតិបត្តិយ៉ាងកណ្តាល មិនប៉ះពាល់នូវធម៌អមខាងទាំង ២[១] នោះ ដែលតថាគតបានត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ ធ្វើឲ្យកើតសេចក្តីចេះដឹង តែងប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់កិលេស ដើម្បីស្គាល់នូវអរិយសច្ច ដើម្បីត្រាស់ដឹងនូវអរិយសច្ច ដើម្បីព្រះនិព្វាន ។ បុគ្គលគប្បីដឹង នូវការលើកតម្កើងផង គប្បីដឹងនូវការបន្ទុះបង្អាប់ផង លុះដឹងនូវការលើកតម្កើង ទាំងដឹងនូវការបន្ទុះបង្អាប់ហើយ មិនគប្បីលើកតម្កើង មិនគប្បីបន្ទុះបង្អាប់ ត្រូវសំដែងធម៌ដោយត្រង់ គប្បីដឹងនូវសេចក្តីសុខដែលថោកថយ លុះដឹងនូវសេចក្តីសុខដែលថោកថយហើយ គប្បីប្រកបរឿយ ៗ នូវសេចក្តីសុខក្នុងសន្តាន មិនគប្បីពោលពាក្យក្នុងទីកំបាំងមុខ (ពាក្យញុះញង់) មិនគប្បីពោលពាក្យសៅហ្មង[២] ក្នុងទីចំពោះមុខ គប្បីពោលកុំឲ្យរួសរាន់ពេក មិនគប្បីពោលរួសរាន់ពេក មិនគប្បីប្រកាន់ភាសាក្នុងជនបទ មិនគប្បីប្រព្រឹត្តកន្លងនូវឈ្មោះ[៣] នេះជាឧទ្ទេសនៃអរណវិភង្គ ។

---

១ ក្នុងអដ្ឋកថាធម្មចក្កថា លាមកកោដ្ឋាសៈ គឺធម៌ជាចំណែកខាងលាមក ឬ អាក្រក់ ។ ២ ពាក្យកោសកៀរបញ្ឈឺចិត្តជាដើម ។ ៣ ជាឈ្មោះរបស់ទាំងពួងមានភាជន៍ជាដើម ។

[១៣០] ន កាមសុខមនុយុញ្ជេយ្យ ហីនំ គម្មំ បោថុជ្ជនិកំ អនរិយំ អនត្ថសញ្ហិតំ ន ច អត្តកិលមថានុយោគមនុយុញ្ជេយ្យ ទុក្ខំ អនរិយំ អនត្ថសញ្ហិតន្តិ ឥតិ ខោ[១] បនេតំ វុត្តំ ។ កិញ្ចេតំ បដិច្ច វុត្តំ ។ យោ កាមប្បដិសន្ធិសុខិនោ សោមនស្សានុយោគោ ហីនោ គម្មោ បោថុជ្ជនិកោ អនរិយោ អនត្ថសញ្ហិតោ សទុក្ខោ ឯសោ ធម្មោ សឧបឃាតោ សឧបាយាសោ សបរិឡាហោ មិច្ឆាបដិបទា ។ យោ កាមប្បដិសន្ធិសុខិនោ សោមនស្សានុយោគំ អននុយោគោ ហីនំ គម្មំ បោថុជ្ជនិកំ អនរិយំ

១ ឱ. ខោសទ្ទោ នត្ថិ ។

[១៣០] ឯពាក្យថា បុគ្គលមិនគប្បីប្រកបរឿយ ៗ នូវសេចក្ដីសុខក្នុងកាម ដែលជាធម៌ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ មួយទៀត មិនគប្បីប្រកបរឿយ ៗ នូវសេចក្ដីព្យាយាម ធ្វើខ្លួនឯងឲ្យលំបាក ជារបស់នាំមកនូវសេចក្ដីទុក្ខ មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ដូច្នេះនុ៎ះ តថាគតបានពោលហើយ ។ ពាក្យនុ៎ះ តថាគតបានពោលហើយ ព្រោះអាស្រ័យសេចក្ដីដូចម្ដេច ។ ធម៌ណា គឺការប្រកបរឿយ ៗ នូវសេចក្ដីសោមនស្ស របស់បុគ្គលដែលមានសេចក្ដីសុខដោយកាមប្បដិសន្ធិ[១] ដែលជាធម៌ថោកទាប ជាធម៌របស់អ្នកស្រុក ជាធម៌របស់បុថុជ្ជន មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ធម៌នេះ ជាធម៌ប្រកបដោយសេចក្ដីទុក្ខ ប្រកបដោយសេចក្ដីលំបាក ប្រកបដោយសេចក្ដីចង្អៀតចង្អល់ ប្រកបដោយសេចក្ដីក្ដៅក្រហាយ ជាសេចក្ដីប្រតិបត្តិខុស ។ ធម៌ណា គឺការមិនប្រកបរឿយ ៗ នូវសេចក្ដីព្យាយាមដោយសោមនស្ស របស់បុគ្គលដែលមានសេចក្ដីសុខដោយកាមប្បដិសន្ធិ ជាសេចក្ដីព្យាយាមថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់ព្រះអរិយបុគ្គល

---

១ ការជាប់ចំពាក់ក្នុងកាម ។

អនត្ថសញ្ហិតំ អទុក្ខោ ឯសោ ធម្មោ អនុបឃាតោ អនុបាយាសោ អបរិឡាហោ សម្មាបដិបទា ។ យោ អត្តកិលមថានុយោគោ ទុក្ខោ អនរិយោ អនត្ថសញ្ហិតោ សទុក្ខោ ឯសោ ធម្មោ សឧបឃាតោ សឧបាយាសោ សបរិឡាហោ មិច្ឆាបដិបទា ។ យោ អត្តកិលមថានុយោគំ អននុយោគោ ទុក្ខំ អនរិយំ អនត្ថសញ្ហិតំ អទុក្ខោ ឯសោ ធម្មោ អនុបឃាតោ អនុបាយាសោ អបរិឡាហោ សម្មាបដិបទា ។ ន កាមសុខមនុយុញ្ជេយ្យ ហីនំ គម្មំ បោថុជ្ជនិកំ អនរិយំ អនត្ថសញ្ហិតំ ន ច អត្តកិលមថានុយោគមនុយុញ្ជេយ្យ ទុក្ខំ អនរិយំ អនត្ថសញ្ហិតន្តិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

មិនប្រកបដោយប្រយោជន៍ ធម៌នេះ ជាធម៌មិននាំមកនូវសេចក្តីទុក្ខ មិនលំបាក មិនចង្អៀតចង្អល់ មិនក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិត្រូវ ។ ធម៌ណា គឺសេចក្តីព្យាយាមធ្វើខ្លួនឯងឲ្យលំបាក ជារបស់នាំមកនូវសេចក្តីទុក្ខ មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ធម៌នេះ រមែងប្រកបដោយសេចក្តីទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិខុស ។ ធម៌ណា គឺការមិនប្រកបរឿយ ៗ នូវសេចក្តីព្យាយាមធ្វើខ្លួនឯងឲ្យលំបាក ជាសេចក្តីព្យាយាមនាំមកនូវទុក្ខ មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ធម៌នុ៎ះ មិននាំមកនូវសេចក្តីទុក្ខ មិនលំបាក មិនចង្អៀតចង្អល់ មិនក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិត្រូវ ។ ពាក្យណា ដែលតថាគតពោលហើយថា បុគ្គលមិនគប្បីប្រកបរឿយ ៗ នូវសេចក្តីសុខក្នុងកាម ដែលជាធម៌ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់ព្រះអរិយ-បុគ្គល មិនប្រកបដោយប្រយោជន៍ មួយទៀត មិនគប្បីប្រកបរឿយ ៗ នូវសេចក្តីព្យាយាមធ្វើខ្លួនឯងឲ្យលំបាក នាំមកនូវទុក្ខ មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ដូច្នេះ ពាក្យនុ៎ះតថាគតពោលហើយ ព្រោះអាស្រ័យសេចក្តីនេះឯង ។

វិភង្គវគ្គស្ស អរណវិភង្គសុត្តេ មជ្ឈិមប្បដិបទា

[១៣១] ឯតេតេ[១] ឧភោ អន្តេ អនុបគម្ម មជ្ឈិមា បដិបទា តថាគតេន អភិសម្ពុទ្ធា ចក្ខុករណី ញាណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតីតិ ឥតិ ខោ បនេតំ វុត្តំ ។ កិញ្ចេតំ បដិច្ច វុត្តំ ។ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។ ឯតេតេ ឧភោ អន្តេ អនុបគម្ម មជ្ឈិមា បដិបទា តថាគតេន អភិសម្ពុទ្ធា ចក្ខុករណី ញាណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

---

១ ម. ឯតេ ខោ ។

វិភង្គវគ្គ អរណវិភង្គសូត្រ មជ្ឈិមប្បដិបទា

[១៣១] ឯពាក្យថា មជ្ឈិមប្បដិបទា គឺសេចក្ដីប្រតិបត្តិយ៉ាងកណ្ដាល មិនប៉ះពាល់នូវធម៌អមខាងទាំង ២ នុ៎ះ ដែលតថាគតត្រាស់ដឹងហើយ ជាសេចក្ដីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ ធ្វើឲ្យកើតសេចក្ដីចេះដឹង តែងប្រព្រឹត្តទៅ ដើម្បីសេចក្ដីស្ងប់រម្ងាប់កិលេស ដើម្បីស្គាល់នូវអរិយសច្ច ដើម្បីត្រាស់ដឹងនូវអរិយសច្ច ដើម្បីព្រះនិព្វាន ដូច្នេះនុ៎ះ តថាគតបានពោលហើយ ។ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យសេចក្ដីដូចម្ដេច ។ អដ្ឋង្គិកមគ្គ ដ៏ប្រសើរនេះឯង គឺសេចក្ដីយល់ត្រូវ ១ សេចក្ដីត្រិះរិះត្រូវ ១ វាចាត្រូវ ១ ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ សេចក្ដីព្យាយាមត្រូវ ១ ការរលឹកត្រូវ ១ ការតម្កល់ចិត្តនឹងត្រូវ ១ ។ ពាក្យណាដែលតថាគតពោលហើយថា មជ្ឈិមប្បដិបទា គឺសេចក្ដីប្រតិបត្តិជាកណ្ដាល មិនបានប៉ះពាល់នូវធម៌អមខាងទាំង ២ នុ៎ះ ដែលតថាគតត្រាស់ដឹងហើយ ជាសេចក្ដីប្រតិបត្តិ ធ្វើឲ្យកើតបញ្ញាចក្ខុ ធ្វើឲ្យកើតសេចក្ដីចេះដឹង តែងប្រព្រឹត្តទៅ ដើម្បីសេចក្ដីស្ងប់រម្ងាប់កិលេស ដើម្បីស្គាល់អរិយសច្ច ដើម្បីត្រាស់ដឹងអរិយសច្ច ដើម្បីព្រះនិព្វាន ដូច្នេះ ពាក្យនុ៎ះ ដែលតថាគតពោលហើយ ព្រោះអាស្រ័យសេចក្ដីនេះឯង ។

[១៣២] ឧស្សាទនញ្ច ជញ្ញា អប្បសាទនញ្ច ជញ្ញា ឧស្សាទនញ្ច ញត្វា អប្បសាទនញ្ច ញត្វា នេវុស្សាទេយ្យ ន អប្បសាទេយ្យ ធម្មមេវ ទេសេយ្យាតិ ឥតិ ខោ បនេតំ វុត្តំ ។ កិញ្ចេតំ បដិច្ច វុត្តំ ។ កថញ្ច ភិក្ខវេ ឧស្សាទនា ច ហោតិ អប្បសាទនា ច[១] នោ ច ធម្មទេសនា ។ យេ កាមប្បដិសន្ធិសុខិនោ សោមនស្សានុយោគំ អនុយុត្តា ហីនំ គម្មំ បោថុជ្ជនិកំ អនរិយំ អនត្ថសញ្ហិតំ សព្វេ តេ សទុក្ខា សឧបឃាតា សឧបាយាសា សបរិឡាហា មិច្ឆាបដិបន្នាតិ ឥតិ វទំ[២] ឥត្ថេកេ អប្បសាទេតិ ។ យេ កាមប្បដិសន្ធិសុខិនោ សោមនស្សានុយោគំ អននុយុត្តា

១ ឱ. ច ហោតីតិ ទិស្សតិ ។ ២ ម. បរំ ។

[១៣២] ឯពាក្យថា បុគ្គលគប្បីដឹងនូវការលើកតម្កើងផង គប្បីដឹងនូវការបន្ទុះបង្អាប់ផង លុះដឹងនូវការលើកតម្កើង ទាំងដឹងនូវការបន្ទុះបង្អាប់ហើយ មិនគប្បីលើកតម្កើង មិនគប្បីបន្ទុះបង្អាប់ គប្បីសំដែងធម៌ដោយត្រង់ ដូច្នេះនុ៎ះ តថាគតបានពោលហើយ ។ ពាក្យនុ៎ះ តថាគតបានពោលហើយ ព្រោះអាស្រ័យសេចក្ដីដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ការលើកតម្កើងនិងការបន្ទុះបង្អាប់ មិនមែនជាការសំដែងធម៌ តើដូចម្ដេច ។ កាលដែលបុគ្គលអ្នកសំដែងធម៌ពោលថា ជនទាំងឡាយណា មានសេចក្ដីសុខដោយកាមប្បដិសន្ធិ រមែងប្រកបរឿយ ៗ នូវសេចក្ដីព្យាយាមដោយសោមនស្ស ដែលជារបស់ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ជនទាំងអស់នោះ ឈ្មោះថាប្រកបដោយទុក្ខ ប្រកបដោយសេចក្ដីលំបាក ប្រកបដោយសេចក្ដីចង្អៀតចង្អល់ ប្រកបដោយសេចក្ដីក្ដៅក្រហាយ ជាអ្នកប្រតិបត្តិខុស ដូច្នេះឈ្មោះថាបន្ទុះបង្អាប់បុគ្គលពួកខ្លះ ដោយប្រការដូច្នេះ ។ កាលដែលបុគ្គលសំដែងធម៌ពោលថា ជនទាំងឡាយណា មានសេចក្ដីសុខដោយកាមប្បដិសន្ធិ មិនប្រកបរឿយ ៗ នូវសេចក្ដីព្យាយាមដោយសោមនស្ស

១៤៩



ហីនំ គម្មំ ចោជុជ្ជនិកំ អនរិយំ អនត្ថសញ្ហិតំ សព្វេ តេ អទុក្ខា អនុបឃាតា អនុបាយាសា អបរិឡាហា សម្មាបដិបន្នាតិ ឥតិ វទំ ឥត្ថេកេ ឧស្សាទេតិ ។ យេ អត្តកិលមថានុយោគំ អនុយុត្តា ទុក្ខំ អនរិយំ អនត្ថសញ្ហិតំ សព្វេ តេ សទុក្ខា សឧបឃាតា សឧបាយាសា សបរិឡាហា មិច្ឆាបដិបន្នាតិ ឥតិ វទំ ឥត្ថេកេ អបសាទេតិ ។ យេ អត្តកិលមថា-នុយោគំ អននុយុត្តា ទុក្ខំ អនរិយំ អនត្ថសញ្ហិតំ

ដែលជារបស់ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ជនទាំងអស់នោះមិនមានសេចក្ដីទុក្ខ មិនមានសេចក្ដីលំបាក មិនមានសេចក្ដីចង្អៀតចង្អល់ មិនមានសេចក្ដីក្ដៅក្រហាយ ជាអ្នកប្រតិបត្តិត្រូវ ដូច្នេះឈ្មោះថាលើកតម្កើងបុគ្គលពួកខ្លះ ដោយប្រការដូច្នេះ ។ កាលដែលបុគ្គលអ្នកសំដែងធម៌ពោលថា ជនទាំងឡាយណា ប្រកបរឿយ ៗ នូវសេចក្ដីព្យាយាមធ្វើខ្លួនឯងឲ្យលំបាក នាំមកនូវសេចក្ដីទុក្ខ មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ជនទាំងអស់នោះប្រកបដោយសេចក្ដីទុក្ខ ប្រកបដោយសេចក្ដីលំបាក ប្រកបដោយសេចក្ដីចង្អៀតចង្អល់ ប្រកបដោយសេចក្ដីក្ដៅក្រហាយ ជាអ្នកប្រតិបត្តិខុស ដូច្នេះឈ្មោះថាបន្ទុះបង្អាប់បុគ្គលពួកខ្លះ ដោយប្រការដូច្នេះ ។ កាលដែលបុគ្គលអ្នកសំដែងធម៌ពោលថា ជនទាំងឡាយណាមិនប្រកបរឿយ ៗ នូវសេចក្ដីព្យាយាមធ្វើខ្លួនឯងឲ្យលំបាក ជារបស់នាំមកនូវសេចក្ដីទុក្ខ មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍

សព្វេ តេ អទុក្ខា អនុបឃាតា អនុចាយាសា អបរិឡា-
ហា សម្មាបដិបន្នាតិ ឥតិ វជំ ឥត្ថេកោ ឧស្សាទេតិ ។
យេសំ កោសញ្ចិ ភវសញ្ញោជនំ អប្បហីនំ សព្វេ
តេ សទុក្ខា សឧបឃាតា សឧចាយាសា សបរិ-
ឡាហា មិច្ឆាបដិបន្នាតិ ឥតិ វជំ ឥត្ថេកោ អប្ប-
សាទេតិ ។ យេសំ កោសញ្ចិ ភវសញ្ញោជនំ បហី-
នំ សព្វេ តេ អទុក្ខា អនុបឃាតា អនុចាយាសា
អបរិឡាហា សម្មាបដិបន្នាតិ ឥតិ វជំ ឥត្ថេកោ
ឧស្សាទេតិ ។ ឯវំ ខោ ភិក្ខវេ ឧស្សាទនា ច
ហោតិ អប្បសាទនា ច ដោ ច ជម្មទេសនា ។

ជនទាំងអស់នោះមិនមានទុក្ខ មិនមានសេចក្តីលំបាក មិនមានសេចក្តីចង្អៀតចង្អល់ មិនមានសេចក្តីក្តៅក្រហាយ ជាអ្នកប្រតិបត្តិត្រូវ ដូច្នេះឈ្មោះថាលើកតម្កើងបុគ្គលពួកខ្លះ ដោយប្រការដូច្នេះ ។ កាលដែលបុគ្គលអ្នកសំដែងធម៌ពោលថា ជនទាំងឡាយណាមួយ មិនបានលះបង់នូវសំយោជនៈក្នុងភព (តណ្ហា) ជនទាំងអស់នោះ ប្រកបដោយសេចក្តីទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ ជាអ្នកប្រតិបត្តិខុស ដូច្នេះឈ្មោះថាបន្តុះបង្អាប់បុគ្គលពួកខ្លះ ដោយប្រការដូច្នេះ ។ កាលដែលបុគ្គលអ្នកសំដែងធម៌ពោលថា បុគ្គលណាមួយ លះបង់សំយោជនៈក្នុងភពបានហើយ ជនទាំងអស់នោះ មិនមានទុក្ខ មិនមានសេចក្តីលំបាក មិនមានសេចក្តីចង្អៀតចង្អល់ មិនមានសេចក្តីក្តៅក្រហាយ ជាអ្នកប្រតិបត្តិត្រូវ ដូច្នេះឈ្មោះថា លើកតម្កើងបុគ្គលពួកខ្លះ ដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ការលើកតម្កើងនិងការបន្តុះបង្អាប់ មិនមែនជាការសំដែងធម៌ យ៉ាងនេះឯង ។

[១៣៣] កថញ្ច ភិក្ខវេ នេវុស្សាទនា ហោតិ ន អបសាទនា ធម្មទេសនា ច ។ យេ ច[១] កាមប្បដិសន្ធិសុខិនោ សោមនស្សានុយោគំ អនុយុត្តា ហីនំ គម្មំ ពោថុជ្ជនិកំ អនរិយំ អនត្ថសញ្ហិតំ សព្វេ តេ សទុក្ខា សឧបឃាតា សឧបាយាសា សបរិឡាហា មិច្ឆាបដិបន្នាតិ ន ឯវមាហ ។ អនុយោគោ ច ខោ សទុក្ខោ ឯសោ ធម្មោ សឧបឃាតោ សឧបាយាសោ សបរិឡាហោ មិច្ឆាបដិបទាតិ ឥតិ វទំ ធម្មមេវ ទេសេតិ ។ យេ កាមប្បដិសន្ធិសុខិនោ សោមនស្សានុយោគំ អននុយុត្តា ហីនំ គម្មំ

១ ឱ. ម. ចសទ្ទោ នត្ថិ ។

[១៣៣] ម្នាលភិក្ខុទាំងឡាយ ចុះការមិនលើកតម្កើង ការមិនបន្តុះបង្អាប់ ជាការសំដែងធម៌ដោយត្រង់ តើដូចម្តេច ។ បុគ្គលអ្នកសំដែងធម៌មិនបានពោលយ៉ាងនេះថា ជនទាំងឡាយណា ដែលជាអ្នកមានសេចក្តីសុខដោយកាមប្បដិសន្ធិ ប្រកបរឿយ ៗ នូវសេចក្តីព្យាយាមដោយសោមនស្ស ដែលជាធម៌ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ជនទាំងអស់នោះ ឈ្មោះថាប្រកបដោយទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ ជាអ្នកប្រតិបត្តិខុស ដូច្នេះ ។ កាលដែលបុគ្គលអ្នកសំដែងធម៌ ពោលថា អនុយោគធម៌[១]នុ៎ះ ប្រកបដោយសេចក្តីទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិខុស ដូច្នេះឈ្មោះថាសំដែងធម៌ដោយត្រង់ ។ បុគ្គលអ្នកសំដែងធម៌ មិនបានពោលយ៉ាងនេះថា ជនទាំងឡាយណាជាអ្នកមានសេចក្តីសុខដោយកាមប្បដិសន្ធិ មិនប្រកបរឿយ ៗ នូវសេចក្តីព្យាយាមដោយសោមនស្ស ដែលជាធម៌ថោកទាប ជារបស់អ្នកស្រុក

១ ការប្រកបព្យាយាមដោយសោមនស្ស ។

១៤២



បោថុជ្ជនិកំ អនរិយំ អនត្ថសញ្ហិតំ សព្វេ តេ អទុក្ខា អនុបឃាតា អនុបាយាសា អបរិឡាហា សម្មាបដិបន្នាតិ ន ឯវមាហ ។ អននុយោគោ ច ខោ អទុក្ខោ ឯសោ ធម្មោ អនុបឃាតោ អនុបាយាសោ អបរិឡាហោ សម្មាបដិបទាតិ ឥតិ វទំ ធម្មមេវ ទេសេតិ ។ យេ អត្តកិលមថានុយោគំ អនុយុត្តា ទុក្ខំ អនរិយំ អនត្ថសញ្ហិតំ សព្វេ តេ សទុក្ខា សឧបឃាតា សឧបាយាសា សបរិឡាហា មិច្ឆាបដិបន្នាតិ ន ឯវមាហ ។ អនុយោគោ ច ខោ សទុក្ខោ ឯសោ ធម្មោ សឧបឃាតោ សឧបាយាសោ

ជារបស់បុថុជ្ជន មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ជនទាំងអស់នោះ មិនមានទុក្ខ មិនមានសេចក្តីលំបាក មិនមានសេចក្តីចង្អៀតចង្អល់ មិនក្តៅក្រហាយ ជាអ្នកប្រតិបត្តិត្រូវដូច្នេះ ។ កាលដែលបុគ្គលអ្នកសំដែងធម៌ ពោលថា អននុយោគធម៌[១] នុ៎ះ មិនមានសេចក្តីទុក្ខ មិនមានសេចក្តីលំបាក មិនមានការចង្អៀតចង្អល់ មិនមានសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិត្រូវ ដូច្នេះ ឈ្មោះថាសំដែងធម៌ដោយត្រង់ ។ បុគ្គលអ្នកសំដែងធម៌ មិនបានពោលយ៉ាងនេះថា ជនទាំងឡាយណាជាអ្នកប្រកបរឿយ ៗ នូវសេចក្តីព្យាយាមធ្វើខ្លួនឯងឲ្យលំបាក នាំមកនូវសេចក្តីទុក្ខ មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ជនទាំងអស់នោះ ប្រកបដោយសេចក្តីទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ ជាអ្នកប្រតិបត្តិខុស ដូច្នេះ ។ កាលដែលបុគ្គលអ្នកសំដែងធម៌ពោលថា អនុយោគធម៌[២] នេះ ប្រកបដោយសេចក្តីទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់

១ ការមិនប្រកបព្យាយាមដោយសោមនស្ស ។ ២ ការប្រកបព្យាយាមធ្វើខ្លួនឯងឲ្យលំបាក ។

សបរិឡាហោ មិច្ឆាបដិបជាតិ ឥតិ វជំ ជម្មមេវ ងេសេតិ ។ យេ អត្តកិលមថានុយោកំ អននុយុត្តា ទុក្ខំ អនរិយំ អនត្ថសញ្ហិតំ សព្វេ តេ អទុក្ខា អនុបឃាតា អនុចាយាសា អបរិឡាហា សម្មាបដិ-បន្នាតិ ន ឃវមាហ ។ អននុយោគោ ច ខោ អទុក្ខោ ឃសោ ជម្មោ អនុបឃាតោ អនុចាយាសោ អបរិឡាហោ សម្មាបដិបជាតិ ឥតិ វជំ ជម្មមេវ ងេសេតិ ។ យេសំ កោសញ្ចិ ភវសញ្ញោជនំ អប្ប-ហីនំ សព្វេ តេ សទុក្ខា សឧបឃាតា សឧចា-យាសា សបរិឡាហា មិច្ឆាបដិបន្នាតិ ន ឃវមា-ហ ។ ភវសញ្ញោជនេ ខោ អប្បហីនេ ភវោ អប្បហីនោ ហោតីតិ ឥតិ វជំ ជម្មមេវ ងេសេតិ ។

ប្រកបដោយសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិខុស ដូច្នេះឈ្មោះថាសំដែងធម៌ដោយត្រង់ ។ បុគ្គលអ្នកសំដែងធម៌ មិនបានពោលយ៉ាងនេះថា ជនទាំងឡាយណាដែលមិនប្រកបរឿយ ៗ នូវសេចក្តីព្យាយាមធ្វើខ្លួនឯងឲ្យលំបាក នាំមកនូវទុក្ខ មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ជនទាំងអស់នោះ មិនមានទុក្ខ មិនមានសេចក្តីលំបាក មិនមានសេចក្តីចង្អៀតចង្អល់ មិនមានសេចក្តីក្តៅក្រហាយ ជាអ្នកប្រតិបត្តិត្រូវ ដូច្នេះ ។ កាលដែលបុគ្គលអ្នកសំដែងធម៌ ពោលថា អនុយោគធម៌[១]នុ៎ះ មិនមានទុក្ខ មិនមានសេចក្តីលំបាក មិនមានសេចក្តីចង្អៀតចង្អល់ មិនមានសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិត្រូវ ដូច្នេះ ឈ្មោះថាសំដែងធម៌ដោយត្រង់ ។ បុគ្គលអ្នកសំដែងធម៌ មិនបានពោលយ៉ាងនេះថា ជនទាំងឡាយណាមួយ មិនបានលះបង់នូវភវសំយោជនៈ[២] ជនទាំងអស់នោះ ប្រកបដោយសេចក្តីទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ ជាអ្នកប្រតិបត្តិខុស ដូច្នេះ ។ កាលដែលបុគ្គលអ្នកសំដែងធម៌ ពោលថា កាលបើភវសំយោជនៈមិនទាន់លះបង់នៅឡើយ ភពក៏មិនបានលះបង់ទៅដែរ ដូច្នេះ ឈ្មោះថាសំដែងធម៌ដោយត្រង់ ។

---

១ ការមិនប្រកបព្យាយាមធ្វើខ្លួនឯងឲ្យលំបាក ។ ២ ចំណងសត្វក្នុងភពបានដល់តណ្ហា ។

យេសំ កោសញ្ញិ ភវសញ្ញោជនំ បហីនំ សព្វេ តេ អទុក្ខា អនុបឃាតា អនុចាយាសា អបរិឡាហា សម្មាបដិបន្នាតិ ន ឯវមាហ ។ ភវសញ្ញោជនេ ច ខោ បហីនេ ភវោ បហីនោ ហោតីតិ ឥតិ វទំ ធម្មមេវ ទេសេតិ ។ ឯវំ ខោ ភិក្ខវេ នេវុស្សាទនា ហោតិ ន អប្បសាទនា ធម្មទេសនា វ ។ ឧស្សាទនញ្ច ជញ្ញា អប្បសាទនញ្ច ជញ្ញា ឧស្សាទនញ្ច ញត្វា អប្បសាទនញ្ច ញត្វា នេវុស្សាទេយ្យ ន អប្បសា-ទេយ្យ ធម្មមេវ ទេសេយ្យាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

[១៣៤] សុខវិនិច្ឆយំ ជញ្ញា សុខវិនិច្ឆយំ ញត្វា អជ្ឈត្តំ សុខមនុយុញ្ជេយ្យាតិ ឥតិ ខោ បនេតំ វុត្តំ ។

បុគ្គលអ្នកសំដែងធម៌ មិនបានពោលយ៉ាងនេះថា ជនទាំងឡាយណាមួយ បានលះបង់នូវភវសំយោជនៈ ជនទាំងអស់នោះ មិនមានទុក្ខ មិនមានសេចក្តីលំបាក មិនមានសេចក្តីចង្អៀតចង្អល់ មិនមានសេចក្តីក្តៅក្រហាយ ជាអ្នកប្រតិបត្តិត្រូវ ដូច្នេះ ។ កាលដែលបុគ្គលអ្នកសំដែងធម៌ពោលថា កាលបើភវសំយោជនៈលះបង់ទៅហើយ ភពក៏លះបង់ទៅដែរ ដូច្នេះ ឈ្មោះថាសំដែងធម៌ដោយត្រង់ ។ ម្នាលភិក្ខុទាំងឡាយ ការមិនលើកតម្កើង ការមិនបន្ទុះបង្អាប់ ជាការសំដែងធម៌ដោយត្រង់យ៉ាងនេះឯង ។ ពាក្យណា ដែលតថាគតពោលហើយថា បុគ្គលគប្បីដឹងនូវការលើកតម្កើងផង គប្បីដឹងនូវការបន្ទុះបង្អាប់ផង លុះដឹងនូវការលើកតម្កើង និងដឹងនូវការបន្ទុះបង្អាប់ហើយ មិនគប្បីលើកតម្កើង មិនគប្បីបន្ទុះបង្អាប់ គប្បីសំដែងធម៌ដោយត្រង់ ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យសេចក្តីនេះឯង ។

[១៣៤] ពាក្យថា បុគ្គល គប្បីដឹងនូវសេចក្តីសុខដែលថោកថយ លុះដឹងនូវសេចក្តីសុខដែលថោកថយហើយ គប្បីប្រកបរឿយ ៗ នូវសេចក្តីសុខក្នុងសន្តាន ដូច្នេះ ពាក្យនុ៎ះ តថាគតបានពោលហើយ ។

កិញ្ចេតំ បដិច្ច វុត្តំ ។ បញ្ចិមេ ភិក្ខវេ កាមគុណា កតមេ បញ្ច ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា សោត-វិញ្ញេយ្យា សទ្ទា... ឃានវិញ្ញេយ្យា គន្ធា... ជិវ្ហា-វិញ្ញេយ្យា រសា... កាយវិញ្ញេយ្យា ផោដ្ឋព្វា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា ឥមេ ខោ ភិក្ខវេ បញ្ច កាមគុណា ។ យំ ខោ ភិក្ខវេ ឥមេ បញ្ច កាមគុណេ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ ឥទំ វុច្ចតិ កាមសុខំ បុថុជ្ជន-សុខំ មិឡ្ហសុខំ អនរិយសុខំ ។ ន សេវិតព្វំ[១] ន ភាវេតព្វំ ន ពហុលីកាតព្វំ ភាយិតព្វំ ឯតស្ស សុខស្សាតិ វទាមិ ។ ឥធ ភិក្ខវេ ភិក្ខុ

១ ឱ. ន អាសេវិតព្វំ ។

ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យសេចក្តីដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កាមគុណនេះមាន ៥ ប្រការ កាមគុណ ៥ ប្រការ តើអ្វីខ្លះ រូបដែលគប្បីដឹងដោយចក្ខុ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពជាទីស្រឡាញ់ ប្រកបដោយកាម ជាទីតាំងនៃសេចក្តីត្រេកអរ សំឡេងដែលគប្បីដឹងដោយត្រចៀក... ក្លិនដែលគប្បីដឹងដោយច្រមុះ... រសដែលគប្បីដឹងដោយអណ្តាត... ផោដ្ឋព្វៈដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពជាទីស្រឡាញ់ ប្រកបដោយកាម ជាទីតាំងនៃសេចក្តីត្រេកអរ ម្នាលភិក្ខុទាំងឡាយ នេះឯង កាមគុណមាន ៥ ប្រការ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខនិងសោមនស្សណា តែងកើតឡើង ព្រោះអាស្រ័យនូវកាមគុណទាំង ៥ នេះ សេចក្តីសុខនិងសោមនស្សនេះ តថាគតហៅថា ជាសេចក្តីសុខក្នុងកាម ជាសេចក្តីសុខរបស់បុថុជ្ជន ជាសេចក្តីសុខដ៏លាមក មិនមែនជាសេចក្តីសុខរបស់ព្រះអរិយបុគ្គលទេ ។ តថាគតពោលថា បុគ្គលមិនគប្បីសេព មិនគប្បីចម្រើន មិនគប្បីធ្វើឲ្យច្រើន គប្បីខ្លាចសេចក្តីសុខនេះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ

វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ... តតិយំ ឈានំ... ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ឥទំ វុច្ចតិ នេក្ខម្មសុខំ បវិវេកសុខំ ឧបសមសុខំ សម្ពោធិសុខំ ។ អាសេវិតព្វំ ភាវេតព្វំ ពហុលីកាតព្វំ ន ភាយិតព្វំ ឯតស្ស សុខស្សាតិ វទាមិ ។ សុខវិនិច្ឆយំ ជញ្ញា សុខវិនិច្ឆយំ ញត្វា អជ្ឈត្តំ សុខមនុយុញ្ជេយ្យាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយបានដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្កៈនិងវិចារៈ មានបីតិនិងសុខដែលកើតអំពីសេចក្តីស្ងាត់ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ព្រោះរម្ងាប់វិតក្កៈនិងវិចារៈ ក៏បានដល់នូវទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្តាននៃខ្លួន ប្រកបដោយសេចក្តីជ្រះថ្លាគឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខដែលកើតអំពីសមាធិគឺបឋមជ្ឈាន... បានដល់នូវតតិយជ្ឈាន... បានដល់នូវចតុត្ថជ្ឈាន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ នេះ តថាគតហៅថា នេក្ខម្មសុខ[១] បវិវេកសុខ[២] ឧបសមសុខ[៣] សម្ពោធិសុខ[៤] ។ តថាគតពោលថា បុគ្គលគួរសេព គួរចម្រើន គួរធ្វើឲ្យច្រើន មិនគួរខ្លាចសេចក្តីសុខនេះឡើយ ។ ពាក្យណាដែលតថាគតពោលហើយថា បុគ្គលគប្បីដឹង នូវសេចក្តីសុខដែលថោកថយ លុះដឹង នូវសេចក្តីសុខដែលថោកថយហើយ គប្បីប្រកបរឿយ ៗ នូវសេចក្តីសុខក្នុងសន្តាន ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យសេចក្តីនេះឯង ។

---

១ សុខកើតអំពីការចេញចាកកាម ។ ២ សុខកើតអំពីសេចក្តីស្ងាត់ចាកកាមនិងអកុសលធម៌ ។ ៣ សុខកើតអំពីការរម្ងាប់នីវរណធម៌ជាដើម ។ ៤ សុខប្រព្រឹត្តទៅដើម្បីត្រាស់ដឹងមគ្គ ផល និព្វាន ។

វិភង្គវគ្គស្ស អរណវិភង្គសុត្តេ រហោ វាទស្ស អភាសនា

[១៣៨] រហោ វាទំ ន ភាសេយ្យ សម្មុខា ជាតិទីណំ ភណោតិ ឥតិ ខោ បនេតំ វុត្តំ ។ កិញ្ចេតំ បដិច្ច វុត្តំ ។ តត្រ ភិក្ខវេ យំ ជញ្ញា រហោ វាទំ អភូតំ អតច្ឆំ អនត្ថសញ្ហិតំ សសក្កំ តំ រហោ វាទំ ន ភាសេយ្យ យម្បិ ជញ្ញា រហោ វាទំ ភូតំ តច្ឆំ អនត្ថសញ្ហិតំ តស្សបិ សិក្ខេយ្យ អវចនាយ យញ្ច ខោ ជញ្ញា រហោ វាទំ ភូតំ តច្ឆំ អត្ថសញ្ហិតំ តត្រ កាលញ្ញូ អស្ស តស្ស រហោ វាទស្ស វច-នាយ ។ តត្រ ភិក្ខវេ យំ ជញ្ញា សម្មុខា ទីណវាទំ អភូតំ អតច្ឆំ អនត្ថសញ្ហិតំ ស-សក្កំ តំ សម្មុខា ទីណវាទំ ន ភាសេយ្យ យម្បិ ជញ្ញា សម្មុខា ទីណវាទំ ភូតំ តច្ឆំ អនត្ថសញ្ហិតំ តស្សបិ សិក្ខេយ្យ អវចនាយ

វិភង្គវគ្គ អរណវិភង្គសូត្រ ការមិនពោលពាក្យក្នុងទីកំបាំងមុខ

[១៣៥] ពាក្យថា បុគ្គលមិនគប្បីពោលពាក្យក្នុងទីកំបាំងមុខ មិនគប្បីពោលពាក្យនាំឲ្យសៅហ្មងក្នុងទីចំពោះមុខ ដូច្នេះ នុ៎ះ តថាគតបានពោលហើយ ។ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យសេចក្តីដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បណ្តាពាក្យទាំងនោះ បុគ្គលដឹងនូវពាក្យស្វាត់កំបាំងណា ជាពាក្យមិនពិត មិនទៀង មិនប្រកបដោយប្រយោជន៍ ដោយពិត មិនគប្បីពោលពាក្យស្វាត់កំបាំងឡើយ មួយទៀត បុគ្គលដឹងនូវពាក្យស្វាត់កំបាំងណា ជាពាក្យពិត ពាក្យទៀង តែមិនប្រកបដោយប្រយោជន៍ បុគ្គលគប្បីរៀនដើម្បីមិននិយាយនូវពាក្យនោះ មួយទៀត បុគ្គលដឹងនូវពាក្យស្វាត់កំបាំងណា ជាពាក្យពិត ពាក្យទៀង ហើយប្រកបដោយប្រយោជន៍ បុគ្គលគួរជាអ្នកដឹងនូវកាលគួរក្នុងពាក្យនោះ ដើម្បីនិយាយនូវពាក្យស្វាត់កំបាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាពាក្យទាំងនោះ បុគ្គលដឹងនូវពាក្យណា ដែលនាំឲ្យសៅហ្មងក្នុងទីចំពោះមុខ ជាពាក្យមិនពិត មិនទៀង មិនប្រកបដោយប្រយោជន៍ ដោយពិត មិនគប្បីពោលពាក្យដែលនាំឲ្យសៅហ្មងក្នុងទីចំពោះមុខនោះទេ មួយទៀត បុគ្គលដឹងនូវពាក្យណា ដែលនាំឲ្យសៅហ្មងក្នុងទីចំពោះមុខ ជាពាក្យពិត ពាក្យទៀង តែមិនប្រកបដោយប្រយោជន៍ បុគ្គលគប្បីរៀន ដើម្បីមិនពោលនូវពាក្យនោះ

យញ្ច ខោ ជញ្ញា សម្មុខា ខីណវាទំ ភូតំ តច្ឆំ អត្ថសញ្ហិតំ តត្រ កាលញ្ញូ អស្ស តស្ស សម្មុខា ខីណវាទស្ស វចនាយ ។ រហោ វាទំ ន ភាសេយ្យ សម្មុខា ណាតិខីណំ ភណេតិ ឥតិ យន្តំ វុត្តំ ឥទ-មេតំ បដិច្ច វុត្តំ ។

[១៣៦] អតរមានោ វ[១] ភាសេយ្យ ណោ តរមា-ណោតិ ឥតិ ខោ បនេតំ វុត្តំ ។ កិញ្ចេតំ បដិច្ច វុត្តំ ។ តត្រ ភិក្ខវេ តរមានស្ស ភាសតោ

១ ម. ច ។

មួយទៀត បុគ្គលដឹងនូវពាក្យណា ដែលនាំឲ្យសៅហ្មងក្នុងទីចំពោះមុខ ជាពាក្យពិត ពាក្យទៀង ហើយប្រកបដោយប្រយោជន៍ បុគ្គលគួរជាអ្នកដឹងនូវកាលគួរក្នុងពាក្យនោះ ដើម្បីនិយាយ នូវពាក្យដែលនាំឲ្យសៅហ្មងក្នុងទីចំពោះមុខនោះ ។ ពាក្យណា ដែលតថាគតបានពោលហើយថា បុគ្គលមិនគប្បីពោលពាក្យក្នុងទីកំបាំងមុខ មិនគប្បីពោលពាក្យដែលនាំឲ្យសៅហ្មងក្នុងទីចំពោះមុខ ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យសេចក្តីនេះឯង ។

[១៣៦] ពាក្យថា បុគ្គលគប្បីពោលកុំឲ្យរួសរាន់ពេក មិនគប្បីពោលរួសរាន់ពេក នុ៎ះ តថាគតបានពោលហើយ ។ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យសេចក្តីដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបុគ្គលទាំងនោះ បុគ្គលដែលពោលរហ័ស

កាយោបិ កិលមតិ ចិត្តម្បិ ឧបហញ្ញតិ សរោបិ ឧបហញ្ញតិ កណ្ឋោបិ អាតុរិយតិ អវិសដ្ឋំបិ ហោតិ អវិញ្ញេយ្យំ តរមានស្ស ភាសិតំ ។ តត្រ ភិក្ខវេ អតរមានស្ស ភាសតោ កាយោបិ ន កិលមតិ ចិត្តម្បិ ន ឧបហញ្ញតិ សរោបិ ន ឧបហញ្ញតិ កណ្ឋោបិ ន អាតុរិយតិ វិសដ្ឋម្បិ ហោតិ វិញ្ញេយ្យំ អតរមានស្ស ភាសិតំ ។ អតរមានោ វ ភាសេយ្យ នោ តរមានោតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

[១៣៧] ជនបទនិរុត្តឹ ណាភិនិវេសេយ្យ សមញ្ញំ ណាតិធាវេយ្យាតិ ឥតិ ខោ បនេតំ វុត្តំ ។ កិញ្ចេតំ បដិច្ច វុត្តំ ។ កថញ្ច ភិក្ខវេ ជនបទនិរុត្តិយា ច អភិនិវេសោ ហោតិ សមញ្ញាយ ច អតិសារោ ។ ឥធ ភិក្ខវេ តទេវេកច្ចេសុ ជនបទេសុ ចាតីតិ សញ្ជានន្តិ បត្តន្តិ សញ្ជានន្តិ បិដ្ឋន្តិ[១] សញ្ជានន្តិ សរាវន្តិ សញ្ជា-នន្តិ ហារោសន្តិ[២] សញ្ជានន្តិ ចោណន្តិ សញ្ជានន្តិ

១ ឱ. ម. វិត្ថន្តិ ។ ២ ឱ. ម. ធារោបន្តិ ។

កាយក៏រមែងលំបាក ចិត្តក៏រមែងព្រួយ សំឡេងក៏ស្អក កក៏ឈឺចាប់ សំដីរបស់បុគ្គល ដែលពោលញាប់ ជាសំដីមិនស្រឡះផង ស្តាប់មិនជាក់ផង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបុគ្គលទាំងនោះ បុគ្គលដែលពោលមិនរហ័សពេក កាយក៏មិនលំបាក ចិត្តក៏មិនព្រួយ សំឡេងក៏មិនស្អក កក៏មិនឈឺចាប់ សំដីរបស់បុគ្គលដែលពោលមិនញាប់ ជាសំដីស្រឡះផង ដឹងសេចក្តីច្បាស់ផង ។ ពាក្យណា ដែលតថាគតពោលហើយថា បុគ្គលគប្បីពោលកុំឲ្យរួសរាន់ពេក មិនគប្បីពោលរួសរាន់ពេក ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យសេចក្តីនេះឯង ។

[១៣៧] ពាក្យថា បុគ្គល មិនគប្បីប្រកាន់ភាសាក្នុងជនបទ មិនគប្បីប្រព្រឹត្តកន្លងនូវឈ្មោះ ដូច្នេះនុ៎ះ តថាគតបានពោលហើយ ។ ពាក្យនុ៎ះតថាគតពោលហើយ ព្រោះអាស្រ័យសេចក្តីដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ចុះការប្រកាន់នូវភាសាក្នុងជនបទ និងការប្រព្រឹត្តកន្លងនូវឈ្មោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងជនបទខ្លះ ក្នុងលោកនេះ ភាជនៈតែមួយបែបនោះសោះ តែជនទាំងឡាយរមែងស្គាល់ថាបាតិខ្លះ រមែងស្គាល់ថាបត្តៈខ្លះ រមែងស្គាល់ថាបិដ្ឋៈខ្លះ រមែងស្គាល់ថាសរាវៈខ្លះ រមែងស្គាល់ថាហរោសៈខ្លះ រមែងស្គាល់ថាបោណៈខ្លះ

ហនន្តិ[១] សញ្ជានន្តិ[២] បិបិលន្តិ[៣] សញ្ជានន្តិ ។ ឥតិ យថា យថា នំ តេសុ តេសុ ជនបទេសុ សញ្ជានន្តិ តថា តថា ថាមសា បរាមាសា អភិនិវិស្ស វោហរតិ ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ ឯវំ ខោ ភិក្ខវេ ជនបទនិរុត្តិយា ច អភិនិវេសោ ហោតិ សមញ្ញាយ ច អតិសារោ ។ កថញ្ច ភិក្ខវេ ជនបទនិរុត្តិយា ច អនភិនិវេសោ ហោតិ សមញ្ញាយ ច អនតិសារោ ។ ឥធ ភិក្ខវេ តទេវេកច្ចេសុ ជនបទេសុ បាតីតិ សញ្ជានន្តិ បត្តន្តិ សញ្ជានន្តិ បិដ្ឋន្តិ សញ្ជានន្តិ សរាវន្តិ សញ្ជានន្តិ ហរោសន្តិ សញ្ជានន្តិ ចោណន្តិ សញ្ជានន្តិ ហានន្តិ សញ្ជានន្តិ

១-២ ឱ. ម. ឥមេ បាឋា នត្ថិ ។ ៣ ឱ. ម. បិសីលន្តិ ។

រមែងស្គាល់ថាហនៈខ្លះ រមែងស្គាល់ថាបិបិលៈខ្លះ[១] ។ ព្រោះហេតុនោះ ពួកជនស្គាល់នូវរបស់នោះ ក្នុងជនបទនោះ ៗ យ៉ាងណា ៗ បុគ្គលខ្លះក៏ប្រកាន់មាំមួនយ៉ាងនោះ ៗ ហើយពោលថា[២] ពាក្យនេះជាពាក្យពិត ពាក្យដទៃ ជាមោឃៈ ។ ម្នាលភិក្ខុទាំងឡាយ ការប្រកាន់នូវភាសាក្នុងជនបទ និងការប្រព្រឹត្តកន្លងនូវឈ្មោះ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះការដែលមិនប្រកាន់នូវភាសាក្នុងជនបទ និងការមិនប្រព្រឹត្តកន្លងនូវឈ្មោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងជនបទខ្លះក្នុងលោកនេះ ភាជនៈតែមួយបែបនោះសោះ តែជនទាំងឡាយ រមែងស្គាល់ថាបាតិខ្លះ រមែងស្គាល់ថាបត្តៈខ្លះ រមែងស្គាល់ថាបិដ្ឋៈខ្លះ រមែងស្គាល់ថាសរាវៈខ្លះ រមែងស្គាល់ថាហរោសៈខ្លះ រមែងស្គាល់ថាបោណៈខ្លះ រមែងស្គាល់ថាហនៈខ្លះ

---

១ ពួកសព្ទទាំងអស់នេះ ជាឈ្មោះរបស់ភាជន៍តែមួយបែបសម្រាប់ប្រើប្រាស់ក្នុងសម័យនោះ ដូចយ៉ាងឈ្មោះថាអាឡ្ហកៈ ទោណៈជាដើម ។ ឯប្រយោគនេះបានសេចក្តីថា ភាជនៈតែមួយ តែស្រុកខ្លះហៅថាបាតិ ខ្លះហៅថាបត្តៈ ។ ២ បុថុជ្ជនដែលល្ងង់ខ្លៅ កាលបើទៅកាន់ជនបទដែលគេហៅភាជនៈនោះថា បត្តៈ ដូច្នេះ បានឮគេនិយាយគ្នាថា អ្នកទាំងឡាយចូរយកបត្តៈមក ចូរលាងបត្តៈទៅ ហើយនិយាយប្រកាន់ថា ភាជនៈនេះមិនមែនឈ្មោះបត្តៈទេ ឈ្មោះបាតិទេតើ អ្នកឯងចូរហៅបាតិដូច្នេះវិញ ។ អដ្ឋកថា ។

បិបិលន្តិ សញ្ជានន្តិ ។ ឥតិ យថា យថា នំ តេសុ តេសុ ជនបទេសុ សញ្ជានន្តិ ឥទំ កិរ មេ អាយស្មន្តោ សន្ធាយ វោហរន្តីតិ តថា តថា វោហរតិ អបរាមសំ[១] ។ ឯវំ ខោ ភិក្ខវេ ជនបទនិរុត្តិយា ច អនភិនិវេសោ ហោតិ សមញ្ញាយ ច អនតិសារោ ។ ជនបទនិរុត្តឹ នាភិនិវេសេយ្យ សមញ្ញំ នាតិធាវេយ្យាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

[១៣៨] តត្រ ភិក្ខវេ យោ កាមប្បដិសន្ធិសុខិនោ សោមនស្សានុយោគោ ហីនោ គម្មោ ចោថុជ្ជនិកោ អនរិយោ អនត្ថសញ្ហិតោ សទុក្ខោ ឯសោ ធម្មោ សឧបឃាតោ សឧចាយាសោ សបរិឡាហោ

១ ម. អបរាមសត ។

រមែងស្គាល់ថាបិបិលៈខ្វះ ។ ព្រោះហេតុនោះ ពួកជន តែងស្គាល់នូវភាជនៈនោះ ក្នុងជនបទនោះ ៗ ថា លោកមានអាយុទាំងនេះ ពោលសំដៅរបស់នេះ ដូច្នេះ យ៉ាងណា ៗ បុគ្គលខ្វះមិនប្រកាន់មាំ តែងពោលយ៉ាងនោះ ៗ ម្នាលភិក្ខុទាំងឡាយ ការមិនប្រកាន់នូវភាសាក្នុងជនបទ និងការមិនប្រព្រឹត្តកន្លងនូវឈ្មោះ យ៉ាងនេះឯង ។ ពាក្យណា ដែលតថាគតបានពោលហើយថា បុគ្គល មិនគប្បីប្រកាន់នូវភាសាក្នុងជនបទ មិនគប្បីប្រព្រឹត្តកន្លងនូវឈ្មោះ ដូច្នេះ ពាក្យនុ៎ះ តថាគតបានពោលហើយ ព្រោះអាស្រ័យសេចក្តីនេះឯង ។

[១៣៨] ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ ធម៌ណា គឺសេចក្តីព្យាយាមដោយសោមនស្ស របស់បុគ្គលដែលមានសេចក្តីសុខដោយកាមប្បដិសន្ធិ ជាធម៌ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ធម៌នុ៎ះ ប្រកបដោយសេចក្តីទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ

មិច្ឆាបដិបទា តស្មា ឯសោ ធម្មោ សរណោ ។ តត្រ ភិក្ខវេ យោ កាមប្បដិសន្ធិសុខិនោ សោមនស្សានុយោគំ អននុយោគោ ហីនំ គម្មំ ពោថុជ្ជនិកំ អនរិយំ អនត្ថសញ្ហិតំ អទុក្ខោ ឯសោ ធម្មោ អនុបឃាតោ អនុបាយាសោ អបរិឡាហោ សម្មាបដិបទា តស្មា ឯសោ ធម្មោ អរណោ ។

[១៣៩] តត្រ ភិក្ខវេ យោ អត្តកិលមថានុយោគោ ទុក្ខោ អនរិយោ អនត្ថសញ្ហិតោ សទុក្ខោ ឯសោ ធម្មោ សឧបឃាតោ សឧបាយាសោ សបរិឡាហោ មិច្ឆាបដិបទា តស្មា ឯសោ ធម្មោ សរណោ ។

ជាសេចក្តីប្រតិបត្តិខុស ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថា ប្រកបដោយសេចក្តីសៅហ្មង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ ធម៌ណា គឺការមិនប្រកបរឿយ ៗ នូវសេចក្តីព្យាយាមដោយសោមនស្ស របស់បុគ្គល ដែលមានសេចក្តីសុខដោយកាមប្បដិសន្ធិ ជាធម៌ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ធម៌នុ៎ះ មិនមានទុក្ខ មិនមានសេចក្តីលំបាក មិនមានសេចក្តីចង្អៀតចង្អល់ មិនមានសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិត្រូវ ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថាមិនមានសេចក្តីសៅហ្មង ។

[១៣៩] ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ ធម៌ណា គឺសេចក្តីព្យាយាមធ្វើខ្លួនឯងឲ្យលំបាក ជាធម៌នាំមកនូវសេចក្តីទុក្ខ មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ធម៌នុ៎ះ ប្រកបដោយសេចក្តីទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិខុស ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថាប្រកបដោយសេចក្តីសៅហ្មង ។

តត្រ ភិក្ខវេ យោ អត្តកិលមថានុយោគំ អននុយោគោ ទុក្ខំ អនរិយំ អនត្ថសញ្ហិតំ អទុក្ខោ ឯសោ ធម្មោ អនុបឃាតោ អនុបាយាសោ អបរិឡាហោ សម្មា-បដិបទា តស្មា ឯសោ ធម្មោ អរណោ ។

[១៨០] តត្រ ភិក្ខវេ យាយំ មជ្ឈិមា បដិបទា តថាគតេន អភិសម្ពុទ្ធា ចក្ខុករណី ញាណករណី ឧបសមាយ អភិញ្ញាយ សម្ពោធាយ និព្វានាយ សំវត្តតិ អទុក្ខោ ឯសោ ធម្មោ អនុបឃាតោ អនុបាយាសោ អបរិឡាហោ សម្មាបដិបទា តស្មា ឯសោ ធម្មោ អរណោ ។

ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ ធម៌ណា គឺការមិនប្រកបរឿយ ៗ នូវសេចក្តីព្យាយាមធ្វើខ្លួនឯងឲ្យលំបាក ជាសេចក្តីព្យាយាមនាំមកនូវសេចក្តីទុក្ខ មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ធម៌នុ៎ះ មិននាំមកនូវទុក្ខ មិនមានសេចក្តីលំបាក មិនមានសេចក្តីចង្អៀតចង្អល់ មិនមានសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិត្រូវ ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថាមិនមានសេចក្តីសៅហ្មង ។

[១៨០] ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ សេចក្តីប្រតិបត្តិយ៉ាងកណ្តាលណា ដែលព្រះតថាគតត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ ធ្វើឲ្យកើតសេចក្តីចេះដឹង ប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រម្ងាប់កិលេស ដើម្បីស្គាល់នូវអរិយសច្ច ដើម្បីត្រាស់ដឹងនូវអរិយសច្ច ដើម្បីព្រះនិព្វាន ធម៌នុ៎ះ ឈ្មោះថាមិននាំមកនូវទុក្ខ មិនមានសេចក្តីលំបាក មិនមានសេចក្តីចង្អៀតចង្អល់ មិនមានសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិត្រូវ ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថាមិនមានសេចក្តីសៅហ្មង ។

[១៤១] តត្រ ភិក្ខវេ យាយំ ឧស្សាទនា ច អប្បសាទនា ច នោ ច ធម្មទេសនា សទុក្ខោ ឯសោ ធម្មោ សឧបឃាតោ សឧបាយាសោ សបរិឡាហោ មិច្ឆាបដិបទា តស្មា ឯសោ ធម្មោ សរណោ ។ តត្រ ភិក្ខវេ យាយំ នេវុស្សាទនា ន អប្បសាទនា ធម្មទេសនា វ អទុក្ខោ ឯសោ ធម្មោ អនុបឃាតោ អនុបាយាសោ អបរិឡាហោ សម្មាបដិបទា តស្មា ឯសោ ធម្មោ អរណោ ។

[១៤២] តត្រ ភិក្ខវេ យមិទំ កាមសុខំ បុថុជ្ជនសុខំ មិឡ្ហសុខំ អនរិយសុខំ សទុក្ខោ ឯសោ ធម្មោ សឧបឃាតោ សឧបាយាសោ សបរិឡាហោ មិច្ឆាបដិបទា តស្មា ឯសោ ធម្មោ សរណោ ។

[១៤១] ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ ការលើកតម្កើងនិងការបន្ទុះបង្អាប់ ទាំងមិនមែនជាការសំដែងធម៌ ណា ធម៌នុ៎ះ ឈ្មោះថាប្រកបដោយទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិខុស ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថាប្រកបដោយសេចក្តីសៅហ្មង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ ការដែលមិនលើកតម្កើង និងការមិនបន្ទុះបង្អាប់ ទាំងការសំដែងធម៌ដោយត្រង់ ណា ធម៌នេះ មិននាំមកនូវទុក្ខ មិនមានសេចក្តីលំបាក មិនមានសេចក្តីចង្អៀតចង្អល់ មិនមានសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិត្រូវ ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថាមិនមានសេចក្តីសៅហ្មង ។

[១៤២] ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ សេចក្តីសុខណា ជាសេចក្តីសុខក្នុងកាម ជាសេចក្តីសុខរបស់បុថុជ្ជន ជាសេចក្តីសុខដ៏លាមក មិនមែនជាសេចក្តីសុខរបស់ព្រះអរិយបុគ្គល ធម៌នុ៎ះ ប្រកបដោយសេចក្តីទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិខុស ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថាប្រកបដោយសេចក្តីសៅហ្មង ។

តត្រ ភិក្ខវេ យមិទំ នេក្ខម្មសុខំ បវិវេកសុខំ ឧបសមសុខំ សម្ពោធិសុខំ អនុត្តោ ឯសោ ធម្មោ អនុបឃាតោ អនុបាយាសោ អបរិឡាហោ សម្មាប-ដិបទា តស្មា ឯសោ ធម្មោ អរណោ ។

[១៤៣] តត្រ ភិក្ខវេ យ្វាយំ រហោ វាទោ អភូតោ អតច្ឆោ អនត្ថសញ្ហិតោ សទុក្ខោ ឯសោ ធម្មោ សឧបឃាតោ សឧបាយាសោ សបរិឡាហោ មិច្ឆាបដិបទា តស្មា ឯសោ ធម្មោ សរណោ ។ តត្រ ភិក្ខវេ យោ ចាយំ រហោ វាទោ ភូតោ តច្ឆោ អនត្ថសញ្ហិតោ សទុក្ខោ ឯសោ ធម្មោ សឧបឃាតោ សឧបាយាសោ សបរិឡាហោ

ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ សេចក្តីសុខណា ដែលជាសេចក្តីសុខក្នុងការចេញចាកកាម ជាសេចក្តីសុខក្នុងការស្ងាត់ ជាសេចក្តីសុខក្នុងការរម្ងាប់កិលេស ជាសេចក្តីសុខក្នុងការត្រាស់ដឹងមគ្គផល ធម៌នុ៎ះ មិននាំមកនូវទុក្ខ មិនមានសេចក្តីលំបាក មិនមានសេចក្តីចង្អៀតចង្អល់ មិនមានសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិត្រូវ ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថាមិនមានសេចក្តីសៅហ្មង ។

[១៤៣] ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ ពាក្យស្ងាត់កំបាំង ណា ជាពាក្យមិនពិត មិនទៀង មិនប្រកបដោយប្រយោជន៍ ធម៌នុ៎ះ ប្រកបដោយសេចក្តីទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិខុស ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថាប្រកបដោយសេចក្តីសៅហ្មង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ ពាក្យស្ងាត់កំបាំង ណា ជាពាក្យពិត ទៀង តែមិនប្រកបដោយប្រយោជន៍ ធម៌នុ៎ះ ប្រកបដោយសេចក្តីទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ

មិច្ឆាបដិបទា តស្មា ឯសោ ធម្មោ សរណោ ។ តត្រ ភិក្ខវេ យោ ចាយំ រហោ វាទោ ភូតោ តច្ឆោ អត្ថសញ្ហិតោ អទុក្ខោ ឯសោ ធម្មោ អនុបឃាតោ អនុបាយាសោ អបរិឡាហោ សម្មាបដិបទា តស្មា ឯសោ ធម្មោ អរណោ ។

[១៤៤] តត្រ ភិក្ខវេ យ្វាយំ សម្មុខា ខីណវាទោ អភូតោ អតច្ឆោ អនត្ថសញ្ហិតោ សទុក្ខោ ឯសោ ធម្មោ សឧបឃាតោ សឧបាយាសោ សបរិឡាហោ មិច្ឆាបដិបទា តស្មា ឯសោ ធម្មោ សរណោ ។ តត្រ ភិក្ខវេ យោ ចាយំ សម្មុខា ខីណវាទោ ភូតោ តច្ឆោ អនត្ថសញ្ហិតោ សទុក្ខោ ឯសោ ធម្មោ សឧបឃាតោ សឧបាយាសោ សបរិឡាហោ មិច្ឆាបដិបទា តស្មា ឯសោ ធម្មោ

ជាសេចក្តីប្រតិបត្តិខុស ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថាប្រកបដោយសេចក្តីសៅហ្មង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ ពាក្យស្វាត់កំបាំង ណា ជាពាក្យពិត ទៀង ប្រកបដោយប្រយោជន៍ ធម៌នុ៎ះ មិននាំមកនូវសេចក្តីទុក្ខ មិនមានសេចក្តីលំបាក មិនមានសេចក្តីចង្អៀតចង្អល់ មិនមានសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិត្រូវ ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថាមិនមានសេចក្តីសៅហ្មង ។

[១៨៨] ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ ពាក្យនាំឲ្យសៅហ្មងក្នុងទីចំពោះមុខ ណា ជាពាក្យមិនពិត មិនទៀង មិនប្រកបដោយប្រយោជន៍ ធម៌នុ៎ះ ប្រកបដោយសេចក្តីទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិខុស ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថាប្រកបដោយសេចក្តីសៅហ្មង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ ពាក្យនាំឲ្យសៅហ្មងក្នុងទីចំពោះមុខ ណា ជាពាក្យពិត ទៀង តែមិនប្រកបដោយប្រយោជន៍ ធម៌នុ៎ះ ប្រកបដោយសេចក្តីទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិខុស ព្រោះហេតុនោះ ធម៌នុ៎ះ

សរណោ ។ តត្រ ភិក្ខវេ យោ ចាយំ សម្មុខា ខីណាវាទោ ភូតោ តច្ឆោ អត្ថសញ្ហិតោ អទុក្ខោ ឯសោ ធម្មោ អនុបឃាតោ អនុបាយាសោ អបរិឡាហោ សម្មាបដិបទា តស្មា ឯសោ ធម្មោ អរណោ ។

[១៤៩] តត្រ ភិក្ខវេ យមិទំ តរមានស្ស ភាសិតំ សទុក្ខោ ឯសោ ធម្មោ សឧបឃាតោ សឧបាយាសោ សបរិឡាហោ មិច្ឆាបដិបទា តស្មា ឯសោ ធម្មោ សរណោ ។ តត្រ ភិក្ខវេ យមិទំ អតរមានស្ស ភាសិតំ អទុក្ខោ ឯសោ ធម្មោ អនុបឃាតោ អនុបាយាសោ អបរិឡាហោ សម្មាបដិបទា តស្មា ឯសោ ធម្មោ អរណោ ។

ឈ្មោះថាប្រកបដោយសេចក្ដីសៅហ្មង ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាធម៌ទាំងនោះ ពាក្យនាំឲ្យសៅហ្មងក្នុងទីចំពោះមុខ ណា ជាពាក្យពិតទៀង ទាំងប្រកបដោយប្រយោជន៍ ធម៌នុ៎ះ មិននាំមកនូវទុក្ខ មិនមានសេចក្ដីលំបាក មិនមានសេចក្ដីចង្អៀតចង្អល់ មិនមានសេចក្ដីក្ដៅក្រហាយ ជាសេចក្ដីប្រតិបត្តិត្រូវ ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថាមិនមានសេចក្ដីសៅហ្មង ។

[១៤៥] ម្នាលភិក្ខុទាំងឡាយ បណ្ដាធម៌ទាំងនោះ ធម៌ណា គឺពាក្យរបស់បុគ្គលអ្នកពោលរហ័សពេក ធម៌នុ៎ះ ប្រកបដោយសេចក្ដីទុក្ខ ប្រកបដោយសេចក្ដីលំបាក ប្រកបដោយសេចក្ដីចង្អៀតចង្អល់ ប្រកបដោយសេចក្ដីក្ដៅក្រហាយ ជាសេចក្ដីប្រតិបត្តិខុស ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថាប្រកបដោយសេចក្ដីសៅហ្មង ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាធម៌ទាំងនោះ ធម៌ណា គឺពាក្យរបស់បុគ្គលអ្នកពោលមិនរហ័សពេក ធម៌នុ៎ះ មិននាំមកនូវទុក្ខ មិនមានសេចក្ដីលំបាក មិនមានសេចក្ដីចង្អៀតចង្អល់ មិនមានសេចក្ដីក្ដៅក្រហាយ ជាសេចក្ដីប្រតិបត្តិត្រូវ ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថាមិនមានសេចក្ដីសៅហ្មង ។

[១៤៦] តត្រ ភិក្ខវេ យ្វាយំ ជនបទនិរុត្តិយា ច អភិនិវេសោ សមញ្ញាយ ច អតិសារោ សទុក្ខោ ឯសោ ធម្មោ សឧបឃាតោ សឧបាយាសោ សបរិឡាហោ មិច្ឆាបដិបទា តស្មា ឯសោ ធម្មោ សរណោ ។ តត្រ ភិក្ខវេ យ្វាយំ ជនបទនិរុត្តិយា ច អនភិនិវេសោ សមញ្ញាយ ច អនតិសារោ អទុក្ខោ ឯសោ ធម្មោ អនុបឃាតោ អនុបាយាសោ អបរិឡាហោ សម្មាបដិបទា តស្មា ឯសោ ធម្មោ អរណោ ។

[១៤៧] តស្មាតិហ ភិក្ខវេ សរណញ្ច ធម្មំ ជានិស្សាម អរណញ្ច ធម្មំ ជានិស្សាម សរណញ្ច ធម្មំ ញត្វា អរណញ្ច ធម្មំ ញត្វា អរណប្បដិបទំ បដិបជ្ជិស្សាមាតិ ឯវញ្ហិ វោ ភិក្ខវេ[១] សិក្ខិតព្វំ ។ សុភូតិ ច បន ភិក្ខវេ កុលបុត្តោ

---

១ ឱ. ឯវំ ខោ ភិក្ខវេតិ ទិស្សតិ ។

[១៤៦] ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ ធម៌ណា គឺការប្រកាន់មាំនូវភាសាក្នុងជនបទ និងការប្រព្រឹត្តកន្លងនូវឈ្មោះ ធម៌នុ៎ះ ប្រកបដោយសេចក្តីទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិខុស ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថាប្រកបដោយសេចក្តីសៅហ្មង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ ធម៌ណា គឺការមិនប្រកាន់នូវភាសាក្នុងជនបទ និងការមិនប្រព្រឹត្តកន្លងនូវឈ្មោះ ធម៌នុ៎ះ មិននាំមកនូវទុក្ខ មិនមានសេចក្តីលំបាក មិនមានសេចក្តីចង្អៀតចង្អល់ មិនមានសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិត្រូវ ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថា មិនមានសេចក្តីសៅហ្មង ។

[១៤៧] ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយគប្បីសិក្សាក្នុងសាសនានេះថា យើងទាំងឡាយ នឹងដឹងនូវធម៌ ដែលប្រកបដោយសេចក្តីសៅហ្មងផង និងដឹងនូវធម៌ដែលមិនមានសេចក្តីសៅ-ហ្មងផង លុះដឹងនូវធម៌ដែលប្រកបដោយសេចក្តីសៅហ្មង និងដឹងនូវធម៌ដែលមិនមានសេចក្តីសៅហ្មងហើយ ក៏នឹងដើរទៅកាន់ផ្លូវប្រតិបត្តិដែលមិនមានសេចក្តីសៅហ្មង ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវសិក្សាយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចំណែកសុភូតិកុលបុត្ត

១៦៩

វិភង្គវគ្គស្ស អរណវិភង្គសុត្តេ ភាសិតាភិនន្ទនំ

# អរណប្បដិបទំ បដិបន្នោតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

អរណវិភង្គសុត្តំ នវមំ និដ្ឋិតំ ។

បានដើរទៅកាន់ផ្លូវប្រតិបត្តិដែលមិនមានសេចក្តីសៅហ្មង ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងនោះក៏មានសេចក្តីត្រេកអរ រីករាយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ អរណវិភង្គសូត្រ ទី ៩ ។

# ទសមំ ធាតុវិភង្គសុត្តំ

[១៤៨] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា មគធេសុ ចារិកញ្ចរមានោ យេន រាជគហំ តទវសរិ យេន ភគ្គវោ កុម្ភការោ តេនុបសង្កមិ ឧបសង្ក-មិត្វា ភគ្គវំ កុម្ភការំ ឯតទវោច សចេ តេ ភគ្គវ អគរុ វិហរាម និវេសនេ ឯករត្តិន្តិ ។ ន ខោ មេ ភន្តេ គរុ អត្ថិ ចេត្ថ បព្វជិតោ បឋមំ វា-សូបគតោ ហោតិ សចេ សោ អនុជានាតិ វិហរថ ភន្តេ យថាសុខន្តិ ។

[១៤៩] តេន ខោ បន សមយេន បុក្កុសា-តិ នាម កុលបុត្តោ ភគវន្តំ ឧទ្ទិស្ស សទ្ធាយ អគារស្មា អនគារិយំ បព្វជិតោ ។ សោ តស្មឹ កុម្ភ-ការនិវេសនេ បឋមំ វាសូបគតោ ហោតិ ។ អថខោ ភគវា យេនាយស្មា បុក្កុសាតិ តេនុបសង្កមិ ឧប-សង្កមិត្វា អាយស្មន្តំ បុក្កុសាតឹ ឯតទវោច សចេ តេ ភិក្ខុ អគរុ វិហរាម និវេសនេ ឯករត្តិន្តិ ។

# ធាតុវិភង្គសូត្រ ទី ១០

[១៨៨] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់ស្តេចទៅកាន់ចារិកក្នុងដែនរបស់ពួកអ្នកមគធៈ បានដល់ទៅក្រុងរាជគ្រឹះ ចូលទៅរកស្មូនផ្ទាំងឈ្មោះភគ្គវៈ លុះចូលទៅដល់ហើយ ទើបត្រាស់នឹងស្មូនផ្ទាំងឈ្មោះភគ្គវៈ យ៉ាងនេះថា ម្នាលភគ្គវៈ បើអ្នកមិនមានសេចក្តីចង្អៀតចង្អល់ទេ តថាគតសូមនៅក្នុងផ្ទះ បានមួយរាត្រី ។ ស្មូនផ្ទាំងក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឥតមានសេចក្តីចង្អៀតចង្អល់អ្វីទេ ប៉ុន្តែមានអ្នកបួសចូលទៅនៅក្នុងផ្ទះនេះមុនរួចហើយ បពិត្រព្រះអង្គដ៏ចម្រើន បើអ្នកបួសនោះយល់ព្រម សូមព្រះអង្គគង់នៅតាមសេចក្តីសប្បាយចុះ ។

[១៨៩] សម័យនោះឯង កុលបុត្តឈ្មោះបុក្កុសាតិ ចេញចាកផ្ទះហើយចូលទៅកាន់ផ្នួសព្រោះសទ្ធា ចំពោះព្រះមានព្រះភាគ ។ បុក្កុ-សាតិកុលបុត្តនោះឯង ជាអ្នកចូលមកនៅមុន ក្នុងផ្ទះស្មូនផ្ទាំងនោះ ។ ព្រះមានព្រះភាគ ទ្រង់ចូលទៅរកបុក្កុសាតិមានអាយុ លុះចូលទៅដល់ហើយ ទើបត្រាស់នឹងបុក្កុសាតិមានអាយុថា ម្នាលភិក្ខុ បើអ្នកមិនមានសេចក្តីចង្អៀតចង្អល់ទេ តថាគត សូមនៅក្នុងផ្ទះបានមួយរាត្រី

វិភង្គវគ្គស្ស ធាតុវិភង្គសុត្តេ ភគវតោ កុម្ភការនិវេសនំ បវិសនា

ឧរុន្ទំ អាវុសោ កុម្ភការនិវេសនំ វិហរតាយស្មា យថាសុខន្តិ ។

[១៤០] អថខោ ភគវា កុម្ភការនិវេសនំ បវិសិត្វា ឯកមន្តំ តិណសន្ថរកំ បញ្ញាបេត្វា និសីទិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ។ អថខោ ភគវា ពហុទេវ រត្តឹ និសជ្ជាយ វីតិនាមេសិ ។ អាយស្មាបិ ខោ បុក្កុសាតិ ពហុទេវ រត្តឹ និសជ្ជាយ វីតិនាមេសិ ។ អថខោ ភគវតោ ឯតទហោសិ បាសាទិកំ នុ ខោ អយំ កុលបុត្តោ ឥរិយតិ យន្នូនាហំ បុច្ឆេយ្យន្តិ ។ អថខោ ភគវា អាយស្មន្តំ បុក្កុសាតឹ ឯតទវោច កំសិ ត្វំ ភិក្ខុ ឧទ្ទិស្ស បព្វជិតោ កោ វា តេ សត្ថា កស្ស វា ត្វំ ធម្មំ រោចេសីតិ ។

បុក្កុសាតិតបថា ម្នាលអាវុសោ នេះកុម្ភការនិវេសន៍ ឈ្មោះឱរុន្ធ[១] សូមលោកមានអាយុ នៅតាមសេចក្តីសប្បាយចុះ ។

[១៥០] ទើបព្រះមានព្រះភាគ ទ្រង់ចូលទៅកាន់កុម្ភការនិវេសន៍ ទ្រង់ក្រាលកម្រាលស្មៅក្នុងទីសមគួរ ហើយគង់ផ្គត់ព្រះភ្នែន តាំងព្រះកាយត្រង់ ផ្ចង់ព្រះសតិឲ្យមានមុខឆ្ពោះទៅរកកម្មដ្ឋាន ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់គង់ដល់យប់ជ្រៅ ។ ឯបុក្កុសាតិមានអាយុ ក៏អង្គុយនៅដល់យប់ជ្រៅដែរ ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រិះរិះយ៉ាងនេះថា កុលបុត្តនេះ ប្រតិបត្តិវត្តគួរជ្រះថ្លាដែរឬហ្ន៎ បើដូច្នោះ គួរតែតថាគតសួរមើល ។ ទើបព្រះមានព្រះភាគ ទ្រង់សួរបុក្កុសាតិមានអាយុ យ៉ាងនេះថា ម្នាលភិក្ខុ អ្នកបួសចំពោះលោកណា លោកណាជាគ្រូអ្នក មួយទៀត អ្នកពេញចិត្តនឹងធម៌របស់លោកណា ។

១ ផ្ទះរបស់ស្មូនឆ្នាំង ។

[១៤១] អត្ថាវុសោ សមណោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ តំ ខោ បន ភគវន្តំ គោតមំ ឯវំកល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ តាហំ ភគវន្តំ ឧទ្ទិស្ស បព្វជិតោ សោ ច មេ ភគវា សត្ថា តស្សាហំ ភគវតោ ធម្មំ រោចេមីតិ ។ កហំ បន ភិក្ខុ ឯតរហិ សោ ភគវា វិហរតិ អរហំ សម្មាសម្ពុទ្ធោតិ ។ អត្ថាវុសោ ឧត្តរេសុ ជនបទេសុ សាវត្ថី នាម នគរំ តត្ថ សោ ភគវា ឯតរហិ វិហរតិ អរហំ សម្មាសម្ពុទ្ធោតិ ។ ទិដ្ឋបុព្វោ បន តេ ភិក្ខុ សោ ភគវា ទិស្វា ច បន

[១៩១] បុក្កុសាតិតបថា ម្នាលអាវុសោ ព្រះសមណគោតមជាសក្យបុត្រ ចេញចាកសក្យត្រកូលទៅបួស កិត្តិសព្ទសរសើរព្រះគោតមដ៏ចម្រើននោះ ពីរោះល្បីឮខ្ចរខ្ចាយទៅយ៉ាងនេះថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ឆ្ងាយចាកកិលេស ត្រាស់ដឹងដោយព្រះអង្គឯងដោយប្រពៃ ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ ទ្រង់មានព្រះដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណ ជាអ្នកទូន្មាននូវបុរសដែលគួរទូន្មាន ព្រះអង្គជាសាស្តាចារ្យនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ព្រះអង្គលែងត្រឡប់មកកាន់ភពថ្មីទៀត ដោយហេតុនេះ ៗ ខ្ញុំបួសចំពោះព្រះមានព្រះភាគអង្គនោះ ព្រះមានព្រះភាគអង្គនោះឯង ជាគ្រូរបស់ខ្ញុំ ខ្ញុំពេញចិត្តនឹងធម៌របស់ព្រះមានព្រះភាគអង្គនោះ ។ ម្នាលភិក្ខុ ចុះឥឡូវនេះ ព្រះមានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ លោកគង់នៅក្នុងទីណា ។ ម្នាលអាវុសោ ឥឡូវនេះ ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ព្រះអង្គគង់នៅក្នុងក្រុងសាវត្ថី ដែលមាននៅក្នុងជនបទប៉ែកខាងជើង ។ ម្នាលភិក្ខុ ចុះព្រះមានព្រះភាគអង្គនោះ អ្នកដែលបានឃើញឬទេ ប្រសិនបើឃើញ

ជានេយ្យាសីតិ ។ ន ខោ មេ អាវុសោ ទិដ្ឋបុព្វោ សោ ភគវា ទិស្វាហំ(១) ន ជានេយ្យន្តិ ។

[១៨២] អថខោ ភគវតោ ឯតទហោសិ មមំ(២) ខ្វាយំ កុលបុត្តោ ឧទ្ទិស្ស បព្វជិតោ យន្នូនស្សាហំ ធម្មំ ទេសេយ្យន្តិ ។ អថខោ ភគវា អាយស្មន្តំ បុក្កុសាតឹ អាមន្តេសិ ធម្មំ តេ(៣) ភិក្ខុ ទេសិស្សាមិ តំ សុណាថ(៤) សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវមាវុសោតិ ខោ អាយស្មា បុក្កុសាតិ ភគវតោ បច្ចស្សោសិ ។

[១៨៣] ភគវា ឯតទវោច ឆធាតុរោ(៥) អយំ ភិក្ខុ បុរិសោ ឆផស្សាយតនោ អដ្ឋារសមនោបវិចារោ

---

១ ឱ. ម. ទិស្វា ចាហំ ។ ២ ឱ. មំ ។ ម. មមញ្ច ។ ៣ ឱ. ធម្មន្តេ ។ ៤ ឱ. ម. សុណាហិ ។ ៥ ម. ឆធាតុកោ ។

អាចស្គាល់ឬទេ ។ ម្នាលអាវុសោ ព្រះមានព្រះភាគអង្គនោះ ខ្ញុំមិនដែលបានឃើញទេ ទុកជាខ្ញុំឃើញ ក៏គង់មិនស្គាល់ដែរ ។

[១៩២] ទើបព្រះមានព្រះភាគ ទ្រង់ត្រិះរិះយ៉ាងនេះថា កុលបុត្តនេះបួសចំពោះតថាគត បើដូច្នោះ គួរតថាគតសំដែងធម៌ដល់កុលបុត្តនេះ ។ ទើបព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលនឹងបុក្កុសាតិមានអាយុថា ម្នាលភិក្ខុ យើងនឹងសំដែងធម៌ដល់អ្នក ចូរអ្នកយកចិត្តទុកដាក់ស្តាប់ធម៌នោះដោយប្រពៃចុះ យើងនឹងសំដែង ។ បុក្កុសាតិមានអាយុ ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា អើ អាវុសោ ។

[១៩៣] ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុ បុរសនេះ មានធាតុ ៦ មានផស្សាយតនៈ ៦[១] មានមនោបវិចារៈ[២] ១៨

១ ហេតុនៃផស្សៈ ។ ២ ការពិចារណាដោយចិត្ត ។

ចតុរាធិដ្ឋានោ យត្ថ ឋិតំ មញ្ញស្សវា នប្បវត្តន្តិ មញ្ញស្សវេ ខោ បន នប្បវត្តមានេ មុនិ សន្តោតិ វុច្ចតិ បញ្ញំ នប្បមជ្ជេយ្យ សច្ចមនុរក្ខេយ្យ ចាគមនុព្រូហេយ្យ សន្តិមេវ សោ សិក្ខេយ្យាតិ អយមុទ្ទេសោ ឆធាតុវិភង្គស្ស ។

[១៩៤] ឆធាតុរោ អយំ ភិក្ខុ បុរិសោតិ ឥតិ ខោ បនេតំ វុត្តំ ។ កិញ្ចេតំ បដិច្ច វុត្តំ ។ ឆយិមា ភិក្ខុ ធាតុយោ[១] បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ អាកាសធាតុ វិញ្ញាណធាតុ ។ ឆធាតុរោ អយំ ភិក្ខុ បុរិសោតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

១ ឱ. ឆយិមា ភិក្ខុ ធាតុយោតិ ន ទិស្សតិ ។

មានអធិដ្ឋាន[១] ៤ សេចក្តីសំគាល់និងសេចក្តីរិលរល់ តែងមិនប្រព្រឹត្តទៅកាន់បុគ្គលដែលឋិតនៅ ក្នុងអធិដ្ឋានទាំងឡាយណា កាលបើសេចក្តីសំគាល់និងសេចក្តីរិលរល់មិនប្រព្រឹត្តទៅហើយ បុគ្គលនោះយើងហៅថា អ្នកប្រាជ្ញមានចិត្តស្ងប់រម្ងាប់ បុគ្គលមិនគួរបណ្តែតបណ្តោយបញ្ញា[២] គួររក្សារឿយ ៗ នូវសច្ចៈ[៣] គួរចម្រើនរឿយ ៗ នូវចាគៈ[៤] គួរសិក្សានូវសន្តិ[៥] នេះ ជាឧទ្ទេសនៃឆធាតុវិភង្គ ។

[១៥៤] ពាក្យថា ម្នាលភិក្ខុ បុរសនេះមានធាតុ ៦ ដូច្នេះនុ៎ះ យើងបានពោលហើយ ។ ពាក្យនុ៎ះយើងពោលហើយ ព្រោះអាស្រ័យសេចក្តីដូចម្តេច ។ ម្នាលភិក្ខុ ឯធាតុនេះមាន ៦ ប្រការ គឺបឋវីធាតុ (ធាតុដី) ១ អាបោធាតុ (ធាតុទឹក) ១ តេជោធាតុ (ធាតុភ្លើង) ១ វាយោធាតុ (ធាតុខ្យល់) ១ អាកាសធាតុ (ធាតុអាកាស) ១ វិញ្ញាណធាតុ (ធាតុវិញ្ញាណ ឬចិត្ត) ១ ។ ពាក្យណា ដែលយើងបានពោលហើយថា ម្នាលភិក្ខុ បុរសនេះមានធាតុ ៦ ដូច្នេះ ពាក្យនុ៎ះ យើងបានពោលហើយ ព្រោះអាស្រ័យសេចក្តីនេះឯង ។

---

១ ធម្មជាតិជាទីតាំងជាទីអាស្រ័យ ។ ២ សមាធិបញ្ញា និងវិបស្សនាបញ្ញា ។ ៣ វចីសច្ចៈ ។ ៤ ការលះបង់កិលេស ។ ៥ ការរម្ងាប់កិលេស ។

[១៨៥] ឆឡាយតនោ អយំ ភិក្ខុ បុរិសោតិ ឥតិ ខោ បនេតំ វុត្តំ ។ កិញ្ចេតំ បដិច្ច វុត្តំ ។ ចក្ខាយតនំ(១) សោតាយតនំ ឃានាយតនំ ជិវ្ហាយតនំ កាយាយតនំ មនាយតនំ ។ ឆឡាយតនោ អយំ ភិក្ខុ បុរិសោតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

[១៨៦] អដ្ឋារសមនោបវិចារោ អយំ ភិក្ខុ បុរិសោតិ ឥតិ ខោ បនេតំ វុត្តំ ។ កិញ្ចេតំ បដិច្ច វុត្តំ ។ ចក្ខុនា រូបំ ទិស្វា សោមនស្សដ្ឋានិយំ រូបំ ឧបវិចរតិ ទោមនស្សដ្ឋានិយំ រូបំ ឧបវិចរតិ ឧបេក្ខដ្ឋានិយំ រូបំ ឧបវិចរតិ សោតេន សទ្ទំ សុត្វា ។ បេ ។ ឃានេន គន្ធំ ឃាយិត្វា... ជិវ្ហាយ រសំ សាយិត្វា... កាយេន ផោដ្ឋព្វំ ផុសិត្វា...

១ ឱ. ម. ចក្ខុសម្ផស្សាយតនំ ។

[១៥៥] ពាក្យថា ម្នាលភិក្ខុ បុរសនេះមានផស្សាយតនៈ ៦ ដូច្នេះនុ៎ះ យើងបានពោលហើយ ។ ពាក្យនុ៎ះ យើងពោលហើយ ព្រោះអាស្រ័យសេចក្តីដូចម្តេច ។ ចក្ខុ ជាផស្សាយតនៈ ១ សោតៈ ជាផស្សាយតនៈ ១ ឃានៈ ជាផស្សាយតនៈ ១ ជិវ្ហា ជាផស្សាយតនៈ ១ កាយ ជាផស្សាយតនៈ ១ មនោ ជាផស្សាយតនៈ ១ ។ ពាក្យណា ដែលយើងបានពោលហើយថា ម្នាលភិក្ខុ បុរសនេះ មានផស្សាយតនៈ ៦ ដូច្នេះ ពាក្យនុ៎ះ យើងបានពោលហើយ ព្រោះអាស្រ័យសេចក្តីនេះឯង ។

[១៥៦] ពាក្យថា ម្នាលភិក្ខុ បុរសនេះមានមនោបវិចារៈ ១៨ ដូច្នេះនុ៎ះ យើងបានពោលហើយ ។ ពាក្យនុ៎ះ យើងពោលហើយ ព្រោះអាស្រ័យសេចក្តីដូចម្តេច ។ បុគ្គល បានឃើញរូបដោយភ្នែក ហើយពិចារណារូបដែលជាទីតាំង[១] នៃសោមនស្សវេទនា ពិចារណារូបដែលជាទីតាំងនៃទោមនស្សវេទនា ពិចារណារូបដែលជាទីតាំងនៃឧបេក្ខាវេទនា ស្តាប់សំឡេងដោយត្រចៀក ។ បេ ។ ហិតក្លិនដោយច្រមុះ... ទទួលរសដោយអណ្តាត... ពាល់ត្រូវផោដ្ឋព្វៈដោយកាយ...

១ ជាហេតុឲ្យកើតសោមនស្សវេទនា ។

មនសា ធម្មំ វិញ្ញាយ សោមនស្សដ្ឋានីយំ ធម្មំ ឧបវិចរតិ ទោមនស្សដ្ឋានីយំ ធម្មំ ឧបវិចរតិ ឧបេក្ខដ្ឋានីយំ ធម្មំ ឧបវិចរតិ ឥតិ ឆ សោមនស្សុបវិចារា ឆ ទោមនស្សុបវិចារា ឆ ឧបេក្ខុបវិចារា ។ អដ្ឋារសមនោបវិចារោ អយំ ភិក្ខុ បុរិសោតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

[១៦៧] ចតុរាធិដ្ឋានោ អយំ ភិក្ខុ បុរិសោតិ ឥតិ ខោ បនេតំ វុត្តំ ។ កិញ្ចេតំ បដិច្ច វុត្តំ ។ បញ្ញាធិដ្ឋានោ សច្ចាធិដ្ឋានោ ចាគាធិដ្ឋានោ ឧបសមាធិដ្ឋានោ ។ ចតុរាធិដ្ឋានោ អយំ ភិក្ខុ បុរិសោតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

ដឹងច្បាស់នូវធម៌ដោយចិត្ត ហើយពិចារណាធម៌ដែលជាទីតាំងនៃសោមនស្សវេទនា ពិចារណាធម៌ដែលជាទីតាំងនៃទោមនស្សវេទនា ពិចារណាធម៌ដែលជាទីតាំងនៃឧបេក្ខាវេទនា ត្រូវជាសោមនស្សុបវិចារៈ ៦ ទោមនស្សុបវិចារៈ ៦ ឧបេក្ខុបវិចារៈ ៦ ដោយប្រការដូច្នេះ ។ ពាក្យណា ដែលយើងបានពោលហើយថា ម្នាលភិក្ខុ បុរសនេះ មានមនោបវិចារៈ ១៨ ដូច្នេះ ពាក្យនុ៎ះ យើងបានពោលហើយ ព្រោះអាស្រ័យសេចក្តីនេះឯង ។

[១៩៧] ពាក្យថា ម្នាលភិក្ខុ បុរសនេះ មានអធិដ្ឋាន[១] ៤ ដូច្នេះនុ៎ះ យើងបានពោលហើយ ។ ពាក្យនុ៎ះ យើងពោលហើយព្រោះអាស្រ័យសេចក្តីដូចម្តេច ។ បុរសមាន អធិដ្ឋានក្នុងសញ្ញា ១ មានអធិដ្ឋានក្នុងសច្ចៈ ១ មានអធិដ្ឋានក្នុងចាគៈ ១ មានអធិដ្ឋានក្នុងឧបសមៈ[២] ១ ។ ពាក្យណា ដែលយើងបានពោលហើយថា ម្នាលភិក្ខុ បុរសនេះ មានអធិដ្ឋាន ៤ ដូច្នេះ ពាក្យនុ៎ះ យើងពោលហើយ ព្រោះអាស្រ័យសេចក្តីនេះឯង ។

---

១ ការតម្កល់ចិត្តទុក ។ ២ ការរម្ងាប់កិលេស ដូចគ្នានឹង សន្តិ ដែលបានពោលរួចហើយខាងដើម ។

១៧៧



[១៩៨] បញ្ញំ នប្បមជ្ជេយ្យ សច្ចមនុរក្ខេយ្យ ចាគមនុព្រូហេយ្យ សន្តិមេវ សោ សិក្ខេយ្យាតិ ឥតិ ខោ បនេតំ វុត្តំ ។ កិញ្ចេតំ បដិច្ច វុត្តំ ។ កថញ្ច ភិក្ខុ បញ្ញំ នប្បមជ្ជតិ ។ ឆយិមា ភិក្ខុ[១] ធាតុយោ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ អាកាសធាតុ វិញ្ញាណធាតុ ។

[១៩៩] កតមា ច ភិក្ខុ បឋវីធាតុ ។ បឋវីធាតុ សិយា អជ្ឈត្តិកា សិយា ពាហិរា ។ កតមា ច ភិក្ខុ អជ្ឈត្តិកា បឋវីធាតុ ។ យំ អជ្ឈត្តំ បច្ចត្តំ កក្ខលំ ខរិគតំ ឧបាទិន្នំ សេយ្យថីទំ កេសា លោមា នខា ទន្តា តចោ មំសំ នហារូ អដ្ឋី អដ្ឋិមិញ្ជំ វក្កំ ហទយំ យកនំ កិលោមកំ បិហកំ បប្ផាសំ អន្តំ អន្តគុណំ ឧទរិយំ ករីសំ យំ វា បនញ្ញម្បិ កិញ្ចិ អជ្ឈត្តំ បច្ចត្តំ កក្ខលំ ខរិគតំ ឧបាទិន្នំ អយំ វុច្ចតិ ភិក្ខុ អជ្ឈត្តិកា បឋវីធាតុ ។

១ ឱ. ភិក្ខូតិ ន ទិស្សតិ ។

[១៥៨] ពាក្យថា បុគ្គលនោះ មិនគួរបណ្ដែតបណ្ដោយបញ្ញា គួររក្សារឿយ ៗ នូវសច្ចៈ គួរចម្រើនរឿយ ៗ នូវចាគៈ គួរសិក្សានូវសន្តិ ដូច្នេះនុ៎ះ យើងបានពោលហើយ ។ ពាក្យនុ៎ះ យើងពោលហើយ ព្រោះអាស្រ័យសេចក្ដីដូចម្ដេច ។ ម្នាលភិក្ខុ ចុះបុគ្គល មិនបណ្ដែតបណ្ដោយបញ្ញា តើដូចម្ដេច ។ ម្នាលភិក្ខុ ធាតុនេះ មាន ៦ ប្រការ គឺបឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ អាកាសធាតុ ១ វិញ្ញាណធាតុ ។

[១៥៩] ម្នាលភិក្ខុ ចុះបឋវីធាតុ តើដូចម្ដេច ។ ឯបឋវីធាតុ ខាងក្នុងក៏មាន ខាងក្រៅក៏មាន ។ ម្នាលភិក្ខុ ចុះបឋវីធាតុជាខាងក្នុង តើដូចម្ដេច ។ ធម្មជាតណា ដែលកើតក្នុងខ្លួន អាស្រ័យនូវខ្លួន ជារបស់កក ជារបស់រឹង មានវិញ្ញាណចូលទៅអាស្រ័យនៅ គឺសក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង ទាច បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ឬរបស់ដទៃណាមួយ ជាធម្មជាតកើតក្នុងខ្លួន អាស្រ័យនូវខ្លួន ជារបស់កក ជារបស់រឹង មានវិញ្ញាណចូលទៅអាស្រ័យនៅដែរ ម្នាលភិក្ខុ នេះ យើងហៅថាបឋវីធាតុខាងក្នុង ។

យា ចេវ ខោ បន អជ្ឈត្តិកា បឋវីធាតុ យា ច ពាហិរា បឋវីធាតុ បឋវីធាតុរេវេសា ។ តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា បឋវីធាតុយា និព្វិន្ទតិ បឋវីធាតុយា ចិត្តំ វិរាជេតិ ។

[១៦០] កតមា ច ភិក្ខុ អាបោធាតុ ។ អាបោធាតុ សិយា អជ្ឈត្តិកា សិយា ពាហិរា ។ កតមា ច ភិក្ខុ អជ្ឈត្តិកា អាបោធាតុ ។ យំ អជ្ឈត្តំ បច្ចត្តំ អាបោ អាបោគតំ ឧបាទិន្នំ សេយ្យថីទំ បិត្តំ សេម្ហំ បុព្វោ លោហិតំ សេទោ មេទោ អស្សុ វសា ខេឡោ សិង្ឃាណិកា លសិកា មុត្តំ យំ វា បនញ្ញម្បិ កិញ្ចិ អជ្ឈត្តំ បច្ចត្តំ អាបោ អាបោគតំ ឧបាទិន្នំ អយំ វុច្ចតិ ភិក្ខុ អជ្ឈត្តិកា អាបោធាតុ ។ យា ចេវ ខោ បន អជ្ឈត្តិកា អាបោធាតុ យា ច ពាហិរា អាបោធាតុ

មួយទៀត បឋវីធាតុខាងក្នុងណាក្តី បឋវីធាតុខាងក្រៅណាក្តី ទាំងពីរនេះ ជាបឋវីធាតុដូចគ្នា ។ បុគ្គលគួរឃើញតាមពិតនូវបឋវីធាតុនោះ ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនជារបស់អាត្មាអញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អាត្មាអញ ។ លុះឃើញតាមពិតនូវបឋវីធាតុនោះដោយបញ្ញាដ៏ប្រពៃយ៉ាងនេះហើយ រមែងនឿយណាយក្នុងបឋវីធាតុ រមែងញ៉ាំងចិត្តឲ្យគ្រាកចេញអំពីបឋវីធាតុ ។

[១៦០] ម្នាលភិក្ខុ ចុះអាបោធាតុ តើដូចម្តេច ។ អាបោធាតុ ខាងក្នុងក៏មាន ខាងក្រៅក៏មាន ។ ម្នាលភិក្ខុ អាបោធាតុខាងក្នុង តើដូចម្តេច ។ ធម្មជាតណា ដែលកើតក្នុងខ្លួន អាស្រ័យនូវខ្លួន ជារបស់ជ្រាយ ជារបស់រលាយ មានវិញ្ញាណចូលទៅអាស្រ័យនៅ គឺប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសំបោរ ទឹករំអិល មូត្រ ឬរបស់ដទៃណាមួយ ដែលកើតក្នុងខ្លួន អាស្រ័យនូវខ្លួន ជារបស់ជ្រាយ ជារបស់រលាយ មានវិញ្ញាណចូលទៅអាស្រ័យនៅ ម្នាលភិក្ខុ នេះ យើងហៅថាអាបោធាតុខាងក្នុង ។ អាបោធាតុខាងក្នុងណាក្តី អាបោធាតុខាងក្រៅណាក្តី

អាបោធាតុរេវេសា ។ តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា អាបោធាតុយា និព្វិន្ទតិ អាបោធាតុយា ចិត្តំ វិរាជេតិ ។

[១៦១] កតមា ច ភិក្ខុ តេជោធាតុ ។ តេជោធាតុ សិយា អជ្ឈត្តិកា សិយា ពាហិរា ។ កតមា ច ភិក្ខុ អជ្ឈត្តិកា តេជោធាតុ ។ យំ អជ្ឈត្តំ បច្ចត្តំ តេជោ តេជោគតំ ឧបាទិន្នំ សេយ្យថីទំ យេន ច សន្តប្បតិ យេន ច ជីរិយតិ យេន ច បរិឌយ្ហតិ យេន ច អសិតបីតខាយិតសាយិតំ សម្មាបរិណាមំ គច្ឆតិ យំ វា បនញ្ញម្បិ កិញ្ចិ អជ្ឈត្តំ បច្ចត្តំ តេជោ តេជោគតំ ឧបាទិន្នំ អយំ វុច្ចតិ ភិក្ខុ អជ្ឈត្តិកា តេជោធាតុ ។ យា ចេវ ខោ បន អជ្ឈត្តិកា តេជោធាតុ យា ច ពាហិរា តេជោធាតុ តេជោធាតុរេវេសា ។

ទាំងពីរនេះ ជាអាបោធាតុដូចគ្នា ។ បុគ្គលគួរឃើញតាមពិតនូវអាបោ-ធាតុនោះដោយបញ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ លុះឃើញតាមពិតនូវអាបោធាតុនោះដោយបញ្ញាដ៏ប្រពៃយ៉ាងនេះហើយ រមែងនឿយណាយក្នុងអាបោធាតុ រមែងញុំាងចិត្តឲ្យគ្រាកចេញអំពីអាបោធាតុ ។

[១៦១] ម្នាលភិក្ខុ ចុះតេជោធាតុ តើដូចម្តេច ។ តេជោធាតុខាងក្នុងក៏មាន ខាងក្រៅក៏មាន ។ ម្នាលភិក្ខុ ចុះតេជោធាតុខាងក្នុង តើដូចម្តេច ។ ធម្មជាតណា ដែលកើតក្នុងខ្លួន អាស្រ័យនូវខ្លួន ជារបស់មានចំហាយ ជារបស់មានកម្តៅ មានវិញ្ញាណចូលទៅអាស្រ័យនៅ គឺភ្លើងធាតុដែលធ្វើកាយឲ្យក្តៅស្រួល ១ ភ្លើងធាតុដែលធ្វើកាយឲ្យទ្រុឌទ្រោមឬគ្រាំគ្រាទៅ ១ ភ្លើងធាតុដែលធ្វើកាយឲ្យក្តៅពេលពាល ១ ភ្លើងធាតុដែលធ្វើអាហារដែលបុគ្គលស៊ី ផឹក ទំពាស៊ី ក្រេបជញ្ជាប់ឲ្យដល់នូវការរលាយទៅដោយស្រួល ១ ឬធម្មជាតដទៃណាមួយដែលកើតក្នុងខ្លួន អាស្រ័យនូវខ្លួន ជារបស់មានចំហាយ ជារបស់មានកម្តៅ មានវិញ្ញាណចូលទៅអាស្រ័យនៅ ម្នាលភិក្ខុ នេះ យើងហៅថាតេជោធាតុខាងក្នុង ។ មួយទៀត តេជោធាតុខាងក្នុងណាក្តី តេជោធាតុខាងក្រៅណាក្តី ទាំងពីរនេះហៅថាតេជោធាតុដូចគ្នា ។

តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា តេជោធាតុយា និព្វិន្ទតិ តេជោធាតុយា ចិត្តំ វិរាជេតិ ។

[១៦២] កតមា ច ភិក្ខុ វាយោធាតុ ។ វាយោធាតុ សិយា អជ្ឈត្តិកា សិយា ពាហិរា ។ កតមា ច ភិក្ខុ អជ្ឈត្តិកា វាយោធាតុ ។ យំ អជ្ឈត្តំ បច្ចត្តំ វាយោ វាយោគតំ ឧបាទិន្នំ សេយ្យថីទំ ឧទ្ធង្គមា វាតា អធោគមា វាតា កុច្ឆិសយា វាតា កោដ្ឋសយា វាតា អង្គមង្គានុសារិនោ វាតា អស្សាសោ បស្សាសោ យំ វា បនញ្ញម្បិ កិញ្ចិ អជ្ឈត្តំ បច្ចត្តំ វាយោ វាយោគតំ ឧបាទិន្នំ

បុគ្គលគួរឃើញតាមពិតនូវតេជោធាតុនោះ ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះ ថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ លុះឃើញតាមពិតនូវតេជោធាតុនោះ ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះហើយ រមែងនឿយណាយក្នុងតេជោធាតុ រមែងញុំាងចិត្តឲ្យគ្រាកចេញអំពីតេជោធាតុ ។

[១៦២] ម្នាលភិក្ខុ ចុះវាយោធាតុ តើដូចម្ដេច ។ វាយោធាតុខាងក្នុងក៏មាន ខាងក្រៅក៏មាន ។ ម្នាលភិក្ខុ ចុះវាយោធាតុខាងក្នុងតើដូចម្ដេច ។ ធម្មជាតណា ដែលកើតក្នុងខ្លួន អាស្រ័យនូវខ្លួន ជារបស់បក់ទៅមក ជារបស់ផ្សព្វផ្សាយទៅមក មានវិញ្ញាណចូលទៅអាស្រ័យនៅ គឺខ្យល់ដែលបក់ឡើងលើ ខ្យល់ដែលបក់ចុះក្រោម ខ្យល់ដែលខាំងនៅក្នុងផ្ទៃ ខ្យល់ដែលខាំងនៅក្នុងក្រពះ ខ្យល់ដែលរត់តាមអវយវៈតូចធំ ខ្យល់ដកដង្ហើមចេញ ខ្យល់ដកដង្ហើមចូល ឬធម្មជាតដទៃណាមួយ ដែលកើតក្នុងខ្លួន អាស្រ័យនូវខ្លួន ជារបស់បក់ទៅមក ជារបស់ផ្សព្វផ្សាយទៅមក មានវិញ្ញាណចូលទៅអាស្រ័យនៅ

អយំ វុច្ចតិ ភិក្ខុ អជ្ឈត្តិកា វាយោធាតុ ។ យា ចេវ ខោ បន អជ្ឈត្តិកា វាយោធាតុ យា ច ពា-ហិរា វាយោធាតុ វាយោធាតុរេវេសា ។ តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ ឯវមេតំ យថា-ភូតំ សម្មប្បញ្ញាយ ទិស្វា វាយោធាតុយា និព្វិន្ទតិ វាយោធាតុយា ចិត្តំ វិរាជេតិ ។

[១៦៣] កតមា ច ភិក្ខុ អាកាសធាតុ ។ អាកាសធាតុ សិយា អជ្ឈត្តិកា សិយា ពាហិរា ។ កតមា ច ភិក្ខុ អជ្ឈត្តិកា អាកាសធាតុ ។ យំ អជ្ឈត្តំ បច្ចត្តំ អាកាសំ អាកាសគតំ ឧបាទិន្នំ សេយ្យថីទំ កណ្ណច្ឆិទ្ទំ នាសច្ឆិទ្ទំ មុខទ្វារំ យេន ច អសិតបីតខាយិតសាយិតំ អជ្ឈោហរតិ យត្ថ ច អសិតបីតខាយិតសាយិតំ សន្តិដ្ឋតិ យេន ច អ-សិតបីតខាយិតសាយិតំ អធោភាគា និក្ខមតិ យំ វា បនញ្ញម្បិ កិញ្ចិ អជ្ឈត្តំ បច្ចត្តំ អាកាសំ

ម្នាលភិក្ខុ នេះហៅថា វាយោធាតុខាងក្នុង ។ មួយទៀត វាយោធាតុខាងក្នុងណាក្តី វាយោធាតុខាងក្រៅណាក្តី ទាំងពីរនេះ ហៅថា វាយោធាតុដូចគ្នា ។ បុគ្គលគួរឃើញតាមពិតនូវវាយោធាតុនោះ ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ លុះឃើញតាមពិតនូវវាយោធាតុនោះ ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះហើយ រមែងនឿយណាយក្នុងវាយោធាតុ រមែងញ៉ាំងចិត្តឲ្យគ្រាកចេញអំពីវាយោធាតុ ។

[១៦៣] ម្នាលភិក្ខុ ចុះអាកាសធាតុ តើដូចម្តេច ។ អាកាសធាតុខាងក្នុងក៏មាន ខាងក្រៅក៏មាន ។ ម្នាលភិក្ខុ ចុះអាកាសធាតុខាងក្នុង តើដូចម្តេច ។ ធម្មជាតណា ដែលកើតក្នុងខ្លួន អាស្រ័យនូវខ្លួន ជារបស់សូន្យ ជារបស់ទទេ មានវិញ្ញាណចូលទៅអាស្រ័យនៅ គឺរន្ធត្រចៀក រន្ធច្រមុះ ទ្វារមាត់ និងប្រទេសសម្រាប់លេបអាហារដែលស៊ី ផឹក ទំពា ក្រេប ជញ្ជាប់ និងកន្លែងជាទីឋិតនៃអាហារដែលស៊ី ផឹក ទំពា ក្រេប ជញ្ជាប់ និងប្រទេសជាទីហូរចេញតាមចំណែកខាងក្រោមនៃអាហារដែលស៊ី ផឹក ទំពា ក្រេប ជញ្ជាប់ ឬធម្មជាតដទៃណាមួយ ដែលកើតក្នុងខ្លួន អាស្រ័យនូវខ្លួន ជារបស់សូន្យ

អាកាសគតំ ឧបាទិន្នំ អយំ វុច្ចតិ ភិក្ខុ អជ្ឈត្តិកា អាកាសធាតុ ។ យា ចេវ ខោ បន អជ្ឈត្តិកា អាកាសធាតុ យា ច ពាហិរា អាកាសធាតុ អាកាសធាតុរេវេសា ។ តំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទិស្វា អាកាសធាតុយា និព្វិន្ទតិ អាកាសធាតុយា ចិត្តំ វិរាជេតិ ។ អថាបរំ វិញ្ញាណំយេវ អវសិស្សតិ បរិសុទ្ធំ បរិយោទាតំ តេន វិញ្ញាណេន កិញ្ចិ ជានាតិ សុខន្តិបិ វិជានាតិ ទុក្ខន្តិបិ វិជានាតិ អទុក្ខមសុខន្តិបិ វិជានាតិ ។

ជារបស់ទទេ មានវិញ្ញាណចូលទៅអាស្រ័យនៅ ម្នាលភិក្ខុ នេះហៅថា អាកាសធាតុខាងក្នុង ។ មួយទៀត អាកាសធាតុខាងក្នុងណាក្តី អាកាសធាតុខាងក្រៅណាក្តី ទាំងពីរនេះហៅថា អាកាសធាតុដូចគ្នា ។ បុគ្គល គួរឃើញតាមពិតនូវអាកាសធាតុនោះ ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ លុះឃើញតាមពិតនូវអាកាសធាតុនោះ ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះហើយ រមែងនឿយណាយក្នុងអាកាសធាតុ រមែងញ៉ាំងចិត្តឲ្យគ្រាកចេញអំពីអាកាសធាតុ ។ ចំណែកខាងក្រោយ នៅសល់តែវិញ្ញាណដ៏បរិសុទ្ធ ផូរផង់ បុគ្គលតែងដឹងអ្វីមួយ គឺដឹងថាសុខខ្លះ ដឹងថាទុក្ខខ្លះ ដឹងថាមិនមែនទុក្ខមិនមែនសុខខ្លះ ដោយវិញ្ញាណនោះឯង ។

វិភង្គវគ្គស្ស ធាតុវិភង្គសុត្តេ វេទនា

[១៦៤] សុខវេទនីយំ ភិក្ខុ ផស្សំ បដិច្ច ឧប្ប-ជ្ជតិ សុខា វេទនា ។ សោ សុខំ វេទនំ វេទិយមានោ សុខំ វេទនំ វេទិយាមីតិ បជានាតិ តស្សេវ សុខវេទនី-យស្ស ផស្សស្ស និរោធា យំ តជ្ជំ វេទយិតំ សុខវេទ-នីយំ ផស្សំ បដិច្ច ឧប្បន្នា សុខា វេទនា សា និរុជ្ឈ-តិ សា វូបសម្មតីតិ បជានាតិ ។ ទុក្ខវេទនីយំ ភិក្ខុ ផស្សំ បដិច្ច ឧប្បជ្ជតិ ទុក្ខា វេទនា ។ សោ ទុក្ខំ វេទនំ វេទិយមានោ ទុក្ខំ វេទនំ វេទិយាមីតិ បជានាតិ តស្សេវ ទុក្ខវេទនីយស្ស ផស្សស្ស និរោធា យំ តជ្ជំ វេទយិតំ ទុក្ខវេទនីយំ ផស្សំ បដិច្ច ឧប្បន្នា ទុក្ខា វេទនា សា និរុជ្ឈតិ សា វូបសម្មតីតិ បជានាតិ ។ អទុក្ខមសុខវេទនីយំ ភិក្ខុ ផស្សំ បដិច្ច ឧប្បជ្ជតិ អទុក្ខមសុខា វេទនា ។

[១៦៤] ម្នាលភិក្ខុ សុខវេទនាដែលកើតឡើង ព្រោះអាស្រ័យផស្សៈជាហេតុនៃសុខវេទនា ។ បុគ្គលនោះ កាលដែលទទួលនូវសុខវេទនា រមែងដឹងច្បាស់ថា អាត្មាអញទទួលនូវសុខវេទនា រមែងដឹងច្បាស់ថា វេទនាណា ដែលកើតអំពីផស្សៈនោះ គឺសុខវេទនាដែលកើតឡើង ព្រោះអាស្រ័យនូវផស្សៈ ដែលជាហេតុនៃសុខវេទនា វេទនានោះក៏រលត់ទៅ វេទនានោះក៏ស្ងប់រម្ងាប់ ព្រោះការរលត់នៃផស្សៈដែលជាហេតុនៃសុខវេទនានោះឯង ។ ម្នាលភិក្ខុ ទុក្ខវេទនាតែងកើតឡើង ព្រោះអាស្រ័យផស្សៈជាហេតុនៃទុក្ខវេទនា ។ បុគ្គលនោះ កាលទទួលនូវទុក្ខវេទនា រមែងដឹងច្បាស់ថា អាត្មាអញទទួលទុក្ខវេទនា រមែងដឹងច្បាស់ថា វេទនាណា ដែលកើតអំពីផស្សៈនោះ គឺទុក្ខវេទនាដែលកើតឡើង ព្រោះអាស្រ័យនូវផស្សៈដែលជាហេតុនៃទុក្ខ-វេទនា វេទនានោះក៏រលត់ទៅ វេទនានោះក៏ស្ងប់រម្ងាប់ ព្រោះការរលត់នៃផស្សៈដែលជាហេតុនៃទុក្ខវេទនានោះឯង ។ ម្នាលភិក្ខុ អទុក្ខមសុខវេទនាតែងកើតឡើង ព្រោះអាស្រ័យផស្សៈជាហេតុនៃអទុក្ខមសុខវេទនា ។

សោ អទុក្ខមសុខំ វេទនំ វេទិយមានោ អទុក្ខម-សុខំ វេទនំ វេទិយាមីតិ បជានាតិ តស្សេវ អទុក្ខ-មសុខវេទនីយស្ស ផស្សស្ស និរោធា យំ តជ្ជំ វេទយិតំ អទុក្ខមសុខវេទនីយំ ផស្សំ បដិច្ច ឧប្បន្នា អទុក្ខមសុខា វេទនា សា និរុជ្ឈតិ សា វូបសម្មតីតិ បជានាតិ ។

[១៦៩] សេយ្យថាបិ ភិក្ខុ ទ្វិន្នំ កដ្ឋានំ សង្ឃដ្ឋ-ជា សមោធានា ឧស្មា ជាយតិ តេជោ អភិនិព្វត្តតិ តេសំយេវ ទ្វិន្នំ កដ្ឋានំ នានាភាវា វិនិក្ខេចា យា តជ្ជា ឧស្មា សា និរុជ្ឈតិ សា វូបសម្មតិ ឯវមេវ ខោ ភិក្ខុ សុខវេទនីយំ ផស្សំ បដិច្ច ឧប្បជ្ជតិ សុខា វេទនា ។ សោ សុខំ វេទនំ វេទិយមានោ សុខំ វេទនំ វេទិយាមីតិ បជានាតិ

បុគ្គលនោះ កាលទទួលអទុក្ខមសុខវេទនា រមែងដឹងច្បាស់ថា អាត្មាអញទទួលអទុក្ខមសុខវេទនា រមែងដឹងច្បាស់ថា វេទនាណា ដែលកើតអំពីផស្សៈនោះ គឺអទុក្ខមសុខវេទនាដែលកើតឡើង ព្រោះអាស្រ័យផស្សៈ ដែលជាហេតុនៃអទុក្ខមសុខវេទនា វេទនានោះ ក៏រលត់ទៅ វេទនានោះក៏ស្ងប់រម្ងាប់ ព្រោះការរលត់នៃផស្សៈដែលជាហេតុនៃអទុក្ខ-មសុខវេទនានោះឯង ។

[១៦៥] ម្នាលភិក្ខុ ដូចកម្តៅតែងកើតមាន ភ្លើងតែងកើតមាន ព្រោះកិរិយាខ្ទប់គ្នា ព្រោះកិរិយាប្រជុំគ្នានៃកំណាត់ឈើទាំងពីរ កម្តៅណាដែលកើតអំពីកិរិយាខ្ទប់គ្នានោះ កម្តៅនោះក៏រលត់ទៅ កម្តៅនោះក៏ស្ងប់រម្ងាប់ ព្រោះកិរិយាញែកគ្នា ព្រោះកិរិយាបែកគ្នានៃកំណាត់ឈើទាំងពីរនោះឯង មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុ មានឧបមេយ្យដូចសុខវេទនាតែងកើតឡើង ព្រោះអាស្រ័យផស្សៈជាហេតុនៃសុខវេទនា បុគ្គលនោះ កាលទទួលសុខវេទនា រមែងដឹងច្បាស់ថា អាត្មាអញទទួល

តស្សេវ សុខវេទនីយស្ស និរោធា យំ តជ្ជំ វេទយិតំ សុខវេទនីយំ ផស្សំ បដិច្ច ឧប្បន្នា សុខា វេទនា សា និរុជ្ឈតិ សា វូបសម្មតីតិ បជានាតិ ។ ទុក្ខវេទនីយំ ភិក្ខុ ផស្សំ បដិច្ច ឧប្បជ្ជតិ ទុក្ខា វេទនា ។ សោ ទុក្ខំ វេទនំ វេទិ-យមានោ ទុក្ខំ វេទនំ វេទិយាមីតិ បជានាតិ តស្សេវ ទុក្ខវេទនីយស្ស ផស្សស្ស និរោធា យំ តជ្ជំ វេទយិតំ ទុក្ខវេទនីយំ ផស្សំ បដិច្ច ឧប្បន្នា ទុក្ខា វេទនា សា និរុជ្ឈតិ សា វូបសម្មតីតិ បជានាតិ ។ អទុក្ខមសុខ-វេទនីយំ ភិក្ខុ ផស្សំ បដិច្ច ឧប្បជ្ជតិ អទុក្ខមសុខា វេទនា ។ សោ អទុក្ខមសុខំ វេទនំ វេទិយមានោ

សុខវេទនា រមែងដឹងច្បាស់ថា វេទនាណា ដែលកើតអំពីផស្សៈនោះ គឺសុខវេទនាដែលកើតឡើង ព្រោះអាស្រ័យផស្សៈ ដែលជាហេតុនៃសុខវេទនា វេទនានោះក៏រលត់ទៅ វេទនានោះក៏ស្ងប់រម្ងាប់ ព្រោះការរលត់នៃផស្សៈ ជាហេតុនៃសុខវេទនានោះឯង ។ ម្នាលភិក្ខុ ទុក្ខវេទនាតែងកើតឡើង ព្រោះអាស្រ័យផស្សៈជាហេតុនៃទុក្ខ-វេទនា ។ បុគ្គលនោះ កាលទទួលទុក្ខវេទនា រមែងដឹងច្បាស់ថា អាត្មាអញទទួលទុក្ខវេទនា រមែងដឹងច្បាស់ថា វេទនាណា ដែលកើតអំពីផស្សៈនោះ គឺទុក្ខវេទនាដែលកើតឡើង ព្រោះអាស្រ័យផស្សៈ ដែលជាហេតុនៃទុក្ខវេទនា វេទនានោះក៏រលត់ទៅ វេទនានោះក៏ស្ងប់រម្ងាប់ ព្រោះការរលត់នៃផស្សៈ ដែលជាហេតុនៃទុក្ខវេទនានោះឯង ។ ម្នាលភិក្ខុ អទុក្ខមសុខវេទនាតែងកើតឡើង ព្រោះអាស្រ័យផស្សៈជាហេតុនៃអទុក្ខមសុខវេទនា ។ បុគ្គលនោះ កាលទទួលអទុក្ខមសុខវេទនា

អទុក្ខមសុខំ វេទនំ វេទិយាមីតិ បជានាតិ តស្សេវ អទុក្ខមសុខវេទនីយស្ស ផស្សស្ស និរោធា យំ តជ្ជំ វេទយិតំ អទុក្ខមសុខវេទនីយំ ផស្សំ បដិច្ច ឧប្បន្នា អទុក្ខមសុខា វេទនា សា និរុជ្ឈតិ សា វូបសម្មតីតិ បជានាតិ ។ អថាបរំ ឧបេក្ខាយេវ អវសិស្សតិ បរិសុទ្ធា បរិយោទាតា មុទុ ច កម្មញ្ញា ច បភស្សរា ច ។

[១៦៦] សេយ្យថាបិ ភិក្ខុ ទក្ខោ សុវណ្ណការោ វា សុវណ្ណការន្តេវាសី វា ឧក្កំ ពន្ធេយ្យ ឧក្កំ ពន្ធិត្វា ឧក្កាមុខំ អាលិម្បេយ្យ ឧក្កាមុខំ អាលិម្បេត្វា សណ្ឌាសេន ជាតរូបំ គហេត្វា ឧក្កាមុខេ បក្ខិបេយ្យ ។ តមេនំ កាលេន កាលំ អភិធមេយ្យ កាលេន កាលំ ឧទកេន បរិប្ផោសេយ្យ

រមែងដឹងច្បាស់ថា អាត្មាអញទទួលអទុក្ខមសុខវេទនា រមែងដឹងច្បាស់ថា វេទនាណា ដែលកើតអំពីផស្សៈនោះ គឺអទុក្ខមសុខវេទនាដែលកើតឡើង ព្រោះអាស្រ័យផស្សៈ ដែលជាហេតុនៃអទុក្ខមសុខវេទនា វេទនានោះក៏រលត់ទៅ វេទនានោះក៏ស្ងប់រម្ងាប់ ព្រោះការរលត់នៃផស្សៈ ដែលជាហេតុនៃអទុក្ខមសុខវេទនានោះឯង ក៏យ៉ាងនោះដែរ ។ ចំណែកខាងក្រោយ នៅសល់តែឧបេក្ខាដ៏បរិសុទ្ធ ផូរផង់ ជាធម្មជាតិទន់ផង គួរដល់ការងារផង ភ្លឺថ្លាផង ។

[១៦៦] ម្នាលភិក្ខុ ដូចជាងមាសក្តី កូនសិស្សរបស់ជាងមាសក្តី ដែលប្រសប់ គប្បីរៀបចំនូវចង្ក្រានស្នប់ លុះរៀបចំនូវចង្ក្រានស្នប់រួចហើយ គប្បីដុតនូវមាត់នៃចង្ក្រានស្នប់ លុះដុតនូវមាត់នៃចង្ក្រានស្នប់រួចហើយ គប្បីយកដង្កាប់ចាប់មាសដាក់ទៅក្នុងមាត់នៃចង្ក្រានស្នប់ ។ គប្បីផ្លុំនូវមាត់នៃចង្ក្រានស្នប់នោះសព្វ ៗ កាល យកទឹកប្រោះព្រំសព្វ ៗ កាល

១៨៧



កាលេន កាលំ អជ្ឈុបេក្ខេយ្យ ។ តំ ហោតិ ជាតរូបំ និហតំ និទ្ធីតកសាវំ មុទុ ច កម្មញ្ញំ ច បភស្សរញ្ច[១] យស្សា យស្សា[២] បិលន្ធនវិកតិយា អាកង្ខតិ យទិ បដ្ដិកាយ[៣] យទិ កុណ្ឌលាយ យទិ គីវេយ្យកាយ យទិ សុវណ្ណមាលាយ តញ្ចស្ស អត្ថំ អនុភោតិ ឯវមេវ ខោ ភិក្ខុ អថាបរំ ឧបេក្ខាយេវ អវសិស្សតិ បរិសុទ្ធា បរិយោទាតា មុទុ ច កម្មញ្ញា ច បភស្សរា ច ។ សោ ឯវំ បជានាតិ ឥមញ្ចេ អហំ ឧបេក្ខំ ឯវំបរិសុទ្ធំ ឯវំបរិយោទាតំ អាកាសានញ្ចាយតនំ ឧបសំហរេយ្យំ តទនុធម្មញ្ច ចិត្តំ ភាវេយ្យំ ឯវម្មេ អយំ ឧបេក្ខា តន្និស្សិតា តទុបាទានា ចិរំ ទីឃមទ្ធានំ តិដ្ឋេយ្យ

---

១ ឱ. តំ ហោតិ ជាតរូបំ ធន្តំ សុទ្ធន្តំ និទ្ធន្តំ នីហដំ និទ្ធីតកសាវំ មុទុ ច កម្មញ្ញញ្ច បភស្សរញ្ចាតិ ទិស្សន្តិ ។ ម. តំ ហោតិ ជាតរូបំ សុទ្ធន្តំ និទ្ធន្តំ និហតំ និហតកសាវំ មុទុញ្ច កម្មញ្ញញ្ច បភស្សរញ្ចាតិ ទិស្សន្តិ ។ ២ ម. ច ។ ៣ អាកង្ខតិ បរិមជ្ជកាយស្សាតិបិ ទិស្សតិ ។

សំឡឹងមើលសព្វ ៗ កាល ។ មាសនោះ ប្រាសចាកទោស ប្រាសចាកមន្ទិល ជាមាសទន់ផង គួរដល់ការងារផង ភ្លឺថ្លាផង ទោះបីប្រាថ្នានឹងធ្វើគ្រឿងប្រដាប់ដ៏ប្លែកណា ៗ គឺខ្សែខ្លួនក្តី ការក្តី កងកក្តី ផ្កាមាសក្តី មាសនោះ នឹងសម្រេចប្រយោជន៍ដល់បុគ្គលនោះបាន មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុ មានឧបមេយ្យដូចចំណែកខាងក្រោយ នៅសល់តែឧបេក្ខា[១] ដ៏បរិសុទ្ធ ផូរផង់ ជាធម្មជាតិទន់ផង គួរដល់ការងារផង ភ្លឺថ្លាផង យ៉ាងនោះឯង ។ បុគ្គលនោះ តែងដឹងច្បាស់យ៉ាងនេះថា បើអាត្មាអញបង្អោននូវឧបេក្ខានេះ ដែលបរិសុទ្ធយ៉ាងនេះ ផូរផង់យ៉ាងនេះ ទៅកាន់អាកាសានញ្ចាយតនជ្ឈាន ហើយចម្រើនចិត្ត[២] ជាធម៌ដ៏សមគួរដល់អាកាសានញ្ចាយតនជ្ឈាននោះ ឧបេក្ខារបស់អាត្មាអញនេះ អាស្រ័យនូវអាកាសានញ្ចាយតនជ្ឈាននោះ អែបនែបនឹងអាកាសានញ្ចាយតនជ្ឈាននោះយ៉ាងនេះ គប្បីឋិតនៅអស់កាលជាយូរអង្វែង[៣]

---

១ ឧបេក្ខានេះ សំដៅយកចតុត្ថជ្ឈានុបេក្ខា គឺឧបេក្ខាដែលមានក្នុងរូបាវចរចតុត្ថជ្ឈាន ។

២ បានខាងរូបាវចរជ្ឈាន ។ ៣ កំណត់ពីរហ្មឺនកប្ប ។

ឥមញ្ចេ អហំ ឧបេក្ខំ ឯវំបរិសុទ្ធំ ឯវំបរិយោទាតំ វិញ្ញាណញ្ចាយតនំ ឧបសំហរេយ្យំ តទនុធម្មញ្ច ចិត្តំ ភាវេយ្យំ ឯវំមេ អយំ ឧបេក្ខា តន្និស្សិតា តទុបាទានា ចិរំ ទីឃមទ្ធានំ តិដ្ឋេយ្យ ឥមញ្ចេ អហំ ឧបេក្ខំ ឯវំបរិសុទ្ធំ ឯវំបរិយោទាតំ អាកិញ្ចញ្ញាយតនំ ឧបសំហរេយ្យំ តទនុធម្មញ្ច ចិត្តំ ភាវេយ្យំ ឯវំមេ អយំ ឧបេក្ខា តន្និស្សិតា តទុបាទានា ចិរំ ទីឃមទ្ធានំ តិដ្ឋេយ្យ ឥមញ្ចេ អហំ ឧបេក្ខំ ឯវំបរិសុទ្ធំ ឯវំបរិយោទាតំ នេវសញ្ញានាសញ្ញាយតនំ ឧបសំហរេយ្យំ តទនុធម្មញ្ច ចិត្តំ ភាវេយ្យំ ឯវំមេ អយំ ឧបេក្ខា តន្និស្សិតា តទុបាទានា ចិរំ ទីឃមទ្ធានំ តិដ្ឋេយ្យាតិ ។ សោ ឯវំ បជានាតិ ឥមញ្ចេ អហំ ឧបេក្ខំ

ប្រសិនបើអាត្មាអញបង្អោនទូវឧបេក្ខានេះ ដែលបរិសុទ្ធយ៉ាងនេះ ផូរផង់យ៉ាងនេះ ទៅកាន់វិញ្ញាណញ្ចាយតនជ្ឈាន ហើយចម្រើនចិត្ត ជាធម៌ដ៏សមគួរដល់វិញ្ញាណញ្ចាយតនជ្ឈាននោះ ឧបេក្ខារបស់អាត្មាអញនេះ ដែលអាស្រ័យនូវវិញ្ញាណញ្ចាយតនជ្ឈាននោះ ដែលអែបនែបនឹងវិញ្ញាណញ្ចាយតនជ្ឈាននោះយ៉ាងនេះ ក៏គប្បីឋិតនៅអស់កាលជាយូរអង្វែង ប្រសិនបើអាត្មាអញបង្អោនទូវឧបេក្ខានេះ ដែលបរិសុទ្ធយ៉ាងនេះ ផូរផង់យ៉ាងនេះ ទៅកាន់អាកិញ្ចញ្ញាយតនជ្ឈាន ហើយចម្រើនចិត្ត ជាធម៌ដ៏សមគួរដល់អាកិញ្ចញ្ញាយតនជ្ឈាននោះ ឧបេក្ខារបស់អាត្មាអញនេះ ដែលអាស្រ័យនូវអាកិញ្ចញ្ញាយតនជ្ឈាននោះ ដែលអែបនែបនឹងអាកិញ្ចញ្ញាយតនជ្ឈាននោះយ៉ាងនេះ ក៏គប្បីឋិតនៅអស់កាលជាយូរអង្វែង ប្រសិនបើអាត្មាអញបង្អោនទូវឧបេក្ខានេះ ដែលបរិសុទ្ធយ៉ាងនេះ ផូរផង់យ៉ាងនេះ ទៅកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន ហើយចម្រើនចិត្ត ជាធម៌ដ៏សមគួរដល់នេវសញ្ញានាសញ្ញាយតនជ្ឈាននោះ ឧបេក្ខារបស់អាត្មាអញនេះ ដែលអាស្រ័យនូវនេវសញ្ញានា-សញ្ញាយតនជ្ឈាននោះ ដែលអែបនែបនឹងនេវសញ្ញានាសញ្ញាយតនជ្ឈាននោះយ៉ាងនេះ ក៏គប្បីឋិតនៅអស់កាលជាយូរអង្វែង ។ បុគ្គលនោះតែងដឹងច្បាស់យ៉ាងនេះថា ប្រសិនបើអាត្មាអញបង្អោនទូវឧបេក្ខានេះ

ឯវំបរិសុទ្ធំ ឯវំបរិយោទាតំ អាកាសានញ្ចាយតនំ ឧបសំហរេយ្យំ តទនុធម្មញ្ច ចិត្តំ ភាវេយ្យំ សង្ខតមេតំ ឥមញ្ចេ អហំ ឧបេក្ខំ ឯវំបរិសុទ្ធំ ឯវំបរិយោទាតំ វិញ្ញាណញ្ចាយតនំ ឧបសំហរេយ្យំ តទនុធម្មញ្ច ចិត្តំ ភាវេយ្យំ សង្ខតមេតំ ឥមញ្ចេ អហំ ឧបេក្ខំ ឯវំបរិសុទ្ធំ ឯវំបរិយោទាតំ អាកិញ្ចញ្ញាយតនំ ឧបសំហរេយ្យំ តទនុធម្មញ្ច ចិត្តំ ភាវេយ្យំ សង្ខតមេតំ ឥមញ្ចេ អហំ ឧបេក្ខំ ឯវំបរិសុទ្ធំ ឯវំបរិយោទាតំ នេវសញ្ញានាសញ្ញាយតនំ ឧបសំហរេយ្យំ តទនុធម្មញ្ច ចិត្តំ ភាវេយ្យំ សង្ខតមេតន្តិ ។ សោ នេវាភិសង្ខ-រោតិ នាភិសញ្ចេតយតិ ភវាយ វា វិភវាយ វា ។

ដែលបរិសុទ្ធយ៉ាងនេះ ផូរផង់យ៉ាងនេះ ទៅកាន់អាកាសានញ្ចាយតនជ្ឈានហើយចម្រើនចិត្ត ជាធម៌ដ៏សមគួរដល់អាកាសានញ្ចាយតនជ្ឈាននោះ ឈានទុំះ នៅជាសង្ខតជ្ឈាន[១] ប្រសិនបើអាត្មាអញបង្អោននូវឧបេក្ខានេះ ដែលបរិសុទ្ធយ៉ាងនេះ ផូរផង់យ៉ាងនេះ ទៅកាន់វិញ្ញាណញ្ចាយតនជ្ឈាន ហើយចម្រើនចិត្ត ជាធម៌ដ៏សមគួរដល់វិញ្ញាណញ្ចាយតនជ្ឈាននោះ ឈានទុំះក៏នៅជាសង្ខតជ្ឈាន ប្រសិនបើអាត្មាអញបង្អោននូវឧបេក្ខានេះ ដែលបរិសុទ្ធយ៉ាងនេះ ផូរផង់យ៉ាងនេះ ទៅកាន់អាកិញ្ចញ្ញាយតនជ្ឈាន ហើយចម្រើនចិត្ត ជាធម៌ដ៏សមគួរដល់អាកិញ្ចញ្ញាយតនជ្ឈាននោះ ឈានទុំះក៏នៅជាសង្ខតជ្ឈាន ប្រសិនបើអាត្មាអញបង្អោននូវឧបេក្ខានេះ ដែលបរិសុទ្ធយ៉ាងនេះ ផូរផង់យ៉ាងនេះ ទៅកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន ហើយចម្រើនចិត្ត ជាធម៌ដ៏សមគួរដល់នេវសញ្ញានាសញ្ញាយតនជ្ឈាននោះ ឈានទុំះក៏នៅជាសង្ខតជ្ឈាន ។ បុគ្គលនោះក៏លែងតាក់តែង លែងត្រិះរិះគិត ដើម្បីសេចក្តីចម្រើនឬសេចក្តីវិនាស ។

---

១ ប្រែថា ឈាននៅមានបច្ច័យតាក់តែង គឺនៅមានជាតិ ជរា ជាប់តាម នៅមានមរណៈគ្របសង្កត់ តាំងនៅក្នុងសេចក្តីទុក្ខ ជាឈាននៅមិនមែនជាទីពឹងមាំ ។

សោ អនភិសង្ខរោន្តោ អនភិសញ្ចេតយន្តោ ភវាយ វិភវាយ ន កិញ្ចិ លោកេ ឧបាទិយតិ អនុបាទិយំ[១] ន បរិតស្សតិ អបរិតស្សំ[៣] បច្ចត្តំយេវ បរិនិព្វាយតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ សោ សុខញ្ចេ វេទនំ វេទេតិ សា អនិច្ចាតិ បជានាតិ អនជ្ឈោសិតាតិ បជានាតិ អនភិនន្ទិតាតិ បជានាតិ ។ ទុក្ខញ្ចេ វេទនំ វេទេតិ សា អនិច្ចាតិ បជានាតិ អនជ្ឈោសិតាតិ បជានាតិ អនភិនន្ទិតាតិ បជានាតិ ។ អទុក្ខមសុខញ្ចេ វេទនំ វេទេតិ សា អនិច្ចាតិ បជានាតិ អនជ្ឈោសិតាតិ បជានាតិ អនភិនន្ទិតាតិ បជានាតិ ។

---

១ អនុបាទិយតន្តិប្បត្តិ ។ ២ អបរិតស្សតន្តិបិ ។

បុគ្គលនោះ កាលលែងតាក់តែង លែងត្រិះរិះគិត ដើម្បីសេចក្តីចម្រើន ឬសេចក្តីវិនាស ក៏លែងប្រកាន់របស់នីមួយ ក្នុងលោក កាលបើលែងប្រកាន់ហើយ ក៏មិនតក់ស្លុត កាលមិនតក់ស្លុត រមែងរំលត់កិលេសដោយពិតប្រាកដ រមែងដឹងច្បាស់ថា ជាតិ (របស់អាត្មាអញ) អស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបាននៅគ្រប់គ្រាន់ហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ បើបុគ្គលនោះ ទទួលសុខវេទនា ក៏ដឹងច្បាស់ថា សុខវេទនានោះមិនទៀង ដឹងច្បាស់ថា សុខវេទនានោះ អាត្មាអញមិនគួរនឹងជ្រប់ជាប់ឡើយ ដឹងច្បាស់ថា សុខវេទនានោះ អាត្មាអញមិនគួរនឹងត្រេកអរឡើយ ។ ប្រសិនបើបុគ្គលនោះ ទទួលទុក្ខវេទនា ក៏ដឹងច្បាស់ថា ទុក្ខវេទនានោះមិនទៀង ដឹងច្បាស់ថា ទុក្ខវេទនានោះ អាត្មាអញមិនគួរនឹងជ្រប់ជាប់ឡើយ ដឹងច្បាស់ថា ទុក្ខវេទនានោះ អាត្មាអញមិនគួរនឹងត្រេកអរឡើយ ។ ប្រសិនបើបុគ្គលនោះ ទទួលអទុក្ខមសុខវេទនា ក៏ដឹងច្បាស់ថា អទុក្ខមសុខវេទនានោះមិនទៀង ដឹងច្បាស់ថា អទុក្ខមសុខវេទនានោះ អាត្មាអញមិនគួរនឹងជ្រប់ជាប់ឡើយ ដឹងច្បាស់ថា អទុក្ខមសុខវេទនានោះ អាត្មាអញមិនគួរនឹងត្រេកអរឡើយ ។

១៩១



សោ សុខញ្ចេ វេទនំ វេទេតិ វិសំយុត្តោ នំ(១) វេទេតិ ។ សោ ទុក្ខញ្ចេ វេទនំ វេទេតិ វិសំយុត្តោ នំ(២) វេទេតិ ។ អទុក្ខមសុខញ្ចេ វេទនំ វេទេតិ វិសំយុត្តោ នំ(៣) វេទេតិ ។ សោ កាយបរិយន្តិកំ វេទនំ វេទិយមានោ កាយបរិយន្តិកំ វេទនំ វេទិយាមីតិ បជានាតិ ។ ជីវិតបរិយន្តិកំ វេទនំ វេទិយមានោ ជីវិតបរិយន្តិកំ វេទនំ វេទិយាមីតិ បជានាតិ ។ កាយស្ស ភេទា(៤) ឧទ្ធំ ជីវិតបរិយាទានា ឥធេវ សព្វវេទយិតានិ អនភិនន្ទិតានិ សីតីភវិស្សន្តីតិ បជានាតិ ។

---

១-២-៣ អដ្ឋកថាយំ វិសំយុត្តោ ន វេទេតីតិ បាឋោ ទិស្សន្តិ ។ ៤ ម. ឯត្ថន្តរេ បរម្មរណាតិ ទិស្សតិ ។

បើបុគ្គលនោះ ទទួលសុខវេទនា រមែងមានចិត្តនឿយណាយ ហើយទទួលសុខវេទនានោះ ។ បើបុគ្គលនោះ ទទួលទុក្ខវេទនា រមែងមានចិត្តនឿយណាយ ហើយទទួលទុក្ខវេទនានោះ ។ បើបុគ្គលនោះ ទទួលអទុក្ខមសុខវេទនា រមែងមានចិត្តនឿយណាយ ហើយទទួលអទុក្ខមសុខវេទនានោះ ។ កាលបុគ្គលនោះ ទទួលវេទនាដែលមានកាយជាទីបំផុត ក៏រមែងដឹងច្បាស់ថា អាត្មាអញទទួលវេទនាមានកាយជាទីបំផុត ។ កាលទទួលវេទនាដែលមានជីវិតជាទីបំផុត ក៏រមែងដឹងច្បាស់ថា អាត្មាអញទទួលវេទនាមានជីវិតជាទីបំផុត ។ ដឹងច្បាស់ថា កាលបើមានរាងកាយបែកធ្លាយទៅហើយ ខាងនាយអំពីការអស់ជីវិតទៅ វេទនាទាំងពួង ដែលអាត្មាអញមិនគួរត្រេកអរ ក្នុងលោកនេះ នឹងរលត់អស់ទៅមិនមានសល់ ។

[១៦៧] សេយ្យថាបិ ភិក្ខុ តេលញ្ច បដិច្ច វដ្ដិញ្ច បដិច្ច តេលប្បទីបោ ឈាយតិ ។ តស្សេវ តេលស្ស ច វដ្ដិយា ច បរិយាទានា អញ្ញស្ស ច អនុបហារា[១] អនាហារោ និព្វាយតិ ឯវមេវ ខោ[២] ភិក្ខុ កាយបរិយន្តិកំ វេទនំ វេទិយមានោ កាយបរិយន្តិកំ វេទនំ វេទិយាមីតិ បជានាតិ ។ ជីវិតបរិយន្តិកំ វេទនំ វេទិយមានោ ជីវិតបរិយន្តិកំ វេទនំ វេទិយាមីតិ បជានាតិ ។ កាយស្ស ភេទា ឧទ្ធំ ជីវិតបរិយាទានា ឥធេវ សព្វវេទយិតានិ អន-ភិនន្ទិតានិ សីតីភវិស្សន្តីតិ បជានាតិ ។ តស្មា ឯវំ សមន្នាគតោ ភិក្ខុ ឥមិនា បរមេន បញ្ញាធិដ្ឋា-នេន សមន្នាគតោ ហោតិ ។ ឯសា ហិ ភិក្ខុ បរមា អរិយា បញ្ញា យទិទំ សព្វទុក្ខក្ខយេ ញាណំ ។ តស្ស សា វិមុត្តិ សច្ចេ ឋិតា

១ ម. អនុបាទានា ។ ២ ឱ. ខោសទ្ទោ នត្ថិ ។

[១៦៧] ម្នាលភិក្ខុ ដូចជាប្រទីបប្រេង តែងឆេះរុងរឿង ព្រោះអាស្រ័យប្រេងផង ព្រោះអាស្រ័យប្រឆេះផង ។ អណ្ដាតប្រទីបមិនមានអាហារ តែងរលត់ទៅ ព្រោះអស់ប្រេងនិងប្រឆេះមុននោះផង ព្រោះមិនបានបន្ថែមប្រេងនិងប្រឆេះដទៃទៀត យ៉ាងណាមិញ ម្នាលភិក្ខុ កាលបុគ្គលនោះទទួលវេទនាមានកាយជាទីបំផុត ក៏ដឹងច្បាស់ថា អាត្មាអញទទួលវេទនាមានកាយជាទីបំផុត ។ កាលទទួលវេទនាមានជីវិតជាទីបំផុត ក៏ដឹងច្បាស់ថា អាត្មាអញទទួលវេទនាមានជីវិតជាទីបំផុត ។ ដឹងច្បាស់ថា កាលបើមានរាងកាយបែកធ្លាយទៅហើយ ខាងនាយអំពីការអស់ជីវិតទៅ វេទនាទាំងពួង ដែលអាត្មាអញមិនគួរត្រេកអរ ក្នុងលោកនេះ នឹងរលត់អស់ទៅមិនមានសល់ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុ ព្រោះហេតុនោះ បុគ្គលដែលប្រកបដោយគុណធម៌យ៉ាងនេះ ទើបឈ្មោះថាប្រកបដោយបញ្ញាធិដ្ឋានដ៏ឧត្ដមនេះ ។ ម្នាលភិក្ខុ ព្រោះថាសេចក្ដីដឹងក្នុងធម៌[១] ជាទីអស់ទៅនៃទុក្ខទាំងពួងណា សេចក្ដីដឹងនុ៎ះ ហៅថាបញ្ញាដ៏ប្រសើរក្រៃលែង ។ វិមុត្តិនោះរបស់បុគ្គលនោះ ឋិតនៅក្នុងសច្ចៈ

---

១ អរហត្តផល ។

១៩៣



អកុប្បា ហោតិ ។ តំ ហិ ភិក្ខុ មុសា យំ មោសធម្មំ តំ សច្ចំ យំ អមោសធម្មំ និព្វានំ តស្មា ឯវំ សមន្នាគតោ ភិក្ខុ ឥមិនា បរមេន សច្ចាធិដ្ឋានេន សមន្នាគតោ ហោតិ ។ ឯតំ ហិ ភិក្ខុ បរមំ អរិយសច្ចំ យទិទំ អមោសធម្មំ និព្វានំ ។ តស្សេវ ខោ បន បុព្វេ អវិទ្វសុនោ ឧបធី ហោន្តិ សមត្តា សមាទិន្នា ។ ត្យស្ស បហីនា ហោន្តិ ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវង្កតា អាយតឹ អនុប្បាទធម្មា តស្មា ឯវំ សមន្នាគតោ ភិក្ខុ ឥមិនា បរមេន ចាគាធិដ្ឋានេន សមន្នាគតោ ហោតិ ។ ឯសោ ហិ ភិក្ខុ បរមោ អរិយោ ចាគោ យទិទំ សព្វូបធិប្ប-ដិនិស្សគ្គោ ។ តស្សេវ ខោ បន បុព្វេ អវិទ្វសុនោ

ជាវិមុត្តិ មិនកម្រើក ។ ម្នាលភិក្ខុ ព្រោះថា របស់ណាដែលមានសេចក្តីវិនាសជាធម្មតា របស់នោះជារបស់មុសា ព្រះនិព្វានណាដែលមានសេចក្តីមិនវិនាសជាធម្មតា ព្រះនិព្វាននោះ ជារបស់សច្ចៈ ម្នាលភិក្ខុ ព្រោះហេតុនោះ បុគ្គល ដែលប្រកបដោយគុណធម៌យ៉ាងនេះ ទើបឈ្មោះថាប្រកបដោយសច្ចាធិដ្ឋានដ៏ឧត្តមនេះ ។ ម្នាលភិក្ខុ ព្រោះថា ព្រះនិព្វានណា ដែលមានសេចក្តីមិនវិនាសជាធម្មតា ព្រះនិព្វាននុ៎ះ ឈ្មោះថាជាអរិយសច្ចដ៏ឧត្តម ។ ក៏កាលពីដើម[១] បុគ្គលនោះ មិនទាន់ដឹងច្បាស់ តែងបំពេញ តែងកាន់យក នូវឧបធិ[២] ទាំងឡាយ ។ ឧបធិទាំងនោះ បុគ្គលនោះ បានលះបង់ហើយ បានគាស់រំលើងឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ជាសភាវៈដល់នូវការមិនមាន មានសភាពមិនកើតទៀតជាធម្មតាតទៅ ម្នាលភិក្ខុ ព្រោះហេតុនោះ បុគ្គលដែលប្រកបដោយគុណធម៌យ៉ាងនេះ ទើបឈ្មោះថាប្រកបដោយចាគាធិដ្ឋានដ៏ឧត្តមនេះ ។ ម្នាលភិក្ខុ ព្រោះថា ការលះបង់នូវឧបធិទាំងពួងណា ការលះបង់នុ៎ះ ហៅថាចាគៈដ៏ប្រសើរក្រៃលែង ។ កាលពីដើម បុគ្គលនោះមិនទាន់ដឹងច្បាស់

---

១ អំពីកាលដែលនៅជាបុថុជ្ជន ។ ២ ឧបធិ ៤ គឺខន្ធូបធិ ១ កិលេសូបធិ ១ អភិសង្ខារូបធិ ១ បញ្ចកាមគុណូបធិ ១ ។

អភិជ្ឈា ហោតិ ឆន្ទោ សារាគោ ស្វាស្ស បហីនោ ហោតិ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវង្កតោ អាយតឹ អនុប្បាទធម្មោ ។ តស្សេវ ខោ បន បុព្វេ អវិទ្ទសុនោ អាឃាតោ ហោតិ ព្យាបាទោ សម្បទោសោ ស្វាស្ស បហីនោ ហោតិ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវង្កតោ អាយតឹ អនុប្បាទ-ធម្មោ ។ តស្សេវ ខោ បន បុព្វេ អវិទ្ទសុនោ អវិជ្ជា ហោតិ សម្មោហោ សម្បមោហោ ស្វាស្ស បហីនោ ហោតិ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ

*អភិជ្ឈា[១] ឆន្ទៈ[២] និងសារាគៈ[៣] ក៏មាននៅ កិលេសនោះ បុគ្គលនោះបានលះបង់ចោលហើយ បានគាស់រំលើងឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ជាសភាវៈដល់នូវការមិនមាន មានសភាពមិនកើតតទៅទៀតជាធម្មតា ។ មួយទៀត កាលពីដើម បុគ្គលនោះមិនទាន់ដឹងច្បាស់ អាឃាត[៤] ព្យាបាទ[៥] និងសម្បទោសៈ[៦] ក៏មាននៅ កិលេសនោះ បុគ្គលនោះ បានលះបង់ហើយ បានគាស់រំលើងឫសគល់ចោលហើយ បានធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត ជាសភាវៈដល់នូវការមិនមាន មានសភាពមិនកើតតទៅទៀតជាធម្មតា ។ កាលពីដើម បុគ្គលនោះមិនទាន់ដឹងច្បាស់ អវិជ្ជា[៧] សម្មោហៈ[៨] និងសម្បមោហៈ[៩]ក៏មាននៅ កិលេសនោះ បុគ្គលនោះ បានលះបង់ហើយ បានគាស់រំលើងឫសគល់ចោលហើយ បានធ្វើឲ្យនៅសល់តែទីនៅដូចជាទីនៅនៃដើមត្នោត*

---

១ សេចក្តីរំពៃចង់បាន ។ ២ សេចក្តីប្រាថ្នា ។ ៣ សេចក្តីត្រេកអរក្នុងកាមគុណ ។ ទាំង ៣ បទនេះជាឈ្មោះនៃលោភៈ ឬ រាគៈ ។ ៤ គំនុំ ។ ៥ ការញុំាងប្រយោជន៍និងសុខរបស់អ្នកដទៃឲ្យវិនាស ។ ៦ ការប្រទូស្ត ។ ទាំង ៣ បទនេះជាឈ្មោះនៃទោសៈ ។ ៧ សេចក្តីមិនដឹង ។ ៨ សេចក្តីវង្វេង ។ ៩ សេចក្តីភាន់ច្រឡំ ។ ទាំង ៣ បទនេះជាឈ្មោះនៃមោហៈ ។

អនភាវង្កតោ អាយតឹ អនុប្បាទធម្មោ តស្មា ឯវំ សមន្នាគតោ ភិក្ខុ ឥមិនា បរមេន ឧបសមាធិដ្ឋានេន សមន្នាគតោ ហោតិ ។ ឯសោ ហិ ភិក្ខុ បរមោ អរិយោ ឧបសមោ យទិទំ រាគទោសមោហានំ ឧបសមោ ។ បញ្ញំ នប្បមជ្ជេយ្យ សច្ចមនុរក្ខេយ្យ ចាគមនុព្រូហេយ្យ សន្តិមេវ សោ សិក្ខេយ្យាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

[១៦៨] យត្ថ ឋិតំ មញ្ញស្សវា នប្បវត្តន្តិ មញ្ញស្សវេ ខោ បន នប្បវត្តមានេ មុនិ សន្តោតិ វុច្ចតីតិ ឥតិ ខោ បនេតំ វុត្តំ ។ កិញ្ចេតំ បដិច្ច វុត្តំ ។

ជាសភាវៈដល់នូវការមិនមាន មានសភាពមិនកើតតទៅទៀតជាធម្មតា ម្នាលភិក្ខុ ព្រោះហេតុនោះ បុគ្គលដែលប្រកបដោយគុណធម៌យ៉ាងនេះ ទើបឈ្មោះថាប្រកបដោយឧបសមាធិដ្ឋានដ៏ឧត្តមនេះ ។ ម្នាលភិក្ខុ ព្រោះថា ការរម្ងាប់នូវរាគៈទោសៈនិងមោហៈទាំងឡាយណា ការរម្ងាប់នុ៎ះ ឈ្មោះថាឧបសមៈដ៏ប្រសើរក្រៃលែង ។ ពាក្យណា ដែលយើងពោលហើយថា បុគ្គលនោះ មិនគួរបណ្តែតបណ្តោយបញ្ញា[១] គួររក្សារឿយ ៗ នូវសច្ចៈ គួរចម្រើនរឿយ ៗ នូវចាគៈ គួរសិក្សានូវសន្តិដូច្នេះ ពាក្យនុ៎ះ យើងពោលហើយ ព្រោះអាស្រ័យសេចក្តីនេះឯង ។

[១៦៨] ពាក្យថា សេចក្តីសំគាល់និងសេចក្តីវិលវល់ តែងមិនប្រព្រឹត្តទៅកាន់បុគ្គលដែលឋិតនៅ ក្នុងអធិដ្ឋានទាំងឡាយណា កាលបើសេចក្តីសំគាល់និងសេចក្តីវិលវល់ មិនប្រព្រឹត្តទៅហើយ បុគ្គលនោះ យើងហៅថាជាអ្នកប្រាជ្ញមានចិត្តស្ងប់រម្ងាប់ ដូច្នេះនុ៎ះ យើងបានពោលហើយ ។ ពាក្យនុ៎ះយើងពោលហើយ ព្រោះអាស្រ័យសេចក្តីដូចម្តេច ។

---

១ បានសេចក្តីថាមិនគួរបណ្តែតបណ្តោយបញ្ញា គួរតែយកបញ្ញាទៅពិចារណាធាតុទាំង ៦ នោះឲ្យឃើញថាមិនមែនរបស់ខ្លួន មិនមែនខ្លឹមសារ ហើយនឿយណាយនឹងធាតុទាំង ៦ នោះ ញុំាងចិត្តឲ្យគ្រាកចេញអំពីធាតុទាំង ៦ នោះ ។

អស្មីតិ ភិក្ខុ មញ្ញិតមេតំ ណាហមស្មីតិ[១] មញ្ញិតមេតំ ភវិស្សន្តិ មញ្ញិតមេតំ ន ភវិស្សន្តិ មញ្ញិតមេតំ រូបី ភវិស្សន្តិ មញ្ញិតមេតំ អរូបី ភវិស្សន្តិ មញ្ញិតមេតំ សញ្ញី ភវិស្សន្តិ មញ្ញិតមេតំ អសញ្ញី ភវិស្សន្តិ មញ្ញិ-តមេតំ នេវសញ្ញីណាសញ្ញី ភវិស្សន្តិ មញ្ញិតមេតំ ។ មញ្ញិតំ ភិក្ខុ រោគោ មញ្ញិតំ គណ្ឌោ មញ្ញិតំ សល្លំ ។ សព្វមញ្ញិតានំ ត្វេវ ភិក្ខុ សមតិក្កមា មុនិ សន្តោតិ វុច្ចតិ ។ មុនិ ខោ បន ភិក្ខុ សន្តោ ន ជាយតិ ន ជិយ្យតិ ន មិយ្យតិ ន កុប្បតិ

១ ឱ. ម. អយមហមស្មីតិ ។

ម្នាលភិក្ខុ សេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញកើតមានឥឡូវនេះ សេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញមិនកើតមានឥឡូវនេះ សេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញនឹងកើតមាន សេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញនឹងមិនកើតមាន សេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញនឹងមានរូប សេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញនឹងមិនមានរូប សេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញនឹងមានសញ្ញា សេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញនឹងមិនមានសញ្ញា សេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ។ ម្នាលភិក្ខុ សេចក្តីសំគាល់ ឈ្មោះថាជារោគ សេចក្តីសំគាល់ ឈ្មោះថាជាបូស សេចក្តីសំគាល់ ឈ្មោះថាជាសរ ។ ម្នាលភិក្ខុ បុគ្គលនោះ យើងហៅថា ជាអ្នកប្រាជ្ញមានចិត្តស្ងប់រម្ងាប់ ព្រោះតែការប្រព្រឹត្តកន្លងនូវសេចក្តីសំគាល់ទាំងពួងបាន ។ ម្នាលភិក្ខុ ឯអ្នកប្រាជ្ញ ដែលមានចិត្តស្ងប់រម្ងាប់ រមែងលែងកើត លែងចាស់ លែងស្លាប់ លែងស្អប់

នប្បហោតិ ។ តម្ហិ ចេ ភិក្ខុ នត្ថិ យេន ជាយេថ អជាយមានោ កឹ ជិយ្យិស្សតិ អជិយ្យមានោ កឹ មិយ្យិស្សតិ អមិយ្យមានោ កឹ កុប្បិស្សតិ អកុប្បមានោ កិស្ស បិហេស្សតិ ។ យត្ថ ឋិតំ មញ្ញស្សវា នប្បវត្តន្តិ មញ្ញស្សវេ ខោ បន នប្បវត្តមានេ មុនិ សន្តោតិ វុច្ចតីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ ឥមំ ខោ មេ ត្វំ ភិក្ខុ សង្ខិត្តេន ឆធាតុវិភង្គំ ធារេហីតិ ។

លែងស្រឡាញ់ ។ ម្នាលភិក្ខុ សត្វគប្បីកើត ដោយហេតុណា ហេតុនោះ របស់បុគ្គលនោះ មិនមានឡើយ កាលបុគ្គលនោះមិនកើត នឹងចាស់មកពីណា កាលបើមិនចាស់ហើយ នឹងស្លាប់មកពីណា កាលបើមិនស្លាប់ហើយ នឹងស្អប់មកពីណា កាលបើមិនស្អប់ហើយ នឹងស្រឡាញ់មកពីណា ។ ពាក្យណា ដែលយើងពោលហើយថា សេចក្តីសំគាល់និងសេចក្តីវិលវល់ តែងមិនប្រព្រឹត្តទៅកាន់បុគ្គលដែលឋិតនៅក្នុងអធិដ្ឋានទាំងឡាយណា កាលបើសេចក្តីសំគាល់និងសេចក្តីវិលវល់មិនប្រព្រឹត្តទៅហើយ បុគ្គលនោះ យើងហៅថាជាអ្នកប្រាជ្ញមានចិត្តស្ងប់រម្ងាប់ដូច្នេះ ពាក្យនុ៎ះ យើងពោលហើយ ព្រោះអាស្រ័យសេចក្តីនេះឯង ។ ម្នាលភិក្ខុ ចូរអ្នកចាំទុក នូវចំណែកនៃធាតុទាំង ៦ ដោយសេចក្តីសង្ខេបរបស់យើងនេះចុះ ។

[១៦៩] អថខោ អាយស្មា បុណ្ណោ ភិក្ខុ សាធុ សត្ថា ភិក្ខុ មេ អនុប្បត្តោ សុគតោ ភិក្ខុ មេ អនុប្បត្តោ សម្មាសម្ពុទ្ធោ ភិក្ខុ មេ អនុប្បត្តោតិ ឧដ្ឋាយាសនា ឯកំសំ ចីវរំ កត្វា ភគវតោ បាទេសុ សិរសា និបតិត្វា ភគវន្តំ ឯតទវោច អច្ចយោ មំ ភន្តេ អច្ចគមា យថាពាលំ យថាមូឡ្ហំ យថាអកុសលំ យោហំ ភគវន្តំ អាវុសោវាទេន សមុទាចរិតព្វំ អមញ្ញិស្សំ តស្ស មេ ភន្តេ ភគវា អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ អាយតឹ សំវរាយាតិ ។

[១៧០] តគ្ឃ ត្វំ ភិក្ខុ អច្ចយោ អច្ចគមា យថាពាលំ យថាមូឡ្ហំ យថាអកុសលំ យំ មំ ត្វំ អាវុសោវាទេន សមុទាចរិតព្វំ អមញ្ញិត្ថោ យតោ ច ខោ ត្វំ ភិក្ខុ អច្ចយំ អច្ចយតោ ទិស្វា យថាធម្មំ បដិករោសិ តន្តេ មយំ បដិគ្គណ្ហាម

[១៦៩] គ្រានោះឯង បុក្កុសាតិមានអាយុ ក៏ភ្ញាក់ស្មារតីដឹងថា ព្រះសាស្តារបស់អញ ស្តេចមកដល់ហើយតើ ព្រះសុគតរបស់អញ ស្តេចមកដល់ហើយតើ ព្រះសម្មាសម្ពុទ្ធរបស់អញ ស្តេចមកដល់ហើយតើ ដូច្នេះ ក៏ក្រោកអំពីអាសនៈ ធ្វើចីវរឆៀងស្មាម្ខាង ក្រាបទៀបបាទារបស់ព្រះមានព្រះភាគដោយត្បូងហើយ ទើបសូមខមាទោសចំពោះព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ មានសេចក្តីល្មើសហើយ ដោយហេតុថាខ្ញុំព្រះអង្គ ជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស ព្រោះខ្ញុំព្រះអង្គបានសំគាល់នូវព្រះមានព្រះភាគ ថាជាបុគ្គលដែលគេគប្បីហៅរក ដោយពាក្យថា អាវុសោ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់អត់ទោសតាមទោសរបស់ខ្ញុំព្រះអង្គនោះ ដើម្បីនឹងសង្រួមតទៅមុខទៀត ។

[១៧០] ព្រះអង្គទ្រង់ត្រាស់ថា អើភិក្ខុ អ្នកមានសេចក្តីល្មើសហើយ ដោយហេតុថាអ្នក ជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស ព្រោះអ្នក បានសំគាល់នូវតថាគតថាជាបុគ្គលដែលគេគប្បីហៅរក ដោយពាក្យថា អាវុសោ ដូច្នេះ ម្នាលភិក្ខុ កាលណាបើអ្នក បានឃើញទោស តាមទោសហើយសំដែងដោយសមគួរតាមធម៌ហើយ យើងនឹងអត់ទោសនោះ ដល់អ្នក

វុឌ្ឍិ ហេសា ភិក្ខុ អរិយស្ស វិនយេ យោ អច្ចយំ អច្ចយតោ ទិស្វា យថាធម្មំ បដិករោតិ អាយតឹ សំវរំ អាបជ្ជតីតិ ។ លភេយ្យាហំ ភន្តេ ភគវតោ សន្តិកេ ឧបសម្បទន្តិ ។ បរិបុណ្ណំ បន តេ ភិក្ខុ បត្តចីវរន្តិ ។ ន ខោ មេ ភន្តេ បរិបុណ្ណំ បត្តចីវរន្តិ ។ ន ខោ ភិក្ខុ តថាគតា អបរិបុណ្ណបត្តចីវរំ ឧបសម្បាទេន្តីតិ ។

[១៧១] អថខោ អាយស្មា បុក្កុសាតិ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បត្តចីវរបរិយេសនំ បក្កាមិ ។ អថខោ អាយស្មន្តំ បុក្កុសាតឹ បត្តចីវរបរិយេសនំ ចរន្តំ គាវី[១] ជីវិតា វោរោបេសិ ។ អថខោ សម្ពហុលា ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។

---

១ ឱ. ភន្តគាវី ។ ម. វិព្ភន្តគាវី ។

ម្នាលភិក្ខុ បុគ្គលណា ឃើញនូវទោសតាមទោស ហើយសំដែងដោយសមគួរតាមធម៌ហើយ ដល់នូវការសង្រួមតទៅ នេះ ជាសេចក្តីចម្រើនរបស់បុគ្គលនោះ ក្នុងអរិយវិន័យ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគួរបាននូវឧបសម្បទាក្នុងសំណាក់ព្រះមានព្រះភាគ ។ ម្នាលភិក្ខុ ចុះបាត្រនិងចីវររបស់អ្នក មានគ្រប់គ្រាន់ហើយឬ ។ បពិត្រព្រះអង្គដ៏ចម្រើន បាត្រនិងចីវររបស់ខ្ញុំព្រះអង្គ មិនទាន់មានគ្រប់គ្រាន់ទេ ។ ម្នាលភិក្ខុ ព្រះតថាគតទាំងឡាយ មិនដែលឲ្យឧបសម្បទា ដល់កុលបុត្ត ដែលមានបាត្រនិងចីវរមិនគ្រប់គ្រាន់ទេ ។

[១៧១] គ្រានោះឯង បុក្កុសាតិមានអាយុ ត្រេកអរ រីករាយនឹងភាសិតរបស់ព្រះមានព្រះភាគ ក្រោកអំពីអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ហើយធ្វើប្រទក្សិណចៀសចេញទៅកាន់ទីស្វែងរកបាត្រនិងចីវរ ។ គ្រាកាលដែលបុក្កុសាតិមានអាយុ កំពុងត្រាច់ទៅកាន់ទីស្វែងរកបាត្រនិងចីវរ មេគោក៏មកបុះផ្តាច់ជីវិតទៅ ។ គ្រានោះឯងភិក្ខុច្រើនរូប នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ទើបក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។

ឯកាមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ យោ សោ ភន្តេ បុក្កុសាតិ នាម កុលបុត្តោ ភគវតា សង្ខិត្តេន ឱវាទេន ឱវទិតោ សោ កាលកតោ តស្ស កា គតិ កោ អភិសម្បរាយោតិ ។

[១៧២] បណ្ឌិតោ ភិក្ខវេ បុក្កុសាតិ កុលបុត្តោ បច្ចបាទិ ធម្មស្សានុធម្មំ ន ច មំ ធម្មាធិករណំ វិហេបេសិ បុក្កុសាតិ ភិក្ខវេ កុលបុត្តោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកោ តត្ថ បរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកាតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

ធាតុវិភង្គសុត្តំ ទសមំ និដ្ឋិតំ ។

លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន កុលបុត្តឈ្មោះបុក្កុសាតិណា ដែលព្រះមានព្រះភាគ ទ្រង់ប្រដៅដោយឱវាទសង្ខេប បុក្កុសាតិកុលបុត្តនោះ ធ្វើមរណកាលទៅហើយ ចុះគតិនិងបរលោករបស់បុក្កុសាតិកុលបុត្តនោះ តើដូចម្តេច ។

[១៧២] ម្នាលភិក្ខុទាំងឡាយ បុក្កុសាតិកុលបុត្តជាបណ្ឌិត បានដល់នូវធម៌សមគួរដល់ធម៌ មិនបាច់ញុំាងតថាគតឲ្យនឿយព្រួយ ព្រោះធម៌ជាហេតុ ម្នាលភិក្ខុទាំងឡាយ បុក្កុសាតិកុលបុត្តជាឱបបាតិកៈ ព្រោះអស់ទៅនៃឱរម្ភាគិយសំយោជនៈទាំង ៥ ហើយបរិនិព្វាន ក្នុងលោកនោះតែម្តង មានសភាពមិនបានត្រឡប់ចាកលោកនោះមកវិញឡើយ ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់សូត្រនេះចប់ហើយ ភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអរ រីករាយ នឹងភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ ធាតុវិភង្គសូត្រ ជាគម្រប់ ១០ ។

# ឯកាទសមំ សច្ចវិភង្គសុត្តំ

[១៧៣] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា ពារាណសិយំ វិហរតិ ឥសិបតនេ មិគទាយេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

[១៧៤] ភគវា ឯតទវោច តថាគតេន ភិក្ខវេ អរហតា សម្មាសម្ពុទ្ធេន ពារាណសិយំ ឥសិបតនេ មិគទាយេ អនុត្តរំ ធម្មចក្កំ បវត្តិតំ អប្បដិវត្តិយំ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មឹ យទិទំ ចតុន្នំ អរិយសច្ចានំ អាចិក្ខនា ទេសនា បញ្ញាបនា បដ្ឋបនា វិវរណា វិភជនា ឧត្តានីកម្មំ កតមេសំ ចតុន្នំ ទុក្ខស្ស អរិយសច្ចស្ស អាចិក្ខនា ទេសនា បញ្ញាបនា បដ្ឋបនា វិវរណា វិភជនា ឧត្តានីកម្មំ

# សច្ចវិភង្គសូត្រ ទី ១១

[១៧៣] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ។ ក្នុងទីនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[១៧៤] ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំង-ឡាយ ធម្មចក្រដ៏ប្រសើរ ដែលតថាគតជាអរហន្តសម្មាសម្ពុទ្ធឲ្យប្រព្រឹត្តទៅក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ជាធម្មចក្រ ដែលសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី នរណាមួយក្តី ក្នុងលោក មិនអាចធ្វើបដិវត្តិបាន គឺការប្រាប់ ការសំដែង ការបញ្ញាក់ ការតែងតាំង ការបើក ការវែកញែកនិងការធ្វើឲ្យងាយ នូវអរិយសច្ចទាំង ៤ អរិយសច្ចទាំង ៤ តើដូចម្តេច គឺការប្រាប់ ការសំដែង ការបញ្ញាក់ ការតែងតាំង ការបើក ការវែកញែក និងការធ្វើឲ្យងាយ នូវទុក្ខអរិយសច្ច ១

ទុក្ខសមុទយស្ស អរិយសច្ចស្ស អាចិក្ខនា ទេសនា បញ្ញាបនា បដ្ឋបនា វិវរណា វិភជនា ឧត្តានីកម្មំ ទុក្ខនិរោធស្ស អរិយសច្ចស្ស អាចិក្ខនា ទេសនា បញ្ញាបនា បដ្ឋបនា វិវរណា វិភជនា ឧត្តានីកម្មំ ទុក្ខនិរោធគាមិនិយា បដិបទាយ អរិយសច្ចស្ស អាចិក្ខនា ទេសនា បញ្ញាបនា បដ្ឋបនា វិវរណា វិភជនា ឧត្តានីកម្មំ តថាគតេន ភិក្ខវេ អរហតា សម្មាសម្ពុទ្ធេន ពារាណសិយំ ឥសិបតនេ មិគទាយេ អនុត្តរំ ធម្មចក្កំ បវត្តិតំ អប្បដិវត្តិយំ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មឹ យទិទំ ឥមេសំ ចតុន្នំ អរិយសច្ចានំ អាចិក្ខនា ទេសនា បញ្ញាបនា បដ្ឋ-បនា វិវរណា វិភជនា ឧត្តានីកម្មំ ។ សេវថ ភិក្ខវេ សារីបុត្តមោគ្គល្លានេ ភជថ ភិក្ខវេ សារីបុត្តមោគ្គល្លា-នេ បណ្ឌិតា ភិក្ខូ អនុគ្គាហកា សព្រហ្មចារីនំ ។

ការប្រាប់ ការសំដែង ការបញ្ញាក់ ការតែងតាំង ការបើក ការវែកញែក និងការធ្វើឲ្យងាយ នូវទុក្ខសមុទយអរិយសច្ច ១ ការប្រាប់ ការសំដែង ការបញ្ញាក់ ការតែងតាំង ការបើក ការវែកញែក និងការធ្វើឲ្យងាយ នូវទុក្ខនិរោធអរិយសច្ច ១ ការប្រាប់ ការសំដែង ការបញ្ញាក់ ការតែងតាំង ការបើក ការវែកញែក និងការធ្វើឲ្យងាយ នូវទុក្ខនិរោធគាមិនីបដិ-បទាអរិយសច្ច ១ ម្នាលភិក្ខុទាំងឡាយ ធម្មចក្រដ៏ប្រសើរ ដែលតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ឲ្យប្រព្រឹត្តទៅក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ជាធម្មចក្រដែលសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី នរណាមួយក្តី ក្នុងលោក មិនអាចធ្វើបដិវត្តិបាន គឺការប្រាប់ ការសំដែង ការបញ្ញាក់ ការតែងតាំង ការបើក ការវែកញែក និងការធ្វើឲ្យងាយ នូវអរិយសច្ចទាំង ៤ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរសេពនូវសារីបុត្តនិងមោគ្គល្លានចុះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរគប់រកសារីបុត្តនិងមោគ្គល្លានចុះ ព្រោះសារីបុត្តនិងមោគ្គល្លាន ជាបណ្ឌិតភិក្ខុ ជាអ្នកអនុគ្រោះសព្រហ្មចារីទាំងឡាយ ។

សេយ្យថាបិ ភិក្ខវេ ជនេតា ឯវំ សារីបុត្តោ ។ សេយ្យថាបិ ជាតស្ស អាចាទេតា ឯវំ មោគ្គល្លានោ ។ សារីបុត្តោ ភិក្ខវេ សោតាបត្តិផលេ វិនេតិ មោគ្គល្លានោ ឧត្តមត្ថេ សារីបុត្តោ ភិក្ខវេ បហោតិ ចត្តារិ អរិយសច្ចានិ វិត្ថារេន អាចិក្ខិតុំ ទេសេតុំ បញ្ញាបេតុំ បដ្ឋបេតុំ វិវរិតុំ វិភជិតុំ ឧត្តានីកាតុន្តិ ។ ឥទមវោច ភគវា ឥទំ វត្វាន សុគតោ ឧដ្ឋាយាសនា វិហារំ បាវិសិ ។

[១៧៤] តត្រ ខោ អាយស្មា សារីបុត្តោ អចិរប្បក្កន្តស្ស ភគវតោ ភិក្ខូ អាមន្តេសិ អាវុសោ ភិក្ខវោតិ ។ អាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស បច្ចស្សោសុំ ។ អាយស្មា សារីបុត្តោ ឯតទវោច តថាគតេន អាវុសោ អរហតា សម្មាសម្ពុទ្ធេន ពារាណសិយំ ឥសិបតនេ មិគទាយេ អនុត្តរំ ធម្មចក្កំ បវត្តិតំ អប្បដិវត្តិយំ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា

ម្នាលភិក្ខុទាំងឡាយ សារីបុត្តប្រៀបដូចជាម្ដាយបង្កើតកូន ។ មោគ្គល្លាន ប្រៀបដូចជាអ្នកចិញ្ចឹមកូនដែលកើតហើយ ។ ម្នាលភិក្ខុទាំងឡាយ សារីបុត្ត ទូន្មានបុគ្គលក្នុងសោតាបត្តិផល មោគ្គល្លាន ទូន្មានបុគ្គលក្នុងប្រយោជន៍ដ៏ខ្ពង់ខ្ពស់ ម្នាលភិក្ខុទាំងឡាយ សារីបុត្ត អាចប្រាប់ សំដែង បញ្ញាក់ តែងតាំង បើក វែកញែក ធ្វើឲ្យងាយ នូវអរិយសច្ចទាំង ៤ ដោយពិស្ដារបាន ។ ព្រះមានព្រះភាគ បានសំដែងពាក្យនេះរួចហើយ លុះព្រះសុគត ទ្រង់សំដែងសេចក្ដីនេះរួចហើយ ក៏ក្រោកអំពីអាសនៈ ហើយស្ដេចចូលទៅកាន់វិហារ ។

[១៧៥] កាលដែលព្រះមានព្រះភាគ ស្ដេចចៀសចេញទៅមិនយូរប៉ុន្មាន ព្រះសារីបុត្តមានអាយុ ក៏ហៅភិក្ខុទាំងឡាយក្នុងទីនោះថា នែអាវុសោភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ក៏ទទួលពាក្យព្រះសារីបុត្តមានអាយុថា អើអាវុសោ ។ ព្រះសារីបុត្តមានអាយុពោលដូច្នេះថា នែអាវុសោទាំងឡាយ ធម្មចក្រដ៏ប្រសើរ ដែលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់បានឲ្យប្រព្រឹត្តទៅក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ជាធម្មចក្រដែលសមណៈក្ដី ព្រាហ្មណ៍ក្ដី ទេវតាក្ដី មារក្ដី

ព្រហ្មំ វា កោនចិ វា លោកស្មឹ យមិទំ ចតុន្នំ អរិយសច្ចានំ អាចិក្ខនា ទេសនា បញ្ញាបនា បដ្ឋបនា វិវរណា វិភជនា ឧត្តានីកម្មំ កតមេសំ ចតុន្នំ ទុក្ខស្ស អរិយសច្ចស្ស អាចិក្ខនា ទេសនា បញ្ញាបនា បដ្ឋបនា វិវរណា វិភជនា ឧត្តានីកម្មំ ទុក្ខសមុទយស្ស អរិយសច្ចស្ស អាចិក្ខនា ទេសនា បញ្ញាបនា បដ្ឋបនា វិវរណា វិភជនា ឧត្តានីកម្មំ ទុក្ខនិរោធស្ស អរិយសច្ចស្ស អាចិក្ខនា ទេសនា បញ្ញាបនា បដ្ឋបនា វិវរណា វិភជនា ឧត្តានីកម្មំ ទុក្ខនិរោធគាមិនិយា បដិបទាយ អរិយសច្ចស្ស អាចិក្ខនា ទេសនា បញ្ញាបនា បដ្ឋបនា វិវរណា វិភជនា ឧត្តានីកម្មំ ។

ព្រហ្មក្តី នរណាមួយក្តី ក្នុងលោក មិនអាចធ្វើបដិវត្តិបាន គឺការប្រាប់ ការសំដែង ការបញ្ញាក់ ការតែងតាំង ការបើក ការវែកញែក និងការធ្វើឲ្យរាក់ នូវអរិយសច្ចទាំង ៤ អរិយសច្ចទាំង ៤ តើដូចម្តេច គឺការប្រាប់ ការសំដែង ការបញ្ញាក់ ការតែងតាំង ការបើក ការវែកញែក និងការធ្វើឲ្យរាក់ នូវទុក្ខអរិយសច្ច ១ ការប្រាប់ ការសំដែង ការបញ្ញាក់ ការតែងតាំង ការបើក ការវែកញែក និងការធ្វើឲ្យរាក់ នូវទុក្ខសមុទយអរិយសច្ច ១ ការប្រាប់ ការសំដែង ការបញ្ញាក់ ការតែងតាំង ការបើក ការវែកញែក និងការធ្វើឲ្យរាក់ នូវទុក្ខនិរោធអរិយ-សច្ច ១ ការប្រាប់ ការសំដែង ការបញ្ញាក់ ការតែងតាំង ការបើក ការវែកញែក និងការធ្វើឲ្យរាក់ នូវទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ១ ។

វិភង្គវគ្គស្ស សច្ចវិភង្គសុត្តេ ទុក្ខអរិយសច្ចំ

[១៧៦] កតមញ្ចាវុសោ ទុក្ខំ អរិយសច្ចំ ។ ជាតិបិ ទុក្ខា ជរាបិ ទុក្ខា មរណម្បិ ទុក្ខំ សោកបរិទេវទុក្ខទោមនស្សុបាយាសាបិ ទុក្ខា យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា ។ កតមា ចាវុសោ ជាតិ យា តេសំ តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជាតិ សញ្ជាតិ ឱក្កន្តិ និព្វត្តិ អភិនិព្វត្តិ ខន្ធានំ បាតុភាវោ អាយតនានំ បដិលាភោ អយំ វុច្ចតាវុសោ ជាតិ ។ កតមា ចាវុសោ ជរា យា តេសំ តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជរា ជីរណតា ខណ្ឌិច្ចំ បាលិច្ចំ វលិត្តចតា អាយុនោ សំហានិ ឥន្ទ្រិយានំ បរិបាកោ អយំ វុច្ចតាវុសោ ជរា ។ កតមញ្ចាវុសោ មរណំ យា តេសំ តេសំ សត្តានំ តម្ហា តម្ហា សត្តនិកាយា ចុតិ ចវនតា ភេទោ អន្តរធានំ មច្ចុ មរណំ កាលកិរិយា ខន្ធានំ ភេទោ កឡេវរស្ស និក្ខេបោ ជីវិតិន្ទ្រិយស្ស ឧបច្ឆេទោ ឥទំ វុច្ចតាវុសោ មរណំ ។

វិភង្គវគ្គ សច្ចវិភង្គសូត្រ ទុក្ខអរិយសច្ច

[១៧៦] ម្នាលអាវុសោទាំងឡាយ ទុក្ខអរិយសច្ច តើដូចម្តេច ។ ជាតិទុក្ខ ១ ជរាទុក្ខ ១ មរណទុក្ខ ១ សោកទុក្ខ ១ បរិទេវទុក្ខ ១ ទុក្ខទុក្ខ ១ ទោមនស្សទុក្ខ ១ ឧបាយាសទុក្ខ ១ យម្បិច្ឆំ ន លភតិ តម្បិទុក្ខ ១ ដោយបំប្រួញ បញ្ចុបាទានក្ខន្ធឈ្មោះថាទុក្ខ ។ ម្នាលអាវុ-សោទាំងឡាយ ជាតិ តើដូចម្តេច ការកើត ការកើតព្រម ការចុះកាន់គភ៌ ការប្រព្រឹត្តទៅមិនដាច់ ការវិលត្រឡប់ ការកើតប្រាកដនៃខន្ធ និងការបានចំពោះនូវអាយតនៈ ណា របស់ពួកសត្វនោះ ៗ ក្នុងសត្តនិកាយនោះ ៗ ម្នាលអាវុសោទាំងឡាយ នេះហៅថា ជាតិ ។ ម្នាលអាវុសោទាំងឡាយ ជរា តើដូចម្តេច សេចក្តីចាស់ ភាពគ្រាំគ្រា ធ្មេញបាក់ សក់ស្កូវ ស្បែកជ្រួញជ្រីវយុរយារ ការថយអាយុ ការចាស់ជោរនៃឥន្ទ្រិយ ណា របស់ពួកសត្វនោះ ៗ ក្នុងសត្តនិកាយនោះ ៗ ម្នាលអាវុសោទាំងឡាយ នេះហៅថា ជរា ។ ម្នាលអាវុសោទាំងឡាយ មរណៈ តើដូចម្តេច ការច្យុត ការឃ្លាតចាកសត្តនិកាយនោះ ៗ ការបែកធ្លាយ ការបាត់បង់ សេចក្តីស្លាប់ មរណៈ កាលកិរិយា ការបែកធ្លាយខន្ធ ការដាក់ចុះនូវសាកសព ការផ្តាច់បង់នូវជីវិតិន្ទ្រិយ ណា របស់ពួកសត្វនោះ ៗ ម្នាលអាវុសោទាំងឡាយ នេះហៅថា មរណៈ ។

កតមោ ចាវុសោ សោកោ យោ ខោ អាវុសោ អញ្ញតរញ្ញតរេន ព្យសនេន សមន្នាគតស្ស អញ្ញត-រញ្ញតរេន ទុក្ខធម្មេន ផុដ្ឋស្ស សោកោ សោចនា សោចិតត្តំ អន្តោសោកោ អន្តោបរិសោកោ អយំ វុច្ចតាវុសោ សោកោ ។ កតមោ ចាវុសោ បរិ-ទេវោ យោ ខោ អាវុសោ អញ្ញតរញ្ញតរេន ព្យស-នេន សមន្នាគតស្ស អញ្ញតរញ្ញតរេន ទុក្ខធម្មេន ផុដ្ឋស្ស អាទេវោ បរិទេវោ អាទេវនា បរិទេវនា អា-ទេវិតត្តំ បរិទេវិតត្តំ អយំ វុច្ចតាវុសោ បរិទេវោ ។ កតមញ្ចាវុសោ ទុក្ខំ យំ ខោ អាវុសោ កាយិកំ ទុក្ខំ កាយិកំ អសាតំ កាយសម្ផស្សជំ ទុក្ខំ អសាតំ វេទយិតំ ឥទំ វុច្ចតាវុសោ ទុក្ខំ ។

ម្នាលអាវុសោទាំងឡាយ សោក: តើដូចម្តេច ម្នាលអាវុសោទាំងឡាយ សេចក្តីស្ងួតស្ងប់ ការស្រពោនស្រពាប់ ការស្រណោះស្រណោក ការក្រៀមក្រំខាងក្នុង ការសង្រេងសង្រៃខាងក្នុង ណា របស់សត្វ ដែលប្រកបដោយសេចក្តីវិនាសណាមួយ ឬត្រូវសេចក្តីទុក្ខណាមួយប៉ះពាល់ហើយ ម្នាលអាវុសោទាំងឡាយ នេះហៅថា សោក: ។ ម្នាលអាវុសោទាំងឡាយ បរិទេវ: តើដូចម្តេច ម្នាលអាវុសោទាំងឡាយ ទំនួញ ការទួញរៀបរាប់ ការត្អូញត្អែរ ការយំយែក ការអណ្តឺតអណ្តក ការយំរៀបរាប់ ណា របស់សត្វដែលប្រកបដោយសេចក្តីវិនាសណាមួយ ឬត្រូវសេចក្តីទុក្ខណាមួយប៉ះពាល់ហើយ ម្នាលអាវុសោទាំងឡាយ នេះហៅថា បរិទេវ: ។ ម្នាលអាវុសោទាំងឡាយ ទុក្ខ: តើដូចម្តេច ម្នាលអាវុសោទាំងឡាយ សេចក្តីលំបាក ការមិនសប្បាយកាយ សេចក្តីទុក្ខកើតអំពីកាយសម្ផស្ស ការទទួលអារម្មណ៍មិនជាទីសប្បាយ ណា ម្នាលអាវុសោទាំងឡាយ នេះហៅថា ទុក្ខ: ។

២០៧



កតមញ្ចាវុសោ ទោមនស្សំ យំ ខោ អាវុសោ ចេតសិកំ ទុក្ខំ ចេតសិកំ អសាតំ មនោសម្ផស្សជំ ទុក្ខំ អសាតំ វេទយិតំ ឥទំ វុច្ចតាវុសោ ទោមនស្សំ ។ កតមោ ចាវុសោ ឧបាយាសោ យោ ខោ អាវុសោ អញ្ញតរញ្ញតរេន ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន ទុក្ខធម្មេន ផុដ្ឋស្ស អាយាសោ ឧបាយាសោ អាយាសិតត្តំ ឧបាយាសិតត្តំ អយំ វុច្ចតាវុសោ ឧបាយាសោ ។ កតមញ្ចាវុសោ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ ជាតិធម្មានំ អាវុសោ សត្តានំ ឯវំ ឥច្ឆា ឧប្បជ្ជតិ អហោ វត មយំ ន ជាតិធម្មា អស្សាម ន ច វត នោ ជាតិ អាគច្ឆេយ្យាតិ ន ខោ បនេតំ ឥច្ឆាយ បត្តព្វំ ឥទម្បិ

ម្នាលអាវុសោទាំងឡាយ ទោមនស្ស តើដូចម្តេច ម្នាលអាវុសោទាំង-ឡាយ សេចក្តីលំបាកក្នុងចិត្ត ការមិនសប្បាយចិត្ត សេចក្តីទុក្ខកើតអំពីមនោសម្ផស្ស ការទទួលអារម្មណ៍មិនជាទីសប្បាយ ណា ម្នាលអាវុសោទាំងឡាយ នេះហៅថា ទោមនស្ស ។ ម្នាលអាវុសោទាំងឡាយ ឧបាយាសៈ តើដូចម្តេច ម្នាលអាវុសោទាំងឡាយ សេចក្តីតានតឹងការចង្អៀតចិត្ត ការខ្នាំងខ្នាស់ ការតឹងចិត្ត ណា របស់សត្វ ដែលប្រ-កបដោយសេចក្តីវិនាសណាមួយ ឬត្រូវសេចក្តីទុក្ខណាមួយប៉ះពាល់ហើយ ម្នាលអាវុសោទាំងឡាយ នេះហៅថា ឧបាយាសៈ ។ ម្នាលអាវុសោទាំងឡាយ យម្បិច្ឆំ ន លភតិ តម្បិទុក្ខ តើដូចម្តេច ម្នាលអាវុសោទាំងឡាយ ពួកសត្វដែលមានជាតិជាធម្មតា រមែងមានសេចក្តីប្រាថ្នាយ៉ាងនេះថា ឱហ្ន៎ សូមឲ្យយើងទាំងឡាយ កុំគប្បីជាអ្នកមានជាតិជាធម្មតាឡើយ ពុំនោះសោត ជាតិកុំគប្បីមកដល់យើងទាំងឡាយឡើយ អំពើនុ៎ះឯង ក៏សត្វទាំងឡាយ មិនគប្បីដល់តាមសេចក្តីប្រាថ្នាឡើយ នេះ

យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ ជរាធម្មានំ អាវុសោ សត្តានំ... ព្យាធិធម្មានំ អាវុសោ សត្តានំ... មរណធម្មានំ អាវុសោ សត្តានំ... សោកបរិទេវទុក្ខទោមនស្សុបាយាសធម្មានំ អាវុសោ សត្តានំ ឯវំ ឥច្ឆា ឧប្បជ្ជតិ អហោ វត មយំ ន សោកបរិទេវទុក្ខទោមនស្សុបាយាសធម្មា អស្សាម ន ច វត នោ សោកបរិទេវទុក្ខទោមនស្សុបាយាសា អាគច្ឆេយ្យុន្តិ ន ខោ បនេតំ ឥច្ឆាយ បត្តព្វំ ឥទម្បិ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ ។ កតមេ ចាវុសោ សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា សេយ្យថីទំ រូបុបាទានក្ខន្ធោ វេទនុបាទានក្ខន្ធោ សញ្ញុបាទានក្ខន្ធោ សង្ខារុបាទានក្ខន្ធោ វិញ្ញាណុបាទានក្ខន្ធោ ឥមេ វុច្ចន្តាវុសោ សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា ។ ឥទំ វុច្ចតាវុសោ ទុក្ខំ អរិយសច្ចំ ។

ហៅថា យម្បិច្ឆំ ន លភតិ តម្បិទុក្ខំដែរ ម្នាលអាវុសោទាំងឡាយ ពួកសត្វដែលមានជរាជាធម្មតា... ម្នាលអាវុសោទាំងឡាយ ពួកសត្វដែលមានព្យាធិជាធម្មតា... ម្នាលអាវុសោទាំងឡាយ ពួកសត្វដែលមានសេចក្តីស្លាប់ជាធម្មតា... ម្នាលអាវុសោទាំងឡាយ ពួកសត្វដែលមានសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ជាធម្មតា រមែងមានសេចក្តីប្រាថ្នាកើតឡើងយ៉ាងនេះថា ឱហ្ន៎ សូមឲ្យយើងទាំងឡាយ កុំគប្បីជាអ្នកមានសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ចិត្តជាធម្មតាឡើយ ពុំនោះសោត សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ កុំគប្បីមក ដល់យើងទាំងឡាយឡើយ អំពើនុ៎ះឯងក៏សត្វទាំងឡាយ មិនគប្បីដល់តាមសេចក្តីប្រាថ្នាឡើយ នេះហៅថា យម្បិច្ឆំ ន លភតិ តម្បិទុក្ខំដែរ ។ ម្នាលអាវុសោទាំងឡាយ ដោយបំប្រួញ បញ្ចុបាទានក្ខន្ធ ឈ្មោះថាទុក្ខ តើដូចម្តេច រូបជាឧបាទានក្ខន្ធ ១ វេទនាជាឧបាទានក្ខន្ធ ១ សញ្ញាជាឧបាទានក្ខន្ធ ១ សង្ខារជាឧបាទានក្ខន្ធ ១ វិញ្ញាណជាឧបាទានក្ខន្ធ ១ ម្នាលអាវុសោទាំងឡាយ ទាំងនេះហៅថា បញ្ចុបាទានក្ខន្ធទុក្ខ ដោយបំប្រួញ ។ ម្នាលអាវុសោទាំងឡាយ នេះហៅថា ទុក្ខអរិយសច្ច ។

[១៧៧] កតមញ្ចាវុសោ ទុក្ខសមុទយោ អរិយសច្ចំ ។ យាយំ តណ្ហា បោនោព្ភវិកា នន្ទិរាគសហគតា តត្រតត្រាភិនន្ទិនី សេយ្យថីទំ កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ឥទំ វុច្ចតាវុសោ ទុក្ខសមុទយោ អរិយសច្ចំ ។

[១៧៨] កតមញ្ចាវុសោ ទុក្ខនិរោធោ អរិយសច្ចំ ។ យោ តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធោ ចាគោ បដិនិស្សគ្គោ មុត្តិ អនាលយោ ឥទំ វុច្ចតាវុសោ ទុក្ខនិរោធោ អរិយសច្ចំ ។

[១៧៩] កតមញ្ចាវុសោ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ ។ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ

[១៧៧] ម្នាលអាវុសោទាំងឡាយ ទុក្ខសមុទយអរិយសច្ច តើដូចម្តេច ។ តណ្ហាណា ដែលនាំសត្វទៅកើតទៀត ប្រកបព្រម ដោយសេចក្តីត្រេកត្រអាល មានសេចក្តីត្រេកអរ ក្នុងភពនោះ ៗ គឺ កាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ម្នាលអាវុសោទាំងឡាយ នេះហៅថា ទុក្ខសមុទយអរិយសច្ច ។

[១៧៨] ម្នាលអាវុសោទាំងឡាយ ទុក្ខនិរោធអរិយសច្ច តើដូចម្តេច ។ សេចក្តីវិនាសនិងការរលត់មិនមានសល់ នៃតណ្ហានោះឯង កិរិយាលះបង់ ការរលាស់ចោល ការជម្រុះចោល នូវតណ្ហានោះឯង ការមិនអាល័យ ក្នុងតណ្ហានោះឯង ណា ម្នាលអាវុសោទាំងឡាយ នេះហៅថា ទុក្ខនិរោធអរិយសច្ច ។

[១៧៩] ម្នាលអាវុសោទាំងឡាយ ទុក្ខនិរោធគាមិនីបដិបទា-អរិយសច្ច តើដូចម្តេច ។ អរិយមគ្គប្រកបដោយអង្គ ៨ ប្រការនេះឯង គឺសេចក្តីយល់ឃើញត្រូវ ១ សេចក្តីត្រិះរិះត្រូវ ១ វាចាត្រូវ ១ ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ ព្យាយាមត្រូវ ១ សេចក្តីរលឹកត្រូវ ១

សម្មាសមាធិ ។ កតមា ចាវុសោ សម្មាទិដ្ឋិ យំ ខោ អាវុសោ ទុក្ខេ ញាណំ ទុក្ខសមុទយេ ញាណំ ទុក្ខនិរោធេ ញាណំ ទុក្ខនិរោធគាមិនិយា បដិបទាយ ញាណំ អយំ វុច្ចតាវុសោ សម្មាទិដ្ឋិ ។ កតមោ ចាវុសោ សម្មាសង្កប្បោ នេក្ខម្មសង្កប្បោ អព្យាបាទសង្កប្បោ អវិហឹសាសង្កប្បោ អយំ វុច្ចតាវុសោ សម្មាសង្កប្បោ ។ កតមា ចាវុសោ សម្មាវាចា មុសាវាទា វេរមណី បិសុណាយ វាចាយ វេរមណី ផរុសាយ វាចាយ វេរមណី សម្ផប្បលាបា វេរមណី អយំ វុច្ចតាវុសោ សម្មាវាចា ។ កតមោ ចាវុសោ សម្មាកម្មន្តោ បាណាតិបាតា វេរមណី អទិន្នាទានា វេរមណី កាមេសុមិច្ឆាចារា វេរមណី

ការតម្កល់ចិត្តត្រូវ ១ ។ ម្នាលអាវុសោទាំងឡាយ សេចក្តីយល់ឃើញត្រូវ តើដូចម្តេច ម្នាលអាវុសោទាំងឡាយ សេចក្តីដឹងក្នុងកងទុក្ខ សេចក្តីដឹងក្នុងហេតុឲ្យកើតទុក្ខ សេចក្តីដឹងក្នុងធម៌រំលត់ទុក្ខ សេចក្តីដឹងក្នុងសេចក្តីប្រតិបត្តិដើម្បីរំលត់ទុក្ខ ម្នាលអាវុសោទាំងឡាយ នេះហៅថា សេចក្តីយល់ឃើញត្រូវ ។ ម្នាលអាវុសោទាំងឡាយ សេចក្តីត្រិះរិះត្រូវ តើដូចម្តេច សេចក្តីត្រិះរិះដើម្បីចេញចាកកាម ១ សេចក្តីត្រិះរិះដើម្បីមិនព្យាបាទ ១ សេចក្តីត្រិះរិះដើម្បីមិនបៀតបៀន ១ ម្នាលអាវុសោទាំងឡាយ នេះហៅថា សេចក្តីត្រិះរិះត្រូវ ។ ម្នាលអាវុសោទាំងឡាយ វាចាត្រូវ តើដូចម្តេច ការវៀរចាកសំដីកុហក ១ ការវៀរចាកសំដីញុះញង់ ១ ការវៀរចាកសំដីទ្រគោះ ១ ការវៀរចាកពាក្យពេយរាយឥតប្រយោជន៍ ១ ម្នាលអាវុសោទាំងឡាយ នេះហៅថា វាចាត្រូវ ។ ម្នាលអាវុសោទាំងឡាយ ការងារត្រូវ តើដូចម្តេច ការវៀរចាកបាណាតិបាត ១ ការវៀរចាកអទិន្នាទាន ១ ការវៀរចាកកាមេសុមិច្ឆាចារ ១

អយំ វុច្ចតាវុសោ សម្មាកម្មន្តោ ។ កតមោ ចាវុសោ សម្មាអាជីវោ ឥធាវុសោ អរិយសាវកោ មិច្ឆាអាជីវំ បហាយ សម្មាអាជីវេន ជីវិកំ កប្បេតិ អយំ វុច្ចតាវុសោ សម្មាអាជីវោ ។ កតមោ ចាវុសោ សម្មាវាយាមោ ឥធាវុសោ ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ

ម្នាលអាវុសោទាំងឡាយ នេះហៅថា ការងារត្រូវ ។ ម្នាលអាវុសោទាំងឡាយ ការចិញ្ចឹមជីវិតត្រូវ តើដូចម្តេច ម្នាលអាវុសោទាំងឡាយ អរិយសាវ័ក ក្នុងសាសនានេះ លះបង់នូវការចិញ្ចឹមជីវិតខុស ហើយសម្រេចជីវិតដោយការចិញ្ចឹមជីវិតត្រូវ ម្នាលអាវុសោទាំងឡាយ នេះហៅថា ការចិញ្ចឹមជីវិតត្រូវ ។ ម្នាលអាវុសោទាំងឡាយ ព្យាយាមត្រូវ តើដូចម្តេច ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈឲ្យកើតឡើង ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តម្កល់ចិត្ត ដើម្បីញុំាងអកុសលធម៌ដ៏លាមកទាំងឡាយ ដែលមិនទាន់កើត មិនឲ្យកើតឡើងបាន ញុំាងឆន្ទៈឲ្យកើតឡើង ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តម្កល់ចិត្ត ដើម្បីលះបង់នូវអកុសលធម៌ដ៏លាមកទាំងឡាយ ដែលកើតឡើងហើយ ញុំាងឆន្ទៈឲ្យកើតឡើង ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តម្កល់ចិត្ត ដើម្បីញុំាងកុសលធម៌ទាំងឡាយ ដែលមិនទាន់កើតឡើង ឲ្យកើតឡើង ញុំាងឆន្ទៈឲ្យកើតឡើង ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តម្កល់ចិត្ត ដើម្បីញុំាងកុសលធម៌ទាំងឡាយ ដែលកើតឡើងហើយ ឲ្យបានឋិតថេរនៅ មិនឲ្យវិនាសទៅវិញ ឲ្យបានចម្រើនធំទូលាយ ឲ្យកើតបរិបូណ៌

អយំ វុច្චតាវុសោ សម្មាវាយាមោ ។ កតមា ចាវុសោ សម្មាសតិ ឥធាវុសោ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ វេទនាសុ វេទនានុបស្សី វិហរតិ ។ បេ ។ ចិត្តេ ចិត្តានុបស្សី ។ បេ ។ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ អយំ វុច្ចតាវុសោ សម្មាសតិ ។ កតមោ ចាវុសោ សម្មាសមាធិ ឥធាវុសោ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ...

ម្នាលអាវុសោទាំងឡាយ នេះហៅថា ព្យាយាមត្រូវ ។ ម្នាលអាវុសោ ទាំងឡាយ សេចក្តីរលឹកត្រូវ តើដូចម្តេច ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញរឿយ ៗ នូវកាយក្នុងកាយ មាន ព្យាយាមដុតកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី បន្ទោបង់នូវ អភិជ្ឈានិងទោមនស្សក្នុងលោក ពិចារណាឃើញរឿយ ៗ នូវវេទនាក្នុង វេទនាទាំងឡាយ ។ បេ ។ ពិចារណាឃើញរឿយ ៗ នូវចិត្តក្នុងចិត្ត ។ បេ ។ ពិចារណាឃើញរឿយ ៗ នូវធម៌ក្នុងធម៌ទាំងឡាយ មាន ព្យាយាមដុតកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី បន្ទោបង់នូវ អភិជ្ឈានិងទោមនស្សក្នុងលោក ម្នាលអាវុសោទាំងឡាយ នេះហៅថា សេចក្តីរលឹកត្រូវ ។ ម្នាលអាវុសោទាំងឡាយ ការតម្កល់ចិត្តត្រូវ តើដូច ម្តេច ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាម ទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ បានដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ មានបីតិនិងសុខ ដែលកើតអំពី សេចក្តីស្ងាត់ ក៏សម្រេចសម្រាន្តនៅគ្រប់ឥរិយាបថ ភិក្ខុបានដល់នូវទុតិ- យជ្ឈាន ជាធម្មជាតកើតមានក្នុងសន្តានចិត្ត ប្រកបដោយសេចក្តីជ្រះថ្លា គឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មាន តែបីតិនិងសុខៈកើតអំពីសមាធិគឺបឋមជ្ឈាន ព្រោះរម្ងាប់វិតក្កៈនិងវិចារៈ . . .

២១៣



តតិយំ ឈានំ... ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ អយំ វុច្ចតាវុសោ សម្មាសមាធិ ។ ឥទំ វុច្ចតាវុសោ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ ។

[១៨០] តថាគតេនាវុសោ អរហតា សម្មាសម្ពុទ្ធេន ពារាណសិយំ ឥសិបតនេ មិគទាយេ អនុត្តរំ ធម្មចក្កំ បវត្តិតំ អប្បដិវត្តិយំ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មឹ យទិទំ ឥមេសំ ចតុន្នំ អរិយសច្ចានំ អាចិក្ខនា ទេសនា បញ្ញាបនា បដ្ឋបនា វិវរណា វិភជនា ឧត្តានីកម្មន្តិ ។ ឥទមវោចាយស្មា សារីបុត្តោ អត្តមនា តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស ភាសិតំ អភិនន្ទុន្តិ ។

សច្ចវិភង្គសុត្តំ ឯកាទសមំ និដ្ឋិតំ ។

(បានដល់) នូវតតិយជ្ឈាន... បានដល់នូវចតុត្ថជ្ឈាន សម្រេចសម្រាន្ត នៅគ្រប់ឥរិយាបថ ម្នាលអាវុសោទាំងឡាយ នេះហៅថា ការតម្កល់ចិត្តត្រូវ ។ ម្នាលអាវុសោទាំងឡាយ នេះហៅថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ។

[១៨០] ម្នាលអាវុសោទាំងឡាយ ធម្មចក្រដ៏ប្រសើរ ដែលព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ឲ្យប្រព្រឹត្តទៅក្នុងឥសិបតនមិគទាយវ័នទៀបក្រុងពារាណសី ជាធម្មចក្រ ដែលសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី នរណាមួយក្តី ក្នុងលោក មិនអាចធ្វើបដិវត្តិបាន គឺការប្រាប់ ការសំដែង ការបញ្ញាក់ ការតែងតាំង ការបើក ការវែកញែក និងការធ្វើឲ្យងាយ នូវអរិយសច្ចទាំង ៤ នេះឯង ។ លុះព្រះសារីបុត្តមានអាយុ សំដែងព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងនោះក៏មានចិត្តត្រេកអរ រីករាយ នឹងភាសិតរបស់ព្រះសារីបុត្តមានអាយុ ។

ចប់ សច្ចវិភង្គសូត្រ ទី ១១ ។

# ទ្វាទសមំ ទក្ខិណាវិភង្គសុត្តំ

[១៨១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ និគ្រោធារាមេ ។ អថខោ មហាបជាបតី គោតមី នវំ ទុស្សយុគំ អាទាយ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នា ខោ មហាបជាបតី គោតមី ភគវន្តំ ឯត-ទវោច ឥទំ មេ ភន្តេ នវំ ទុស្សយុគំ ភគវន្តំ ឧទ្ទិស្ស សាមំ កន្តំ សាមំ វាយិតំ តំ មេ ភន្តេ ភគវា បដិគ្គណ្ហាតុ អនុកម្បំ ឧបាទាយាតិ ។

# ទក្ខិណាវិភង្គសូត្រ ទី ១២

[១៨១] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់ក្នុងនិគ្រោធារាម ជិតក្រុងកបិលព័ស្តុ ក្នុងដែនសក្កៈ ។ គ្រានោះ ព្រះនាងមហាបជាបតិគោតមី នាំយកសំពត់ថ្មី ១ គូ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់ក្នុងទីសមគួរ ។ លុះព្រះនាងមហាបជាបតិគោតមី គង់ក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សំពត់ថ្មី ១ គូនេះ ខ្ញុំម្ចាស់វៃខ្លួនឯង ត្បាញខ្លួនឯង ផ្តង់ចំពោះព្រះមានព្រះភាគ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគអាស្រ័យនូវសេចក្តីអនុគ្រោះចំពោះខ្ញុំម្ចាស់ ទទួលយកនូវសំពត់នោះ ។

វិភង្គវគ្គស្ស ទក្ខិណាវិភង្គសុត្តេ មហាបជាបតិយា អាយាចនំ

[១៨២] ឯវំ វុត្តេ ភគវា មហាបជាបតឹ គោតមឹ ឯតទវោច សង្ឃេ គោតមិ ទេហិ សង្ឃេ តេ ទិន្នេ អហញ្ចេវ បូជិតោ ភវិស្សាមិ សង្ឃោ ចាតិ ។ ទុតិយម្បិ ខោ មហាបជាបតី គោតមី ភគវន្តំ ឯតទវោច ឥទំ មេ ភន្តេ នវំ ទុស្សយុគំ ភគវន្តំ ឧទ្ទិស្ស សាមំ កន្តំ សាមំ វាយិតំ តំ មេ ភន្តេ ភគវា បដិគ្គណ្ហាតុ អនុកម្បំ ឧបាទាយាតិ ។ ទុតិយម្បិ ខោ ភគវា មហាបជាបតឹ គោតមឹ ឯត-ទវោច សង្ឃេ គោតមិ ទេហិ សង្ឃេ តេ ទិន្នេ

[១៨២] កាលបើព្រះនាងមហាបជាបតិគោតមី ក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះមានព្រះភាគ ក៏មានព្រះបន្ទូលនឹងព្រះនាងមហា-បជាបតិគោតមីដូច្នេះថា បពិត្រព្រះនាងគោតមី សូមព្រះនាងប្រគេន (សំពត់នេះ) ចំពោះសង្ឃវិញចុះ កាលបើព្រះនាងប្រគេនសំពត់នេះចំពោះសង្ឃហើយ តថាគតឈ្មោះថាព្រះនាងបានបូជាហើយផង ទាំងសង្ឃក៏ឈ្មោះថាព្រះនាងបានបូជាហើយដែរ ។ ព្រះនាងមហាបជាបតិ-គោតមី ក្រាបបង្គំទូលអង្វរព្រះមានព្រះភាគ អស់វារៈ ២ ដងដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សំពត់ថ្មី ១ គូនេះ ខ្ញុំម្ចាស់រវៃខ្លួនឯង ត្បាញខ្លួនឯង ឧទ្ទិសចំពោះព្រះមានព្រះភាគ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគអាស្រ័យនូវសេចក្តីអនុគ្រោះចំពោះខ្ញុំម្ចាស់ ទទួលយកនូវសំពត់នោះ ។ ព្រះមានព្រះភាគទ្រង់មានព្រះបន្ទូលនឹងព្រះនាងមហាបជាបតិគោតមី អស់វារៈ ២ ដងដូច្នេះថា បពិត្រព្រះនាងគោតមី សូមព្រះនាងប្រគេនសង្ឃវិញចុះ កាលបើព្រះនាងប្រគេនសង្ឃហើយ

២១៦



អហាញ្ចេវ បូជិតោ ភវិស្សាមិ សង្ឃោ ចាតិ ។ តតិ-
យម្បិ ខោ មហាបជាបតី គោតមី ភគវន្តំ ឯតទវោច
ឥទំ មេ ភន្តេ នវំ ទុស្សយុគំ ភគវន្តំ ឧទ្ទិស្ស
សាមំ កន្តំ សាមំ វាយិតំ តំ មេ ភន្តេ ភគវា
បដិគ្គណ្ហាតុ អនុកម្បំ ឧបាទាយាតិ ។ តតិយម្បិ
ខោ ភគវា មហាបជាបតឹ គោតមឹ ឯតទវោច
សង្ឃេ គោតមិ ទេហិ សង្ឃេ តេ ទិន្នេ អហាញ្ចេវ
បូជិតោ ភវិស្សាមិ សង្ឃោ ចាតិ ។

តថាគតក៏ឈ្មោះថាព្រះនាងបានបូជាហើយផង ទាំងសង្ឃក៏ឈ្មោះថាព្រះនាងបានបូជាហើយដែរ ។ ព្រះនាងមហាបជាបតិគោតមី ក្រាបបង្គំទូលព្រះមានព្រះភាគ អស់វារៈ ៣ ដងដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សំពត់ថ្មី ១ គូនេះ ខ្ញុំម្ចាស់រវៃខ្លួនឯង ត្បាញខ្លួនឯង ឧទ្ទិសចំពោះព្រះមានព្រះភាគ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគអាស្រ័យនូវសេចក្តីអនុគ្រោះចំពោះខ្ញុំម្ចាស់ ហើយទទួលយកនូវសំពត់នោះ ។ ព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលនឹងព្រះនាងមហាបជា-បតិគោតមី អស់វារៈ ៣ ដងដូច្នេះថា បពិត្រព្រះនាងគោតមី សូមព្រះនាងប្រគេនសង្ឃវិញចុះ កាលបើព្រះនាងប្រគេនសង្ឃហើយ តថាគតក៏ឈ្មោះថាព្រះនាងបានបូជាហើយផង ទាំងសង្ឃក៏ឈ្មោះថាព្រះនាងបានបូជាហើយដែរ ។

[១៨៣] ឯវំ វុត្តេ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច បដិគ្គណ្ហាតុ ភន្តេ ភគវា មហាបជាបតិយា គោតមិយា នវំ ទុស្សយុគំ ពហុការា ភន្តេ ម-ហាបជាបតី គោតមី ភគវតោ មាតុច្ឆា អាចាទិកា ចោសិកា ខីរស្ស ទាយិកា ភគវន្តំ ជនេត្តិ-យា កាលកតាយ ថញ្ញំ ចាយេសិ ភគវាបិ ភន្តេ ពហុការោ មហាបជាបតិយា គោតមិយា ភគវន្តំ ភន្តេ អាគម្ម មហាបជាបតី គោតមី ពុទ្ធំ សរណំ គតា ធម្មំ សរណំ គតា សង្ឃំ សរណំ គតា ភគវន្តំ ភន្តេ អាគម្ម មហាបជាបតី គោតមី ចាណាតិចាតា បដិវិរតា អទិន្នាទានា បដិវិរតា កាមេសុមិច្ឆាចារា បដិវិរតា មុសាវាទា បដិវិរតា សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតា

វិភង្គវគ្គ ទក្ខិណាវិភង្គសូត្រ កិរិយាអង្វរករនៃព្រះអានន្ទ

[១៨៣] កាលបើព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏ក្រាបបង្គំទូលអង្វរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់ទទួលសំពត់ថ្មី ១ គូ របស់ព្រះនាងមហាបជាបតិគោតមី បពិត្រព្រះអង្គដ៏ចម្រើន ព្រះនាងមហាបជាបតិគោតមី ជាអ្នកមានឧបការៈច្រើន ជាព្រះមាតុច្ឆារបស់ព្រះមានព្រះភាគ ជាអ្នកថែរក្សា អ្នកចិញ្ចឹម អ្នកថ្វាយទឹកក្សីរ កាលព្រះមាតាបង្កើតព្រះមានព្រះភាគ ទ្រង់ទិវង្គតទៅ នាងបានបំបៅទឹកដោះ បពិត្រព្រះអង្គដ៏ចម្រើន សូម្បីព្រះមានព្រះភាគក៏មានឧបការៈច្រើន ដល់ព្រះនាងមហាបជាបតិគោតមីដែរ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះព្រះនាងមហាបជាបតិគោតមី អាស្រ័យព្រះមានព្រះភាគ ទើបបានដល់នូវព្រះពុទ្ធជាទីពឹង បានដល់នូវព្រះធម៌ជាទីពឹង បានដល់នូវព្រះសង្ឃជាទីពឹង បពិត្រព្រះអង្គដ៏ចម្រើន ព្រះនាងមហាបជាបតិគោតមី អាស្រ័យព្រះមានព្រះភាគ ទើបជាអ្នកបានវៀរចាកការសម្លាប់សត្វ វៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យ វៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ វៀរចាកការនិយាយកុហក វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ

ភគវន្តំ ភន្តេ អាគម្ម មហាបជាបតី គោតមី ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតា ធម្មេ អវេច្ចប្បសាទេន សមន្នាគតា សង្ឃេ អវេច្ចប្បសាទេន សមន្នាគតា អរិយកន្តេហិ សីលេហិ សមន្នាគតា ភគវន្តំ ភន្តេ អាគម្ម មហាបជាបតី គោតមី ទុក្ខេ និក្កង្ខា ទុក្ខសមុទយេ និក្កង្ខា ទុក្ខនិរោធេ និក្កង្ខា ទុក្ខនិរោធគាមិនិយា បដិបទាយ និក្កង្ខា ភគវាបិ ភន្តេ ពហុការោ មហាបជាបតិយា គោតមិយាតិ ។

[១៨៤] ឯវមេតំ អានន្ទ ឯវមេតំ អានន្ទ យំ ហានន្ទ បុគ្គលោ បុគ្គលំ អាគម្ម ពុទ្ធំ សរណំ គតោ ហោតិ ធម្មំ សរណំ គតោ ហោតិ សង្ឃំ សរណំ គតោ ហោតិ ឥមស្សានន្ទ បុគ្គលស្ស ឥមិនា បុគ្គ-លេន ន សុប្បដិការំ វទាមិ យទិទំ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ ចីវរបិណ្ឌបាតសេ-នាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានុប្បទានេន ។

បពិត្រព្រះអង្គដ៏ចម្រើន ព្រះនាងមហាបជាបតិគោតមី អាស្រ័យនូវព្រះមានព្រះភាគ ទើបប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើក ក្នុងព្រះពុទ្ធ ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើក ក្នុងព្រះធម៌ ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើក ក្នុងព្រះសង្ឃ ប្រកបដោយសីលទាំងឡាយ ដែលជាទីត្រេកអរនៃព្រះអរិយបុគ្គល បពិត្រព្រះអង្គដ៏ចម្រើន ព្រះនាងមហាបជាបតិគោតមី អាស្រ័យនូវព្រះមានព្រះភាគ ទើបជាអ្នកអស់សង្ស័យក្នុងទុក្ខ អស់សង្ស័យ ក្នុងហេតុឲ្យកើតទុក្ខ អស់សង្ស័យ ក្នុងធម៌រំលត់ទុក្ខ អស់សង្ស័យ ក្នុងសេចក្តីប្រតិបត្តិទៅកាន់ទីរំលត់ទុក្ខ បពិត្រព្រះអង្គដ៏ចម្រើន សូម្បីព្រះមានព្រះភាគ ក៏មានឧបការៈច្រើន ដល់ព្រះនាងមហាបជាបតិគោតមីដែរ ។

[១៨២] ព្រះមានព្រះភាគទ្រង់ត្រាស់ថា អើយ៉ាងហ្នឹងហើយ អានន្ទ អើយ៉ាងហ្នឹងហើយ អានន្ទ ម្នាលអានន្ទ បុគ្គលអាស្រ័យបុគ្គលណា ទើបបានដល់ព្រះពុទ្ធជាទីពឹង បានដល់ព្រះធម៌ជាទីពឹង បានដល់ព្រះសង្ឃជាទីពឹង ម្នាលអានន្ទ តថាគតមិនសំដែងនូវការថ្វាយបង្គំ ការក្រោកទទួល អញ្ជលិកម្ម សាមីចិកម្ម និងការឲ្យនូវចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារជាបច្ច័យដល់អ្នកជំងឺ ថាជាកម្មដែលបុគ្គលនេះ តបស្នងដល់បុគ្គលនេះ បានដោយល្អឡើយ ។

២១៩

វិភង្គវគ្គស្ស ទក្ខិណាវិភង្គសុត្តេ សុប្បដិការាភាវោ

យំ ហានន្ទ បុគ្គលោ បុគ្គលំ អាគម្ម បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ កាមេសុមិច្ឆាចារា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ហោតិ ឥមស្សានន្ទ បុគ្គលស្ស ឥមិនា បុគ្គលេន ន សុប្បដិការំ វទាមិ យទិទំ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានុប្បទានេន ។ យំ ហានន្ទ បុគ្គលោ បុគ្គលំ អាគម្ម ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ ធម្មេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ

ម្នាលអានន្ទ មួយទៀត បុគ្គលអាស្រ័យនូវបុគ្គលណា ហើយបាន វៀរចាកការសម្លាប់សត្វ វៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យ វៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ វៀរចាកការនិយាយកុហក វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹងគឺសុរានិង មេរ័យ ម្នាលអានន្ទ តថាគតមិនសំដែងនូវការថ្វាយបង្គំ ការក្រោកទទួល អញ្ជលិកម្ម សាមីចិកម្ម និងការឲ្យនូវចីវរ បិណ្ឌបាត សេនាសនៈ និង គេសជ្ជបរិក្ខារជាបច្ច័យដល់អ្នកជំងឺ ថាជាកម្មដែលបុគ្គលនេះ តបស្នង ដល់បុគ្គលនេះ បានដោយល្អឡើយ ។ ម្នាលអានន្ទ មួយទៀត បុគ្គល អាស្រ័យនូវបុគ្គលណា ហើយបានប្រកបដោយសេចក្តីជ្រះថ្លា មិនកម្រើកក្នុងព្រះពុទ្ធ ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះធម៌

សង្ឃេ អវេច្ចប្បសាទេន សមន្នាគតោ ហោតិ អរិយកន្តេហិ សីលេហិ សមន្នាគតោ ហោតិ ឥមស្សានន្ទ បុគ្គលស្ស ឥមិនា បុគ្គលេន ន សុប្បដិការំ វទាមិ យទិទំ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានុប្បទានេន ។ យំ ហានន្ទ បុគ្គលោ បុគ្គលំ អាគម្ម ទុក្ខេ និក្កង្ខោ ហោតិ ទុក្ខសមុទយេ និក្កង្ខោ ហោតិ ទុក្ខនិរោធេ និក្កង្ខោ ហោតិ ទុក្ខនិរោធគាមិនិយា បដិបទាយ និក្កង្ខោ ហោតិ ឥមស្សានន្ទ បុគ្គលស្ស ឥមិនា បុគ្គលេន ន សុប្បដិការំ វទាមិ យទិទំ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានុប្បទានេន ។

[១៨៤] ចុទ្ទស ខោ បនិមានន្ទ បាដិបុគ្គលិកា ទក្ខិណា ។ តថាគតេ អរហន្តេ សម្មាសម្ពុទ្ធេ ទានំ ទេតិ អយំ បឋមា បាដិបុគ្គលិកា ទក្ខិណា ។

ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះសង្ឃ ប្រកបដោយសីលទាំងឡាយជាទីត្រេកអរនៃព្រះអរិយបុគ្គល ម្នាលអានន្ទ តថាគតមិនសំដែង នូវការថ្វាយបង្គំ ការក្រោកទទួល អញ្ជលិកម្ម សាមីចិកម្ម និងការឲ្យនូវចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារជាបច្ច័យដល់អ្នកជំងឺ ថាជាកម្មដែលបុគ្គលនេះ តបស្នងដល់បុគ្គលនេះ បានដោយល្អឡើយ ។ ម្នាលអានន្ទ មួយទៀត បុគ្គលអាស្រ័យនូវបុគ្គលណា ហើយជាអ្នកអស់សង្ស័យក្នុងទុក្ខ អស់សង្ស័យក្នុងហេតុឲ្យកើតទុក្ខ អស់សង្ស័យក្នុងធម៌រំលត់ទុក្ខ អស់សង្ស័យក្នុងសេចក្តីប្រតិបត្តិទៅកាន់ធម៌រំលត់ទុក្ខ ម្នាលអានន្ទ តថាគតមិនសំដែង នូវការថ្វាយបង្គំ ការក្រោកទទួល អញ្ជលិកម្ម សាមីចិកម្ម និងការឲ្យនូវចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារជាបច្ច័យដល់អ្នកជំងឺ ថាជាកម្មដែលបុគ្គលនេះ តបស្នងដល់បុគ្គលនេះ បានដោយល្អឡើយ ។

[១៨៥] ម្នាលអានន្ទ បាដិបុគ្គលិកាទក្ខិណា (ទានដែលឲ្យចំពោះបុគ្គល) នេះ មាន ១៤ យ៉ាង ។ បុគ្គលឲ្យទានចំពោះព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ នេះ ជាបាដិបុគ្គលិកាទក្ខិណា ទី ១ ។

បច្ចេកសម្ពុទ្ធេ ទានំ ទេតិ អយំ ទុតិយា បាដិបុគ្គលិ-
កា ទក្ខិណា ។ តថាគតស្សាវកេ អរហន្តេ ទានំ
ទេតិ អយំ តតិយា បាដិបុគ្គលិកា ទក្ខិណា ។
អរហត្តផលសច្ឆិកិរិយាយ បដិបន្នេ ទានំ ទេតិ
អយំ ចតុត្ថី បាដិបុគ្គលិកា ទក្ខិណា ។ អនា-
គាមិស្ស ទានំ ទេតិ អយំ បញ្ចមី បាដិបុគ្គលិកា
ទក្ខិណា ។ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នេ
ទានំ ទេតិ អយំ ឆដ្ឋី បាដិបុគ្គលិកា ទក្ខិណា ។
សកទាគាមិស្ស ទានំ ទេតិ អយំ សត្តមី
បាដិបុគ្គលិកា ទក្ខិណា ។ សកទាគាមិផលសច្ឆិ-
កិរិយាយ បដិបន្នេ ទានំ ទេតិ អយំ អដ្ឋមី
បាដិបុគ្គលិកា ទក្ខិណា ។ សោតាបន្នេ ទានំ
ទេតិ អយំ នវមី បាដិបុគ្គលិកា ទក្ខិណា ។

ឲ្យទានចំពោះព្រះបច្ចេកពុទ្ធ នេះ ជាបាដិបុគ្គលិកាទក្ខិណា ទី ២ ។ ឲ្យទានចំពោះព្រះអរហន្តជាសាវ័ករបស់ព្រះតថាគត នេះ ជាបាដិបុគ្គលិកាទក្ខិណា ទី ៣ ។ ឲ្យទានចំពោះបុគ្គលអ្នកប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល នេះ ជាបាដិបុគ្គលិកាទក្ខិណា ទី ៤ ។ ឲ្យទានចំពោះអនាគាមិបុគ្គល នេះ ជាបាដិបុគ្គលិកាទក្ខិណា ទី ៥ ។ ឲ្យទានចំពោះបុគ្គលអ្នកប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវអនាគាមិផល នេះ ជាបាដិបុគ្គលិកាទក្ខិណា ទី ៦ ។ ឲ្យទានចំពោះសកទាគាមិបុគ្គល នេះ ជាបាដិបុគ្គលិកាទក្ខិណា ទី ៧ ។ ឲ្យទានចំពោះបុគ្គលអ្នកប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសកទាគាមិផល នេះ ជាបាដិបុគ្គលិកាទក្ខិណា ទី ៨ ។ ឲ្យទានចំពោះសោតាបន្នបុគ្គល នេះ ជាបាដិបុគ្គលិកាទក្ខិណា ទី ៩ ។

សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នេ ទានំ ទេតិ អយំ ឆសមី ចាដិបុគ្គលិកា ទក្ខិណា ។ ពាហិរកេ កាមេសុ វីតរាគេ ទានំ ទេតិ អយំ ឯកាទសមី ចាដិបុគ្គលិកា ទក្ខិណា ។ បុថុជ្ជនសីលវន្តេ ទានំ ទេតិ អយំ ទ្វាទសមី ចាដិបុគ្គលិកា ទក្ខិណា ។ បុថុជ្ជនទុស្សីលេ ទានំ ទេតិ អយំ តេរសមី ចាដិបុគ្គលិកា ទក្ខិណា ។ តិរច្ឆានគតេ ទានំ ទេតិ អយំ ចុទ្ទសមី ចាដិបុគ្គលិកា ទក្ខិណាតិ[១] ។

១ ឥតិសទ្ទោ កត្ថចិ ទិស្សតិ ន កត្ថចិ ។

*ឲ្យទានចំពោះបុគ្គលអ្នកប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិ-ផល[១] នេះ ជាបាដិបុគ្គលិកាទក្ខិណា ទី ១០ ។ ឲ្យទានចំពោះអ្នកបួសជាខាងក្រៅ (ពុទ្ធសាសនា) ដែលប្រាសចាកតម្រេកក្នុងកាម[២] ទាំង-ឡាយ នេះ ជាបាដិបុគ្គលិកាទក្ខិណា ទី ១១ ។ ឲ្យទានចំពោះបុថុជ្ជនមានសីល នេះ ជាបាដិបុគ្គលិកាទក្ខិណា ទី ១២ ។ ឲ្យទានចំពោះបុថុជ្ជនទ្រុស្តសីល នេះ ជាបាដិបុគ្គលិកាទក្ខិណា ទី ១៣ ។ ឲ្យទានចំពោះសត្វតិរច្ឆាន នេះ ជាបាដិបុគ្គលិកាទក្ខិណា ទី ១៤ ។*

---

១ អដ្ឋកថាថា សូម្បីឧបាសកដល់សរណគមន៍ ៣ ក្តី កាន់សីល ៥ ក្តី សីល ១០ ក្តី សាម-ណេរ ឬ ភិក្ខុដែលទើបនឹងបួសបាន ១ ថ្ងៃក្តី ភិក្ខុមានវត្តប្រតិបត្តិដែលបួសយូរហើយ ភិក្ខុទ្រទ្រង់វិបស្សនាក្តី ទាំងអស់នេះ ឈ្មោះថាប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ។ តែបុគ្គលឲ្យទានចំពោះបុគ្គលទាំងអម្បាលនេះ បានផលច្រើនជាងគ្នាជាលំដាប់ ។ ២ សំដៅពួកអ្នកជាកម្មវាទី កិរិយវាទី ដែលបានអភិញ្ញាជាលោកិយទាំង ៥ ។

វិភង្គវគ្គស្ស ទក្ខិណាវិភង្គសុត្តេ ទក្ខិណាភេទោ

[១៨៦] តត្រានន្ទ តិរច្ឆានគតេ ទានំ ទត្វា សតគុណា ទក្ខិណា បាដិកង្ខិតព្វា ។ បុថុជ្ជន-ទុស្សីលេ ទានំ ទត្វា សហស្សគុណា ទក្ខិណា បាដិកង្ខិតព្វា ។ បុថុជ្ជនសីលវន្តេ ទានំ ទត្វា សតសហស្សគុណា ទក្ខិណា បាដិកង្ខិតព្វា ។ ពាហិរកេ កាមេសុ វីតរាគេ ទានំ ទត្វា កោដិ-សតសហស្សគុណា ទក្ខិណា បាដិកង្ខិតព្វា ។ សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នេ ទានំ ទត្វា អសង្ខ្យេយ្យា អប្បមេយ្យា ទក្ខិណា បាដិកង្ខិតព្វា ។

[១៨៦] ម្នាលអានន្ទ បណ្ដាបុគ្គលអ្នកទទួលទានទាំងនោះ ទក្ខិណាមានគុណមួយរយ[១] ដែលបុគ្គលត្រូវបាន ព្រោះឲ្យទានចំពោះសត្វតិរច្ឆាន ។ ទក្ខិណាមានគុណមួយពាន់ ដែលបុគ្គលត្រូវបាន ព្រោះឲ្យទានចំពោះបុថុជ្ជនទ្រុស្ដសីល ។ ទក្ខិណាមានគុណមួយសែន ដែលបុគ្គលត្រូវបាន ព្រោះឲ្យទានចំពោះបុថុជ្ជនមានសីល ។ ទក្ខិណាមានគុណមួយសែនកោដិ ដែលបុគ្គលត្រូវបាន ព្រោះឲ្យទានចំពោះអ្នកបួសខាងក្រៅ ដែលប្រាសចាកតម្រេកក្នុងកាមទាំងឡាយ ។ ទក្ខិណាមានគុណរាប់មិនបាន ប្រមាណមិនកើត ដែលបុគ្គលត្រូវបាន ព្រោះឲ្យទានចំពោះបុគ្គលដែលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ។

---

១ អដ្ឋកថាថា ឲ្យនូវអានិសង្ស ១០០ គឺ ១០០ អត្តភាព ក្នុងអត្តភាពមួយ ៗ មានអាយុវែង ១ សម្បុរល្អ ១ សេចក្ដីសុខ ១ កម្លាំង ១ ប្រាជ្ញា ១ រួមជាអានិសង្ស ៥០០ ។ ទានក្រៅពីសត្វតិរច្ឆានទៅក៏គុណជាប្រាំ ៗ តាមឧបាយនេះដែរ ។

កោ បន ភាវោ សោតាបន្នោ កោ បន ភាវោ សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ កោ បន ភាវោ សកទាគាមិស្ស កោ បន ភាវោ អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ កោ បន ភាវោ អនាគាមិស្ស កោ បន ភាវោ អរហត្តផលសច្ឆិកិរិយាយ បដិបន្នោ កោ បន ភាវោ តថាគតស្សាវកោ អរហន្តោ កោ បន ភាវោ បច្ចេកសម្ពុទ្ធោ កោ បន ភាវោ តថាគតោ អរហន្តោ សម្មាសម្ពុទ្ធោ ។

នឹងបាច់និយាយទៅអ្វី (ដល់ទក្ខិណាដែលបុគ្គលឲ្យ) ចំពោះសោតាបន្ន-បុគ្គល នឹងនិយាយទៅថ្វី ចំពោះបុគ្គលដែលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល នឹងនិយាយទៅថ្វី ចំពោះសកទាគាមិបុគ្គល នឹងនិយាយទៅអ្វី ចំពោះបុគ្គលដែលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល នឹងនិយាយទៅថ្វី ចំពោះអនាគាមិបុគ្គល នឹងនិយាយទៅថ្វី ចំពោះបុគ្គលដែលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល នឹងនិយាយទៅថ្វី ចំពោះព្រះអរហន្តជាសាវ័ករបស់តថាគត នឹងនិយាយទៅថ្វី ចំពោះព្រះបច្ចេកសម្ពុទ្ធ នឹងនិយាយទៅថ្វី ចំពោះព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ។

វិភង្គវគ្គស្ស ទក្ខិណាវិភង្គសុត្តំ ទក្ខិណាភេទោ

[១៨៧] សត្ត ខោ បនិមានន្ទ សង្ឃគតា ទក្ខិណា ។ ពុទ្ធប្បមុខេ ឧភតោសង្ឃេ ទានំ ទេតិ អយំ បឋមា សង្ឃគតា ទក្ខិណា ។ តថាគតេ បរិនិព្ពុតេ ឧភតោសង្ឃេ ទានំ ទេតិ អយំ ទុតិយា សង្ឃគតា ទក្ខិណា ។ ភិក្ខុសង្ឃេ ទានំ ទេតិ អយំ តតិយា សង្ឃគតា ទក្ខិណា ។ ភិក្ខុនីសង្ឃេ ទានំ ទេតិ អយំ ចតុត្ថី សង្ឃគតា ទក្ខិណា ។ ឯត្តកោ មេ ភិក្ខូ ច ភិក្ខុនិយោ ច សង្ឃតោ ឧទ្ទិស្សថាតិ

វិភង្គវគ្គ ទក្ខិណាវិភង្គសូត្រ សេចក្ដីផ្សេងគ្នានៃទក្ខិណាទាន

*[១៨៧] ម្នាលអានន្ទ សង្ឃគតាទក្ខិណា (ទានដែលតម្កល់ក្នុងសង្ឃ) នេះមាន ៧ យ៉ាង ។ បុគ្គលឲ្យទានចំពោះសង្ឃទាំងពីរចំណែក មានព្រះពុទ្ធជាប្រធាន[១] នេះជាសង្ឃគតាទក្ខិណា ទី ១ ។ កាលបើព្រះតថាគតបរិនិព្វានទៅ បុគ្គលឲ្យទានចំពោះសង្ឃទាំងពីរចំណែក នេះជាសង្ឃគតាទក្ខិណា ទី ២ ។ ឲ្យទានចំពោះតែភិក្ខុសង្ឃ នេះជាសង្ឃគតាទក្ខិណា ទី ៣ ។ ឲ្យទានចំពោះតែភិក្ខុនីសង្ឃ នេះជាសង្ឃគតាទក្ខិណា ទី ៤ ។ បុគ្គល (ទៅនិមន្តអំពីសំណាក់សង្ឃ) ថា សូមលោកទាំងឡាយ ចាត់ពួកភិក្ខុប៉ុណ្ណេះ ពួកភិក្ខុនីប៉ុណ្ណេះ អំពីសង្ឃ ដើម្បីខ្ញុំ*

---

១ សង្ឃទាំងពីរចំណែក គឺពួកភិក្ខុសង្ឃអង្គុយម្ខាង ពួកភិក្ខុនីអង្គុយម្ខាង ព្រះសាស្ដាជាម្ចាស់គង់ត្រង់កណ្ដាល ដូច្នេះហៅថា សង្ឃទាំងពីរចំណែកមានព្រះពុទ្ធជាប្រធាន ។ សង្ឃគតាទិក្ខណាទី ១ នេះ គ្មានទក្ខិណាណាវិសេសស្មើឡើយ ។ ប៉ុន្តែកាលដែលព្រះសាស្ដាបរិនិព្វានទៅហើយនោះ គេតម្កល់ព្រះពុទ្ធប្បដិមា ឬព្រះធាតុ លើអាសនៈក្នុងទីចំពោះមុខសង្ឃទាំងពីរចំណែក តម្កល់ម្ហូបចំណីលើតុ ឬជើងស្រាពក់ហើយធ្វើកិច្ចទក្ខិណោទកជាដើម ថ្វាយវត្ថុទាំងពួងដល់ព្រះសាស្ដាជាមុន ទើបថ្វាយសង្ឃទាំងពីរចំណែកជាខាងក្រោយ យ៉ាងនេះក៏ឈ្មោះថា ថ្វាយទានដល់សង្ឃទាំងពីរចំណែកមានព្រះពុទ្ធជាប្រធានដែរ (សម័យឥឡូវនេះគ្មានភិក្ខុនី មានតែភិក្ខុ ដូច្នេះឈ្មោះថា ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន) ។ ភោជនដែលថ្វាយដល់ព្រះសាស្ដាយ៉ាងនេះ ត្រូវប្រគេនដល់ភិក្ខុណាដែលប្រតិបត្តិព្រះសាស្ដា ដែលបរិបូណ៌ដោយវត្តប្រតិបត្តិ ព្រោះជាវត្ថុរបស់ព្រះពុទ្ធជាបិតា ត្រូវបានដល់ភិក្ខុជាកូន ឬ នឹងប្រគេនដល់សង្ឃក៏គួរ ។ បើវត្ថុនោះជាប្រេង ឬសាជក ត្រូវអុជប្រទីប ចងជាទង់ ឬពិតានថ្វាយ ។ អដ្ឋកថា ។

ទានំ ទេតិ អយំ បញ្ចមី សង្ឃគតា ទក្ខិណា ។ ឯត្តកេ មេ ភិក្ខូ សង្ឃតោ ឧទ្ទិស្សថាតិ ទានំ ទេតិ អយំ ឆដ្ឋី សង្ឃគតា ទក្ខិណា ។ ឯត្តកា មេ ភិក្ខុនិយោ សង្ឃតោ ឧទ្ទិស្សថាតិ ទានំ ទេតិ អយំ សត្តមី សង្ឃគតា ទក្ខិណា ។

[១៨៨] ភវិស្សន្តិ ខោ បនានន្ទ អនាគតមទ្ធានំ គោត្រភុនោ កាសាវកណ្ឋា ទុស្សីលា បាបធម្មា តេសុ ទុស្សីលេសុ សង្ឃំ ឧទ្ទិស្ស ទានំ ទស្សន្តិ តទាបហំ អានន្ទ សង្ឃគតំ ទក្ខិណំ អសង្ខេយ្យំ អប្បមេយ្យំ វទាមិ ន ត្វេវាហំ អានន្ទ កេនចិ បរិយាយេន សង្ឃគតាយ ទក្ខិណាយ បាដិបុគ្គ-លិកទានំ មហប្ផលតរំ វទាមិ ។

ហើយទើបឲ្យទាន នេះជាសង្ឃគតាទក្ខិណា ទី ៥ ។ បុគ្គល (ទៅនិមន្ត អំពីសំណាក់សង្ឃ) ថា សូមលោកទាំងឡាយ ចាត់ពួកភិក្ខុប៉ុណ្ណោះអំពី សង្ឃ ដើម្បីខ្ញុំ ហើយទើបឲ្យទាន នេះជាសង្ឃគតាទក្ខិណា ទី ៦ ។ បុគ្គល (ទៅនិមន្តអំពីសំណាក់សង្ឃ) ថា សូមលោកទាំងឡាយ ចាត់ ពួកភិក្ខុនីប៉ុណ្ណោះអំពីសង្ឃ ដើម្បីខ្ញុំ ហើយទើបឲ្យទាន នេះជាសង្ឃ-គតាទក្ខិណា ទី ៧ ។

[១៨៨] ម្នាលអានន្ទ ក្នុងកាលជាអនាគត នឹងមានគោត្រភូ-សង្ឃ (សង្ឃមានតែឈ្មោះ) មានតែសំពត់កាសាវៈចង់ក ជាអ្នកទ្រុស្ត សីល មានធម៌ដ៏លាមក ជនទាំងនោះ ឧទ្ទិសចំពោះសង្ឃ ហើយនឹង ឲ្យទាន ដល់បុគ្គលទ្រុស្តសីលទាំងនោះ ម្នាលអានន្ទ សូម្បីក្នុងកាល នោះ ក៏តថាគតពោលថាសង្ឃគតាទក្ខិណាទាន មានអានិសង្សរាប់មិន បាន ប្រមាណមិនកើតដែរ ម្នាលអានន្ទ តថាគតមិនដែលពោលនូវ បាដិបុគ្គលិកទានថាមានផលច្រើន ជាងសង្ឃគតាទក្ខិណាទាន ដោយ បរិយាយណាមួយឡើយ ។

២២៧

វិភង្គវគ្គស្ស ទក្ខិណាវិភង្គសុត្តេ ទក្ខិណាវិសុទ្ធិ

[១៨៩] ចតស្សោ ខោ ឥមានន្ទ ទក្ខិណាវិសុទ្ធិយោ ។ កតមា ចតស្សោ ។ អត្ថានន្ទ ទក្ខិណា ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ អត្ថានន្ទ ទក្ខិណា បដិគ្គាហកតោ វិសុជ្ឈតិ នោ ទាយកតោ អត្ថានន្ទ ទក្ខិណា នេវ ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ អត្ថានន្ទ ទក្ខិណា ទាយកតោ ចេវ វិសុជ្ឈតិ បដិគ្គាហកតោ ច ។

[១៩០] កថញ្ចានន្ទ ទក្ខិណា ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ ។ ឥធានន្ទ ទាយកោ ហោតិ សីលវា កល្យាណធម្មោ បដិគ្គាហកា ហោន្តិ ទុស្សីលា បាបធម្មា ឯវំ ខោ អានន្ទ ទក្ខិណា ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ ។

[១៩១] កថញ្ចានន្ទ ទក្ខិណា បដិគ្គាហកតោ វិសុជ្ឈតិ នោ ទាយកតោ ។ ឥធានន្ទ ទាយកោ ហោតិ ទុស្សីលោ បាបធម្មោ បដិគ្គាហកា ហោន្តិ សីលវន្តោ កល្យាណធម្មា ឯវំ ខោ អានន្ទ ទក្ខិណា បដិគ្គាហកតោ វិសុជ្ឈតិ នោ ទាយកតោ ។

[១៨៩] ម្នាលអានន្ទ ទក្ខិណាវិសុទ្ធិ (ការបរិសុទ្ធនិងមិនបរិសុទ្ធរបស់ទាន) នេះមាន ៤ យ៉ាង ។ ឯទក្ខិណាវិសុទ្ធិទាំង ៤ តើដូចម្តេច ។ ម្នាលអានន្ទ ទក្ខិណា បរិសុទ្ធខាងអ្នកឲ្យ មិនបរិសុទ្ធខាងអ្នកទទួល ១ ម្នាលអានន្ទ ទក្ខិណា បរិសុទ្ធខាងអ្នកទទួល មិនបរិសុទ្ធខាងអ្នកឲ្យ ១ ម្នាលអានន្ទ ទក្ខិណា មិនបរិសុទ្ធខាងអ្នកឲ្យផង មិនបរិសុទ្ធខាងអ្នកទទួលផង ១ ម្នាលអានន្ទ ទក្ខិណាបរិសុទ្ធខាងអ្នកឲ្យផង បរិសុទ្ធខាងអ្នកទទួលផង ។

[១៩០] ម្នាលអានន្ទ ទក្ខិណា បរិសុទ្ធខាងអ្នកឲ្យ មិនបរិសុទ្ធខាងអ្នកទទួល តើដូចម្តេច ។ ម្នាលអានន្ទ អ្នកឲ្យក្នុងលោកនេះ ជាបុគ្គលមានសីល មានធម៌ល្អ ឯពួកអ្នកទទួល ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក ម្នាលអានន្ទ យ៉ាងនេះឯង ឈ្មោះថា ទក្ខិណា បរិសុទ្ធខាងអ្នកឲ្យ មិនបរិសុទ្ធខាងអ្នកទទួល ។

[១៩១] ម្នាលអានន្ទ ទក្ខិណា បរិសុទ្ធខាងអ្នកទទួល តែមិនបរិសុទ្ធខាងអ្នកឲ្យ តើដូចម្តេច ។ ម្នាលអានន្ទ អ្នកឲ្យក្នុងលោកនេះ ជាបុគ្គលទ្រុស្តសីល មានធម៌ដ៏លាមក ឯពួកអ្នកទទួល ជាបុគ្គលមានសីល មានធម៌ល្អ ម្នាលអានន្ទ យ៉ាងនេះឯង ឈ្មោះថា ទក្ខិណាបរិសុទ្ធខាងអ្នកទទួល មិនបរិសុទ្ធខាងអ្នកឲ្យ ។

[១៩២] កថញ្ចានន្ទ ទក្ខិណា នេវ ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ ។ ឥធានន្ទ ទាយកោ ច ហោតិ ទុស្សីលោ បាបធម្មោ បដិគ្គាហកា ច ហោន្តិ ទុស្សីលា បាបធម្មា ឯវំ ខោ អានន្ទ ទក្ខិណា នេវ ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ ។

[១៩៣] កថញ្ចានន្ទ ទក្ខិណា ទាយកតោ ចេវ វិសុជ្ឈតិ បដិគ្គាហកតោ ច ។ ឥធានន្ទ ទាយកោ ច ហោតិ សីលវា កល្យាណធម្មោ បដិគ្គាហកា ច ហោន្តិ សីលវន្តោ កល្យាណធម្មា ឯវំ ខោ អានន្ទ ទក្ខិណា ទាយកតោ ចេវ វិសុជ្ឈតិ បដិគ្គាហកតោ ច ។ ឥមា ខោ អានន្ទ ចតស្សោ ទក្ខិណាវិសុទ្ធិយោតិ ។

[១៩២] ម្នាលអានន្ទ ទក្ខិណា មិនបរិសុទ្ធខាងអ្នកឱ្យផង មិនបរិសុទ្ធខាងអ្នកទទួលផង តើដូចម្តេច ។ ម្នាលអានន្ទ អ្នកឱ្យក្នុងលោកនេះ ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក ទាំងពួកអ្នកទទួលក៏ជាបុគ្គលទ្រុស្តសីល មានធម៌ដ៏លាមកដូចគ្នា ម្នាលអានន្ទ យ៉ាងនេះឯង ឈ្មោះថា ទក្ខិណា មិនបរិសុទ្ធខាងអ្នកឱ្យផង មិនបរិសុទ្ធខាងអ្នកទទួលផង ។

[១៩៣] ម្នាលអានន្ទ ទក្ខិណា បរិសុទ្ធខាងអ្នកឱ្យផង បរិសុទ្ធខាងអ្នកទទួលផង តើដូចម្តេច ។ ម្នាលអានន្ទ អ្នកឱ្យក្នុងលោកនេះ ជាបុគ្គលមានសីល មានធម៌ល្អ ទាំងពួកអ្នកទទួល ក៏ជាបុគ្គលមានសីល មានធម៌ល្អដូចគ្នា ម្នាលអានន្ទ យ៉ាងនេះឯង ឈ្មោះថា ទក្ខិណា បរិសុទ្ធខាងអ្នកឲ្យផង បរិសុទ្ធខាងអ្នកទទួលផង ។ ម្នាលអានន្ទ នេះឯង ជាទក្ខិណាវិសុទ្ធិ ៤ យ៉ាង ។

[១៩៤] ឥទមវោច ភគវា ឥទំ វត្វាន សុគតោ អថាបរំ ឯតទវោច សត្ថា

យោ សីលវា ទុស្សីលេសុ ទទាតិ
ទានំ ធម្មេន លទ្ធំ សុបសន្នចិត្តោ
អភិសទ្ទហំ កម្មផលំ ឧឡារំ
សា ទក្ខិណា ទាយកតោ វិសុជ្ឈតិ
យោ ទុស្សីលោ សីលវន្តេសុ ទទាតិ
ទានំ អធម្មេន លទ្ធំ អប្បសន្នចិត្តោ
អនភិសទ្ទហំ កម្មផលំ ឧឡារំ
សា ទក្ខិណា បដិគ្គាហកតោ វិសុជ្ឈតិ
យោ ទុស្សីលោ ទុស្សីលេសុ ទទាតិ
ទានំ អធម្មេន លទ្ធំ អប្បសន្នចិត្តោ
អនភិសទ្ទហំ កម្មផលំ ឧឡារំ
ន តំ ទានំ វិបុលផលន្តិ ព្រូមិ[១]

១ ឱ. សា ទក្ខិណា នេវ ឧភតោ វិសុជ្ឈតីតិ ទិស្សន្តិ ។

[១៩៤] ព្រះមានព្រះភាគទ្រង់ត្រាស់នូវព្រះសូត្រនេះ លុះព្រះសុគតជាសាស្តា ទ្រង់ត្រាស់នូវព្រះសូត្រនេះរួចហើយ ទើបទ្រង់ត្រាស់នូវព្រះគាថាតទៅទៀតដូច្នេះថា

បុគ្គលណា ជាអ្នកមានសីល មានចិត្តជ្រះថ្លាដោយប្រពៃ ជឿស៊ប់នូវកម្មនិងផលរបស់កម្មដ៏លើសលុប ឱ្យទានដែលខ្លួនបានមកដោយធម៌ ចំពោះពួកបុគ្គលទ្រុស្តសីល ទក្ខិណានោះ បរិសុទ្ធខាងអ្នកឱ្យ បុគ្គលណា ជាអ្នកទ្រុស្តសីល មានចិត្តមិនបានជ្រះថ្លា មិនជឿស៊ប់នូវកម្មនិងផលរបស់កម្មដ៏លើសលុប ឲ្យទានដែលខ្លួនបានមកមិនដោយធម៌ ចំពោះពួកបុគ្គលអ្នកមានសីល ទក្ខិណានោះ បរិសុទ្ធខាងអ្នកទទួល បុគ្គលណា ជាអ្នកទ្រុស្តសីល មានចិត្តមិនបានជ្រះថ្លា មិនជឿស៊ប់នូវកម្មនិងផលរបស់កម្មដ៏លើសលុប ឱ្យទានដែលខ្លួនបានមកមិនដោយធម៌ ចំពោះពួកបុគ្គលទ្រុស្តសីល តថាគតមិនពោលថា ទាននោះមានផលដ៏បរិបូណ៌ទេ

យោ សីលវា សីលវន្តេសុ ទទាតិ
ទានំ ធម្មេន លទ្ធំ សុបសន្នចិត្តោ
អភិសទ្ទហំ កម្មផលំ ឧឡារំ
តំ វេ ទានំ វិបុលផលន្តិ ព្រូមិ
យោ វីតរាគោ វីតរាគេសុ ទទាតិ
ទានំ ធម្មេន លទ្ធំ សុបសន្នចិត្តោ
អភិសទ្ទហំ កម្មផលំ ឧឡារំ
តំ វេ ទានំ អាមិសទានានមគ្គន្តិ ។

ទក្ខិណាវិភង្គសុត្តំ ទ្វាទសមំ និដ្ឋិតំ ។

វិភង្គវគ្គោ ចតុត្ថោ ។

បុគ្គលណា ជាអ្នកមានសីល មានចិត្តជ្រះថ្លាដោយប្រពៃ ជឿស៊ប់នូវកម្មនិងផលរបស់កម្មដ៏លើសលុប ឱ្យទានដែលខ្លួនបានមកដោយធម៌ ចំពោះពួកបុគ្គលមានសីល តថាគតពោលថា ទាននោះឯង ទើបបានផលដ៏បរិបូណ៌ បុគ្គលណា ជាអ្នកប្រាសចាករាគៈ មានចិត្តជ្រះថ្លាដោយប្រពៃ ជឿស៊ប់នូវកម្មនិងផលរបស់កម្មដ៏លើសលុប ឱ្យទានដែលខ្លួនបានមកដោយធម៌ ចំពោះពួកបុគ្គលប្រាសចាករាគៈ ទាននោះឯង ប្រសើរជាងពួកអាមិសទាន (ទាំងអស់) ។

ចប់ ទក្ខិណាវិភង្គសូត្រ ទី ១២ ។

ចប់ វិភង្គវគ្គ ទី ៤ ។

វិភង្គវគ្គស្ស ទក្ខិណាវិភង្គសុត្តេ និគមគាថា

## តស្សុទ្ទានំ

ភទ្ទិសាល សមិទ្ធិ ចន្ទោ
អត្តិវេស្សនមាណវោ វញ្ញាណី
សារថិ ឧទ្ទិស្សិជា អរណោន
បុក្កាស សច្ចវោ វគាធំ[១] ។

---

១ ឱ. ឥទំ ឧទ្ទានំ ន ទិស្សតិ ។ តស្ស វគ្គស្ស ឧទ្ទានំ ភទ្ទិកានន្ទកច្ចានលោមសកង្គិយ-សុភោ មហាកម្មសឡាយតនវិភង្គំ ឧទ្ទេសអរណោធាតុសច្ចំ ទក្ខិណាវិភង្គសុត្តន្តីតិ ទិស្សន្តិ ។

# ឧទ្ទាននៃវិភង្គវគ្គនោះគឺ

*ភទ្ទេករត្តសូត្រ ១ រឿងព្រះអានន្ទសំដែង (ភទ្ទេករត្តសូត្រ) ក្នុងឧបដ្ឋានសាលា ១ រឿងព្រះសមិទ្ធិ (ក្នុងមហាកច្ចាន-ភទ្ទេករត្តសូត្រ) ១ រឿងចន្ទនទេវបុត្រ (ក្នុងលោមសកង្គិយ-សូត្រ) ១ រឿងមាណពអគ្គិវេសនគោត្រ (ក្នុងចូឡកម្ម-វិភង្គសូត្រ) ១ រឿងបុគ្គលឈ្មោះថាមានញាណដ៏ប្រសើរ (ក្នុងមហាកម្មវិភង្គសូត្រ) ១ រឿងព្រះសម្ពុទ្ធព្រះនាមបុរិ-សទម្មសារថិ (ក្នុងសឡាយតនវិភង្គសូត្រ) ១ ឧទ្ទេសវិភង្គ-សូត្រ ១ អរណវិភង្គសូត្រ ១ រឿងបុក្កុសកុលបុត្រ (ក្នុងធាតុ-វិភង្គសូត្រ) ១ រឿងសច្ចៈដ៏ប្រសើរ (ក្នុងសច្ចវិភង្គសូត្រ) ១ រឿងទាន (ក្នុងទក្ខិណាវិភង្គសូត្រ) ១ ។*

# សឡាយតនវគ្គោ

## បឋមំ អនាថបិណ្ឌិកោវាទសុត្តំ

[១៩៤] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អនាថបិណ្ឌិកោ គហបតិ អាពាធិកោ ហោតិ ទុក្ខិតោ ពាឡ្ហគិលានោ ។ អថខោ អនាថបិណ្ឌិកោ គហបតិ អញ្ញតរំ បុរិសំ អាមន្តេសិ ឯហិ ត្វំ ភោ[១] បុរិស យេន ភគវា តេនុបសង្កម ឧបសង្កមិត្វា មម វចនេន ភគវតោ បាទេ សិរសា វន្ទាហិ ឯវញ្ច វទេហិ អនាថបិណ្ឌិកោ ភន្តេ គហបតិ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ សោ ភគវតោ បាទេ សិរសា វន្ទតីតិ យេន ចាយស្មា សារីបុត្តោ តេនុបសង្កម ឧបសង្កមិត្វា មម វចនេន អាយស្មតោ សារីបុត្តស្ស បាទេ[២] វន្ទាហិ ឯវញ្ច វទេហិ អនាថបិណ្ឌិកោ ភន្តេ គហបតិ

១ ឱ. ម. អម្ភោ ។ ២ ម. ឯត្តន្តរេ សិរសាតិ ទិស្សតិ ។

# សឡាយតនវគ្គ

## អនាថបិណ្ឌិកោវាទសូត្រ ទី ១

[១៩៥] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកគហបតី ជិតក្រុងសាវត្ថី ។ សម័យនោះឯង អនាថបិណ្ឌិកគហបតី មានអាពាធ ដល់នូវសេចក្តីទុក្ខ មានជំងឺធ្ងន់ ។ គ្រានោះ អនាថបិណ្ឌិកគហបតី ហៅបុរសម្នាក់មកថា នែបុរសដ៏ចម្រើន អ្នកឯងចូរមកអាយ ចូរអ្នកទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ចូរអ្នកថ្វាយបង្គំព្រះបាទាព្រះមានព្រះភាគដោយសិរ្ស: តាមពាក្យរបស់យើង រួចហើយ ចូរក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន អនាថបិណ្ឌិក-គហបតី មានអាពាធ ដល់នូវសេចក្តីទុក្ខ មានជំងឺធ្ងន់ គាត់ក្រាបថ្វាយបង្គំព្រះបាទាព្រះមានព្រះភាគដោយសិរ្ស: រួចហើយ ចូរអ្នកទៅគាល់ព្រះសារីបុត្តមានអាយុ លុះចូលទៅដល់ហើយ ចូរអ្នកថ្វាយបង្គំព្រះបាទាព្រះសារីបុត្តមានអាយុ តាមពាក្យរបស់យើង រួចហើយ ចូរអ្នកទូលយ៉ាងនេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន អនាថបិណ្ឌិកគហបតី

អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ សោ អាយស្មតោ សារីបុត្តស្ស បាទេ សិរសា វន្ទតីតិ ឯវញ្ច វទេហិ សាធុ កិរ ភន្តេ អាយស្មា សារីបុត្តោ យេន អនាថបិណ្ឌិកស្ស គហបតិស្ស និវេសនំ តេនុបសង្កមតុ អនុកម្បំ ឧបាទាយាតិ ។ ឯវម្ភន្តេតិ ខោ សោ បុរិសោ អនាថបិណ្ឌិកស្ស គហបតិស្ស បដិស្សុត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។

[១៩៦] ឯកមន្តំ និសិន្នោ ខោ សោ បុរិសោ ភគវន្តំ ឯតទវោច អនាថបិណ្ឌិកោ ភន្តេ គហបតិ អាពាធិកោ ទុក្ខិតោ ពាឡ្ហគិលានោ សោ ភគវតោ បាទេ សិរសា វន្ទតីតិ យេន ចាយស្មា សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ សារីបុត្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ បុរិសោ អាយស្មន្តំ សារីបុត្តំ ឯតទវោច អនាថបិណ្ឌិកោ ភន្តេ គហបតិ អាពាធិកោ ទុក្ខិតោ

មានអាពាធ ដល់នូវសេចក្តីទុក្ខ មានជំងឺធ្ងន់ គាត់ថ្វាយបង្គំព្រះបាទាព្រះសារីបុត្តមានអាយុដោយសិរ្សៈ ដូច្នេះផង ចូរអ្នកទូលយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន ខ្ញុំព្រះករុណាសូមអង្វរ សូមព្រះសារីបុត្តមានអាយុ អាស្រ័យនូវសេចក្តីអនុគ្រោះ ចូលទៅកាន់លំនៅរបស់អនាថ-បិណ្ឌិកគហបតី ដូច្នេះផង ។ បុរសនោះ ទទួលពាក្យអនាថបិណ្ឌិក-គហបតីថា បាទ លោកដ៏ចម្រើន ហើយក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគរួចហើយអង្គុយក្នុងទីដ៏សមគួរ ។

[១៩៦] លុះបុរសនោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អនាថបិណ្ឌិក-គហបតី មានអាពាធ ដល់នូវសេចក្តីទុក្ខ មានជំងឺធ្ងន់ គាត់ក្រាបថ្វាយបង្គំព្រះបាទាព្រះមានព្រះភាគដោយសិរ្សៈ ហើយបុរសនោះ ក៏ចូលទៅរកព្រះសារីបុត្តមានអាយុ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះសារីបុត្តមានអាយុ ហើយអង្គុយក្នុងទីសមគួរ ។ លុះបុរសនោះ អង្គុយក្នុងទីសមគួរហើយ ក៏ទូលព្រះសារីបុត្តមានអាយុ ដូច្នេះថា បពិត្រលោកដ៏ចម្រើន អនាថបិណ្ឌិកគហបតី មានអាពាធ ដល់នូវសេចក្តីទុក្ខ

ពាឡ្ហគិលានោ សោ អាយស្មតោ សារីបុត្តស្ស បាទេ សិរសា វន្ទតិ ឯវញ្ច វទេតិ សាធុ កិរ ភន្តេ អាយស្មា សារីបុត្តោ យេន អនាថបិណ្ឌិកស្ស គហបតិស្ស និវេសនំ តេនុបសង្កមតុ អនុកម្បំ ឧបាទាយាតិ ។ អធិវាសេសិ ខោ អាយស្មា សារីបុត្តោ តុណ្ហីភាវេន ។ អថខោ អាយស្មា សារីបុត្តោ និវាសេត្វា បត្តចីវរំ អាទាយ អាយស្មតា អានន្ទេន បច្ឆាសមណេន យេន អនាថបិណ្ឌិកស្ស គហបតិស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។

[១៩៧] និសជ្ជ ខោ អាយស្មា សារីបុត្តោ អនាថបិណ្ឌិកំ គហបតឹ ឯតទវោច កច្ចិ តេ គហបតិ ខមនីយំ កច្ចិ យាបនីយំ កច្ចិ ទុក្ខា វេទនា បដិក្កមន្តិ នោ អភិក្កមន្តិ បដិក្កមោសានំ បញ្ញាយតិ នោ អភិក្កមោតិ ។ ន មេ ភន្តេ សារីបុត្ត ខមនីយំ

មានជំងឺធ្ងន់ គាត់ថ្វាយបង្គំព្រះបាទាព្រះសារីបុត្តមានអាយុ ដោយសិរ្សៈ ហើយបុរសនោះក៏ទូលយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន ខ្ញុំព្រះករុណាសូមអង្វរ សូមព្រះសារីបុត្តមានអាយុ អាស្រ័យនូវសេចក្តីអនុគ្រោះ ចូលទៅកាន់ផ្ទះរបស់អនាថបិណ្ឌិកគហបតី (ឲ្យទាន) ។ ព្រះសារីបុត្តមានអាយុ ក៏ទទួលនិមន្តន៍ដោយតុណ្ហីភាព ។ លំដាប់នោះ ព្រះសារីបុត្តមានអាយុ ស្លៀកស្បង់ប្រដាប់ដោយបាត្រនិងចីវរ មានព្រះអានន្ទមានអាយុជាបច្ឆាសមណៈ ក៏ចូលទៅកាន់ផ្ទះ របស់អនាថបិណ្ឌិកគហបតី លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលប្រគេន ។

[១៩៧] លុះព្រះសារីបុត្តមានអាយុ គង់រួចហើយ ក៏មានថេរវាចានឹងអនាថបិណ្ឌិកគហបតីដូច្នេះថា ម្នាលគហបតី សរីរយន្ត អ្នកល្មមអត់ធន់បានដែរឬ ល្មមឲ្យប្រព្រឹត្តទៅបានដែរឬ ទុក្ខវេទនាបានស្រាកស្រាន្ត មិនចម្រើនឡើងទេឬ ការធូរថយរមែងប្រាកដ ឯការចម្រើនឡើងរមែងមិនប្រាកដទេឬ ។ បពិត្រព្រះសារីបុត្តដ៏ចម្រើន ខ្ញុំអត់ធន់មិនបានទេ

ន យាបនីយំ ពាឡ្ហា មេ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ អភិក្កមោសានំ បញ្ញាយតិ នោ បដិក្កមោតិ[១] ។

[១៩៨] សេយ្យថាបិ ភន្តេ សារីបុត្ត ពលវា បុរិសោ តិណ្ហេន សិខរេន មុទ្ធានំ អភិមត្ថេយ្យ ឯវមេវ ខោ មេ ភន្តេ សារីបុត្ត អធិមត្តា វាតា មុទ្ធានំ ឱហនន្តិ ន មេ ភន្តេ សារីបុត្ត ខមនីយំ ន យាបនីយំ ពាឡ្ហា មេ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ អភិក្កមោសានំ បញ្ញាយតិ នោ បដិក្កមោតិ ។

[១៩៩] សេយ្យថាបិ ភន្តេ សារីបុត្ត ពលវា បុរិសោ ទឡ្ហេន វរត្តខណ្ឌេន សីសេ សីសវេឋនំ ទទេយ្យ ឯវមេវ ខោ មេ ភន្តេ សារីបុត្ត អធិមត្តា វាតា សីសំ បរិកន្តន្តិ ន មេ ភន្តេ ខមនីយំ ន យាបនីយំ ពាឡ្ហា មេ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ អភិក្កមោសានំ បញ្ញាយតិ នោ បដិក្កមោតិ ។

---

១ ឱ. ឥតិសទ្ទោ ន ទិស្សតិ ។

ឲ្យប្រព្រឹត្តទៅមិនបានទេ ទុក្ខវេទនាដ៏ក្លារបស់ខ្ញុំ ចេះតែចម្រើនឡើង មិនស្រាកស្រាន្តទេ ការចម្រើន ចេះតែប្រាកដ ការធូរថយ មិនប្រាកដទេ ។

[១៩៨] បពិត្រព្រះសារីបុត្តដ៏ចម្រើន បុរសមានកម្លាំង ចាក់អំបែងក្បាលដោយដែកស្រួចមុត យ៉ាងណាមិញ បពិត្រព្រះសារីបុត្តដ៏ចម្រើន ខ្យល់ដ៏ខ្លាំង ចាក់ដោតអំបែងក្បាលខ្ញុំ ក៏យ៉ាងនោះដែរ បពិត្រព្រះសារីបុត្តដ៏ចម្រើន ខ្ញុំអត់ធន់មិនបានទេ ឲ្យប្រព្រឹត្តទៅមិនបានទេ ព្រោះទុក្ខវេទនាដ៏ក្លារបស់ខ្ញុំ រមែងចម្រើនឡើង មិនស្រាកស្រាន្តទេ មានតែរឹតឡើង ឥតធូរថយសោះ ។

[១៩៩] បពិត្រព្រះសារីបុត្តដ៏ចម្រើន បុរសមានកម្លាំងយកចង្វាយព្រ័ត្រដ៏មាំ មកត្របែងក្បាល យ៉ាងណាមិញ បពិត្រព្រះសារីបុត្តដ៏ចម្រើន ខ្យល់ដ៏ខ្លាំង ធ្មៀលក្បាលខ្ញុំ ក៏យ៉ាងនោះដែរ បពិត្រព្រះសារីបុត្តដ៏ចម្រើន ខ្ញុំអត់ធន់មិនបានទេ ឲ្យប្រព្រឹត្តទៅមិនបានទេ ព្រោះទុក្ខវេទនាដ៏ក្លារបស់ខ្ញុំ តែងចម្រើនឡើង មិនស្រាកស្រាន្តទេ មានតែរឹតឡើង ឥតធូរថយសោះ ។

[២០០] សេយ្យថាបិ ភន្តេ សារីបុត្ត ទក្ខោ គោឃាតកោ វា គោឃាតកន្តេវាសី វា តិណ្ហេន គោវិកន្តនេន កុច្ឆឹ បរិកន្តេយ្យ ឯវមេវ ខោ មេ ភន្តេ សារីបុត្ត អធិមត្តា វាតា កុច្ឆឹ បរិកន្តន្តិ ន មេ ភន្តេ ខមនីយំ ន យាបនីយំ ពាឡ្ហា មេ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ អភិក្កមោសានំ បញ្ញាយតិ នោ បដិក្កមោតិ ។

[២០១] សេយ្យថាបិ ភន្តេ សារីបុត្ត ទ្វេ ពលវន្តោ បុរិសា ទុព្វលតរំ បុរិសំ នានាពាហាសុ គហេត្វា អង្គារកាសុយា សន្តាបេយ្យុំ សម្បរិតាបេយ្យុំ ឯវមេវ ខោ មេ ភន្តេ សារីបុត្ត អធិមត្តោ កាយស្មឹ ឌាហោ ន មេ ភន្តេ សារីបុត្ត ខមនីយំ ន យាបនីយំ ពាឡ្ហា មេ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ អភិក្កមោសានំ បញ្ញាយតិ នោ បដិក្កមោតិ ។

[២០០] បពិត្រព្រះសារីបុត្តដ៏ចម្រើន អ្នកសម្លាប់គោក្តី កូនសិស្សរបស់អ្នកសម្លាប់គោដ៏ឈ្លាសក្តី វះពោះ ដោយកាំបិតសម្រាប់វះគោដ៏មុត យ៉ាងណាមិញ បពិត្រព្រះសារីបុត្តដ៏ចម្រើន ខ្យល់ដែលខ្លាំង រមែងអារពោះរបស់ខ្ញុំ ក៏យ៉ាងនោះឯង បពិត្រព្រះសារីបុត្តដ៏ចម្រើន ខ្ញុំអត់ធន់មិនបានទេ ឲ្យប្រព្រឹត្តទៅមិនបានទេ ព្រោះទុក្ខវេទនាដ៏ក្លារបស់ខ្ញុំតែងចម្រើនឡើង មិនស្រាកស្រាន្ត មានតែរឹតឡើង ឥតធូរថយសោះ ។

[២០១] បពិត្រព្រះសារីបុត្តដ៏ចម្រើន បុរស ២ នាក់ មានកម្លាំងចាប់បុរសម្នាក់ដែលខ្សោយជាង ត្រង់ដើមដៃទាំងពីរ ពាលកម្តៅលើរណ្តៅរងើកភ្លើង យ៉ាងណាមិញ បពិត្រព្រះសារីបុត្តដ៏ចម្រើន ឯសេចក្តីក្តៅក្រហាយដ៏ខ្លាំង ក្នុងកាយរបស់ខ្ញុំ ក៏យ៉ាងនោះឯង បពិត្រព្រះសារីបុត្តដ៏ចម្រើន ខ្ញុំអត់ធន់មិនបានទេ ឲ្យប្រព្រឹត្តទៅមិនបានទេ ព្រោះទុក្ខវេទនាដ៏ក្លារបស់ខ្ញុំ តែងចម្រើនឡើង មិនស្រាកស្រាន្តទេ មានតែរឹតឡើង ឥតធូរថយសោះ ។

[២០២] តស្មាតិហ តេ គហបតិ ឯវំ សិក្ខិតព្វំ ន ចក្ខុំ ឧបាទិយិស្សាមិ ន ច មេ ចក្ខុនិស្សិតំ វិញ្ញាណំ ភវិស្សតីតិ ឯវញ្ហិ តេ គហបតិ សិក្ខិតព្វំ ។ តស្មា-តិហ តេ គហបតិ ឯវំ សិក្ខិតព្វំ ន សោតំ ឧបា-ទិយិស្សាមិ ន ច មេ សោតនិស្សិតំ វិញ្ញាណំ ភវិស្ស-តីតិ ឯវញ្ហិ តេ គហបតិ សិក្ខិតព្វំ ។ តស្មាតិហ តេ គហបតិ ឯវំ សិក្ខិតព្វំ ន ឃានំ ឧបាទិ-យិស្សាមិ ន ច មេ ឃាននិស្សិតំ វិញ្ញាណំ ភវិស្សតីតិ ឯវញ្ហិ តេ គហបតិ សិក្ខិតព្វំ ។ តស្មាតិហ តេ គហបតិ ឯវំ សិក្ខិតព្វំ ន ជិវ្ហំ ឧបាទិយិស្សាមិ ន ច មេ ជិវ្ហានិស្សិតំ វិញ្ញាណំ ភវិស្សតីតិ ឯវញ្ហិ តេ គហបតិ សិក្ខិតព្វំ ។

[២០២] ព្រះសារីបុត្ត តបថា ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវចក្ខុ ទាំងវិញ្ញាណដែលអាស្រ័យចក្ខុ របស់អាត្មាអញក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញ នឹងមិនប្រកាន់នូវត្រចៀក ទាំងវិញ្ញាណដែលអាស្រ័យត្រចៀក របស់អាត្មាអញនឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវច្រមុះ ទាំងវិញ្ញាណដែលអាស្រ័យច្រមុះ របស់អាត្មាអញ ក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវអណ្តាត ទាំងវិញ្ញាណដែលអាស្រ័យអណ្តាត របស់អាត្មាអញក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។

តស្មាតិហ តេ គហបតិ ឯវំ សិក្ខិតព្វំ ន កាយំ ឧបាទិយិស្សាមិ ន ច មេ កាយនិស្សិតំ វិញ្ញាណំ ភវិស្សតីតិ ឯវញ្ហិ តេ គហបតិ សិក្ខិតព្វំ ។ តស្មាតិហ តេ គហបតិ ឯវំ សិក្ខិតព្វំ ន មនំ ឧបាទិយិស្សាមិ ន ច មេ មនោនិស្សិតំ វិញ្ញាណំ ភវិស្សតីតិ ឯវញ្ហិ តេ គហបតិ សិក្ខិតព្វំ ។

[២០៣] តស្មាតិហ តេ គហបតិ ឯវំ សិក្ខិតព្វំ ន រូបំ ឧបាទិយិស្សាមិ ន ច មេ រូបនិស្សិតំ វិញ្ញាណំ ភវិស្សតីតិ ឯវញ្ហិ តេ គហបតិ សិក្ខិតព្វំ ។ តស្មា-តិហ តេ គហបតិ ឯវំ សិក្ខិតព្វំ ន សទ្ទំ ឧ-បាទិយិស្សាមិ... ន គន្ធំ ឧបាទិយិស្សាមិ... ន រសំ ឧបាទិយិស្សាមិ... ន ផោដ្ឋព្វំ ឧបាទិយិស្សាមិ... ន ធម្មំ ឧបាទិយិស្សាមិ ន ច មេ ធម្មនិស្សិតំ វិញ្ញាណំ ភវិស្សតីតិ ឯវញ្ហិ តេ គហបតិ សិក្ខិតព្វំ ។

ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវកាយ ទាំងវិញ្ញាណដែលអាស្រ័យកាយ របស់អាត្មាអញ ក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សា យ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសា-សនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវចិត្ត ទាំងវិញ្ញាណដែលអាស្រ័យចិត្ត របស់អាត្មាអញ ក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។

[២០៣] ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវរូប ទាំងវិញ្ញាណដែលអាស្រ័យរូប របស់អាត្មាអញ ក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវសំឡេង... នឹងមិនប្រកាន់នូវក្លិន... នឹងមិនប្រកាន់នូវរស... នឹងមិនប្រកាន់នូវផ្សព្វ... នឹងមិនប្រកាន់នូវធម្មារម្មណ៍ ទាំងវិញ្ញាណដែលអាស្រ័យធម្មារម្មណ៍ របស់អាត្មាអញ ក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។

សឡាយតនវគ្គស្ស អនាថបិណ្ឌិកោវាទសុត្តេ ចក្ខុសម្ផស្សាទិ

[២០៤] តស្មាតិហ តេ គហបតិ ឯវំ សិក្ខិតព្វំ ន ចក្ខុំវិញ្ញាណំ ឧបាទិយិស្សាមិ ន ច មេ ចក្ខុ-វិញ្ញាណនិស្សិតំ វិញ្ញាណំ ភវិស្សតីតិ ឯវញ្ហិ តេ គហបតិ សិក្ខិតព្វំ ។ តស្មាតិហ តេ គហបតិ ឯវំ សិក្ខិតព្វំ ន សោតវិញ្ញាណំ ឧបាទិយិស្សាមិ... ន ឃានវិញ្ញាណំ ឧបាទិយិស្សាមិ... ន ជិវ្ហាវិញ្ញាណំ ឧបាទិយិស្សាមិ... ន កាយវិញ្ញាណំ ឧបាទិយិស្សា-មិ... ន មនោវិញ្ញាណំ ឧបាទិយិស្សាមិ ន ច មេ មនោវិញ្ញាណនិស្សិតំ វិញ្ញាណំ ភវិស្សតីតិ ឯវញ្ហិ តេ គហបតិ សិក្ខិតព្វំ ។

[២០៥] តស្មាតិហ តេ គហបតិ ឯវំ សិក្ខិតព្វំ ន ចក្ខុសម្ផស្សំ ឧបាទិយិស្សាមិ ន ច មេ ចក្ខុ-សម្ផស្សនិស្សិតំ វិញ្ញាណំ ភវិស្សតីតិ ឯវញ្ហិ តេ គហបតិ សិក្ខិតព្វំ ។ តស្មាតិហ តេ គហ-បតិ ឯវំ សិក្ខិតព្វំ ន សោតសម្ផស្សំ ឧបាទិ-យិស្សាមិ... ន ឃានសម្ផស្សំ ឧបាទិយិស្សាមិ...

[២០៤] ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវចក្ខុវិញ្ញាណ ទាំងវិញ្ញាណដែលអាស្រ័យចក្ខុវិញ្ញាណ របស់អាត្មាអញនឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវសោតវិញ្ញាណ... នឹងមិនប្រកាន់នូវឃានវិញ្ញាណ... នឹងមិនប្រកាន់នូវជិវ្ហាវិញ្ញាណ... នឹងមិនប្រកាន់នូវកាយវិញ្ញាណ... នឹងមិនប្រកាន់នូវមនោវិញ្ញាណ ទាំងវិញ្ញាណដែលអាស្រ័យមនោវិញ្ញាណ របស់អាត្មាអញ ក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។

[២០៥] ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវចក្ខុសម្ផស្ស ទាំងវិញ្ញាណដែលអាស្រ័យចក្ខុសម្ផស្ស របស់អាត្មាអញនឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវសោតសម្ផស្ស... នឹងមិនប្រកាន់នូវឃានសម្ផស្ស...

ន ជិវ្ហាសម្ផស្សំ ឧបាទិយិស្សាមិ... ន កាយសម្ផស្សំ ឧបាទិយិស្សាមិ... ន មនោសម្ផស្សំ ឧបាទិយិស្សាមិ ន ច មេ មនោសម្ផស្សនិស្សិតំ វិញ្ញាណំ ភវិស្សតីតិ ឯវញ្ហិ តេ គហបតិ សិក្ខិតព្វំ ។

[២០៦] តស្មាតិហ តេ គហបតិ ឯវំ សិក្ខិតព្វំ ន ចក្ខុសម្ផស្សជំ វេទនំ ឧបាទិយិស្សាមិ ន ច មេ ចក្ខុសម្ផស្សជវេទនានិស្សិតំ វិញ្ញាណំ ភវិស្សតីតិ ឯវញ្ហិ តេ គហបតិ សិក្ខិតព្វំ ។ តស្មាតិហ តេ គហបតិ ឯវំ សិក្ខិតព្វំ ន សោតសម្ផស្សជំ វេទនំ ឧបាទិយិស្សាមិ... ន ឃានសម្ផស្សជំ វេទនំ ឧបាទិយិស្សាមិ... ន ជិវ្ហាសម្ផស្សជំ វេទនំ ឧបាទិយិស្សាមិ... ន កាយសម្ផស្សជំ វេទនំ ឧបាទិយិស្សាមិ... ន មនោសម្ផស្សជំ វេទនំ ឧបាទិយិស្សាមិ ន ច មេ មនោសម្ផស្សជវេទនានិស្សិតំ វិញ្ញាណំ ភវិស្សតីតិ ឯវញ្ហិ តេ គហបតិ សិក្ខិតព្វំ ។

នឹងមិនប្រកាន់នូវជិវ្ហាសម្ផស្ស... នឹងមិនប្រកាន់នូវកាយសម្ផស្ស... នឹងមិនប្រកាន់នូវមនោសម្ផស្ស ទាំងវិញ្ញាណ ដែលអាស្រ័យមនោសម្ផស្ស របស់អាត្មាអញ ក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។

[២០៦] ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់ នូវវេទនាដែលកើតអំពីចក្ខុសម្ផស្ស ទាំងវិញ្ញាណ ដែលអាស្រ័យវេទនា ដែលកើតអំពីចក្ខុសម្ផស្ស របស់អាត្មាអញនឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវវេទនាដែលកើតអំពីសោតសម្ផស្ស... នឹងមិនប្រកាន់នូវវេទនា ដែលកើតអំពីឃានសម្ផស្ស... នឹងមិនប្រកាន់នូវវេទនាដែលកើតអំពីជិវ្ហាសម្ផស្ស... នឹងមិនប្រកាន់នូវវេទនាដែលកើតអំពីកាយសម្ផស្ស... នឹងមិនប្រកាន់នូវវេទនាដែលកើតអំពីមនោសម្ផស្ស ទាំងវិញ្ញាណដែលអាស្រ័យវេទនា ដែលកើតអំពីមនោសម្ផស្ស របស់អាត្មាអញនឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។

សឡាយតនវគ្គស្ស អនាថបិណ្ឌិកោវាទសុត្តេ បញ្ចក្ខន្ធា

[២០៧] តស្មាតិហ តេ គហបតិ ឯវំ សិក្ខិតព្វំ ន បឋវីធាតុំ ឧបាទិយិស្សាមិ ន ច មេ បឋវីធាតុនិស្សិតំ វិញ្ញាណំ ភវិស្សតីតិ ឯវញ្ហិ តេ គហបតិ សិក្ខិតព្វំ ។ តស្មាតិហ តេ គហបតិ ឯវំ សិក្ខិតព្វំ ន អាបោធាតុំ ឧបាទិយិស្សាមិ... ន តេជោធាតុំ ឧបាទិយិស្សាមិ... ន វាយោធាតុំ ឧបាទិយិស្សាមិ... ន អាកាសធាតុំ ឧបាទិយិស្សាមិ... ន វិញ្ញាណធាតុំ ឧបាទិយិស្សាមិ ន ច មេ វិញ្ញាណធាតុនិស្សិតំ វិញ្ញាណំ ភវិស្សតីតិ ឯវញ្ហិ តេ គហបតិ សិក្ខិតព្វំ ។

[២០៨] តស្មាតិហ តេ គហបតិ ឯវំ សិក្ខិតព្វំ ន រូបំ ឧបាទិយិស្សាមិ ន ច មេ រូបនិស្សិតំ វិញ្ញាណំ ភវិស្សតីតិ ឯវញ្ហិ តេ គហបតិ សិក្ខិតព្វំ ។ តស្មាតិហ តេ គហបតិ ឯវំ សិក្ខិតព្វំ ន វេទនំ ឧបាទិយិស្សាមិ... ន សញ្ញំ ឧបាទិយិស្សាមិ... ន សង្ខារេ ឧបាទិយិស្សាមិ... ន វិញ្ញាណំ ឧបាទិយិស្សាមិ ន ច មេ វិញ្ញាណនិស្សិតំ វិញ្ញាណំ ភវិស្សតីតិ ឯវញ្ហិ តេ គហបតិ សិក្ខិតព្វំ ។

[២០៧] ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញ មិនប្រកាន់នូវបឋវីធាតុ ទាំងវិញ្ញាណដែលអាស្រ័យបឋវីធាតុ របស់អាត្មាអញ ក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវអាបោធាតុ... នឹងមិនប្រកាន់នូវតេជោធាតុ... នឹងមិនប្រកាន់នូវវាយោធាតុ... នឹងមិនប្រកាន់នូវអាកាសធាតុ... នឹងមិនប្រកាន់នូវវិញ្ញាណធាតុ ទាំងវិញ្ញាណដែលអាស្រ័យវិញ្ញាណធាតុ របស់អាត្មាអញ ក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។

[២០៨] ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវរូប ទាំងវិញ្ញាណដែលអាស្រ័យរូបរបស់អាត្មាអញ ក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវវេទនា... នឹងមិនប្រកាន់នូវសញ្ញា... នឹងមិនប្រកាន់នូវសង្ខារទាំងឡាយ... នឹងមិនប្រកាន់នូវវិញ្ញាណ ទាំងវិញ្ញាណដែលអាស្រ័យវិញ្ញាណ របស់អាត្មាអញក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។

[២០៩] តស្មាតិហ តេ គហបតិ ឯវំ សិក្ខិតព្វំ ន អាកាសានញ្ចាយតនំ ឧបាទិយិស្សាមិ ន ច មេ អាកាសានញ្ចាយតននិស្សិតំ វិញ្ញាណំ ភវិស្សតីតិ ឯវញ្ហិ តេ គហបតិ សិក្ខិតព្វំ ។ តស្មាតិហ តេ គហបតិ ឯវំ សិក្ខិតព្វំ ន វិញ្ញាណញ្ចាយតនំ ឧបាទិយិស្សាមិ... ន អាកិញ្ចញ្ញាយតនំ ឧបាទិយិស្សាមិ... ន នេវសញ្ញានាសញ្ញាយតនំ ឧបាទិយិស្សាមិ ន ច មេ នេវសញ្ញានាសញ្ញាយតននិស្សិតំ វិញ្ញាណំ ភវិស្សតីតិ ឯវញ្ហិ តេ គហបតិ សិក្ខិតព្វំ ។

[២១០] តស្មាតិហ តេ គហបតិ ឯវំ សិក្ខិតព្វំ ន ឥធលោកំ ឧបាទិយិស្សាមិ ន ច មេ ឥធលោកនិស្សិតំ វិញ្ញាណំ ភវិស្សតីតិ

[២០៩] ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវអាកាសានញ្ចាយតនៈ ទាំងវិញ្ញាណដែលអាស្រ័យអាកាសានញ្ចាយតនៈរបស់អាត្មាអញ ក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវវិញ្ញាណញ្ចាយតនៈ... នឹងមិនប្រកាន់នូវអាកិញ្ចញ្ញាយតនៈ... នឹងមិនប្រកាន់នូវនេវសញ្ញានាសញ្ញាយតនៈ ទាំងវិញ្ញាណដែលអាស្រ័យនេវសញ្ញានាសញ្ញាយតនៈរបស់អាត្មាអញ ក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។

[២១០] ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវលោកនេះ[១] ទាំងវិញ្ញាណដែលអាស្រ័យលោកនេះ របស់អាត្មាអញក៏នឹងមិនមានឡើយ

---

១ អដ្ឋកថាថា លោកនេះសំដៅយកកន្លែងសម្រាប់នៅ គ្រឿងសម្រាប់ស៊ី និងគ្រឿងស្លៀកពាក់ ។

ឯវញ្ហិ តេ គហបតិ សិក្ខិតព្វំ ។ តស្មាតិហ តេ គហបតិ ឯវំ សិក្ខិតព្វំ ន បរលោកំ ឧបាទិយិស្សាមិ ន ច មេ បរលោកនិស្សិតំ វិញ្ញាណំ ភវិស្សតីតិ ឯវញ្ហិ តេ គហបតិ សិក្ខិតព្វំ ។

[២១១] តស្មាតិហ តេ គហបតិ ឯវំ សិក្ខិតព្វំ យម្បិ មេ ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ បរិយេសិតំ អនុវិ-ចរិតំ មនសា តម្បិ ន ឧបាទិយិស្សាមិ ន ច មេ តន្និស្សិតំ វិញ្ញាណំ ភវិស្សតីតិ ឯវញ្ហិ តេ គហបតិ សិក្ខិតព្វន្តិ ។

ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវលោកខាងមុខ[១] ទាំងវិញ្ញាណ ដែលអាស្រ័យលោកខាងមុខរបស់អាត្មាអញនឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។

[២១១] ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា ធម្មជាតណា ដែលអាត្មាអញ បានឃើញហើយ ឮហើយ ប៉ះពាល់ហើយ ដឹងច្បាស់ហើយ ស្វែងរកហើយ ស្ទាបស្ទង់ដោយចិត្តហើយ អាត្មាអញ នឹងមិនប្រកាន់នូវធម្មជាតនោះ ទាំងវិញ្ញាណដែលអាស្រ័យធម្មជាតនោះ របស់អាត្មាអញក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។

---

១ អដ្ឋកថា ថា សង្គ្រោះយកលោកដទៃ លើកលែងតែមនុស្សលោកចេញ ។ អធិប្បាយថា ឲ្យលះចិត្តគិតថា អាត្មាអញនឹងកើតក្នុងទេវលោកឯណោះ នៅក្នុងទេវលោកឯណោះ បរិភោគ និងស្លៀកដណ្តប់យ៉ាងនេះ ។

[២១២] ឯវំ វុត្តេ អនាថបិណ្ឌិកោ គហបតិ បរោទិ អស្សូនិ បវត្តេសិ ។ អថខោ អាយស្មា អានន្ទោ អនាថបិណ្ឌិកំ គហបតឹ ឯតទវោច ឱលេយ្យាសិ[១] ខោ ត្វំ គហបតិ សំសីទិ[២] ខោ ត្វំ គហបតីតិ ។ នាហំ ភន្តេ អានន្ទ ឱលេយ្យាមិ ន សំសីទាមិ អបិច មេ ទីឃរត្តំ សត្ថា បយិរុបាសិតោ មនោភាវនីយា ច ភិក្ខូ ន ច មេ ឯវរូបី ធម្មីកថា សុតបុព្វាតិ ។ ន ខោ គហបតិ គិហីនំ ឱទាតវសនានំ ឯវរូបី ធម្មីកថា បដិភាតិ បព្វជិតានំ[៣] គហបតិ ឯវរូបី ធម្មីកថា បដិភាតីតិ ។ តេនហិ ភន្តេ សារីបុត្ត គិហីនំបិ ឱទាតវសនានំ ឯវរូបី ធម្មីកថា បដិភាតុ សន្តិ ហិ ភន្តេ[៤] កុលបុត្តា អប្បរជក្ខជាតិកា អស្សវនតា ធម្មស្ស បរិហាយន្តិ[៥] ធម្មស្ស អញ្ញាតារោ ភវិស្សន្តិ ។

---

១ ឱ. ម. ឱលីយសិ ។ ២ ឱ. ម. សំសីទសិ ។ ៣ ឱ. ម. ឯតត្ថុត្តរេ ខោសទ្ទោ ទិស្សតិ ។ ៤ ភន្តេ សារីបុត្ត ។ ៥ ឱ. ម. បរិហាយន្តិ ភវិស្សន្តិ ។

[២១២] កាលដែលព្រះសារីបុត្តមានថេរវាចាយ៉ាងនេះហើយ អនាថបិណ្ឌិកគហបតីយំសម្រក់ទឹកភ្នែក ។ គ្រានោះ ព្រះអានន្ទមានអាយុ មានថេរវាចានឹងអនាថបិណ្ឌិកគហបតីដូច្នេះថា ម្នាលគហបតី អ្នកជាប់នៅក្នុងទ្រព្យសម្បត្តិឬ ម្នាលគហបតី អ្នកលិចនៅក្នុងទ្រព្យសម្បត្តិឬ ។ អនាថបិណ្ឌិកគហបតីឆ្លើយថា បពិត្រព្រះអានន្ទដ៏ចម្រើន ខ្ញុំមិនជាប់ មិនលិចនៅក្នុងទ្រព្យសម្បត្តិទេ តែថាខ្ញុំព្រះករុណា ដែលចូលទៅអង្គុយជិតព្រះសាស្តា អស់កាលយូរហើយផង ចូលទៅអង្គុយជិតពួកភិក្ខុជាអ្នកចម្រើនចិត្ត អស់កាលយូរហើយផង ក៏ខ្ញុំព្រះករុណា មិនដែលបានស្តាប់ធម្មីកថាមានសភាពដូច្នេះឡើយ ។ ម្នាលគហបតី ធម្មីកថាមានសភាពដូច្នេះ តែងមិនច្បាស់ប្រាកដដល់ពួកគ្រហស្ថអ្នកស្លៀកសទេ ម្នាលគហបតី ឯធម្មីកថាមានសភាពដូច្នេះ រមែងច្បាស់ប្រាកដដល់ពួកបព្វជិត (តែប៉ុណ្ណោះ) ។ បពិត្រព្រះសារីបុត្តដ៏ចម្រើន បើដូច្នោះ ធម្មីកថាមានសភាពដូច្នេះ សូមឲ្យបានច្បាស់ប្រាកដដល់ពួកគ្រហស្ថអ្នកស្លៀកសផង បពិត្រលោកដ៏ចម្រើន ព្រោះថា មានពួកកុលបុត្តដែលប្រកបដោយជាតិជាអ្នកមានធូលីតិចក្នុងភ្នែក ជាអ្នកដឹងច្បាស់នូវធម៌ ព្រោះតែមិនបានស្តាប់ធម៌ មុខជានឹងសាបសូន្យចាកធម៌មិនខាន ។

អថខោ អាយស្មា ច សារីបុត្តោ អាយស្មា ច អានន្ទោ អនាថបិណ្ឌិកំ គហបតឹ ឥមិនា ឱវាទេន ឱវទិត្វា ឧដ្ឋាយាសនា បក្កមឹសុ ។

[២១៣] អថខោ អនាថបិណ្ឌិកោ គហបតិ អចិរបក្កន្តេ អាយស្មន្តេ ច សារីបុត្តេ អាយស្មន្តេ ច អានន្ទេ កាលមកាសិ តុសិតំ កាយំ ឧបបជ្ជតិ ។ អថខោ អនាថបិណ្ឌិកោ ទេវបុត្តោ អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណោ កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ អនាថបិណ្ឌិកោ ទេវបុត្តោ ភគវន្តំ គាថាហិ អជ្ឈភាសិ

ឥទំ ហិតំ ជេតវនំ

ឥសិសង្ឃនិសេវិតំ

អាវុត្ថំ ធម្មរាជេន

លុះព្រះសារីបុត្តមានអាយុ និងព្រះអានន្ទមានអាយុ ទូន្មានអនាថ-បិណ្ឌិកគហបតី ដោយឱវាទនេះរួចហើយ ក៏ក្រោកចាកអាសនៈចៀសចេញទៅ ។

[២១៣] កាលបើព្រះសារីបុត្តមានអាយុ និងព្រះអានន្ទមានអាយុចៀសចេញទៅ អស់កាលមិនយូរប៉ុន្មាន អនាថបិណ្ឌិកគហបតីក៏ធ្វើមរណកាល ទៅកើតក្នុងពួកទេវតាឋានតុសិត ។ លំដាប់នោះ អនាថបិណ្ឌិកទេវបុត្ត លុះរាត្រីបឋមយាមកន្លងទៅហើយ មានពន្លឺដ៏រុងរឿង ញុំាងវត្តជេតពនទាំងអស់ឲ្យភ្លឺស្វាងហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកទេវបុត្តឋិតនៅក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដោយគាថាទាំងឡាយថា

វត្តជេតពននេះ សុទ្ធតែពួកអ្នកស្វែងរកគុណដ៏ល្អ នៅ
អាស្រ័យជានិច្ច ដែលព្រះពុទ្ធជាធម្មរាជ គង់អាស្រ័យនៅ

បីតិសញ្ជននំ មម
កម្មំ វិជ្ជា ច ធម្មោ ច
សីលំ ជីវិតមុត្តមំ
ឯតេន មច្ចា សុជ្ឈន្តិ
ន គោត្តេន ន ធនេន វា
តស្មា ហិ បណ្ឌិតោ ចោសោ
សម្បស្សំ អត្ថមត្តនោ
យោនិសោ វិចិនេ ធម្មំ
ឯវំ តត្ថ វិសុជ្ឈតិ
សារីបុត្តោ វ បញ្ញាយ
សីលេន ឧបសមេន ច
យោ ហិ ចារគតោ ភិក្ខុ
ឯតាវបរមោ សិយាតិ ។

ឥទមវោច អនាថបិណ្ឌិកោ ទេវបុត្តោ សមនុញ្ញោ សត្ថា អហោសិ ។ អថខោ អនាថបិណ្ឌិកោ ទេវបុត្តោ សមនុញ្ញោ មេ សត្ថាតិ ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយិ ។

ជាទីញ៉ាំងបីតិឲ្យកើតព្រមដល់ខ្ញុំព្រះអង្គ កម្មគឺមគ្គចេតនា ១ វិជ្ជាគឺមគ្គបញ្ញា ១ ធម៌ទាំងឡាយ ជាបក្ខពួកខាងសមាធិ ១ សីល ឈ្មោះថាជីវិតខ្ពស់បំផុត ១ សត្វទាំងឡាយរមែងស្អាតដោយធម៌នេះ មិនមែនដោយគោត្រ ឬមិនមែនដោយទ្រព្យឡើយ ព្រោះហេតុនោះ បុរសជាបណ្ឌិត កាលបើឃើញច្បាស់នូវប្រយោជន៍របស់ខ្លួន ត្រូវពិចារណាធម៌ ដោយឧបាយនៃប្រាជ្ញា ទើបស្អាតក្នុងធម៌នោះយ៉ាងនេះបាន មានតែព្រះសារីបុត្តមួយ ទើបប្រសើរដោយបញ្ញាផង ដោយសីលផង ដោយកិរិយារម្ងាប់នូវកិលេសផង ទុកជាភិក្ខុណាដល់នូវត្រើយគឺព្រះនិព្វាន (ភិក្ខុនោះ) ក៏មានគុណអស់ត្រឹមប៉ុណ្ណោះឯង ។

លុះអនាថបិណ្ឌិកទេវបុត្ត ពោលនូវគាថានេះចប់ ព្រះសាស្តាក៏មានព្រះហឫទ័យត្រេកអរ ។ លំដាប់នោះ អនាថបិណ្ឌិកទេវបុត្តដឹងថាព្រះសាស្តារបស់អាត្មាអញ មានព្រះហឫទ័យត្រេកអរហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណរួចក៏បាត់ក្នុងទីនោះទៅ ។

សទ្ធាយតនវគ្គស្ស អនាថបិណ្ឌិកោវាទសុត្តេ ជេតវនប្បសំសនំ

[២១៤] អថខោ ភគវា តស្សា រត្តិយា អច្ចយេន ភិក្ខូ អាមន្តេសិ ឥមំ ភិក្ខវេ រត្តឹ អញ្ញតរោ ទេវបុត្តោ អភិក្កន្តាយ រត្តិយា អភិក្កន្តវណ្ណោ កេវលកប្បំ ជេតវនំ ឱភាសេត្វា យេនាហំ តេនុបសង្កមិ ឧបសង្កមិត្វា មំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ សោ ទេវបុត្តោ មំ ឥមាហិ[១] គាថាហិ អជ្ឈភាសិ

ឥទំ ហិតំ ជេតវនំ

ឥសិសង្ឃនិសេវិតំ

អាវុត្ថំ ធម្មរាជេន

បីតិសញ្ជននំ មម

កម្មំ វិជ្ជា ច ធម្មោ ច

សីលំ ជីវិតមុត្តមំ

១ ឱ. ឥមាហីតិ ន ទិស្សតិ ។

[២១៤] លុះកន្លងរាត្រីនោះទៅហើយ ព្រះមានព្រះភាគក៏ត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ កាលដែលរាត្រីបឋមយាមកន្លងទៅហើយ ក្នុងយប់នេះឯង មានទេវបុត្តមួយអង្គ មានរស្មីដ៏រុងរឿង ញុំាងវត្តជេតពនទាំងអស់ឲ្យភ្លឺស្វាង ហើយក៏ចូលមករកតថាគត លុះចូលមកដល់ ថ្វាយបង្គំតថាគត ហើយឋិតនៅក្នុងទីសមគួរ ។ លុះទេវបុត្តនោះ ឋិតនៅក្នុងទីសមគួរហើយ ពោលគាថាទាំងនេះ ចំពោះតថាគតថា

វត្តជេតពននេះ សុទ្ធតែពួកលោកអ្នកស្វែងរកគុណដ៏ល្អ នៅ
អាស្រ័យជានិច្ច ដែលព្រះពុទ្ធជាធម្មរាជ គង់អាស្រ័យនៅ
ហើយ ជាទីញុំាងបីតិឲ្យកើតព្រម ដល់ខ្ញុំព្រះអង្គ កម្ម ១
វិជ្ជា ១ ធម៌ទាំងឡាយ ១ សីល ឈ្មោះថាជីវិតខ្ពស់បំផុត ១

ឯតេន មច្ចា សុជ្ឈន្តិ
ន គោត្តេន ន ធនេន វា
តស្មា ហិ បណ្ឌិតោ បោសោ
សម្បស្សំ អត្ថមត្តនោ
យោនិសោ វិចិនេ ធម្មំ
ឯវំ តត្ថ វិសុជ្ឈតិ
សារីបុត្តោវ បញ្ញាយ
សីលេន ឧបសមេន ច
យោ ហិ បារគតោ ភិក្ខុ
ឯតាវបរមោ សិយាតិ ។

ឥទមវោច ភិក្ខវេ សោ ទេវបុត្តោ សមនុញ្ញោ មេ សត្ថាតិ មំ អភិវាទេត្វា បទក្ខិណំ កត្វា តត្ថេវន្តរធាយីតិ ។

សត្វទាំងឡាយ រមែងស្អាតដោយធម៌នេះ មិនមែនដោយគោត្រ ឬមិនមែនដោយទ្រព្យឡើយ ព្រោះហេតុនោះ បុរសជាបណ្ឌិត កាលបើឃើញច្បាស់នូវប្រយោជន៍របស់ខ្លួនហើយ ត្រូវពិចារណានូវធម៌ដោយឧបាយនៃប្រាជ្ញា ទើបស្អាតក្នុងធម៌នោះ យ៉ាងនេះបាន មានតែព្រះសារីបុត្តមួយ ទើបប្រសើរដោយបញ្ញាផង ដោយសីលផង ដោយកិរិយារម្ងាប់នូវកិលេសផង ទុកជាភិក្ខុណាបានដល់នូវត្រើយគឺព្រះនិព្វាន (ភិក្ខុនោះ) ក៏មានគុណអស់ត្រឹមប៉ុណ្ណោះឯង ។

ម្នាលភិក្ខុទាំងឡាយ លុះទេវបុត្តនោះ ពោលនូវគាថានេះចប់ហើយ ដឹងថាព្រះសាស្តា របស់អាត្មាអញ មានព្រះហឫទ័យត្រេកអរហើយ ក៏ក្រាបថ្វាយបង្គំតថាគត ធ្វើប្រទក្សិណរួចក៏បាត់ ក្នុងទីនោះទៅ ។

សឡាយតនវគ្គស្ស អនាថបិណ្ឌិកោវាទសុត្តេ ភាសិតាភិនន្ទនំ

[២១៤] ឯវំ វុត្តេ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច សោ ហិ នូន សោ ភន្តេ អនាថបិណ្ឌិកោ ទេវបុត្តោ ភវិស្សតិ អនាថបិណ្ឌិកោ ភន្តេ គហបតិ អាយស្មន្តេ សារីបុត្តេ អភិប្បសន្នោ[១] អហោសីតិ ។ សាធុ សាធុ អានន្ទ យាវតកំ ខោ អានន្ទ តក្កាយ បត្តព្វំ អនុប្បត្តំ តយា អនាថបិណ្ឌិកោ សោ ទេវ-បុត្តោ នញ្ញោតិ ។ ឥទមវោច ភគវា អត្តមនោ អាយស្មា អានន្ទោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

អនាថបិណ្ឌិកោវាទសុត្តំ បឋមំ និដ្ឋិតំ ។

១ ឱ. អវេច្ចប្បសន្នោ ។

សឡាយតនវគ្គ អនាថបិណ្ឌិកោវាទសូត្រ សេចក្តីត្រេកអរចំពោះភាសិត

[២១៥] កាលបើព្រះមានព្រះភាគ មានព្រះពុទ្ធដីកាយ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ទេវបុត្តនោះឯង ប្រាកដជាអនាថបិណ្ឌិកគហបតីនោះ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះអនាថបិណ្ឌិកគហបតី បានជ្រះថ្លាក្រៃពេក ក្នុងព្រះសារីបុត្តមានអាយុ ។ ម្នាលអានន្ទ ត្រូវហើយ ៗ ម្នាលអានន្ទ ហេតុដែលអ្នកបានត្រិះរិះនោះ ត្រូវហើយ ទេវបុត្តនោះគឺអនាថបិណ្ឌិកហ្នឹងឯង មិនមែនអ្នកដទៃទេ ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់នូវពាក្យនេះចប់ហើយ ព្រះអានន្ទមានអាយុ មានសេចក្តីត្រេកអររីករាយ នឹងភាសិតព្រះមានព្រះភាគ ។

ចប់ អនាថបិណ្ឌិកោវាទសូត្រ ទី ១ ។

# ទុតិយំ ឆន្នោវាទសុត្តំ

[២១៦] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន អាយស្មា ច សារីបុត្តោ អាយស្មា ច មហាចុន្ទោ អាយស្មា ច ឆន្នោ គិជ្ឈកូដេ បព្វតេ វិហរន្តិ ។ តេន ខោ បន សមយេន អាយស្មា ឆន្នោ អាពាធិកោ ហោតិ ទុក្ខិតោ ពាឡ្ហគិលានោ ។

[១១៧] អថខោ អាយស្មា សារីបុត្តោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេនាយស្មា មហាចុន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ មហាចុន្ទំ ឯតទវោច អាយាមាវុសោ ចុន្ទ យេនាយស្មា ឆន្នោ តេនុបសង្កមិស្សាម[១] គិលានបុច្ឆកាតិ ។ ឯវមាវុសោតិ ខោ អាយស្មា មហាចុន្ទោ អាយស្មតោ សារីបុត្តស្ស បច្ចស្សោសិ ។

---

១ ឱ. តេនុបសង្កមេយ្យាម ។

# ឆន្នោវាទសូត្រ ទី ២

[២១៦] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគគង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជ-គ្រឹះ ។ ក៏ក្នុងសម័យនោះ ព្រះសារីបុត្រមានអាយុ ព្រះមហាចុន្ទៈមានអាយុ និងព្រះឆន្នៈមានអាយុ កំពុងគង់នៅនាភ្នំគិជ្ឈកូដ ។ សម័យនោះឯង ព្រះឆន្នៈមានអាយុ មានអាពាធ ដល់នូវសេចក្តីទុក្ខឈឺចាប់ជាទម្ងន់ ។

[២១៧] គ្រានោះ ព្រះសារីបុត្រ មានអាយុ ចេញចាកផលសមាបត្តិ ក្នុងសាយណ្ហសម័យ ហើយចូលទៅរកព្រះមហាចុន្ទៈមានអាយុ លុះចូលទៅដល់ហើយ បាននិយាយនឹងព្រះមហាចុន្ទៈមានអាយុយ៉ាងនេះថា ម្នាលចុន្ទៈមានអាយុ មក យើងចូលទៅរកព្រះឆន្នៈមានអាយុ នឹងបានសួរជំងឺ ។ ព្រះមហាចុន្ទៈមានអាយុទទួលពាក្យព្រះសារីបុត្រមានអាយុថា ករុណា លោកមានអាយុ ។

អថខោ អាយស្មា ច សារីបុត្តោ អាយស្មា ច មហាចុន្ទោ យេនាយស្មា ឆន្នោ តេនុបសង្កមឹសុ ឧបសង្កមិត្វា អាយស្មតា ឆន្នេន សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ អាយស្មន្តំ ឆន្នំ ឯតទវោច កច្ចិ តេ អាវុសោ ឆន្ន ខមនីយំ កច្ចិ យាបនីយំ កច្ចិ[១] ទុក្ខា វេទនា បដិក្កមន្តិ នោ អភិក្កមន្តិ បដិក្កមោសានំ បញ្ញាយតិ នោ អភិក្កមោតិ ។ ន មេ អាវុសោ សារីបុត្ត ខមនីយំ ន យាបនីយំ ពាឡ្ហា មេ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ អភិក្កមោសានំ បញ្ញាយតិ នោ បដិក្កមោតិ ។

[២១៨] សេយ្យថាបិ អាវុសោ សារីបុត្ត ពលវា បុរិសោ តិណ្ហេន សិខរេន សីសំ អភិមត្ថេយ្យ ឯវមេវ ខោ មេ អាវុសោ សារីបុត្ត អធិមត្តា វាតា មុទ្ធានំ ឱហនន្តិ ន មេ អាវុសោ សារីបុត្ត ខមនីយំ ន យាបនីយំ

១ ឱ. ម. កច្ចិ តេ ។

លំដាប់នោះ ព្រះសារីបុត្រ មានអាយុ និងព្រះមហាចុន្ទៈ មានអាយុ ចូលទៅរកព្រះឆន្នៈមានអាយុ លុះចូលទៅដល់ហើយ ក៏និយាយរាក់-ទាក់សំណេះសំណាល ជាមួយនឹងព្រះឆន្នៈមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យគួររលឹកហើយ ទើបអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះសារីបុត្រមានអាយុ អង្គុយនៅក្នុងទីដ៏សមគួរហើយ បានសួរព្រះឆន្នៈមានអាយុយ៉ាងនេះថា ម្នាលអាវុសោឆន្នៈ លោកអាចអត់ធន់បានឬទេ លោកអាចញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបានឬទេ ទុក្ខវេទនាបានស្រាកស្រាន្ត មិនចម្រើនឡើងទេឬ ការធូរថយប្រាកដ ការចម្រើនមិនប្រាកដទេឬ ។ ព្រះឆន្នត្ថេរនិយាយថា ម្នាលអាវុសោសារីបុត្រ ខ្ញុំមិនអាចអត់ធន់បានទេ ខ្ញុំមិនអាចញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបានទេ ទុក្ខ-វេទនារបស់ខ្ញុំខ្លាំងណាស់ ចេះតែចម្រើនឡើង មិនស្រាកស្រាន្តទេ ការចម្រើនឡើងនៃទុក្ខវេទនាចេះតែប្រាកដ ការធូរថយមិនប្រាកដទេ ។

[២១៨] ម្នាលអាវុសោសារីបុត្រ បុរសមានកម្លាំង គប្បីចាក់ក្បាលដោយដែកស្រួចដ៏មុត យ៉ាងណា ម្នាលអាវុសោសារីបុត្រ ខ្យល់ដ៏ក្រៃលែងចាក់នូវក្បាលខ្ញុំ យ៉ាងនោះដែរ ម្នាលអាវុសោសារីបុត្រ ខ្ញុំមិនអាចអត់ធន់បានទេ ខ្ញុំមិនអាចញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅបានទេ

ពាឡ្ហា មេ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ អភិក្កមោសានំ បញ្ញាយតិ នោ បដិក្កមោតិ ។

[២១៩] សេយ្យថាបិ អាវុសោ សារីបុត្ត ពលវា បុរិសោ ទឡ្ហេន វរត្តខណ្ឌេន សីសេ សីសវេឋនំ ទទេយ្យ ឯវមេវ ខោ មេ អាវុសោ សារីបុត្ត អធិមត្តា វាតា សីសំ បរិកន្តន្តិ ន មេ អាវុសោ សារីបុត្ត ខមនីយំ ន យាបនីយំ ពាឡ្ហា មេ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ អភិក្កមោសានំ បញ្ញាយតិ នោ បដិក្កមោតិ ។

[២២០] សេយ្យថាបិ អាវុសោ សារីបុត្ត ទក្ខោ គោឃាតកោ វា គោឃាតកន្តេវាសី វា តិណ្ហេន គោវិកន្តនេន កុច្ឆឹ បរិកន្តេយ្យ ឯវមេវ ខោ មេ អាវុសោ សារីបុត្ត អធិមត្តា វាតា កុច្ឆឹ បរិកន្តន្តិ ន មេ អាវុសោ សារីបុត្ត ខមនីយំ

ទុក្ខវេទនាខ្ញុំខ្លាំងណាស់ ចេះតែចម្រើនឡើង មិនស្រាកស្រាន្តទេ ការចម្រើនឡើងនៃទុក្ខវេទនា ចេះតែប្រាកដ ការធូរថយមិនប្រាកដឡើយ ។

[២១៩] ម្នាលអាវុសោ សារីបុត្រ បុរសមានកម្លាំងរុំត្រឡែងក្បាលដោយកំណាត់ព្រ័ត្រដ៏មាំ យ៉ាងណា ម្នាលអាវុសោសារីបុត្រ ខ្យល់ដ៏ក្រៃលែងចាក់ដោតក្បាលខ្ញុំ យ៉ាងនោះដែរ ម្នាលអាវុសោ សារីបុត្រ ខ្ញុំមិនអាចអត់ធន់បានទេ ខ្ញុំមិនអាចញុំាងអត្តភាព ឲ្យប្រព្រឹត្តទៅបានទេ ទុក្ខវេទនារបស់ខ្ញុំខ្លាំងណាស់ ចេះតែចម្រើនទៅមុខ មិនស្រាកស្រាន្តទេ ការចម្រើនឡើងនៃទុក្ខវេទនាចេះតែប្រាកដ ការធូរថយមិនប្រាកដឡើយ ។

[២២០] ម្នាលអាវុសោ សារីបុត្រ អ្នកសម្លាប់គោ ឬកូនសិស្សអ្នកសម្លាប់គោ ដែលប៉ិនប្រសប់ គប្បីវះពោះគោ ដោយកាំបិតសម្រាប់អារគោដ៏មុត យ៉ាងណា ម្នាលអាវុសោសារីបុត្រ ខ្យល់ដ៏ក្រៃលែងវះអារពោះខ្ញុំ យ៉ាងនោះដែរ ម្នាលអាវុសោសារីបុត្រ ខ្ញុំមិនអាចអត់ធន់បានទេ

២៤៣



ន យាបនីយំ ពាឡ្ហា មេ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ អភិក្កមោសានំ បញ្ញាយតិ នោ បដិក្កមោតិ ។

[២២១] សេយ្យថាបិ អាវុសោ សារីបុត្ត ទ្វេ ពលវន្តោ បុរិសា ទុព្វលតរំ បុរិសំ នានាពាហាសុ គហេត្វា អង្គារកាសុយា សន្តាបេយ្យុំ សម្បរិតា-បេយ្យុំ ឯវមេវ ខោ មេ អាវុសោ សារីបុត្ត អធិមត្តោ កាយស្មឹ ឌាហោ ន មេ អាវុសោ សារីបុត្ត ខមនីយំ ន យាបនីយំ ពាឡ្ហា មេ ទុក្ខា វេទនា អភិក្កមន្តិ នោ បដិក្កមន្តិ អភិក្កមោសានំ បញ្ញាយតិ នោ បដិក្កមោ សត្ថំ អាវុសោ សារីបុត្ត អាហរិស្សាមិ នាវកង្ខាមិ ជីវិតន្តិ ។

ខ្ញុំមិនអាចញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅបានទេ ទុក្ខវេទនានៃខ្ញុំ ខ្លាំងណាស់ ចេះតែចម្រើនទៅមុខ មិនស្រាកស្រាន្តទេ ការចម្រើនឡើងនៃទុក្ខវេទនា ចេះតែប្រាកដ ការធូរថយមិនប្រាកដឡើយ ។

[២២១] ម្នាលអាវុសោ សារីបុត្រ បុរសមានកម្លាំងពីរនាក់ ចាប់នូវបុរសមានកម្លាំងថយ ត្រង់ដើមដៃម្ខាង ៗ ម្នាក់ នាំយកទៅពេលកម្តៅលើរណ្តៅរងើកភ្លើង យ៉ាងណា ម្នាលអាវុសោ សារីបុត្រ សេចក្តីក្តៅក្រហាយ ក្នុងរាងកាយរបស់ខ្ញុំដ៏ក្រៃលែង យ៉ាងនោះដែរ ម្នាលអាវុសោ សារីបុត្រ ខ្ញុំមិនអាចអត់ធន់បានទេ ខ្ញុំមិនអាចញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបានទេ ទុក្ខវេទនារបស់ខ្ញុំខ្លាំងណាស់ ចេះតែចម្រើនទៅមុខ មិនស្រាកស្រាន្តទេ ការចម្រើនឡើងនៃទុក្ខវេទនា ចេះតែប្រាកដ ការធូរថយមិនប្រាកដឡើយ ម្នាលអាវុសោសារីបុត្រ ខ្ញុំនឹងនាំយកនូវកាំបិត[១] ខ្ញុំមិនអាល័យជីវិតទេ ។

---

១ គ្រឿងសស្ត្រាសម្រាប់នាំបង់នូវជីវិត ឬសម្រាប់ប្រហារជីវិត ។

[២២២] មាយស្មា ឆន្នោ សត្ថំ អាហរេសិ យាវេតាយស្មា ឆន្នោ យាវេទត្ថំ មយំ អាយស្មន្តំ ឆន្នំ ឥច្ឆាម សចេ អាយស្មតោ ឆន្នស្ស នត្ថិ សប្បាយានិ ភោជនានិ អហំ អាយស្មតោ ឆន្នស្ស សប្បាយានិ ភោជនានិ បរិយេសិស្សាមិ សចេ អាយស្មតោ ឆន្នស្ស នត្ថិ សប្បាយានិ ភេសជ្ជានិ អហំ អាយស្មតោ ឆន្នស្ស សប្បាយានិ ភេសជ្ជានិ បរិយេសិស្សាមិ សចេ អាយស្មតោ ឆន្នស្ស នត្ថិ បដិរូបោ ឧបដ្ឋាកោ អហំ អាយស្មន្តំ ឆន្នំ ឧបដ្ឋហិស្សាមិ មាយស្មា ឆន្នោ សត្ថំ អាហរេសិ យាវេតាយស្មា ឆន្នោ យាវេទត្ថំ មយំ អាយស្មន្តំ ឆន្នំ ឥច្ឆាមាតិ ។

[២២៣] នមេ មេ អាវុសោ សារីបុត្ត នត្ថិ សប្បាយានិ ភោជនានិ នបិ មេ នត្ថិ សប្បាយានិ ភេសជ្ជានិ នបិ មេ នត្ថិ បដិរូបោ ឧបដ្ឋាកោ អបិចាវុសោ សារីបុត្ត បរិចិណ្ណោ[១] សត្ថា ទីឃរត្តំ មនាបេនេវ នោ អមនាបេន

១ ឱ. ម. ឯត្តន្តរេ មេតិ ទិស្សតិ ។

[២២២] ព្រះសារីបុត្រនិយាយថា ឆន្នៈមានអាយុ កុំកាន់យកកាំបិតឡើយ ឆន្នៈមានអាយុ ចូរញុំាងអត្តភាពឲ្យប្រព្រឹត្តទៅចុះ ពួកយើងចង់ឲ្យឆន្នៈមានអាយុ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ប្រសិនបើមិនមានភោជនជាទីសប្បាយ សម្រាប់ឆន្នៈមានអាយុទេ ខ្លួនខ្ញុំនឹងស្វែងរកភោជនជាទីសប្បាយ ឲ្យឆន្នៈមានអាយុ ប្រសិនបើមិនមានភេសជ្ជៈជាទីសប្បាយ សម្រាប់ឆន្នៈមានអាយុទេ ខ្លួនខ្ញុំនឹងស្វែងរកភេសជ្ជៈជាទីសប្បាយឲ្យឆន្នៈមានអាយុ ប្រសិនបើមិនមានមនុស្សជាឧបដ្ឋាកដ៏សមគួរសម្រាប់ឆន្នៈមានអាយុទេ ខ្លួនខ្ញុំនឹងបម្រើឆន្នៈមានអាយុ ឆន្នៈមានអាយុ កុំកាន់យកកាំបិតឡើយ ឆន្នៈមានអាយុ ចូរញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ យើងប្រាថ្នាឲ្យឆន្នៈមានអាយុ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅណាស់ ។

[២២៣] ឆន្នភិក្ខុឆ្លើយថា ម្នាលអាវុសោសារីបុត្រ ភោជនជាទីសប្បាយ សម្រាប់ខ្ញុំមិនមែនគ្មានទេ ភេសជ្ជៈជាទីសប្បាយសម្រាប់ខ្ញុំមិនមែនគ្មានទេ មនុស្សជាឧបដ្ឋាកដ៏សមគួរសម្រាប់ខ្ញុំមិនមែនគ្មានទេ ម្នាលអាវុសោសារីបុត្រ តែថាខ្ញុំធ្លាប់បម្រើព្រះសាស្ដា យូរអង្វែងមកហើយ ដោយសេចក្ដីពេញចិត្តពិត ៗ មិនមែនបម្រើដោយសេចក្ដីមិនពេញចិត្តទេ

ឯតំ ហិ អាវុសោ សារីបុត្ត សាវកស្ស បដិរូបំ យំ សត្ថារំ បរិចរេយ្យ មនាបេនេវ នោ អមនាបេន អនុបវជ្ជំ ឆន្នោ ភិក្ខុ សត្ថំ អាហរិស្សតីតិ ឯវមេតំ[១] អាវុសោ សារីបុត្ត ធារេហីតិ ។ បុច្ឆេយ្យាម មយំ អាយស្មន្តំ ឆន្នំ កញ្ចិ[២] ទេសំ សចេ អាយស្មា ឆន្នោ ឱកាសំ ករោតិ បញ្ហស្ស វេយ្យាករណាយាតិ ។ បុច្ឆាវុសោ សារីបុត្ត សុត្វា វេទិស្សាមីតិ ។

[២២៨] ចក្ខុំ អាវុសោ ឆន្ន ចក្ខុវិញ្ញាណំ ចក្ខុវិញ្ញាណវិញ្ញាតព្វេ ធម្មេ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សសិ សោតំ អាវុសោ ឆន្ន សោតវិញ្ញាណំ ។ បេ ។ ឃានំ អាវុសោ ឆន្ន ឃានវិញ្ញាណំ... ជិវ្ហំ អាវុសោ ឆន្ន ជិវ្ហាវិញ្ញាណំ... កាយំ អាវុសោ ឆន្ន កាយវិញ្ញាណំ... មនំ អាវុសោ ឆន្ន មនោវិញ្ញាណំ មនោវិញ្ញាណវិញ្ញាតព្វេ ធម្មេ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សតីតិ ។

១ ម. ឯវមេវ ខោ ត្វំ ។ ២ ឱ. កញ្ចិទេវ ។ ម. កិញ្ចិទេវ ។

ម្នាលអាវុសោសារីបុត្រ ព្រោះថា អំពើដែលសមគួរដល់សាវ័ក គឺត្រូវ បម្រើព្រះសាស្តា ដោយសេចក្តីពេញចិត្តពិត ៗ មិនមែនបម្រើដោយ សេចក្តីមិនពេញចិត្តនោះទេ ម្នាលអាវុសោសារីបុត្រ អ្នកចូរចាំទុក សេចក្តីនុ៎ះយ៉ាងនេះថា ឆន្នភិក្ខុនឹងកាន់យកកាំបិតឥតទោសពៃរ៍អ្វីទេ ។ ព្រះសារីបុត្រសួរថា បើឆន្នៈមានអាយុបើកឱកាសដើម្បីឆ្លើយប្រស្នាបាន យើងនឹងសួរនូវហេតុបន្តិចបន្តួចនឹងឆន្នៈមានអាយុ ។ ឆន្នភិក្ខុឆ្លើយថា ម្នាល អាវុសោសារីបុត្រ អ្នកសួរមកចុះ ខ្ញុំស្តាប់ហើយគង់នឹងដឹង ។

[២២៤] ម្នាលអាវុសោឆន្នៈ អ្នកពិចារណាឃើញនូវចក្ខុ នូវចក្ខុ-វិញ្ញាណ និងពួកធម៌ដែលគប្បីដឹងដោយចក្ខុវិញ្ញាណថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ដូច្នេះដែរឬ ម្នាលអាវុសោឆន្នៈ អ្នកពិចារណា ឃើញនូវសោតៈ នូវសោតវិញ្ញាណ ។ បេ ។ ម្នាលអាវុសោឆន្នៈ អ្នកពិចារ-ណាឃើញនូវឃានៈ នូវឃានវិញ្ញាណ... ម្នាលអាវុសោឆន្នៈ អ្នកពិចារ-ណាឃើញនូវជិវ្ហា នូវជិវ្ហាវិញ្ញាណ... ម្នាលអាវុសោឆន្នៈ អ្នកពិចារណា ឃើញនូវកាយ នូវកាយវិញ្ញាណ... ម្នាលអាវុសោឆន្នៈ អ្នកពិចារណា ឃើញនូវមនោ នូវមនោវិញ្ញាណ និងពួកធម៌ដែលគប្បីដឹងដោយមនោ-វិញ្ញាណថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ដូច្នេះដែរឬ ។

ចក្ខុំ អាវុសោ សារីបុត្ត ចក្ខុវិញ្ញាណំ ចក្ខុវិញ្ញាណវិញ្ញាតព្វេ ធម្មេ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សាមិ សោតំ អាវុសោ សារីបុត្ត សោតវិញ្ញាណំ... ឃានំ អាវុសោ សារីបុត្ត ឃានវិញ្ញាណំ... ជិវ្ហំ អាវុសោ សារីបុត្ត ជិវ្ហាវិញ្ញាណំ... កាយំ អាវុសោ សារីបុត្ត កាយវិញ្ញាណំ... មនំ អាវុសោ សារីបុត្ត មនោវិញ្ញាណំ មនោវិញ្ញាណវិញ្ញាតព្វេ ធម្មេ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សាមីតិ ។

[២២៥] ចក្ខុស្មឹ អាវុសោ ឆន្ន ចក្ខុវិញ្ញាណេ ចក្ខុវិញ្ញាណវិញ្ញាតព្វេសុ ធម្មេសុ កឹ ទិស្វា កឹ អភិញ្ញាយ ចក្ខុំ ចក្ខុវិញ្ញាណំ ចក្ខុវិញ្ញាណវិញ្ញាតព្វេ ធម្មេ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សសិ សោតស្មឹ អាវុសោ ឆន្ន សោតវិញ្ញាណេ... ឃានស្មឹ អាវុសោ ឆន្ន ឃានវិញ្ញាណេ...

ម្នាលអាវុសោសារីបុត្រ ខ្ញុំពិចារណាឃើញនូវចក្ខុ នូវចក្ខុវិញ្ញាណ និង ពួកធម៌ដែលគប្បីដឹងដោយចក្ខុវិញ្ញាណថា នុ៎ះមិនមែនរបស់អញ នុ៎ះ មិនមែនជាអញ នុ៎ះមិនមែនខ្លួនអញទេ ម្នាលអាវុសោសារីបុត្រ ខ្ញុំ ពិចារណាឃើញនូវសោតៈ នូវសោតវិញ្ញាណ... ម្នាលអាវុសោសារីបុត្រ ខ្ញុំពិចារណាឃើញនូវឃានៈ នូវឃានវិញ្ញាណ... ម្នាលអាវុសោសារីបុត្រ ខ្ញុំពិចារណាឃើញនូវជិវ្ហា នូវជិវ្ហាវិញ្ញាណ... ម្នាលអាវុសោសារីបុត្រ ខ្ញុំពិចារណាឃើញនូវកាយ នូវកាយវិញ្ញាណ... ម្នាលអាវុសោសារីបុត្រ ខ្ញុំពិចារណាឃើញនូវមនោ នូវមនោវិញ្ញាណ និងពួកធម៌ដែលគប្បីដឹង ដោយមនោវិញ្ញាណថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះ មិនមែនជាខ្លួនអញ ។

[២២៥] ព្រះសារីបុត្រសួរថា ម្នាលអាវុសោឆន្នៈ អ្នកឃើញ ដូចម្តេច ដឹងដូចម្តេច ក្នុងចក្ខុ ក្នុងចក្ខុវិញ្ញាណ និងក្នុងពួកធម៌ដែល គប្បីដឹងដោយចក្ខុវិញ្ញាណ ទើបពិចារណាឃើញនូវចក្ខុ នូវចក្ខុវិញ្ញាណ និងពួកធម៌ដែលគប្បីដឹងដោយចក្ខុវិញ្ញាណថា នុ៎ះមិនមែនរបស់អញ នុ៎ះ មិនមែនជាអញ នុ៎ះមិនមែនជាខ្លួនអញទេ ម្នាលអាវុសោឆន្នៈ ក្នុងសោតៈ ក្នុងសោតវិញ្ញាណ... ម្នាលអាវុសោឆន្នៈ ក្នុងឃានៈ ក្នុងឃានវិញ្ញាណ...

២៤៧



ជិវ្ហាយ អាវុសោ ឆន្ន ជិវ្ហាវិញ្ញាណេ... កាយស្មឹ អាវុសោ ឆន្ន កាយវិញ្ញាណេ... មនស្មឹ អាវុសោ ឆន្ន មនោវិញ្ញាណេ មនោវិញ្ញាណវិញ្ញាតព្វេសុ ធម្មេសុ កឹ ទិស្វា កឹ អភិញ្ញាយ មនំ មនោវិញ្ញាណំ មនោវិញ្ញាណវិញ្ញាតព្វេ ធម្មេ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សសីតិ ។ ចក្ខុស្មឹ អាវុសោ សារីបុត្ត ចក្ខុវិញ្ញាណេ ចក្ខុវិញ្ញាណវិញ្ញាតព្វេសុ ធម្មេសុ និរោធំ ទិស្វា និរោធំ អភិញ្ញាយ ចក្ខុំ ចក្ខុវិញ្ញាណំ ចក្ខុវិញ្ញាណវិញ្ញាតព្វេ ធម្មេ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សាមិ សោតស្មឹ អាវុសោ សារីបុត្ត សោតវិញ្ញាណេ... ឃានស្មឹ អាវុសោ សារីបុត្ត ឃានវិញ្ញាណេ... ជិវ្ហាយ អាវុសោ សារីបុត្ត ជិវ្ហាវិញ្ញាណេ... កាយស្មឹ អាវុសោ សារីបុត្ត កាយវិញ្ញាណេ... មនស្មឹ អាវុសោ សារីបុត្ត មនោវិញ្ញាណេ មនោវិញ្ញាណវិញ្ញាតព្វេសុ ធម្មេសុ និរោធំ ទិស្វា និរោធំ អភិញ្ញាយ

ម្នាលអាវុសោឆន្នៈ ក្នុងជិវ្ហា ក្នុងជិវ្ហាវិញ្ញាណ... ម្នាលអាវុសោឆន្នៈ ក្នុងកាយ ក្នុងកាយវិញ្ញាណ... ម្នាលអាវុសោឆន្នៈ អ្នកឃើញដូចម្ដេច ដឹងដូចម្ដេច ក្នុងមនោ ក្នុងមនោវិញ្ញាណ និងក្នុងពួកធម៌ដែលគប្បីដឹងដោយមនោវិញ្ញាណ ទើបពិចារណាឃើញ នូវមនោ នូវមនោ-វិញ្ញាណ និងពួកធម៌ដែលគប្បីដឹងដោយមនោវិញ្ញាណថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ ។ ម្នាលអាវុសោសារីបុត្រ ខ្ញុំឃើញនូវសេចក្ដីរលត់ ដឹងនូវសេចក្ដីរលត់ ក្នុងចក្ខុ ក្នុងចក្ខុវិញ្ញាណ និងក្នុងពួកធម៌ដែលគប្បីដឹងដោយចក្ខុវិញ្ញាណ បើពិចារណាឃើញនូវចក្ខុ នូវចក្ខុវិញ្ញាណ និងពួកធម៌ដែលគប្បីដឹងដោយចក្ខុវិញ្ញាណថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនអញទេ ម្នាលអាវុសោសារីបុត្រ ក្នុងសោតៈ ក្នុងសោតវិញ្ញាណ... ម្នាលអាវុសោសារីបុត្រ ក្នុងឃានៈ ក្នុងឃាន-វិញ្ញាណ... ម្នាលអាវុសោសារីបុត្រ ក្នុងជិវ្ហា ក្នុងជិវ្ហាវិញ្ញាណ... ម្នាលអាវុសោសារីបុត្រ ក្នុងកាយ ក្នុងកាយវិញ្ញាណ... ម្នាលអាវុសោសារីបុត្រ ខ្ញុំឃើញនូវសេចក្ដីរលត់ ដឹងនូវសេចក្ដីរលត់ ក្នុងមនោ ក្នុងមនោវិញ្ញាណ និងក្នុងពួកធម៌ដែលគប្បីដឹង ដោយមនោវិញ្ញាណ

មនំ មនោវិញ្ញាណំ មនោវិញ្ញាណវិញ្ញាតព្វេ ធម្មេ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សាមីតិ ។

[២២៦] ឯវំ វុត្តេ អាយស្មា មហាចុន្ទោ អាយស្មន្តំ ឆន្នំ ឯតទវោច តស្មាតិហ អាវុសោ ឆន្ន ឥទម្បិ តស្ស ភគវតោ សាសនំ និច្ចកប្បំ មនសិ[១] កាតព្វំ និស្សិតស្ស ចលិតំ អនិស្សិតស្ស ចលិតំ នត្ថិ ចលិតេ អសតិ បស្សទ្ធិ បស្សទ្ធិយា សតិ នតិ ន ហោតិ នតិយា អសតិ អាគតិគតិ ន ហោតិ អាគតិគតិយា អសតិ ចុតូបបាតោ ន ហោតិ ចុតូបបាតេ អសតិ នេវិធ ន ហុរំ ន ឧភយមន្តរេន ឯសេវន្តោ ទុក្ខស្សាតិ ។ អថខោ

១ ឱ. ម. មនសីតិ ទិស្សតិ ។

ទើបពិចារណាឃើញនូវមនោ នូវមនោវិញ្ញាណ និងពួកធម៌ដែលគប្បីដឹង ដោយមនោវិញ្ញាណថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអញ នុ៎ះ មិនមែនជាខ្លួនរបស់អញទេ ។

[២២៦] កាលបើឆន្នភិក្ខុនិយាយយ៉ាងនេះហើយ ព្រះមហា-ចុន្ទៈមានអាយុ និយាយនឹងឆន្នៈមានអាយុយ៉ាងនេះថា ម្នាលអាវុសោ ឆន្នៈ ព្រោះហេតុនោះ សាសនានេះ របស់ព្រះមានព្រះភាគនោះ បុគ្គលគួរធ្វើទុកក្នុងចិត្តអស់កាលជានិច្ច បុគ្គលដែលមានតណ្ហានិងទិដ្ឋិអាស្រ័យនៅហើយ តែងមានសេចក្តីញាប់ញ័រ បុគ្គលដែលមិនមានតណ្ហានិងទិដ្ឋិអាស្រ័យនៅហើយ មិនមានសេចក្តីញាប់ញ័រទេ កាលបើសេចក្តីញាប់ញ័រមិនមានហើយ សេចក្តីស្ងប់រម្ងាប់ នៃកាយនិងចិត្តរមែងមាន កាលបើសេចក្តីស្ងប់រម្ងាប់មានហើយ តណ្ហាក៏មិនមាន កាលបើតណ្ហាមិនមានហើយ អាគតិ និងគតិ[១] ក៏មិនមាន កាលបើអាគតិ និងគតិមិនមានហើយ ចុតិនិងបដិសន្ធិក៏មិនមាន កាលបើចុតិនិងបដិសន្ធិ មិនមានហើយ លោកនេះក៏មិនមាន លោកខាងមុខក៏មិនមាន លោកទាំងពីរក៏មិនមាន នេះហៅថាទីបំផុតនៃទុក្ខ ។ គ្រានោះឯង

---

១ ដំណើរមកដោយអំណាចបដិសន្ធិហៅអាគតិ ដំណើរទៅដោយអំណាចចុតិ ហៅគតិ ។

អាយស្មា ច សារីបុត្តោ អាយស្មា ច មហាចុន្ទោ អាយស្មន្តំ ឆន្នំ ឥមិនា ឱវាទេន ឱវទិត្វា ឧដ្ឋាយាសនា បក្កមឹសុ ។

[២២៧] អថខោ អាយស្មា ឆន្នោ អចិរបក្កន្តេ អាយស្មន្តេ ច សារីបុត្តេ អាយស្មន្តេ ច មហាចុន្ទេ សត្ថំ អាហរេសិ ។ អថខោ អាយស្មា សារីបុត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ ភគវន្តំ ឯតទវោច អាយស្មតា ភន្តេ ឆន្នេន សត្ថំ អាហរិតំ តស្ស កា គតិ កោ អភិសម្បរាយោតិ ។ ននុ តេ សារីបុត្ត ឆន្នេន ភិក្ខុនា សម្មុខាយេវ អនុបវជ្ជតា ព្យាកតាតិ ។ អត្ថិ ភន្តេ បុព្វជិរំ នាម វជ្ជិគ្គាមោ តត្ថាយស្មតោ[១] ឆន្នស្ស មិត្តកុលានិ សុហជ្ជកុលានិ ឧបវជ្ជកុលានីតិ ។

១ ឱ. តត្រាយស្មតោ ។

ព្រះសារីបុត្រមានអាយុ និងព្រះមហាចុន្ទៈមានអាយុ បាននិយាយទូន្មានឆន្នៈមានអាយុ ដោយឱវាទនេះហើយ ក៏ក្រោកអំពីអាសនៈចេញទៅ ។

[២២៧] គ្រាកាលដែលព្រះសារីបុត្រមានអាយុ និងព្រះមហាចុន្ទៈមានអាយុ ចេញទៅមិនយូរប៉ុន្មាន ព្រះឆន្នៈមានអាយុក៏នាំយកនូវកាំបិត ។ គ្រានោះ ព្រះសារីបុត្រមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគហើយអង្គុយនៅក្នុងទីសមគួរ ។ លុះព្រះសារីបុត្រមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ឆន្នៈមានអាយុ នាំយកនូវកាំបិតហើយ គតិរបស់លោក ដូចម្តេចទៅ បរលោកដូចម្តេចទៅ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលសារីបុត្រ ការមិនមានទោស (នោះ) ឆន្នភិក្ខុបានព្យាករចំពោះមុខអ្នកឯងហើយតើ ។ បពិត្រព្រះអង្គដ៏ចម្រើន មានស្រុកវជ្ជី ឈ្មោះបុព្វជីរៈ ត្រកូលជាមិត្រ ត្រកូលជាសំឡាញ់ ត្រកូលដែលគួរចូលទៅរក របស់ឆន្នៈមានអាយុ មាននៅក្នុងស្រុកនោះ ។

[២២៨] ហោន្តិ ហោតានិ(១) សារីបុត្ត ឆន្នស្ស ភិក្ខុនោ មិត្តកុលានិ សុហជ្ជកុលានិ ឧបវជ្ជកុលានិ នាហំ សារីបុត្ត ឯត្តាវតា ឧបវជ្ជោតិ វទាមិ យោ ខោ សារីបុត្ត ឥមញ្ច កាយំ និក្ខិបតិ អញ្ញញ្ច កាយំ ឧបាទិយតិ តមហំ ឧបវជ្ជោតិ វទាមិ តំ ឆន្នស្ស ភិក្ខុនោ នត្ថិ អនុបវជ្ជំ(២) ឆន្នោ ភិក្ខុ សត្ថំ អាហរេសីតិ(៣) ។ ឥទមវោច ភគវា អត្តមនោ អាយស្មា សារីបុត្តោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

ឆន្នោវាទសុត្តំ ទុតិយំ និដ្ឋិតំ ។

---

១ ឱ. ហោន្តិ ហោតេ ។ ម. បោសន្តិ ហោតេ ។ ២ ឱ. ម. អនុបវជ្ជោ ។ ៣ ម. ឥតោ បរំ ឯវមេតំ សារីបុត្ត ធារេហីតិ ។

[២២៨] ព្រះមានព្រះភាគត្រាស់ថា ម្នាលសារីបុត្រ ត្រកូលទាំងនោះ គឺត្រកូលជាមិត្រ ត្រកូលជាសំឡាញ់ ត្រកូលដែលគួរចូលទៅរករបស់ឆន្នភិក្ខុ មានមែនហើយ ម្នាលសារីបុត្រ តែតថាគតមិនហៅថាជាបុគ្គលគួរតិះដៀល ដោយហេតុមានប្រមាណប៉ុណ្ណេះទេ ម្នាលសារីបុត្រ អ្នកណាដាក់ចុះនូវកាយនេះផង ប្រកាន់នូវកាយឯទៀតផង តថាគតហៅអ្នកនោះថា គួរគេតិះដៀល ដំណើរនោះ មិនមានដល់ឆន្នភិក្ខុទេ ឆន្នភិក្ខុនាំយកនូវកាំបិតឥតមានទោសឡើយ ។ លុះព្រះមានព្រះភាគពោលពាក្យនេះហើយ ព្រះសារីបុត្រមានអាយុ ក៏មានសេចក្ដីត្រេកអរ រីករាយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ ឆន្នោវាទសូត្រ ទី ២ ។

# តតិយំ បុណ្ណោវាទសុត្តំ

[២២៩] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អា-រាមេ ។ អថខោ អាយស្មា បុណ្ណោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា បុណ្ណោ ភគវន្តំ ឯតទវោច សាធុ មំ ភន្តេ ភគវា សង្ខិត្តេន ឱវាទេន ឱវទតុ យមហំ ភគវតោ ធម្មំ សុត្វា ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរេយ្យន្តិ ។ តេនហិ បុណ្ណ សុណាហិ សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវម្ភន្តេតិ ខោ សោ អាយស្មា បុណ្ណោ ភគវតោ បច្ចស្សោសិ ។

# បុណ្ណោវាទសូត្រ ទី ៣

[២២៩] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រះបុណ្ណៈមានអាយុចេញចាកទីសម្ងំ ក្នុងវេលារសៀល ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះបុណ្ណៈមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ មេត្តាប្រោស ទូន្មានខ្ញុំព្រះអង្គដោយព្រះឱវាទយ៉ាងសង្ខេប លុះខ្ញុំព្រះអង្គស្តាប់នូវធម៌ របស់ព្រះមានព្រះភាគហើយ នឹងចេញទៅតែម្នាក់ឯង មិនប្រមាទ មានព្យាយាមជាគ្រឿងដុតបំផ្លាញកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន សម្រេចសម្រាន្តឥរិយាបថទាំង ៤ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលបុណ្ណៈ បើដូច្នោះ អ្នកចូរប្រុងស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យល្អ តថាគតនឹងសំដែង ។ ព្រះបុណ្ណៈមានអាយុនោះទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[២៣០] ភគវា ឯតទវោច សន្តិ ខោ បុណ្ណ ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ អភិនន្ទតិ អភិវទតិ អជ្ឈោសាយ តិដ្ឋតិ តស្ស តំ អភិនន្ទតោ អភិវទតោ អជ្ឈោសាយ តិដ្ឋតោ ឧប្បជ្ជតិ នន្ទិ នន្ទិសមុទយា ទុក្ខសមុទយោ បុណ្ណាតិ វទាមិ ។ សន្តិ ខោ បុណ្ណ សោតវិញ្ញេយ្យា សទ្ទា... ឃានវិញ្ញេយ្យា គន្ធា... ជិវ្ហាវិញ្ញេយ្យា រសា... កាយវិញ្ញេយ្យា ផោដ្ឋព្វា... មនោវិញ្ញេយ្យា ធម្មា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ អភិនន្ទតិ អភិវទតិ អជ្ឈោសាយ តិដ្ឋតិ តស្ស តំ អភិនន្ទតោ អភិវទតោ អជ្ឈោសាយ តិដ្ឋតោ ឧប្បជ្ជតិ នន្ទិ នន្ទិសមុទយា ទុក្ខសមុទយោ បុណ្ណាតិ វទាមិ ។

[២៣០] ព្រះមានព្រះភាគ ត្រាស់យ៉ាងនេះថា ម្នាលបុណ្ណៈ រូបដែលគប្បីដឹងដោយភ្នែក ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរឲ្យកើតតម្រេកក៏មាន បើភិក្ខុរីករាយ ពោលសរសើរ ប្រកាន់ខ្ជាប់នូវរូបនោះ កាលដែលភិក្ខុនោះរីករាយ ពោលសរសើរ ប្រកាន់ខ្ជាប់នូវរូបនោះហើយ សេចក្តីរីករាយក៏កើតឡើង ម្នាលបុណ្ណៈ តថាគតពោលថា ការកើតឡើងនៃសេចក្តីទុក្ខ ព្រោះការកើតឡើងនៃសេចក្តីរីករាយ ។ ម្នាលបុណ្ណៈ សំឡេងដែលគប្បីដឹងដោយត្រចៀក... ក្លិនដែលគប្បីដឹងដោយច្រមុះ... រសដែលគប្បីដឹងដោយអណ្តាត... ផោដ្ឋព្វៈដែលគប្បីដឹងដោយកាយ... ធម៌ដែលគប្បីដឹងដោយចិត្ត ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរឲ្យកើតតម្រេកក៏មាន បើភិក្ខុ រីករាយ ពោលសរសើរ ប្រកាន់ខ្ជាប់នូវធម៌នោះ កាលដែលភិក្ខុនោះ រីករាយ ពោលសរសើរ ប្រកាន់ខ្ជាប់ នូវធម៌នោះហើយ សេចក្តីរីករាយក៏កើតឡើង ម្នាលបុណ្ណៈ តថាគតពោលថា ការកើតឡើងនៃសេចក្តីទុក្ខ ព្រោះការកើតឡើងនៃសេចក្តីរីករាយ ។

សឡាយតនវគ្គស្ស បុណ្ណោវាទសុត្តេ ឱវាទទានំ

[២៣១] សន្តិ ខោ[១] បុណ្ណ ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ នាភិនន្ទតិ នាភិវទតិ នាជ្ឈោសាយ តិដ្ឋតិ តស្ស តំ អនភិនន្ទតោ អនភិវទតោ អនជ្ឈោសាយ តិដ្ឋតោ នន្ទិ និរុជ្ឈតិ នន្ទិនិរោធា ទុក្ខនិរោធោ បុណ្ណាតិ វទាមិ ។ សន្តិ ខោ បុណ្ណ សោតវិញ្ញេយ្យា សទ្ទា... ឃានវិញ្ញេយ្យា គន្ធា... ជិវ្ហាវិញ្ញេយ្យា រសា... កាយវិញ្ញេយ្យា ផោដ្ឋព្វា... មនោវិញ្ញេយ្យា ធម្មា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសញ្ហិតា រជនីយា តញ្ចេ ភិក្ខុ នាភិនន្ទតិ នាភិវទតិ នាជ្ឈោសាយ តិដ្ឋតិ តស្ស តំ អនភិនន្ទតោ អនភិវទតោ អនជ្ឈោសាយ តិដ្ឋតោ នន្ទិ និរុជ្ឈតិ

១ ឱ. ម. ច ខោ ។

[២៣១] ម្នាលបុណ្ណៈ រូបដែលគប្បីដឹងដោយចក្ខុ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរឲ្យកើតតម្រេកក៏មាន បើភិក្ខុមិនរីករាយ មិនពោលសរសើរ មិនប្រកាន់ខ្ជាប់នូវរូបនោះ កាលដែលភិក្ខុនោះមិនរីករាយ មិនពោលសរ-សើរ មិនប្រកាន់ខ្ជាប់នូវរូបនោះហើយ សេចក្ដីរីករាយក៏រលត់ទៅ ម្នាលបុណ្ណៈ តថាគតពោលថា ការរលត់សេចក្ដីទុក្ខ ព្រោះការរលត់សេចក្ដីរីករាយ ។ ម្នាលបុណ្ណៈ សំឡេងដែលគប្បីដឹងដោយត្រចៀក... ក្លិនដែលគប្បីដឹងដោយច្រមុះ... រសដែលគប្បីដឹងដោយអណ្ដាត... ផោដ្ឋព្វៈដែលគប្បីដឹងដោយកាយ... ធម៌ដែលគប្បីដឹងដោយចិត្ត ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរឲ្យកើតតម្រេកក៏មាន បើភិក្ខុមិនរីករាយ មិនពោលសរសើរ មិនប្រកាន់ខ្ជាប់នូវធម៌នោះ កាលដែលភិក្ខុនោះមិនរីករាយ មិនពោលសរសើរ មិនប្រកាន់ខ្ជាប់នូវធម៌នោះហើយ សេចក្ដីរីករាយក៏រលត់ទៅ

នន្ទិនិរោធា ទុក្ខនិរោធោ បុណ្ណាតិ វទាមិ ។ ឥមិនា ច ត្វំ បុណ្ណ មយា សង្ខិត្តេន ឱវាទេន ឱវទិតោ កតមស្មឹ(១) ជនបទេ វិហរិស្សសីតិ ។ ឥមិនាហំ ភន្តេ ភគវតា សង្ខិត្តេន ឱវាទេន ឱវទិ-តោ អត្ថិ សុនាបរន្តោ នាម ជនបទោ តត្ថាហំ វិហរិស្សាមីតិ ។

[២៣២] ចណ្ឌា ខោ បុណ្ណ សុនាបរន្តកា មនុស្សា ផរុសា ខោ បុណ្ណ សុនាបរន្តកា មនុស្សា សចេ តំ បុណ្ណ សុនាបរន្តកា មនុស្សា អក្កោ-សិស្សន្តិ បរិភាសិស្សន្តិ តត្ថ តេ បុណ្ណ កិន្តិ ភ-វិស្សតីតិ ។ សចេ មំ ភន្តេ សុនាបរន្តកា មនុស្សា អក្កោសិស្សន្តិ បរិភាសិស្សន្តិ តត្ថ មេ ឯវំ ភ-វិស្សតិ ភទ្ទកា វតិមេ សុនាបរន្តកា មនុស្សា សុភទ្ទកា វតិមេ សុនាបរន្តកា មនុស្សា យំ មេ នយិមេ ចាណិនា បហារំ ទេន្តីតិ ឯវមេត្ថ ភគវា ភវិស្សតិ ឯវមេត្ថ សុគត ភវិស្សតីតិ ។

---

១ ឱ. ម. កតរស្មឹ ។

ម្នាលបុណ្ណៈ តថាគតពោលថា ការរលត់សេចក្ដីទុក្ខ ព្រោះការរលត់សេចក្ដីរីករាយ ។ ម្នាលបុណ្ណៈ តថាគតទូន្មានអ្នកដោយឱវាទយ៉ាងសង្ខេបនេះឯងហើយ តើអ្នកនឹងនៅក្នុងជនបទណា ។ ព្រះបុណ្ណៈក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទូន្មានខ្ញុំព្រះអង្គដោយឱវាទសង្ខេបនេះហើយ ខ្ញុំព្រះអង្គនឹងនៅក្នុងជនបទឈ្មោះសុនាបរន្តៈ ។

[២៣២] ព្រះមានព្រះភាគត្រាស់ថា ម្នាលបុណ្ណៈ ពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទ សុទ្ធតែកាច ៗ ម្នាលបុណ្ណៈ ពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទ សុទ្ធតែរឹងរូស ម្នាលបុណ្ណៈ ប្រសិនបើពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទ ជេរ គម្រាមអ្នក ម្នាលបុណ្ណៈ អ្នកនឹងប្រព្រឹត្តក្នុងហេតុនោះដូចម្ដេចទៅ ។ ព្រះបុណ្ណៈក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទនឹងជេរ គម្រាមខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនោះយ៉ាងនេះថា ពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទនេះ ជាមនុស្សល្អ ពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទនេះ ល្អណាស់ហ្ន៎ ដោយហេតុមនុស្សទាំងនេះ មិនប្រហារអាត្មាអញ ដោយបាតដៃ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនុ៎ះយ៉ាងនេះ បពិត្រព្រះសុគត ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនុ៎ះយ៉ាងនេះ ។

២៦៤

សឡាយតនវគ្គស្ស បុណ្ណោវាទសុត្តេ សុនាបរន្តកានំ ចណ្ឌាភាវោ

[២៣៣] សចេ បន តេ បុណ្ណ សុនាបរន្តកា មនុស្សា បាណិនា បហារំ ទស្សន្តិ តត្ថ បន តេ បុណ្ណ កិន្តិ ភវិស្សតីតិ ។ សចេ មេ ភន្តេ សុនា-បរន្តកា មនុស្សា បាណិនា បហារំ ទស្សន្តិ តត្ថ មេ ឯវំ ភវិស្សតិ ភទ្ទកា វតិមេ សុនាបរន្តកា មនុស្សា សុភទ្ទកា វតិមេ សុនាបរន្តកា មនុស្សា យំ មេ នយិមេ លេឌ្ឌុនា បហារំ ទេន្តីតិ ឯវមេត្ថ ភគវា ភវិស្សតិ ឯវមេត្ថ សុគត ភវិស្សតីតិ ។

[២៣៤] សចេ បន តេ បុណ្ណ សុនាបរន្តកា មនុស្សា លេឌ្ឌុនា បហារំ ទស្សន្តិ តត្ថ បន តេ បុណ្ណ កិន្តិ ភវិស្សតីតិ ។ សចេ មេ ភន្តេ សុនា-បរន្តកា មនុស្សា លេឌ្ឌុនា បហារំ ទស្សន្តិ

[២៣៣] ព្រះមានព្រះភាគសួរថា ម្នាលបុណ្ណៈ ប្រសិនបើពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទ នឹងប្រហារអ្នក ដោយបាតដៃ ម្នាលបុណ្ណៈ តើអ្នកនឹងប្រព្រឹត្តក្នុងហេតុនោះដូចម្តេច ។ ព្រះបុណ្ណៈក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទ នឹងប្រហារខ្ញុំព្រះអង្គ ដោយបាតដៃ ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនោះយ៉ាងនេះថា ពួកមនុស្សអ្នកនៅក្នុងសុនាបរន្ត-ជនបទនេះ ជាមនុស្សល្អ ពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទនេះល្អណាស់ហ្ន៎ ដោយហេតុមនុស្សទាំងនេះ មិនប្រហារអាត្មាអញដោយដុំដី បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនុ៎ះយ៉ាងនេះ បពិត្រព្រះសុគត ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនុ៎ះយ៉ាងនេះ ។

[២៣៤] ម្នាលបុណ្ណៈ ប្រសិនបើពួកមនុស្សអ្នកនៅក្នុងសុនាបរន្ត-ជនបទ នឹងប្រហារអ្នក ដោយដុំដី ម្នាលបុណ្ណៈ អ្នកនឹងប្រព្រឹត្តក្នុងហេតុនោះដូចម្តេចទៀត ។ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទ នឹងប្រហារខ្ញុំព្រះអង្គ ដោយដុំដី

តត្ថ មេ ឯវំ ភវិស្សតិ ភទ្ទកា វតិមេ សុនាបរន្តកា មនុស្សា សុភទ្ទកា វតិមេ សុនាបរន្តកា មនុស្សា យំ មេ នយិមេ ទណ្ឌេន បហារំ ទេន្តីតិ ឯវមេត្ថ ភគវា ភវិស្សតិ ឯវមេត្ថ សុគត ភវិស្សតីតិ ។

[២៣៥] សចេ បន តេ បុណ្ណ សុនាបរន្តកា មនុស្សា ទណ្ឌេន បហារំ ទស្សន្តិ តត្ថ បន តេ បុណ្ណ កិន្តិ ភវិស្សតីតិ ។ សចេ មេ ភន្តេ សុនាបរន្តកា មនុស្សា ទណ្ឌេន បហារំ ទស្សន្តិ តត្ថ មេ ឯវំ ភវិស្សតិ ភទ្ទកា វតិមេ សុនាបរន្តកា មនុស្សា សុភទ្ទកា វតិមេ សុនាបរន្តកា មនុស្សា យំ មេ នយិមេ សត្ថេន បហារំ ទេន្តីតិ ឯវមេត្ថ ភគវា ភវិស្សតិ ឯវមេត្ថ សុគត ភវិស្សតីតិ ។

ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនោះ យ៉ាងនេះថា ពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទនេះ ជាមនុស្សល្អ ពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទនេះ ល្អណាស់ហ្ន៎ ដោយហេតុមនុស្សទាំងនេះ មិនប្រហារអាត្មាអញ ដោយដំបង បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនុ៎ះយ៉ាងនេះ បពិត្រព្រះសុគត ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនុ៎ះយ៉ាងនេះ ។

[២៣៥] ម្នាលបុណ្ណៈ ប្រសិនបើ ពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទ នឹងប្រហារអ្នកដោយដំបង ម្នាលបុណ្ណៈ តើអ្នកនឹងប្រព្រឹត្តក្នុងហេតុនោះដូចម្តេចទៀត ។ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទ នឹងប្រហារខ្ញុំព្រះអង្គ ដោយដំបង ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនោះយ៉ាងនេះថា ពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទនេះ ជាមនុស្សល្អ ពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទនេះ ល្អណាស់ហ្ន៎ ដោយហេតុមនុស្សទាំងនេះ មិនប្រហារអាត្មាអញ ដោយកាំបិត បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនុ៎ះយ៉ាងនេះ បពិត្រព្រះសុគត ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនុ៎ះយ៉ាងនេះ ។

២៦៧

សឡាយតនវគ្គស្ស បុណ្ណោវាទសុត្តេ សុនាបរន្តកានំ ចណ្ឌាភាវោ

[២៣៦] សចេ បន តេ បុណ្ណ សុនាបរន្តកា មនុស្សា សត្ថេន បហារំ ទស្សន្តិ តត្ថ បន តេ បុណ្ណ កិន្តិ ភវិស្សតីតិ ។ សចេ មេ ភន្តេ សុនាបរន្តកា មនុស្សា សត្ថេន បហារំ ទស្សន្តិ តត្ថ មេ ឯវំ ភវិស្សតិ ភទ្ទកា វតិមេ សុនាបរន្តកា មនុស្សា សុភទ្ទកា វតិមេ សុនាបរន្តកា មនុស្សា យំ មំ នយិមេ តិណ្ហេន សត្ថេន ជីវិតា វោរោបេន្តីតិ ឯវមេត្ថ ភគវា ភវិស្សតិ ឯវមេត្ថ សុគត ភវិស្សតីតិ ។

[២៣៧] សចេ បន តំ បុណ្ណ សុនាបរន្តកា មនុស្សា តិណ្ហេន សត្ថេន ជីវិតា វោរោបេស្សន្តិ តត្ថ បន តេ បុណ្ណ កិន្តិ ភវិស្សតីតិ ។ សចេ មំ ភន្តេ សុនាបរន្តកា មនុស្សា តិណ្ហេន សត្ថេន ជីវិតា វោរោបេស្សន្តិ តត្ថ មេ ឯវំ ភវិស្សតិ សន្តិ ខោ ភគវតោ សាវកា កាយេន ច ជីវិតេន ច អដ្ដិយមានា ជិគុច្ឆិយមានា[១]

១ ឱ. ម. ជិគុច្ឆមានា ។

[២៣៦] ម្នាលបុណ្ណៈ ប្រសិនបើ ពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទ នឹងប្រហារអ្នក ដោយកាំបិត ម្នាលបុណ្ណៈ តើអ្នកនឹងប្រព្រឹត្តក្នុងហេតុនោះ ដូចម្តេចទៀត ។ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើ ពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទ នឹងប្រហារខ្ញុំព្រះអង្គ ដោយកាំបិត ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនោះ យ៉ាងនេះថា ពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទនេះ ជាមនុស្សល្អ ពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទនេះ ល្អណាស់ហ្ន៎ ដោយហេតុមនុស្សទាំងនេះ មិនផ្តាច់ជីវិតខ្ញុំព្រះអង្គ ដោយកាំបិតដ៏មុតឡើយ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនុ៎ះយ៉ាងនេះ បពិត្រព្រះសុគត ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនុ៎ះយ៉ាងនេះ ។

[២៣៧] ម្នាលបុណ្ណៈ ប្រសិនបើ ពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទ នឹងផ្តាច់ជីវិតអ្នក ដោយកាំបិតដ៏មុត ម្នាលបុណ្ណៈ តើអ្នកនឹងប្រព្រឹត្តក្នុងហេតុនោះដូចម្តេចទៀត ។ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើ ពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទ នឹងផ្តាច់ជីវិតខ្ញុំព្រះអង្គដោយកាំបិតដ៏មុតមែន ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនុ៎ះ យ៉ាងនេះថា ពួកសាវ័ករបស់ព្រះមានព្រះភាគ ជាទុក្ខ ធុញទ្រាន់ ខ្ពើមកាយនឹងជីវិត

សត្ថហារកំ បរិយេសន្តិ តំ មេ ឥទំ អបរិយិដ្ឋំយេវ សត្ថហារកំ លទ្ធន្តិ ឯវមេត្ថ ភគវា ភវិស្សតិ ឯវមេត្ថ សុគត ភវិស្សតីតិ ។

[២៣៨] សាធុ សាធុ បុណ្ណ សក្ខិស្សសិ ខោ ត្វំ បុណ្ណ ឥមិនា ទមូបសមេន សមន្នាគតោ សុនាបរន្តស្មឹ ជនបទេ វិហរិតុំ យស្សទានិ ត្វំ បុណ្ណ កាលំ មញ្ញសីតិ ។ អថខោ អាយស្មា បុណ្ណោ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា សេនាសនំ សំសាមេត្វា បត្តចីវរមាទាយ យេន សុនាបរន្តោ ជនបទោ តេន ចារិកំ បក្កាមិ ។ អនុបុព្វេន ចារិកញ្ចរមានោ យេន សុនាបរន្តោ ជនបទោ តទវសរិ ។

តែងស្វែងរក នូវគ្រឿងសស្ត្រាជាគ្រឿងនាំបង់នូវជីវិត អាត្មាអញមិនបាច់ស្វែង រកនូវគ្រឿងសស្ត្រា ជាគ្រឿងនាំបង់នូវជីវិតនោះទេ ស្រាប់តែបានមក បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនុ៎ះយ៉ាងនេះ បពិត្រព្រះសុគត ខ្ញុំព្រះអង្គ នឹងប្រព្រឹត្តក្នុងហេតុនុ៎ះយ៉ាងនេះ ។

[២៣៨] ម្នាលបុណ្ណៈ ប្រពៃណាស់ហើយ ម្នាលបុណ្ណៈ អ្នកឯងប្រកបដោយការទូន្មានចិត្តនិងការរម្ងាប់ចិត្តនេះហើយ ទើបគួរនឹងនៅក្នុងសុនាបរន្តជនបទបាន ម្នាលបុណ្ណៈ ចូរអ្នកសំគាល់នូវកាលគួរនឹងទៅឥឡូវនេះចុះ ។ គ្រានោះឯង ព្រះបុណ្ណៈមានអាយុ ត្រេកអរ អនុមោទនា ចំពោះភាសិត នៃព្រះមានព្រះភាគ ហើយក្រោកចាកអាសនៈ ថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយរៀបចំសេនាសនៈ រួចចាប់យកបាត្រនិងចីវរ និមន្តទៅកាន់ចារិក ក្នុងសុនាបរន្តជនបទ ។ លុះនិមន្តទៅកាន់ចារិកតាមលំដាប់ ក៏បានដល់សុនាបរន្តជនបទនោះ ។

សឡាយតនវគ្គស្ស បុណ្ណោវាទសុត្តេ បុណ្ណស្ស បរិនិព្វានំ

[២៣៩] តត្រ សុទំ អាយស្មា បុណ្ណោ សុនាបរន្តស្មឹ ជនបទេ វិហរតិ ។ អថខោ អាយស្មា បុណ្ណោ តេនេវន្តរវស្សេន បញ្ចមត្តានិ ឧបាសកសតានិ បដិទេសេសិ[១] តេនេវន្តរវស្សេន បញ្ចមត្តានិ ឧបាសិកាសតានិ បដិទេសេសិ តេនេវន្តរវស្សេន តិស្សោ វិជ្ជា សច្ឆាកាសិ ។ អថខោ អាយស្មា បុណ្ណោ អបរេន សមយេន បរិនិព្វាយិ ។ អថខោ សម្ពហុលា ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ យោ សោ ភន្តេ បុណ្ណោ នាម កុលបុត្តោ ភគវតា សង្ខិត្តេន ឱវាទេន ឱវទិតោ សោ កាលកតោ តស្ស កា គតិ កោ អភិសម្បរាយោតិ ។

---

១ ឱ. បដិបាទេសិ ។ ម. បដិវេទេសិ ។

[២៣៩] ឮថា ព្រះបុណ្ណៈមានអាយុ គង់នៅក្នុងសុនាបរន្តជនបទនោះ ។ គ្រានោះឯង ព្រះបុណ្ណៈមានអាយុ បានទូន្មានពួកឧបាសកប្រមាណ ៥០០ ខាងក្នុងវស្សានោះ បានទូន្មានពួកឧបាសិកាប្រមាណ ៥០០ ខាងក្នុងវស្សានោះ ហើយលោកបានធ្វើឲ្យជាក់ច្បាស់នូវវិជ្ជា ៣ ខាងក្នុងវស្សានោះដែរ ។ លំដាប់នោះ ព្រះបុណ្ណៈមានអាយុ ក៏បរិនិព្វានទៅ ក្នុងសម័យខាងក្រោយ ។ គ្រានោះឯង ភិក្ខុជាច្រើនរូប ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន កុលបុត្រឈ្មោះបុណ្ណៈដែលព្រះមានព្រះភាគ ទូន្មានដោយឱវាទសង្ខេប លោកធ្វើមរណកាលទៅហើយ គតិរបស់លោកដូចម្តេច បរលោកដូចម្តេចទៅ ។

[២៤០] បណ្ឌិតោ ភិក្ខវេ បុណ្ណោ កុលបុត្តោ បច្ចបាទិ ធម្មស្សានុធម្មំ ន ច មំ ធម្មាធិករណំ វិហេឋេសិ បរិនិព្វុតោ ភិក្ខវេ បុណ្ណោ កុលបុត្តោតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

បុណ្ណោវាទសុត្តំ តតិយំ និដ្ឋិតំ ។

[២៤០] ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កុលបុត្រឈ្មោះបុណ្ណៈជាបណ្ឌិត បានប្រព្រឹត្តធម៌ដ៏សមគួរដល់នវលោកុត្តរធម៌ ទាំងមិនបានញុំាំងតថាគតឲ្យលំបាកព្រោះធម៌ជាហេតុ ម្នាលភិក្ខុទាំងឡាយ កុលបុត្រឈ្មោះបុណ្ណៈ បរិនិព្វានហើយ ។ លុះព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះហើយ ភិក្ខុទាំងនោះ ក៏មានសេចក្តីត្រេកអរ រីករាយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ បុណ្ណោវាទសូត្រ ទី ៣ ។

# ចតុត្ថំ នន្ទកោវាទសុត្តំ

[២៤១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អា-រាមេ ។ អថខោ មហាបជាបតី គោតមី បញ្ចមត្តេហិ ភិក្ខុនីសតេហិ សទ្ធឹ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតា ខោ មហាបជាបតី គោតមី ភគវន្តំ ឯតទវោច ឱវទតុ ភន្តេ ភគវា ភិក្ខុនិយោ អនុសា-សតុ ភន្តេ ភគវា ភិក្ខុនិយោ ករោតុ ភន្តេ ភគវា ភិក្ខុនីនំ ធម្មីកថន្តិ ។

[២៤២] តេន ខោ បន សមយេន ថេរា ភិក្ខូ ភិក្ខុនិយោ ឱវទន្តិ បរិយាយេន ។ អា-យស្មា បន នន្ទកោ ន ឥច្ឆតិ ភិក្ខុនិយោ ឱវទិតុំ

# នន្ទកោវាទសូត្រ ទី ៤

[២៤១] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ លំដាប់នោះ ព្រះនាងមហាបជាបតិគោតមី ព្រមទាំងភិក្ខុនី ប្រមាណប្រាំរយរូប នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ លុះព្រះនាងមហាបជាបតិគោតមី ឋិតនៅក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់ទូន្មានពួកភិក្ខុនី បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់ប្រៀនប្រដៅពួកភិក្ខុនី បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ធ្វើនូវធម្មីកថាដល់ពួកភិក្ខុនី ។

[២៤២] ក្នុងសម័យនោះឯង ពួកភិក្ខុជាថេរៈតែងទូន្មានពួកភិក្ខុនីតាមវេន ។ ។ ចំណែកនន្ទកៈមានអាយុ មិនចង់ទូន្មានពួកភិក្ខុនី

បរិយាយេន ។ អថខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ កស្ស នុ ខោ អានន្ទ អជ្ជ បរិយាយោ ភិក្ខុនិយោ ឱវទិតុំ បរិយាយេនាតិ ។ សព្វេហេវ ភន្តេ កតោ បរិយាយោ(១) ភិក្ខុនិយោ ឱវទិតុំ បរិយាយេន អយំ ភន្តេ អាយស្មា នន្ទកោ ន ឥច្ឆតិ ភិក្ខុនិយោ ឱវទិតុំ បរិយាយេនាតិ ។ អថខោ ភគវា អាយស្មន្តំ នន្ទកំ អាមន្តេសិ ឱវទ នន្ទក ភិក្ខុនិយោ អនុសាស នន្ទក ភិក្ខុនិយោ ករោហិ ត្វំ ព្រាហ្មណ ភិក្ខុនីនំ ធម្មីកថន្តិ ។ ឯវម្ភន្តេតិ ខោ(២) អាយស្មា នន្ទកោ ភគវតោ បដិស្សុត្វា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថឹ បិណ្ឌាយ បាវិសិ ។ សាវត្ថិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ អត្តទុតិយោ យេន រាជការាមោ តេនុបសង្កមិ ។ អទ្ទសាសុំ ខោ តា ភិក្ខុនិយោ អាយស្មន្តំ នន្ទកំ ទូរតោវ អាគច្ឆន្តំ ទិស្វាន អាសនំ បញ្ញាបេតុំ ឧទកញ្ច បាទានំ ឧបដ្ឋបេសុំ ។

---

១ ឱ. នន្ទកស្ស ភន្តេ បរិយាយោ ។ ២ ឱ. ខោ សោ ។

តាមវេនឡើយ ។ ទើបព្រះមានព្រះភាគ ត្រាស់ហៅព្រះអានន្ទមានអាយុមកថា ម្នាលអានន្ទ ថ្ងៃនេះ ជាវេនភិក្ខុណាហ្ន៎ ដែលត្រូវឲ្យឱវាទពួកភិក្ខុនីតាមវេន ។ ព្រះអានន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុទាំងអស់ បានធ្វើវេន ដើម្បីទូន្មានពួកភិក្ខុនី តាមវេន ៗ ហើយ បពិត្រព្រះអង្គដ៏ចម្រើន នន្ទកៈមានអាយុនេះ មិនចង់ទូន្មានពួកភិក្ខុនីតាមវេនទេ ។ លំដាប់នោះ ព្រះមានព្រះភាគ ត្រាស់ហៅនន្ទកៈមានអាយុមកថា ម្នាលនន្ទកៈ អ្នកចូរទូន្មានពួកភិក្ខុនី ម្នាលនន្ទកៈ អ្នកចូរប្រៀនប្រដៅពួកភិក្ខុនី ម្នាលព្រាហ្មណ៍ អ្នកចូរធ្វើនូវធម្មីកថា ដល់ពួកភិក្ខុនី ។ នន្ទកៈមានអាយុ ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត ។ លុះត្រាច់ទៅបិណ្ឌបាតក្នុងក្រុងសាវត្ថីហើយ ត្រឡប់មកពីបិណ្ឌបាតវិញ ក្នុងវេលាក្រោយភត្ត មានខ្លួនជាគម្រប់ពីរ គឺមានគ្នាពីរនាក់ ចូលទៅកាន់រាជការាម ។ ពួកភិក្ខុនីទាំងនោះ បានឃើញនន្ទកៈមានអាយុ មកអំពីចម្ងាយ លុះឃើញហើយ ក៏ក្រាលអាសនៈ តម្កល់ទឹកសម្រាប់លាងព្រះបាទ ។

និសីទិ ខោ អាយស្មា នន្ទកោ បញ្ញត្តេ អាសនេ និសជ្ជ ចានេ បក្ខាលេសិ ។ តាបិ ខោ ភិក្ខុនិយោ អាយស្មន្តំ នន្ទកំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។

[២៤៣] ឯកមន្តំ និសិន្នា ខោ តា ភិក្ខុនិយោ អាយស្មា នន្ទកោ ឯតទវោច បដិបុច្ឆកថា ខោ ភគិនិយោ ភវិស្សតិ តត្ថ អាជានន្តីតិ អាជាជាមាតិស្ស វចនីយំ ន អាជានន្តីតិ ន អាជាជាមាតិស្ស វចនីយំ យស្សា វា បនស្ស កង្ខា វា វិមតិ វា អហមេវ តត្ថ បដិបុច្ឆិតព្វោ ឥទំ ភន្តេ កថំ ឥមស្ស ក្វត្ថោតិ ។ ឯត្តកេនបិ មយំ ភន្តេ អយ្យស្ស នន្ទកស្ស អត្តមនា អភិនន្ទាម[១] យន្នោ អយ្យោ នន្ទកោ បវារេតីតិ ។

---

១ ឱ. ម. អភិរទ្ធោ ។

នន្ទកៈមានអាយុអង្គុយលើអាសនៈ ដែលគេក្រាលទុកហើយ លុះអង្គុយស៊ប់ ទើបលាងជើង ។ ភិក្ខុនីទាំងនោះថ្វាយបង្គំនន្ទកៈមានអាយុ ហើយអង្គុយក្នុងទីសមគួរ ។

[២៤៣] លុះភិក្ខុនីទាំងនោះ អង្គុយក្នុងទីសមគួរហើយ នន្ទកៈមានអាយុ បាននិយាយយ៉ាងនេះថា ម្នាលនាងទាំងឡាយ តទៅមុខ បើមានពាក្យគេសាកសួរ បើពួកភិក្ខុនីដឹងច្បាស់ក្នុងប្រស្នានោះ គប្បីឆ្លើយថា ពួកយើងដឹង បើមិនដឹងទេ គប្បីឆ្លើយថា ពួកយើងមិនដឹងទេ មួយទៀត ភិក្ខុនីណាមានសេចក្ដីសង្ស័យឬងឿងឆ្ងល់ ភិក្ខុនីនោះគប្បីសួរយើងក្នុងប្រស្នានោះចុះថា បពិត្រលោកដ៏ចម្រើន ពាក្យនេះដូចម្ដេច សេចក្ដីអធិប្បាយរបស់ពាក្យនេះដូចម្ដេច ។ ពួកភិក្ខុនីតបថា បពិត្រលោកដ៏ចម្រើន លោកម្ចាស់នន្ទកៈ បវារណាយើង ដោយពាក្យណា ពួកយើងមានចិត្តត្រេកអរ រីករាយ ចំពោះលោកម្ចាស់នន្ទកៈដោយពាក្យមានប្រមាណប៉ុណ្ណោះ ។

[២៤៤] តំ កឹ មញ្ញថ ភិក្ខវេ ចក្ខុ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ[១] មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ តំ កឹ មញ្ញថ ភិក្ខវេ សោតំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ ឃានំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ ជិវ្ហា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ ។ បេ ។ កាយោ និច្ចោ វា អនិច្ចោ វាតិ ។ អនិច្ចោ ភន្តេ ។ បេ ។ មនោ និច្ចោ វា អនិច្ចោ វាតិ ។ អនិច្ចោ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។

១ ឱ. សោ ឯវំ សព្វត្ថ ។

[២៤៤] នន្ទកៈភិក្ខុសួរថា ម្នាលនាងទាំងឡាយ ពួកនាងសំគាល់នូវសេចក្តីនោះដូចម្តេច ចក្ខុទៀងឬមិនទៀង ។ មិនទៀងទេលោកម្ចាស់ ។ របស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ របស់នោះជាទុក្ខ លោកម្ចាស់ ។ របស់ណាដែលមិនទៀង ជាទុក្ខមានសេចក្តីប្រែប្រួលជាធម្មតា គួរយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញដូច្នេះដែរឬ ។ មិនគួរយល់ឃើញយ៉ាងនោះទេ លោកម្ចាស់ ។ ម្នាលនាងទាំងឡាយ ពួកនាងសំគាល់សេចក្តីនោះដូចម្តេច ត្រចៀកទៀងឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ បេ ។ ច្រមុះទៀងឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ បេ ។ អណ្តាតទៀងឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ បេ ។ កាយទៀងឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ បេ ។ ចិត្តទៀងឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ ចុះរបស់ណាដែលមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ របស់នោះជាទុក្ខ លោកម្ចាស់ ។

យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ តំ កិស្ស ហេតុ ។ បុព្វេវ នោ ហេតំ ភន្តេ យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋំ ឥតិបិមេ ឆ អជ្ឈត្តិកា អាយតនា អនិច្ចាតិ ។ សាធុ សាធុ ភគិនិយោ ឯវំ ហេតំ ភគិនិយោ ហោតិ អរិយសាវកស្ស យថាភូតំ សម្មប្បញ្ញាយ បស្សតោ ។

[២៤៩] តំ កឹ មញ្ញថ ភគិនិយោ រូបា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ តំ កឹ មញ្ញថ ភគិនិយោ សទ្ទា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ ។ បេ ។

របស់ណាដែលមិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា គួរយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញដូច្នេះដែរឬ ។ មិនគួរយល់ឃើញយ៉ាងនោះទេ លោកម្ចាស់ ។ សេចក្ដីនោះ ព្រោះហេតុអ្វី ។ បពិត្រលោកដ៏ចម្រើន ព្រោះថា ក្នុងកាលមុន ពួកយើងបានឃើញតាមពិតនូវសេចក្ដីនុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃថា អាយតនៈខាងក្នុងទាំងប្រាំមួយនេះ មិនទៀងទេ ។ ម្នាលនាងទាំងឡាយ ប្រពៃណាស់ហើយ ម្នាលនាងទាំងឡាយ សេចក្ដីនុ៎ះ អរិយសាវ័ក ក៏ឃើញដោយប្រាជ្ញាដ៏ប្រពៃតាមពិតយ៉ាងនោះដែរ ។

[២៤៥] ម្នាលនាងទាំងឡាយ ពួកនាងសំគាល់សេចក្ដីនោះដូចម្ដេច រូបទៀងឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ របស់នោះជាទុក្ខ លោកម្ចាស់ ។ របស់ណាមិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា គួរយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញដូច្នេះដែរឬ ។ មិនគួរយល់ឃើញយ៉ាងនោះទេ លោកម្ចាស់ ។ ម្នាលនាងទាំងឡាយ ពួកនាងសំគាល់សេចក្ដីនោះដូចម្ដេច សំឡេងទៀងឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ បេ ។

តង្ការ និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ ។ បេ ។ សោ និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ ។ បេ ។ ជោដ្ធព្វា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ ។ បេ ។ ធម្មា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ តំ កិស្ស ហេតុ ។ បុព្វេ នោ ហេតំ[១] ភន្តេ យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋំ ឥតិបិមេ ឆយិមេ អាយតនា អនិច្ចាតិ ។ សាធុ សាធុ ភគិនិយោ ឯវំ ហេតំ ភគិនិយោ ហោតិ អរិយសាវកស្ស យថាភូតំ សម្មប្បញ្ញាយ បស្សតោ ។

---

១ ម. ឯតំ ។

ក្លិនទៀងឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ បេ ។ រសទៀង ឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ បេ ។ ផោដ្ឋព្វៈទៀងឬមិន ទៀង ។ មិនទៀងទេ លោកម្ចាស់ ។ បេ ។ ធម្មារម្មណ៍ទៀងឬមិន ទៀង ។ មិនទៀងទេ លោកម្ចាស់ ។ របស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ របស់នោះជាទុក្ខ លោកម្ចាស់ ។ របស់ណាដែលមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរ យល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ដូច្នេះដែរឬ ។ មិនគួរយល់ឃើញយ៉ាងនោះទេ លោកម្ចាស់ ។ សេចក្តីនោះ ព្រោះហេតុអ្វី ។ បពិត្រលោកដ៏ចម្រើន ព្រោះថា ក្នុង កាលមុន ពួកយើងបានឃើញតាមពិត នូវសេចក្តីនុ៎ះដោយប្រាជ្ញាដ៏ប្រពៃ អាយតនៈខាងក្រៅទាំង ៦ នេះ មិនទៀងទេ ។ ម្នាលនាងទាំងឡាយ ប្រពៃណាស់ហើយ ម្នាលនាងទាំងឡាយ សេចក្តីនុ៎ះ អរិយសាវ័ក ក៏ឃើញដោយប្រាជ្ញាដ៏ប្រពៃតាមពិត យ៉ាងនោះដែរ ។

[២៤៦] តំ កឹ មញ្ញថ ភគិនិយោ ចក្ខុវិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ តំ កឹ មញ្ញថ ភគិនិយោ សោតវិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ ឃានវិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ ជិវ្ហាវិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ កាយវិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ មនោវិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។

[២៤៦] ម្នាលនាងទាំងឡាយ ពួកនាងសំគាល់សេចក្តីនោះដូចម្តេច ចក្ខុវិញ្ញាណ ទៀងឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ របស់ណាដែលមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ របស់នោះជាទុក្ខ លោកម្ចាស់ ។ របស់ណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញដូច្នេះដែរឬ ។ មិនគួរយល់ឃើញយ៉ាងនោះទេ លោកម្ចាស់ ។ ម្នាលនាងទាំងឡាយ ពួកនាងសំគាល់សេចក្តីនោះដូចម្តេច សោតវិញ្ញាណទៀងឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ បេ ។ ឃានវិញ្ញាណទៀងឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ បេ ។ ជិវ្ហាវិញ្ញាណទៀងឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ បេ ។ កាយវិញ្ញាណទៀងឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ បេ ។ មនោវិញ្ញាណទៀងឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ របស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ របស់នោះជាទុក្ខ លោកម្ចាស់ ។ របស់ណាដែលមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរយល់ឃើញនូវរបស់នោះថា នុ៎ះជារបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញដូច្នេះដែរឬ ។

ចោ ហោតំ ភន្តេ ។ តំ កិស្ស ហេតុ ។ បុព្វេវ ចោ ហោតំ ភន្តេ យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋំ ឥតិបិមេ ឆ វិញ្ញាណកាយា អនិច្ចាតិ ។ សាធុ សាធុ ភតិនិយោ ឯវំ ហោតំ ភតិនិយោ ហោតិ អរិយសាវកស្ស យថាភូតំ សម្មប្បញ្ញាយ បស្សតោ ។

[២៤៧] សេយ្យថាបិ ភតិនិយោ តេលប្បទីបស្ស ឈាយតោ តេលម្បិ អនិច្ចំ វិបរិណាមធម្មំ វដ្ដិបិ អនិច្ចា វិបរិណាមធម្មា អច្ចិបិ អនិច្ចា វិបរិណាមធម្មា អាភាបិ អនិច្ចា វិបរិណាមធម្មា ។ យោ នុ ខោ ភតិនិយោ ឯវំ វទេយ្យ អមុស្ស តេលប្បទីបស្ស ឈាយតោ តេលម្បិ អនិច្ចំ វិបរិណាមធម្មំ វដ្ដិបិ អនិច្ចា វិបរិណាមធម្មា អច្ចិបិ អនិច្ចា វិបរិណាមធម្មា យា ច ខ្វស្ស អាភា សា និច្ចា ធុវា សស្សតា អវិបរិណាមធម្មាតិ សម្មា នុ ខោ សោ ភតិនិយោ វទមានោ វទេយ្យាតិ ។ នោ ហេតំ ភន្តេ ។

មិនគួរយល់ឃើញយ៉ាងនុ៎ះទេ លោកម្ចាស់ ។ សេចក្តីនោះ ព្រោះហេតុអ្វី ។ បពិត្រលោកដ៏ចម្រើន ព្រោះថា ក្នុងកាលមុន ពួកយើងបានឃើញតាមពិតនូវសេចក្តីនុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃថា វិញ្ញាណកាយទាំង ៦ នេះ មិនទៀងទេ ។ ម្នាលនាងទាំងឡាយ ប្រពៃណាស់ហើយ ម្នាលនាងទាំងឡាយ សេចក្តីនុ៎ះអរិយសាវ័កក៏ឃើញដោយប្រាជ្ញាដ៏ប្រពៃតាមពិត យ៉ាងនោះដែរ ។

[២៤៧] ម្នាលនាងទាំងឡាយ សេចក្តីប្រៀបថា ប្រទីបពេញដោយប្រេងកំពុងឆេះ ប្រេងក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ប្រឆេះក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា អណ្តាតភ្លើងក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ពន្លឺក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ។ ម្នាលនាងទាំងឡាយ ជនណានិយាយយ៉ាងនេះថា ប្រទីបពេញដោយប្រេងឯណោះកំពុងឆេះ ប្រេងក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ប្រឆេះក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា អណ្តាតភ្លើងក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ពន្លឺណារបស់ប្រទីបនោះ ពន្លឺនោះទើបទៀងទាត់ ឋិតថេរមិនមានសេចក្តីប្រែប្រួលជាធម្មតា ម្នាលនាងទាំងឡាយ ជននោះឈ្មោះថា និយាយត្រឹមត្រូវដែរឬ ។ ការនិយាយនុ៎ះមិនត្រូវទេ លោកម្ចាស់ ។

តំ កិស្ស ហេតុ ។ អមុស្ស ហិ ភន្តេ តេលប្បទី-បស្ស ឈាយតោ តេលម្បិ អនិច្ចំ វិបរិណាមធម្មំ វដ្ដិបិ អនិច្ចា វិបរិណាមធម្មា អច្ចិបិ អនិច្ចា វិបរិណាមធម្មា បគេវស្ស អាភា អនិច្ចា វិបរិណាមធម្មាតិ ។

[២៤៨] ឯវមេវ ខោ ភគិនិយោ យោ នុ ខោ ឯវំ វទេយ្យ ឆ ខោមេ អជ្ឈត្តិកា អាយតនា អនិច្ចា យញ្ច ខោ អជ្ឈត្តិកេ អាយតនេ បដិច្ច ប-ដិសំវេទេមិ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តំ និច្ចំ ធុវំ សស្សតំ អវិបរិណាមធម្មន្តិ សម្មា នុ ខោ សោ ភគិនិយោ វទមានោ វទេយ្យាតិ ។ នោ ហេតំ ភន្តេ ។

ពាក្យនោះមិនត្រូវ ព្រោះហេតុអ្វី ។ បពិត្រលោកដ៏ចម្រើន ព្រោះថា ប្រទីបពេញដោយប្រេងឯណោះ កំពុងតែឆេះ ប្រេងក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ប្រឆេះក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា អណ្តាតភ្លើងក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ចាំបាច់និយាយទៅថ្វី ដល់ទៅពន្លឺរបស់ប្រទីបនោះ ដែលជារបស់មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ។

[២៤៨] ម្នាលនាងទាំងឡាយ សេចក្តីនេះក៏ដូច្នេះដែរ ជនណានិយាយយ៉ាងនេះថា អាយតនៈខាងក្នុងប្រាំមួយនេះ មិនទៀង អាត្មាអញទទួលដឹងអារម្មណ៍ណា ជាសុខ ឬជាទុក្ខ ឬមិនទុក្ខមិនសុខ ព្រោះអាស្រ័យអាយតនៈខាងក្នុង អារម្មណ៍នោះទៀងទាត់ ឋិតថេរ មិនមានសេចក្តីប្រែប្រួលជាធម្មតា ម្នាលនាងទាំងឡាយ ជននោះឈ្មោះថានិយាយត្រឹមត្រូវដែរឬ ។ ការនិយាយនុ៎ះមិនត្រឹមត្រូវទេ លោកម្ចាស់ ។

តំ កិស្ស ហេតុ ។ តជ្ជំ តជ្ជំ ភន្តេ បច្ចយំ បដិច្ច តជ្ជា តជ្ជា វេទនា ឧប្បជ្ជតិ(១) តជ្ជស្ស តជ្ជស្ស បច្ចយស្ស និរោធា តជ្ជា តជ្ជា វេទនា និរុជ្ឈតីតិ(២) ។ សាធុ សាធុ ភគិនិយោ ឯវំ ហេតំ ភគិនិយោ ហោតិ អរិយសាវកស្ស យថាភូតំ សម្មប្បញ្ញាយ បស្សតោ ។

[២៤៩] សេយ្យថាបិ ភគិនិយោ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ មូលម្បិ អនិច្ចំ វិបរិណាមធម្មំ ខន្ធោបិ អនិច្ចោ វិបរិណាមធម្មោ សាខាបលាសម្បិ អនិច្ចំ វិបរិណាមធម្មំ ឆាយាបិ អនិច្ចា វិបរិណាមធម្មា ។ យោ នុ ខោ ភគិនិយោ ឯវំ វទេយ្យ អមុស្ស មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ មូលម្បិ អនិច្ចំ វិបរិណាមធម្មំ ខន្ធោបិ អនិច្ចោ វិបរិណាមធម្មោ

១ ឱ. ឧប្បជ្ជន្តិ ។ ២ ឱ. និរុជ្ឈន្តីតិ ។

ពាក្យនោះមិនត្រឹមត្រូវ ព្រោះហេតុអ្វី ។ បពិត្រលោកដ៏ចម្រើន ព្រោះថា វេទនាដែលកើត អំពីអាយតនៈខាងក្នុងនោះ ៗ តែងកើតឡើង ព្រោះអាស្រ័យបច្ច័យ ដែលកើតអំពីអាយតនៈខាងក្នុងនោះ ៗ វេទនាដែលកើតអំពីអាយតនៈខាងក្នុងនោះ ៗ តែងរលត់ទៅ ព្រោះរលត់នៃបច្ច័យដែលកើតអំពីអាយតនៈខាងក្នុងនោះ ៗ ។ ម្នាលនាងទាំងឡាយ ប្រពៃណាស់ហើយ ម្នាលនាងទាំងឡាយ សេចក្តីនុ៎ះ អរិយសាវ័កក៏ឃើញតាមពិត ដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនោះដែរ ។

[២៤៩] ម្នាលនាងទាំងឡាយ ប្រៀបដូចជាឈើធំ មានខ្លឹម កំពុងឈរនៅ ឫសក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ដើមក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា មែកនិងសន្លឹកក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ស្រមោលក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ។ ម្នាលនាងទាំងឡាយ ជនណានិយាយយ៉ាងនេះថា ឈើធំឯណោះមានខ្លឹម កំពុងឈរនៅ ឫសក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ដើមក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា

សាខាបលាសម្បិ អនិច្ចំ វិបរិណាមធម្មំ យា ច ខ្វស្ស ឆាយា សា អនិច្ចា ធុវា សស្សតា អវិបរិណាមធម្មាតិ សម្មា នុ ខោ សោ ភគិនិយោ វទមានោ វទេយ្យាតិ ។ នោ ហេតំ ភន្តេ ។ តំ កិស្ស ហេតុ ។ អមុស្ស ហិ ភន្តេ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ មូលម្បិ អនិច្ចំ វិបរិណាមធម្មំ ខន្ធោបិ អនិច្ចោ វិបរិណាមធម្មោ សាខាបលាសម្បិ អនិច្ចំ វិបរិណាមធម្មំ បគេវស្ស ឆាយា អនិច្ចា វិបរិណាមធម្មាតិ ។

[២៨០] ឯវមេវ ខោ ភគិនិយោ យោ នុ ខោ ឯវំ វទេយ្យ ឆ ខោមេ ពាហិរា អាយតនា អនិច្ចា យញ្ច ខោ ពាហិរេ អាយតនេ បដិច្ច បដិសំវេទេមិ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តំ និច្ចំ ធុវំ

មែកនិងសន្ទឹកក៏មិនទៀង មានសេចក្ដីប្រែប្រួលជាធម្មតា ស្រមោលណា របស់ឈើនោះ ស្រមោលនោះទៀងទាត់ ឋិតថេរ មិនមានសេចក្ដីប្រែប្រួលជាធម្មតា អ្នកនោះ ឈ្មោះថានិយាយត្រឹមត្រូវដែរឬ ។ ការនិយាយនុ៎ះមិនត្រូវទេ លោកម្ចាស់ ។ ការនិយាយនោះមិនត្រូវព្រោះហេតុអ្វី ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រោះថា ឈើធំឯណោះមានខ្លឹម កំពុងឈរនៅ ឫសក៏មិនទៀង មានសេចក្ដីប្រែប្រួលជាធម្មតា ដើមក៏មិនទៀង មានសេចក្ដីប្រែប្រួលជាធម្មតា មែកនិងសន្ទឹកក៏មិនទៀង មានសេចក្ដីប្រែប្រួលជាធម្មតា ចាំបាច់និយាយទៅថ្វីដល់ស្រមោលរបស់ឈើនោះ ដែលជារបស់មិនទៀង មានសេចក្ដីប្រែប្រួលជាធម្មតា ។

[២៥០] ម្នាលនាងទាំងឡាយ សេចក្ដីនេះ ក៏យ៉ាងនោះដែរ ជនណានិយាយយ៉ាងនេះថា អាយតនៈខាងក្រៅប្រាំមួយនេះ មិនទៀង អាត្មាអញអាស្រ័យអាយតនៈខាងក្រៅហើយ ទទួលដឹងអារម្មណ៍ណាជាសុខ ឬជាទុក្ខ ឬមិនមែនទុក្ខមិនមែនសុខ អារម្មណ៍នោះទៀងទាត់

សស្សតំ អវិបរិណាមធម្មន្តិ សម្មា នុ ខោ សោ ភគិនិយោ វេទមានោ វេទេយ្យាតិ ។ នោ ហេតំ ភន្តេ ។ តំ កិស្ស ហេតុ ។ តជ្ជំ តជ្ជំ ភន្តេ បច្ចយំ បដិច្ច តជ្ជា តជ្ជា វេទនា ឧប្បជ្ជតិ តជ្ជស្ស តជ្ជស្ស បច្ចយស្ស និរោធា តជ្ជា តជ្ជា វេទនា និរុជ្ឈតីតិ ។ សាធុ សាធុ ភគិនិយោ ឯវំ ហេតំ ភគិនិយោ ហោតិ អរិយសាវកស្ស យថាភូតំ សម្មប្បញ្ញាយ បស្សតោ ។

[២៨១] សេយ្យថាបិ ភគិនិយោ ទក្ខោ គោឃាតកោ វា គោឃាតកន្តេវាសី វា គាវឹ វធិត្វា តិណ្ហេន គោវិកន្តនេន គាវឹ វិកន្តេយ្យ អនុបហច្ច អន្តរំ មំសកាយំ អនុបហច្ច ពាហិរំ ចម្មកាយំ យំ យទេវ តត្ថ អន្តរា វិលិមំសំ[១] អន្តរា នហារុ អន្តរា ពន្ធនំ តំ តទេវ តិណ្ហេន គោវិកន្តនេន សញ្ឆិន្ទេយ្យ សង្កន្តេយ្យ សម្បរិកន្តេយ្យ សញ្ឆិន្ទិត្វា សង្កន្តិត្វា សម្បរិកន្តិត្វា វិធុនិត្វា ពាហិរំ ចម្មកាយំ តេនេវ ចម្មេន តំ គាវឹ បដិច្ឆាទេត្វា

---

១ ឱ. ចិលិមំ ។ ម. វិលិមំ ។

ឋិតថេរ មិនមានសេចក្តីប្រែប្រួលជាធម្មតា ម្នាលនាងទាំងឡាយ ជននោះឈ្មោះថានិយាយត្រឹមត្រូវដែរឬ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ការនិយាយនុ៎ះមិនត្រូវទេ ។ ការនិយាយនោះមិនត្រូវ ព្រោះហេតុអ្វី ។ បពិត្រលោកដ៏ចម្រើន ព្រោះថា វេទនាដែលកើតអំពីអាយតនៈខាងក្រៅនោះ ៗ តែងកើតឡើង ព្រោះអាស្រ័យបច្ច័យដែលកើតអំពីអាយតនៈខាងក្រៅនោះ ៗ វេទនាដែលកើតអំពីអាយតនៈខាងក្រៅនោះ ៗ រលត់ទៅវិញ ព្រោះរលត់បច្ច័យដែលកើតអំពីអាយតនៈខាងក្រៅនោះ ៗ ។ ម្នាលនាងទាំងឡាយ ប្រពៃណាស់ ម្នាលនាងទាំងឡាយ សេចក្តីនុ៎ះ អរិយសាវ័ក ក៏ឃើញតាមពិត ដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនោះដែរ ។

[២៩១] ម្នាលនាងទាំងឡាយ ប្រៀបដូចជាបុរសអ្នកសម្លាប់គោ ឬកូនសិស្សអ្នកសម្លាប់គោដែលប្រសប់ សម្លាប់នូវមេគោ ហើយពន្ធះនូវមេគោដោយកាំបិតសម្រាប់អារគោដ៏មុត មិនឲ្យខូចសាច់ខាងក្នុង មិនឲ្យខូចស្បែកខាងក្រៅ បណ្តាវត្ថុទាំងនោះ វត្ថុណា ៗ គឺសាច់វាវខាងក្នុងក្តី សរសៃខាងក្នុងក្តី ចំណងខាងក្នុងក្តី ក៏អារពន្ធះកាត់យកវត្ថុនោះ ៗ ដោយកាំបិតសម្រាប់អារគោដ៏មុត លុះអារពន្ធះកាត់រួចហើយ ក៏បកយកស្បែកខាងក្រៅ មកគ្របមេគោដោយស្បែកនោះវិញដដែល

ឯវំ វទេយ្យ តថេវាយំ គាវី សំយុត្តា ឥមិនា ចម្មេនាតិ សម្មា នុ ខោ សោ ភគិនិយោ វទមានោ វទេយ្យាតិ ។ នោ ហេតំ ភន្តេ ។ តំ កិស្ស ហេតុ ។ អសុ ហិ ភន្តេ ទក្ខោ គោឃាតកោ វា គោឃាតកន្តេវាសី វា គាវឹ វធិត្វា តិណ្ហេន គោវិកន្តនេន គាវឹ វិកន្តេយ្យ អនុបហច្ច អន្តរំ មំសកាយំ អនុបហច្ច ពាហិរំ ចម្មកាយំ យំ យទេវ តត្ថ អន្តរា វិលិមំសំ អន្តរា នហារុ អន្តរា ពន្ធនំ តំ តទេវ តិណ្ហេន គោវិកន្តនេន សញ្ឆិន្ទេយ្យ សង្កន្តេយ្យ សម្បរិកន្តេយ្យ សញ្ឆិន្ទិត្វា សង្កន្តិត្វា សម្បរិកន្តិត្វា វិធុនិត្វា ពាហិរំ ចម្មកាយំ តេនេវ ចម្មេន តំ គាវឹ បដិច្ឆាទេត្វា កិញ្ចាបិ សោ ឯវំ វទេយ្យ តថេវាយំ គាវី សំយុត្តា ឥមិនា ចម្មេនាតិ អថខោ សា គាវី វិសំយុត្តា តេនេវ ចម្មេន ។

ហើយនិយាយយ៉ាងនេះថា មេគោនេះ នៅមានស្បែកដូចមុនដដែល ម្នាលនាងទាំងឡាយ ជននោះ ឈ្មោះថានិយាយត្រឹមត្រូវដែរឬ ។ បពិត្រលោកម្ចាស់ ការនិយាយនោះមិនត្រូវទេ ។ ការនិយាយនោះមិនត្រូវ ព្រោះហេតុអ្វី ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រោះថា បុរសអ្នកសម្លាប់គោ ឬកូនសិស្សអ្នកសម្លាប់គោឯណោះដែលប្រសប់ បានសម្លាប់នូវមេគោ ហើយអារនូវមេគោដោយកាំបិតសម្រាប់អារគោដ៏មុត មិនឲ្យខូចសាច់ខាងក្នុង មិនឲ្យខូចស្បែកខាងក្រៅ បណ្ដាវត្ថុទាំងនោះ វត្ថុណា ៗ គឺសាច់វាវខាងក្នុងក្ដី សរសៃខាងក្នុងក្ដី ចំណងខាងក្នុងក្ដី ក៏អារពន្ទះកាត់យកវត្ថុនោះ ៗ ដោយកាំបិតសម្រាប់អារគោដ៏មុត លុះអារពន្ទះកាត់រួចហើយ ក៏បកយកស្បែកខាងក្រៅ មកគ្របមេគោនោះដោយស្បែកនោះវិញដដែល ជននោះនិយាយយ៉ាងនេះថា មេគោនេះនៅមានស្បែកដូចមុនដដែល ដូច្នេះក៏ពិតមែនហើយ ប៉ុន្តែមេគោនោះ ប្រាសចាកស្បែកនោះហើយដោយប្រាកដ ។

[២៩២] ឧបមា ខោ មេ អយំ កតិនិយោ កតា អត្ថស្ស វិញ្ញាបនាយ ។ អយមេវេត្ថ អត្ថោ ។ អណ្ឌពេ មំសកាយោតិ ខោ កតិនិយោ ឆន្នេតំ អជ្ឈត្តិកានំ អាយតនានំ អធិវចនំ ។ ពាហិរេ ចម្មកាយោតិ ខោ កតិនិយោ ឆន្នេតំ ពាហិរានំ អាយតនានំ អធិវចនំ ។ អន្តរា វិលិមំសំ អន្តរា នហារុ អន្តរា ពន្ធនន្តិ ខោ កតិនិយោ នន្ទិរាគស្សេតំ អធិវចនំ ។ តិណ្ហំ គោវិ-កន្តនន្តិ ខោ កតិនិយោ អរិយាយេតំ បញ្ញាយ អធិ-វចនំ ។ យាយំ អរិយា បញ្ញា អន្តរា កិលេសំ អន្តរា សញ្ញោជនំ អន្តរា ពន្ធនំ សញ្ចិន្ទតិ សង្កន្តតិ សម្បរិកន្តតិ ។

[២៩៣] សត្ត ខោ ឥមេ កតិនិយោ ពោជ្ឈង្គា យេសំ ភាវិតត្តា ពហុលីកតត្តា ភិក្ខុ អាសវានំ ខ-យា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ កតមេ សត្ត ។ ឥធ កតិនិយោ ភិក្ខុ សតិ-សម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ

[២៥២] ម្នាលនាងទាំងឡាយ ពាក្យឧបមាដែលយើងធ្វើហើយនេះ ដើម្បីឲ្យពួកនាងដឹងច្បាស់នូវសេចក្តីអធិប្បាយ ។ ឯសេចក្តីអធិប្បាយក្នុងអាយតនៈនុ៎ះដូចតទៅនេះ ។ ម្នាលនាងទាំងឡាយ ពាក្យថា សាច់ខាងក្នុងនុ៎ះ ជាឈ្មោះនៃអាយតនៈខាងក្នុងប្រាំមួយ ។ ម្នាលនាងទាំងឡាយ ពាក្យថា ស្បែកខាងក្រៅនុ៎ះ ជាឈ្មោះនៃអាយតនៈខាងក្រៅប្រាំមួយ ។ ម្នាលនាងទាំងឡាយ ពាក្យថា សាច់ វាវខាងក្នុងក្តី សរសៃខាងក្នុងក្តី ចំណងខាងក្នុងក្តី នុ៎ះជាឈ្មោះនៃនន្ទិរាគ ។ ម្នាលនាងទាំងឡាយ ពាក្យថា កាំបិតសម្រាប់អារគោដ៏មុតនុ៎ះ ជាឈ្មោះនៃប្រាជ្ញាដ៏ប្រសើរ ។ ប្រាជ្ញាដ៏ប្រសើរនេះ តែងអារពន្ធុះកាត់កិលេសខាងក្នុង សំយោជនៈខាងក្នុង ចំណងខាងក្នុង ។

[២៥៣] ម្នាលនាងទាំងឡាយ ពោជ្ឈង្គទាំងប្រាំពីរនេះ ភិក្ខុណាចម្រើនហើយ ធ្វើឲ្យរឿយ ៗ ហើយ ភិក្ខុនោះ រមែងអស់អាសវៈទាំងឡាយ ហើយត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ បានដល់ដោយខ្លួនឯងក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ពោជ្ឈង្គទាំង ៧ ដូចម្តេចខ្លះ ។ ម្នាលនាងទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើននូវសតិសម្ពោជ្ឈង្គដែលអាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យសេចក្តីប្រាសចាកតម្រេក

និរោធនិស្សិតំ វោស្សគ្គបរិណាមិំ[១] ធម្មវិចយសម្ពោជ្ឈង្គំ ភាវេតិ... វីរិយសម្ពោជ្ឈង្គំ ភាវេតិ... បីតិសម្ពោជ្ឈង្គំ ភាវេតិ... បស្សទ្ធិសម្ពោជ្ឈង្គំ ភាវេតិ... សមាធិសម្ពោជ្ឈង្គំ ភាវេតិ... ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមិំ ។ ឥមេ ខោ ភគិនិយោ សត្ត ពោជ្ឈង្គា យេសំ ភាវិតត្តា ពហុលីកតត្តា ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ។

[២៥៤] អថខោ អាយស្មា នន្ទកោ តា ភិក្ខុនិយោ ឥមិនា ឱវាទេន ឱវទិត្វា ឧយ្យោជេសិ គច្ឆថ ភគិនិយោ កាលោតិ ។ អថខោ តា ភិក្ខុនិយោ

១ ឱ. ម. វោស្សគ្គបរិណាមឹ ។

អាស្រ័យសេចក្តីរលត់ ឈមមុខទៅកាន់សេចក្តីលះបង់ ចម្រើននូវធម្មវិចយសម្ពោជ្ឈង្គ... ចម្រើននូវវីរិយសម្ពោជ្ឈង្គ... ចម្រើននូវបីតិសម្ពោជ្ឈង្គ... ចម្រើននូវបស្សទ្ធិសម្ពោជ្ឈង្គ... ចម្រើននូវសមាធិសម្ពោជ្ឈង្គ... ចម្រើននូវឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យសេចក្តីប្រាសចាកតម្រេក អាស្រ័យសេចក្តីរលត់ ឈមមុខទៅកាន់សេចក្តីលះបង់ ។ ម្នាលនាងទាំងឡាយ ពោជ្ឈង្គទាំង ៧ នេះឯង ដែលភិក្ខុណាបានចម្រើន បានធ្វើឲ្យរឿយ ៗ ហើយ ភិក្ខុនោះ រមែងអស់អាសវៈទាំងឡាយ ហើយត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ បានដល់ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈសម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ។

[២៥៤] លំដាប់នោះឯង ព្រះនន្ទកៈមានអាយុ ទូន្មានពួកភិក្ខុនីនោះ ដោយឱវាទនេះហើយ ទើបបញ្ជូនទៅថា ម្នាលនាងទាំងឡាយ ចូរពួកនាងទៅចុះ ព្រោះកាលគួរហើយ ។ ទើបភិក្ខុនីទាំងនោះ

អាយស្មតោ នន្ទកស្ស ភាសិតំ អភិនន្ទិត្វា អនុមោ-
ទិត្វា ឧដ្ឋាយាសនា អាយស្មន្តំ នន្ទកំ អភិវាទេត្វា
បទក្ខិណំ កត្វា យេន ភគវា តេនុបសង្កមឹសុ ឧប-
សង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។ ឯក-
មន្តំ ឋិតា ខោ តា ភិក្ខុនិយោ ភគវា ឯតទវោច គច្ឆ-
ថ ភិក្ខុនិយោ កាលោតិ ។ អថខោ តា ភិក្ខុនិយោ
ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កមឹសុ ។

[២៨៨] អថខោ ភគវា អចិរបក្កន្តាសុ តាសុ
ភិក្ខុនីសុ ភិក្ខូ អាមន្តេសិ សេយ្យថាបិ ភិក្ខវេ
តទហុបោសថេ ចាតុទ្ទសេ ន ហោតិ ពហុ-
នោ ជនស្ស កង្ខា វា វិមតិ វា ឩនោ នុ
ខោ ចន្ទោ បុណ្ណោ នុ ខោ ចន្ទោតិ អថខោ
ឩនោ ចន្ទោ ត្វេវ ហោតិ ឯវមេវ ខោ ភិក្ខវេ

ត្រេកអរអនុមោទនានូវភាសិតរបស់ព្រះនន្ទកៈមានអាយុ ហើយក៏ក្រោកអំពីអាសនៈ ថ្វាយបង្គំព្រះនន្ទកៈមានអាយុ ធ្វើប្រទក្សិណហើយ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ លុះភិក្ខុនីទាំងនោះ ឋិតនៅក្នុងទីដ៏សមគួរហើយ ទើបព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុនីទាំងឡាយ ចូរពួកនាងទៅចុះ ព្រោះកាលគួរហើយ ។ ទើបភិក្ខុនីទាំងនោះ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយចេញទៅ ។

[២៥៥] កាលដែលភិក្ខុនីទាំងនោះ ចេញទៅមិនយូរប៉ុន្មាន ទើបព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃឧបោសថទី ១៤ ជនជាច្រើន រមែងមិនមានសេចក្តីសង្ស័យឬងឿងឆ្ងល់ថា ព្រះចន្ទខ្វះ ឬព្រះចន្ទពេញដូច្នេះឡើយ រមែងចូលចិត្តថាព្រះចន្ទខ្វះដោយពិត សេចក្តីនេះមានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ

តា[១] នន្ទកស្ស ធម្មទេសនាយ អត្តមនា ចេវ ហោន្តិ នោ ច ខោ បរិបុណ្ណសង្កប្បាតិ ។ អថខោ ភគវា អាយស្មន្តំ នន្ទកំ អាមន្តេសិ តេនហិ ត្វំ នន្ទក ស្វេបិ តា ភិក្ខុនិយោ តេនេវោវាទេន ឱវទេយ្យាសីតិ ។ ឯវម្ភន្តេតិ ខោ អាយស្មា នន្ទកោ ភគវតោ បច្ចស្សោសិ ។

[២៩៦] អថខោ អាយស្មា នន្ទកោ តស្សា រត្តិយា អច្ចយេន បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ[២] សាវត្ថិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ អត្តទុតិយោ យេន រាជការាមោ តេនុបសង្កមិ ។ អទ្ទសាសុំ ខោ តា ភិក្ខុនិយោ អាយស្មន្តំ នន្ទកំ ទូរតោ វ អាគច្ឆន្តំ ។ ទិស្វាន អាសនំ បញ្ញាបេសុំ ឧទកញ្ច បាទានំ ឧបដ្ឋបេសុំ ។ និសីទិ ខោ អាយស្មា នន្ទកោ បញ្ញត្តេ អាសនេ ។ និសជ្ជ បាទេ បក្ខាលេសិ ។ តាបិ ខោ ភិក្ខុនិយោ អាយស្មន្តំ នន្ទកំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។

១ ឱ. ម. តា ភិក្ខុនិយោតិ ទិស្សតិ ។ ២ ឱ. ម. ឯត្ថន្តរេ សាវត្ថឹ បិណ្ឌាយ បាវិសីតិ ទិស្សតិ ។

ក៏ពួកភិក្ខុនីនោះ គ្រាន់តែមានសេចក្ដីត្រេកអរនឹងធម្មទេសនារបស់នន្ទក-ភិក្ខុមែន ប៉ុន្តែមានបំណងមិនបានពេញលេញឡើយ មានឧបមេយ្យយ៉ាងនោះឯង ។ គ្រានោះឯង ព្រះមានព្រះភាគហៅព្រះនន្ទកៈមានអាយុថា ម្នាលនន្ទកៈ បើដូច្នោះ ក្នុងថ្ងៃស្អែក អ្នកគប្បីទូន្មានពួកភិក្ខុនីនោះដោយឱវាទនោះទៀត ។ ព្រះនន្ទកៈមានអាយុ ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

[២៥៦] លំដាប់នោះឯង ព្រះនន្ទកៈមានអាយុ កាលរាត្រីនោះកន្លងទៅ ក៏ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី លុះត្រឡប់មកអំពីបិណ្ឌបាតវិញ ក្នុងវេលាក្រោយភត្ត មានខ្លួនជាគម្រប់ពីរ ចូលទៅកាន់រាជការាម ។ ភិក្ខុនីទាំងនោះ បានឃើញព្រះនន្ទកៈមានអាយុ និមន្តមកអំពីចម្ងាយ ។ លុះឃើញហើយ ក៏នាំគ្នាក្រាលអាសនៈផង តម្កល់ទឹកសម្រាប់លាងជើងផង ។ ព្រះនន្ទកៈមានអាយុ គង់លើអាសនៈដែលពួកភិក្ខុនីក្រាលហើយ ។ លុះគង់រួចហើយ ទើបលាងនូវជើងទាំងឡាយ ។ ឯពួកភិក្ខុនីនោះ ថ្វាយបង្គំព្រះនន្ទកៈមានអាយុ ហើយអង្គុយនៅក្នុងទីសមគួរ ។

[២៤៧] ឯកមន្តំ និសិន្នា ខោ តា ភិក្ខុនិយោ អាយស្មា នន្ទកោ ឯតទវោច បដិបុច្ឆកថា ខោ ភគិនិយោ ភវិស្សតិ តត្ថ អាជានន្តីតិ អាជានាមាតិស្ស វចនីយំ ន អាជានន្តីតិ ន អាជានាមាតិស្ស វចនីយំ យស្សា វា បនស្ស កង្ខា វា វិមតិ វា អហមេវ តត្ថ បដិបុច្ឆិតព្វោ ឥទំ ភន្តេ កថំ ឥមស្ស ក្វត្ថោតិ ។ ឯត្តកេនបិ មយំ ភន្តេ អយ្យស្ស នន្ទកស្ស អត្តមនា អភិនន្ទាម[១] យន្នោ អយ្យោ នន្ទកោ បវារេតីតិ ។

[២៤៨] តំ កឹ មញ្ញថ ភគិនិយោ ចក្ខុ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ តំ កឹ មញ្ញថ ភគិនិយោ សោតំ

១ ឱ. ម. អភិរទ្ធា ។

[២៥៧] លុះពួកភិក្ខុនីនោះ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះនន្ទកៈមានអាយុ បានសួរយ៉ាងនេះថា ម្នាលនាងទាំងឡាយ បើមានពាក្យសាកសួរ ពួកភិក្ខុនីអាចដឹងក្នុងប្រស្នានោះ គប្បីឆ្លើយថា ពួកយើងដឹង (បើ) មិនដឹងទេ គប្បីឆ្លើយថា ពួកយើងមិនដឹងទេ បើសេចក្តីសង្ស័យ ឬងឿងឆ្ងល់ មានដល់ភិក្ខុនីណា ភិក្ខុនីនោះ គប្បីសួរយើង ក្នុងប្រស្នានោះ ថា បពិត្រលោកដ៏ចម្រើន ពាក្យនេះដូចម្តេច សេចក្តីអធិប្បាយរបស់ពាក្យនេះដូចម្តេច ។ បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់នន្ទកៈ បវារណាយើងដោយពាក្យណា យើងមានសេចក្តីត្រេកអរីករាយ ចំពោះលោកម្ចាស់នន្ទកៈ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ។

[២៥៨] ម្នាលនាងទាំងឡាយ ពួកនាងសំគាល់សេចក្តីនោះដូចម្តេច ចក្ខុទៀងឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ ចុះរបស់ណា មិនទៀង របស់នោះ ជាទុក្ខឬជាសុខ ។ ជាទុក្ខ លោកម្ចាស់ ។ របស់ណា ដែលមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរយល់ឃើញរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញដូច្នេះដែរឬ ។ មិនគួរយល់ឃើញយ៉ាងនោះទេ លោកម្ចាស់ ។ ម្នាលនាងទាំងឡាយ ពួកនាងសំគាល់សេចក្តីនោះដូចម្តេច ត្រចៀក

២៨៩



និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ ឃានំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ ជិវ្ហា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ ។ បេ ។ កាយោ និច្ចោ វា អនិច្ចោ វាតិ ។ អនិច្ចោ ភន្តេ ។ បេ ។ មនោ និច្ចោ វា អនិច្ចោ វាតិ ។ អនិច្ចោ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ តំ កិស្ស ហេតុ ។ បុព្វេវ នោ ហេតំ ភន្តេ យថាភូតំ សម្មប្ប-ញ្ញាយ សុទិដ្ឋំ ឥតិបិមេ ឆ អជ្ឈត្តិកា អាយ-តនា អនិច្ចាតិ ។ សាធុ សាធុ ភគិនិយោ ឯវំ ហេតំ ភគិនិយោ ហោតិ អរិយសាវកស្ស យថាភូតំ សម្មប្បញ្ញាយ បស្សតោ ។

ទៀងឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ បេ ។ ច្រមុះទៀងឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ បេ ។ អណ្តាតទៀងឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ បេ ។ កាយទៀងឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ បេ ។ ចិត្តទៀងឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ របស់ណាដែលមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ ជាទុក្ខ លោកម្ចាស់ ។ របស់ណាដែលមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញដូច្នេះដែរឬ ។ មិនគួរយល់ឃើញយ៉ាងនោះទេ លោកម្ចាស់ ។ សេចក្តីនោះព្រោះហេតុអ្វី ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រោះថា ក្នុងកាលមុន ពួកយើងបានឃើញតាមពិតនូវសេចក្តីនុ៎ះដោយប្រាជ្ញាដ៏ប្រពៃថា អាយតនៈខាងក្នុង ៦ នេះ មិនទៀងទេ ។ ម្នាលនាងទាំងឡាយ ប្រពៃណាស់ហើយ ម្នាលនាងទាំងឡាយ រឿងនុ៎ះអរិយសាវ័ក ក៏ឃើញពិតប្រាកដដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនោះដែរ ។

[២៨៩] តំ កឹ មញ្ញថ ភគិនិយោ រូបា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ តំ កឹ មញ្ញថ ភគិនិយោ សទ្ទា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ ។ បេ ។ គន្ធា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ ។ បេ ។ រសា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ ។ បេ ។ ផោដ្ឋព្វា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ ។ បេ ។ ធម្មា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។

[២៥៩] ម្នាលនាងទាំងឡាយ ពួកនាងសំគាល់សេចក្តីនោះដូចម្តេច រូបទៀងឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ ចុះរបស់ណា ដែលមិនទៀង របស់នោះ ជាទុក្ខឬជាសុខ ។ ជាទុក្ខ លោកម្ចាស់ ។ របស់ណា ដែលមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញដូច្នេះដែរឬ ។ មិនគួរយល់ឃើញយ៉ាងនោះទេ លោកម្ចាស់ ។ ម្នាលនាងទាំងឡាយ ពួកនាងសំគាល់សេចក្តីនោះដូចម្តេច សំឡេងទៀងឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ បេ ។ ក្លិនទៀងឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ បេ ។ រសទៀងឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ បេ ។ ផោដ្ឋព្វៈទៀងឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ បេ ។ ធម្មារម្មណ៍ទៀងឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ ចុះរបស់ណាដែលមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ ជាទុក្ខ លោកម្ចាស់ ។ របស់ណា ដែលមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញដូច្នេះដែរឬ ។

នោ ហេតំ ភន្តេ ។ តំ កិស្ស ហេតុ ។ បុព្វេវ នោ ហេតំ ភន្តេ យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋំ ឥតិបិមេ ឆ ពាហិរា អាយតនា អនិច្ចាតិ ។ សាធុ សាធុ ភគិនិយោ ឯវំ ហេតំ ភគិនិយោ ហោតិ អរិយស្សាវកស្ស យថាភូតំ សម្មប្បញ្ញាយ បស្សតោ ។

[២៦០] តំ កឹ មញ្ញថ ភគិនិយោ ចក្ខុវិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យម្ប-នានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ តំ កិស្ស ហេតុ ។ បុព្វេវ នោ ហេតំ ភន្តេ យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋំ ឥតិបិមេ ឆ វិញ្ញាណកាយា អនិច្ចាតិ ។

មិនគួរយល់ឃើញយ៉ាងនោះទេ លោកម្ចាស់ ។ សេចក្តីនោះ ព្រោះហេតុអ្វី ។ បពិត្រលោកដ៏ចម្រើន ព្រោះថា ក្នុងកាលមុន ពួកយើងបានឃើញតាមពិតនូវសេចក្តីនុ៎ះដោយប្រាជ្ញាដ៏ប្រពៃថា អាយតនៈខាងក្រៅទាំង ៦ នេះមិនទៀងទេ ។ ម្នាលនាងទាំងឡាយ ប្រពៃពេកហើយ ម្នាលនាងទាំងឡាយ សេចក្តីនុ៎ះអរិយសាវ័ក ក៏ឃើញពិតប្រាកដដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនោះដែរ ។

[២៦០] ម្នាលនាងទាំងឡាយ ពួកនាងសំគាល់នូវសេចក្តីនោះដូចម្តេច ចក្ខុវិញ្ញាណទៀងឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ ចុះរបស់ណាដែលមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ ជាទុក្ខលោកម្ចាស់ ។ របស់ណាដែលមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញដូច្នេះដែរឬ ។ មិនគួរយល់ឃើញយ៉ាងនុ៎ះទេ លោកម្ចាស់ ។ សេចក្តីនោះ ព្រោះហេតុអ្វី ។ បពិត្រលោកដ៏ចម្រើន ព្រោះថា ក្នុងកាលមុន ពួកយើងបានឃើញតាមពិតនូវសេចក្តីនុ៎ះដោយប្រាជ្ញាដ៏ប្រពៃថា វិញ្ញាណកាយទាំង ៦ នេះមិនទៀង ។

សាធុ សាធុ ភគិនិយោ ឯវំ ហេតំ ភគិនិយោ ហោតិ អរិយសាវកស្ស យថាភូតំ សម្មប្បញ្ញាយ បស្ស-តោ ។ សោតវិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ ឃានវិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ ជិវ្ហាវិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ កាយវិញ្ញា-ណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ មនោវិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ តំ កិស្ស ហេតុ ។ បុព្វេ វ នោ ហេតំ ភន្តេ យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋំ ឥតិបិមេ ឆ វិញ្ញាណកា-យា អនិច្ចាតិ ។ សាធុ សាធុ ភគិនិយោ ឯវំ ហេតំ ភគិនិយោ ហោតិ អរិយសាវកស្ស យថាភូតំ សម្មប្បញ្ញាយ បស្សតោ ។

ម្នាលនាងទាំងឡាយ ប្រពៃពេកហើយ ម្នាលនាងទាំងឡាយ សេចក្តីនុ៎ះអរិយសាវ័ក ក៏ឃើញពិតប្រាកដដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនោះដែរ ។ សោតវិញ្ញាណទៀងឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ បេ ។ ឃានវិញ្ញាណទៀងឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ បេ ។ ជិវ្ហាវិញ្ញាណទៀងឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ បេ ។ កាយវិញ្ញាណទៀងឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ បេ ។ មនោវិញ្ញាណទៀងឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ ចុះរបស់ណា ដែលមិនទៀង របស់នោះ ជាទុក្ខឬជាសុខ ។ ជាទុក្ខលោកម្ចាស់ ។ របស់ណា ដែលមិនទៀង ជាទុក្ខ ប្រែប្រួលជាធម្មតា គួរយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញដូច្នេះដែរឬ ។ មិនគួរយល់ឃើញយ៉ាងនោះទេ លោកម្ចាស់ ។ សេចក្តីនោះ ព្រោះហេតុអ្វី ។ បពិត្រលោកដ៏ចម្រើន ព្រោះថា ក្នុងកាលមុន ពួកយើងបានឃើញតាមពិត នូវសេចក្តីនុ៎ះដោយប្រាជ្ញាដ៏ប្រពៃថា វិញ្ញាណកាយទាំង ៦ នេះ មិនទៀងទេ ។ ម្នាលនាងទាំងឡាយ ប្រពៃពេកហើយ ម្នាលនាងទាំងឡាយ រឿងនុ៎ះ អរិយសាវ័ក ក៏ឃើញពិតប្រាកដដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនេះដែរ ។

[២៦១] សេយ្យថាបិ ភគិនិយោ តេលប្បទីបស្ស ឈាយតោ តេលម្បិ អនិច្ចំ វិបរិណាមធម្មំ វដ្ដិបិ អនិច្ចា វិបរិណាមធម្មា អច្ចិបិ អនិច្ចា វិបរិណាមធម្មា អាភាបិ អនិច្ចា វិបរិណាមធម្មា ។ យោ នុ ខោ ភគិនិយោ ឯវំ វទេយ្យ អមុស្ស តេលប្បទីបស្ស ឈាយតោ តេលម្បិ អនិច្ចំ វិបរិណាមធម្មំ វដ្ដិបិ អនិច្ចា វិបរិណាមធម្មា អច្ចិបិ អនិច្ចា វិបរិណាមធម្មា យា ច ខ្វស្ស អាភា សា និច្ចា ធុវា សស្សតា អវិបរិណាមធម្មាតិ សម្មា នុ ខោ សោ ភគិនិយោ វទមានោ វទេយ្យាតិ ។ នោ ហេតំ ភន្តេ ។ តំ កិស្ស ហេតុ ។ អមុស្ស ហិ ភន្តេ តេលប្បទីបស្ស ឈាយតោ តេលម្បិ អនិច្ចំ វិបរិណាមធម្មំ វដ្ដិបិ អនិច្ចា វិបរិណាមធម្មា អច្ចិបិ អនិច្ចា វិបរិណាមធម្មា បគេវស្ស អាភា អនិច្ចា វិបរិណាមធម្មាតិ ។

សឡាយតនវគ្គ នន្ទកោវាទសូត្រ ឧបមាដោយប្រទីបប្រេង

[២៦១] ម្នាលនាងទាំងឡាយ ប្រៀបដូចជាប្រទីបពេញដោយប្រេងកំពុងឆេះ ប្រេងក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ប្រឆេះក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា អណ្តាតភ្លើងក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ពន្លឺក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ។ ម្នាលនាងទាំងឡាយ ជនណានិយាយយ៉ាងនេះថា ប្រទីបពេញដោយប្រេងឯណោះ កំពុងឆេះ ប្រេងក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ប្រឆេះក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា អណ្តាតភ្លើងក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា តែពន្លឺណារបស់ប្រទីបនោះ ពន្លឺនោះទៀងទាត់ ឋិតថេរ មិនមានសេចក្តីប្រែប្រួលជាធម្មតា ម្នាលនាងទាំងឡាយ ជននោះឈ្មោះថា និយាយត្រឹមត្រូវដែរឬ ។ បពិត្រលោកដ៏ចម្រើន ការនិយាយនោះមិនត្រឹមត្រូវទេ ។ ការនិយាយនោះមិនត្រូវ ព្រោះហេតុអ្វី ។ បពិត្រលោកដ៏ចម្រើន ព្រោះថា ប្រទីបពេញដោយប្រេងឯណោះ កំពុងឆេះ ប្រេងក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ប្រឆេះក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា អណ្តាតភ្លើងក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ចាំបាច់និយាយទៅថ្វីដល់ពន្លឺរបស់ប្រទីបនោះ ដែលជារបស់មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ។

[២៦២] ឯវមេវ ខោ ភគិនិយោ យោ នុ ខោ ឯវំ វទេយ្យ ឆ ខោមេ អជ្ឈត្តិកា អាយតនា អនិច្ចា យញ្ច ខោ ឆ អជ្ឈត្តិកេ អាយតនេ បដិច្ច បដិសំវេទេមិ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តំ និច្ចំ ធុវំ សស្សតំ អវិបរិណាមធម្មន្តិ សម្មា នុ ខោ សោ ភគិនិយោ វទមានោ វទេយ្យាតិ ។ នោ ហេតំ ភន្តេ ។ តំ កិស្ស ហេតុ ។ តជ្ជំ តជ្ជំ ភន្តេ បច្ចយំ បដិច្ច តជ្ជា តជ្ជា វេទនា ឧប្បជ្ជតិ តជ្ជស្ស តជ្ជស្ស បច្ចយស្ស និរោធា តជ្ជា តជ្ជា វេទនា និរុជ្ឈតីតិ ។ សាធុ សាធុ ភគិនិយោ ឯវំ ហេតំ ភគិនិយោ ហោតិ អរិយសាវកស្ស យថាភូតំ សម្មប្បញ្ញាយ បស្សតោ ។

[២៦៣] សេយ្យថាបិ ភគិនិយោ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ មូលម្បិ អនិច្ចំ វិបរិណាមធម្មំ ខន្ធោ-បិ អនិច្ចោ វិបរិណាមធម្មោ សាខាបលាសម្បិ អនិច្ចំ

[២៦២] ម្នាលនាងទាំងឡាយ ដំណើរនេះក៏ដូច្នោះដែរ ជនណានិយាយយ៉ាងនេះថា អាយតនៈខាងក្នុងទាំង ៦ នេះមិនទៀង អាត្មាអញអាស្រ័យអាយតនៈខាងក្នុងទាំង ៦ ហើយ ទទួលដឹងវេទនាណាជាសុខ ឬជាទុក្ខ ឬក៏មិនមែនទុក្ខមិនមែនសុខ វេទនានោះ ទៀងទាត់ឋិតថេរ មិនមានសេចក្តីប្រែប្រួលជាធម្មតា ម្នាលនាងទាំងឡាយ ជននោះឈ្មោះថា និយាយត្រូវដែរឬ ។ បពិត្រលោកដ៏ចម្រើន ការនិយាយនោះមិនត្រូវទេ ។ ការនិយាយនោះមិនត្រូវ ព្រោះហេតុអ្វី ។ បពិត្រលោកដ៏ចម្រើន ព្រោះថា វេទនាដែលកើតអំពីអាយតនៈខាងក្នុងនោះ ៗ តែងកើតឡើង ព្រោះអាស្រ័យបច្ច័យដែលកើតអំពីអាយតនៈខាងក្នុងនោះ ៗ វេទនាដែលកើតអំពីអាយតនៈខាងក្នុងនោះ ៗ រលត់ទៅព្រោះរលត់នៃបច្ច័យដែលកើតអំពីអាយតនៈខាងក្នុងនោះ ៗ ។ ម្នាលនាងទាំងឡាយ ប្រពៃពេកហើយ ម្នាលនាងទាំងឡាយ សេចក្តីនុ៎ះអរិយសាវ័ក ក៏ឃើញពិតប្រាកដដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនោះដែរ ។

[២៦៣] ម្នាលនាងទាំងឡាយ ប្រៀបដូចជាឈើធំមានខ្លឹមកំពុងឈរនៅ ឫសក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ដើមក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា មែកនិងសន្លឹកក៏មិនទៀង

វិបរិណាមធម្មំ ឆាយាបិ អនិច្ចា វិបរិណាមធម្មា ។ យោ នុ ខោ ភគិនិយោ ឯវំ វទេយ្យ អមុស្ស មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ មូលម្បិ អនិច្ចំ វិបរិណាមធម្មំ ខន្ធោបិ អនិច្ចោ វិបរិណាមធម្មោ សាខាបលាសម្បិ អនិច្ចំ វិបរិណាមធម្មំ យា ច ខ្វស្ស ឆាយា សា និច្ចា ធុវា សស្សតា អវិបរិណាមធម្មាតិ សម្មា នុ ខោ សោ ភគិនិយោ វទមានោ វទេយ្យាតិ ។ នោ ហេតំ ភន្តេ ។ តំ កិស្ស ហេតុ ។ អមុស្ស ហិ ភន្តេ មហតោ រុក្ខស្ស តិដ្ឋតោ សារវតោ មូលម្បិ អនិច្ចំ វិបរិណាមធម្មំ ខន្ធោបិ អនិច្ចោ វិបរិណាមធម្មោ សាខាបលាសម្បិ អនិច្ចំ វិបរិណាមធម្មំ បគេវស្ស ឆាយា អនិច្ចា វិបរិណាមធម្មាតិ ។

មានសេចក្តីប្រែប្រួលជាធម្មតា ស្រមោលក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ។ ម្នាលនាងទាំងឡាយ ជនណានិយាយយ៉ាងនេះថា ឈើធំឯណោះមានខ្លឹម កំពុងឈរនៅ ឫសក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ដើមក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា មែកនិងសន្លឹកក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា តែស្រមោលណារបស់ឈើនោះ ស្រមោលនោះ ទៀងទាត់ ឋិតថេរ មិនមានសេចក្តីប្រែប្រួលជាធម្មតាឡើយ ម្នាលនាងទាំងឡាយ ជននោះឈ្មោះថា និយាយត្រឹមត្រូវដែរឬ ។ បពិត្រលោកដ៏ចម្រើន ការនិយាយនុ៎ះមិនត្រូវទេ ។ ការនិយាយនោះមិនត្រូវ ព្រោះហេតុអ្វី ។ បពិត្រលោកដ៏ចម្រើន ព្រោះថា ឈើធំឯណោះមានខ្លឹម កំពុងឈរនៅ ឫសក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ដើមក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា មែកនិងសន្លឹកក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ចាំបាច់និយាយទៅថ្វីដល់ទៅស្រមោលរបស់ឈើនោះ ដែលជារបស់មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ។

[២៦៤] ឯវមេវ ខោ ភគិនិយោ យោ នុ ខោ ឯវំ វទេយ្យ ឆ ខោមេ ពាហិរា អាយតនា អ-និច្ចា យញ្ច ខោ ពាហិរេ អាយតនេ បដិច្ច បដិ-សំវេទេមិ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តំ និច្ចំ ធុវំ សស្សតំ អវិបរិណាមធម្មន្តិ សម្មា នុ ខោ សោ ភគិនិយោ វទមានោ វទេយ្យាតិ ។ នោ ហេតំ ភន្តេ ។ តំ កិស្ស ហេតុ ។ តជ្ជំ តជ្ជំ ភន្តេ បច្ចយំ បដិច្ច តជ្ជា តជ្ជា វេទនា ឧប្បជ្ជតិ តជ្ជស្ស តជ្ជស្ស បច្ចយស្ស និរោធា តជ្ជា តជ្ជា វេទនា និរុជ្ឈតីតិ ។ សាធុ សាធុ ភគិនិយោ ឯវំ ហេតំ ភគិនិយោ ហោតិ អរិយសាវកស្ស យថាភូតំ សម្មប្បញ្ញាយ បស្សតោ ។

[២៦៤] ម្នាលនាងទាំងឡាយ សេចក្តីនេះក៏ដូច្នោះដែរ ជនណានិយាយយ៉ាងនេះថា អាយតនៈខាងក្រៅទាំង ៦ នេះមិនទៀង អាត្មាអញអាស្រ័យអាយតនៈខាងក្រៅហើយ ទទួលដឹងវេទនាណាជាសុខ ឬជាទុក្ខ ឬក៏មិនមែនទុក្ខមិនមែនសុខ អារម្មណ៍នោះទៀងទាត់ ឋិតថេរ មិនមានសេចក្តីប្រែប្រួលជាធម្មតាឡើយ ម្នាលនាងទាំងឡាយ ជននោះឈ្មោះថានិយាយត្រឹមត្រូវដែរឬ ។ បពិត្រលោកដ៏ចម្រើន ការនិយាយនុ៎ះមិនត្រូវទេ ។ ការនិយាយនោះមិនត្រូវ ព្រោះហេតុអ្វី ។ បពិត្រលោកដ៏ចម្រើន ព្រោះថា វេទនាដែលកើតអំពីអាយតនៈខាងក្រៅនោះ ៗ តែងកើតឡើង ព្រោះអាស្រ័យបច្ច័យដែលកើតអំពីអាយតនៈខាងក្រៅនោះ ៗ វេទនាដែលកើតអំពីអាយតនៈខាងក្រៅនោះ ៗ រលត់ទៅ ព្រោះរលត់នៃបច្ច័យដែលកើតអំពីអាយតនៈខាងក្រៅនោះ ៗ ។ ម្នាលនាងទាំងឡាយ ប្រពៃពេកហើយ ម្នាលនាងទាំងឡាយ សេចក្តីនុ៎ះ អរិយសាវ័កក៏ឃើញពិតប្រាកដដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនោះដែរ ។

[២៦៤] សេយ្យថាបិ ភតិនិយោ ឧក្ខោ គោឃាតកោ វា គោឃាតកន្តេវាសី វា គាវឹ វធិត្វា តិណ្ហេន គោវិកន្តនេន គាវឹ វិកន្តេយ្យ អនុបហច្ច អន្តរំ មំសកាយំ អនុបហច្ច ពាហិរំ ចម្មកាយំ យំ យទេវ តត្ថ អន្តរា វិលិមំសំ អន្តរា នហារុ អន្តរា ពន្ធនំ តំ តទេវ តិណ្ហេន គោវិកន្តនេន សញ្ឆិន្ទេយ្យ សង្កន្តេយ្យ សម្បរិកន្តេយ្យ សញ្ឆិន្ទិត្វា សង្កន្តិត្វា សម្បរិកន្តិត្វា វិធុនិត្វា ពាហិរំ ចម្មកាយំ តេនេវ ចម្មេន តំ គាវឹ បដិច្ឆាទេត្វា ឯវំ វទេយ្យ តថេវាយំ គាវី សំយុត្តា ឥមិនា ចម្មេនាតិ សម្មា នុ ខោ សោ ភតិនិយោ វទមានោ វទេយ្យាតិ ។ នោ ហេតំ ភន្តេ ។ តំ កិស្ស ហេតុ ។ អមុ ហិ ភន្តេ ឧក្ខោ គោឃាតកោ វា គោឃាតកន្តេវាសី វា គាវឹ វធិត្វា តិណ្ហេន គោវិកន្តនេន គាវឹ វិកន្តេយ្យ អនុបហច្ច អន្តរំ មំសកាយំ អនុបហច្ច ពាហិរំ ចម្មកាយំ យំ យទេវ តត្ថ អន្តរា វិលិមំសំ អន្តរា នហារុ អន្តរា ពន្ធនំ

សឡាយតនវគ្គ នន្ទកោវាទសូត្រ ឧបមាដោយបុរសអ្នកសម្លាប់គោ

[២៦៥] ម្នាលនាងទាំងឡាយ ប្រៀបដូចជាបុរសអ្នកសម្លាប់គោ ឬកូនសិស្សអ្នកសម្លាប់គោដែលប្រសប់ សម្លាប់មេគោ ហើយពន្លះនូវមេគោ ដោយកាំបិតសម្រាប់អារគោដ៏មុត មិនឲ្យខូចសាច់ខាងក្នុង មិនឲ្យខូចស្បែកខាងក្រៅ បណ្តាវត្ថុទាំងនោះ វត្ថុណា ៗ គឺសាច់វាវខាងក្នុងក្តី សរសៃខាងក្នុងក្តី ចំណងខាងក្នុង ក៏អារពន្លះកាត់វត្ថុនោះ ៗ ដោយកាំបិតសម្រាប់អារគោដ៏មុត លុះអារពន្លះកាត់រួចហើយ ក៏បកយកស្បែកខាងក្រៅ មកគ្របមេគោនោះ ដោយស្បែកនោះវិញដដែល ហើយនិយាយយ៉ាងនេះថា មេគោនេះ នៅមានស្បែកដូចមុនដដែល ម្នាលនាងទាំងឡាយ ជននោះឈ្មោះថា និយាយត្រឹមត្រូវដែរឬ ។ បពិត្រលោកដ៏ចម្រើន ការនិយាយនោះមិនត្រូវទេ ។ ការនិយាយនោះមិនត្រូវ ព្រោះហេតុអ្វី ។ បពិត្រលោកដ៏ចម្រើន ព្រោះថា បុរសអ្នកសម្លាប់គោ ឬកូនសិស្សអ្នកសម្លាប់គោឯណោះដែលប្រសប់ បានសម្លាប់មេគោ ហើយពន្លះនូវមេគោ ដោយកាំបិតសម្រាប់អារគោដ៏មុត មិនឲ្យខូចសាច់ខាងក្នុង មិនឲ្យខូចស្បែកខាងក្រៅ បណ្តាវត្ថុទាំងនោះ វត្ថុណា ៗ គឺសាច់វាវខាងក្នុងក្តី សរសៃខាងក្នុងក្តី ចំណងខាងក្នុងក្តី

តំ តនេវ តិណ្ហេន គោវិកន្តនេន ការី សញ្ឆិន្ទេយ្យ សង្កន្តេយ្យ សម្បរិកន្តេយ្យ សញ្ឆិន្ទិត្វា សង្កន្តិត្វា សម្បរិកន្តិត្វា វិធុនិត្វា ពាហិរំ ចម្មកាយំ តេនេវ ចម្មេន តំ ការី បដិច្ឆាទេត្វា កិញ្ចាបិ សោ ឯវំ វទេយ្យ តថេវាយំ ការី សំយុត្តា ឥមិនា ចម្មេនាតិ អថខោ សា ការី វិសំយុត្តា តេនេវ ចម្មេន ។

[២៦៦] ឧបមា ខោ មេ អយំ ភគិនិយោ កតា អត្ថស្ស វិញ្ញាបនាយ ។ អយមេវេត្ថ អត្ថោ ។ អន្តរា មំសកាយោតិ ខោ ភគិនិយោ ឆន្នេតំ អជ្ឈត្តិកានំ អាយតនានំ អធិវចនំ ។ ពាហិរោ ចម្មកាយោតិ ខោ ភគិនិយោ ឆន្នេតំ ពាហិរានំ អាយតនានំ អធិវចនំ ។ អន្តរា វិលិមំសំ អន្តរា នហារុ អន្តរា ពន្ធនន្តិ ខោ ភគិនិយោ នន្ទិរាគស្សេតំ អធិវចនំ ។ តិណ្ហំ គោវិកន្តនន្តិ ខោ ភគិនិយោ អរិយាយេតំ បញ្ញាយ អធិវចនំ ។ យាយំ អរិយា បញ្ញា អន្តរា កិលេសំ អន្តរា សញ្ញោជនំ អន្តរា ពន្ធនំ សញ្ឆិន្ទតិ សង្កន្តតិ សម្បរិកន្តតិ ។

ក៏អារពន្ទះកាត់វត្ថុនោះ ៗ ដោយកាំបិតសម្រាប់អារគោដ៏មុត លុះអារពន្ទះកាត់រួចហើយ ក៏បកយកស្បែកខាងក្រៅ មកគ្របមេគោនោះ ដោយស្បែកនោះដដែល អ្នកនោះនិយាយយ៉ាងនេះថា មេគោនេះ នៅមានស្បែកដូចមុនដដែល ក៏ពិតមែនហើយ ប៉ុន្តែមេគោនោះប្រាសចាកស្បែកនោះទៅហើយ ។

[២៦៦] ម្នាលនាងទាំងឡាយ ពាក្យឧបមា ដែលយើងធ្វើហើយនេះ ដើម្បីឲ្យពួកនាងដឹងច្បាស់នូវសេចក្តីអធិប្បាយ ។ ឯសេចក្តីអធិប្បាយក្នុងអាយតនៈនុ៎ះដូចតទៅនេះ ។ ម្នាលនាងទាំងឡាយ ពាក្យថា សាច់ខាងក្នុងដូច្នេះនុ៎ះ ជាឈ្មោះនៃអាយតនៈខាងក្នុង ៦ ។ ម្នាលនាងទាំងឡាយ ពាក្យថាស្បែកខាងក្រៅដូច្នេះនុ៎ះ ជាឈ្មោះនៃអាយតនៈខាងក្រៅ ៦ ។ ម្នាលនាងទាំងឡាយ ពាក្យថា សាច់វាវខាងក្នុងក្តី សរសៃខាងក្នុងក្តី ចំណងខាងក្នុងក្តី ដូច្នេះនុ៎ះ ជាឈ្មោះនៃនន្ទិរាគៈ ។ ម្នាលនាងទាំងឡាយ ពាក្យថា កាំបិតសម្រាប់អារគោដ៏មុតដូច្នេះនុ៎ះ ជាឈ្មោះនៃប្រាជ្ញាដ៏ប្រសើរ ។ ប្រាជ្ញាដ៏ប្រសើរនេះ តែងអារពន្ទះកាត់នូវកិលេសខាងក្នុង សំយោជនៈខាងក្នុង និងចំណងខាងក្នុង ។

សឡាយតនវគ្គស្ស នន្ទកោវាទសុត្តេ សត្តពោជ្ឈង្គា

[២៦៧] សត្ត ខោ ឥមេ ភតិនិយោ ពោជ្ឈង្គា យេសំ ភាវិតត្តា ពហុលីកតត្តា ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ និដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ កតមេ សត្ត ។ ឥធ ភតិនិយោ ភិក្ខុ សតិ-សម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធ-និស្សិតំ វោស្សគ្គបរិណាមំ ធម្មវិចយសម្ពោជ្ឈង្គំ ភា-វេតិ... វីរិយសម្ពោជ្ឈង្គំ ភាវេតិ... បីតិសម្ពោជ្ឈង្គំ ភា-វេតិ... បស្សទ្ធិសម្ពោជ្ឈង្គំ ភាវេតិ... សមាធិសម្ពោជ្ឈង្គំ ភាវេតិ... ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមំ ។ ឥមេ ខោ ភតិនិយោ សត្ត ពោជ្ឈង្គា យេសំ ភាវិតត្តា ពហុលីកតត្តា ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ និដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ។

[២៦៧] ម្នាលនាងទាំងឡាយ ពោជ្ឈង្គទាំងប្រាំពីរនេះ ភិក្ខុណាចម្រើនហើយ ធ្វើឲ្យរឿយ ៗ ហើយ ភិក្ខុនោះ រមែងអស់អាសវៈទាំងឡាយ ហើយត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់បានដោយខ្លួនឯង ក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ពោជ្ឈង្គទាំង ៧ ដូចម្តេចខ្លះ ។ ម្នាលនាងទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើននូវសតិសម្ពោជ្ឈង្គ ដែលអាស្រ័យ នូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវសេចក្តីប្រាសចាកតម្រេក អាស្រ័យនូវសេចក្តីរលត់ ឈមមុខទៅកាន់សេចក្តីលះបង់ ចម្រើននូវធម្មវិចយសម្ពោជ្ឈង្គ... ចម្រើននូវវីរិយសម្ពោជ្ឈង្គ... ចម្រើននូវបីតិសម្ពោជ្ឈង្គ... ចម្រើននូវបស្សទ្ធិសម្ពោជ្ឈង្គ... ចម្រើននូវសមាធិសម្ពោជ្ឈង្គ... ចម្រើននូវឧបេក្ខាសម្ពោជ្ឈង្គ... ដែលអាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវសេចក្តីប្រាសចាកតម្រេក អាស្រ័យនូវសេចក្តីរលត់ ឈមមុខទៅកាន់សេចក្តីលះបង់ ។ ម្នាលនាងទាំងឡាយ ពោជ្ឈង្គទាំង ៧ នេះឯង ដែលភិក្ខុណាបានចម្រើន បានធ្វើឲ្យរឿយ ៗ ហើយ ភិក្ខុនោះរមែងអស់អាសវៈទាំងឡាយ ហើយត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់បានដល់ដោយខ្លួនឯងក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។

[២៦៨] អថខោ អាយស្មា នន្ទកោ តា ភិក្ខុនិយោ ឥមិនា ឱវាទេន ឱវទិត្វា ឧយ្យោជេសិ គច្ឆថ ភគិនិយោ កាលោតិ ។ អថខោ តា ភិក្ខុនិយោ អាយស្មតោ នន្ទកស្ស ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា អាយស្មន្តំ នន្ទកំ អភិវាទេត្វា បទក្ខិណំ កត្វា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។ ឯកមន្តំ ឋិតា ខោ តា ភិក្ខុនិយោ ភគវា ឯតទវោច គច្ឆថ ភិក្ខុនិយោ កាលោតិ ។ អថខោ តា ភិក្ខុនិយោ ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កមឹសុ ។

[២៦៩] អថខោ ភគវា អចិរបក្កន្តាសុ តាសុ ភិក្ខុនីសុ ភិក្ខូ អាមន្តេសិ សេយ្យថាបិ ភិក្ខវេ តទហុបោសថេ បណ្ណរសេ ន ហោតិ ពហុនោ ជនស្ស កង្ខា វា វិមតិ វា ឩនោ នុ ខោ ចន្ទោ បុណ្ណោ នុ ខោ ចន្ទោតិ អថខោ បុណ្ណោ ចន្ទោ ត្វេវ ហោតិ

[២៦៨] លំដាប់នោះឯង លុះព្រះនន្ទកៈមានអាយុ បានទូន្មានភិក្ខុនីទាំងនោះដោយឱវាទនេះហើយ ទើបបញ្ជូនទៅថា ម្នាលនាងទាំងឡាយ ពេលល្មមហើយ ចូរនាំគ្នាទៅចុះ ។ គ្រានោះឯង ពួកភិក្ខុនីនោះ ត្រេកអរ អនុមោទនា នូវភាសិតរបស់ព្រះនន្ទកៈមានអាយុហើយ ក៏ក្រោកអំពីអាសនៈ ថ្វាយបង្គំព្រះនន្ទកៈមានអាយុ ធ្វើប្រទក្សិណហើយ ទើបចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ លុះពួកភិក្ខុនីនោះ ឋិតនៅក្នុងទីដ៏សមគួរហើយ ទើបព្រះមានព្រះភាគត្រាស់យ៉ាងនេះថា ម្នាលនាងទាំងឡាយ ពេលល្មមហើយ ចូរទៅចុះ ។ លំដាប់នោះ ពួកភិក្ខុនីនោះថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយទើបចេញទៅ ។

[២៦៩] កាលដែលពួកភិក្ខុនីនោះ ចេញទៅមិនយូរប៉ុន្មាន ទើបព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃឧបោសថទី ១៤ ជនជាច្រើនតែងមិនមានសេចក្តីសង្ស័យ ឬងឿងឆ្ងល់ថា ព្រះចន្ទខ្វះ ឬព្រះចន្ទពេញដូច្នេះឡើយ គឺចូលចិត្តថា ព្រះចន្ទពេញដោយពិត សេចក្តីនេះ មានឧបមាយ៉ាងណាមិញ

៣០១

សឡាយតនវគ្គស្ស នន្ទកោវាទសុត្តេ ភាសិតាភិនន្ទនំ

ឯវមេវ ខោ ភិក្ខវេ តា ភិក្ខុនិយោ នន្ទកស្ស ធម្មទេសនាយ អត្តមនា ចេវ បរិបុណ្ណសង្កប្បា ច ។ តាសំ ភិក្ខវេ បញ្ចន្នំ ភិក្ខុនីសតានំ យា បច្ឆិមិកា[១] ភិក្ខុនី សា[២] សោតាបន្នា អវិនិបាតធម្មា និយតា សម្ពោធិបរាយណាតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

នន្ទកោវាទសុត្តំ ចតុត្ថំ និដ្ឋិតំ ។

---

១ ឱ. បច្ឆិមា ។ ២ ម. តា ភិក្ខុនិយោ ។

ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីនោះ មានសេចក្តីត្រេកអរក្នុងធម្មទេសនារបស់នន្ទកភិក្ខុផង មានបំណងពេញលេញផង ក៏មានឧបមេយ្យយ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុនីទាំងឡាយប្រាំរយនោះ ភិក្ខុនីណាដែលក្រោយគេបំផុត ភិក្ខុនីនោះ ជាសោតាបន្នា មានសភាពមិនធ្លាក់ទៅក្នុងអបាយភូមិ ជាអ្នកទៀង តទៅកពខាងមុខនឹងបានត្រាស់ដឹង (នូវសច្ចធម៌) ។ លុះព្រះមានព្រះភាគត្រាស់ពាក្យនេះចប់ហើយ ភិក្ខុទាំងនោះ ក៏មានសេចក្តីត្រេកអរ រីករាយចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ នន្ទកោវាទសូត្រ ទី ៤ ។

# បញ្ចមំ ចូឡរាហុលោវាទសុត្តំ

[២៧០] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ ភគវតោ រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ បរិបក្កា ខោ រាហុលស្ស វិមុត្តិបរិបាចនីយា ធម្មា យន្នូនាហំ រាហុលំ ឧត្តរឹ អាសវានំ ខយេ វិនេយ្យន្តិ ។

[២៧១] អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថឹ បិណ្ឌាយ បាវិសិ ។ សាវត្ថិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ អាយស្មន្តំ រាហុលំ អាមន្តេសិ គណ្ហាហិ រាហុល និសីទនំ យេន អន្ធវនំ តេនុបសង្កមិស្សាម

# ចូឡរាហុលោវាទសូត្រ ទី ៥

[២៧០] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងទីស្ងាត់ ពួនសម្ងំ (ក្នុងផលសមាបត្តិ) ក៏មានព្រះតម្រិះក្នុងព្រះហឫទ័យកើតឡើងយ៉ាងនេះថា ធម៌ទាំងឡាយសម្រាប់ធ្វើវិមុត្តិឲ្យចាស់ក្លា របស់រាហុល ចាស់ក្លាហើយ បើដូច្នោះ គួរតែតថាគតទូន្មានរាហុល ក្នុងការអស់ទៅនៃអាសវៈទាំងឡាយ តទៅទៀត ។

[២៧១] គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងវេលាព្រឹកព្រហាម ស្តេចចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត ។ លុះព្រះអង្គស្តេចទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថីហើយ ត្រឡប់មកអំពីបិណ្ឌបាត ក្នុងកាលជាខាងក្រោយនៃភត្តវិញ ទ្រង់ត្រាស់ហៅព្រះរាហុលមានអាយុថា ម្នាលរាហុល ចូរអ្នកកាន់យកសំពត់និសីទនៈ យើងនឹងចូលទៅឯអន្ធវ័ន (ព្រៃជាទីនៅនៃចោរខ្វាក់)

ទិវាវិហារាយាតិ ។ ឯវម្ភន្តេតិ ខោ អាយស្មា រាហុ-
លោ ភគវតោ បដិស្សុត្វា និសីទនំ អាទាយ ភគវន្តំ
បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធិ ។ តេន ខោ បន សម-
យេន អនេកានិ ទេវតាសហស្សានិ ភគវន្តំ អនុ-
ពន្ធានិ ហោន្តិ អជ្ជ ភគវា អាយស្មន្តំ រាហុលំ
ឧត្តរឹ អាសវានំ ខយេ វិនេស្សតីតិ ។ អថខោ ភគវា
អន្ធវនំ អជ្ឈោគាហេត្វា អញ្ញតរស្មឹ រុក្ខមូលេ បញ្ញត្តេ
អាសនេ និសីទិ ។ អាយស្មាបិ ខោ រាហុលោ
ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។

[២៧២] ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ រាហុ-
លំ ភគវា ឯតទវោច តំ កឹ មញ្ញសិ រាហុល
ចក្ខុ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។

ដើម្បីសម្រាកក្នុងវេលាថ្ងៃ ។ ព្រះរាហុលមានអាយុ ទទួលតបព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ហើយក៏កាន់យកសំពត់និសីទនៈ ដើរតាមក្រោយ ៗ ព្រះមានព្រះភាគទៅ ។ សម័យនោះឯង ទេវតាច្រើនពាន់ ទៅតាមព្រះមានព្រះភាគ ដោយគិតថា ថ្ងៃនេះព្រះមានព្រះភាគ នឹងទូន្មានព្រះរាហុលមានអាយុ ក្នុងការអស់ទៅនៃអាសវៈទាំងឡាយ តទៅទៀត ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ស្តេចចូលទៅដល់អន្ធវ័ន ហើយគង់នៅលើអាសនៈដែលគេក្រាលថ្វាយទៀបគល់ឈើមួយដើម ។ ចំណែកព្រះរាហុលមានអាយុ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់នៅក្នុងទីសមគួរ ។

[២៧២] លុះព្រះរាហុលមានអាយុ គង់នៅក្នុងទីសមគួរហើយ ទើបព្រះមានព្រះភាគត្រាស់សួរដូច្នេះថា ម្នាលរាហុល អ្នកសំគាល់សេចក្តីនេះថាដូចម្តេច ចក្ខុទៀងឬមិនទៀង ។ ព្រះរាហុលមានអាយុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។

យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។

[២៧៣] តំ កឹ មញ្ញសិ រាហុល រូបា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។

[២៧៤] តំ កឹ មញ្ញសិ រាហុល ចក្ខុវិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ

ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ បពិត្រព្រះអង្គដ៏ចម្រើន ជាទុក្ខ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា តើគួរនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនគួរនឹងយល់ឃើញយ៉ាងនោះទេ ។

[២៧៣] ម្នាលរាហុល អ្នកសំគាល់សេចក្តីនោះថាដូចម្តេច រូបទៀងឬមិនទៀង ។ បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ បពិត្រព្រះអង្គដ៏ចម្រើន ជាទុក្ខ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា តើគួរនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនគួរនឹងយល់ឃើញយ៉ាងនោះទេ ។

[២៧៤] ម្នាលរាហុល អ្នកសំគាល់សេចក្តីនោះ ថាដូចម្តេច ចក្ខុវិញ្ញាណទៀងឬមិនទៀង ។ បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។ ចុះរបស់ណាមិនទៀង របស់នោះ ជាទុក្ខឬជាសុខ ។ បពិត្រព្រះអង្គដ៏ចម្រើន ជាទុក្ខ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ

វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។

[២៧៥] តំ កឹ មញ្ញសិ រាហុល ចក្ខុសម្ផស្សោ និច្ចោ វា អនិច្ចោ វាតិ ។ អនិច្ចោ ភន្តេ ។ យម្បនា-និច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យម្ប-នានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិ-តុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។

[២៧៦] តំ កឹ មញ្ញសិ រាហុល យមិទំ ចក្ខុ-សម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទនាគតំ សញ្ញាគតំ សង្ខារ-គតំ វិញ្ញាណគតំ តម្បិ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ

មានសេចក្តីប្រែប្រួលជាធម្មតា តើគួរនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនគួរនឹងយល់ឃើញយ៉ាងនោះទេ ។

[២៧៥] ម្នាលរាហុល អ្នកសំគាល់សេចក្តីនោះ ថាដូចម្តេច ចក្ខុសម្ផស្ស ទៀងឬមិនទៀង ។ បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ បពិត្រព្រះអង្គដ៏ចម្រើន ជាទុក្ខ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា តើគួរនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនគួរនឹងយល់ឃើញយ៉ាងនោះទេ ។

[២៧៦] ម្នាលរាហុល អ្នកសំគាល់សេចក្តីនោះ ថាដូចម្តេច ធម្មជាតណាគឺ វេទនា សញ្ញា សង្ខារ វិញ្ញាណ កើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ ធម្មជាតនោះ តើទៀង ឬមិនទៀង ។ បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ បពិត្រព្រះអង្គដ៏ចម្រើន ជាទុក្ខ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា

កាល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហ-
មស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។

[២៧៧] តំ កឹ មញ្ញសិ រាហុល សោតំ និច្ចំ
វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ ឃានំ និច្ចំ
វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ បេ ។ ជិវ្ហា និច្ចា
វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ ។ បេ ។ កាយោ
និច្ចោ វា អនិច្ចោ វាតិ ។ អនិច្ចោ ភន្តេ ។ បេ ។

[២៧៨] តំ កឹ មញ្ញសិ រាហុល មនោ និច្ចោ វា
អនិច្ចោ វាតិ ។ អនិច្ចោ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ
វា សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ
វិបរិណាមធម្មំ កាល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម
ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។

តើគួរនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនគួរនឹងយល់ឃើញយ៉ាងនោះទេ ។

[២៧៧] ម្នាលរាហុល អ្នកសំគាល់សេចក្ដីនោះ ថាដូចម្ដេច ត្រចៀកទៀងឬមិនទៀង ។ បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។ បេ ។ ច្រមុះទៀងឬមិនទៀង ។ បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។ បេ ។ អណ្ដាតទៀងឬមិនទៀង ។ បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។ បេ ។ កាយទៀងឬមិនទៀង ។ បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។ បេ ។

[២៧៨] ម្នាលរាហុល អ្នកសំគាល់សេចក្ដីនោះថាដូចម្ដេច ចិត្តទៀងឬមិនទៀង ។ បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ បពិត្រព្រះអង្គដ៏ចម្រើន ជាទុក្ខ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា តើគួរនឹងយល់ឃើញរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនគួរនឹងយល់ឃើញយ៉ាងនោះទេ ។

[២៧៩] តំ កឹ មញ្ញសិ រាហុល ធម្មា និច្ចា វា អនិច្ចា វាតិ ។ អនិច្ចា ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។

[២៨០] តំ កឹ មញ្ញសិ រាហុល មនោវិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។

[២៧៩] ម្នាលរាហុល អ្នកសំគាល់សេចក្តីនោះថាដូចម្តេច ធម្មារម្មណ៍ទៀងឬមិនទៀង ។ បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ បពិត្រព្រះអង្គដ៏ចម្រើន ជាទុក្ខ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា តើគួរនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនគួរនឹងយល់ឃើញយ៉ាងនោះទេ ។

[២៨០] ម្នាលរាហុល អ្នកសំគាល់សេចក្តីនោះថាដូចម្តេច មនោវិញ្ញាណទៀងឬមិនទៀង ។ បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ បពិត្រព្រះអង្គដ៏ចម្រើន ជាទុក្ខ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា តើគួរនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនគួរនឹងយល់ឃើញយ៉ាងនោះទេ ។

[២៨១] តំ កឹ មញ្ញសិ រាហុល មនោសម្ផស្សោ និច្ចោ វា អនិច្ចោ វាតិ ។ អនិច្ចោ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។

[២៨២] តំ កឹ មញ្ញសិ រាហុល យមិទំ មនោ-សម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគតំ តម្បិ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វិបរិ-ណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។

[២៨៣] ឯវំ បស្សំ រាហុល សុតវា អរិយ-សាវកោ ចក្ខុស្មឹបិ[១] និព្វិន្ទតិ រូបេសុបិ និព្វិន្ទតិ

---
១ ឱ. ម. អបិសទ្ទោ ន ទិស្សតិ ។

[២៨១] ម្នាលរាហុល អ្នកសំគាល់សេចក្តីនោះ ថាដូចម្តេច មនោសម្ផស្ស ទៀងឬមិនទៀង ។ បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ បពិត្រព្រះអង្គដ៏ចម្រើន ជាទុក្ខ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា តើគួរនឹងយល់ឃើញ នូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនគួរនឹងយល់ឃើញយ៉ាងនោះទេ ។

[២៨២] ម្នាលរាហុល អ្នកសំគាល់សេចក្តីនោះ ថាដូចម្តេច ធម្មជាតណាគឺវេទនា សញ្ញា សង្ខារ វិញ្ញាណ តែងកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ ធម្មជាតនោះ តើទៀងឬមិនទៀង ។ បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ។ បពិត្រព្រះអង្គដ៏ចម្រើន ជាទុក្ខ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា តើគួរនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនគួរនឹងយល់ឃើញយ៉ាងនោះទេ ។

[២៨៣] ម្នាលរាហុល អរិយសាវ័ក ដែលមានសេចក្តីចេះដឹងយល់ឃើញយ៉ាងនេះ ក៏នឿយណាយក្នុងចក្ខុផង នឿយណាយក្នុងរូបផង

៣០៩



ចក្ខុវិញ្ញាណេបិ និព្វិន្ទតិ ចក្ខុសម្ផស្សេបិ និព្វិន្ទតិ យមិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគតំ តស្មឹបិ និព្វិន្ទតិ ។ សោតស្មឹបិ និព្វិន្ទតិ សទ្ទេសុបិ និព្វិន្ទតិ... ឃានស្មឹបិ និព្វិន្ទតិ... គន្ធេសុបិ និព្វិន្ទតិ... ជិវ្ហាយបិ និព្វិន្ទតិ រសេសុបិ និព្វិន្ទតិ... កាយស្មឹបិ និព្វិន្ទតិ ផោដ្ឋព្វេសុបិ និព្វិន្ទតិ... មនស្មឹបិ និព្វិន្ទតិ ធម្មេសុបិ និព្វិន្ទតិ មនោវិញ្ញាណេបិ និព្វិន្ទតិ មនោសម្ផស្សេបិ និព្វិន្ទតិ យមិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទនាគតំ សញ្ញាគតំ សង្ខារគតំ វិញ្ញាណគតំ តស្មឹបិ និព្វិន្ទតិ ។ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ វិមុត្តស្មឹ វិមុត្តមិតិ[១] ញាណំ ហោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

១ វិមុត្តមីតិបិ បាហោ ។

នឿយណាយ ក្នុងចក្ខុវិញ្ញាណផង នឿយណាយក្នុងចក្ខុសម្ផស្សផង នឿយណាយក្នុងវេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យផង ។ នឿយណាយក្នុងត្រចៀកផង នឿយណាយក្នុងសំឡេងផង... នឿយណាយក្នុងច្រមុះផង នឿយណាយក្នុងក្លិនផង... នឿយណាយក្នុងអណ្ដាតផង នឿយណាយក្នុងរសផង... នឿយណាយក្នុងកាយផង នឿយណាយក្នុងផោដ្ឋព្វៈផង... នឿយណាយក្នុងចិត្តផង នឿយណាយក្នុងធម្មារម្មណ៍ផង នឿយណាយក្នុងមនោវិញ្ញាណផង នឿយណាយក្នុងមនោសម្ផស្សផង នឿយណាយក្នុងវេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលកើតឡើង ព្រោះមនោ-សម្ផស្សជាបច្ច័យផង ។ កាលអរិយសាវ័ក នឿយណាយ (យ៉ាងនេះ) ហើយ ក៏ប្រាសចាកតម្រេក ចិត្តក៏ផុតស្រឡះ (ចាកអាសវៈ) ព្រោះប្រាសចាកតម្រេក កាលបើចិត្តផុតស្រឡះហើយ ប្រាជ្ញាក៏កើតឡើងថា ចិត្តផុតស្រឡះហើយ អរិយសាវ័កនោះ ក៏ដឹងច្បាស់ដូច្នេះថា ជាតិ (របស់អាត្មាអញ) អស់ហើយ ព្រហ្មចរិយៈអាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ចអាត្មាអញបានធ្វើរួចហើយ កិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[២៨៤] ឥទមវោច ភគវា អត្តមនោ អាយស្មា រាហុលោ ភគវតោ ភាសិតំ អភិនន្ទីតិ ។ ឥមស្មិ-ញ្ច បន[១] វេយ្យាករណស្មឹ ភញ្ញមានេ អាយស្ម-តោ រាហុលស្ស អនុបាទាយ អាសវេហិ ចិត្តំ វិ-មុច្ចិ ។ តាសញ្ច អនេកានំ ទេវតាសហស្សានំ វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ យំ កិញ្ចិ សមុ-ទយធម្មំ សព្វន្តំ និរោធធម្មន្តិ ។

ចូឡរាហុលោវាទសុត្តំ បញ្ចមំ និដ្ឋិតំ ។

---

១ ឱ. ឥមស្មឹ ខោ បន ។

[២៨២] លុះព្រះមានព្រះភាគ ទ្រង់សំដែងនូវព្រះសូត្រនេះចប់ហើយ ព្រះរាហុលមានអាយុ ក៏មានសេចក្តីត្រេកអរ នឹងភាសិតនៃព្រះមានព្រះភាគ ។ កាលដែលព្រះមានព្រះភាគ ទ្រង់សំដែងនូវវេយ្យាករណ៍នេះចប់ហើយ ចិត្តរបស់រាហុលមានអាយុ ក៏បានរួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ (ថាអញ ថាយើង) ទៀតឡើយ ។ ធម្មចក្ខុ[១] (ភ្នែកឃើញធម៌) ដ៏ប្រាសចាកធូលីគឺរាគាទិក្កិលេស ប្រាសចាកមន្ទិលគឺអកុសល បានកើតឡើងហើយ ដល់ពួកទេវតាច្រើនពាន់ទាំងនោះថា ធម្មជាតណាមួយ មានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានកិរិយារលត់ទៅវិញជាធម្មតា ។

ចប់ ចូឡរាហុលោវាទសូត្រ ទី ៥ ។

---

១ ក្នុងព្រះសូត្រនេះសំដៅយកមគ្គ ៤ និងផល ៤ ហៅថាធម្មចក្ខុ ព្រោះថា បណ្តាទេវតាទាំងនោះ ទេវតាពួកខ្លះ ដែលស្តាប់ព្រះសូត្រនេះ បានជាសោតាបន្នបុគ្គល ខ្លះបានជាសកទាគាមិបុគ្គល ខ្លះបានជាអនាគាមិបុគ្គល ខ្លះបានជាព្រះខីណាស្រព ។

## ឆដ្ឋំ ឆឆក្កសុត្តំ

[២៨៥] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច ធម្មំ វោ ភិក្ខវេ ទេសិស្សាមិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសិស្សាមិ យទិទំ ឆ ឆក្កានិ តំ សុណាថ សាធុកំ មនសិករោថ ទេសិស្សាមីតិ ។ ឯវម្ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

# ឆឆក្កសូត្រ ទី ៦

[២៨៥] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ កាលព្រះមានព្រះភាគ គង់នៅក្នុងវត្តនោះ បានត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងធម៌ មានលំអបទដើម មានលំអបទកណ្តាល មានលំអបទចុងប្រកាសព្រហ្មចរិយធម៌ ព្រមទាំងអត្ថ ទាំងព្យញ្ជនៈ ដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ចំពោះអ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់នូវធម៌ដែលមានចំនួនប្រាំមួយឆក្កៈ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសំដែងឲ្យស្តាប់ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[២៨៦] ភគវា ឯតទវោច ឆ អជ្ឈត្តិកានិ អាយតនានិ វេទិតព្វានិ ឆ ពាហិរានិ អាយតនានិ វេទិតព្វានិ ឆ វិញ្ញាណកាយា វេទិតព្វា ឆ ផស្សកាយា វេទិតព្វា ឆ វេទនាកាយា វេទិតព្វា ឆ តណ្ហាកាយា វេទិតព្វា ។

[២៨៧] ឆ អជ្ឈត្តិកានិ អាយតនានិ វេទិតព្វានីតិ ឥតិ ខោ បនេតំ វុត្តំ ។ កិញ្ចេតំ បដិច្ច វុត្តំ ។ ចក្ខាយតនំ សោតាយតនំ ឃានាយតនំ ជិវ្ហាយតនំ កាយាយតនំ មនាយតនំ ។ ឆ អជ្ឈត្តិកានិ អាយតនានិ វេទិតព្វានីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ ឥទំ បឋមំ ឆក្កំ ។

[២៨៦] ព្រះមានព្រះភាគបានត្រាស់ដូច្នេះថា អាយតនៈខាងក្នុង ៦ ក៏គួរដឹង អាយតនៈខាងក្រៅ ៦ ក៏គួរដឹង វិញ្ញាណកាយ (ពួកវិញ្ញាណ) ៦ ក៏គួរដឹង ផស្សកាយ (ពួកផស្សៈ) ៦ ក៏គួរដឹង វេទនាកាយ (ពួកវេទនា) ៦ ក៏គួរដឹង តណ្ហាកាយ (ពួកតណ្ហា) ៦[១] ក៏គួរដឹង ។

[២៨៧] ឯពាក្យថា អាយតនៈខាងក្នុង ៦ ក៏គួរដឹង ដូច្នេះនុ៎ះ តថាគតបានពោលហើយ ។ ចុះពាក្យដែលតថាគតពោលហើយនុ៎ះ តើព្រោះអាស្រ័យសេចក្តី ដូចម្តេច ។ ចក្ខាយតនៈ ១ សោតាយតនៈ ១ ឃានាយតនៈ ១ ជិវ្ហាយតនៈ ១ កាយាយតនៈ ១ មនាយតនៈ ១ ។ ពាក្យណា ដែលតថាគត ពោលហើយថា អាយតនៈខាងក្នុង ៦ ក៏គួរដឹង ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យសេចក្តីនេះឯង ។ នេះ ឆក្កៈ ទី ១ ។

---

១ មាតិកានេះហើយដែលពាក្យខាងដើមថា ៦ ឆក្កៈ គឺធម៌មានពួក ៦ មានចំនួន ៦ ដង ។

[២៨៨] ឆ ពាហិរានិ អាយតនានិ វេទិតព្វានីតិ ឥតិ ខោ បនេតំ វុត្តំ ។ កិញ្ចេតំ បដិច្ច វុត្តំ ។ រូបាយតនំ សទ្ទាយតនំ គន្ធាយតនំ រសាយតនំ ផោដ្ឋព្វាយតនំ ធម្មាយតនំ ។ ឆ ពាហិរានិ អាយតនានិ វេទិតព្វានីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ ឥទំ ទុតិយំ ឆក្កំ ។

[២៨៩] ឆ វិញ្ញាណកាយា វេទិតព្វាតិ ឥតិ ខោ បនេតំ វុត្តំ ។ កិញ្ចេតំ បដិច្ច វុត្តំ ។ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ សោតញ្ច បដិច្ច សទ្ទេ ច ឧប្បជ្ជតិ សោតវិញ្ញាណំ ឃានញ្ច បដិច្ច គន្ធេ ច ឧប្បជ្ជតិ ឃានវិញ្ញាណំ ជិវ្ហញ្ច បដិច្ច រសេ ច ឧប្បជ្ជតិ ជិវ្ហាវិញ្ញាណំ កាយញ្ច បដិច្ច ផោដ្ឋព្វេ ច ឧប្បជ្ជតិ កាយវិញ្ញាណំ មនញ្ច បដិច្ច ធម្មេ ច ឧប្បជ្ជតិ មនោវិញ្ញាណំ ។ ឆ វិញ្ញាណកាយា វេទិតព្វាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ ឥទំ តតិយំ ឆក្កំ ។

[២៨៨] ពាក្យថា អាយតនៈខាងក្រៅ ៦ ក៏គួរដឹង ដូច្នេះនុ៎ះ តថាគតបានពោលហើយ ។ ចុះពាក្យដែលតថាគតពោលហើយនុ៎ះ តើព្រោះអាស្រ័យសេចក្តីដូចម្តេច ។ រូបាយតនៈ ១ សទ្ទាយតនៈ ១ គន្ធាយតនៈ ១ រសាយតនៈ ១ ផោដ្ឋព្វាយតនៈ ១ ធម្មាយតនៈ ១ ។ ពាក្យណា ដែលតថាគតពោលហើយថា អាយតនៈខាងក្រៅ ៦ ក៏គួរដឹង ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យសេចក្តីនេះឯង ។ នេះ ឆក្កៈទី ២ ។

[២៨៩] ពាក្យថា វិញ្ញាណកាយ ៦ ក៏គួរដឹង ដូច្នេះនុ៎ះ តថាគតបានពោលហើយ ។ ចុះពាក្យដែលតថាគតពោលហើយនុ៎ះ តើព្រោះអាស្រ័យសេចក្តីដូចម្តេច ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យភ្នែកនិងរូប ១ សោតវិញ្ញាណ កើតឡើង ព្រោះអាស្រ័យត្រចៀកនិងសំឡេង ១ ឃានវិញ្ញាណ កើតឡើង ព្រោះអាស្រ័យច្រមុះនិងក្លិន ១ ជិវ្ហាវិញ្ញាណកើតឡើង ព្រោះអាស្រ័យអណ្តាតនិងរស ១ កាយវិញ្ញាណ កើតឡើង ព្រោះអាស្រ័យកាយនិងផោដ្ឋព្វៈ ១ មនោវិញ្ញាណ កើតឡើង ព្រោះអាស្រ័យចិត្តនិងធម្មារម្មណ៍ ១ ។ ពាក្យណា ដែលតថាគតពោលហើយថា វិញ្ញាណកាយ ៦ ក៏គួរដឹង ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យសេចក្តីនេះឯង ។ នេះ ឆក្កៈទី ៣ ។

[២៩០] ឆ ផស្សកាយា វេទិតព្វាតិ ឥតិ ខោ បនេតំ វុត្តំ ។ កិញ្ចេតំ បដិច្ច វុត្តំ ។ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ។ សោតញ្ច បដិច្ច សទ្ទេ ច ឧប្បជ្ជតិ សោតវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ។ ឃានញ្ច បដិច្ច គន្ធេ ច ឧប្បជ្ជតិ ឃានវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ។ ជិវ្ហញ្ច បដិច្ច រសេ ច ឧប្បជ្ជតិ ជិវ្ហាវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ។ កាយញ្ច បដិច្ច ផោដ្ឋព្វេ ច ឧប្បជ្ជតិ កាយវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ។ មនញ្ច បដិច្ច ធម្មេ ច ឧប្បជ្ជតិ មនោវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ។ ឆ ផស្សកាយា វេទិតព្វាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ ឥទំ ចតុត្ថំ ឆក្កំ ។

[២៩០] ពាក្យថា ផស្សកាយ ៦ ក៏គួរដឹង ដូច្នេះនុ៎ះ តថាគត បានពោលហើយ ។ ចុះពាក្យដែលតថាគតពោលហើយនុ៎ះ តើព្រោះអាស្រ័យសេចក្ដីដូចម្ដេច ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យភ្នែកនិងរូប ការជួបជុំនៃរបស់ទាំង ៣ ហៅថា ផស្សៈ ១ ។ សោតវិញ្ញាណ កើតឡើង ព្រោះអាស្រ័យត្រចៀកនិងសំឡេង ការជួបជុំនៃរបស់ទាំង ៣ ហៅថាផស្សៈ ១ ។ ឃានវិញ្ញាណ កើតឡើង ព្រោះអាស្រ័យច្រមុះនិងក្លិន ការជួបជុំនៃរបស់ទាំង ៣ ហៅថា ផស្សៈ ១ ។ ជិវ្ហាវិញ្ញាណ កើតឡើង ព្រោះអាស្រ័យអណ្ដាតនិងរស ការជួបជុំនៃរបស់ទាំង ៣ ហៅថាផស្សៈ ១ ។ កាយវិញ្ញាណ កើតឡើង ព្រោះអាស្រ័យកាយនិងផោដ្ឋព្វៈ ការជួបជុំនៃរបស់ទាំង ៣ ហៅថា ផស្សៈ ១ ។ មនោវិញ្ញាណ កើតឡើង ព្រោះអាស្រ័យចិត្តនិងធម្មារម្មណ៍ ការជួបជុំនៃរបស់ទាំង ៣ ហៅថា ផស្សៈ ១ ។ ពាក្យណា ដែលតថាគត ពោលហើយថា ផស្សកាយ ៦ ក៏គួរដឹង ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យសេចក្ដីនេះផង ។ នេះឆក្កៈ ទី ៤ ។

សឡាយតនវគ្គស្ស ឆឆក្កសុត្តេ ឆ វេទនាកាយា

[២៩១] ឆ វេទនាកាយា វេទិតព្វាតិ ឥតិ ខោ បនេតំ វុត្តំ ។ កិញ្ចេតំ បដិច្ច វុត្តំ ។ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សប្បច្ចយា វេទនា ។ សោតញ្ច បដិច្ច សទ្ទេ ច ឧប្បជ្ជតិ សោតវិញ្ញាណំ... ឃានញ្ច បដិច្ច គន្ធេ ច ឧប្បជ្ជតិ ឃានវិញ្ញាណំ.... ជិវ្ហញ្ច បដិច្ច រសេ ច ឧប្បជ្ជតិ ជិវ្ហាវិញ្ញាណំ... កាយញ្ច បដិច្ច ផោដ្ឋព្វេ ច ឧប្បជ្ជតិ កាយវិញ្ញាណំ... មនញ្ច បដិច្ច ធម្មេ ច ឧប្បជ្ជតិ មនោវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សប្បច្ចយា វេទនា ។ ឆ វេទនាកាយា វេទិតព្វាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ ឥទំ បញ្ចមំ ឆក្កំ ។

សឡាយតនវគ្គ ឆឆក្កសូត្រ វេទនាកាយប្រាំមួយ

[២៩១] ពាក្យថា វេទនាកាយ ៦ ក៏គួរដឹង ដូច្នេះនុ៎ះ តថាគតបានពោលហើយ ។ ចុះពាក្យដែលតថាគតពោលហើយនុ៎ះ តើព្រោះអាស្រ័យសេចក្ដីដូចម្ដេច ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យភ្នែកនិងរូប ការជួបជុំនៃរបស់ទាំង ៣ ហៅថា ផស្សៈ ព្រោះផស្សៈជាបច្ច័យ ទើបមានវេទនា ១ ។ សោតវិញ្ញាណកើតឡើង ព្រោះអាស្រ័យត្រចៀកនិងសំឡេង... ឃានវិញ្ញាណកើតឡើង ព្រោះអាស្រ័យច្រមុះនិងក្លិន... ជិវ្ហាវិញ្ញាណ កើតឡើង ព្រោះអាស្រ័យអណ្ដាតនិងរស... កាយវិញ្ញាណ កើតឡើង ព្រោះអាស្រ័យកាយនិងផោដ្ឋព្វៈ... មនោ-វិញ្ញាណ កើតឡើង ព្រោះអាស្រ័យចិត្តនិងធម្មារម្មណ៍ ការជួបជុំនៃរបស់ទាំង ៣ ហៅថា ផស្សៈ ព្រោះផស្សៈជាបច្ច័យ ទើបមានវេទនា ១ ។ ពាក្យណា ដែលតថាគតពោលហើយថា វេទនា-កាយ ៦ ក៏គួរដឹង ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យសេចក្ដីនេះឯង ។ នេះ ឆក្កៈ ទី ៥ ។

[២៩២] ឆ តណ្ហាកាយា វេទិតព្វាតិ ឥតិ ខោ បនេតំ វុត្តំ ។ កិញ្ចេតំ បដិច្ច វុត្តំ ។ ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា ។ សោតញ្ច បដិច្ច សទ្ទេ ច ឧប្បជ្ជតិ សោតវិញ្ញាណំ... ឃានញ្ច បដិច្ច គន្ធេ ច ឧប្បជ្ជតិ ឃានវិញ្ញាណំ... ជិវ្ហញ្ច បដិច្ច រសេ ច ឧប្បជ្ជតិ ជិវ្ហាវិញ្ញាណំ... កាយញ្ច បដិច្ច ផោដ្ឋព្វេ ច ឧប្បជ្ជតិ កាយវិញ្ញាណំ... មនញ្ច បដិច្ច ធម្មេ ច ឧប្បជ្ជតិ មនោវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សប្បច្ចយា វេទនា វេទនាបច្ចយា តណ្ហា ។ ឆ តណ្ហាកាយា វេទិតព្វាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ ឥទំ ឆដ្ឋំ ឆក្កំ ។

[២៩២] ពាក្យថា តណ្ហាកាយ ៦ ក៏គួរដឹង ដូច្នេះនុ៎ះ តថាគតបានពោលហើយ ។ ចុះពាក្យដែលតថាគត ពោលហើយនុ៎ះ តើព្រោះអាស្រ័យសេចក្តីដូចម្តេច ។ ចក្ខុវិញ្ញាណ កើតឡើង ព្រោះអាស្រ័យភ្នែកនិងរូប ការជួបជុំនៃរបស់ទាំង ៣ ហៅថាផស្សៈ ព្រោះផស្សៈជាបច្ច័យ ទើបមានវេទនា ព្រោះវេទនាជាបច្ច័យ ទើបមានតណ្ហា ១ ។ សោតវិញ្ញាណកើតឡើង ព្រោះអាស្រ័យត្រចៀកនិងសំឡេង... ឃានវិញ្ញាណកើតឡើង ព្រោះអាស្រ័យច្រមុះនិងក្លិន... ជិវ្ហាវិញ្ញាណ កើតឡើង ព្រោះអាស្រ័យអណ្តាតនិងរស... កាយវិញ្ញាណ កើតឡើង ព្រោះអាស្រ័យកាយនិងផោដ្ឋព្វៈ... មនោវិញ្ញាណ កើតឡើង ព្រោះអាស្រ័យចិត្តនិងធម្មារម្មណ៍ ការជួបជុំនៃរបស់ទាំង ៣ ហៅថាផស្សៈ ព្រោះផស្សៈជាបច្ច័យ ទើបមានវេទនា ព្រោះវេទនាជាបច្ច័យ ទើបមានតណ្ហា ១ ។ ពាក្យណា ដែលតថាគតពោលហើយថា តណ្ហាកាយ ៦ ក៏គួរដឹង ដូច្នេះ ពាក្យនុ៎ះ តថាគត ពោលហើយ ព្រោះអាស្រ័យសេចក្តីនេះឯង ។ នេះ ឆក្កៈទី ៦ ។

សឡាយតនវគ្គស្ស ឆឆក្កសុត្តេ អនត្តតា

[២៩៣] ចក្ខុ អត្តាតិ យោ ឞវំ[១] វទេយ្យ តំ ន ឧបបជ្ជតិ ។ ចក្ខុស្ស ឧប្បាទោបិ វយោបិ បញ្ញាយតិ ។ យស្ស ខោ បន ឧប្បាទោបិ វយោបិ បញ្ញាយតិ អត្តា មេ ឧប្បជ្ជតិ ច វេតិ ចាតិ ឥច្ចស្ស ឞវមាគតំ ហោតិ តស្មា តំ ន ឧបបជ្ជតិ ចក្ខុ អត្តាតិ យោ វទេយ្យ ។ ឥតិ ចក្ខុ អនត្តា ។ រូបា អត្តាតិ យោ វទេយ្យ តំ ន ឧបបជ្ជតិ ។ រូបានំ ឧប្បាទោបិ វយោបិ បញ្ញាយតិ ។ យស្ស ខោ បន ឧប្បាទោបិ វយោបិ បញ្ញាយតិ អត្តា មេ ឧប្បជ្ជតិ ច វេតិ ចាតិ ឥច្ចស្ស ឞវមាគតំ ហោតិ តស្មា តំ ន ឧបបជ្ជតិ រូបា អត្តាតិ យោ វទេយ្យ ។ ឥតិ ចក្ខុ អនត្តា រូបា អនត្តា ។

១ ឱ. ម. ឯវន្តិ ន ទិស្សតិ ។

[២៩៣] បុគ្គលណា និយាយយ៉ាងនេះថា ភ្នែកជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ (ព្រោះថា) ភ្នែកគេតែងដឹងច្បាស់ថា មានការកើតឡើងផង ការវិនាសទៅវិញផង ។ លុះតែបុគ្គលណា ដឹងច្បាស់នូវការកើតឡើង និងការវិនាសទៅវិញថា ខ្លួនរបស់អញ កើតឡើងផង វិនាសទៅវិញផង បុគ្គលនោះឯង ទើបឈ្មោះថាយល់ឃើញត្រូវ ហេតុនោះបានជាថា បុគ្គលណា និយាយថា ភ្នែកជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ ព្រោះហេតុនោះ ភ្នែកមិនមែនជាខ្លួនឡើយ ។ បុគ្គលណា និយាយថា រូបជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ (ព្រោះថា) រូបគេតែងដឹងច្បាស់ថា មានការកើតឡើងផង ការវិនាសទៅវិញផង ។ លុះតែបុគ្គលណា ដឹងច្បាស់នូវការកើតឡើង និងការវិនាសទៅវិញថា ខ្លួនរបស់អញ កើតឡើងផង វិនាសទៅវិញផង បុគ្គលនោះឯង ទើបឈ្មោះថា យល់ឃើញត្រូវ ហេតុនោះបានជាថា បុគ្គលណា និយាយថា រូបជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ ព្រោះហេតុនោះ ភ្នែកមិនមែនជាខ្លួន រូបក៏មិនមែនជាខ្លួនឡើយ ។

ចក្ខុវិញ្ញាណំ អត្តាតិ យោ វទេយ្យ តំ ន ឧបបជ្ជតិ ។ ចក្ខុវិញ្ញាណស្ស ឧប្បាទោបិ វយោបិ បញ្ញាយតិ ។ យស្ស ខោ បន ឧប្បាទោបិ វយោបិ បញ្ញាយតិ អត្តា មេ ឧប្បជ្ជតិ ច វេតិ ចាតិ ឥច្ចស្ស ឯវមាគតំ ហោតិ តស្មា តំ ន ឧបបជ្ជតិ ចក្ខុវិញ្ញាណំ អត្តាតិ យោ វទេយ្យ ។ ឥតិ ចក្ខុ អនត្តា រូបា អនត្តា ចក្ខុវិញ្ញាណំ អនត្តា ។ ចក្ខុសម្ផស្សោ អត្តាតិ យោ វទេយ្យ តំ ន ឧបបជ្ជតិ ។ ចក្ខុសម្ផស្សស្ស ឧប្បាទោបិ វយោបិ បញ្ញាយតិ ។ យស្ស ខោ បន ឧប្បាទោបិ វយោបិ បញ្ញាយតិ អត្តា មេ ឧប្បជ្ជតិ ច វេតិ ចាតិ ឥច្ចស្ស ឯវមាគតំ ហោតិ តស្មា តំ ន ឧបបជ្ជតិ ចក្ខុសម្ផស្សោ អត្តាតិ យោ វទេយ្យ ។

បុគ្គលណានិយាយថា ចក្ខុវិញ្ញាណជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ (ព្រោះថា) ចក្ខុវិញ្ញាណគេតែងដឹងច្បាស់ថា មានការកើតឡើងផង ការវិនាសទៅវិញផង ។ លុះតែបុគ្គលណាដឹងច្បាស់នូវការកើតឡើងនិងការវិនាសទៅវិញថា ខ្លួនរបស់អញកើតឡើងផង វិនាសទៅវិញផង បុគ្គលនោះឯងទើបឈ្មោះថាយល់ឃើញត្រូវ ហេតុនោះបានជាថាបុគ្គលណានិយាយថា ចក្ខុវិញ្ញាណជាខ្លួន ពាក្យរបស់បុគ្គលនោះមិនកើតការទេ ។ ព្រោះហេតុនោះ ភ្នែកមិនមែនជាខ្លួន រូបមិនមែនជាខ្លួន ចក្ខុវិញ្ញាណក៏មិនមែនជាខ្លួនឡើយ ។ បុគ្គលណានិយាយថា ចក្ខុ-សម្ផស្សជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ (ព្រោះថា) ចក្ខុសម្ផស្ស គេតែងដឹងច្បាស់ថាមានការកើតឡើងផង ការវិនាសទៅវិញផង ។ លុះតែបុគ្គលណា ដឹងច្បាស់នូវការកើតឡើង និងការវិនាសទៅវិញថា ខ្លួនរបស់អញកើតឡើងផង វិនាសទៅវិញផង បុគ្គលនោះឯង ទើបឈ្មោះថាយល់ឃើញត្រូវ ហេតុនោះបានជាថា បុគ្គលណានិយាយថា ចក្ខុសម្ផស្សជាខ្លួន ពាក្យរបស់បុគ្គលនោះមិនកើតការទេ ។

៣១៩

សឡាយតនវគ្គស្ស ឆឆក្កសុត្តេ អនត្តតា

ឥតិ ចក្ខុ អនត្តា រូបា អនត្តា ចក្ខុវិញ្ញាណំ អនត្តា ចក្ខុសម្ផស្សោ អនត្តា ។ វេទនា អត្តាតិ យោ វទេយ្យ តំ ន ឧបបជ្ជតិ ។ វេទនាយ ឧប្បាទោបិ វយោបិ បញ្ញាយតិ ។ យស្ស ខោ បន ឧប្បាទោបិ វយោបិ បញ្ញាយតិ អត្តា មេ ឧប្បជ្ជតិ ច វេតិ ចាតិ ឥច្ចស្ស ឯវមាគតំ ហោតិ តស្មា តំ ន ឧបបជ្ជតិ វេទនា អត្តាតិ យោ វទេយ្យ ។ ឥតិ ចក្ខុ អនត្តា រូបា អនត្តា ចក្ខុវិញ្ញាណំ អនត្តា ចក្ខុសម្ផស្សោ អនត្តា វេទនា អនត្តា ។ តណ្ហា អត្តាតិ យោ វទេយ្យ តំ ន ឧបបជ្ជតិ ។ តណ្ហាយ ឧប្បាទោបិ វយោបិ បញ្ញាយតិ ។ យស្ស ខោ បន ឧប្បាទោបិ វយោបិ បញ្ញាយតិ អត្តា មេ

ព្រោះហេតុនោះ ភ្នែកមិនមែនជាខ្លួន រូបមិនមែនជាខ្លួន ចក្ខុវិញ្ញាណមិនមែនជាខ្លួន ចក្ខុសម្ផស្សក៏មិនមែនជាខ្លួនឡើយ ។ បុគ្គលណា និយាយថា វេទនាជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ (ព្រោះថា) វេទនា គេតែងដឹងច្បាស់ថា មានការកើតឡើងផង ការវិនាសទៅវិញផង ។ លុះតែបុគ្គលណា ដឹងច្បាស់នូវការកើតឡើងនិងការវិនាសទៅវិញថា ខ្លួនរបស់អញកើតឡើងផង វិនាសទៅវិញផង បុគ្គលនោះឯង ទើបឈ្មោះថាយល់ឃើញត្រូវ ហេតុនោះបានជាថា បុគ្គលណានិយាយថា វេទនាជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ ព្រោះហេតុនោះ ភ្នែកមិនមែនជាខ្លួន រូបមិនមែនជាខ្លួន ចក្ខុវិញ្ញាណមិនមែនជាខ្លួន ចក្ខុសម្ផស្សមិនមែនជាខ្លួន វេទនាក៏មិនមែនជាខ្លួនឡើយ ។ បុគ្គលណា និយាយថា តណ្ហាជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ (ព្រោះថា) តណ្ហា គេតែងដឹងច្បាស់ថា មានការកើតឡើងផង ការវិនាសទៅវិញផង ។ លុះតែបុគ្គលណា ដឹងច្បាស់នូវការកើតឡើងនិងការវិនាសទៅវិញថា ខ្លួនរបស់អញ

ឧប្បជ្ជតិ ច វេតិ ចាតិ ឥច្ចស្ស ឯវមាគតំ ហោតិ តស្មា តំ ន ឧបបជ្ជតិ តណ្ហា អត្តាតិ យោ វទេយ្យ ។ ឥតិ ចក្ខុ អនត្តា រូបា អនត្តា ចក្ខុវិញ្ញាណំ អនត្តា ចក្ខុសម្ផស្សោ អនត្តា វេទនា អនត្តា តណ្ហា អនត្តា ។

[២៩៤] សោតំ អត្តាតិ យោ វទេយ្យ... ឃានំ អត្តាតិ យោ វទេយ្យ... ជិវ្ហា អត្តាតិ យោ វទេយ្យ... កាយោ អត្តាតិ យោ វទេយ្យ... មនោ អត្តាតិ យោ វទេយ្យ តំ ន ឧបបជ្ជតិ ។ មនស្ស ឧប្បា-ទោបិ វយោបិ បញ្ញាយតិ ។ យស្ស ខោ បន ឧប្បាទោបិ វយោបិ បញ្ញាយតិ អត្តា មេ ឧប្បជ្ជតិ ច វេតិ ចាតិ ឥច្ចស្ស ឯវមាគតំ ហោតិ តស្មា តំ ន ឧបបជ្ជតិ មនោ អត្តាតិ យោ វទេយ្យ ។ ឥតិ មនោ អនត្តា ។ ធម្មា អត្តាតិ យោ វទេយ្យ

កើតឡើងផង វិនាសទៅវិញផង បុគ្គលនោះឯង ទើបឈ្មោះថាយល់ឃើញត្រូវ ហេតុនោះបានជាថា បុគ្គលណានិយាយថា តណ្ហាជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ ព្រោះហេតុនោះ ភ្នែកមិនមែនជាខ្លួន រូបមិនមែនជាខ្លួន ចក្ខុវិញ្ញាណមិនមែនជាខ្លួន ចក្ខុសម្ផស្សមិនមែនជាខ្លួន វេទនាមិនមែនជាខ្លួន តណ្ហាក៏មិនមែនជាខ្លួនឡើយ ។

[២៩២] បុគ្គលណានិយាយថា ត្រចៀកជាខ្លួន... បុគ្គលណានិយាយថា ច្រមុះជាខ្លួន... បុគ្គលណានិយាយថា អណ្តាតជាខ្លួន... បុគ្គលណានិយាយថា កាយជាខ្លួន... បុគ្គលណានិយាយថា ចិត្តជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ (ព្រោះថា) ចិត្តគេតែងដឹងច្បាស់ថា មានការកើតឡើងផង ការវិនាសទៅវិញផង ។ លុះតែបុគ្គលណា ដឹងច្បាស់នូវការកើតឡើងនិងការវិនាសទៅវិញថា ខ្លួនរបស់អញកើតឡើងផង វិនាសទៅវិញផង បុគ្គលនោះឯង ទើបឈ្មោះថាយល់ឃើញត្រូវ ហេតុនោះបានជាថា បុគ្គលណានិយាយថា ចិត្តជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ ព្រោះហេតុនោះ ចិត្តមិនមែនជាខ្លួនឡើយ ។ បុគ្គលណានិយាយថា ធម្មារម្មណ៍ជាខ្លួន

តំ ន ឧបបជ្ជតិ ។ ធម្មានំ[១] ឧប្បាទោបិ វយោបិ បញ្ញាយតិ ។ យស្ស ខោ បន ឧប្បាទោបិ វយោបិ បញ្ញាយតិ អត្តា មេ ឧប្បជ្ជតិ ច វេតិ ចាតិ ឥច្ចស្ស ឯវមាគតំ ហោតិ តស្មា តំ ន ឧបបជ្ជតិ ធម្មា អត្តាតិ យោ វទេយ្យ ។ ឥតិ មនោ អនត្តា ធម្មា អនត្តា ។ មនោវិញ្ញាណំ អត្តាតិ យោ វទេយ្យ តំ ន ឧបបជ្ជតិ ។ មនោវិញ្ញាណស្ស ឧប្បាទោបិ វយោបិ បញ្ញាយតិ ។ យស្ស ខោ បន ឧប្បាទោបិ វយោបិ បញ្ញាយតិ អត្តា មេ ឧប្បជ្ជតិ ច វេតិ ចាតិ ឥច្ចស្ស ឯវមាគតំ ហោតិ តស្មា តំ ន ឧបបជ្ជតិ មនោវិញ្ញាណំ អត្តាតិ យោ វទេយ្យ ។ ឥតិ មនោ អនត្តា ធម្មា អនត្តា មនោវិញ្ញាណំ អនត្តា ។

---

១ ឱ. ធម្មស្ស ។

ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ (ព្រោះថា) ធម្មារម្មណ៍ គេតែងដឹងច្បាស់ថាមានការកើតឡើងផង ការវិនាសទៅវិញផង ។ លុះតែបុគ្គលណា ដឹងច្បាស់នូវការកើតឡើងនិងការវិនាសទៅវិញថា ខ្លួនរបស់អញ កើតឡើងផង វិនាសទៅវិញផង បុគ្គលនោះឯង ទើបឈ្មោះថា យល់ឃើញត្រូវ ហេតុនោះបានជាថា បុគ្គលណា និយាយថា ធម្មារម្មណ៍ជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ ព្រោះហេតុនោះ ចិត្តមិនមែនជាខ្លួន ធម្មារម្មណ៍ក៏មិនមែនជាខ្លួនឡើយ ។ បុគ្គលណា និយាយថា មនោវិញ្ញាណជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ (ព្រោះថា) មនោវិញ្ញាណ គេតែងដឹងច្បាស់ថាមានការកើតឡើងផង ការវិនាសទៅវិញផង ។ លុះតែបុគ្គលណា ដឹងច្បាស់នូវការកើតឡើងនិងការវិនាសទៅវិញថា ខ្លួនរបស់អញកើតឡើងផង វិនាសទៅវិញផង បុគ្គលនោះឯង ទើបឈ្មោះថា យល់ឃើញត្រូវ ហេតុនោះបានជាថា បុគ្គលណា និយាយថា មនោវិញ្ញាណជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ ព្រោះហេតុនោះ ចិត្តមិនមែនជាខ្លួន ធម្មារម្មណ៍មិនមែនជាខ្លួន មនោវិញ្ញាណក៏មិនមែនជាខ្លួនឡើយ ។

មនោសម្ផស្សោ អត្តាតិ យោ វទេយ្យ តំ ន ឧ-
បបជ្ជតិ ។ មនោសម្ផស្សស្ស ឧប្បាទោបិ វយោបិ
បញ្ញាយតិ ។ យស្ស ខោ បន ឧប្បាទោបិ វយោបិ
បញ្ញាយតិ អត្តា មេ ឧប្បជ្ជតិ ច វេតិ ចាតិ
ឥច្ចស្ស ឯវមាគតំ ហោតិ តស្មា តំ ន ឧបបជ្ជតិ
មនោសម្ផស្សោ អត្តាតិ យោ វទេយ្យ ។ ឥតិ
មនោ អនត្តា ធម្មា អនត្តា មនោវិញ្ញាណំ អនត្តា
មនោសម្ផស្សោ អនត្តា ។ វេទនា អត្តាតិ យោ
វទេយ្យ តំ ន ឧបបជ្ជតិ ។ វេទនាយ ឧប្បាទោបិ
វយោបិ បញ្ញាយតិ ។ យស្ស ខោ បន ឧប្បាទោបិ
វយោបិ បញ្ញាយតិ អត្តា មេ ឧប្បជ្ជតិ ច វេតិ
ចាតិ ឥច្ចស្ស ឯវមាគតំ ហោតិ តស្មា តំ ន
ឧបបជ្ជតិ វេទនា អត្តាតិ យោ វទេយ្យ ។ ឥតិ
មនោ អនត្តា ធម្មា អនត្តា មនោវិញ្ញាណំ អនត្តា

បុគ្គលណា និយាយថា មនោសម្ផស្សជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ (ព្រោះថា) មនោសម្ផស្ស គេតែងដឹងច្បាស់ថា មានការកើតឡើងផង ការវិនាសទៅវិញផង ។ លុះតែបុគ្គលណាដឹងច្បាស់នូវការកើតឡើងនិងការវិនាសទៅវិញថា ខ្លួនរបស់អញ កើតឡើងផង វិនាសទៅវិញផង បុគ្គលនោះឯង ទើបឈ្មោះថា យល់ឃើញត្រូវ ហេតុនោះបានជាថា បុគ្គលណា និយាយថា មនោសម្ផស្សជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ ព្រោះហេតុនោះ ចិត្តមិនមែនជាខ្លួន ធម្មារម្មណ៍មិនមែនជាខ្លួន មនោវិញ្ញាណមិនមែនជាខ្លួន មនោសម្ផស្សក៏មិនមែនជាខ្លួនឡើយ ។ បុគ្គលណា និយាយថា វេទនាជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ (ព្រោះថា) វេទនា គេតែងដឹងច្បាស់ថា មានការកើតឡើងផង ការវិនាសទៅវិញផង ។ លុះតែបុគ្គលណា ដឹងច្បាស់នូវការកើតឡើងនិងការវិនាសទៅវិញថា ខ្លួនរបស់អញ កើតឡើងផង វិនាសទៅវិញផង បុគ្គលនោះឯង ទើបឈ្មោះថាយល់ឃើញត្រូវ ហេតុនោះបានជាថា បុគ្គលណា និយាយថា វេទនាជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ ព្រោះហេតុនោះ ចិត្ត មិនមែនជាខ្លួន ធម្មារម្មណ៍មិនមែនជាខ្លួន មនោវិញ្ញាណមិនមែនជាខ្លួន

មនោសម្ផស្សោ អនត្តា វេទនា អនត្តា ។ តណ្ហា អត្តាតិ យោ វទេយ្យ តំ ន ឧបបជ្ជតិ ។ តណ្ហាយ ឧប្បាទោបិ វយោបិ បញ្ញាយតិ ។ យស្ស ខោ បន ឧប្បាទោបិ វយោបិ បញ្ញាយតិ អត្តា មេ ឧប្បជ្ជតិ ច វេតិ ចាតិ ឥច្ចស្ស ឯវមាគតំ ហោតិ តស្មា តំ ន ឧបបជ្ជតិ តណ្ហា អត្តាតិ យោ វទេយ្យ ។ ឥតិ មនោ អនត្តា ធម្មា អនត្តា មនោវិញ្ញាណំ អនត្តា មនោសម្ផស្សោ អនត្តា វេទនា អនត្តា តណ្ហា អនត្តា ។

[២៩៥] អយំ ខោ បន ភិក្ខវេ សក្កាយសមុទ-យគាមិនី បដិបទា ។ ចក្ខុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សតិ ។ រូបេ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សតិ ។ ចក្ខុវិញ្ញាណំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សតិ ។ ចក្ខុសម្ផស្សំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សតិ ។

មនោសម្ផស្ស មិនមែនជាខ្លួន វេទនាក៏មិនមែនជាខ្លួនឡើយ ។ បុគ្គលណានិយាយថា តណ្ហាជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ (ព្រោះថា) តណ្ហា គេតែងដឹងច្បាស់ថា មានការកើតឡើងផង ការវិនាសទៅវិញផង ។ លុះតែបុគ្គលណា ដឹងច្បាស់នូវការកើតឡើងនិងការវិនាសទៅវិញថា ខ្លួនរបស់អញ កើតឡើងផង វិនាសទៅវិញផង បុគ្គលនោះឯង ទើបឈ្មោះថា យល់ឃើញត្រូវ ហេតុនោះបានជាថា បុគ្គលណា និយាយថា តណ្ហាជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ ព្រោះហេតុនោះ ចិត្តមិនមែនជាខ្លួន ធម្មារម្មណ៍មិនមែនជាខ្លួន មនោវិញ្ញាណមិនមែនជាខ្លួន មនោសម្ផស្សមិនមែនជាខ្លួន វេទនាមិនមែនជាខ្លួន តណ្ហាក៏មិនមែនជាខ្លួនឡើយ ។

[២៩៥] ម្នាលភិក្ខុទាំងឡាយ នេះបដិបទា ជាដំណើរកើតនៃសក្កាយ ។ បុគ្គលពិចារណាឃើញចក្ខុថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ។ ពិចារណាឃើញរូបថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ។ ពិចារណាឃើញចក្ខុវិញ្ញាណថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ។ ពិចារណាឃើញចក្ខុសម្ផស្សថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ។

វេទនំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សតិ ។ តណ្ហំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សតិ ។ សោតំ ឯតំ មម... ឃានំ ឯតំ មម... ជិវ្ហំ ឯតំ មម... កាយំ ឯតំ មម... មនំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សតិ ។ ធម្មេ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សតិ ។ មនោវិញ្ញាណំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សតិ ។ តណ្ហំ ឯតំ មម ឯ-សោហមស្មិ ឯសោ មេ អត្តាតិ សមនុបស្សតិ ។

[២៩៦] អយំ ខោ បន ភិក្ខវេ សក្កាយនិរោ-ធគាមិនី បដិបទា ។ ចក្ខុំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សតិ ។ រូបេ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សតិ

ពិចារណាឃើញវេទនាថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ។ ពិចារណាឃើញតណ្ហាថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ។ ពិចារណាឃើញត្រចៀកថា នុ៎ះរបស់អញ... ពិចារណាឃើញច្រមុះថា នុ៎ះរបស់អញ... ពិចារណាឃើញអណ្តាតថា នុ៎ះរបស់អញ... ពិចារណាឃើញកាយថា នុ៎ះរបស់អញ... ពិចារណាឃើញចិត្តថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ។ ពិចារណាឃើញធម្មារម្មណ៍ថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ។ ពិចារណាឃើញមនោវិញ្ញាណថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ។ ពិចារណាឃើញតណ្ហាថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ។

[២៩៦] ម្នាលភិក្ខុទាំងឡាយ នេះបដិបទាជាដំណើររលត់ទៅនៃសក្កាយ ។ បុគ្គល ពិចារណាឃើញចក្ខុថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនអញ ។ ពិចារណាឃើញរូបថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនអញ ។

៣២៤



ចក្ខុវិញ្ញាណំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សតិ ។ ចក្ខុសម្ផស្សំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សតិ ។ វេទនំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សតិ ។ តណ្ហំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សតិ ។ សោតំ នេតំ មម... ឃានំ នេតំ មម... ជិវ្ហំ នេតំ មម... កាយំ នេតំ មម... មនំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សតិ ។ ធម្មេ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សតិ ។

ពិចារណាឃើញចក្ខុវិញ្ញាណថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនអញ ។ ពិចារណាឃើញចក្ខុសម្ផស្សថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនអញ ។ ពិចារណាឃើញវេទនាថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនអញ ។ ពិចារណាឃើញតណ្ហាថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនអញ ។ ពិចារណាឃើញត្រចៀកថា នុ៎ះមិនមែនរបស់អញ... ពិចារណាឃើញច្រមុះថា នុ៎ះមិនមែនរបស់អញ... ពិចារណាឃើញអណ្ដាតថា នុ៎ះមិនមែនរបស់អញ... ពិចារណាឃើញកាយថា នុ៎ះមិនមែនរបស់អញ... ពិចារណាឃើញចិត្តថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនអញ ។ ពិចារណាឃើញធម្មារម្មណ៍ថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនអញ ។

មនោវិញ្ញាណំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សតិ ។ មនោសម្ផស្សំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សតិ ។ វេទនំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សតិ ។ តណ្ហំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ សមនុបស្សតិ ។

[២៩៧] ចក្ខុញ្ច ភិក្ខវេ បដិច្ច រូបេ ច ឧប្ប-ជ្ជតិ ចក្ខុវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្ស-បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អ-ទុក្ខមសុខំ វា ។ សោ សុខាយ វេទនាយ ផុដ្ឋោ សមានោ អភិនន្ទតិ អភិវទតិ អជ្ឈោសាយ តិដ្ឋតិ តស្ស រាគានុសយោ អនុសេតិ ។ ទុក្ខាយ វេទនាយ

ពិចារណាឃើញមនោវិញ្ញាណថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនអញ ។ ពិចារណាឃើញមនោសម្ផស្សថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនអញ ។ ពិចារណាឃើញវេទនាថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនអញ ។ ពិចារណាឃើញតណ្ហាថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនអញ ។

[២៩៧] ម្នាលភិក្ខុទាំងឡាយ ចក្ខុវិញ្ញាណកើតឡើង ព្រោះអាស្រ័យភ្នែកនិងរូប ការជួបជុំនៃរបស់ទាំង ៣ ហៅថា ផស្សៈ វេទនា ជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើងព្រោះផស្សៈជាបច្ច័យ ។ បុគ្គលនោះ កាលបើសុខវេទនាពាល់ត្រូវ រមែងរីករាយ ក្អាកក្អាយ តាំងនៅក្នុងសេចក្តីពេញចិត្ត រាគានុស័យនៃបុគ្គលនោះ ក៏ដេកសម្ងំនៅ ។ កាលបើទុក្ខវេទនា

៣២៧



ផុដ្ឋោ សមានោ សោចតិ កិលមតិ បរិទេវតិ ឧរត្តាឡឹ កន្ទតិ សម្មោហំ អាបជ្ជតិ តស្ស បដិឃានុសយោ អនុសេតិ ។ អទុក្ខមសុខាយ វេទនាយ ផុដ្ឋោ សមានោ តស្សា វេទនាយ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្បជានាតិ តស្ស អវិជ្ជានុសយោ អនុសេតិ ។ សោ វត ភិក្ខវេ សុខាយ វេទនាយ រាគានុសយំ អប្បហាយ ទុក្ខាយ វេទនាយ បដិឃានុសយំ អប្បដិវិនោទេត្វា អទុក្ខមសុខាយ វេទនាយ អវិជ្ជានុសយំ អសមូហនិត្វា អវិជ្ជំ អប្បហាយ វិជ្ជំ អនុប្បាទេត្វា ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ភវិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ សោតញ្ច ភិក្ខវេ បដិច្ច សទ្ទេ ច ឧប្បជ្ជតិ សោតវិញ្ញាណំ… ឃានញ្ច ភិក្ខវេ បដិច្ច គន្ធេ ច ឧប្បជ្ជតិ ឃានវិញ្ញាណំ…

ពាល់ត្រូវ រមែងក្រៀមក្រំចិត្ត លំបាក ខ្សឹកខ្សួល គក់ទ្រូង ទ្រហោយំ ដល់នូវសេចក្តីវង្វេង បដិឃានុស័យនៃបុគ្គលនោះ ក៏ដេកសម្ងំនៅ ។ កាលបើអទុក្ខមសុខវេទនា ពាល់ត្រូវ រមែងមិនដឹងច្បាស់តាមពិត នូវការកើតឡើងផង នូវសេចក្តីវិនាសទៅផង នូវអានិសង្សផង នូវទោសផង នៃវេទនានោះ និងការរលាស់ចេញនូវវេទនានោះ អវិជ្ជានុស័យនៃបុគ្គលនោះ ក៏ដេកសម្ងំនៅ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលនោះឯង បើទុកជាមិនបាច់លះបង់នូវរាគានុស័យ ក្នុងសុខវេទ-នា មិនបាច់បន្ទោបង់នូវបដិឃានុស័យ ក្នុងទុក្ខវេទនា មិនបាច់គាស់រំលើងនូវអវិជ្ជានុស័យ ក្នុងអទុក្ខមសុខវេទនា មិនបាច់លះបង់នូវអវិជ្ជា មិនបាច់ញុំាងវិជ្ជាឲ្យកើតឡើងក៏ដោយ ក៏គង់ជាអ្នកធ្វើនូវទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្ននេះបាន ពាក្យដូច្នេះនុ៎ះ មិនសមហេតុឡើយ ។ ម្នាលភិក្ខុទាំងឡាយ សោតវិញ្ញាណកើតឡើង ព្រោះអាស្រ័យត្រចៀកនិងសំឡេង... ឃានវិញ្ញាណកើតឡើង ព្រោះអាស្រ័យច្រមុះនិងក្លិន...

ជិវ្ហញ្ច ភិក្ខវេ បដិច្ច រសេ ច ឧប្បជ្ជតិ ជិវ្ហាវិញ្ញាណំ... កាយញ្ច ភិក្ខវេ បដិច្ច ផោដ្ឋព្វេ ច ឧប្បជ្ជតិ កាយវិញ្ញាណំ... មនញ្ច ភិក្ខវេ បដិច្ច ធម្មេ ច ឧប្បជ្ជតិ មនោវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា ។ សោ សុខាយ វេទនាយ ផុដ្ឋោ សមានោ អភិនន្ទតិ អភិវទតិ អជ្ឈោសាយ តិដ្ឋតិ តស្ស រាគានុសយោ អនុសេតិ ។ ទុក្ខាយ វេទនាយ ផុដ្ឋោ សមានោ សោចតិ កិលមតិ បរិទេវតិ ឧរត្តាឡឹ កន្ទតិ សម្មោហំ អាបជ្ជតិ តស្ស បដិឃានុសយោ អនុសេតិ ។ អទុក្ខមសុខាយ វេទនាយ ផុដ្ឋោ សមានោ តស្សា វេទនាយ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ នប្ប-ជានាតិ តស្ស អវិជ្ជានុសយោ អនុសេតិ ។ សោ វត ភិក្ខវេ សុខាយ វេទនាយ រាគានុសយំ អប្បហាយ ទុក្ខាយ វេទនាយ បដិឃានុសយំ អប្បដិវិនោទេត្វា

ជិវ្ហាវិញ្ញាណកើតឡើង ព្រោះអាស្រ័យអណ្តាតនិងរស... កាយ-វិញ្ញាណកើតឡើង ព្រោះអាស្រ័យកាយនិងផោដ្ឋព្វៈ... មនោ-វិញ្ញាណកើតឡើង ព្រោះអាស្រ័យចិត្តនិងធម្មារម្មណ៍ ការជួបជុំនៃរបស់ទាំង ៣ ហៅថាផស្សៈ វេទនា ជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី រមែងកើតឡើង ព្រោះផស្សៈជាបច្ច័យ ។ បុគ្គលនោះកាលបើសុខវេទនាពាល់ត្រូវ រមែងរីករាយ ក្អាកក្អាយ តាំងនៅក្នុងសេចក្តីពេញចិត្ត រាគានុស័យនៃបុគ្គលនោះ ក៏ដេកសម្ងំនៅ ។ កាលទុក្ខវេទនាពាល់ត្រូវ រមែងក្រៀមក្រំចិត្ត លំបាក ខ្សឹកខ្សួល គក់ទ្រូងទ្រហោយំ ដល់នូវសេចក្តីវង្វេង បដិឃានុស័យនៃបុគ្គលនោះ ក៏ដេកសម្ងំនៅ ។ កាលអទុក្ខមសុខវេទនាពាល់ត្រូវ រមែងមិនដឹងច្បាស់តាមពិត នូវការកើតឡើងផង នូវសេចក្តីវិនាសទៅផង នូវអានិសង្សផង នូវទោសផង នៃវេទនានោះ និងការរលាស់ចេញនូវវេទនានោះ អវិជ្ជានុស័យនៃបុគ្គលនោះ ក៏ដេកសម្ងំនៅ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលនោះឯង បើទុកជាមិនបាច់លះបង់នូវរាគានុស័យក្នុងសុខវេទនា មិនបាច់បន្ទោបង់ នូវបដិឃានុស័យ ក្នុងទុក្ខវេទនា

អទុក្ខមសុខាយ វេទនាយ អវិជ្ជានុសយំ អសមូហនិត្វា អវិជ្ជំ អប្បហាយ វិជ្ជំ អនុប្បាទេត្វា ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ភវិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។

[២៩៨] ចក្ខុញ្ច ខោ ភិក្ខវេ បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា ។ សោ សុខាយ វេទនាយ ផុដ្ឋោ សមានោ នាភិនន្ទតិ នាភិវទតិ នាជ្ឈោសាយ តិដ្ឋតិ តស្ស រាគានុសយោ នានុសេតិ ។ ទុក្ខាយ វេទនាយ ផុដ្ឋោ សមានោ ន សោចតិ ន កិលមតិ ន បរិទេវតិ ន ឧរត្តាឡឹ កន្ទតិ ន សម្មោហំ អាបជ្ជតិ តស្ស បដិឃានុសយោ នានុសេតិ ។ អទុក្ខមសុខាយ វេទនាយ ផុដ្ឋោ សមានោ តស្សា វេទនាយ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានាតិ តស្ស អវិជ្ជានុសយោ នានុសេតិ ។

មិនបាច់គាស់រំលើងនូវអវិជ្ជានុស័យ ក្នុងអទុក្ខមសុខវេទនា មិនបាច់លះបង់នូវអវិជ្ជា មិនបាច់ញុំាងវិជ្ជាឲ្យកើតឡើងក៏ដោយ ក៏គង់ជាអ្នកធ្វើទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្ននេះបាន ពាក្យដូច្នេះនុ៎ះ មិនសមហេតុឡើយ ។

[២៩៨] ម្នាលភិក្ខុទាំងឡាយ ចក្ខុវិញ្ញាណកើតឡើង ព្រោះអាស្រ័យភ្នែកនិងរូប ការជួបជុំនៃរបស់ទាំង ៣ ហៅថាផស្សៈ វេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី រមែងកើតឡើងព្រោះផស្សៈជាបច្ច័យ ។ បុគ្គលនោះ កាលបើសុខវេទនាពាល់ត្រូវ រមែងមិនរីករាយ មិនភ្ញាកភ្ញាយ មិនតាំងនៅក្នុងសេចក្តីពេញចិត្តទេ រាគានុស័យនៃបុគ្គលនោះ ក៏មិនដេកសម្ងំនៅឡើយ ។ កាលទុក្ខវេទនាពាល់ត្រូវ រមែងមិនក្រៀមក្រំចិត្ត មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូងទ្រហោយំ មិនដល់នូវសេចក្តីវង្វេងទេ បដិឃានុស័យនៃបុគ្គលនោះ ក៏មិនដេកសម្ងំនៅឡើយ ។ កាលអទុក្ខមសុខវេទនាពាល់ត្រូវ រមែងដឹងច្បាស់តាមពិត នូវការកើតឡើងផង នូវសេចក្តីវិនាសទៅផង នូវអានិសង្សផង នូវទោសផង នៃវេទនានោះ និងការរលាស់ចេញនូវវេទនានោះ អវិជ្ជានុស័យនៃបុគ្គលនោះ ក៏មិនដេកសម្ងំនៅឡើយ ។

សោ ចេ ភិក្ខវេ សុខាយ វេទនាយ រាគានុសយំ បហាយ ទុក្ខាយ វេទនាយ បដិឃានុសយំ បដិវិនោទេត្វា អទុក្ខមសុខាយ វេទនាយ អវិជ្ជានុសយំ សមូហនិត្វា អវិជ្ជំ បហាយ វិជ្ជំ ឧប្បាទេត្វា ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ភវិស្សតីតិ ឋានមេតំ វិជ្ជតិ ។ សោតញ្ច ភិក្ខវេ បដិច្ច សទ្ទេ ច ឧប្បជ្ជតិ សោតវិញ្ញាណំ... ឃានញ្ច ភិក្ខវេ បដិច្ច គន្ធេ ច ឧប្បជ្ជតិ ឃានវិញ្ញាណំ... ជិវ្ហញ្ច ភិក្ខវេ បដិច្ច រសេ ច ឧប្បជ្ជតិ ជិវ្ហាវិញ្ញាណំ... កាយញ្ច ភិក្ខវេ បដិច្ច ផោដ្ឋព្វេ ច ឧប្បជ្ជតិ កាយវិញ្ញាណំ... មនញ្ច ភិក្ខវេ បដិច្ច ធម្មេ ច ឧប្បជ្ជតិ មនោវិញ្ញាណំ តិណ្ណំ សង្គតិ ផស្សោ ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា ។ សោ សុខាយ វេទនាយ ផុដ្ឋោ សមានោ នាភិនន្ទតិ នាភិវទតិ នាជ្ឈោសាយ តិដ្ឋតិ តស្ស រាគានុសយោ នានុសេតិ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលនោះឯង លះបង់នូវរាគានុស័យ ក្នុងសុខ-វេទនា បន្ទោបង់នូវបដិឃានុស័យ ក្នុងទុក្ខវេទនា គាស់រំលើងនូវអវិជ្ជា-នុស័យ ក្នុងអទុក្ខមសុខវេទនា លះបង់នូវអវិជ្ជា ញុំាងវិជ្ជាឲ្យកើតឡើង ហើយ និងជាអ្នកធ្វើទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្ននេះបាន ពាក្យដូច្នេះនុ៎ះ ទើបសមហេតុ ។ ម្នាលភិក្ខុទាំងឡាយ សោតវិញ្ញាណកើតឡើង ព្រោះអាស្រ័យត្រចៀកនិងសំឡេង... ម្នាលភិក្ខុទាំងឡាយ ឃានវិញ្ញាណ កើតឡើង ព្រោះអាស្រ័យច្រមុះនិងក្លិន... ម្នាលភិក្ខុទាំងឡាយ ជិវ្ហា-វិញ្ញាណកើតឡើង ព្រោះអាស្រ័យអណ្ដាតនិងរស... ម្នាលភិក្ខុទាំង-ឡាយ កាយវិញ្ញាណកើតឡើង ព្រោះអាស្រ័យកាយនិងផោដ្ឋព្វៈ... ម្នាលភិក្ខុទាំងឡាយ មនោវិញ្ញាណ កើតឡើង ព្រោះអាស្រ័យ ចិត្តនិងធម្មារម្មណ៍ ការជួបជុំនៃរបស់ទាំង ៣ ហៅថា ផស្សៈ វេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី រមែងកើត ឡើង ព្រោះផស្សៈជាបច្ច័យ ។ បុគ្គលនោះ កាលសុខវេទនា ពាល់ត្រូវ រមែងមិនរីករាយ មិនក្អាកក្អាយ មិនតាំងនៅក្នុងសេចក្តី ពេញចិត្តទេ រាគានុស័យនៃបុគ្គលនោះ ក៏មិនដេកសម្ងំនៅឡើយ ។

៣៣១

សឡាយតនវគ្គស្ស ឆឆក្កសុត្តេ ឋានភាវោ

ទុក្ខាយ វេទនាយ ផុដ្ឋោ សមានោ ន សោចតិ ន កិលមតិ ន បរិទេវតិ ន ឧរត្តាឡឹ កន្ទតិ ន សម្មោហំ អាបជ្ជតិ តស្ស បដិឃានុសយោ នានុសេតិ ។ អទុក្ខមសុខាយ វេទនាយ ផុដ្ឋោ សមានោ តស្សា វេទនាយ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានាតិ តស្ស អវិជ្ជានុសយោ នានុសេតិ ។ សោ វត ភិក្ខវេ សុខាយ វេទនាយ រាគានុសយំ បហាយ ទុក្ខាយ វេទនាយ បដិឃានុសយំ បដិវិនោទេត្វា អទុក្ខមសុខាយ វេទនាយ អវិជ្ជានុសយំ សមូហនិត្វា អវិជ្ជំ បហាយ វិជ្ជំ ឧប្បាទេត្វា ទិដ្ឋេវ ធម្មេ ទុក្ខស្សន្តករោ ភវិស្សតីតិ ឋានមេតំ វិជ្ជតីតិ ។

កាលទុក្ខវេទនាពាល់ត្រូវ រមែងមិនក្រៀមក្រំចិត្ត មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូងទ្រហោយំ មិនដល់នូវសេចក្តីវង្វេងទេ បដិឃានុស័យនៃបុគ្គលនោះ ក៏មិនដេកសម្ងំនៅឡើយ ។ កាលអទុក្ខមសុខវេទនាពាល់ត្រូវ តែងដឹងច្បាស់តាមពិត នូវការកើតឡើងផង នូវសេចក្តីវិនាសទៅផង នូវអានិសង្សផង នូវទោសផង នៃវេទនានោះ និងការរលាស់ចេញនូវវេទនានោះ អវិជ្ជានុស័យនៃបុគ្គលនោះ ក៏មិនដេកសម្ងំនៅឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលនោះឯង លះបង់នូវរាគានុស័យ ក្នុងសុខវេទនា បន្ទោបង់នូវបដិឃានុស័យ ក្នុងទុក្ខវេទនា គាស់រំលើងនូវអវិជ្ជានុស័យ ក្នុងអទុក្ខមសុខវេទនា លះបង់នូវអវិជ្ជា ញុំាងវិជ្ជាឲ្យកើតឡើងហើយ និងជាអ្នកធ្វើទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្ននេះបាន ពាក្យដូច្នេះនុ៎ះ ទើបសមហេតុ ។

[២៩៩] ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ ចក្ខុស្មឹបិ និព្វិន្ទតិ រូបេសុបិ និព្វិន្ទតិ ចក្ខុវិញ្ញាណេបិ និព្វិន្ទតិ ចក្ខុសម្ផស្សេបិ និព្វិន្ទតិ វេទនាយបិ និព្វិន្ទតិ តណ្ហាយបិ និព្វិន្ទតិ សោតស្មឹបិ និព្វិន្ទតិ សទ្ទេសុបិ និព្វិន្ទតិ... ឃានស្មឹបិ និព្វិន្ទតិ គន្ធេសុបិ និព្វិន្ទតិ... ជិវ្ហាយបិ និព្វិន្ទតិ រសេសុបិ និព្វិន្ទតិ... កាយស្មឹបិ និព្វិន្ទតិ ផោដ្ឋព្វេសុបិ និព្វិន្ទតិ... មនស្មឹបិ និព្វិន្ទតិ ធម្មេសុបិ និព្វិន្ទតិ មនោវិញ្ញាណេបិ និព្វិន្ទតិ មនោសម្ផស្សេបិ និព្វិន្ទតិ វេទនាយបិ និព្វិន្ទតិ តណ្ហាយបិ និព្វិន្ទតិ ។ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។

[២៩៩] ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កដែលមានសេចក្តីចេះដឹង កាលយល់ឃើញ យ៉ាងនេះ ក៏នឿយណាយក្នុងភ្នែកផង នឿយណាយក្នុងរូបផង នឿយណាយក្នុងចក្ខុវិញ្ញាណផង នឿយណាយក្នុងចក្ខុសម្ផស្សផង នឿយណាយក្នុងវេទនាផង នឿយណាយក្នុងតណ្ហាផង នឿយណាយក្នុងត្រចៀកផង នឿយណាយក្នុងសំឡេងផង... នឿយណាយក្នុងច្រមុះផង នឿយណាយក្នុងក្លិនផង... នឿយណាយក្នុងអណ្តាតផង នឿយណាយក្នុងរសផង... នឿយណាយក្នុងកាយផង នឿយណាយក្នុងផោដ្ឋព្វៈផង... នឿយណាយក្នុងចិត្តផង នឿយណាយក្នុងធម្មារម្មណ៍ផង នឿយណាយក្នុងមនោវិញ្ញាណផង នឿយណាយក្នុងមនោសម្ផស្សផង នឿយណាយក្នុងវេទនាផង នឿយណាយក្នុងតណ្ហាផង ។ កាលបើនឿយណាយហើយ ក៏ប្រាសចាកតម្រេក ចិត្តក៏ផុតស្រឡះ (ចាកអាសវៈ) ព្រោះការប្រាសចាកតម្រេក កាលចិត្តផុតស្រឡះហើយ ញាណក៏កើតឡើងថា ចិត្តផុតស្រឡះហើយ អរិយសាវ័កនោះរមែងដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ច អាត្មាអញបានធ្វើរួចហើយ កិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

៣៣៣

សឡាយតនវគ្គស្ស ឆឆក្កសុត្តេ ភាសិតាភិនន្ទនំ

ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។ ឥមស្មិញ្ច បន វេយ្យាករណស្មឹ ភញ្ញមានេ សដ្ឋីមត្តានំ ភិក្ខូនំ អនុបាទាយ អាសវេហិ ចិត្តានិ វិមុច្ចឹសូតិ ។

ឆឆក្កសុត្តំ ឆដ្ឋំ និដ្ឋិតំ ។

លុះព្រះមានព្រះភាគ សំដែងព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងនោះ ក៏មានសេចក្តីត្រេកអរ រីករាយនឹងភាសិតនៃព្រះមានព្រះភាគ ។ ក៏ កាលដែលព្រះមានព្រះភាគ សំដែងវេយ្យាករណ៍នេះចប់ហើយ ចិត្ត របស់ភិក្ខុទាំងឡាយប្រមាណ ៦០ រូប ក៏រួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនបានប្រកាន់មាំទៀតឡើយ ។

ចប់ ឆឆក្កសូត្រ ទី ៦ ។

# សត្តមំ សឡាយតនវិភង្គសុត្តំ

[៣០០] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អា-រាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខ-វោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច មហាសឡាយតនិកំ[១] វោ ភិក្ខវេ ទេសិស្សាមិ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវម្ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

[៣០១] ភគវា ឯតទវោច ចក្ខុំ ភិក្ខវេ អជានំ អបស្សំ យថាភូតំ រូបេ អជានំ អបស្សំ យថាភូតំ ចក្ខុវិញ្ញាណំ អជានំ អបស្សំ

១ ម. មហាសឡាយតនានិ ។

# សឡាយតនវិភង្គសូត្រ ទី ៧

[៣០០] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ព្រះមានព្រះភាគ បានត្រាស់ហៅភិក្ខុទាំងឡាយ ក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវធម្មបរិយាយ ជាគ្រឿងបំភ្លឺនូវអាយតនៈធំៗប្រាំមួយ ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់ពាក្យនោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[៣០១] ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បុគ្គល កាលមិនដឹង មិនឃើញនូវចក្ខុតាមពិត មិនដឹង មិនឃើញនូវរូបតាមពិត មិនដឹង មិនឃើញនូវចក្ខុវិញ្ញាណតាមពិត

យថាភូតំ ចក្ខុសម្ផស្សំ អជានំ អបស្សំ យថាភូតំ យមិទំ[១] ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អជានំ អបស្សំ យថាភូតំ ចក្ខុស្មឹ សារជ្ជតិ រូបេសុ សារជ្ជតិ ចក្ខុវិញ្ញាណេ សារជ្ជតិ ចក្ខុសម្ផស្សេ សារជ្ជតិ យ-មិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មឹបិ សារជ្ជតិ ។ តស្ស សារត្តស្ស សំយុត្តស្ស សម្មូឡ្ហស្ស អស្សា-ទានុបស្សិនោ វិហរតោ អាយតឹ បញ្ចុបាទានក្ខន្ធា ឧបចយំ គច្ឆន្តិ ។ តណ្ហា ចស្ស បោនោព្ភវិកា នន្ទិ-រាគសហគតា តត្រតត្រាភិនន្ទិនី សា ចស្ស បវឌ្ឍតិ ។

---

១ ឱ. ម. យម្បិទំ ។

មិនដឹង មិនឃើញនូវចក្ខុសម្ផស្សតាមពិតទេ វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនមែនជាទុក្ខមិនមែនជាសុខក្តី តែងកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ ក៏មិនដឹង មិនឃើញតាមពិត នូវវេទនានោះផង រមែងត្រេកអរក្នុងចក្ខុ ត្រេកអរក្នុងរូប ត្រេកអរក្នុងចក្ខុវិញ្ញាណ ត្រេកអរក្នុងចក្ខុសម្ផស្ស វេទនាណាជាសុខក្តី ជាទុក្ខក្តី មិនមែនជាទុក្ខមិនមែនជាសុខក្តី តែងកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ ក៏ត្រេកអរក្នុងវេទនានោះផង ។ កាលបុគ្គលនោះ មានចិត្តត្រេកអរជ្រុលជ្រប់វង្វេងផុលផប់ ជាអ្នកពិចារណាឃើញនូវសេចក្តីត្រេកអរ[១] ហើយ ឧបាទានក្ខន្ធទាំង ៥ ក៏ដល់នូវសេចក្តីចម្រើនតទៅ ។ ឯតណ្ហា ដែលតាក់តែងនូវភពថ្មី ប្រកបដោយតម្រេក ដោយអំណាចនៃសេចក្តីត្រេកត្រអាល មានកិរិយារីករាយ ក្នុងអារម្មណ៍នោះ ៗ ជាប្រក្រតីរបស់បុគ្គលនោះ តណ្ហានោះ របស់បុគ្គលនោះ រមែងចម្រើនឡើង ។

១ អានិសង្ស ។

តស្ស កាយិកាបិ ទរថា បវឌ្ឍន្តិ ចេតសិកាបិ ទរថា បវឌ្ឍន្តិ កាយិកាបិ សន្តាបា បវឌ្ឍន្តិ ចេតសិកាបិ សន្តាបា បវឌ្ឍន្តិ កាយិកាបិ បរិឡាហា បវឌ្ឍន្តិ ចេតសិកាបិ បរិឡាហា បវឌ្ឍន្តិ ។ សោ កាយិកទុក្ខម្បិ ចេតោទុក្ខម្បិ បដិសំវេទេតិ ។

[៣០២] សោតំ ភិក្ខវេ អជានំ អបស្សំ យថាភូតំ... ឃានំ ភិក្ខវេ អជានំ អបស្សំ យថាភូតំ... ជិវ្ហំ ភិក្ខវេ អជានំ អបស្សំ យថាភូតំ... កាយំ ភិក្ខវេ អជានំ អបស្សំ យថាភូតំ... មនំ ភិក្ខវេ អជានំ អបស្សំ យថាភូតំ ធម្មេ[១] អជានំ អបស្សំ យថាភូតំ

១ ឱ. ម. ធម្មេ ភិក្ខវេ ។

បុគ្គលនោះ រមែងមានសេចក្តីក្រវល់ក្រវាយប្រព្រឹត្តទៅក្នុងកាយ ចម្រើនឡើងផង មានសេចក្តីក្រវល់ក្រវាយប្រព្រឹត្តទៅក្នុងចិត្ត ចម្រើនឡើងផង មានសេចក្តីក្តៅក្រហាយប្រព្រឹត្តទៅក្នុងកាយ ចម្រើនឡើងផង មានសេចក្តីក្តៅក្រហាយប្រព្រឹត្តទៅក្នុងចិត្ត ចម្រើនឡើងផង មានសេចក្តីអន្ទះអន្ទែងប្រព្រឹត្តទៅក្នុងកាយ ចម្រើនឡើងផង មានសេចក្តីអន្ទះអន្ទែងប្រព្រឹត្តទៅក្នុងចិត្ត ក៏ចម្រើនឡើងផង ។ បុគ្គលនោះ រមែងរងទុក្ខប្រព្រឹត្តទៅក្នុងកាយផង រងទុក្ខប្រព្រឹត្តទៅក្នុងចិត្តផង ។

[៣០២] ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនដឹង មិនឃើញនូវត្រចៀកតាមពិត... ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនដឹង មិនឃើញនូវច្រមុះតាមពិត... ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនដឹង មិនឃើញនូវអណ្តាតតាមពិត... ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនដឹង មិនឃើញនូវកាយតាមពិត... ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនដឹង មិនឃើញនូវចិត្តតាមពិត មិនដឹង មិនឃើញនូវធម្មារម្មណ៍តាមពិត

៣៣៧



មនោវិញ្ញាណំ អជានំ អបស្សំ យថាភូតំ មនោសម្ផស្សំ អជានំ អបស្សំ យថាភូតំ យមិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ អជានំ អបស្សំ យថាភូតំ មនស្មឹ សារជ្ជតិ ធម្មេសុ សារជ្ជតិ មនោវិញ្ញាណេ សារជ្ជតិ មនោសម្ផស្សេ សារជ្ជតិ យមិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មឹបិ សារជ្ជតិ ។ តស្ស សារត្តស្ស សំយុត្តស្ស សម្មូឡ្ហស្ស អស្សាទានុបស្សិនោ វិហរតោ អាយតឹ បញ្ចុបាទានក្ខន្ធា ឧបចយំ គច្ឆន្តិ ។ តណ្ហា ចស្ស ពោនោព្ភវិកា នន្ទិរាគសហគតា តត្រតត្រាភិនន្ទិនី សា ចស្ស បវឌ្ឍតិ ។ តស្ស កាយិកាបិ ទរថា បវឌ្ឍន្តិ ចេតសិកាបិ ទរថា បវឌ្ឍន្តិ កាយិកាបិ សន្តាបា បវឌ្ឍន្តិ

មិនដឹង មិនឃើញនូវមនោវិញ្ញាណតាមពិត មិនដឹង មិនឃើញនូវមនោ-សម្ផស្សតាមពិត វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខ មិនមែនសុខក្តី តែងកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ ក៏មិនដឹង មិនឃើញតាមពិត នូវវេទនានោះផង តែងត្រេកអរក្នុងចិត្ត ត្រេកអរក្នុងធម្មារម្មណ៍ ត្រេកអរក្នុងមនោវិញ្ញាណ ត្រេកអរក្នុងមនោសម្ផស្ស វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី តែងកើតឡើង ព្រោះមនោ-សម្ផស្សជាបច្ច័យ ក៏ត្រេកអរក្នុងវេទនានោះផង ។ កាលបុគ្គលនោះ មានចិត្តត្រេកអរជ្រុលជ្រប់ វង្វេងផុលផប់ ជាអ្នកពិចារណាឃើញនូវសេចក្តីត្រេកអរហើយ ឧបាទានក្ខន្ធទាំង ៥ ក៏ដល់នូវសេចក្តីចម្រើនតទៅ ។ ឯតណ្ហា ដែលតាក់តែងភពថ្មី ប្រកបដោយតម្រេកដោយអំណាចនៃសេច-ក្តីត្រេកត្រអាល មានការរីករាយក្នុងអារម្មណ៍នោះ ៗ ជាប្រក្រតី របស់បុគ្គលនោះ តណ្ហានោះ របស់បុគ្គលនោះ រមែងចម្រើនឡើង ។ បុគ្គលនោះ រមែងមានសេចក្តីក្រវល់ក្រវាយ ប្រព្រឹត្តទៅក្នុងកាយ ចម្រើនឡើងផង មានសេចក្តីក្រវល់ក្រវាយ ប្រព្រឹត្តទៅក្នុងចិត្ត ចម្រើនឡើងផង មានសេចក្តីក្តៅក្រហាយ ប្រព្រឹត្តទៅក្នុងកាយ ចម្រើនឡើងផង

ចេតសិកាបិ សន្តាបា បវឌ្ឍន្តិ កាយិកាបិ បរិឡាហា បវឌ្ឍន្តិ ចេតសិកាបិ បរិឡាហា បវឌ្ឍន្តិ ។ សោ កាយិកទុក្ខម្បិ ចេតោទុក្ខម្បិ បដិសំវេទេតិ ។

[៣០៣] ចក្ខុញ្ច ខោ ភិក្ខវេ ជានំ បស្សំ យថាភូតំ រូបេ ជានំ បស្សំ យថាភូតំ ចក្ខុវិញ្ញាណំ ជានំ បស្សំ យថាភូតំ ចក្ខុសម្ផស្សំ ជានំ បស្សំ យថាភូតំ យមិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ ជានំ បស្សំ យថាភូតំ ចក្ខុស្មឹ ន សារជ្ជតិ រូបេសុ ន សារជ្ជតិ ចក្ខុវិញ្ញាណេ ន សារជ្ជតិ ចក្ខុសម្ផស្សេ ន សារជ្ជតិ យមិទំ ចក្ខុសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មឹបិ ន សារជ្ជតិ ។ តស្ស អសារត្តស្ស អសំយុត្តស្ស អសម្មូឡ្ហស្ស អាទីនវានុបស្សិនោ វិហរតោ អាយតឹ បញ្ចុបាទានក្ខន្ធា អបចយំ គច្ឆន្តិ ។

មានសេចក្ដីក្ដៅក្រហាយ ប្រព្រឹត្តទៅក្នុងចិត្ត ចម្រើនឡើងផង មានសេចក្ដីអន្ទះអន្ទែង ប្រព្រឹត្តទៅក្នុងកាយ ចម្រើនឡើងផង មានសេចក្ដីអន្ទះអន្ទែង ប្រព្រឹត្តទៅក្នុងចិត្ត ចម្រើនឡើងផង ។ បុគ្គលនោះរមែងរងទុក្ខប្រព្រឹត្តទៅក្នុងកាយផង រងទុក្ខប្រព្រឹត្តទៅក្នុងចិត្តផង ។

[៣០៣] ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលដឹង ឃើញនូវចក្ខុតាមពិត កាលដឹង ឃើញនូវរូបតាមពិត កាលដឹង ឃើញនូវចក្ខុ-វិញ្ញាណតាមពិត កាលដឹង ឃើញនូវចក្ខុសម្ផស្សតាមពិត វេទនាណាជាសុខក្ដី ជាទុក្ខក្ដី មិនមែនទុក្ខមិនមែនសុខក្ដី តែងកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ ក៏ដឹង ឃើញនូវវេទនានោះតាមពិតផង តែមិនត្រេកអរក្នុងចក្ខុ មិនត្រេកអរក្នុងរូប មិនត្រេកអរក្នុងចក្ខុវិញ្ញាណ មិនត្រេកអរក្នុងចក្ខុសម្ផស្សទេ វេទនាណាជាសុខក្ដី ជាទុក្ខក្ដី មិនមែនទុក្ខមិនមែនសុខក្ដី តែងកើតឡើង ព្រោះចក្ខុសម្ផស្សជាបច្ច័យ ក៏មិនត្រេកអរ ក្នុងវេទនានោះផង ។ កាលបុគ្គលនោះ មិនមានចិត្តត្រេកអរ មិនជ្រុលជ្រប់ មិនវង្វេងវង្វាន់ ជាអ្នកពិចារណាឃើញនូវទោសហើយ ឧបាទានក្ខន្ធទាំង ៥ ក៏ដល់នូវសេចក្ដីមិនចម្រើនតទៅ ។

តណ្ហា ចស្ស ចោនោព្ភវិកា នន្ទិរាគសហគតា តត្រតត្រាភិនន្ទិនី សា ចស្ស បហីយតិ ។ តស្ស កាយិកាបិ ទរថា បហីយន្តិ ចេតសិកាបិ ទរថា បហីយន្តិ កាយិកាបិ សន្តាបា បហីយន្តិ ចេ-តសិកាបិ សន្តាបា បហីយន្តិ កាយិកាបិ បរិឡាហា បហីយន្តិ ចេតសិកាបិ បរិឡាហា បហីយន្តិ ។ សោ កាយិកសុខម្បិ ចេតោសុខម្បិ បដិសំវេទេតិ ។ យា តថាភូតស្ស[១] ហោតិ ទិដ្ឋិ សាស្ស ហោតិ សម្មាទិដ្ឋិ

១ ឱ. យថាភូតស្ស ។

ឯតណ្ហា ដែលតាក់តែងភពថ្មី ប្រកបដោយតម្រេកដោយអំណាចនៃសេចក្ដីត្រេកត្រអាល មានសេចក្ដីរីករាយក្នុងអារម្មណ៍នោះ ៗ ជាប្រក្រតីរបស់បុគ្គលនោះ តណ្ហានោះ បុគ្គលនោះឯងលះបង់ចេញបាន ។ សេចក្ដីក្រវល់ក្រវាយ ប្រព្រឹត្តទៅក្នុងកាយ បុគ្គលនោះ រមែងលះបង់បានផង សេចក្ដីក្រវល់ក្រវាយ ប្រព្រឹត្តទៅក្នុងចិត្ត ក៏រមែងលះបង់បានផង សេចក្ដីក្ដៅក្រហាយ ប្រព្រឹត្តទៅក្នុងកាយ ក៏រមែងលះបង់បានផង សេចក្ដីក្ដៅក្រហាយ ប្រព្រឹត្តទៅក្នុងចិត្ត ក៏រមែងលះបង់បានផង សេចក្ដីអន្ទះអន្ទែង ប្រព្រឹត្តទៅក្នុងកាយ ក៏រមែងលះបង់បានផង សេចក្ដីអន្ទះអន្ទែង ប្រព្រឹត្តទៅក្នុងចិត្ត ក៏រមែងលះបង់បានផង ។ បុគ្គលនោះតែងរងនូវសេចក្ដីសុខ ប្រព្រឹត្តទៅក្នុងកាយ និងសេចក្ដីសុខប្រព្រឹត្តទៅក្នុងចិត្ត ។ សេចក្ដីយល់ឃើញណា របស់បុគ្គលមានសភាពដូច្នោះ[១] សេចក្ដីយល់ឃើញនោះ របស់បុគ្គលនោះ ឈ្មោះថាសេចក្ដីយល់ឃើញត្រូវ

---

១ បានដល់បុគ្គលដែលព្រមព្រៀងដោយសេចក្ដីសុខក្នុងចិត្ត ប្រកបដោយកុសល ។ អដ្ឋកថា ។

យោ តថាគតស្ស សង្កប្បោ ស្វាស្ស ហោតិ សម្មាសង្កប្បោ យោ តថាគតស្ស វាយាមោ ស្វាស្ស ហោតិ សម្មាវាយាមោ យា តថាគតស្ស សតិ ស្វាស្ស ហោតិ សម្មាសតិ យោ តថាគតស្ស សមាធិ ស្វាស្ស ហោតិ សម្មាសមាធិ ។ បុព្វេវ ខោ បនស្ស កាយ-កម្មំ អាជីវោ សុបរិសុទ្ធោ ហោតិ ។ ឯវមស្សាយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវនាបារិបូរឹ គច្ឆតិ ។

[៣០៤] តស្ស ឯវំ ឥមំ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវ-យតោ ចត្តារោបិ សតិប្បដ្ឋានា ភាវនាបារិបូរឹ គច្ឆន្តិ ចត្តារោបិ សម្មប្បធានា ភាវនាបារិបូរឹ គច្ឆន្តិ ចត្តារោបិ ឥទ្ធិបាទា ភាវនាបារិបូរឹ គច្ឆន្តិ បញ្ចបិ ឥន្ទ្រិយានិ ភា-វនាបារិបូរឹ គច្ឆន្តិ បញ្ចបិ ពលានិ ភាវនាបារិបូរឹ គច្ឆន្តិ

សេចក្តីត្រិះរិះណា របស់បុគ្គលមានសភាពដូច្នោះ សេចក្តីត្រិះរិះនោះ របស់បុគ្គលនោះ ឈ្មោះថាសេចក្តីត្រិះរិះត្រូវ សេចក្តីព្យាយាមណា របស់បុគ្គលមានសភាពដូច្នោះ សេចក្តីព្យាយាមនោះ របស់បុគ្គលនោះ ឈ្មោះថាសេចក្តីព្យាយាមត្រូវ ការរលឹកណា របស់បុគ្គលមានសភាពដូច្នោះ ការរលឹកនោះ របស់បុគ្គលនោះ ឈ្មោះថាការរលឹកត្រូវ ការតាំងចិត្តនឹងណា របស់បុគ្គលមានសភាពដូច្នោះ ការតាំងចិត្តនឹងនោះ របស់បុគ្គលនោះ ឈ្មោះថាការតាំងចិត្តនឹងត្រូវ ។ បុគ្គលនោះឯង ឈ្មោះថាមានកាយកម្ម វចីកម្ម និងអាជីវៈដ៏បរិសុទ្ធល្អ ក្នុងកាលមុនពិត ។ អដ្ឋង្គិកមគ្គដ៏ប្រសើរនេះ របស់បុគ្គលនោះ រមែងដល់នូវការពេញបរិបូណ៌ ដោយភាវនាយ៉ាងនេះឯង ។

[៣០៤] កាលបុគ្គលនោះ ចម្រើននូវអដ្ឋង្គិកមគ្គដ៏ប្រសើរនេះ យ៉ាងនេះហើយ សតិប្បដ្ឋាន ៤ ក្តី តែងដល់នូវការបរិបូណ៌ដោយភាវនា សម្មប្បធាន ៤ ក្តី តែងដល់នូវការបរិបូណ៌ដោយភាវនា ឥទ្ធិបាទ ៤ ក្តី ក៏ដល់នូវការបរិបូណ៌ដោយភាវនា ឥន្ទ្រិយ ៥ ក្តី ក៏ដល់នូវការបរិបូណ៌ដោយភាវនា ពលៈ ៥ ក្តី ក៏ដល់នូវការបរិបូណ៌ដោយភាវនា

សត្តបិ ពោជ្ឈង្គា ភាវនាបារិបូរឹ គច្ឆន្តិ ។ តស្សិមេ ទ្វេ ធម្មា យុគនទ្ធា[១] វត្តន្តិ សមថោ ច វិបស្សនា ច ។ សោ យេ ធម្មា អភិញ្ញា បរិញ្ញេយ្យា តេ ធម្មេ អភិញ្ញា បរិជានាតិ យេ ធម្មា អភិញ្ញា បហាតព្វា តេ ធម្មេ អភិញ្ញា បជហាតិ យេ ធម្មា អភិញ្ញា ភាវេតព្វា តេ ធម្មេ អភិញ្ញា ភាវេតិ យេ ធម្មា អភិញ្ញា សច្ឆិកា-តព្វា តេ ធម្មេ អភិញ្ញា សច្ឆិករោតិ ។ កតមេ ច ភិក្ខវេ ធម្មា អភិញ្ញា បរិញ្ញេយ្យា បញ្ចុបាទានក្ខន្ធា-តិស្ស វចនីយំ សេយ្យថីទំ រូបុបាទានក្ខន្ធោ វេទនុបា-ទានក្ខន្ធោ សញ្ញុបាទានក្ខន្ធោ សង្ខារុបាទានក្ខន្ធោ វិញ្ញាណុបាទានក្ខន្ធោ ឥមេ ធម្មា អភិញ្ញា បរិញ្ញេយ្យា ។ កតមេ ច ភិក្ខវេ ធម្មា អភិញ្ញា បហាតព្វា អវិជ្ជា ច ភវតណ្ហា ច ឥមេ ធម្មា អភិញ្ញា បហាតព្វា ។

---

១ ឱ. ម. យុគនន្ធា ។

ពោជ្ឈង្គ ៧ ក៏ដល់នូវការបរិបូណ៌ដោយភាវនា ។ ធម៌ ២ យ៉ាងនេះ គឺសមថៈ ១ វិបស្សនា ១ ជាធម៌ទាក់ទងគ្នានឹងគ្នា តែងប្រព្រឹត្តទៅដល់បុគ្គលនោះ ។ ធម៌ទាំងឡាយណា ដែលគប្បីកំណត់ដឹងដោយប្រាជ្ញាដ៏ឧត្តម បុគ្គលនោះ ក៏កំណត់ដឹងនូវធម៌ទាំងនោះ ដោយប្រាជ្ញាដ៏ឧត្តម ធម៌ទាំងឡាយណា ដែលគប្បីលះបង់ដោយប្រាជ្ញាដ៏ឧត្តម ក៏លះបង់នូវធម៌ទាំងនោះដោយប្រាជ្ញាដ៏ឧត្តម ធម៌ទាំងឡាយណា ដែលគប្បីចម្រើនដោយប្រាជ្ញាដ៏ឧត្តម ក៏ចម្រើននូវធម៌ទាំងនោះដោយប្រាជ្ញាដ៏ឧត្តម ធម៌ទាំងឡាយណា ដែលគប្បីធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តម ក៏ធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះដោយប្រាជ្ញាដ៏ឧត្តម ។ ម្នាលភិក្ខុទាំងឡាយ ចុះធម៌ទាំងឡាយ ដែលគប្បីកំណត់ដឹងដោយប្រាជ្ញាដ៏ឧត្តម តើដូចម្តេច ត្រូវឆ្លើយថា បានដល់ឧបាទានក្ខន្ធ (គំនរ ជាគ្រឿងប្រកាន់មាំ) ទាំង ៥ គឺរូបូបាទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ សង្ខារូបាទានក្ខន្ធ ១ វិញ្ញាណូបាទានក្ខន្ធ ១ នេះឯងដែលជាធម៌គប្បីកំណត់ដឹងដោយប្រាជ្ញាដ៏ឧត្តម ។ ម្នាលភិក្ខុទាំងឡាយ ចុះធម៌ទាំងឡាយ ដែលគប្បីលះបង់ដោយប្រាជ្ញាដ៏ឧត្តម តើដូចម្តេច អវិជ្ជានិងភវតណ្ហានេះឯង ជាធម៌ត្រូវលះបង់ដោយប្រាជ្ញាដ៏ឧត្តម ។

កតមេ ច ភិក្ខវេ ធម្មា អភិញ្ញា ភាវេតព្វា ស-
មថោ ច វិបស្សនា ច ឥមេ ធម្មា អភិញ្ញា ភាវេតព្វា ។
កតមេ ច ភិក្ខវេ ធម្មា អភិញ្ញា សច្ឆិកាតព្វា វិជ្ជា
ច វិមុត្តិ ច ឥមេ ធម្មា អភិញ្ញា សច្ឆិកាតព្វា ។

[៣០៥] សោតំ ភិក្ខវេ ជានំ បស្សំ យថាភូតំ...
ឃានំ ភិក្ខវេ ជានំ បស្សំ យថាភូតំ... ជិវ្ហំ ភិក្ខវេ
ជានំ បស្សំ យថាភូតំ... កាយំ ភិក្ខវេ ជានំ បស្សំ
យថាភូតំ... មនំ ភិក្ខវេ ជានំ បស្សំ យថាភូតំ
ធម្មេ ជានំ បស្សំ យថាភូតំ មនោវិញ្ញាណំ ជានំ
បស្សំ យថាភូតំ មនោសម្ផស្សំ ជានំ បស្សំ យថាភូតំ
យមិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ
វា ទុក្ខំ វា អទុក្ខមសុខំ វា តម្បិ ជានំ បស្សំ
យថាភូតំ មនស្មឹ ន សារជ្ជតិ ធម្មេសុ ន សារជ្ជតិ
មនោវិញ្ញាណេ ន សារជ្ជតិ មនោសម្ផស្សេ ន សារជ្ជតិ

ម្នាលភិក្ខុទាំងឡាយ ចុះធម៌ទាំងឡាយ ដែលគប្បីចម្រើនដោយប្រាជ្ញាដ៏ឧត្តម តើដូចម្តេច សមថៈនិងវិបស្សនានេះឯង ជាធម៌ត្រូវចម្រើនដោយប្រាជ្ញាដ៏ឧត្តម ។ ម្នាលភិក្ខុទាំងឡាយ ចុះធម៌ទាំងឡាយ ដែលគប្បីធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តម តើដូចម្តេច វិជ្ជានិងវិមុត្តិនេះឯង ជាធម៌ត្រូវធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តម ។

[៣០៥] ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលដឹង ឃើញនូវត្រចៀកតាមពិត... ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលដឹង ឃើញនូវច្រមុះតាមពិត... ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលដឹង ឃើញនូវអណ្តាតតាមពិត... ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលដឹង ឃើញនូវកាយតាមពិត... ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលដឹង ឃើញនូវចិត្តតាមពិត កាលដឹង ឃើញនូវធម្មារម្មណ៍តាមពិត កាលដឹង ឃើញនូវមនោ-វិញ្ញាណតាមពិត កាលដឹង ឃើញនូវមនោសម្ផស្សតាមពិត វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនមែនជាទុក្ខមិនមែនជាសុខក្តី រមែងកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ ក៏ដឹង ឃើញនូវវេទនានោះតាមពិតផង តែមិនត្រេកអរ ក្នុងចិត្ត មិនត្រេកអរ ក្នុងធម្មារម្មណ៍ មិនត្រេកអរ ក្នុងមនោវិញ្ញាណ មិនត្រេកអរ ក្នុងមនោសម្ផស្សទេ

យមិទំ មនោសម្ផស្សប្បច្ចយា ឧប្បជ្ជតិ វេទយិតំ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា តស្មឹបិ ន សារជ្ជតិ ។ តស្ស អសារត្តស្ស អសំយុត្តស្ស អសម្មូឡ្ហស្ស អាទីនវានុបស្សិនោ វិហរតោ អាយតឹ បញ្ចុបាទានក្ខន្ធា អបចយំ គច្ឆន្តិ ។ តណ្ហា ចស្ស បោនោព្ភវិកា នន្ទិរាគសហគតា តត្រតត្រាភិនន្ទិនី សា ចស្ស បហីយតិ ។ តស្ស កាយិកាបិ ទរថា បហីយន្តិ ចេតសិកាបិ ទរថា បហីយន្តិ កាយិកាបិ សន្តាបា បហីយន្តិ ចេតសិកាបិ សន្តាបា បហីយន្តិ កាយិកាបិ បរិឡាហា បហីយន្តិ ចេតសិកាបិ បរិឡាហា បហីយន្តិ ។ សោ កាយិកសុខម្បិ ចេតោសុខម្បិ បដិសំវេទេតិ ។

វេទនាណា ជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី តែងកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ ក៏មិនត្រេកអរក្នុងវេទនានោះផង ។ កាលបុគ្គលនោះមិនត្រេកអរ មិនជ្រុលជ្រប់ មិនវង្វេងផុលផប់ ជាអ្នកពិចារណាឃើញទោសរឿយ ៗ ឧបាទានក្ខន្ធទាំង ៥ ក៏ដល់នូវសេចក្តីមិនចម្រើនតទៅ ។ ឯតណ្ហាដែលតាក់តែងភពថ្មី ប្រកបដោយតម្រេកដោយអំណាចនៃសេចក្តីត្រេកត្រអាល មានសេចក្តីរីករាយក្នុងអារម្មណ៍នោះ ៗ ជាប្រក្រតី របស់បុគ្គលនោះ តណ្ហានោះ ក៏បុគ្គលនោះឯងលះបង់បាន ។ សេចក្តីក្រវល់ក្រវាយ ប្រព្រឹត្តទៅក្នុងកាយ ក៏បុគ្គលនោះលះបង់បាន សេចក្តីក្រវល់ក្រវាយ ប្រព្រឹត្តទៅក្នុងចិត្ត ក៏លះបង់បាន សេចក្តីក្តៅក្រហាយ ប្រព្រឹត្តទៅក្នុងកាយ ក៏លះបង់បាន សេចក្តីក្តៅក្រហាយ ប្រព្រឹត្តទៅក្នុងចិត្ត ក៏លះបង់បាន សេចក្តីអន្ទះអន្ទែងប្រព្រឹត្តទៅក្នុងកាយ ក៏លះបង់បាន សេចក្តីអន្ទះអន្ទែង ប្រព្រឹត្តទៅក្នុងចិត្ត ក៏លះបង់បាន ។ បុគ្គលនោះ តែងទទួលនូវសេចក្តីសុខ ប្រព្រឹត្តទៅក្នុងកាយ និងសេចក្តីសុខ ប្រព្រឹត្តទៅក្នុងចិត្ត ។

យា តថាភូតស្ស ទិដ្ឋិ សាស្ស ហោតិ សម្មាទិដ្ឋិ យោ តថាភូតស្ស សង្កប្បោ ស្វាស្ស ហោតិ សម្មាសង្កប្បោ យោ តថាភូតស្ស វាយាមោ ស្វាស្ស ហោតិ សម្មាវាយាមោ យា តថាភូតស្ស សតិ សាស្ស ហោតិ សម្មាសតិ យោ តថាភូតស្ស សមាធិ ស្វាស្ស ហោតិ សម្មាសមាធិ ។ បុព្វេវ ខោ បនស្ស កាយកម្មំ វចីកម្មំ អាជីវោ សុបរិសុទ្ធោ ហោតិ ។ ឯវមស្សាយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវនាបារិបូរឹ គច្ឆតិ ។

សេចក្តីយល់ឃើញណា របស់បុគ្គលមានសភាពដូច្នោះ សេចក្តីយល់ឃើញនោះ របស់បុគ្គលនោះ ឈ្មោះថាសេចក្តីយល់ឃើញត្រូវ សេចក្តីត្រិះរិះណា របស់បុគ្គលមានសភាពដូច្នោះ សេចក្តីត្រិះរិះនោះ របស់បុគ្គលនោះ ឈ្មោះថាសេចក្តីត្រិះរិះត្រូវ សេចក្តីព្យាយាមណា របស់បុគ្គលមានសភាពដូច្នោះ សេចក្តីព្យាយាមនោះ របស់បុគ្គលនោះ ឈ្មោះថាសេចក្តីព្យាយាមត្រូវ ការរលឹកណា របស់បុគ្គលមានសភាពដូច្នោះ ការរលឹកនោះ របស់បុគ្គលនោះ ឈ្មោះថាការរលឹកត្រូវ ការតាំងចិត្តនឹងណា របស់បុគ្គលមានសភាពដូច្នោះ ការតាំងចិត្តនឹងនោះ របស់បុគ្គលនោះ ឈ្មោះថាការតាំងចិត្តនឹងត្រូវ ។ បុគ្គលនោះឯង ឈ្មោះថាមានកាយកម្ម វចីកម្ម និងអាជីវៈ បរិសុទ្ធល្អក្នុងកាលមុនពិត ។ អដ្ឋង្គិកមគ្គដ៏ប្រសើរនេះ របស់បុគ្គលនោះ រមែងដល់នូវការបរិបូណ៌ ដោយការនោយ៉ាងនេះ ។

[៣០៦] តស្ស ឯវំ អរិយំ អដ្ឋង្គិកំ មគ្គំ ភាវយតោ ចត្តារោបិ សតិប្បដ្ឋានា ភាវនាបារិបូរឹ គច្ឆន្តិ ចត្តារោបិ សម្មប្បធានា ភាវនាបារិបូរឹ គច្ឆន្តិ ចត្តារោបិ ឥទ្ធិបាទា ភាវនាបារិបូរឹ គច្ឆន្តិ បញ្ចបិ ឥន្ទ្រិយានិ ភាវនាបារិបូរឹ គច្ឆន្តិ បញ្ចបិ ពលានិ ភាវនាបារិបូរឹ គច្ឆន្តិ សត្តបិ ពោជ្ឈង្គា ភាវនាបារិបូរឹ គច្ឆន្តិ ។ តស្សិមេ ទ្វេ ធម្មា យុគនទ្ធា វត្តន្តិ សមថោ ច វិបស្សនា ច ។ សោ យេ ធម្មា អភិញ្ញា បរិញ្ញេយ្យា តេ ធម្មេ អភិញ្ញា បរិជានាតិ យេ ធម្មា អភិញ្ញា បហាតព្វា តេ ធម្មេ អភិញ្ញា បជហាតិ យេ ធម្មា អភិញ្ញា ភាវេតព្វា តេ ធម្មេ អភិញ្ញា ភាវេតិ យេ ធម្មា អភិញ្ញា សច្ឆិកាតព្វា តេ ធម្មេ អភិញ្ញា សច្ឆិករោតិ ។ កតមេ ច ភិក្ខវេ ធម្មា អភិញ្ញា បរិញ្ញេយ្យា បញ្ចុបាទានក្ខន្ធាតិស្ស វចនីយំ សេយ្យថីទំ រូបុបាទានក្ខន្ធោ

[៣០៦] កាលបុគ្គលនោះ ចម្រើនអដ្ឋង្គិកមគ្គ ដ៏ប្រសើរយ៉ាងនេះហើយ សតិប្បដ្ឋាន ៤ ក្តី តែងដល់នូវការបរិបូណ៌ដោយភាវនា សម្មប្បធាន ៤ ក្តី ក៏ដល់នូវការបរិបូណ៌ដោយភាវនា ឥទ្ធិបាទ ៤ ក្តី ក៏ដល់នូវការបរិបូណ៌ដោយភាវនា ឥន្ទ្រិយ ៥ ក្តី ក៏ដល់នូវការបរិបូណ៌ដោយភាវនា ពលៈ ៥ ក្តី ក៏ដល់នូវការបរិបូណ៌ដោយភាវនា ពោជ្ឈង្គ ៧ ក្តី ក៏ដល់នូវការបរិបូណ៌ដោយភាវនា ។ បុគ្គលនោះ តែងមានធម៌ពីរយ៉ាងនេះ គឺសមថៈ ១ វិបស្សនា ១ ប្រព្រឹត្តទាក់ទងគូនឹងគ្នា ។ ធម៌ទាំងឡាយណា ដែលគប្បីកំណត់ដឹងដោយប្រាជ្ញាដ៏ឧត្តម បុគ្គលនោះ ក៏កំណត់ដឹងនូវធម៌ទាំងនោះ ដោយប្រាជ្ញាដ៏ឧត្តម ធម៌ទាំងឡាយណា ដែលគប្បីលះបង់ដោយប្រាជ្ញាដ៏ឧត្តម ក៏លះបង់នូវធម៌ទាំងនោះដោយប្រាជ្ញាដ៏ឧត្តម ធម៌ទាំងឡាយណា ដែលគប្បីចម្រើនដោយប្រាជ្ញាដ៏ឧត្តម ក៏ចម្រើននូវធម៌ទាំងនោះដោយប្រាជ្ញាដ៏ឧត្តម ធម៌ទាំងឡាយណា ដែលគប្បីធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តម ក៏ធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះ ដោយប្រាជ្ញាដ៏ឧត្តម ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ដែលគប្បីកំណត់ដឹង ដោយប្រាជ្ញាដ៏ឧត្តម តើដូចម្តេចគប្បីឆ្លើយថា បានដល់ឧបាទានក្ខន្ធទាំង ៥ គឺ រូបូបាទានក្ខន្ធ ១

វេទនូបាទានក្ខន្ធោ សញ្ញូបាទានក្ខន្ធោ សង្ខារូបាទា-នក្ខន្ធោ វិញ្ញាណូបាទានក្ខន្ធោ ឥមេ ធម្មា អភិញ្ញា បរិញ្ញេយ្យា ។ កតមេ ច ភិក្ខវេ ធម្មា អភិញ្ញា បហាតព្វា អវិជ្ជា ច ភវតណ្ហា ច ឥមេ ធម្មា អភិញ្ញា បហាតព្វា ។ កតមេ ច ភិក្ខវេ ធម្មា អភិញ្ញា ភាវេតព្វា សមថោ ច វិបស្សនា ច ឥមេ ធម្មា អភិញ្ញា ភាវេតព្វា ។ កតមេ ច ភិក្ខវេ ធម្មា អភិញ្ញា សច្ឆិកាតព្វា វិជ្ជា ច វិមុត្តិ ច ឥមេ ធម្មា អភិញ្ញា សច្ឆិកាតព្វាតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

សឡាយតនវិភង្គសុត្តំ  សត្តមំ  និដ្ឋិតំ ។

វេទនូបាទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ សង្ខារូបាទានក្ខន្ធ ១ វិញ្ញាណូ-បាទានក្ខន្ធ ១ នេះឯង ជាធម៌ដែលគប្បីកំណត់ដឹងដោយប្រាជ្ញាដ៏ឧត្តម ។ ម្នាលភិក្ខុទាំងឡាយ ចុះធម៌ទាំងឡាយ ដែលគប្បីលះបង់ដោយប្រាជ្ញាដ៏ឧត្តម តើដូចម្ដេច អវិជ្ជានិងភវតណ្ហានេះឯង ជាធម៌ដែលគប្បីលះបង់ដោយប្រាជ្ញាដ៏ឧត្តម ។ ម្នាលភិក្ខុទាំងឡាយ ចុះធម៌ទាំងឡាយ ដែលគប្បីចម្រើនដោយប្រាជ្ញាដ៏ឧត្តម តើដូចម្ដេច សមថៈនិងវិបស្សនានេះឯង ជាធម៌ដែលគប្បីចម្រើនដោយប្រាជ្ញាដ៏ឧត្តម ។ ម្នាលភិក្ខុទាំងឡាយ ចុះធម៌ទាំងឡាយ ដែលគប្បីធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តម តើដូចម្ដេច វិជ្ជានិងវិមុត្តិនេះឯង ជាធម៌ដែលគប្បីធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តម ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងនោះ ជាអ្នកមានសេចក្ដីត្រេកអរ រីករាយ នឹងភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ សឡាយតនវិភង្គសូត្រ ទី ៧ ។

# អដ្ឋមំ នគរវិន្ទេយ្យសុត្តំ

[៣០៧] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កោសលេសុ ចារិកញ្ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ យេន នគរវិន្ទំ នាម កោសលានំ ព្រាហ្មណគ្គាមោ តទវសរិ ។ អស្សោសុំ ខោ នគរវិន្ទេយ្យកា ព្រាហ្មណគហបតិកា សមណោ ខលុ ភោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ កោសលេសុ ចារិកញ្ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ នគរវិន្ទំ អនុប្បត្តោ តំ ខោ បន ភគវន្តំ គោតមំ ឯវំកល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ

# នគរវិន្ទេយ្យសូត្រ ទី ៨

[៣០៧] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់ត្រាច់ទៅកាន់ចារិកក្នុងដែនកោសល ព្រមដោយភិក្ខុសង្ឃច្រើនរូប ក៏បានស្តេចទៅដល់ព្រាហ្មណគ្រាម ឈ្មោះនគរវិន្ទៈ របស់ពួកអ្នកកោសល ។ ពួកព្រាហ្មណ៍និងគហបតីអ្នកស្រុកនគរវិន្ទៈ បានឮដំណឹងថា ព្រះសមណគោតម ជាសក្យបុត្រចេញចាកសក្យត្រកូលទៅទ្រង់ព្រះផ្នួស ឥឡូវនេះ ទ្រង់ពុទ្ធដំណើរទៅកាន់ចារិកក្នុងដែនកោសល ព្រមដោយភិក្ខុសង្ឃច្រើនរូប ក៏បានស្តេចមកដល់ស្រុកនគរវិន្ទៈហើយ កិត្តិសព្ទដ៏ពីរោះ របស់ព្រះគោតមដ៏ចម្រើននោះ ក៏ឮខ្ចរខ្ចាយសុសសាយយ៉ាងនេះថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ឆ្ងាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ព្រះអង្គបរិបូណ៌ដោយវិជ្ជានិងចរណៈ ព្រះអង្គមានដំណើរល្អ ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណ ព្រះអង្គជាអ្នកទូន្មាននូវបុរស ដែលគួរទូន្មានបាន

សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា សោ ឥមំ លោកំ សទេវកំ សមារកំ សព្រហ្មកំ សស្សមណព្រាហ្មណឹ បជំ សទេវមនុស្សំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ សាធុ ខោ បន តថារូបានំ អរហតំ ទស្សនំ ហោតីតិ ។ អថខោ នគរវិន្ទេយ្យកា ព្រាហ្មណគហបតិកា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា អប្បេកច្ចេ ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ យេន ភគវា តេនញ្ជលិម្បណាមេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ ភគវតោ សន្តិកេ នាមគោត្តំ សាវេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ តុណ្ហីភូតា ឯកមន្តំ និសីទឹសុ ។

ព្រះអង្គជាសាស្តាចារ្យ នៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គបាន ត្រាស់ដឹងនូវចតុរារិយសច្ច ព្រះអង្គលែងមកកាន់ភពថ្មីទៀត ព្រះអង្គទ្រង់ ធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ប្រសើររបស់ព្រះអង្គ នូវលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក នូវពពួកសត្វ ព្រមទាំង សមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ហើយ អាចប្រកាសបាន ទ្រង់សំដែងធម៌ មានលំអបទដើម មានលំអបទ កណ្តាល មានលំអបទចុង ព្រះអង្គប្រកាសព្រហ្មចរិយធម៌ ព្រមទាំង អត្ថនិងព្យញ្ជនៈដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ក៏ដំណើរដែលបានជួបនឹង ព្រះអរហន្តទាំងឡាយ មានសភាពយ៉ាងនោះ ជាការប្រពៃពេក ។ គ្រានោះឯង ពួកព្រាហ្មណ៍និងគហបតីអ្នកស្រុកនគរវិន្ទៈ ក៏នាំគ្នាចូល ទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ពួកខ្លះថ្វាយបង្គំ ព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះប្រណម្យអញ្ជលី ឆ្ពោះទៅរកព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះប្រ-កាសនាមនិងគោត្រក្នុងសំណាក់ព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏ សមគួរ ពួកខ្លះអង្គុយនៅស្ងៀម ក្នុងទីដ៏សមគួរ ។

[៣០៧] ឯកមន្តំ និសិន្នេ ខោ នគរវិន្ទេយ្យកេ ព្រាហ្មណគហបតិកេ ភគវា ឯតទវោច សចេ វោ[១] គហបតយោ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ បុច្ឆេយ្យុំ កថំរូបា[២] គហបតយោ សមណព្រាហ្មណា ន សក្កាតព្វា ន គរុកាតព្វា ន មានេតព្វា ន បូជេតព្វាតិ ឯវំ បុដ្ឋា តុម្ហេ គហបតយោ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ ឯវំ ព្យាករេយ្យាថ យេ តេ សមណព្រាហ្មណា ចក្ខុវិញ្ញេយ្យេសុ រូបេសុ អវីតរាគា អវីតទោសា អវីតមោហា អជ្ឈត្តំ អវូបសន្តចិត្តា សមវិសមំ ចរន្តិ កាយេន វាចាយ មនសា ឯវរូបា សមណព្រាហ្មណា ន សក្កាតព្វា ន គរុកាតព្វា ន មានេតព្វា ន បូជេតព្វា តំ កិស្ស ហេតុ មយម្បិ ហិ ចក្ខុវិញ្ញេយ្យេសុ រូបេសុ អវីតរាគា អវីតទោសា អវីតមោហា អជ្ឈត្តំ អវូបសន្តចិត្តា សមវិសមំ ចរាម

១ ម. តេ ។ ២ ម. កថំភូតា ។

[៣០៩] លុះពួកព្រាហ្មណ៍និងគហបតី អ្នកស្រុកនគរវិន្ទៈអង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់សួរដូច្នេះថា ម្នាលគហបតីទាំងឡាយ បើបរិព្វាជកជាអន្យតិរ្ថិយ (មានលទ្ធិផ្សេង) សួរអ្នកទាំងឡាយយ៉ាងនេះថា ម្នាលគហបតីទាំងឡាយ ពួកសមណព្រាហ្មណ៍បែបណា ដែលគេមិនគួរធ្វើសក្ការៈ មិនគួរគោរព មិនគួររាប់អាន មិនគួរបូជា ម្នាលគហបតីទាំងឡាយ អ្នកទាំងឡាយ កាលបើបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះ សួរយ៉ាងនេះហើយ គប្បីដោះស្រាយយ៉ាងនេះថា ពួកសមណព្រាហ្មណ៍ណា មិនទាន់ប្រាសចាករាគៈ មិនទាន់ប្រាសចាកទោសៈ មិនទាន់ប្រាសចាកមោហៈ ក្នុងរូបដែលគប្បីដឹងបានដោយភ្នែក ជាអ្នកមានចិត្តមិនស្ងប់រម្ងាប់ខាងក្នុងសន្តានប្រព្រឹត្តត្រូវខ្លះ ខុសខ្លះ ដោយកាយ វាចា ចិត្ត ពួកសមណព្រាហ្មណ៍បែបនេះឯង គេមិនគួរធ្វើសក្ការៈ មិនគួរគោរព មិនគួររាប់អាន មិនគួរបូជាឡើយ ដំណើរនោះ តើព្រោះហេតុអ្វី ព្រោះថាសូម្បីពួកយើង ក៏មិនទាន់ប្រាសចាករាគៈ មិនទាន់ប្រាសចាកទោសៈ មិនទាន់ប្រាសចាកមោហៈ ក្នុងរូបដែលគប្បីដឹងបានដោយភ្នែក ជាអ្នកមានចិត្តមិនស្ងប់រម្ងាប់ ខាងក្នុងសន្តាន នៅប្រព្រឹត្តត្រូវខ្លះ ខុសខ្លះ

កាយេន វាចាយ មនសា តេសន្តោ សមចរិយម្បិ ហេតំ ឧត្តរឹ អបស្សន្តំ តស្មា តេ ភោន្តោ សមណព្រាហ្មណា ន សក្កាតព្វា ន គរុកាតព្វា ន មានេតព្វា ន បូជេតព្វា ។ យេ តេ សមណព្រាហ្មណា សោតវិញ្ញេយ្យេសុ សទ្ទេសុ... ឃានវិញ្ញេយ្យេសុ គន្ធេសុ... ជិវ្ហាវិញ្ញេយ្យេសុ រសេសុ... កាយវិញ្ញេយ្យេសុ ផោដ្ឋព្វេសុ... មនោវិញ្ញេយ្យេសុ ធម្មេសុ អវីតរាគា អវីតទោសា អវីតមោហា អជ្ឈត្តំ អវូបសន្តចិត្តា សមវិសមំ ចរន្តិ កាយេន វាចាយ មនសា ឯវរូបា សមណព្រាហ្មណា ន សក្កាតព្វា ន គរុកាតព្វា ន មានេតព្វា ន បូជេតព្វា តំ កិស្ស ហេតុ មយម្បិ ហិ មនោវិញ្ញេយ្យេសុ ធម្មេសុ អវីតរាគា អវីតទោសា អវីតមោហា អជ្ឈត្តំ អវូបសន្តចិត្តា សមវិសមំ ចរាម

ដោយកាយវាចាចិត្តដែរ នេះឯងជាសេចក្ដីប្រព្រឹត្តត្រឹមត្រូវ របស់យើងទាំងនោះ ដែលមិនឃើញនូវធម៌ខ្ពង់ខ្ពស់ ព្រោះហេតុនោះ ពួកសមណ-ព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ គេមិនគួរធ្វើសក្ការៈ មិនគួរគោរព មិនគួររាប់អាន មិនគួរបូជាឡើយ ។ ពួកសមណព្រាហ្មណ៍ណា មិនទាន់ប្រាសចាករាគៈ មិនទាន់ប្រាសចាកទោសៈ មិនទាន់ប្រាសចាកមោហៈ ក្នុងសំឡេង ដែលគប្បីដឹងបានដោយត្រចៀក... ក្នុងក្លិនដែលគប្បីដឹងបានដោយច្រមុះ... ក្នុងឱជារស ដែលគប្បីដឹងបានដោយអណ្ដាត... ក្នុងផោដ្ឋព្វៈ ដែលគប្បីដឹងបានដោយកាយ... មិនទាន់ប្រាសចាករាគៈ មិនទាន់ប្រាសចាកទោសៈ មិនទាន់ប្រាសចាកមោហៈ ក្នុងធម្មារម្មណ៍ ដែលគប្បីដឹងបានដោយចិត្ត ជាអ្នកមានចិត្តមិនស្ងប់រម្ងាប់ខាងក្នុងសន្ដាន ប្រព្រឹត្តត្រូវខ្លះ ខុសខ្លះ ដោយកាយវាចាចិត្ត ពួកសមណព្រាហ្មណ៍បែបនេះឯង គេមិនគួរធ្វើសក្ការៈ មិនគួរគោរព មិនគួររាប់អាន មិនគួរបូជាឡើយ ដំណើរនោះ តើព្រោះហេតុអ្វី ព្រោះថា សូម្បីពួកយើង ក៏មិនទាន់ប្រាសចាករាគៈ មិនទាន់ប្រាសចាកទោសៈ មិនទាន់ប្រាសចាកមោហៈ ក្នុងធម្មារម្មណ៍ ដែលគប្បីដឹងបានដោយចិត្ត ជាអ្នកមានចិត្តមិនស្ងប់រម្ងាប់ខាងក្នុងសន្ដាន នៅប្រព្រឹត្តត្រូវខ្លះ ខុសខ្លះ

កាយេន វាចាយ មនសា តេសន្តោ សមចរិយម្បិ ហេតំ ឧត្តរឹ អបស្សតំ តស្មា តេ ភោន្តោ សមណព្រាហ្មណា ន សក្កាតព្វា ន គរុកាតព្វា ន មានេតព្វា ន បូជេតព្វាតិ ។ ឯវំ បុដ្ឋា តុម្ហេ គហបតយោ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ ឯវំ ព្យាករេយ្យាថ ។

[៣០៩] សចេ បន វោ គហបតយោ អញ្ញ-តិត្ថិយា បរិព្វាជកា ឯវំ បុច្ឆេយ្យុំ កថំរូបា គហ-បតយោ សមណព្រាហ្មណា សក្កាតព្វា គរុកាតព្វា មានេតព្វា បូជេតព្វាតិ ឯវំ បុដ្ឋា តុម្ហេ គហបតយោ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ ឯវំ ព្យាករេយ្យាថ យេ តេ សមណព្រាហ្មណា ចក្ខុវិញ្ញេយ្យេសុ រូបេសុ វីតរាគា វីតទោសា វីតមោហា អជ្ឈត្តំ វូបសន្តចិត្តា សមចរិយំ ចរន្តិ កាយេន វាចាយ មនសា ឯវរូបា សមណព្រាហ្មណា សក្កាតព្វា គរុកាតព្វា

ដោយកាយវាចាចិត្តដែរ នេះឯងជាសេចក្តីប្រព្រឹត្តត្រឹមត្រូវ របស់យើងទាំងនោះ ដែលមិនឃើញនូវធម៌ខ្ពង់ខ្ពស់ ព្រោះហេតុនោះ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ គេមិនគួរធ្វើសក្ការៈ មិនគួរគោរព មិនគួររាប់អាន មិនគួរបូជាឡើយ ។ ម្នាលគហបតីទាំងឡាយ អ្នកទាំងឡាយ កាលបើបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះ សួរយ៉ាងនេះ គប្បីដោះស្រាយយ៉ាងនេះឯង ។

[៣០៩] ម្នាលគហបតីទាំងឡាយ មួយទៀត បើបរិព្វាជកជាអន្យតិរ្ថិយ សួរអ្នកទាំងឡាយយ៉ាងនេះថា ម្នាលគហបតីទាំងឡាយ ចុះពួកសមណព្រាហ្មណ៍បែបណា ដែលគេគួរធ្វើសក្ការៈ គួរគោរព គួររាប់អាន គួរបូជា ម្នាលគហបតីទាំងឡាយ អ្នកទាំងឡាយ កាលបើបរិព្វាជកជាអន្យតិរ្ថិយទាំងនោះ សួរយ៉ាងនេះ គប្បីដោះស្រាយយ៉ាងនេះថា ពួកសមណព្រាហ្មណ៍ណា ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ ក្នុងរូបដែលគប្បីដឹងបានដោយភ្នែក ជាអ្នកមានចិត្តស្ងប់រម្ងាប់ ខាងក្នុងសន្តាន ប្រព្រឹត្តត្រឹមត្រូវដោយកាយវាចាចិត្ត ពួកសមណព្រាហ្មណ៍បែបនេះឯង ទើបគេគួរធ្វើសក្ការៈ គួរគោរព

មានេតព្វា បូជេតព្វា តំ កិស្ស ហេតុ មយម្បិ ហិ ចក្ខុវិញ្ញេយ្យេសុ រូបេសុ អវីតរាគា អវីតទោសា អវីតមោហា អជ្ឈត្តំ អវូបសន្តចិត្តា សមវិសមំ ចរាម កាយេន វាចាយ មនសា តេសន្នោ សមចរិយម្បិ ហេតំ ឧត្តរឹ បស្សតំ តស្មា តេ ភោន្តោ សមណព្រាហ្មណា សក្កាតព្វា គរុកាតព្វា មានេតព្វា បូជេតព្វា ។ យេ តេ សមណព្រាហ្មណា សោត-វិញ្ញេយ្យេសុ សទ្ទេសុ... ឃានវិញ្ញេយ្យេសុ គន្ធេសុ... ជិវ្ហាវិញ្ញេយ្យេសុ រសេសុ... កាយវិញ្ញេយ្យេសុ ផោដ្ឋ-ព្វេសុ... មនោវិញ្ញេយ្យេសុ ធម្មេសុ វីតរាគា វីតទោសា វីតមោហា អជ្ឈត្តំ វូបសន្តចិត្តា សមចរិយំ ចរន្តិ កាយេន វាចាយ មនសា ឯវរូបា សមណព្រាហ្មណា សក្កាតព្វា គរុកាតព្វា មានេតព្វា បូជេតព្វា

គួររាប់អាន គួរបូជា ដំណើរនោះ តើព្រោះហេតុអ្វី ព្រោះថា សូម្បីពួកយើង មិនទាន់ប្រាសចាករាគៈ មិនទាន់ប្រាសចាកទោសៈ មិនទាន់ប្រាសចាកមោហៈ ក្នុងរូបដែលគប្បីដឹងបានដោយភ្នែក មានចិត្តមិនទាន់ស្ងប់រម្ងាប់ខាងក្នុងសន្តានទេ នៅប្រព្រឹត្តត្រូវខ្លះ ខុសខ្លះ ដោយកាយវាចាចិត្ត នេះឯងជាសេចក្តីប្រព្រឹត្តត្រឹមត្រូវ របស់យើងទាំងនោះ ដែលឃើញនូវធម៌ខ្ពង់ខ្ពស់ ព្រោះហេតុនោះ ពួកសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ទើបគេគួរធ្វើសក្ការៈ គួរគោរព គួររាប់អាន គួរបូជា ។ ពួកសមណព្រាហ្មណ៍ណា ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ ក្នុងសំឡេងដែលគប្បីដឹងបានដោយត្រចៀក... ក្នុងក្លិនដែលគប្បីដឹងបានដោយច្រមុះ... ក្នុងឱជារសដែលគប្បីដឹងបានដោយអណ្តាត... ក្នុងផោដ្ឋព្វៈដែលគប្បីដឹងបានដោយកាយ... ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ ក្នុងធម្មារម្មណ៍ ដែលគប្បីដឹងបានដោយចិត្ត ជាអ្នកមានចិត្តស្ងប់រម្ងាប់ខាងក្នុងសន្តាន ប្រព្រឹត្តត្រឹមត្រូវដោយកាយវាចាចិត្ត ពួកសមណព្រាហ្មណ៍បែបនេះ ទើបគេគួរធ្វើសក្ការៈ គួរគោរព គួររាប់អាន គួរបូជា

តំ កិស្ស ហេតុ មយម្បិ ហិ មនោវិញ្ញេយ្យេសុ ធម្មេសុ អវីតរាគា អវីតទោសា អវីតមោហា អជ្ឈត្តំ អវូបសន្តចិត្តា សមវិសមំ ចរាម កាយេន វាចាយ មនសា តេសន្នោ សមចរិយម្បិ ហេតំ ឧត្តរឹ បស្សតំ តស្មា តេ ភោន្តោ សមណព្រាហ្មណា សក្កាតព្វា គរុកាតព្វា មានេតព្វា បូជេតព្វាតិ ។ ឯវំ បុដ្ឋា តុម្ហេ គហបតយោ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ ឯវំ ព្យាករេយ្យាថ ។

[៣១០] សចេ តេ គហបតយោ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ បុច្ឆេយ្យុំ កោ បនាយស្មន្តានំ អាការា កេ អន្វយា យេន តុម្ហេ អាយស្មន្តោ ឯវំ វទេថ អទ្ធា តេ អាយស្មន្តោ វីតរាគា វា រាគវិនយាយ វា បដិបន្នា វីតទោសា វា ទោសវិនយាយ វា បដិបន្នា វីតមោហា

ដំណើរនោះ តើព្រោះហេតុអ្វី ព្រោះថា សូម្បីពួកយើង មិនទាន់ប្រាសចាករាគៈ មិនទាន់ប្រាសចាកទោសៈ មិនទាន់ប្រាសចាកមោហៈ ក្នុងធម្មារម្មណ៍ដែលគប្បីដឹងបានដោយចិត្ត ជាអ្នកមានចិត្តមិនទាន់ស្ងប់រម្ងាប់ខាងក្នុងសន្តាន នៅប្រព្រឹត្តត្រូវខ្លះ ខុសខ្លះ ដោយកាយវាចាចិត្ត នេះឯងជាសេចក្ដីប្រព្រឹត្តត្រឹមត្រូវ របស់យើងទាំងនោះ ដែលឃើញនូវធម៌ខ្ពង់ខ្ពស់ ព្រោះហេតុនោះ បានជាពួកសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ គេគួរធ្វើសក្ការៈ គួរគោរព គួររាប់អាន គួរបូជា ។ ម្នាលគហបតីទាំងឡាយ អ្នកទាំងឡាយ កាលបើបរិព្វាជកជាអន្យតិរ្ថិយទាំងនោះ សួរយ៉ាងនេះ គប្បីដោះស្រាយយ៉ាងនេះឯង ។

[៣១០] ម្នាលគហបតីទាំងឡាយ បើបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះ សួរយ៉ាងនេះថា ម្នាលអ្នកមានអាយុទាំងឡាយ ចុះលោកមានអាយុទាំងឡាយ មានហេតុដូចម្ដេច មានប្រាជ្ញាយោបល់ដូចម្ដេច ដែលនាំឲ្យអ្នកទាំងឡាយនិយាយយ៉ាងនេះថា អ្នកមានអាយុទាំងនោះ ប្រាសចាករាគៈ ឬកំពុងប្រតិបត្តិដើម្បីបន្ទោបង់នូវរាគៈ ប្រាសចាកទោសៈ ឬកំពុងប្រតិបត្តិដើម្បីបន្ទោបង់នូវទោសៈ ប្រាសចាកមោហៈ

វា មោហវិនយាយ វា បដិបន្នាតិ ឯវំ បុដ្ឋា តុម្ហេ គហបតយោ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ ឯវំ ព្យាករេយ្យាថ តថា ហិ តេ អាយស្មន្តោ អរញ្ញ-វនបត្ថានិ បន្តានិ សេនាសនានិ បដិសេវន្តិ នត្ថិ ខោ បន តត្ថ តថារូបា ចក្ខុវិញ្ញេយ្យា រូបា យេ ទិស្វា ទិស្វា អភិរមេយ្យុំ នត្ថិ ខោ បន តត្ថ តថារូបា សោតវិញ្ញេយ្យា សទ្ទា យេ សុត្វា សុត្វា អភិរមេយ្យុំ នត្ថិ ខោ បន តត្ថ តថារូបា ឃានវិញ្ញេយ្យា គន្ធា យេ ឃាយិត្វា ឃាយិត្វា អភិរមេយ្យុំ នត្ថិ ខោ បន តត្ថ តថារូបា ជិវ្ហាវិញ្ញេយ្យា រសា យេ សាយិត្វា សាយិត្វា អភិរមេយ្យុំ នត្ថិ ខោ បន តត្ថ តថារូបា កាយ-វិញ្ញេយ្យា ផោដ្ឋព្វា យេ ផុសិត្វា ផុសិត្វា អភិរមេយ្យុំ ឥមេ ខោ នោ អាវុសោ អាការា ឥមេ អន្វយា យេន មយំ អាយស្មន្តេ[១] ឯវំ វទេម អទ្ធា តេ អា-យស្មន្តោ វីតរាគា វា រាគវិនយាយ វា បដិបន្នា វីត-ទោសា វា ទោសវិនយាយ វា បដិបន្នា វីតមោហា វា

---

១ អាយស្មន្តោតិ អម្ហាកំ មតិ ។

ឬកំពុងប្រតិបត្តិ ដើម្បីបន្ទោបង់នូវមោហៈដោយពិត ម្នាលគហបតីទាំង-ឡាយ អ្នកទាំងឡាយ កាលបើបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះ សួរយ៉ាងនេះ គប្បីដោះស្រាយយ៉ាងនេះថា ពិតដូច្នោះមែន ព្រោះលោកមានអាយុទាំងនោះ តែងគប់រកសេនាសនៈដ៏ស្ងាត់ គឺព្រៃតូចនិងព្រៃធំ ដ្បិតរូប គប្បីដឹងបានដោយភ្នែក ដែលគេឃើញញយ ៗ ហើយ គួរត្រេកអរបាន មិនមានក្នុងព្រៃនោះឡើយ សំឡេង គប្បីដឹងបានដោយត្រចៀក ដែលគេឮញយ ៗ ហើយ គួរត្រេកអរបាន មិនមានក្នុងព្រៃនោះឡើយ ក្លិនគប្បីដឹងបានដោយច្រមុះ ដែលគេហិតញយ ៗ ហើយ គួរត្រេកអរបាន មិនមានក្នុងព្រៃនោះឡើយ រសគប្បីដឹងបានដោយអណ្តាត ដែលគេទទួលរសញយ ៗ ហើយ គួរត្រេកអរបាន មិនមានក្នុងព្រៃនោះឡើយ ផោដ្ឋព្វៈគប្បីដឹងបានដោយកាយ ដែលគេប៉ះពាល់ញយ ៗ ហើយ គួរត្រេកអរបាន មិនមានក្នុងព្រៃនោះឡើយ ម្នាលអាវុសោទាំងឡាយ យើងទាំងឡាយ មានហេតុនេះឯង មានប្រាជ្ញាយោបល់នេះឯងហើយ ដែលនាំឲ្យពួកយើងនិយាយយ៉ាងនេះ ចំពោះអ្នកមានអាយុទាំងឡាយថា លោកមានអាយុទាំង-នោះ ប្រាសចាករាគៈ ឬកំពុងប្រតិបត្តិដើម្បីបន្ទោបង់រាគៈ ប្រាសចាកទោសៈ ឬកំពុងប្រតិបត្តិដើម្បីបន្ទោបង់ទោសៈ ប្រាសចាកមោហៈ

មោហវិនយាយ វា បដិបន្នាតិ ។ ឯវំ បុដ្ឋា តុម្ហេ គហបតយោ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ ឯវំ ព្យាករេយ្យាថាតិ ។

[៣១១] ឯវំ វុត្តេ នគរវិន្ទេយ្យកា ព្រាហ្មណគហបតិកា ភគវន្តំ ឯតទវោចុំ អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម សេយ្យថាបិ ភោ គោតម និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ ភោតា គោតមេន អនេកបរិយាយេន ធម្មោ បកាសិតោ ឯតេ មយំ ភវន្តំ គោតមំ សរណំ គច្ឆាម ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកេ នោ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតេ សរណង្គតេតិ ។

នគរវិន្ទេយ្យសុត្តំ អដ្ឋមំ និដ្ឋិតំ ។

ឬកំពុងប្រតិបត្តិ ដើម្បីបន្ទោបង់មោហៈដោយពិត ។ ម្នាលគហបតីទាំងឡាយ អ្នកទាំងឡាយ កាលបើបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះសួរយ៉ាងនេះ គប្បីដោះស្រាយយ៉ាងនេះឯង ។

[៣១១] កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ពួកព្រាហ្មណ៍និងគហបតីអ្នកស្រុកនគរវិន្ទៈ បានក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះគោតមដ៏ចម្រើន ទ្រង់សំដែងហើយ ដោយអនេកបរិយាយយ៉ាងនេះ ដូចជាគេផ្ងាររបស់ដែលផ្កាប់ ឬដូចគេបើកបង្ហាញរបស់ដែលកំបាំង ពុំនោះ ដូចជាគេប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ពុំនោះសោត ដូចជាគេទ្រោលប្រទីបក្នុងទីងងឹត ដោយគិតថា មនុស្សដែលមានភ្នែកនឹងមើលឃើញរូបបាន ខ្ញុំព្រះអង្គទាំងឡាយនេះ សូមដល់នូវព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ថាជាទីពឹង សូមព្រះគោតមដ៏ចម្រើន ទ្រង់ជ្រាបទុកនូវខ្ញុំព្រះអង្គទាំងឡាយ ថាជាឧបាសកដល់នូវសរណគមន៍ស្មើដោយជីវិត ចាប់ដើមពីថ្ងៃនេះតទៅ ។

ចប់ នគរវិន្ទេយ្យសូត្រ ទី ៨ ។

# នវមំ បិណ្ឌបាតបារិសុទ្ធិសុត្តំ

[៣១២] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជ-
គហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ អថខោ
អាយស្មា សារីបុត្តោ សាយណ្ហសមយំ បដិសល្លានា
វុដ្ឋិតោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគ-
វន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ
ខោ អាយស្មន្តំ សារីបុត្តំ ភគវា ឯតទវោច វិប្បសន្នា-
និ ខោ តេ សារីបុត្ត ឥន្ទ្រិយានិ បរិសុទ្ធោ ឆវិវណ្ណោ
បរិយោទាតោ កតមេន ត្វំ សារីបុត្ត វិហារេន ឯត-
រហិ ពហុលំ វិហរសីតិ ។ សុញ្ញតាវិហារេន ខោ អហំ
ភន្តេ ឯតរហិ ពហុលំ វិហរាមីតិ ។

# បិណ្ឌបាតបារិសុទ្ធិសូត្រ ទី ៩

[៣១២] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ គ្រានោះឯង ព្រះសារីបុត្តមានអាយុចេញអំពីផលសមាបត្តិក្នុងវេលាសាយណ្ហសម័យ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់នៅក្នុងទីដ៏សមគួរ ។ លុះព្រះសារីបុត្តមានអាយុ គង់នៅក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគ ក៏ទ្រង់ត្រាស់សួរដូច្នេះថា ម្នាលសារីបុត្ត ឥន្ទ្រិយរបស់អ្នកជ្រះថ្លា សម្បុរស្បែករបស់អ្នកស្អាតផូរផង់ ម្នាលសារីបុត្ត ក្នុងកាលឥឡូវនេះ តើលោកច្រើនប្រព្រឹត្តទៅដោយវិហារធម៌ដូចម្តេច ។ ព្រះសារីបុត្តក្រាបបង្គំទូលថា បពិត្រព្រះអង្គ ក្នុងកាលឥឡូវនេះ ខ្ញុំព្រះអង្គ ច្រើនប្រព្រឹត្តទៅដោយសុញ្ញតាវិហារធម៌[១] ។

---

១ បានដល់សុញ្ញតផលសមាបត្តិ ។

[៣១៣] សាធុ សាធុ សារីបុត្ត មហាបុរិសវិហារេន កិរ ត្វំ សារីបុត្ត ឯតរហិ ពហុលំ វិហរសិ មហាបុរិសវិហារោ ហេស សារីបុត្ត យទិទំ សុញ្ញតា ។ តស្មាតិហ សារីបុត្ត ភិក្ខុ សចេ អាកង្ខេយ្យ សុញ្ញតាវិហារេន ពហុលំ វិហរេយ្យន្តិ តេន សារីបុត្ត ភិក្ខុនា ឥតិ បដិសញ្ចិក្ខិតព្វំ យេន ចាហំ មគ្គេន គាមំ បិណ្ឌាយ បាវិសឹ យស្មិញ្ច បទេសេ បិណ្ឌាយ អចរឹ យេន ច មគ្គេន គាមតោ បិណ្ឌាយ បដិក្កមឹ អត្ថិ នុ ខោ មេ តត្ថ ចក្ខុវិញ្ញេយ្យេសុ រូបេសុ ឆន្ទោ វា រាគោ វា ទោសោ វា មោហោ វា បដិឃំ វាបិ ចេតសោតិ ។ សចេ សារីបុត្ត ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ យេន ចាហំ មគ្គេន គាមំ បិណ្ឌាយ បាវិសឹ យស្មិញ្ច បទេសេ បិណ្ឌាយ អចរឹ យេន ច មគ្គេន គាមតោ បិណ្ឌាយ បដិក្កមឹ អត្ថិ មេ តត្ថ

[៣១៣] ម្នាលសារីបុត្ត ប្រពៃណាស់ហើយ ៗ ម្នាលសារីបុត្ត បានឮថា ក្នុងកាលឥឡូវនេះ លោកច្រើនប្រព្រឹត្តទៅដោយវិហារធម៌របស់មហាបុរស[១] ម្នាលសារីបុត្ត ឯវិហារធម៌របស់មហាបុរស ក៏គឺសុញ្ញតាវិហារធម៌នេះឯង ។ ម្នាលសារីបុត្ត ព្រោះហេតុនោះ បើភិក្ខុក្នុងសាសនានេះប្រាថ្នាថា អាត្មាអញគួរតែប្រព្រឹត្តទៅច្រើនដោយសុញ្ញតា-វិហារធម៌ ម្នាលសារីបុត្ត ភិក្ខុនោះគប្បីពិចារណាដូច្នេះថា អាត្មាអញបានចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាតតាមផ្លូវណាក្តី បានត្រាច់ទៅដើម្បីបិណ្ឌបាតក្នុងប្រទេសណាក្តី បានត្រឡប់អំពីបិណ្ឌបាត ចេញអំពីស្រុកតាមផ្លូវណាក្តី តើក្នុងផ្លូវទាំងនោះ អាត្មាអញមានឆន្ទៈគឺសេចក្តីពេញចិត្ត ឬរាគៈគឺសេចក្តីត្រេក ទោសៈគឺសេចក្តីប្រទូស្ត ឬមោហៈគឺសេចក្តីវង្វេង ឬក៏បដិឃៈ គឺសេចក្តីថ្នាំងថ្នាក់នៃចិត្ត ក្នុងរូបដែលគប្បីដឹងបានដោយភ្នែកដែរឬទេ ។ ម្នាលសារីបុត្ត កាលបើភិក្ខុពិចារណាដឹងយ៉ាងនេះថា អាត្មាអញ បានចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាតតាមផ្លូវណាក្តី បានត្រាច់ទៅដើម្បីបិណ្ឌបាតក្នុងប្រទេសណាក្តី បានត្រឡប់អំពីបិណ្ឌ-បាត ចេញអំពីស្រុកតាមផ្លូវណាក្តី ក្នុងផ្លូវទាំងនោះ អាត្មាអញមាន

១ បានដល់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងមហាសាវ័ក ។ អដ្ឋកថា ។

ចក្ខុវិញ្ញេយ្យេសុ រូបេសុ ឆន្ទោ វា រាគោ វា ទោសោ វា មោហោ វា បដិឃំ វាបិ ចេតសោតិ តេន សារីបុត្ត ភិក្ខុនា តេសំយេវ ចាបកានំ អកុសលានំ ធម្មានំ បហានាយ វាយមិតព្វំ ។ សចេ បន សារីបុត្ត ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ យេន ចាហំ មគ្គេន គាមំ បិណ្ឌាយ ចារិសឹ យស្មិញ្ច បទេសេ បិណ្ឌាយ អចរឹ យេន ច មគ្គេន គាមតោ បិណ្ឌាយ បដិក្កមឹ នត្ថិ មេ តត្ថ ចក្ខុវិញ្ញេយ្យេសុ រូបេសុ ឆន្ទោ វា រាគោ វា ទោសោ វា មោហោ វា បដិឃំ វាបិ ចេតសោតិ តេន សារីបុត្ត ភិក្ខុនា តេ-នេវ បីតិបាមុជ្ជេន វិហាតព្វំ អហោរត្តានុសិក្ខិនា កុសលេសុ ធម្មេសុ ។

[៣១៤] បុន ចបរំ សារីបុត្ត ភិក្ខុនា ឥតិ បដិ-សញ្ចិក្ខិតព្វំ យេន ចាហំ មគ្គេន គាមំ បិណ្ឌាយ ចារិ-សឹ យស្មិញ្ច បទេសេ បិណ្ឌាយ អចរឹ យេន ច មគ្គេ-ន គាមតោ បិណ្ឌាយ បដិក្កមឹ អត្ថិ នុ ខោ មេ តត្ថ

ឆន្ទៈ ឬរាគៈ ទោសៈ ឬមោហៈ ឬក៏បដិឃៈនៃចិត្ត ក្នុងរូបដែលគប្បីដឹងបានដោយភ្នែកដែរ ម្នាលសារីបុត្ត ភិក្ខុនោះគប្បីព្យាយាមដើម្បីលះបង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលសារីបុត្ត តែបើភិក្ខុពិចារណាដឹងយ៉ាងនេះវិញថា អាត្មាអញ បានចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាតតាមផ្លូវណាក្តី បានត្រាច់ទៅដើម្បីបិណ្ឌបាតក្នុងប្រទេសណាក្តី បានត្រឡប់អំពីបិណ្ឌបាត ចេញអំពីស្រុក តាមផ្លូវណាក្តី ក្នុងផ្លូវទាំងនោះ អាត្មាអញមិនមានឆន្ទៈ ឬរាគៈ ទោសៈ ឬមោហៈ ឬក៏បដិឃៈនៃចិត្ត ក្នុងរូបដែលគប្បីដឹងបានដោយភ្នែកទេ ម្នាលសារីបុត្ត ភិក្ខុនោះ ត្រូវសិក្សាក្នុងកុសលធម៌ទាំងថ្ងៃទាំងយប់ នៅដោយបីតិនិងបាមោជ្ជៈនោះឯង ។

[៣១៤] ម្នាលសារីបុត្ត មួយទៀត ភិក្ខុគប្បីពិចារណាដូច្នេះថា អាត្មាអញ បានចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត តាមផ្លូវណាក្តី បានត្រាច់ទៅដើម្បីបិណ្ឌបាតក្នុងប្រទេសណាក្តី បានត្រឡប់អំពីបិណ្ឌ-បាត ចេញអំពីស្រុកតាមផ្លូវណាក្តី តើផ្លូវទាំងនោះ អាត្មាអញមាន

សោតវិញ្ញេយ្យេសុ សទ្ទេសុ... ឃានវិញ្ញេយ្យេសុ គន្ធេសុ... ជិវ្ហាវិញ្ញេយ្យេសុ រសេសុ... កាយវិញ្ញេយ្យេសុ ផោដ្ឋព្វេសុ... មនោវិញ្ញេយ្យេសុ ធម្មេសុ ឆន្ទោ វា រាគោ វា ទោសោ វា មោហោ វា បដិឃំ វាបិ ចេតសោតិ ។ សចេ សារីបុត្ត ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ យេន ចាហំ មគ្គេន គាមំ បិណ្ឌាយ បាវិសឹ យស្មិញ្ច បទេសេ បិណ្ឌាយ អចរឹ យេន ច មគ្គេន គាមតោ បិណ្ឌាយ បដិក្កមឹ អត្ថិ មេ តត្ថ មនោវិញ្ញេយ្យេសុ ធម្មេសុ ឆន្ទោ វា រាគោ វា ទោសោ វា មោហោ វា បដិឃំ វាបិ ចេតសោតិ តេន សារីបុត្ត ភិក្ខុនា តេសំយេវ បាបកានំ អកុសលានំ ធម្មានំ បហានាយ វាយមិតព្វំ ។ សចេ បន សារីបុត្ត ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ យេន ចាហំ មគ្គេន គាមំ បិណ្ឌាយ បាវិសឹ យស្មិញ្ច បទេសេ បិណ្ឌាយ អចរឹ

ឆន្ទៈ ឬរាគៈ ទោសៈ ឬមោហៈ ឬក៏បដិឃៈនៃចិត្ត ក្នុងសំឡេងដែលគប្បីដឹងបានដោយត្រចៀក... ក្នុងក្លិនដែលគប្បីដឹងបានដោយច្រមុះ... ក្នុងឱជារសដែលគប្បីដឹងបានដោយអណ្តាត... ក្នុងផោដ្ឋព្វៈដែលគប្បីដឹងបានដោយកាយ... ក្នុងធម្មារម្មណ៍ដែលគប្បីដឹងបានដោយចិត្ត ដែរឬទេ ។ ម្នាលសារីបុត្ត បើភិក្ខុពិចារណាដឹងយ៉ាងនេះថា អាត្មាអញបានចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត តាមផ្លូវណាក្តី បានត្រាច់ទៅដើម្បីបិណ្ឌបាតក្នុងប្រទេសណាក្តី បានត្រឡប់អំពីបិណ្ឌបាត ចេញអំពីស្រុកតាមផ្លូវណាក្តី ក្នុងផ្លូវទាំងនោះ អាត្មាអញ មានឆន្ទៈ ឬរាគៈ ទោសៈ ឬមោហៈ ឬក៏បដិឃៈនៃចិត្ត ក្នុងធម្មារម្មណ៍ដែលគប្បីដឹងបានដោយចិត្តដែរ ម្នាលសារីបុត្ត ភិក្ខុនោះ គប្បីព្យាយាមដើម្បីលះបង់អកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលសារីបុត្ត តែបើភិក្ខុពិចារណាដឹងយ៉ាងនេះវិញថា អាត្មាអញ បានចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាតតាមផ្លូវណាក្តី បានត្រាច់ទៅដើម្បីបិណ្ឌបាតក្នុងប្រទេសណាក្តី

យេន ច មគ្គេន គាមតោ បិណ្ឌាយ បដិក្កមឹ អត្ថិ មេ តត្ថ មនោវិញ្ញេយ្យេសុ ធម្មេសុ ឆន្ទោ វា រាគោ វា ទោសោ វា មោហោ វា បដិឃំ វាបិ ចេតសោតិ តេន សារីបុត្ត ភិក្ខុនា តេនេវ បីតិប្បាមុជ្ជេន វិហាតព្វំ អហោរត្តានុសិក្ខិនា កុសលេសុ ធម្មេសុ ។

[៣១៨] បុន ចបរំ សារីបុត្ត ភិក្ខុនា ឥតិ បដិសញ្ចិក្ខិតព្វំ បហីនា នុ ខោ មេ បញ្ច កាមគុណាតិ ។ សចេ សារីបុត្ត ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ អប្បហីនា ខោ មេ បញ្ច កាមគុណាតិ តេន សារីបុត្ត ភិក្ខុនា បញ្ចន្នំ កាមគុណានំ បហានាយ វាយមិតព្វំ ។ សចេ បន សារីបុត្ត ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ បហីនា ខោ មេ បញ្ច កាមគុណាតិ តេន សារីបុត្ត ភិក្ខុនា តេនេវ បីតិប្បាមុជ្ជេន វិហាតព្វំ អហោរត្តានុសិក្ខិនា កុសលេសុ ធម្មេសុ ។

បានត្រឡប់អំពីបិណ្ឌបាត ចេញអំពីស្រុកតាមផ្លូវណាក្តី ក្នុងផ្លូវទាំងនោះ អាត្មាអញ មិនមានឆន្ទៈ ឬរាគៈ ទោសៈ ឬមោហៈ ឬក៏បដិឃៈនៃចិត្ត ក្នុងធម្មារម្មណ៍ដែលគប្បីដឹងបានដោយចិត្តទេ ម្នាលសារីបុត្ត ភិក្ខុនោះ ត្រូវសិក្សាក្នុងកុសលធម៌ ទាំងថ្ងៃទាំងយប់ ហើយនៅដោយបីតិនិងបាមោជ្ជៈនោះឯង ។

[៣១៥] ម្នាលសារីបុត្ត មួយទៀត ភិក្ខុ គប្បីពិចារណាដូច្នេះថា កាមគុណ ៥ ប្រការ អាត្មាអញបានលះបង់ហើយឬ ។ ម្នាលសារីបុត្ត បើភិក្ខុពិចារណា ដឹងយ៉ាងនេះថា កាមគុណ ៥ ប្រការ អាត្មាអញមិនទាន់បានលះបង់ទេ ម្នាលសារីបុត្ត ភិក្ខុនោះ គប្បីព្យាយាមដើម្បីលះបង់នូវកាមគុណទាំង ៥ ប្រការចេញ ។ ម្នាលសារីបុត្ត តែបើភិក្ខុពិចារណាដឹងយ៉ាងនេះវិញថា កាមគុណទាំង ៥ ប្រការ អាត្មាអញលះបង់ហើយ ម្នាលសារីបុត្ត ភិក្ខុនោះ ត្រូវសិក្សាក្នុងកុសលធម៌ទាំងថ្ងៃទាំងយប់ នៅដោយបីតិនិងបាមោជ្ជៈនោះឯង ។

សឡាយតនវគ្គស្ស  បិណ្ឌបាតបារិសុទ្ធិសុត្តេ  នីវរណប្បញ្ញា

[២១៦] បុន ចបរំ សារីបុត្ត ភិក្ខុនា ឥតិ បដិ- សញ្ចិក្ខិតព្វំ បហីនា នុ ខោ មេ បញ្ច នីវរណាតិ ។ សចេ សារីបុត្ត ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ អប្បហីនា ខោ មេ បញ្ច នីវរណាតិ តេន សារីបុត្ត ភិក្ខុនា បញ្ចន្នំ នីវរណានំ បហានាយ វាយមិតព្វំ ។ សចេ បន សារីបុត្ត ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជា- នាតិ បហីនា ខោ មេ បញ្ច នីវរណាតិ តេន សារីបុត្ត ភិក្ខុនា តេនេវ បីតិប្បាមុជ្ជេន វិហាតព្វំ អហោរត្តានុសិក្ខិនា កុសលេសុ ធម្មេសុ ។

[៣១៧] បុន ចបរំ សារីបុត្ត ភិក្ខុនា ឥតិ បដិសញ្ចិក្ខិតព្វំ បរិញ្ញាតា នុ ខោ មេ ប- ញ្ចុបាទានក្ខន្ធាតិ ។ សចេ សារីបុត្ត ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ អបរិញ្ញាតា ខោ មេ បញ្ចុបាទានក្ខន្ធាតិ តេន សារីបុត្ត ភិក្ខុនា បញ្ចន្នំ ឧបាទានក្ខន្ធានំ បរិញ្ញាយ វាយមិតព្វំ ។

[៣១៦] ម្នាលសារីបុត្ត មួយទៀត ភិក្ខុ គប្បីពិចារណាដូច្នេះថា នីវរណៈទាំង ៥ ប្រការ អាត្មាអញបានលះបង់ហើយឬ ។ ម្នាលសារីបុត្ត បើភិក្ខុពិចារណា ដឹងយ៉ាងនេះថា នីវរណៈទាំង ៥ ប្រការ អាត្មាអញមិនទាន់បានលះបង់ទេ ម្នាលសារីបុត្ត ភិក្ខុនោះ គប្បីព្យាយាមដើម្បីលះបង់ នូវនីវរណៈទាំង ៥ ប្រការចេញ ។ ម្នាលសារីបុត្ត តែបើភិក្ខុពិចារណា ដឹងយ៉ាងនេះវិញថា នីវរណៈទាំង ៥ ប្រការ អាត្មាអញបានលះបង់ហើយ ម្នាលសារីបុត្ត ភិក្ខុនោះ ត្រូវសិក្សាក្នុងកុសលធម៌ ទាំងថ្ងៃទាំងយប់ នៅដោយបីតិនិងបាមោជ្ជៈនោះឯង ។

[៣១៧] ម្នាលសារីបុត្ត មួយទៀត ភិក្ខុ គប្បីពិចារណាដូច្នេះថា ឧបាទានក្ខន្ធទាំង ៥ ប្រការ អាត្មាអញកំណត់ដឹងហើយឬ ។ ម្នាលសារីបុត្ត បើភិក្ខុពិចារណា ដឹងយ៉ាងនេះថា ឧបាទានក្ខន្ធទាំង ៥ ប្រការ អាត្មាអញមិនទាន់កំណត់ដឹងទេ ម្នាលសារីបុត្ត ភិក្ខុនោះ គប្បីព្យាយាមដើម្បីកំណត់ដឹង នូវឧបាទានក្ខន្ធទាំង ៥ ប្រការ ។

សចេ បន សារីបុត្ត ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ បរិញ្ញាតា ខោ មេ បញ្ចុបាទានក្ខន្ធាតិ តេន សារីបុត្ត ភិក្ខុនា តេនេវ បីតិបាមុជ្ជេន វិហាតព្វំ អហោរត្តានុសិក្ខិនា កុសលេសុ ធម្មេសុ ។

[៣១៨] បុន ចបរំ សារីបុត្ត ភិក្ខុនា ឥតិ បដិសញ្ចិក្ខិតព្វំ ភាវិតា នុ ខោ មេ ចត្តារោ សតិបដ្ឋានាតិ ។ សចេ សារីបុត្ត ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ អភាវិតា ខោ មេ ចត្តារោ សតិបដ្ឋានាតិ តេន សារីបុត្ត ភិក្ខុនា ចតុន្នំ សតិបដ្ឋានានំ ភាវនាយ វាយមិតព្វំ ។ សចេ បន សារីបុត្ត ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ ភាវិតា ខោ មេ ចត្តារោ សតិបដ្ឋានាតិ តេន សារីបុត្ត ភិក្ខុនា តេនេវ បីតិបាមុជ្ជេន វិហាតព្វំ អហោរត្តានុសិក្ខិនា កុសលេសុ ធម្មេសុ ។

ម្នាលសារីបុត្ត តែបើភិក្ខុពិចារណា ដឹងយ៉ាងនេះវិញថា ឧបាទានក្ខន្ធទាំង ៥ ប្រការ អាត្មាអញបានកំណត់ដឹងហើយ ម្នាលសារីបុត្ត ភិក្ខុនោះ ត្រូវសិក្សាក្នុងកុសលធម៌ ទាំងថ្ងៃទាំងយប់ នៅដោយបីតិនិងបាមោជ្ជៈនោះឯង ។

[៣១៨] ម្នាលសារីបុត្ត មួយទៀត ភិក្ខុគប្បីពិចារណាដូច្នេះថា សតិប្បដ្ឋានទាំង ៤ ប្រការ អាត្មាអញបានចម្រើនហើយឬ ។ ម្នាលសារីបុត្ត បើភិក្ខុពិចារណាដឹងយ៉ាងនេះថា សតិប្បដ្ឋានទាំង ៤ ប្រការ អាត្មាអញមិនទាន់បានចម្រើនទេ ម្នាលសារីបុត្ត ភិក្ខុនោះគប្បីព្យាយាមដើម្បីចម្រើននូវសតិប្បដ្ឋាន ៤ ប្រការ ។ ម្នាលសារីបុត្ត តែបើភិក្ខុពិចារណា ដឹងយ៉ាងនេះវិញថា សតិប្បដ្ឋានទាំង ៤ ប្រការ អាត្មាអញបានចម្រើនហើយ ម្នាលសារីបុត្ត ភិក្ខុនោះ ត្រូវសិក្សាក្នុងកុសលធម៌ទាំងថ្ងៃទាំងយប់ នៅដោយបីតិនិងបាមោជ្ជៈនោះឯង ។

សឡាយតនវគ្គស្ស បិណ្ឌបាតបារិសុទ្ធិសុត្តេ ឥន្ទ្រិយប្បញ្ញា

[៣១៩] បុន ចបរំ សារីបុត្ត ភិក្ខុនា ឥតិ បដិសញ្ចិក្ខិតព្វំ ភាវិតា នុ ខោ មេ ចត្តារោ សម្មប្បធានាតិ ។ សចេ សារីបុត្ត ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ អភាវិតា ខោ មេ ចត្តារោ សម្មប្បធានាតិ តេន សារីបុត្ត ភិក្ខុនា ចតុន្នំ សម្មប្បធានានំ ភាវនាយ វាយមិតព្វំ ។ សចេ បន សារីបុត្ត ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ ភាវិតា ខោ មេ ចត្តារោ សម្មប្បធានាតិ តេន សារីបុត្ត ភិក្ខុនា តេនេវ បីតិប្បាមុជ្ជេន វិហាតព្វំ អហោរត្តានុសិក្ខិនា កុសលេសុ ធម្មេសុ ។

[៣២០] បុន ចបរំ សារីបុត្ត ភិក្ខុនា ឥតិ បដិសញ្ចិក្ខិតព្វំ ភាវិតា នុ ខោ មេ ចត្តារោ ឥទ្ធិបាទាតិ ។ សចេ សារីបុត្ត ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ អភាវិតា ខោ មេ ចត្តារោ ឥទ្ធិបាទា តេន សារីបុត្ត ភិក្ខុនា ចតុន្នំ ឥទ្ធិបាទានំ ភាវនាយ វាយមិតព្វំ ។ សចេ បន សារីបុត្ត ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ ភាវិតា ខោ មេ ចត្តារោ ឥទ្ធិបាទាតិ

[៣១៩] ម្នាលសារីបុត្ត មួយទៀត ភិក្ខុ គប្បីពិចារណាដូច្នេះថា សម្មប្បធានទាំង ៤ ប្រការ អាត្មាអញបានចម្រើនហើយឬ ។ ម្នាលសារីបុត្ត បើភិក្ខុពិចារណា ដឹងយ៉ាងនេះថា សម្មប្បធានទាំង ៤ ប្រការ អាត្មាអញមិនទាន់បានចម្រើនទេ ម្នាលសារីបុត្ត ភិក្ខុនោះ គប្បីព្យាយាមដើម្បីចម្រើននូវសម្មប្បធានទាំង ៤ ប្រការ ។ ម្នាលសារី-បុត្ត តែបើភិក្ខុពិចារណាដឹងយ៉ាងនេះវិញថា សម្មប្បធានទាំង ៤ ប្រ-ការ អាត្មាអញបានចម្រើនហើយ ម្នាលសារីបុត្ត ភិក្ខុនោះ ត្រូវសិក្សាក្នុងកុសលធម៌ ទាំងថ្ងៃទាំងយប់ នៅដោយបីតិនិងបាមោជ្ជៈនោះឯង ។

[៣២០] ម្នាលសារីបុត្ត មួយទៀត ភិក្ខុគប្បីពិចារណាដូច្នេះថា ឥទ្ធិបាទទាំង ៤ ប្រការ អាត្មាអញបានចម្រើនហើយឬ ។ ម្នាលសារីបុត្ត បើភិក្ខុពិចារណា ដឹងយ៉ាងនេះថា ឥទ្ធិបាទទាំង ៤ ប្រការ អាត្មាអញមិនទាន់បានចម្រើនទេ ម្នាលសារីបុត្ត ភិក្ខុនោះ គប្បីព្យាយាមដើម្បីចម្រើននូវឥទ្ធិបាទទាំង ៤ ប្រការ ។ ម្នាលសារីបុត្ត តែបើភិក្ខុពិចារណាដឹងយ៉ាងនេះវិញថា ឥទ្ធិបាទទាំង ៤ ប្រការ អាត្មាអញបានចម្រើនហើយ

តេន សារីបុត្ត ភិក្ខុនា តេនេវ បីតិប្បាមុជ្ជេន វិហា-
តព្វំ អហោរត្តានុសិក្ខិនា កុសលេសុ ធម្មេសុ ។

[៣២១] បុន ចបរំ សារីបុត្ត ភិក្ខុនា ឥតិ
បដិសញ្ចិក្ខិតព្វំ ភាវិតា នុ ខោ មេ បញ្ចិន្ទ្រិយានីតិ ។
សចេ សារីបុត្ត ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ
អភាវិតានិ ខោ មេ បញ្ចិន្ទ្រិយានីតិ តេន សារីបុត្ត
ភិក្ខុនា បញ្ចន្នំ ឥន្ទ្រិយានំ ភាវនាយ វាយមិតព្វំ ។
សចេ បន សារីបុត្ត ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជា-
នាតិ ភាវិតានិ ខោ មេ បញ្ចិន្ទ្រិយានីតិ តេន សា-
រីបុត្ត ភិក្ខុនា តេនេវ បីតិប្បាមុជ្ជេន វិហាតព្វំ អ-
ហោរត្តានុសិក្ខិនា កុសលេសុ ធម្មេសុ ។

[៣២២] បុន ចបរំ សារីបុត្ត ភិក្ខុនា ឥតិ
បដិសញ្ចិក្ខិតព្វំ ភាវិតានិ នុ ខោ មេ បញ្ច ព-
លានីតិ ។ សចេ សារីបុត្ត ភិក្ខុ បច្ចវេក្ខមានោ
ឯវំ ជានាតិ អភាវិតានិ ខោ មេ បញ្ច ពលានីតិ
តេន សារីបុត្ត ភិក្ខុនា បញ្ចន្នំ ពលានំ ភាវនាយ
វាយមិតព្វំ ។ សចេ បន សារីបុត្ត ភិក្ខុ បច្ចវេក្ខមានោ

ម្នាលសារីបុត្ត ភិក្ខុនោះ ត្រូវសិក្សាក្នុងកុសលធម៌ ទាំងថ្ងៃទាំងយប់ នៅដោយបីតិនិងបាមោជ្ជៈនោះឯង ។

[៣២១] ម្នាលសារីបុត្ត មួយទៀត ភិក្ខុ គប្បីពិចារណាដូច្នេះថា ឥន្ទ្រិយទាំង ៥ ប្រការ អាត្មាអញបានចម្រើនហើយឬ ។ ម្នាលសារីបុត្ត បើភិក្ខុពិចារណា ដឹងយ៉ាងនេះថា ឥន្ទ្រិយទាំង ៥ ប្រការ អាត្មាអញមិនទាន់បានចម្រើនទេ ម្នាលសារីបុត្ត ភិក្ខុនោះគប្បីព្យាយាម ដើម្បីចម្រើន នូវឥន្ទ្រិយទាំង ៥ ប្រការ ។ ម្នាលសារីបុត្ត តែបើភិក្ខុពិចារណា ដឹងយ៉ាងនេះវិញថា ឥន្ទ្រិយទាំង ៥ ប្រការ អាត្មាអញបានចម្រើនហើយ ម្នាលសារីបុត្ត ភិក្ខុនោះ ត្រូវសិក្សាក្នុងកុសលធម៌ ទាំងថ្ងៃទាំងយប់ នៅដោយបីតិនិងបាមោជ្ជៈនោះឯង ។

[៣២២] ម្នាលសារីបុត្ត មួយទៀត ភិក្ខុគប្បីពិចារណាដូច្នេះថា ពលៈទាំង ៥ ប្រការ អាត្មាអញបានចម្រើនហើយឬ ។ ម្នាលសារីបុត្ត បើភិក្ខុពិចារណា ដឹងយ៉ាងនេះថា ពលៈទាំង ៥ ប្រការ អាត្មាអញមិនទាន់បានចម្រើនទេ ម្នាលសារីបុត្ត ភិក្ខុនោះ គប្បីព្យាយាមដើម្បីចម្រើននូវពលៈទាំង ៥ ប្រការ ។ ម្នាលសារីបុត្ត តែបើភិក្ខុពិចារណា

ឯវំ ជានាតិ ភាវិតានិ ខោ មេ បញ្ច ពលានីតិ តេន សារីបុត្ត ភិក្ខុនា តេនេវ បីតិប្បាមុជ្ជេន វិហាតព្វំ អហោរត្តានុសិក្ខិនា កុសលេសុ ធម្មេសុ ។

[៣២៣] បុន ចបរំ សារីបុត្ត ភិក្ខុនា ឥតិ បដិសញ្ចិក្ខិតព្វំ ភាវិតា នុ ខោ មេ សត្ត ពោជ្ឈ-ង្គាតិ ។ សចេ សារីបុត្ត ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ អភាវិតា ខោ មេ សត្ត ពោជ្ឈង្គាតិ តេន សារីបុត្ត ភិក្ខុនា សត្តន្នំ ពោជ្ឈង្គានំ ភាវនាយ វាយមិតព្វំ ។ សចេ បន សារីបុត្ត ភិក្ខុ បច្ចវេក្ខ-មានោ ឯវំ ជានាតិ ភាវិតា ខោ មេ សត្ត ពោជ្ឈង្គាតិ តេន សារីបុត្ត ភិក្ខុនា តេនេវ បីតិប្បាមុជ្ជេន វិហា-តព្វំ អហោរត្តានុសិក្ខិនា កុសលេសុ ធម្មេសុ ។

ដឹងយ៉ាងនេះវិញថា ពលៈទាំង ៥ ប្រការ អាត្មាអញបានចម្រើនហើយ ម្នាលសារីបុត្ត ភិក្ខុនោះ ត្រូវសិក្សាក្នុងកុសលធម៌ ទាំងថ្ងៃទាំងយប់ នៅដោយបីតិនិងបាមោជ្ជៈនោះឯង ។

[៣២៣] ម្នាលសារីបុត្ត មួយទៀត ភិក្ខុ គប្បីពិចារណាដូច្នេះថា ពោជ្ឈង្គទាំង ៧ ប្រការ អាត្មាអញបានចម្រើនហើយឬ ។ ម្នាលសារីបុត្ត បើភិក្ខុពិចារណា ដឹងយ៉ាងនេះថា ពោជ្ឈង្គទាំង ៧ ប្រការ អាត្មាអញមិនទាន់បានចម្រើនទេ ម្នាលសារីបុត្ត ភិក្ខុនោះ គប្បីព្យាយាមដើម្បីចម្រើននូវពោជ្ឈង្គទាំង ៧ ប្រការ ។ ម្នាលសារីបុត្ត តែបើភិក្ខុពិចារណា ដឹងយ៉ាងនេះវិញថា ពោជ្ឈង្គទាំង ៧ ប្រការ អាត្មាអញបានចម្រើនហើយ ម្នាលសារីបុត្ត ភិក្ខុនោះ ត្រូវសិក្សាក្នុងកុសលធម៌ ទាំងថ្ងៃទាំងយប់ នៅដោយបីតិនិងបាមោជ្ជៈនោះឯង ។

[៣២៤] បុន ចបរំ សារីបុត្ត ភិក្ខុនា ឥតិ បដិសញ្ចិក្ខិតព្វំ ភាវិតោ នុ ខោ មេ អរិយោ អដ្ឋង្គិ-កោ មគ្គោតិ ។ សចេ សារីបុត្ត ភិក្ខុ បច្ចវេក្ខមា-នោ ឯវំ ជានាតិ អភាវិតោ ខោ មេ អរិយោ អដ្ឋង្គិ-កោ មគ្គោតិ តេន សារីបុត្ត ភិក្ខុនា អរិយស្ស អដ្ឋង្គិកស្ស មគ្គស្ស ភាវនាយ វាយមិតព្វំ ។ សចេ បន សារីបុត្ត ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ ភាវិតោ ខោ មេ អរិយោ អដ្ឋង្គិកោ មគ្គោតិ តេន សារីបុត្ត ភិក្ខុនា តេនេវ បីតិប្បាមុជ្ជេន វិហាតព្វំ អហោរត្តានុសិក្ខិនា កុសលេសុ ធម្មេសុ ។

[៣២៥] បុន ចបរំ សារីបុត្ត ភិក្ខុនា ឥតិ បដិ-សញ្ចិក្ខិតព្វំ ភាវិតា នុ ខោ មេ សមថោ ច វិបស្ស-នា ចាតិ ។ សចេ សារីបុត្ត ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ អភាវិតា ខោ មេ សមថោ ច វិបស្ស-នា ចាតិ តេន សារីបុត្ត ភិក្ខុនា សមថវិបស្សនានំ ភាវនាយ វាយមិតព្វំ ។ សចេ បន សារីបុត្ត ភិក្ខុ

[៣២៨] ម្នាលសារីបុត្ត មួយទៀត ភិក្ខុ គប្បីពិចារណាដូច្នេះថា អដ្ឋង្គិកមគ្គដ៏ប្រសើរ អាត្មាអញបានចម្រើនហើយឬ ។ ម្នាលសារីបុត្ត បើភិក្ខុពិចារណា ដឹងយ៉ាងនេះថា អដ្ឋង្គិកមគ្គដ៏ប្រសើរ អាត្មាអញមិនទាន់បានចម្រើនទេ ម្នាលសារីបុត្ត ភិក្ខុនោះ គប្បីព្យាយាមដើម្បីចម្រើននូវអដ្ឋង្គិកមគ្គដ៏ប្រសើរ ។ ម្នាលសារីបុត្ត តែបើភិក្ខុពិចារណា ដឹងយ៉ាងនេះវិញថា អដ្ឋង្គិកមគ្គដ៏ប្រសើរ អាត្មាអញបានចម្រើនហើយ ម្នាលសារីបុត្ត ភិក្ខុនោះ ត្រូវសិក្សាក្នុងកុសលធម៌ ទាំងថ្ងៃទាំងយប់ នៅដោយបីតិនិងបាមោជ្ជៈនោះឯង ។

[៣២៩] ម្នាលសារីបុត្ត មួយទៀត ភិក្ខុ គប្បីពិចារណាដូច្នេះថា សមថៈនិងវិបស្សនា អាត្មាអញបានចម្រើនហើយឬ ។ ម្នាលសារីបុត្ត បើភិក្ខុពិចារណា ដឹងយ៉ាងនេះថា សមថៈ និងវិបស្សនា អាត្មាអញមិនទាន់បានចម្រើនទេ ម្នាលសារីបុត្ត ភិក្ខុនោះ គប្បីព្យាយាមដើម្បីចម្រើននូវសមថៈនិងវិបស្សនា ។ ម្នាលសារីបុត្ត តែបើភិក្ខុ

បច្ចវេក្ខមានោ ឯវំ ជានាតិ ភាវិតា ខោ មេ សមថោ ច វិបស្សនា ចាតិ តេន សារីបុត្ត ភិក្ខុនា តេនេវ បីតិប្បាមុជ្ជេន វិហាតព្វំ អហោរត្តានុសិក្ខិនា កុសលេសុ ធម្មេសុ ។

[៣២៦] បុន ចបរំ សារីបុត្ត ភិក្ខុនា ឥតិ បដិសញ្ចិក្ខិតព្វំ សច្ឆិកតា នុ ខោ មេ វិជ្ជា ច វិមុត្តិ ចាតិ ។ សចេ សារីបុត្ត ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ អសច្ឆិកតា ខោ មេ វិជ្ជា ច វិមុត្តិ ចាតិ តេន សារីបុត្ត ភិក្ខុនា វិជ្ជាយ ច វិមុត្តិយា ច សច្ឆិកិរិយាយ វាយមិតព្វំ ។ សចេ បន សារីបុត្ត ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ សច្ឆិកតា ខោ មេ វិជ្ជា ច វិមុត្តិ ចាតិ តេន សារីបុត្ត ភិក្ខុនា តេនេវ បីតិប្បាមុជ្ជេន វិហាតព្វំ អហោរត្តានុសិក្ខិនា កុសលេសុ ធម្មេសុ ។

ពិចារណា ដឹងយ៉ាងនេះវិញថា សមថៈនិងវិបស្សនា អាត្មាអញបាន ចម្រើនហើយ ម្នាលសារីបុត្ត ភិក្ខុនោះ ត្រូវសិក្សាក្នុងកុសលធម៌ ទាំងថ្ងៃទាំងយប់ នៅដោយបីតិនិងបាមោជ្ជៈនោះឯង ។

[៣២៦] ម្នាលសារីបុត្ត មួយវិញទៀត ភិក្ខុគប្បីពិចារណា ដូច្នេះថា វិជ្ជានិងវិមុត្តិ អាត្មាអញបានធ្វើឲ្យជាក់ច្បាស់ហើយឬ ។ ម្នាលសារីបុត្ត បើភិក្ខុពិចារណា ដឹងយ៉ាងនេះថា វិជ្ជានិងវិមុត្តិ អាត្មា អញមិនទាន់បានធ្វើឲ្យជាក់ច្បាស់ទេ ម្នាលសារីបុត្ត ភិក្ខុនោះ គប្បី ព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវវិជ្ជានិងវិមុត្តិ ។ ម្នាលសារីបុត្ត តែបើ ភិក្ខុពិចារណា ដឹងយ៉ាងនេះវិញថា វិជ្ជានិងវិមុត្តិ អាត្មាអញបានធ្វើឲ្យ ជាក់ច្បាស់ហើយ ម្នាលសារីបុត្ត ភិក្ខុនោះ ត្រូវសិក្សាក្នុងកុសលធម៌ ទាំងថ្ងៃទាំងយប់ នៅដោយបីតិនិងបាមោជ្ជៈនោះឯង ។

[៣២៧] យេ ហិ កេចិ សារីបុត្ត អតីតមទ្ធានំ សមណា វា ព្រាហ្មណា វា បិណ្ឌបាតំ បរិសោធេសុំ សព្វេ តេ ឯវមេវ បច្ចវេក្ខិត្វា បច្ចវេក្ខិត្វា បិណ្ឌបាតំ បរិសោធេសុំ ។ យេ ហិ កេចិ សារីបុត្ត អនាគតមទ្ធានំ សមណា វា ព្រាហ្មណា វា បិណ្ឌបាតំ បរិសោធេស្សន្តិ សព្វេ តេ ឯវមេវ បច្ចវេក្ខិត្វា បច្ចវេក្ខិត្វា បិណ្ឌបាតំ បរិសោធេស្សន្តិ ។ យេ ហិ កេចិ សារីបុត្ត ឯតរហិ សមណា វា ព្រាហ្មណា វា បិណ្ឌបាតំ បរិសោធេន្តិ សព្វេ តេ ឯវមេវ បច្ចវេក្ខិត្វា បច្ចវេក្ខិត្វា បិណ្ឌបាតំ បរិសោធេន្តិ ។ តស្មាតិហ វោ សារីបុត្ត សិក្ខិតព្វំ[១] បច្ចវេក្ខិត្វា បច្ចវេក្ខិត្វា បិណ្ឌបាតំ បរិសោធេស្សាមាតិ ឯវញ្ហិ វោ សារីបុត្ត សិក្ខិតព្វន្តិ ។ ឥទមវោច ភគវា អត្តមនោ អាយស្មា សារីបុត្តោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

បិណ្ឌបាតបារិសុទ្ធិសុត្តំ នវមំ និដ្ឋិតំ ។

---

១ ឱ. តេន ហិ វោ សារីបុត្ត ឯវំ សិក្ខិតព្វន្តិ ទិស្សតិ ។

[៣២៧] ម្នាលសារីបុត្ត បុគ្គលណាមួយ ជាសមណៈ ឬព្រាហ្មណ៍ ក្នុងអតីតកាល កាលនឹងធ្វើបិណ្ឌបាតឲ្យបរិសុទ្ធ បុគ្គលទាំងអស់នោះ សុទ្ធតែបានពិចារណារឿយ ៗ ហើយធ្វើបិណ្ឌបាតឲ្យបរិសុទ្ធ យ៉ាងនេះឯង ។ ម្នាលសារីបុត្ត បុគ្គលណាមួយ ជាសមណៈ ឬ ព្រាហ្មណ៍ ក្នុងអនាគតកាល កាលនឹងធ្វើបិណ្ឌបាតឲ្យបរិសុទ្ធ បុគ្គលទាំងអស់នោះ នឹងពិចារណារឿយ ៗ ហើយធ្វើបិណ្ឌបាតឲ្យបរិសុទ្ធ យ៉ាងនេះឯង ។ ម្នាលសារីបុត្ត បុគ្គលណាមួយជាសមណៈឬព្រាហ្មណ៍ ក្នុងកាលឥឡូវនេះ កាលនឹងធ្វើបិណ្ឌបាតឲ្យបរិសុទ្ធ បុគ្គលទាំងអស់នោះ តែងពិចារណារឿយ ៗ ហើយធ្វើបិណ្ឌបាតឲ្យបរិសុទ្ធ យ៉ាងនេះឯង ម្នាលសារីបុត្ត ព្រោះហេតុនោះ អ្នកទាំងឡាយត្រូវសិក្សាក្នុងសាសនានេះថា យើងទាំងឡាយនឹងពិចារណារឿយ ៗ ហើយធ្វើបិណ្ឌបាតឲ្យបរិសុទ្ធដូច្នេះ ម្នាលសារីបុត្ត អ្នកទាំងឡាយត្រូវតែសិក្សា យ៉ាងនេះឯង ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ ព្រះសារីបុត្តមានអាយុមានសេចក្តីត្រេកអរ រីករាយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ បិណ្ឌបាតបារិសុទ្ធិសូត្រ ទី ៩ ។

# ទសមំ ឥន្ទ្រិយភាវនាសុត្តំ

[៣២៨] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កជង្គលាយំ[១] វិហរតិ វេឡុវនេ ។ អថខោ ឧត្តរោ មាណវោ បារាសិរិយន្តេវាសី[២] យេន ភគវា តេនុ-បសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯក-មន្តំ និសីទិ ។

[៣២៩] ឯកមន្តំ និសិន្នំ ខោ ឧត្តរំ មាណវំ បារាសិរិយន្តេវាសឹ ភគវា ឯតទវោច ទេសេតិ ឧត្តរ បារាសិរិយោ ព្រាហ្មណោ សាវកានំ ឥន្ទ្រិយភាវនន្តិ ។ ទេសេតិ ភោ គោតម បារាសិរិយោ ព្រាហ្មណោ សា-វកានំ ឥន្ទ្រិយភាវនន្តិ ។ យថាកថំ[៣] ឧត្តរ ទេសេតិ បារាសិរិយោ ព្រាហ្មណោ សាវកានំ ឥន្ទ្រិយភាវនន្តិ ។ ឥធ ភោ គោតម ចក្ខុនា រូបំ ន បស្សតិ

១ ម. ជង្គលាយំ ។ ២ ម. បារាសិរិយន្តេវាសី ។ ៣ ឱ. ម. យថាកថំ បន ។

# ឥន្ទ្រិយភាវនាសូត្រ ទី ១០

[៣២៨] ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងព្រៃឫស្សី ជិតកជង្គលនិគម ។ គ្រានោះឯង ឧត្តរមាណព ជាកូនសិស្សរបស់បារាសិរិយព្រាហ្មណ៍ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏រីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។

[៣២៩] លុះឧត្តរមាណព ជាកូនសិស្ស របស់បារាសិរិយព្រាហ្មណ៍ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគ ត្រាស់សួរដូច្នេះថា ម្នាលឧត្តរៈ បារាសិរិយព្រាហ្មណ៍ តែងសំដែងវិធីចម្រើនឥន្ទ្រិយរបស់សាវ័កទាំងឡាយ មែនឬ ។ ឧត្តរមាណពក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន បារាសិរិយព្រាហ្មណ៍ តែងសំដែងវិធីចម្រើនឥន្ទ្រិយរបស់សាវ័កទាំងឡាយមែន ។ ព្រះអង្គត្រាស់សួរថា ម្នាលឧត្តរៈ ចុះបារាសិរិយព្រាហ្មណ៍ តែងសំដែងវិធីចម្រើនឥន្ទ្រិយរបស់សាវ័កទាំងឡាយ តើដូចម្តេច ។ បពិត្រព្រះគោតមដ៏ចម្រើន បារាសិរិយព្រាហ្មណ៍សំដែងថា បុគ្គលក្នុងលោកនេះ កុំមើល[១] រូបដោយភ្នែក

១ មិនគប្បីមើល ។ អដ្ឋកថា ។

សោតេន សទ្ទំ ន សុណាតីតិ ឯវំ ខោ ភោ គោតម ទេសេតិ បារាសិរិយោ ព្រាហ្មណោ សាវកានំ ឥន្ទ្រិយ-ភាវនន្តិ ។ ឯវំ សន្តេ ខោ ឧត្តរ អន្ធោ ភាវិតិន្ទ្រិយោ ភវិស្សតិ ពធិរោ ភាវិតិន្ទ្រិយោ ភវិស្សតិ យថា បារា-សិរិយស្ស ព្រាហ្មណស្ស វចនំ អន្ធោ ហិ ឧត្តរ ចក្ខុនា រូបំ ន បស្សតិ ពធិរោ សោតេន សទ្ទំ ន សុណាតីតិ ។ ឯវំ វុត្តេ ឧត្តរោ មាណវោ បារាសិរិយន្តេវាសី តុណ្ហីភូតោ មង្កុភូតោ បត្តក្ខន្ធោ អធោមុខោ បជ្ឈាយន្តោ អប្បដិភាណោ និសីទិ ។

កុំស្តាប់[១] សំឡេងដោយត្រចៀក បពិត្រព្រះគោតមដ៏ចម្រើន ឯបារាសិរិយព្រាហ្មណ៍ តែងសំដែងនូវវិធីចម្រើនឥន្ទ្រិយរបស់សាវ័កទាំងឡាយយ៉ាងនេះឯង ។ ឱឧត្តរៈ កាលបើយ៉ាងនេះ បុគ្គលខ្វាក់នឹងបាននាមថាជាអ្នកចម្រើនឥន្ទ្រិយហើយ បុគ្គលថ្លង់នឹងបាននាមថាជាអ្នកចម្រើនឥន្ទ្រិយហើយ ទើបសមនឹងពាក្យរបស់បារាសិរិយព្រាហ្មណ៍ ម្នាលឧត្តរៈ ព្រោះថា បុគ្គលខ្វាក់ មិនឃើញរូបដោយភ្នែកទេ បុគ្គលថ្លង់ មិនឮសំឡេងដោយត្រចៀកទេ ។ កាលព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ឧត្តរមាណពជាកូនសិស្សបារាសិរិយព្រាហ្មណ៍ ក៏អង្គុយនៅស្ងៀម អៀនអន់ ឱនក ដាក់មុខជ្រប់ មិននិយាយ ។

---

១ មិនគប្បីស្តាប់ ។ អដ្ឋកថា ។

[៣៣០] អថខោ ភគវា ឧត្តរំ មាណវំ បារាសិរិយន្តេវាសឹ តុណ្ហីភូតំ មង្កុភូតំ បត្តក្ខន្ធំ អធោមុខំ បជ្ឈាយន្តំ អប្បដិភាណំ វិទិត្វា អាយស្មន្តំ អានន្ទំ អាមន្តេសិ អញ្ញថា ខោ អានន្ទ ទេសេតិ បារាសិរិយោ ព្រាហ្មណោ ច[១] សាវកានំ ឥន្ទ្រិយភាវនំ អញ្ញថា ច បន អរិយស្ស វិនយេ អនុត្តរា ឥន្ទ្រិយភាវនា ហោតីតិ ។ ឯតស្ស ភគវា កាលោ ឯតស្ស សុគត កាលោ យំ ភគវា អរិយស្ស វិនយេ អនុត្តរំ ឥន្ទ្រិយភាវនំ ទេសេយ្យ ភគវតោ សុត្វា ភិក្ខូ ធារេស្សន្តីតិ ។ តេនហានន្ទ សុណាហិ សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវម្ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បច្ចស្សោសិ ។

---

១ ឱ. ម. ចសទ្ទោ ន ទិស្សតិ ។

សឡាយតនវគ្គ ឥន្ទ្រិយភាវនាសូត្រ ការនិមន្តរបស់ព្រះអានន្ទ

[៣៣០] គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ជ្រាបថា ឧត្តរមាណព ជាសិស្សរបស់បារាសិរិយព្រាហ្មណ៍ អង្គុយនៅស្ងៀម អៀនអន់ ឱនក ដាក់មុខជ្រប់ មិននិយាយហើយ ទើបត្រាស់ហៅព្រះអានន្ទមានអាយុថា ម្នាលអានន្ទ បារាសិរិយព្រាហ្មណ៍ តែងសំដែងនូវវិធីចម្រើនឥន្ទ្រិយ របស់សាវ័កទាំងឡាយ ផ្សេង ចំណែកការចម្រើនឥន្ទ្រិយដ៏ប្រសើរ ក្នុងវិន័យរបស់ព្រះអរិយៈ ផ្សេង ។ ព្រះអានន្ទក្រោបបង្គំទូលថា ព្រះមានព្រះភាគ គប្បីសំដែងនូវវិធីចម្រើនឥន្ទ្រិយដ៏ប្រសើរណា ក្នុងវិន័យរបស់ព្រះអរិយៈ បពិត្រព្រះមានព្រះភាគ កាលនេះ ជាកាលគួរនឹងសំដែងនូវវិធីចម្រើនឥន្ទ្រិយនុ៎ះ បពិត្រព្រះសុគត កាលនេះ ជាកាលគួរនឹងសំដែងនូវវិធីចម្រើនឥន្ទ្រិយនុ៎ះ ភិក្ខុទាំងឡាយ បានស្តាប់ព្រះពុទ្ធដីការបស់ព្រះអង្គហើយ នឹងចងចាំបាន ។ ព្រះអង្គត្រាស់ថា ម្នាលអានន្ទ បើដូច្នោះ អ្នកចូរស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ព្រះអានន្ទមានអាយុក៏ទទួលព្រះបន្ទូលនៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[៣៣១] ភគវា ឯតទវោច កថញ្ច អានន្ទ[១] អរិយស្ស វិនយេ អនុត្តរា ឥន្ទ្រិយភាវនា ហោតិ ។ ឥធានន្ទ ភិក្ខុនោ ចក្ខុនា រូបំ ទិស្វា ឧប្បជ្ជតិ មនាបំ ឧប្បជ្ជតិ អមនាបំ ឧប្បជ្ជតិ មនាបាមនាបំ ។ សោ ឯវំ បជានាតិ ឧប្បន្នំ ខោ មេ ឥទំ មនាបំ ឧប្បន្នំ អមនាបំ ឧប្បន្នំ មនាបាមនាបំ តញ្ច ខោ សង្ខតំ ឱឡារិកំ បដិច្ច សមុប្បន្នំ ឯតំ សន្តំ ឯតំ បណីតំ យទិទំ ឧបេក្ខាតិ ។ តស្ស តំ ឧប្បន្នំ មនាបំ ឧប្បន្នំ អមនាបំ ឧប្បន្នំ មនាបាមនាបំ និរុជ្ឈតិ ឧបេក្ខា សណ្ឋាតិ ។

---

១ ឱ. កថំ បនានន្ទ ។ ម. កថញ្ចានន្ទ ។

[៣៣១] ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរ ដូច្នេះថា ម្នាលអានន្ទ ចុះការចម្រើនឥន្ទ្រិយដ៏ប្រសើរ ក្នុងវិន័យរបស់ព្រះអរិយៈ តើដូចម្តេច ។ ទ្រង់ឆ្លើយដោយព្រះអង្គឯងថា ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ មានសេចក្តីគាប់ចិត្តកើតឡើង មានសេចក្តីមិនគាប់ចិត្តកើតឡើង មានសេចក្តីគាប់ចិត្តខ្លះមិនគាប់ចិត្តខ្លះ កើតឡើង ព្រោះឃើញរូបដោយភ្នែក ។ ភិក្ខុនោះ ដឹងច្បាស់យ៉ាងនេះថា អាត្មាអញ មានសេចក្តីគាប់ចិត្តនេះកើតឡើងហើយ មានសេចក្តីមិនគាប់ចិត្តនេះកើតឡើងហើយ មានសេចក្តីគាប់ចិត្តខ្លះមិនគាប់ចិត្តខ្លះនេះ កើតឡើងហើយ ឯវិបស្សនូបេក្ខាដ៏ល្អិត ដ៏ឧត្តម ក៏កើតឡើង ព្រោះអាស្រ័យសេចក្តីគាប់ចិត្តជាដើម ដែលជារបស់មានបច្ច័យតាក់តែង ជារបស់គ្រោតគ្រាតនោះឯង ។ លុះភិក្ខុនោះមានសេចក្តីគាប់ចិត្តនោះកើតឡើង មានសេចក្តីមិនគាប់ចិត្តនោះកើតឡើង មានសេចក្តីគាប់ចិត្តខ្លះមិនគាប់ចិត្តខ្លះនោះកើតឡើង ហើយរលត់ទៅវិញ វិបស្សនូបេក្ខា ក៏តាំងឡើង ។

សេយ្យថាបិ អានន្ទ ចក្ខុមា បុរិសោ ឧម្មិលេត្វា វា និម្មិលេយ្យ និម្មិលេត្វា វា ឧម្មិលេយ្យ ឯវមេវ ខោ អានន្ទ យស្ស កស្សចិ ឯវំ សីឃំ ឯវំ តុវដំ ឯវំ អប្បកសិរេន ឧប្បន្នំ មនាបំ ឧប្បន្នំ អមនាបំ ឧប្បន្នំ មនាបាមនាបំ និរុជ្ឈតិ ឧបេក្ខា សណ្ឋាតិ អយំ វុច្ចតានន្ទ អរិយស្ស វិនយេ អនុត្តរា ឥន្ទ្រិយភាវនា ចក្ខុវិញ្ញេយ្យេសុ រូបេសុ ។

[៣៣២] បុន ចបរំ អានន្ទ ភិក្ខុនោ សោតេន សទ្ទំ សុត្វា ឧប្បជ្ជតិ មនាបំ ឧប្បជ្ជតិ អមនាបំ ឧប្បជ្ជតិ មនាបាមនាបំ ។ សោ

ម្នាលអានន្ទ បុរសមានភ្នែកភ្លឺ បើកហើយបិទវិញ ឬបិទហើយបើកវិញ មានឧបមាយ៉ាងណាមិញ ម្នាលអានន្ទ បុគ្គលណាមួយ មានសេចក្ដីគាប់ចិត្តកើតឡើង មានសេចក្ដីមិនគាប់ចិត្តកើតឡើង មានសេចក្ដីគាប់ចិត្តខ្វះមិនគាប់ចិត្តខ្វះកើតឡើង ហើយរលត់ទៅវិញ ឯវិបស្សនូបេក្ខាក៏តាំងឡើង ដោយឆាប់យ៉ាងនេះ រហ័សយ៉ាងនេះ មិនមានសេចក្ដីលំបាកយ៉ាងនេះ ក៏មានឧបមេយ្យយ៉ាងនោះឯង ម្នាលអានន្ទ នេះឯងតថាគតហៅថា ការចម្រើននូវឥន្ទ្រិយដ៏ប្រសើរ ក្នុងរូបដែលគប្បីដឹងបានដោយភ្នែក ក្នុងវិន័យរបស់ព្រះអរិយៈ ។

[៣៣២] ម្នាលអានន្ទ មួយទៀត ភិក្ខុមានសេចក្ដីគាប់ចិត្តកើតឡើង មានសេចក្ដីមិនគាប់ចិត្តកើតឡើង មានសេចក្ដីគាប់ចិត្តខ្វះមិនគាប់ចិត្តខ្វះ កើតឡើង ព្រោះស្ដាប់សំឡេងដោយត្រចៀក ។ ភិក្ខុនោះ

ឯវំ បជានាតិ ឧប្បន្នំ ខោ មេ ឥទំ មនាបំ ឧប្បន្នំ អមនាបំ ឧប្បន្នំ មនាបាមនាបំ តញ្ច ខោ សង្ខតំ ឱឡារិកំ បដិច្ច សមុប្បន្នំ ឯតំ សន្តំ ឯតំ បណីតំ យទិទំ ឧបេក្ខាតិ ។ តស្ស តំ ឧប្បន្នំ មនាបំ ឧប្បន្នំ អមនាបំ ឧប្បន្នំ មនាបាមនាបំ និរុជ្ឈតិ ឧបេក្ខា សណ្ឋាតិ ។ សេយ្យថាបិ អានន្ទ ពលវា បុរិសោ អប្បកសិរេន អច្ឆរិកំ បហារេយ្យ ឯវមេវ ខោ អានន្ទ យស្ស កស្សចិ ឯវំ សីឃំ ឯវំ តុវដំ ឯវំ អប្បកសិរេន ឧប្បន្នំ មនាបំ ឧប្បន្នំ អមនាបំ ឧប្បន្នំ មនាបាមនាបំ និរុជ្ឈតិ ឧបេក្ខា សណ្ឋាតិ អយំ វុច្ចតានន្ទ អរិយស្ស វិនយេ អនុត្តរា ឥន្ទ្រិយ-ភាវនា សោតវិញ្ញេយ្យេសុ សទ្ទេសុ ។

ដឹងច្បាស់យ៉ាងនេះថា អាត្មាអញ មានសេចក្តីគាប់ចិត្តនេះកើតឡើង ហើយ មានសេចក្តីមិនគាប់ចិត្តនេះកើតឡើងហើយ មានសេចក្តីគាប់ចិត្ត ខ្លះមិនគាប់ចិត្តខ្លះនេះកើតឡើងហើយ ឯវិបស្សនូបេក្ខាដ៏ល្អិត ដ៏ឧត្តម ក៏កើតឡើង ព្រោះអាស្រ័យសេចក្តីគាប់ចិត្តជាដើម ដែលជារបស់មាន បច្ច័យតាក់តែង ជារបស់គ្រោតគ្រាតនោះឯង ។ លុះភិក្ខុនោះ មានសេច-ក្តីគាប់ចិត្តនោះកើតឡើង មានសេចក្តីមិនគាប់ចិត្តនោះកើតឡើង មាន សេចក្តីគាប់ចិត្តខ្លះមិនគាប់ចិត្តខ្លះនោះ កើតឡើង ហើយរលត់ទៅវិញ វិបស្សនូបេក្ខាក៏តាំងឡើង ។ ម្នាលអានន្ទ បុរសមានកម្លាំង ទះម្រាម ដៃដោយមិនលំបាកយ៉ាងណាមិញ ម្នាលអានន្ទ បុគ្គលណាមួយ មាន សេចក្តីគាប់ចិត្តកើតឡើង មានសេចក្តីមិនគាប់ចិត្តកើតឡើង មានសេចក្តី គាប់ចិត្តខ្លះមិនគាប់ចិត្តខ្លះ កើតឡើង ហើយរលត់ទៅវិញ វិបស្សនូ-បេក្ខាក៏តាំងឡើង ដោយឆាប់យ៉ាងនេះ រហ័សយ៉ាងនេះ មិនមាន សេចក្តីលំបាកយ៉ាងនេះ ក៏មានឧបមេយ្យយ៉ាងនោះឯង ម្នាលអានន្ទ នេះឯងតថាគតហៅថា ការចម្រើនឥន្ទ្រិយដ៏ប្រសើរក្នុងសំឡេង ដែល គប្បីដឹងបានដោយត្រចៀក ក្នុងវិន័យរបស់ព្រះអរិយៈ ។

[៣៣៣] បុន ចបរំ អានន្ទ ភិក្ខុនោ ឃានេន គន្ធំ ឃាយិត្វា ឧប្បជ្ជតិ មនាបំ ឧប្បជ្ជតិ អមនាបំ ឧប្បជ្ជតិ មនាបាមនាបំ ។ សោ ឯវំ បជានាតិ ឧប្បន្នំ ខោ មេ ឥទំ មនាបំ ឧប្បន្នំ អមនាបំ ឧប្បន្នំ មនាបាមនាបំ តញ្ច ខោ សង្ខតំ ឱឡារិកំ បដិច្ច សមុប្បន្នំ ឯតំ សន្តំ ឯតំ បណីតំ យទិទំ ឧបេក្ខាតិ ។ តស្ស តំ ឧប្បន្នំ មនាបំ ឧប្បន្នំ អមនាបំ ឧប្បន្នំ មនាបាមនាបំ និរុជ្ឈតិ ឧបេក្ខា សណ្ឋាតិ ។ សេយ្យថាបិ អានន្ទ ឦសកចោណេ បទុមិនិបត្តេ ឧទកផុសិតានិ បវត្តន្តិ[១] ន សណ្ឋន្តិ ឯវមេវ ខោ អានន្ទ យស្ស កស្សចិ ឯវំ សីឃំ ឯវំ តុវដំ ឯវំ អប្បកសិរេន ឧប្បន្នំ មនាបំ ឧប្បន្នំ អមនាបំ ឧប្បន្នំ មនាបាមនាបំ និរុជ្ឈតិ ឧបេក្ខា សណ្ឋាតិ

១ ម. ឦសកំបោណេ ឧទកផុសិតានិ បវត្តេន្តីតិ ទិស្សតិ ។

សឡាយតនវគ្គ ឥន្ទ្រិយភាវនាសូត្រ ការចម្រើននូវឥន្ទ្រិយ

[៣៣៣] ម្នាលអានន្ទ មួយទៀត ភិក្ខុមានសេចក្តីគាប់ចិត្តកើតឡើង មានសេចក្តីមិនគាប់ចិត្តកើតឡើង មានសេចក្តីគាប់ចិត្តខ្លះមិនគាប់ចិត្តខ្លះកើតឡើង ព្រោះធុំក្លិនដោយច្រមុះ ។ ភិក្ខុនោះរមែងដឹងច្បាស់យ៉ាងនេះថា អាត្មាអញមានសេចក្តីគាប់ចិត្តនេះកើតឡើងហើយ មានសេចក្តីមិនគាប់ចិត្តនេះកើតឡើងហើយ មានសេចក្តីគាប់ចិត្តខ្លះមិនគាប់ចិត្តខ្លះនេះកើតឡើងហើយ ឯវិបស្សនូបេក្ខា ដ៏ល្អិត ដ៏ឧត្តម ក៏កើតឡើងព្រោះអាស្រ័យសេចក្តីគាប់ចិត្តជាដើម ដែលជារបស់មានបច្ច័យតាក់តែងជារបស់គ្រោតគ្រាតនោះឯង ។ លុះភិក្ខុនោះ មានសេចក្តីគាប់ចិត្តនោះកើតឡើង មានសេចក្តីមិនគាប់ចិត្តនោះកើតឡើង មានសេចក្តីគាប់ចិត្តខ្លះមិនគាប់ចិត្តខ្លះនោះកើតឡើង ហើយរលត់ទៅវិញ វិបស្សនូបេក្ខាក៏តាំងឡើង ។ ម្នាលអានន្ទ តំណក់ទឹក រមៀលលើស្លឹកឈូកដែលផ្អៀងបន្តិច រមែងមិនដក់នៅ មានឧបមាយ៉ាងណាមិញ ម្នាលអានន្ទ បុគ្គលណាមួយ មានសេចក្តីគាប់ចិត្តកើតឡើង មានសេចក្តីមិនគាប់ចិត្តកើតឡើង មានសេចក្តីគាប់ចិត្តខ្លះមិនគាប់ចិត្តខ្លះ កើតឡើង ហើយរលត់ទៅវិញ វិបស្សនូបេក្ខា ក៏តាំងឡើង ដោយឆាប់យ៉ាងនេះ រហ័សយ៉ាងនេះ មិនមានសេចក្តីលំបាកយ៉ាងនេះ ក៏មានឧបមេយ្យយ៉ាងនោះឯង

អយំ វុច្ចតានន្ទ អរិយស្ស វិនយេ អនុត្តរា ឥន្ទ្រិយ-ភាវនា ឃានវិញ្ញេយ្យេសុ គន្ធេសុ ។

[៣៣៤] បុន ចបរំ អានន្ទ ភិក្ខុនោ ជិវ្ហាយ រសំ សាយិត្វា ឧប្បជ្ជតិ មនាបំ ឧប្បជ្ជតិ អមនាបំ ឧប្បជ្ជតិ មនាបាមនាបំ ។ សោ ឯវំ បជានាតិ ឧប្បន្នំ ខោ មេ ឥទំ មនាបំ ឧប្បន្នំ អមនាបំ ឧប្បន្នំ មនាបាមនាបំ តញ្ច ខោ សង្ខតំ ឱឡារិកំ បដិច្ច សមុប្បន្នំ ឯតំ សន្តំ ឯតំ បណីតំ យទិទំ ឧបេក្ខាតិ ។ តស្ស តំ ឧប្បន្នំ មនាបំ ឧប្បន្នំ អមនាបំ ឧប្បន្នំ មនាបាមនាបំ និរុជ្ឈតិ

ម្នាលអានន្ទ នេះឯងតថាគតហៅថា ការចម្រើនឥន្ទ្រិយដ៏ប្រសើរក្នុងក្បួនដែលគប្បីដឹងបានដោយច្រមុះ ក្នុងវិន័យរបស់ព្រះអរិយៈ ។

[៣៣៤] ម្នាលអានន្ទ មួយទៀត ភិក្ខុមានសេចក្តីគាប់ចិត្តកើតឡើង មានសេចក្តីមិនគាប់ចិត្តកើតឡើង មានសេចក្តីគាប់ចិត្តខ្លះសេចក្តីមិនគាប់ចិត្តខ្លះកើតឡើង ព្រោះទទួលរសដោយអណ្តាត ។ ភិក្ខុនោះដឹងច្បាស់យ៉ាងនេះថា អាត្មាអញ មានសេចក្តីគាប់ចិត្តនេះកើតឡើងហើយ មានសេចក្តីមិនគាប់ចិត្តនេះកើតឡើងហើយ មានសេចក្តីគាប់ចិត្តខ្លះមិនគាប់ចិត្តខ្លះនេះកើតឡើងហើយ ឯវិបស្សនូបេក្ខា ដ៏ល្អិត ដ៏ឧត្តម ក៏កើតឡើង ព្រោះអាស្រ័យសេចក្តីគាប់ចិត្តជាដើម ដែលជារបស់មានបច្ច័យតាក់តែង ជារបស់គ្រោតគ្រាតនោះឯង ។ លុះភិក្ខុនោះ មានសេចក្តីគាប់ចិត្តនោះកើតឡើង មានសេចក្តីមិនគាប់ចិត្តនោះកើតឡើង មានសេចក្តីគាប់ចិត្តខ្លះមិនគាប់ចិត្តខ្លះនោះ កើតឡើង ហើយរលត់ទៅវិញ

**៣៧៧**

សឡាយតនវគ្គស្ស ឥន្ទ្រិយភាវនាសុត្តេ ឥន្ទ្រិយភាវនា

ឧបេក្ខា សណ្ឋាតិ ។ សេយ្យថាបិ អានន្ទ ពលវា បុរិសោ ជិវ្ហគ្គេ ខេឡបិណ្ឌំ សំយូហិត្វា អប្បកសិរេន វមេយ្យ[១] ឯវមេវ ខោ អានន្ទ យស្ស កស្សចិ ឯវំ សីឃំ ឯវំ តុរិតំ ឯវំ អប្បកសិរេន ឧប្បន្នំ មនាបំ ឧប្បន្នំ អមនាបំ ឧប្បន្នំ មនាបាមនាបំ និរុជ្ឈតិ ឧបេក្ខា សណ្ឋាតិ អយំ វុច្ចតានន្ទ អរិយស្ស វិនយេ អនុត្តរា ឥន្ទ្រិយភាវនា ជិវ្ហាវិញ្ញេយ្យេសុ រសេសុ ។

---

១ ម. សន្ធមេយ្យ ។

ឯវិបស្សនូបេក្ខា ក៏តាំងឡើង ។ ម្នាលអានន្ទ បុរសមានកម្លាំង ប្រមូលដុំទឹកមាត់មកលើចុងអណ្តាត ហើយស្តោះ ដោយមិនលំបាក មានឧបមាយ៉ាងណាមិញ ម្នាលអានន្ទ បុគ្គលណាមួយ មានសេចក្តីគាប់ចិត្តកើតឡើង មានសេចក្តីមិនគាប់ចិត្តកើតឡើង មានសេចក្តីគាប់ចិត្តខ្លះមិនគាប់ចិត្តខ្លះ កើតឡើង ហើយរលត់ទៅវិញ ឯវិបស្សនូ-បេក្ខា ក៏តាំងឡើង ដោយឆាប់យ៉ាងនេះ រហ័សយ៉ាងនេះ មិនមានលំបាកយ៉ាងនេះ ក៏មានឧបមេយ្យយ៉ាងនោះឯង ម្នាលអានន្ទ នេះឯងតថាគតហៅថា ការចម្រើនឥន្ទ្រិយដ៏ប្រសើរក្នុងវស ដែលគប្បីដឹងបានដោយអណ្តាត ក្នុងវិន័យរបស់ព្រះអរិយៈ ។

[៣៣៤] បុន ចបរំ អានន្ទ ភិក្ខុនោ កាយេន ផោដ្ឋព្វំ ផុសិត្វា ឧប្បជ្ជតិ មនាបំ ឧប្បជ្ជតិ អមនាបំ ឧប្បជ្ជតិ មនាបាមនាបំ ។ សោ ឯវំ បជានាតិ ឧប្បន្នំ ខោ មេ ឥទំ មនាបំ ឧប្បន្នំ អមនាបំ ឧប្បន្នំ មនាបាមនាបំ តញ្ច ខោ សង្ខតំ ឱឡារិកំ បដិច្ច សមុប្បន្នំ ឯតំ សន្តំ ឯតំ បណីតំ យទិទំ ឧបេក្ខាតិ ។ តស្ស តំ ឧប្បន្នំ មនាបំ ឧប្បន្នំ អមនាបំ ឧប្បន្នំ មនាបាមនាបំ និរុជ្ឈតិ ឧបេក្ខា សណ្ឋាតិ ។ សេយ្យថាបិ អានន្ទ ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ ខោ អានន្ទ យស្ស កស្សចិ ឯវំ សីឃំ តុវដំ អប្បកសិរេន ឧប្បន្នំ មនាបំ ឧប្បន្នំ អមនាបំ ឧប្បន្នំ មនាបាមនាបំ និរុជ្ឈតិ ឧបេក្ខា សណ្ឋាតិ អយំ វុច្ចតានន្ទ

[៣៣៥] ម្នាលអានន្ទ មួយទៀត ភិក្ខុមានសេចក្តីគាប់ចិត្តកើតឡើង មានសេចក្តីមិនគាប់ចិត្តកើតឡើង មានសេចក្តីគាប់ចិត្តខ្លះមិនគាប់ចិត្តខ្លះ កើតឡើង ព្រោះពាល់ត្រូវនូវផោដ្ឋព្វៈដោយកាយ ។ ភិក្ខុនោះដឹងច្បាស់យ៉ាងនេះថា អាត្មាអញ មានសេចក្តីគាប់ចិត្តនេះកើតឡើងហើយ មានសេចក្តីមិនគាប់ចិត្តនេះកើតឡើងហើយ មានសេចក្តីគាប់ចិត្តខ្លះមិនគាប់ចិត្តខ្លះនេះកើតឡើងហើយ ឯវិបស្សនូបេក្ខា ដ៏ល្អិត ដ៏ឧត្តមក៏កើតឡើង ព្រោះអាស្រ័យសេចក្តីគាប់ចិត្តជាដើម ដែលជារបស់មានបច្ច័យតាក់តែង ជារបស់គ្រោតគ្រាតនោះឯង ។ លុះភិក្ខុនោះ មានសេចក្តីគាប់ចិត្តនោះកើតឡើង មានសេចក្តីមិនគាប់ចិត្តនោះកើតឡើង មានសេចក្តីគាប់ចិត្តខ្លះមិនគាប់ចិត្តខ្លះនោះ កើតឡើង ហើយរលត់ទៅវិញ វិបស្សនូបេក្ខា ក៏តាំងឡើង ។ ម្នាលអានន្ទ បុរសមានកម្លាំង លាដៃដែលបត់ចូល ឬបត់ចូលដៃដែលលាចេញ មានឧបមាយ៉ាងណាមិញ ម្នាលអានន្ទ បុគ្គលណាមួយ មានសេចក្តីគាប់ចិត្តកើតឡើង មានសេចក្តីមិនគាប់ចិត្តកើតឡើង មានសេចក្តីគាប់ចិត្តខ្លះមិនគាប់ចិត្តខ្លះ កើតឡើង ហើយរលត់ទៅវិញ វិបស្សនូបេក្ខា ក៏តាំងឡើង ដោយឆាប់យ៉ាងនេះ រហ័សយ៉ាងនេះ មិនមានសេចក្តីលំបាកយ៉ាងនេះ ក៏មានឧបមេយ្យយ៉ាងនោះឯង ម្នាលអានន្ទ នេះឯងតថាគតហៅថា

អរិយស្ស វិនយេ អនុត្តរា ឥន្ទ្រិយភាវនា កាយវិញ្ញេ-
យ្យេសុ ផោដ្ឋព្វេសុ ។

[៣៣៦] បុន ចបរំ អានន្ទ ភិក្ខុនោ មនសា
ធម្មំ វិញ្ញាយ ឧប្បជ្ជតិ មនាបំ ឧប្បជ្ជតិ អមនាបំ
ឧប្បជ្ជតិ មនាបាមនាបំ ។ សោ ឯវំ បជានាតិ ឧប្បន្នំ
ខោ មេ ឥទំ មនាបំ ឧប្បន្នំ អមនាបំ ឧប្បន្នំ
មនាបាមនាបំ តញ្ច ខោ សង្ខតំ ឱឡារិកំ បដិច្ច
សមុប្បន្នំ ឯតំ សន្តំ ឯតំ បណីតំ យទិទំ ឧបេក្ខាតិ ។
តស្ស តំ ឧប្បន្នំ មនាបំ ឧប្បន្នំ អមនាបំ ឧប្បន្នំ
មនាបាមនាបំ និរុជ្ឈតិ ឧបេក្ខា សណ្ឋាតិ ។ សេយ្យ-
ថាបិ អានន្ទ ពលវា បុរិសោ ទិវសំ សន្តត្តេ អ-
យោកដាហេ ទ្វេ វា តីណិ វា ឧទកផុសិតានិ និ-
បាតេយ្យ ទន្ធោ អានន្ទ ឧទកផុសិតានំ និបាតោ
អថខោ តំ ខិប្បមេវ បរិក្ខយំ បរិយាទានំ គច្ឆេយ្យ

ការចម្រើនឥន្ទ្រិយដ៏ប្រសើរក្នុងផោដ្ឋព្វៈ ដែលគប្បីដឹងបានដោយកាយ ក្នុងវិន័យរបស់ព្រះអរិយៈ ។

[៣៣៦] ម្នាលអានន្ទ មួយវិញទៀត ភិក្ខុ មានសេចក្តីគាប់ចិត្តកើតឡើង មានសេចក្តីមិនគាប់ចិត្តកើតឡើង មានសេចក្តីគាប់ចិត្តខ្លះមិនគាប់ចិត្តខ្លះ កើតឡើង ព្រោះដឹងធម្មារម្មណ៍ដោយចិត្ត ។ ភិក្ខុនោះដឹងច្បាស់យ៉ាងនេះថា អាត្មាអញមានសេចក្តីគាប់ចិត្តនេះកើតឡើងហើយ មានសេចក្តីមិនគាប់ចិត្តនេះកើតឡើងហើយ មានសេចក្តីគាប់ចិត្តខ្លះមិនគាប់ចិត្តខ្លះនេះកើតឡើងហើយ ឯវិបស្សនូបេក្ខា ដ៏ល្អិត ដ៏ឧត្តម ក៏កើតឡើង ព្រោះអាស្រ័យសេចក្តីគាប់ចិត្តជាដើម ដែលជារបស់មានបច្ច័យតាក់តែង ជារបស់គ្រោតគ្រាតនោះឯង ។ លុះភិក្ខុនោះ មានសេចក្តីគាប់ចិត្តនោះកើតឡើង មានសេចក្តីមិនគាប់ចិត្តនោះកើតឡើង មានសេចក្តីគាប់ចិត្តខ្លះមិនគាប់ចិត្តខ្លះនោះ កើតឡើង ហើយរលត់ទៅវិញ វិបស្សនូបេក្ខាក៏តាំងឡើង ។ ម្នាលអានន្ទ បុរសមានកម្លាំង សម្រក់នូវតំណក់ទឹក ២ តំណក់ ឬ ៣ តំណក់ ទៅក្នុងខ្ទះដែកដ៏ក្តៅអស់ ១ ថ្ងៃ ម្នាលអានន្ទ ការសម្រក់នូវតំណក់ទឹកទាំងឡាយយឺតយូរ ឯទឹកនោះ ក៏ដល់នូវការអស់ទៅ ស្ងួតទៅ ដោយឆាប់រហ័ស មានឧបមាយ៉ាងណាមិញ

ឯវមេវ ខោ អានន្ទ យស្ស កស្សចិ ឯវំ សីឃំ ឯវំ តុវដំ ឯវំ អប្បកសិរេន ឧប្បន្នំ មនាបំ ឧប្បន្នំ អមនាបំ ឧប្បន្នំ មនាបាមនាបំ និរុជ្ឈតិ ឧបេក្ខា សណ្ឋាតិ អយំ វុច្ចតានន្ទ អរិយស្ស វិនយេ អនុត្តរា ឥន្ទ្រិយភាវនា មនោវិញ្ញេយ្យេសុ ធម្មេសុ ។ ឯវំ ខោ អានន្ទ អរិយស្ស វិនយេ អនុត្តរា ឥន្ទ្រិយភាវនា ហោតិ ។

[៣៣៧] កថញ្ចានន្ទ សេក្ខោ ហោតិ បាដិបទោ ។ ឥធានន្ទ ភិក្ខុនោ ចក្ខុនា រូបំ ទិស្វា ឧប្បជ្ជតិ មនាបំ ឧប្បជ្ជតិ អមនាបំ ឧប្បជ្ជតិ មនាបាមនាបំ ។ សោ តេន ឧប្បន្នេន មនាបេន ឧប្បន្នេន អមនាបេន ឧប្បន្នេន មនាបាមនាបេន អដ្ដីយតិ ហរាយតិ ជិគុច្ឆតិ ។ សោតេន សទ្ទំ សុត្វា... ឃានេន គន្ធំ ឃាយិត្វា... ជិវ្ហាយ រសំ សាយិត្វា...

ម្នាលអានន្ទ បុគ្គលណាមួយ មានសេចក្តីគាប់ចិត្តកើតឡើង មានសេចក្តីមិនគាប់ចិត្តកើតឡើង មានសេចក្តីគាប់ចិត្តខ្លះមិនគាប់ចិត្តខ្លះនោះកើតឡើង ហើយរលត់ទៅវិញ វិបស្សនូបេក្ខា ក៏តាំងឡើង ដោយឆាប់យ៉ាងនេះ រហ័សយ៉ាងនេះ មិនមានសេចក្តីលំបាកយ៉ាងនេះ ក៏មានឧបមេយ្យយ៉ាងនោះឯង ម្នាលអានន្ទ នេះឯងតថាគតហៅថា ការចម្រើនឥន្ទ្រិយក្នុងធម្មារម្មណ៍ ដែលគប្បីដឹងបានដោយចិត្ត ក្នុងវិន័យរបស់ព្រះអរិយៈ ។ ម្នាលអានន្ទ ការចម្រើនឥន្ទ្រិយដោយចិត្ត ក្នុងវិន័យរបស់ព្រះអរិយៈ យ៉ាងនេះឯង ។

[៣៣៧] ម្នាលអានន្ទ បុគ្គលដែលឈ្មោះថាសេក្ខៈជាអ្នកមានបដិបទា តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ មានសេចក្តីគាប់ចិត្តកើតឡើង មានសេចក្តីមិនគាប់ចិត្តកើតឡើង មានសេចក្តីគាប់ចិត្តខ្លះមិនគាប់ចិត្តខ្លះកើតឡើង ព្រោះឃើញរូបដោយភ្នែក ។ ភិក្ខុនោះ ក៏នឿយណាយ ធុញទ្រាន់ ខ្ពើមរអើម ដោយសេចក្តីគាប់ចិត្តដែលកើតឡើង ដោយសេចក្តីមិនគាប់ចិត្តដែលកើតឡើង ដោយសេចក្តីគាប់ចិត្តខ្លះមិនគាប់ចិត្តខ្លះ ដែលកើតឡើងនោះ ។ ភិក្ខុមានសេចក្តីគាប់ចិត្តកើតឡើង មានសេចក្តីមិនគាប់ចិត្តកើតឡើង មានសេចក្តីគាប់ចិត្តខ្លះមិនគាប់ចិត្តខ្លះកើតឡើង ព្រោះឮសំឡេងដោយត្រចៀក... ព្រោះធុំក្លិនដោយច្រមុះ... ព្រោះទទួលរសដោយអណ្តាត...

កាយេន ផោដ្ឋព្វំ ផុសិត្វា... មនសា ធម្មំ វិញ្ញាយ ឧប្បជ្ជតិ មនាបំ ឧប្បជ្ជតិ អមនាបំ ឧប្បជ្ជតិ មនាបាមនាបំ ។ សោ តេន ឧប្បន្នេន មនាបេន ឧប្បន្នេន អមនាបេន ឧប្បន្នេន មនាបាមនាបេន អដ្ដីយតិ ហរាយតិ ជិគុច្ឆតិ ។ ឯវំ ខោ អានន្ទ សេក្ខោ ហោតិ បាដិបទោ ។

[៣៣៨] កថញ្ចានន្ទ អរិយោ ហោតិ ភាវិតិន្ទ្រិយោ ។ ឥធានន្ទ ភិក្ខុនោ ចក្ខុនា រូបំ ទិស្វា ឧប្បជ្ជតិ មនាបំ ឧប្បជ្ជតិ អមនាបំ ឧប្បជ្ជតិ មនាបាមនាបំ ។ សោ សចេ អាកង្ខតិ បដិក្កូលេ អប្បដិក្កូលសញ្ញី វិហរេយ្យន្តិ អប្បដិក្កូលសញ្ញី តត្ថ វិហរតិ ។ សចេ អាកង្ខតិ អប្បដិក្កូលេ បដិក្កូលសញ្ញី វិហរេយ្យន្តិ បដិក្កូលសញ្ញី តត្ថ វិហរតិ ។ សចេ អាកង្ខតិ បដិក្កូលេ ច អប្បដិក្កូលេ ច អប្បដិក្កូលសញ្ញី វិហរេយ្យន្តិ

ព្រោះពាល់ត្រូវផោដ្ឋព្វៈដោយកាយ... ព្រោះដឹងធម្មារម្មណ៍ដោយចិត្ត ។ ភិក្ខុនោះ ក៏នឿយណាយ ធុញទ្រាន់ ខ្ពើមរអើម ដោយសេចក្តីគាប់ចិត្តដែលកើតឡើង ដោយសេចក្តីមិនគាប់ចិត្តដែលកើតឡើង ដោយសេចក្តីគាប់ចិត្តខ្លះមិនគាប់ចិត្តខ្លះ ដែលកើតឡើងនោះ ។ ម្នាលអានន្ទ បុគ្គលដែលឈ្មោះថាសេក្ខៈជាអ្នកមានបដិបទា យ៉ាងនេះឯង ។

[៣៣៨] ម្នាលអានន្ទ បុគ្គលដែលឈ្មោះថាអរិយៈមានឥន្ទ្រិយចម្រើនហើយ តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ មានសេចក្តីគាប់ចិត្តកើតឡើង មានសេចក្តីមិនគាប់ចិត្តកើតឡើង មានសេចក្តីគាប់ចិត្តខ្លះមិនគាប់ចិត្តខ្លះកើតឡើង ព្រោះឃើញរូបដោយភ្នែក ។ បើភិក្ខុនោះ ប្រាថ្នាថា អាត្មាអញគប្បីជាអ្នកសំគាល់ ក្នុងរបស់គួរខ្ពើមថាជារបស់មិនគួរខ្ពើមដូច្នេះ ហើយក៏សំគាល់ថាជារបស់មិនគួរខ្ពើម ក្នុងរបស់ដែលគួរខ្ពើមនោះ ។ បើប្រាថ្នាថា អាត្មាអញជាអ្នកសំគាល់ក្នុងរបស់មិនគួរខ្ពើម ថាជារបស់គួរខ្ពើមដូច្នេះ ហើយក៏សំគាល់ថាជារបស់គួរខ្ពើម ក្នុងរបស់ដែលមិនគួរខ្ពើមនោះ ។ បើប្រាថ្នាថា អាត្មាអញជាអ្នកសំគាល់ក្នុងរបស់គួរខ្ពើមផង មិនគួរខ្ពើមផង ថាជារបស់មិនគួរខ្ពើម

អប្បដិក្កូលសញ្ញី តត្ថ វិហរតិ ។ សចេ អាកង្ខតិ អប្បដិក្កូលេ ច បដិក្កូលេ ច បដិក្កូលសញ្ញី វិហរេយ្យន្តិ បដិក្កូលសញ្ញី តត្ថ វិហរតិ ។ សចេ អាកង្ខតិ បដិក្កូលញ្ច អប្បដិក្កូលញ្ច តទុភយំ អភិនិវជ្ជេត្វា ឧបេក្ខកោ វិហរេយ្យំ សតោ សម្បជានោតិ ឧបេក្ខកោ តត្ថ វិហរតិ សតោ សម្បជានោ ។

[៣៣៩] បុន ចបរំ អានន្ទ ភិក្ខុនោ សោតេន សទ្ទំ សុត្វា... ឃានេន គន្ធំ ឃាយិត្វា... ជិវ្ហាយ រសំ សាយិត្វា... កាយេន ផោដ្ឋព្វំ ផុសិត្វា... មនសា ធម្មំ វិញ្ញាយ ឧប្បជ្ជតិ មនាបំ ឧប្បជ្ជតិ អមនាបំ ឧប្បជ្ជតិ មនាបាមនាបំ ។ សោ សចេ អាកង្ខតិ បដិក្កូលេ អប្បដិក្កូលសញ្ញី វិហរេយ្យន្តិ អប្បដិក្កូលសញ្ញី តត្ថ វិហរតិ ។ សចេ អាកង្ខតិ អប្បដិក្កូលេ បដិក្កូលសញ្ញី វិហរេយ្យន្តិ បដិក្កូលសញ្ញី តត្ថ វិហរតិ ។ សចេ អាកង្ខតិ

ដូច្នេះ ហើយក៏សំគាល់ថាជារបស់មិនគួរខ្ពើម ក្នុងរបស់ដែលគួរខ្ពើមនិងមិនគួរខ្ពើមនោះ ។ បើប្រាថ្នាថា អាត្មាអញគប្បីជាអ្នកសំគាល់ក្នុងរបស់មិនគួរខ្ពើមផង គួរខ្ពើមផង ថាជារបស់គួរខ្ពើមដូច្នេះ ហើយក៏សំគាល់ថាជារបស់គួរខ្ពើម ក្នុងរបស់ដែលមិនគួរខ្ពើមនិងគួរខ្ពើមនោះ ។ បើប្រាថ្នាថា អាត្មាអញគួរវៀរចេញនូវរបស់ទាំងពីរ គឺរបស់គួរខ្ពើមនិងមិនគួរខ្ពើម ជាអ្នកព្រងើយកន្តើយ មានស្មារតីដឹងសព្វដូច្នេះហើយ ក៏ជាអ្នកព្រងើយកន្តើយ មានស្មារតីដឹងសព្វក្នុងរបស់ទាំងពីរនោះ ។

[៣៣៩] ម្នាលអានន្ទ មួយវិញទៀត ភិក្ខុ មានសេចក្តីគាប់ចិត្តកើតឡើង មានសេចក្តីមិនគាប់ចិត្តកើតឡើង មានសេចក្តីគាប់ចិត្តខ្លះមិនគាប់ចិត្តខ្លះ កើតឡើង ព្រោះឮសំឡេងដោយត្រចៀក... ព្រោះធុំក្លិនដោយច្រមុះ... ព្រោះទទួលរសដោយអណ្តាត... ព្រោះពាល់ត្រូវផោដ្ឋព្វៈដោយកាយ... ព្រោះដឹងធម្មារម្មណ៍ដោយចិត្ត ។ បើភិក្ខុនោះប្រាថ្នាថា អាត្មាអញគប្បីជាអ្នកសំគាល់ ក្នុងរបស់គួរខ្ពើម ថាជារបស់មិនគួរខ្ពើមដូច្នេះ ហើយក៏សំគាល់ថាជារបស់មិនគួរខ្ពើម ក្នុងរបស់ដែលគួរខ្ពើមនោះ ។ បើប្រាថ្នាថា អាត្មាអញគប្បីជាអ្នកសំគាល់ក្នុងរបស់មិនគួរខ្ពើម ថាជារបស់គួរខ្ពើមដូច្នេះ ហើយក៏សំគាល់ថាជារបស់គួរខ្ពើម ក្នុងរបស់ដែលមិនគួរខ្ពើមនោះ ។ បើប្រាថ្នាថា

បដិក្កូលេ ច អប្បដិក្កូលេ ច អប្បដិក្កូលសញ្ញី វិហរេយ្យន្តិ អប្បដិក្កូលសញ្ញី តត្ថ វិហរតិ ។ សចេ អាកង្ខតិ អប្បដិក្កូលេ ច បដិក្កូលេ ច បដិក្កូលសញ្ញី វិហរេយ្យន្តិ បដិក្កូលសញ្ញី តត្ថ វិហរតិ ។ សចេ អាកង្ខតិ បដិក្កូលញ្ច អប្បដិក្កូលញ្ច តទុភយំ អភិនិវជ្ជេត្វា ឧបេក្ខកោ វិហរេយ្យំ សតោ សម្បជានោតិ ឧបេក្ខកោ តត្ថ វិហរតិ សតោ សម្បជានោ ។ ឯវំ ខោ អានន្ទ អរិយោ ហោតិ ភាវិតិន្ទ្រិយោ ។

អាត្មាអញគប្បីជាអ្នកសំគាល់ក្នុងរបស់គួរខ្ពើមផង មិនគួរខ្ពើមផង ថាជារបស់មិនគួរខ្ពើមដូច្នេះ ហើយក៏សំគាល់ថាជារបស់មិនគួរខ្ពើម ក្នុងរបស់ដែលគួរខ្ពើមនិងមិនគួរខ្ពើមនោះ ។ បើប្រាថ្នាថា អាត្មាអញគប្បីជាអ្នកសំគាល់ក្នុងរបស់មិនគួរខ្ពើមផង គួរខ្ពើមផង ថាជារបស់គួរខ្ពើមដូច្នេះ ហើយក៏សំគាល់ថាជារបស់គួរខ្ពើម ក្នុងរបស់ដែលមិនគួរខ្ពើមនិងគួរខ្ពើមនោះ ។ បើប្រាថ្នាថា អាត្មាអញគួរជាអ្នកវៀរស្រឡះនូវរបស់ទាំងពីរ គឺរបស់គួរខ្ពើមនិងរបស់មិនគួរខ្ពើម ជាអ្នកព្រងើយកន្តើយ មានស្មារតីដឹងសព្វដូច្នេះ ហើយក៏ជាអ្នកព្រងើយកន្តើយ មានស្មារតីដឹងសព្វក្នុងរបស់ទាំងពីរនោះ ។ ម្នាលអានន្ទ បុគ្គលដែលឈ្មោះថាអរិយៈ មានឥន្ទ្រិយចម្រើនហើយ យ៉ាងនេះឯង ។

[៣៤០] ឥតិ ខោ អានន្ទ ទេសិតា មយា អរិយស្ស វិនយេ អនុត្តរា ឥន្ទ្រិយភាវនា ទេសិតោ សេក្ខោ បាដិបទោ ទេសិតោ អរិយោ ភាវិតិន្ទ្រិយោ យំ អានន្ទ សត្ថារា ករណីយំ សាវកានំ ហិតេសិនា អនុកម្បកេន អនុកម្បំ ឧបាទាយ កតំ វោ តំ មយា ឯតានិ អានន្ទ រុក្ខមូលានិ ឯតានិ សុញ្ញាគារានិ ឈាយថានន្ទ មា បមាទត្ថ មា បច្ឆា វិប្បដិសារិនោ អហុវត្ថ អយំ វោ អម្ហាកំ អនុសាសនីតិ ។ ឥទមវោច ភគវា អត្តមនោ អាយស្មា អានន្ទោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

ឥន្ទ្រិយភាវនាសុត្តំ ទសមំ និដ្ឋិតំ ។

សឡាយតនវគ្គោ បញ្ចមោ ។

[៣៤០] ម្នាលអានន្ទ ការចម្រើននូវឥន្ទ្រិយដ៏ប្រសើរ ក្នុងវិន័យរបស់ព្រះអរិយៈ តថាគតបានសំដែងហើយ បុគ្គលដែលឈ្មោះថាសេក្ខៈ ប្រកបដោយបដិបទា តថាគតបានសំដែងហើយ បុគ្គលដែលឈ្មោះថាអរិយៈ មានឥន្ទ្រិយចម្រើនហើយ តថាគតក៏បានសំដែងហើយដោយប្រការដូច្នេះឯង ម្នាលអានន្ទ កិច្ចណា ដែលព្រះសាស្តាជាអ្នកស្វែងរកនូវប្រយោជន៍ ជាអ្នកអនុគ្រោះដល់សាវ័កទាំងឡាយ គប្បីធ្វើព្រោះអាស្រ័យសេចក្តីអនុគ្រោះ កិច្ចនោះតថាគតបានធ្វើហើយ ដល់អ្នកទាំងឡាយ ម្នាលអានន្ទ នុ៎ះ រុក្ខមូល នុ៎ះ សុញ្ញាគារ ម្នាលអានន្ទអ្នកទាំងឡាយ ចូរពិនិត្យមើលចុះ ចូរកុំប្រមាទ កុំមានសេចក្តីក្តៅក្រហាយក្នុងកាលជាខាងក្រោយឡើយ នេះហើយជាពាក្យប្រៀនប្រដៅរបស់តថាគត ចំពោះអ្នកទាំងឡាយ ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ ព្រះអានន្ទមានអាយុ មានសេចក្តីត្រេកអរ រីករាយ ចំពោះភាសិតព្រះមានព្រះភាគ ។

ចប់ ឥន្ទ្រិយភាវនាសូត្រ ទី ១០ ។

ចប់ សឡាយតនវគ្គ ទី ៥ ។

៣៨៤

សឡាយតនវគ្គស្ស ឥន្ទ្រិយភាវនាសុត្តេ ឧទ្ទានំ

តស្សុទ្ទានំ

អជាថបិណ្ឌិកោ ឆន្នោ
បុណ្ណោ ននូកោរាហុលោ
ឆផ្ពំ សឡាយតនិកំ
ឯតវិភង្គេយ្យ សុទ្ធិកោ
ឥន្ទ្រិយភាវនា ចាបិ
វគ្គោ ឱត្តរបញ្ចមោ ។

ឧបរិបណ្ណាសកំ និដ្ឋិតំ ។

## ឧទ្ទាននៃសឡាយតនវគ្គនោះ គឺ

*អនាថបិណ្ឌិកោវាទសូត្រ ១ ឆន្នោវាទសូត្រ ១ បុណ្ណោវាទសូត្រ ១ នន្ទកោវាទសូត្រ ១ ចូឡរាហុលោវាទសូត្រ ១ ឆឆក្កសូត្រ ១ សឡាយតនវិភង្គសូត្រ ១ នគរវិន្ទេយ្យសូត្រ ១ បិណ្ឌបាតបារិសុទ្ធិសូត្រ ១ ឥន្ទ្រិយភាវនាសូត្រ ១ (នេះ) ជាវគ្គទី ៥ ខាងចុងបំផុត ។*

ចប់ ឧបរិបណ្ណាសកៈ ។

# សុត្តន្តបិដកេ

# មជ្ឈិមនិកាយស្ស ឧបរិបណ្ណាសកំ

# នវមោ ភាគោ

# វិភង្គវគ្គោ

## បឋមំ ភទ្ទេករត្តសុត្តំ


| មាតិកា | អង្កេ |
|---|---|
| វិភង្គវគ្គស្ស ភទ្ទេករត្តសុត្តេ អនាគតប្បដិកង្ខតា | ៣ |
| អនាគតំ នប្បដិកង្ខតា | ៥ |
| ភទ្ទេករត្តភាវោ | ៧ |


## ទុតិយំ អានន្ទភទ្ទេករត្តសុត្តំ


| | |
|---|---|
| វិភង្គវគ្គស្ស អានន្ទភទ្ទេករត្តសុត្តេ អតីតាន្វាគមនំ | ១១ |
| អនាគតំ នប្បដិកង្ខតា | ១៣ |
| ភទ្ទេករត្តភាវោ | ១៥ |
| អតីតាន្វាគមនំ | ១៧ |


## តតិយំ មហាកច្ចានភទ្ទេករត្តសុត្តំ


| | |
|---|---|
| វិភង្គវគ្គស្ស មហាកច្ចានភទ្ទេករត្តសុត្តេ ភគវន្តូបសង្កមនំ | ២១ |

# សុត្តន្តបិដក មជ្ឈិមនិកាយ

# ឧបរិបណ្ណាសកៈ

# នវមភាគ

# វិភង្គវគ្គ

# ភទ្ទេករត្តសូត្រ ទី ១

មាតិកា ទំព័រ


វិភង្គវគ្គ ភទ្ទេករត្តសូត្រ សេចក្តីសង្ស័យក្នុងខន្ធជាអនាគត................................ ៣

សេចក្តីមិនសង្ស័យក្នុងខន្ធជាអនាគត.............................. ៥

ភាពនៃបុគ្គលអ្នកមានរាត្រីមួយដ៏ចម្រើន.......................... ៧


# អានន្ទភទ្ទេករត្តសូត្រ ទី ២


វិភង្គវគ្គ អានន្ទភទ្ទេករត្តសូត្រ សេចក្តីអាឡោះអាល័យបញ្ចក្ខន្ធជាអតីត.......................... ១១

សេចក្តីមិនប្រាថ្នានូវបញ្ចក្ខន្ធជាអនាគត........................... ១៣

ភាពនៃបុគ្គលអ្នកមានរាត្រីមួយដ៏ចម្រើន.......................... ១៥

សេចក្តីអាឡោះអាល័យបញ្ចក្ខន្ធជាអតីត.......................... ១៧


# មហាកច្ចានភទ្ទេករត្តសូត្រ ទី ៣


វិភង្គវគ្គ មហាកច្ចានភទ្ទេករត្តសូត្រ ព្រះសមិទ្ធិមានអាយុចូលទៅរកព្រះមានព្រះភាគ.... ២១

# មាតិកាបត្តានិ

មាតិកា អង្កេ

វិភង្គវគ្គស្ស មហាកច្ចានភទ្ទេករត្តសុត្តេ ភទ្ទេករត្តភាវោ........................................... ២៣
ភិក្ខូនំ បរិវិតក្កនំ......................................... ២៥
មហាកច្ចានូបសង្កមនំ................................ ២៧
មហាកច្ចានប្បសំសនំ................................ ២៩
អតីតានាគមនំ............................................ ៣១
អនាគតំ បដិកង្ខតា.................................... ៣៣
បច្ចុប្បន្នសំហិរតា....................................... ៣៥
ភាសិតាភិនន្ទនំ............................................ ៣៧
ភទ្ទេករត្តគាថា............................................ ៣៩
ភាសិតាភិនន្ទនំ........................................... ៤១

## ចតុត្ថំ លោមសកង្គិយសុត្តំ

វិភង្គវគ្គស្ស លោមសកង្គិយភទ្ទេករត្តសុត្តេ ភទ្ទេករត្តគាថា.......................................... ៤៣
ភគវន្តូបសង្កមនំ ........................................ ៤៥
ភគវតោ បដិបុច្ឆនំ.................................... ៤៧
អតីតានាគមនំ .......................................... ៤៩
បច្ចុប្បន្នធម្មសំហិរណំ ................................ ៥១

# សង្ខេបប្រាប់មាតិកា


| មាតិកា | | | ទំព័រ |
|---|---|---|---|
| វិភង្គវគ្គ | មហាកច្ចានភទ្ទេករត្តសូត្រ | ភាពនៃបុគ្គលអ្នកមានរាត្រីមួយដ៏ចម្រើន.. | ២៣ |
| | | សេចក្តីត្រិះរិះនៃពួកភិក្ខុ............................. | ២៥ |
| | | ពួកភិក្ខុចូលទៅរកព្រះមហាកច្ចានៈ........... | ២៧ |
| | | សេចក្តីសរសើរព្រះមហាកច្ចានៈ............... | ២៩ |
| | | សេចក្តីអាឡោះអាល័យបញ្ចក្ខន្ធជាអតីត.... | ៣១ |
| | | សេចក្តីប្រាថ្នានូវបញ្ចក្ខន្ធជាអនាគត........... | ៣៣ |
| | | សេចក្តីរសេមរសាមក្នុងពួកធម៌ជាបច្ចុប្បន្ន.. | ៣៥ |
| | | សេចក្តីត្រេកអរចំពោះភាសិត..................... | ៣៧ |
| | | គាថាសំដែងពីរាត្រីមួយដ៏ចម្រើន............... | ៣៩ |
| | | សេចក្តីត្រេកអរចំពោះភាសិត..................... | ៤១ |


# លោមសកង្គិយសូត្រ ទី ៤


| | | | |
|---|---|---|---|
| វិភង្គវគ្គ | លោមសកង្គិយភទ្ទេករត្តសូត្រ | គាថាសំដែងពីរាត្រីមួយដ៏ចម្រើន............... | ៤៣ |
| | | ការចូលទៅគាល់ព្រះមានព្រះភាគ............ | ៤៥ |
| | | ព្រះមានព្រះភាគទ្រង់សួរតប...................... | ៤៧ |
| | | សេចក្តីអាឡោះអាល័យបញ្ចក្ខន្ធជាអតីត..... | ៤៩ |
| | | សេចក្តីរសេមរសាមក្នុងធម៌ជាបច្ចុប្បន្ន........ | ៥១ |

# មាតិកាបត្តានិ


| មាតិកា | | | អង្កេ |
|---|---|---|---|
| វិភង្គវគ្គស្ស | លោមសកង្គិយភទ្ទេករត្តសុត្តេ | ភាសិតាភិនន្ទនំ.............................. | ៥៣ |


## បញ្ចមំ ចូឡកម្មវិភង្គសុត្តំ


| | | | |
|---|---|---|---|
| វិភង្គវគ្គស្ស | ចូឡកម្មវិភង្គសុត្តេ | សុភមាណវស្ស អាយាចនំ........................... | ៥៥ |
| | | បាណាតិបាតវិរតិ............................................ | ៥៧ |
| | | កោធនភាវោ.................................................... | ៥៩ |
| | | ឥស្សាមនកភាវោ.............................................. | ៦១ |
| | | អន្នាទិអទានំ...................................................... | ៦៣ |
| | | ថទ្ធភាវោ.......................................................... | ៦៥ |
| | | អបរិបុច្ឆិតភាវោ................................................. | ៦៧ |
| | | អបាយុកសំវត្តនិកាទិបដិបទា............................ | ៦៩ |
| | | តិសរណគមនំ.................................................. | ៧១ |


## ឆដ្ឋំ មហាកម្មវិភង្គសុត្តំ


| | | | |
|---|---|---|---|
| វិភង្គវគ្គស្ស | មហាកម្មវិភង្គសុត្តេ | កថាសល្លាបោ................................................. | ៧៣ |
| | | កថាសល្លាបារោចនំ.......................................... | ៧៥ |
| | | មហាកម្មវិភង្គវិភជ្ជនំ........................................... | ៧៧ |
| | | ចត្តារោ បុគ្គលា................................................. | ៧៩ |

# សង្ខឹកច្រាប់មាតិកា


| មាតិកា | | | ទំព័រ |
|---|---|---|---|
| វិភង្គវគ្គ | លោមសកង្គិយភទ្ទេករត្តសូត្រ | សេចក្តីត្រេកអរចំពោះភាសិត.................. | ៥៣ |


## ចូឡកម្មវិភង្គសូត្រ ទី ៥


| | | | |
|---|---|---|---|
| វិភង្គវគ្គ | ចូឡកម្មវិភង្គសូត្រ | កិច្ចនិមន្តរបស់សុភមាណព............................. | ៥៥ |
| | | ការវៀរចាកបាណាតិបាត..................................... | ៥៧ |
| | | ភាពនៃបុគ្គលជាអ្នកក្រោធ.................................... | ៥៩ |
| | | ភាពនៃបុគ្គលជាអ្នកច្រណែន................................ | ៦១ |
| | | ការមិនឲ្យនូវវត្ថុមានបាយជាដើម........................... | ៦៣ |
| | | ភាពនៃបុគ្គលជាអ្នករឹងត្អឹង.................................... | ៦៥ |
| | | ភាពនៃបុគ្គលជាអ្នកមិនសាកសួរ........................... | ៦៧ |
| | | សេចក្តីប្រតិបត្តិដែលប្រព្រឹត្តទៅដើម្បីអាយុខ្លីជាដើម... | ៦៩ |
| | | ការដល់នូវត្រៃសរណៈ.......................................... | ៧១ |


## មហាកម្មវិភង្គសូត្រ ទី ៦


| | | | |
|---|---|---|---|
| វិភង្គវគ្គ | មហាកម្មវិភង្គសូត្រ | ពាក្យចរចា.......................................................... | ៧៣ |
| | | ការក្រាបទូលនូវពាក្យចរចា................................... | ៧៥ |
| | | ការចែកនូវមហាកម្មវិភង្គ....................................... | ៧៧ |
| | | បុគ្គលបួនពួក........................................................ | ៧៩ |

# មាតិកាបត្តានិ

មាតិកា អង្កេ

វិភង្គវគ្គស្ស មហាកម្មវិភង្គសុត្តេ អភិនិវិស្សវោហារោ................................................ ៨១
មហាកម្មវិភង្គញ្ញាណំ............................................ ៨៧
វិបាកប្បដិសំវេទភាវោ.......................................... ៩៣

## សត្តមំ សឡាយតនវិភង្គសុត្តំ

វិភង្គវគ្គស្ស សឡាយតនវិភង្គសុត្តេ មនោបវិចារា........................................................... ៩៩
គេហសិតសោមនស្សានិ....................................... ១០១
គេហសិតទោមនស្សានិ....................................... ១០៣
នេក្ខម្មសិតទោមនស្សានិ...................................... ១០៥
នេក្ខម្មសិតុបេក្ខា.................................................. ១០៧
គេហសិតសោមនស្សាទិបជហានំ.......................... ១០៩
តយោ សតិប្បដ្ឋានា............................................... ១១១
ទុតិយសតិប្បដ្ឋានំ................................................. ១១៣
បុរិសទម្មសារថិភាវោ............................................ ១១៥
ភាសិតាភិនន្ទនំ..................................................... ១១៧

## អដ្ឋមំ ឧទ្ទេសវិភង្គសុត្តំ

វិភង្គវគ្គស្ស ឧទ្ទេសវិភង្គសុត្តេ ភិក្ខូនំ បរិវិតក្កនំ.................................................. ១១៩
មហាកច្ចានូបសង្កមនំ........................................... ១២១

# សង្ខឹកច្រាប់មាតិកា


| មាតិកា | | | ទំព័រ |
|---|---|---|---|
| វិភង្គវគ្គ | មហាកម្មវិភង្គសូត្រ | ការពោលដោយទិដ្ឋិក្ខចកាន់................................ | ៨១ |
| | | សេចក្តីយល់ក្នុងមហាកម្មវិភង្គ.............................. | ៨៧ |
| | | ភាពនៃបុគ្គលអ្នកទទួលនូវវិបាក............................ | ៩៣ |


# សឡាយតនវិភង្គសូត្រ ទី ៧


| | | | |
|---|---|---|---|
| វិភង្គវគ្គ | សឡាយតនវិភង្គសូត្រ | មនោបវិចារៈ ...................................................... | ៩៩ |
| | | គេហសិតសោមនស្ស........................................... | ១០១ |
| | | គេហសិតទោមនស្ស ........................................... | ១០៣ |
| | | នេក្ខម្មសិតទោមនស្ស.......................................... | ១០៥ |
| | | នេក្ខម្មសិតុបេក្ខា................................................... | ១០៧ |
| | | ការលះគេហសិតសោមនស្សជាដើម..................... | ១០៩ |
| | | សតិប្បដ្ឋានបី ...................................................... | ១១១ |
| | | សតិប្បដ្ឋានទីពីរ................................................... | ១១៣ |
| | | ភាពនៃបុគ្គលជាសារថីអ្នកទូន្មាននូវបុរស.............. | ១១៥ |
| | | សេចក្តីត្រេកអរចំពោះភាសិត................................ | ១១៧ |


# ឧទ្ទេសវិភង្គសូត្រ ទី ៨


| | | | |
|---|---|---|---|
| វិភង្គវគ្គ | ឧទ្ទេសវិភង្គសូត្រ | សេចក្តីត្រិះរិះរបស់ភិក្ខុទាំងឡាយ...................... | ១១៩ |
| | | ការចូលទៅរកព្រះមហាកច្ចានៈ.............................. | ១២១ |

# មាតិកាបត្តានិ


| មាតិកា | | | អង្កេ |
|---|---|---|---|
| វិភង្គវគ្គស្ស | ឧទ្ទេសវិភង្គសុត្តេ | សារត្ថិកោបមា | ១២៥ |
| | | វិត្ថារុទ្ទេសត្ថវិភជ្ជនំ | ១២៧ |
| | | វិញ្ញាណានិក្ខិត្តតា | ១២៩ |
| | | អជ្ឈត្តចិត្តសណ្ឋិតតា | ១៣១ |
| | | អជ្ឈត្តចិត្តាសណ្ឋិតតា | ១៣៣ |
| | | អនុបាទា បរិតស្សនា | ១៣៥ |
| | | អនុបាទា អបរិតស្សនា | ១៣៧ |
| | | ភគវន្តាពោចនំ | ១៣៩ |


## ៤. អរណវិភង្គសុត្តំ


| | | | |
|---|---|---|---|
| វិភង្គវគ្គស្ស | អរណវិភង្គសុត្តេ | ហីនភាវោ | ១៤៥ |
| | | មជ្ឈិមា បដិបទា | ១៤៧ |
| | | ឧស្សាទនាទិភាវោ | ១៤៩ |
| | | ធម្មទេសនា | ១៥១ |
| | | បញ្ចកាមគុណា | ១៥៥ |
| | | រហោវាទំ នភាសនា | ១៥៧ |
| | | ជនបទនិរុត្តិ | ១៥៩ |
| | | សោមនស្សានុយោគោ | ១៦១ |

# សង្ខេបច្រាប់មាតិកា


| មាតិកា | | | ទំព័រ |
|---|---|---|---|
| វិភង្គវគ្គ | ឧទ្ទេសវិភង្គសូត្រ | ឧបមាដោយបុគ្គលអ្នកត្រូវការដោយខ្លឹមឈើ...... | ១២៥ |
| | | ការចែកអត្ថនៃឧទ្ទេសដោយពិស្តារ.................... | ១២៧ |
| | | វិញ្ញាណមិនរាត់រាយ........................................... | ១២៩ |
| | | ភាពនៃចិត្តឋិតនៅខាងក្នុង................................ | ១៣១ |
| | | ភាពនៃចិត្តមិនឋិតនៅខាងក្នុង.......................... | ១៣៣ |
| | | សេចក្តីតក់ស្លុតព្រោះមិនប្រកាន់មាំ.................... | ១៣៥ |
| | | សេចក្តីមិនតក់ស្លុតព្រោះមិនប្រកាន់មាំ............... | ១៣៧ |
| | | ការក្រាបទូលព្រះមានព្រះភាគ.......................... | ១៣៩ |


# អរណវិភង្គសូត្រ ទី ៩


| | | | |
|---|---|---|---|
| វិភង្គវគ្គ | អរណវិភង្គសូត្រ | ភាពនៃធម៌ថោកទាប................................ | ១៤៥ |
| | | មជ្ឈិមប្បដិបទា................................................ | ១៤៧ |
| | | ភាពនៃកិរិយាលើកតម្កើងជាដើម ...................... | ១៤៩ |
| | | ការសំដែងធម៌................................................... | ១៥២ |
| | | កាមគុណប្រាំ.................................................... | ១៥៥ |
| | | ការមិនពោលពាក្យក្នុងទីកំបាំងមុខ..................... | ១៥៧ |
| | | ភាសាក្នុងជនបទ.............................................. | ១៥៩ |
| | | សេចក្តីព្យាយាមដោយសោមនស្ស.................... | ១៦១ |

# មាតិកាបត្តានិ


| មាតិកា | អង្កេ |
|---|---|
| វិភង្គវគ្គស្ស អរណវិភង្គសុត្តេ មជ្ឈិមា បដិបទា.................................... | ១៦៣ |
| រហោវាទោ..................................................... | ១៦៥ |
| តរមានភាសនំ................................................ | ១៦៧ |
| ភាសិតាភិនន្ទនំ................................................ | ១៦៩ |


# ឧសមំ ធាតុវិភង្គសុត្តំ


| | |
|---|---|
| វិភង្គវគ្គស្ស ធាតុវិភង្គសុត្តេ ភគវតោ កុម្ភការនិវេសនំ បវិសនា..... | ១៧១ |
| ឆធាតុវិភង្គុទ្ទេសោ............................................ | ១៧៣ |
| អដ្ឋារស មនោបវិចារោ................................... | ១៧៥ |
| បឋវីធាតុ......................................................... | ១៧៧ |
| តេជោធាតុ....................................................... | ១៧៩ |
| អាកាសធាតុ.................................................... | ១៨១ |
| វេទនា............................................................. | ១៨៣ |
| ឧស្សូបមា......................................................... | ១៨៥ |
| សុវណ្ណកាពោបមា............................................. | ១៨៧ |
| តេលប្បទីបោបមា............................................. | ១៩៣ |
| មុនិ................................................................. | ១៩៧ |
| ភាសិតាភិនន្ទនំ................................................ | ១៩៩ |

# សង្ខេបទ្រាប់មាតិកា

| មាតិកា | | | ទំព័រ |
|---|---|---|---|
| វិភង្គវគ្គ | អរណវិភង្គសូត្រ | មជ្ឈិមប្បដិបទា........................................ | ១៦៣ |
| | | ពាក្យពោលក្នុងទីកំបាំងមុខ .............................. | ១៦៥ |
| | | ពាក្យពោលរហ័ស ........................................... | ១៦៧ |
| | | សេចក្តីត្រេកអរចំពោះភាសិត............................ | ១៦៩ |

# ធាតុវិភង្គសូត្រ ទី ១០

| | | | |
|---|---|---|---|
| វិភង្គវគ្គ | ធាតុវិភង្គសូត្រ | ព្រះមានព្រះភាគចូលទៅកាន់កុម្ភការនិវេសន៍.. | ១៧១ |
| | | ឧទ្ទេសនៃឆធាតុវិភង្គ ....................................... | ១៧៣ |
| | | មនោបវិចារៈដប់ប្រាំបី...................................... | ១៧៥ |
| | | បឋវីធាតុ........................................................ | ១៧៧ |
| | | តេជោធាតុ ...................................................... | ១៧៩ |
| | | អាកាសធាតុ.................................................... | ១៨១ |
| | | វេទនា ........................................................... | ១៨៣ |
| | | ឧបមាដោយកម្តៅ............................................. | ១៨៥ |
| | | ឧបមាដោយជាងមាស........................................ | ១៨៧ |
| | | ឧបមាដោយប្រទីបអុចប្រេង................................ | ១៩៣ |
| | | អ្នកប្រាជ្ញ ........................................................ | ១៩៧ |
| | | សេចក្តីត្រេកអរចំពោះភាសិត............................ | ១៩៩ |

# មាតិកាបត្តានិ

មាតិកា អង្កេ

## ឯកាទសមំ សច្ចវិភង្គសុត្តំ

វិភង្គវគ្គស្ស សច្ចវិភង្គសុត្តេ ធម្មចក្កប្បវត្តនំ.................................................... ២០៣
ទុក្ខអរិយសច្ចំ.................................................... ២០៥
ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចំ.................................................... ២០៩
មគ្គអរិយសច្ចំ.................................................... ២១១
អរិយសច្ចាចិក្ខនា.................................................... ២១៣

## ទ្វាទសមំ ទក្ខិណាវិភង្គសុត្តំ

វិភង្គវគ្គស្ស ទក្ខិណាវិភង្គសុត្តេ មហាបជាបតិយា អាយាចនំ.................................................... ២១៥
អានន្ទស្ស អាយាចនំ.................................................... ២១៧
សុប្បដិកាវាភាវោ.................................................... ២១៩
ទក្ខិណាភេទោ.................................................... ២២១
ទក្ខិណាវិសុទ្ធិ.................................................... ២២៧

# សឡាយតនវគ្គោ

## បឋមំ អនាថបិណ្ឌិកោវាទសុត្តំ

សឡាយតនវគ្គស្ស អនាថបិណ្ឌិកោវាទសុត្តេ អាពាធប្បវត្តិ.................................................... ២៣៣
អជ្ឈត្តិកាយតនានិ.................................................... ២៣៧
ចក្ខុសម្ផស្សាទិ.................................................... ២៣៩

# សង្ខេបលំដាប់មាតិកា

មាតិកា ទំព័រ

## សច្ចវិភង្គសូត្រ ទី ១១


វិភង្គវគ្គ សច្ចវិភង្គសូត្រ ការញ៉ាំងធម្មចក្រឲ្យប្រព្រឹត្តទៅ......................... ២០៣
ទុក្ខអរិយសច្ច .......................................................... ២០៥
ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច............................ ២០៩
មគ្គអរិយសច្ច ........................................................... ២១១
ការប្រាប់នូវអរិយសច្ច................................................ ២១៣


## ទក្ខិណាវិភង្គសូត្រ ទី ១២


វិភង្គវគ្គ ទក្ខិណាវិភង្គសូត្រ ការអង្វរករនៃនាងមហាបជាបតិគោតមី...................... ២១៥
កិរិយាអង្វរករនៃព្រះអានន្ទ......................................... ២១៧
កិរិយាមិនមែនជាការតបស្នងដោយល្អ ....................... ២១៩
សេចក្តីផ្សេងគ្នានៃទក្ខិណាទាន.................................. ២២១
ទក្ខិណាវិសុទ្ធិ........................................................... ២២៧


## សឡាយតនវគ្គ

## អនាថបិណ្ឌិកោវាទសូត្រ ទី ១


សឡាយតនវគ្គ អនាថបិណ្ឌិកោវាទសូត្រ ការប្រព្រឹត្តទៅនៃអាពាធ.............................. ២៣៣
អាយតនៈខាងក្នុង..................................................... ២៣៧
ចក្ខុសម្ផស្សជាដើម .................................................... ២៣៩

# មាតិកាបត្តាជិ


| មាតិកា | អង្កេ |
|---|---|
| សឡាយតនវគ្គស្ស អនាថបិណ្ឌិកោវាទសុត្តេ បញ្ហក្ខន្ធា | ២៤១ |
| ឥធលោកបរលោកា | ២៤៣ |
| ភគវន្តូបសង្កមនំ | ២៤៥ |
| ជេតវនប្បសំសនំ | ២៤៧ |
| ភាសិតាភិនន្ទនំ | ២៤៩ |

## ទុតិយំ ឆន្នោវាទសុត្តំ

| | |
|---|---|
| សឡាយតនវគ្គស្ស ឆន្នោវាទសុត្តេ អាពាធប្បវត្តិ | ២៥១ |
| សារីបុត្តប្បញ្ញាកម្មំ | ២៥៥ |
| ភគវន្តូបសង្កមនំ | ២៥៩ |

## តតិយំ បុណ្ណោវាទសុត្តំ

| | |
|---|---|
| សឡាយតនវគ្គស្ស បុណ្ណោវាទសុត្តេ ឱវាទទានំ | ២៦៣ |
| សុនាបរន្តកានំ ចណ្ឌភាវោ | ២៦៥ |
| បុណ្ណស្ស បរិនិព្វានំ | ២៦៩ |

## ចតុត្ថំ នន្ទកោវាទសុត្តំ

| | |
|---|---|
| សឡាយតនវគ្គស្ស នន្ទកោវាទសុត្តេ ភិក្ខុនីឱវាទទានំ | ២៧៣ |
| ពាហិរាយតនានិ | ២៧៥ |

# សង្ខេបប្រាប់មាតិកា


| មាតិកា | ទំព័រ |
|---|---|
| សឡាយតនវគ្គ អនាថបិណ្ឌិកោវាទសូត្រ បញ្ហក្ខន្ធ......... | ២៤១ |
| លោកនេះនិងលោកខាងមុខ......... | ២៤៣ |
| អនាថបិណ្ឌិកទេវបុត្តចូលទៅគាល់ព្រះមានព្រះភាគ......... | ២៤៥ |
| សេចក្ដីសរសើរវត្តជេតវន ......... | ២៤៧ |
| សេចក្ដីត្រេកអរចំពោះភាសិត......... | ២៤៩ |


## ឆន្នោវាទសូត្រ ទី ២


| | |
|---|---|
| សឡាយតនវគ្គ ឆន្នោវាទសូត្រ កិរិយាប្រព្រឹត្តទៅនៃអាពាធ......... | ២៥១ |
| បញ្ហាកម្មនៃព្រះសារីបុត្ត......... | ២៥៥ |
| កិរិយាចូលទៅគាល់ព្រះមានព្រះភាគ......... | ២៥៩ |


## បុណ្ណោវាទសូត្រ ទី ៣


| | |
|---|---|
| សឡាយតនវគ្គ បុណ្ណោវាទសូត្រ ការឲ្យឱវាទ ......... | ២៦៣ |
| ភាពកំណាចនៃពួកអ្នកសុនាបរន្តជនបទ......... | ២៦៥ |
| បរិនិព្វាននៃព្រះបុណ្ណ......... | ២៦៩ |


## នន្ទកោវាទសូត្រ ទី ៤


| | |
|---|---|
| សឡាយតនវគ្គ នន្ទកោវាទសូត្រ ការឲ្យឱវាទដល់ភិក្ខុនី......... | ២៧៣ |
| អាយតនៈខាងក្រៅ......... | ២៧៥ |

# មាតិកាបត្តានិ


| មាតិកា | អង្កេ |
|---|---|
| សឡាយតនវគ្គស្ស នន្ទកោវាទសុត្តេ វិញ្ញាណកាយា.......................................... | ២៧៧ |
| វេទនាខន្ធោ............................................................ | ២៧៩ |
| ពាហិរាយតនានិ...................................................... | ២៨១ |
| គោឃាតកោបមា ..................................................... | ២៨៣ |
| សត្តពោជ្ឈង្គា ......................................................... | ២៨៥ |
| រាជការាមូបសង្កមនំ................................................... | ២៨៧ |
| អជ្ឈត្តិកាយតនានិ.................................................... | ២៨៩ |
| វិញ្ញាណកាយា.......................................................... | ២៩១ |
| តេលប្បទីបោបមា..................................................... | ២៩៣ |
| រុក្ខូបមា.................................................................... | ២៩៥ |
| គោឃាតកោបមា...................................................... | ២៩៧ |
| សត្តពោជ្ឈង្គា.......................................................... | ២៩៩ |
| ភាសិតាភិនន្ទនំ......................................................... | ៣០១ |


# បញ្ចមំ ចូឡរាហុលោវាទសុត្តំ


| | |
|---|---|
| សឡាយតនវគ្គស្ស ចូឡរាហុលោវាទសុត្តេ ចក្ខាយតនំ....................................... | ៣០៣ |
| ចក្ខុសម្ផស្សោ.......................................................... | ៣០៥ |
| មនោវិញ្ញាណំ........................................................... | ៣០៧ |

# សង្ខេបប្រាប់មាតិកា


មាតិកា ទំព័រ

សឡាយតនវគ្គ នន្ទកោវាទសូត្រ វិញ្ញាណកាយ.................................................. ២៧៧

វេទនាខន្ធ.................................................. ២៧៩

អាយតនៈខាងក្រៅ.................................................. ២៨១

ឧបមាដោយអ្នកសម្លាប់គោ.................................................. ២៨៣

ពោជ្ឈង្គប្រាំពីរ.................................................. ២៨៥

ការចូលទៅកាន់រាជការាម.................................................. ២៨៧

អាយតនៈខាងក្នុង.................................................. ២៨៩

វិញ្ញាណកាយ.................................................. ២៩១

ឧបមាដោយប្រទីបប្រេង.................................................. ២៩៣

ឧបមាដោយដើមឈើ.................................................. ២៩៥

ឧបមាដោយអ្នកសម្លាប់គោ.................................................. ២៩៧

ពោជ្ឈង្គប្រាំពីរ.................................................. ២៩៩

សេចក្តីត្រេកអរចំពោះភាសិត.................................................. ៣០១


# ចូឡរាហុលោវាទសូត្រ ទី ៥


សឡាយតនវគ្គ ចូឡរាហុលោវាទសូត្រ ចក្ខាយតនៈ.................................................. ៣០៣

ចក្ខុសម្ផស្ស.................................................. ៣០៥

មនោវិញ្ញាណ.................................................. ៣០៧

# មាតិកាបត្តាជិ

មាតិកា អង្កេ

សឡាយតនវគ្គស្ស ចូឡរាហុលោវាទសុត្តេ អាយតនាទិនិព្វិន្ទនំ................................ ៣០៩

## ឆដ្ឋំ ឆឆក្កសុត្តំ

សឡាយតនវគ្គស្ស ឆឆក្កសុត្តេ ឆ វិញ្ញាណកាយា............................................ ៣១៣
ឆ វេទនាកាយា................................................ ៣១៥
អនត្តតា............................................................ ៣១៧
សក្កាយសមុទយគាមិនី...................................... ៣២៣
សក្កាយនិរោធគាមិនី.......................................... ៣២៥
អដ្ឋានភាវោ....................................................... ៣២៧
ឋានភាវោ ......................................................... ៣២៩
ភាសិតាភិនន្ទនំ .................................................. ៣៣៣

## សត្តមំ សឡាយតនវិភង្គសុត្តំ

សឡាយតនវគ្គស្ស សឡាយតនវិភង្គសុត្តេ តណ្ហាបវឌ្ឍនំ........................................ ៣៣៥
តណ្ហាបហានំ .................................................... ៣៣៩
ភាវនាបារិបូរិ...................................................... ៣៤១
បរិជាននាទិ....................................................... ៣៤៣

# សង្ខេបប្រាប់មាតិកា


មាតិកា ទំព័រ

សឡាយតនវគ្គ ចូឡរាហុលោវាទសូត្រ សេចក្តីនឿយណាយក្នុងអាយតនៈជាដើម..... ៣០៩


# ឆឆក្កសូត្រ ទី ៦


សឡាយតនវគ្គ ឆឆក្កសូត្រ វិញ្ញាណកាយប្រាំមួយ ................................ ៣១៣

វេទនាកាយប្រាំមួយ........................................ ៣១៥

ភាពនៃអនត្តា ................................................. ៣១៧

ដំណើរកើតឡើងនៃសក្កាយ ............................ ៣២៣

ដំណើររលត់ទៅនៃសក្កាយ.............................. ៣២៥

ភាពនៃពាក្យមិនសមហេតុ............................... ៣២៧

ភាពនៃពាក្យសមហេតុ...................................... ៣២៩

សេចក្តីត្រេកអរចំពោះភាសិត ........................... ៣៣៣


# សឡាយតនវិភង្គសូត្រ ទី ៧


សឡាយតនវគ្គ សឡាយតនវិភង្គសូត្រ ការចម្រើនឡើងនៃតណ្ហា....................... ៣៣៥

ការលះបង់នូវតណ្ហា......................................... ៣៣៩

ការពេញបរិបូណ៌ដោយភាវនា .......................... ៣៤១

ការកំណត់ដឹងនូវធម៌ជាដើម.............................. ៣៤៣

# មាតិកាបត្តានិ

មាតិកា អង្កេ

## អដ្ឋមំ នគរវិន្ទេយ្យសុត្តំ

សឡាយតនវគ្គស្ស នគរវិន្ទេយ្យសុត្តេ អសក្កាតព្វភាវោ.................................... ៣៤៩
សក្កាតព្វភាវោ.................................................. ៣៥១
អាការន្វយប្បញ្ហា.............................................. ៣៥៣
សរណាគមនំ.................................................... ៣៥៤

## នវមំ បិណ្ឌបាតបារិសុទ្ធិសុត្តំ

សឡាយតនវគ្គស្ស បិណ្ឌបាតបារិសុទ្ធិសុត្តេ សុញ្ញតាវិហារោ.............................. ៣៥៧
នីវរណប្បញ្ហា.................................................... ៣៦១
ឥន្ទ្រិយប្បញ្ហា.................................................... ៣៦៣
ពោជ្ឈង្គប្បញ្ហា.................................................. ៣៦៥
វិជ្ជាវិមុត្តិប្បញ្ហា.................................................. ៣៦៧

## ទសមំ ឥន្ទ្រិយភាវនាសុត្តំ

សឡាយតនវគ្គស្ស ឥន្ទ្រិយភាវនាសុត្តេ អានន្ទស្ស និមន្តនំ.............................. ៣៧១
ឥន្ទ្រិយភាវនា.................................................... ៣៧៣
សេក្ខបាដិបទោ.................................................. ៣៨១
ឧទ្ទានំ.............................................................. ៣៨៥

# សង្ខឹកច្រាប់មាតិកា

មាតិកា ទំព័រ

## នគរវិន្ទេយ្យសូត្រ ទី ៨

សឡាយតនវគ្គ នគរវិន្ទេយ្យសូត្រ ភាពនៃបុគ្គលដែលគេមិនគប្បីធ្វើសក្ការៈ............ ៣៤៩
សឡាយតនវគ្គ នគរវិន្ទេយ្យសូត្រ ភាពនៃបុគ្គលគួរធ្វើសក្ការៈ................................ ៣៥១
ការសួររកហេតុយោបល់.................................. ៣៥៣
ការដល់នូវសរណៈ.......................................... ៣៥៥

## បិណ្ឌបាតបារិសុទ្ធិសូត្រ ទី ៩

សឡាយតនវគ្គ បិណ្ឌបាតបារិសុទ្ធិសូត្រ សុញ្ញតាវិហារសមាបត្តិ ........................ ៣៥៧
នីវរណបញ្ហា.................................................. ៣៦១
ឥន្ទ្រិយបញ្ហា.................................................. ៣៦៣
ពោជ្ឈង្គបញ្ហា.................................................. ៣៦៥
វិជ្ជាវិមុត្តិបញ្ហា.................................................. ៣៦៧

## ឥន្ទ្រិយភាវនាសូត្រ ទី ១០

សឡាយតនវគ្គ ឥន្ទ្រិយភាវនាសូត្រ ការនិមន្តរបស់ព្រះអានន្ទ............................. ៣៧១
ការចម្រើននូវឥន្ទ្រិយ........................................ ៣៧៣
សេក្ខប្បដិបទា................................................. ៣៨១
ឧទ្ទាន................................................................ ៣៨៥

